00573327

E188

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 08 / 2010
ម៉ោង (Time/Heure): 15 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ
**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **ធូ មណី** |
| ក្រឡាបញ្ជីសវនាការ | លឹម ស៊ុយហុង Matteo CRIPPA សែ កុលវុឌ្ឍី<br>Natacha WEXELS-RISER ឌុច ផារី |
| កាលបរិច្ឆេទសវនាការ | ចាប់ផ្តើមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងបញ្ចប់កិច្ចពិភាក្សាដេញដោល<br>ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ |
| កាលបរិច្ឆេទប្រកាសសាលក្រម | ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# សាលក្រម

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY
យ៉ែត ចរិយា
William SMITH

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

00573328

E188

| | |
|---|---|
| **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | ទី ស្រ៊ីនណា |
| គង់ ពិសី | Pierre Olivier SUR |
| ហុង គីមសួន | Alain WERNER |
| យុង ផានិត | Brianne McGONIGLE |
| គីម ម៉េងឃី | Annie DELAHAIE |
| ម៉ុច សុវណ្ណារី | Elizabeth RABESANDRATANA |
| Silke STUDZINSKY | Karim KHAN |
| Martine JACQUIN | Fabienne TRUSSES-NAPROUS |
| Philippe CANONNE | Christine MARTINEAU |

# មាតិកា


១. សេចក្តីផ្តើម ....................................................................................... 11

១.១ ការបង្កើត អ.វ.ត.ក ............................................................................ 11

១.២ សេចក្តីសង្ខេបប្រវត្តិនីតិវិធីនៃសំណុំរឿង ................................................. 12

១.៣ បទចោទប្រឆាំងនឹងជនជាប់ចោទ ......................................................... 14

១.៤ យុត្តាធិការរបស់អង្គជំនុំជម្រះលើជនជាប់ចោទ ........................................ 15

១.៤.១ យុត្តាធិការលើរឿងក្តី យុត្តាធិការក្នុងពេលវេលា និងយុត្តាធិការលើដែនដី............. 17

១.៤.២ យុត្តាធិការលើរូបបុគ្គល ........................................................... 18

១.៥ គោលការណ៍នីត្យានុកូលភាព ............................................................. 23

១.៦ វិធានផ្ទៃក្នុង និងគោលការណ៍នៃភស្តុតាងជាធរមាន ..................................... 29

១.៦.១ ច្បាប់នីតិវិធីជាធរមាន ............................................................... 29

១.៦.២ សំណុំរឿង .............................................................................. 30

១.៦.៣ ការទទួលយកភស្តុតាង ................................................................ 30

១.៦.៤ បន្ទុក និងបទដ្ឋាននៃភស្តុតាង ......................................................... 33

១.៦.៥ ប្រភពនៃភស្តុតាងនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ..................... 34

១.៦.៥.១ អង្គហេតុដែលបានព្រមព្រៀង និងការទទួលស្គាល់របស់ជនជាប់ចោទ ....................... 34

១.៦.៥.២ ការតាំងសំណួរដល់ជនជាប់ចោទ និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ................ 36

១.៦.៥.៣ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ............................................ 37

១.៦.៥.៤ ឯកសារនានា ............................................................................ 39

១.៦.៦ ការប្រកបឈ្មោះ និងទីកន្លែង ......................................................... 40

២. ផ្នែកសំអាងហេតុ និងសំអាងច្បាប់ ........................................................ 40

២.១ បរិបទប្រវត្តិសាស្ត្រ និងជម្លោះប្រដាប់អាវុធ ................................................ 40

២.១.១ ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧............................. 46

២.១.២ ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ........................ 52
២.២ សេចក្តីសង្ខេបអំពីរយៈកាលកម្ពុជាប្រជាធិបតេយ្យ ........................ 56
២.២.១ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ........................ 60
២.២.២ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ........................ 65
២.២.៣ ប្រព័ន្ធតុលាការ ........................ 66
២.២.៤ កងទ័ព ........................ 67
២.២.៥ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលពាក់ព័ន្ធ ........................ 68
២.២.៥.១ ការសម្លាប់ ........................ 68
២.២.៥.២ ការ "កម្ទេច" ខ្មាំង ........................ 69
២.២.៦ សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ........................ 70
២.២.៧ ការផ្សព្វផ្សាយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ........................ 71
២.២.៨ រចនាសម្ព័ន្ធសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា ........................ 74
២.៣ មន្ទីរស២១ និងតួនាទីរបស់ជនជាប់ចោទ ........................ 76
២.៣.១ ព័ត៌មានទាក់ទងនឹងសាវតាររបស់ជនជាប់ចោទ ........................ 76
២.៣.២ មន្ទីរម១៣ ........................ 78
២.៣.៣ មន្ទីរស២១ ........................ 80
២.៣.៣.១ ការបង្កើតមន្ទីរស២១ ........................ 80
២.៣.៣.២ ទីតាំងដំបូងរបស់មន្ទីរស២១ ........................ 82
២.៣.៣.៣ ការតែងតាំង និងតួនាទីជាអនុប្រធានមន្ទីរស២១ ........................ 83
២.៣.៣.៤ ការតែងតាំង និងតួនាទីជាប្រធានមន្ទីរស២១ ........................ 84
២.៣.៣.៤.១ ការផ្លាស់ប្តូរទីតាំងមន្ទីរស២១ ........................ 87
២.៣.៣.៤.២ ទិដ្ឋភាពទូទៅរបស់អ្នកជាប់ឃុំនៅមន្ទីរស២១ ........................ 90
២.៣.៣.៤.៣ រចនាសម្ព័ន្ធមន្ទីរស២១ ........................ 93
២.៣.៣.៤.៣.១ អង្គភាពឯកសារ ........................ 93
២.៣.៣.៤.៣.២ អង្គភាពសួរចម្លើយ ........................ 96
២.៣.៣.៤.៣.៣ អង្គភាពការពារ ........................ 100
២.៣.៣.៤.៣.៤ អង្គភាពផ្សេងៗទៀតរបស់មន្ទីរស២១ ........................ 101
២.៣.៣.៥ ការទទួលខុសត្រូវក្នុងឋានៈជាប្រធានមន្ទីរស២១ ........................ 102

២.៣.៣.៥.១ ការជ្រើសរើសបុគ្គលិក ....................102
២.៣.៣.៥.២ ការបណ្តុះបណ្តាលបុគ្គលិក ....................103
២.៣.៣.៥.៣ តួនាទីក្នុងការចាប់ខ្លួន ....................105
២.៣.៣.៥.៤ តួនាទីក្នុងការពិនិត្យចម្លើយសារភាព ....................110
២.៣.៣.៥.៥ តួនាទីក្នុងការសម្លាប់ ....................114
២.៣.៣.៦ ជើងឯក ....................116
២.៣.៣.៧ ស២៤ ....................118
២.៣.៣.៨ ការបោះបង់ចោលមន្ទីរស២១ ....................125
២.៤ អង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅមន្ទីរស២១ .....126
២.៤.១ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ....................126
២.៤.១.១ ការសម្លាប់ជនបរទេស ....................129
២.៤.១.២ ការសម្លាប់អ្នកជាប់ឃុំដែលជាកម្មាភិបាលជាន់ខ្ពស់ ....................129
២.៤.១.៣ ការសម្លាប់បុគ្គលិកមន្ទីរស២១ ....................130
២.៤.១.៤ ការសម្លាប់កុមារ ....................132
២.៤.១.៥ ការសម្លាប់ទ្រង់ទ្រាយធំ ....................133
២.៤.១.៦ វិធីសាស្ត្រក្នុងការសម្លាប់ ....................135
២.៤.២ ការធ្វើឱ្យទៅជាទាសករ ....................137
២.៤.២.១ លក្ខខណ្ឌនៃការរស់នៅ និងការងារនៅស២៤ ....................138
២.៤.២.២ ការធ្វើឱ្យអ្នកជាប់ឃុំទៅជាទាសករនៅក្នុងមន្ទីរស២១ (ទួលស្លែង) ....................141
២.៤.៣ ការដាក់ក្នុងមន្ទីរឃុំឃាំង ....................142
២.៤.៣.១ ការដកហូតសេរីភាពដោយបំពាន ....................143
២.៤.៣.២ មិនមានការអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់ ....................144
២.៤.៤ ការធ្វើទារុណកម្ម ដោយរួមទាំងការរំលោភលើផ្លូវភេទ ....................145
២.៤.៤.១ ការប្រើទារុណកម្មនៅក្នុងមន្ទីរស២១ (ទួលស្លែង) ....................146
២.៤.៤.១.១ បច្ចេកទេសធ្វើទារុណកម្ម ....................146
២.៤.៤.១.២ ហេតុការណ៍ជាក់លាក់នៃការធ្វើទារុណកម្ម....................151
២.៤.៤.២ គោលបំណងនៃការធ្វើទារុណកម្ម ....................153
២.៤.៤.៣ សមត្ថកិច្ចផ្លូវការរបស់ចារី ....................155
២.៤.៥ អំពើអមនុស្សធម៌ផ្សេងៗទៀត ....................155

២.៤.៥.១ លក្ខខណ្ឌនៃការឃុំខ្លួននៅក្នុងមន្ទីរស២១ (ទួលស្លែង) ....... 156
២.៤.៥.២ ការមិនឱ្យអាហារហូបគ្រប់គ្រាន់ ....... 162
២.៤.៥.៣ ការខ្វះអនាម័យ ....... 163
២.៤.៥.៤ ការខ្វះសេវាព្យាបាលផ្នែកវេជ្ជសាស្ត្រ ....... 164
២.៤.៥.៥ ការបូមឈាម និងការពិសោធន៍វេជ្ជសាស្ត្រ ....... 165
២.៤.៥.៦ ការប្រព្រឹត្តចំពោះអ្នកជាប់ឃុំនៅជើងឯក និង ស២៤ ....... 165
**២.៤.៦ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....... 167**
**២.៥ ច្បាប់ជាធរមាន និងសំអាងហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ....... 169**
**២.៥.១. លក្ខខណ្ឌទូទៅសម្រាប់មាត្រា៥ នៃច្បាប់ អ.វ.ត.ក ....... 178**
២.៥.១.១ ការវាយប្រហារ ....... 179
២.៥.១.២ លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ....... 180
២.៥.១.៣ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ....... 182
២.៥.១.៤ មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ....... 189
២.៥.១.៥ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងការវាយប្រហារ ....... 193
២.៥.១.៦ លក្ខខណ្ឌដឹង ....... 193
**២.៥.២ សំអាងហេតុទាក់ទងនឹងលក្ខខណ្ឌទូទៅសម្រាប់មាត្រា៥ នៃច្បាប់ អ.វ.ត.ក ....... 194**
២.៥.២.១ ការវាយប្រហារ ....... 194
២.៥.២.២ មានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ....... 195
២.៥.២.៣ សំដៅប្រឆាំងទៅលើប្រជាជនជនស៊ីវិល ....... 195
២.៥.២.៤ ដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ....... 197
២.៥.២.៥ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារ ....... 197
២.៥.២.៦ ការដឹងរបស់ជនជាប់ចោទ ....... 198
**២.៥.៣ ច្បាប់ និងសំអាងហេតុទាក់ទងនឹងបទល្មើសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ....... 198**
២.៥.៣.១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ....... 199
២.៥.៣.២ សំអាងហេតុទាក់ទងនឹងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ....... 203
២.៥.៣.៣ ការធ្វើឱ្យទៅជាទាសករ ....... 204
២.៥.៣.៤ សំអាងហេតុទាក់ទងនឹងការធ្វើឱ្យទៅជាទាសករ ....... 206
២.៥.៣.៥ ការដាក់ក្នុងមន្ទីរឃុំឃាំង ....... 206
២.៥.៣.៦ សំអាងហេតុទាក់ទងនឹងការដាក់ក្នុងមន្ទីរឃុំឃាំង ....... 208
២.៥.៣.៧ ការធ្វើទារុណកម្ម ....... 208

២.៥.៣.៨ សំអាងហេតុទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត.....214
២.៥.៣.៩ ការរំលោភលើផ្លូវភេទ.....215
២.៥.៣.១០ សំអាងហេតុទាក់ទងនឹងការរំលោភលើផ្លូវភេទ ដែលជាទម្រង់នៃ ការធ្វើទារុណកម្ម.....217
២.៥.៣.១១ អំពើអមនុស្សធម៌ផ្សេងៗទៀត.....218
២.៥.៣.១២ សំអាងហេតុទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត.....220
២.៥.៣.១៣ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ.....221
២.៥.៣.១៤ សំអាងហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ.....227
២.៥.៣.១៤.១ គោលនយោបាយរើសអើងនៃបទល្មើសជាក់លាក់ទាំងនេះ.....227
២.៥.៣.១៤.២ ផលវិបាកនៃគោលនយោបាយរើសអើងទាំងនេះ.....231
២.៥.៣.១៤.៣ ចេតនាជាក់លាក់របស់ជនជាប់ចោទ.....232
២.៥.៣.១៤.៤ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ.....233
២.៥.៣.១៤.៥ មតិជំទាស់របស់ចៅក្រម CARTWRIGHT.....235
២.៦ ច្បាប់ និងសំអាងហេតុទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩.....236
២.៦.១ លក្ខខណ្ឌទូទៅសម្រាប់មាត្រា៦ នៃច្បាប់ អ.វ.ត.ក.....242
២.៦.១.១ អត្ថិភាពនៃជម្លោះប្រដាប់អាវុធ.....243
២.៦.១.២ លក្ខណៈជាអន្តរជាតិនៃជម្លោះប្រដាប់អាវុធ.....244
២.៦.១.៣ ទំនាក់ទំនងរវាងការប្រព្រឹត្តិរបស់ជនជាប់ចោទនឹងជម្លោះប្រដាប់អាវុធ.....246
២.៦.១.៤ ឋានៈជា "បុគ្គលដែលត្រូវទទួលបានការការពារ" ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩.....247
២.៦.១.៥ ការដឹងរបស់ជនជាប់ចោទ.....249
២.៦.២ សំអាងហេតុទាក់ទងនឹងលក្ខខណ្ឌទូទៅសម្រាប់មាត្រា៦ នៃច្បាប់ អ.វ.ត.ក.....250
២.៦.២.១ អត្ថិភាពនៃជម្លោះប្រដាប់អាវុធ.....250
២.៦.២.២ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ.....250
២.៦.២.៣ ឋានៈជា "បុគ្គលដែលត្រូវទទួលបានការការពារ" ផ្អែកតាម អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩.....251
២.៦.២.៤ ការដឹងរបស់ជនជាប់ចោទ.....253
២.៦.៣ ច្បាប់ និងសំអាងហេតុទាក់ទងនឹងបទល្មើសជាក់លាក់មួយចំនួនដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩.....254
២.៦.៣.១ ការធ្វើមនុស្សឃាតដោយចេតនា.....255
២.៦.៣.២ សំអាងហេតុទាក់ទងនឹងការធ្វើមនុស្សឃាតដោយចេតនា.....255
២.៦.៣.៣ ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌.....257

00573334



២.៦.៣.៤ សំអាងហេតុទាក់ទងនឹងការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ..... 260
២.៦.៣.៤.១ ការធ្វើទារុណកម្ម ..... 260
២.៦.៣.៤.២ ការធ្វើបាបដោយអមនុស្សធម៌ ..... 262
២.៦.៣.៥ ការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួស ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ..... 263
២.៦.៣.៦ សំអាងហេតុទាក់ទងនឹងការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ..... 265
២.៦.៣.៧ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ..... 266
២.៦.៣.៨ សំអាងហេតុទាក់ទងនឹងការដកហូតនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ ..... 267
២.៦.៣.៩ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ..... 268
២.៦.៣.១០ សំអាងហេតុទាក់ទងនឹងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ..... 270
២.៧ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ ..... 270
២.៧.១ ការប្រព្រឹត្ត ..... 277
២.៧.១.១ ការប្រព្រឹត្តតាមរយៈអំពើសកម្ម ឬអកម្ម ..... 277
២.៧.១.២ សំអាងហេតុទាក់ទងនឹងការប្រព្រឹត្តតាមរយៈអំពើសកម្ម ឬអកម្ម ..... 278
២.៧.១.៣ ការប្រព្រឹត្តបទល្មើសតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ..... 280
២.៧.១.៣.១ សារណា និងប្រវត្តិនីតិវិធី ..... 280
២.៧.១.៣.២ វិធាន៩៨(២) នៃវិធានផ្ទៃក្នុង ..... 284
២.៧.១.៣.២.១ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ..... 287
២.៧.១.៣.៣ ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក ..... 292
២.៧.១.៣.៣.១ សញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ..... 292
២.៧.១.៣.៣.២ ការអនុវត្តផ្អែកតាមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ..... 299
២.៧.១.៤ សំអាងហេតុទាក់ទងនឹងការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម ..... 301
២.៧.២ ការរៀបចំផែនការ ..... 303
២.៧.៣ សំអាងហេតុទាក់ទងនឹងការរៀបចំផែនការ ..... 303
២.៧.៤ ការញុះញង់ ..... 304
២.៧.៥ សំអាងហេតុទាក់ទងនឹងការញុះញង់ ..... 306
២.៧.៦ ការបញ្ជា ..... 307
២.៧.៧ សំអាងហេតុទាក់ទងនឹងការបញ្ជា ..... 308

00573335



២.៧.៨ ការជួយនិងជំរុញ ....................................................................309

២.៧.៩ សំអាងហេតុទាក់ទងនឹងការជួយនិងជំរុញ ................................................312

២.៧.១០ ការទទួលខុសត្រូវរបស់ថ្នាក់លើ..........................................................312

២.៧.១០.១ ទំនាក់ទំនងរវាងថ្នាក់លើនឹងអ្នកនៅក្រោមបង្គាប់ .......................................314

២.៧.១០.២ ថ្នាក់លើបានដឹង ឬមានហេតុផលដឹង ........................................................316

២.៧.១០.៣ ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម.................................................317

២.៧.១០.៤ សំអាងហេតុទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ.....................................318

២.៧.១១ ការការពារខ្លួនដែលបានលើកឡើងដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ....319

២.៧.១១.១ បញ្ហារបស់ថ្នាក់លើ ........................................................................320

២.៧.១១.២ ការបង្ខិតបង្ខំ..............................................................................321

២.៧.១២ ពិរុទ្ធភាពពីបទល្មើសច្រើន ...............................................................324

២.៧.១២.១ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ..............326

២.៧.១២.២ ការធ្វើទុក្ខបុកម្នេញ និងបទល្មើសជាក់លាក់ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ..............327

២.៧.១២.៣ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល.....................................................330

២.៧.១២.៤ សេចក្តីសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ............................330

៣ ការផ្តន្ទាទោស ..............................................................................331

៣.១ សារណារបស់ភាគី ..........................................................................331

៣.២ ច្បាប់ជាធរមាន ...............................................................................333

៣.២.១ បទប្បញ្ញត្តិ និងក្របខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនៅ អ.វ.ត.ក ........................333

៣.២.២ គោលការណ៍ និងកត្តានានាដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស ...............................336

៣.២.៣ អានុភាពនៃការរកឃើញពិរុទ្ធភាពច្រើនបទនៅពេលផ្តន្ទាទោស ...........................340

៣.២.៤ ការផ្តន្ទាទោសដែលត្រូវយកមកអនុវត្ត នៅពេលដែលទោសអតិបរមា ឲ្យជាប់ពន្ធនាគារអស់មួយជីវិតមិនត្រូវបានយកមកអនុវត្ត...........................342

៣.៣ សំអាងហេតុ .................................................................................343

៣.៣.១ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម.........................................................................343

៣.៣.២ កត្តានានានៃស្ថានទម្ងន់ទោស ...............................................................345

៣.៣.៣ កត្តានានានៃស្ថានសម្រាលទោស...............................................................347

៣.៣.៤ ការវាយតម្លៃអំពីជំងឺវិលកចរិត និងជំងឺផ្លូវចិត្តរបស់ជនជាប់ចោទ ....................351
៣.៣.៥ សាក្សីអំពីអត្តចរិតរបស់ជនជាប់ចោទ ....................354
៣.៣.៦ បច្ច័យនៃការរំលោភសិទ្ធិរបស់ជនជាប់ចោទពីពេលមុននៅពេលសម្រេចអំពីទោស 357
៣.៣.៧ ការកំណត់ទោស ....................359
៣.៣.៧.១ ទោសជាប់ពន្ធនាគារ ....................359
៣.៣.៧.២ ការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ....................360

**៤. សំណងរដ្ឋប្បវេណី ....................361**

៤.១ ប្រវត្តិនីតិវិធី ....................362
៤.២ ការវាយតម្លៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ....................365
៤.២.១ អត្ថិភាពនៃព្យសនកម្ម ....................365
៤.២.២ អត្ថិភាពនៃទំនាក់ទំនងហេតុនិងផលរវាងព្យសនកម្មរបស់ជនរងគ្រោះ និងកំហុសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ....................367
៤.៣ ការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ....................369
៤.៣.១ ដើមបណ្ដឹងរដ្ឋប្បវេណីដែលប្រកាសថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬ ស២៤ ....................370
៤.៣.២ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ....................376
៤.៤ ការទាមទារសំណង ....................388
៤.៤.១ សំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ....................389
៤.៤.២ ក្របខណ្ឌគតិយុត្តិ ....................396
៤.៤.៣ ការវិភាគអំពីប្រភេទផ្សេងៗនៃសំណងដែលបានស្នើសុំ ....................400
៤.៤.៣.១ សំណើពាក់ព័ន្ធទៅនឹងខ្លឹមសារនៃសាលក្រម ....................400
៤.៤.៣.២ ការចងក្រង និងការបោះពុម្ពផ្សាយពាក្យសម្ដីសុំអភ័យទោស ....................401
៤.៤.៣.៣ សំណើទាក់ទងនឹងការបោះពុម្ពផ្សាយសាលក្រម និងការផ្សព្វផ្សាយ ....................402
៤.៤.៣.៤ សំណើសុំសំណងជាប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្ដឹង រដ្ឋប្បវេណី ឬការបង្កើតនូវមូលនិធិមួយ ....402
៤.៤.៣.៥ សំណើសុំនូវវិធានការមួយចំនួនពីរាជរដ្ឋាភិបាលកម្ពុជា ....................403
៤.៤.៣.៦ សំណើសុំកសាងវត្ត និងបូជនីយដ្ឋានផ្សេងៗទៀត ....................403
៤.៤.៣.៧ សំណើសុំឱ្យអភិរក្សបណ្ណសារមន្ទីរស២១ គំនូររបស់ វ៉ាន់ ណាត និងបរិវេណមន្ទីរស២១ និងស២៤ ........403

៤.៤.៣.៨ សំណើសុំផ្ដល់នូវការថែទាំសុខភាពដោយឥតគិតថ្លៃ និងវិធានការអប់រំ ....................404

៥. ផ្នែកសេចក្ដីសម្រេច ....................406

៦. ឧបសម្ព័ន្ធ I÷ ប្រវត្តិនីតិវិធី ....................410

៦.១ ការចាប់ខ្លួន ការផ្ទេរ និងការឃុំខ្លួនជនជាប់ចោទ....................410

៦.២ ដំណាក់កាលស៊ើបអង្កេត ....................412

៦.២.១ ការស៊ើបអង្កេតបឋម ....................412

៦.២.២ ការបង្ហាញខ្លួនលើកដំបូង និងការចោទប្រកាន់....................412

៦.២.៣ ដីកាបំបែកសំណុំរឿង ....................413

៦.២.៤ សេចក្ដីសន្និដ្ឋាននៃការស៊ើបអង្កេត និងដីកាដំណោះស្រាយ....................413

៦.៣ បណ្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ....................414

៦.៣.១ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ....................414

៦.៣.២ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ....................415

៦.៤ ដើមបណ្ដឹងរដ្ឋប្បវេណី....................416

៦.៤.១ ការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី ....................416

៦.៤.២ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ....................417

៦.៥ កិច្ចដំណើរការជំនុំជម្រះ ....................417

៦.៥.១ ការរៀបចំដំណើរការជំនុំជម្រះ និងសវនាការបឋម....................417

៦.៥.២ អញ្ញត្រកម្ម ....................418

៦.៥.៣ សវនាការលើអង្គសេចក្ដី ....................419

៦.៥.៤ បញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត....................421

៦.៥.៤.១ សំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ....................421

៦.៥.៤.២ សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាន ទៅលើការផ្ដន្ទាទោស និងអត្តចរិតរបស់ជនជាប់ចោទ....................422

៦.៥.៥ សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ....................423

៦.៥.៦ ដំណើរការនីតិវិធីបន្តបន្ទាប់ទៀត ....................425

៧. ឧបសម្ព័ន្ធ II÷ រូបភាពមន្ទីរស២១ (ទួលស្លែង) ដែលថតពីលើអាកាស ....................427

៨. ឧបសម្ព័ន្ធ III÷ បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី....................................................428

៩. ឧបសម្ព័ន្ធទី IV÷ អក្សរកាត់ និងសន្ទានុក្រម...................................................................442

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូង "អង្គជំនុំជម្រះ" នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ក្រោយពីបានទទួលសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសជ[១] សម្រេចចេញសាលក្រមប្រឆាំងឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច "ជនជាប់ចោទ" ដែលជាអតីតគ្រូបង្រៀនគណិតវិទ្យា កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។

### ១.១ ការបង្កើត អ.វ.ត.ក

២. បន្ទាប់ពីមានសំណើផ្លូវការរបស់អាជ្ញាធរកម្ពុជាស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧[២] អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ដែលចែងអំពីការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ("ក.ប.ធ") និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ("កិច្ចព្រមព្រៀង អ.វ.ត.ក")[៣]។

---

[១] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ឯកសារលេខ D99/3/42 ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ។

[២] ឯកសារអង្គការសហប្រជាជាតិ A/51/930-S/1997/488 (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧)។ ឯកសារអង្គការសហប្រជាជាតិ A/RES/52/135 (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨) កថាខណ្ឌ១៦។

[៣] "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះហត្ថលេខានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។ សូមមើលផងដែរ ឯកសាររបស់អង្គការសហប្រជាជាតិ A/RES/57/228B (ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣) (អនុម័តលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀង អ.វ.ត.ក)។ ឯកសាររបស់អង្គការសហប្រជាជាតិ A/60/565 (ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥) កថាខណ្ឌ៤។

៣. អ.វ.ត.ក បានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីការប្រកាសឲ្យប្រើ "ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ""(ច្បាប់ អ.វ.ត.ក)"[៤]។

១.២ សេចក្តីសង្ខេបប្រវត្តិនីតិវិធីនៃសំណុំរឿង

៤. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញានៃ អ.វ.ត.ក បានដាក់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង ដោយស្នើសុំឲ្យបើកការស៊ើបសួរប្រឆាំងនឹងបុគ្គលចំនួនប្រាំរូប ដែលក្នុងចំណោមបុគ្គលទាំងនោះ រួមមានជនជាប់ចោទម្នាក់ផងដែរ[៥]។

៥. នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានសម្រេចចេញដីកាបំបែកសំណុំរឿងរបស់ជនជាប់ចោទ ចំពោះអង្គហេតុពាក់ព័ន្ធនឹងមន្ទីរស២១ ដែលអង្គហេតុនេះត្រូវបានស៊ើបសួរក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ ដែលជាសំណុំរឿងក្តីមួយនេះ[៦]។

៦. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[៧]។

---

[៤] "ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយរួមបញ្ចូលទាំងវិសោធនកម្មដែលបានប្រកាសឲ្យប្រើ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (NS/RKM/1004/006)។

[៥] "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ" ឯកសារD3 ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។

[៦] "ដីកាបំបែកសំណុំរឿង" ឯកសារD18 ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ អង្គហេតុដទៃទៀតដែលពាក់ព័ន្ធនឹងជនជាប់ចោទ ឬជនផ្សេងទៀតដែលមានឈ្មោះក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវស៊ើបសួរក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧។

[៧] "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេក *[ហ្កេក]* អ៊ាវ ហៅ "ឌុច"" ឯកសារD99 ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨។

៧. នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៨]។ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសាលដីកាប្រកាសផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះ[៩]។ អង្គបុរេជំនុំជម្រះទទួលយកមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍មួយផ្នែក ដោយអង្គបុរេជំនុំជម្រះយល់ឃើញថា បទទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន ក្រោមច្បាប់ជាតិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ (ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦) ត្រូវដាក់បញ្ចូលបន្ថែមទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានបដិសេធមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ដែលមូលដ្ឋាននេះលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានរួមបញ្ចូលសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់នៃការទទួលខុសត្រូវទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៨. អង្គបុរេជំនុំជម្រះបានសម្រេចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលដីកានេះត្រូវបានកែប្រែដោយសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់អង្គបុរេជំនុំជម្រះ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ")[១០]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានធ្វើការកែប្រែបានលើកឡើងអំពីការចោទប្រកាន់លើអង្គហេតុទាំងឡាយសម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការកាត់សេចក្តី។

៩. សវនាការបឋមចំពោះមុខអង្គជំនុំជម្រះ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៧ និងទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩[១១]។ សវនាការលើអង្គសេចក្តី បានចាប់ផ្តើមនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងបានបញ្ចប់សវនាការពិភាក្សាដេញដោលនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ បន្ទាប់ពីមានសវនាការអស់រយៈពេល៧២ថ្ងៃ

---

[៨] "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារ D99/3/3 ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨។

[៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ៦៤ (ចំណុច៥)។

[១១] "ដីកាកំណត់កាលបរិច្ឆេទសវនាការបឋម" ឯកសារ E8 ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩។

នៃថ្ងៃជំនុំជម្រះ។ ជនរងគ្រោះចំនួន ៩០នាក់ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានចែកចេញជាបួនក្រុម និងមានមេធាវីតំណាងក្រុមនីមួយៗ ("ដើមបណ្តឹងរដ្ឋប្បវេណី")[១២]។

១០. សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តីជនជាប់ចោទ និងជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលបន្តបន្ទាប់គ្នាចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩[១៣]។

## ១.៣ បទចោទប្រឆាំងនឹងជនជាប់ចោទ

១១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បង្ហាញថា ជនជាប់ចោទក្នុងនាមជាអនុលេខា ឬជាលេខាមន្ទីរស២១ បានរៀបចំផែនការ ញុះញង់ បញ្ជាឲ្យប្រព្រឹត្ត ប្រព្រឹត្ត ឬជួយនិងជំរុញ នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៤] ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា-

---

[១២] ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨ ច្បាប់ ក្នុងរយៈពេលនៃការស៊ើបអង្កេតនេះ។ អង្គជំនុំជម្រះបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦ ច្បាប់បន្តទៀត មុនពេលសវនាការបឋម ពាក្យសុំចំនួន ៤ ក្នុងចំណោមពាក្យសុំទាំងនោះត្រូវបានបដិសេធ ឬត្រូវបានបោះបង់ ។ *សូមមើលផងដែរ* "សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ E2/36, E2/51 និង E2/69" ឯកសារ E2/94/2 ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ ពាក់ព័ន្ធនឹងភស្តុតាងនៃអត្តសញ្ញាណចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36)" ឯកសារ E2/94/4 ចុះថ្ងៃទី១០ សីហា ឆ្នាំ២០០៩ (ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/36)។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពាះលិខិតសុំបោះបង់សិទ្ធិសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារលេខ E2/65/5 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ។ ឧបសម្ព័ន្ធ [III] ភ្ជាប់ទៅនឹងសាលក្រមបញ្ជាក់អំពីឈ្មោះពេញ ទីកន្លែងស្នាក់នៅ ថ្ងៃខែ ឆ្នាំកំណើត ទីកន្លែងកំណើត និងមុខរបររបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ១០១(៦)(ច) នៃវិធានផ្ទៃក្នុង។

[១៣] "ដីកាកំណត់កាលវិភាគសម្រាប់ភាគីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល" ឯកសារ E170 ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩។

[១៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម

ទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[១៥] ព្រមទាំងបទទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន ។ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាមេកើយ។ បទល្មើសដែលបានចោទប្រកាន់ចំពោះគាត់គឺមានចែងនៅក្នុង មាត្រា៥ មាត្រា៦ និងមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក។ រាល់ការចោទប្រកាន់ទាំងអស់គឺទាក់ទងនឹងអំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្តនៅទីក្រុងភ្នំពេញ និងលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

១២. អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែតែប៉ុណ្ណោះ។ ប៉ុន្តែ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ប៉ុន្តែមិនអាចបញ្ចូលធាតុផ្សំថ្មីនៃបទចោទបានឡើយ[១៦]។

## ១.៤ យុត្តាធិការរបស់អង្គជំនុំជម្រះលើជនជាប់ចោទ

១៣. មាត្រា១ នៃ ច្បាប់ អ.វ.ត.ក ផ្តល់អំណាចឲ្យ អ.វ.ត.ក "វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ "កម្ពុជាប្រជាធិបតេយ្យ" និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្ស

---

ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ សូមមើលផងដែរ ផ្នែក (២.៥)។

[១៥] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ រួមមាន៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ សូមមើលផងដែរ ផ្នែក (២.៦) ។

[១៦] វិធាន៩៨(២) នៃវិធានផ្ទៃក្នុងកំណែថ្មីជាភាសាបារាំង មានភាពច្បាស់លាស់ជាងទាក់ទងទៅនឹងបញ្ហានេះ៖ "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលធាតុផ្សំថ្មីនៃបទចោទបានឡើយ"។

ធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[១៧]។

១៤. នៅក្នុងអំឡុងពេលសវនាការបឋម មិនមានការលើកឡើងអំពីអញ្ញត្រកម្មចំពោះយុត្តាធិការរបស់ អ.វ.ត.ក ផ្អែកតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងទេ[១៨]។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មេធាវីការពារក្តីបានលើកឡើងអំពីភាពមិនមានយុត្តាធិការរបស់អង្គជំនុំជម្រះ ដោយផ្អែកលើមូលហេតុថា ជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ[១៩]។

---

[១៧] សូមមើលផងដែរ មាត្រា២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលកំណត់និយមន័យយុត្តាធិការលើរូបបុគ្គល និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ដោយផ្អែកតាម ច្បាប់ អ.វ.ត.ក។

[១៨] វិធាន៨៩(១) បានបញ្ជាក់ថា "អញ្ញត្រកម្មទាក់ទងទៅនឹង៖ ក) យុត្តាធិការរបស់អង្គជំនុំជម្រះ [...] ត្រូវលើកឡើងនៅក្នុងសវនាការបឋម បើមិនដូចនេះទេ មិនអាចត្រូវបានទទួលយកឡើយ"។ សូមមើល ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ទំព័រ១៨-១៩ (មេធាវីការពារក្តី) ("ថាខ្ញុំអត់ប្រឆាំងនឹង[យុត្តាធិការ]ទេ ខ្ញុំដឹងច្បាស់ណាស់ថា បើប្រឆាំងនឹងយុត្តាធិការហ្នឹង មិនព្រមនឹងយុត្តាធិការហ្នឹង ខ្ញុំត្រូវលើកឡើងនិយាយតាំងពីនៅសវនាការបឋម"។ សូមមើលផងដែរ ប្រតិចារឹកចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ទំព័រ១ ("អង្គជំនុំជម្រះសូមលើកឡើងជាថ្មី ចំពោះការយល់ឃើញរបស់ខ្លួនថា នៅក្នុងអំឡុងពេលឆ្លើយតបទៅនឹងការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់របស់សហព្រះរាជអាជ្ញា មេធាវីការពារក្តីមិនបានស្នើសុំជាផ្លូវការណាមួយស្តីពីនីត្យានុកូលភាពនៃដំណើរការនីតិវិធី ឬមួយយុត្តាធិការរបស់តុលាការទេ"។ មេធាវីការពារក្តីមិនជំទាស់នឹងការយល់ឃើញនេះទេ"។

[១៩] ប្រតិចារឹកចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់របស់មេធាវីការពារក្តី) ទំព័រ៨៤-១០៩។ ប្រតិចារឹកចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់របស់មេធាវីការពារក្តី) ទំព័រ៣៩-៤១ (បានចោទប្រកាន់ថា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ មានត្រឹមតែសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍តែប៉ុណ្ណោះ ចំណែកឯជនជាប់ចោទគ្រាន់តែអនុវត្តបញ្ជា ហើយមានមនុស្សត្រូវបានគេសម្លាប់ច្រើនជាងនៅមន្ទីរស២១ទៅទៀត។ ភាពស្មើគ្នាចំពោះមុខច្បាប់ នឹងតម្រូវឲ្យប្រធានមន្ទីរឃុំឃាំងទាំងអស់ផ្សេងទៀត ត្រូវបាននាំយកមកវិនិច្ឆ័យទោសដោយអ.វ.ត.ក ប្រសិនបើជនជាប់ចោទត្រូវបានវិនិច្ឆ័យទោសនោះ។ ប្រតិចារឹកចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ (ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសេចក្តីសន្និដ្ឋានបើករបស់សហព្រះរាជអាជ្ញា) ទំព័រ៧៦-៧៧, ៨២-៨៣។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនជាប់ចោទបំពេញទាំងលក្ខណៈវិនិច្ឆ័យជាមេដឹកនាំជាន់ខ្ពស់ផង និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតផង នៅក្នុងមុខតំណែង និងតួនាទីរបស់គាត់នៅមន្ទីរស២១ លក្ខណៈពិសេសនិងភាពសំខាន់នៃមន្ទីរស២១ សម្រាប់បក្សកុម្មុយនីស្តកម្ពុជា

១៥. អង្គជំនុំជម្រះមិនបានចាត់ទុកនូវសេចក្តីសន្និដ្ឋាន ដែលបានលើកឡើងមិនទាន់ពេលវេលានោះថាជាអញ្ញត្រកម្មនោះទេ។ បន្ថែមលើនេះ មេធាវីការពារក្តីបានលើកឡើងថា ឧបសម្ព័ន្ធ ៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ និងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ បានធ្វើឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ផងដែរ[២០] ។ អង្គជំនុំជម្រះកត់សម្គាល់ថា អំណះអំណាងនេះត្រូវបានលើកឡើងមិនទាន់ពេលវេលា ហេតុដូច្នេះត្រូវបដិសេធចោល ។

### ១.៤.១ យុត្តាធិការលើរឿងក្តី យុត្តាធិការក្នុងពេលវេលា និងយុត្តាធិការលើដែនដី

១៦. តាមឆន្ទានុសិទ្ធិរបស់ខ្លួន[២១] អង្គជំនុំជម្រះបានវាយតម្លៃទៅលើបញ្ហាថាតើអង្គជំនុំជម្រះមានយុត្តាធិការលើជនជាប់ចោទនៅក្នុងរឿងក្តីនេះដែរ ឬទេ ។ យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក កំណត់ត្រឹមតែបទឧក្រិដ្ឋទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា ៣ ថ្មី ដល់មាត្រា ៨ នៃច្បាប់ អ.វ.ត.ក នៅពេលដែលបទល្មើសដែលបានកំណត់នោះបង្កើតបានជាបទល្មើស នៅក្នុងអំឡុងពេល

---

ព្រមទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ។ ("សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ដោយមានឧបសម្ព័ន្ធ១-៥" ឯកសារ E159/9 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ២៣៩-២៤៥។ ប្រតិចារឹកចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់របស់សហព្រះរាជអាជ្ញា) ទំព័រ០៨-១២។ ប្រតិចារឹកចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់សហព្រះរាជអាជ្ញា) ទំព័រ១៤-១៧។ សូមមើលផងដែរ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ឯកសារ D3 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ១១៥។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងដោយខ្លួនឯងទាក់ទងនឹងបញ្ហានេះ គាំទ្រដល់ជំហររបស់សហព្រះរាជអាជ្ញា (ប្រតិចារឹកចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ និងក្រុម៤) ទំព័រ៩៥-៩៩, ១០៨)។

[២០] *សូមមើល* វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី) ទំព័រ៨២-៨៤ (យោងលើ "កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា (ភ្ជាប់ជាមួយឧបសម្ព័ន្ធ)" ធ្វើនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១, 1663 UNTS No. 28613 ("កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសឆ្នាំ១៩៩១")) និងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ (ព្រះរាជក្រមលេខ ០១/នស/៩៤)។ *សូមមើលផងដែរ* កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ E3/11 (ERN 00158836-00158841)។"

[២១] សូមមើល វិធាន ៩៨ (៣) ។

នៃការប្រព្រឹត្ត ដែលបានចោទប្រកាន់នោះតែប៉ុណ្ណោះ (ផ្នែក ១.៥)។ ឧក្រិដ្ឋកម្មនានាដែលចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ គឺស្ថិតនៅក្នុងដែនកំណត់នៃយុត្តាធិការលើរឿងក្តី យុត្តាធិការក្នុងពេលវេលា និងយុត្តាធិការលើដែនដីរបស់ អ.វ.ត.ក។

### ១.៤.២ យុត្តាធិការលើរូបបុគ្គល

១៧. យុត្តាធិការលើរូបបុគ្គល ត្រូវបានកំណត់ចំពោះ"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិនានា ដែលប្រទេសកម្ពុជាបានទទួលស្គាល់"[២២]។

១៨. សហចៅក្រមស៊ើបអង្កេត មិនបានចោទប្រកាន់ជនជាប់ចោទថាជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែបានចោទប្រកាន់ជនជាប់ចោទថាជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលយុត្តាធិការក្នុងពេលវេលារបស់អង្គជំនុំជម្រះ៖

> ១២៩. ការស៊ើបសួរបានបង្ហាញថា ទោះជា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏គាត់អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន ក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខា ក៏ដូចជាតាមរយៈការចូលរួមរបស់គាត់ ដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅស២១ ដែលជាមន្ទីរសន្តិសុខគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា[២៣]។

---

[២២] មាត្រា១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ។

[២៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១២៩ ។

១៩. កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក មិនមានចែងច្បាស់អំពី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។ ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដែលបានបង្កើតឡើងនៅឆ្នាំ១៩៩៨ ផ្អែកតាមសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ បានទទួលភារកិច្ចឲ្យវាយតម្លៃអំពីលទ្ធភាពវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម បានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្លួនថា៖

> ក្រុមអ្នកជំនាញយល់ឃើញថា ពាក្យ"មេដឹកនាំ" មិនគួរត្រូវបានប្រើប្រាស់ស្មើគ្នាចំពោះគ្រប់បុគ្គលទាំងអស់ដែលស្ថិតនៅថ្នាក់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬ បក្សកុម្មុយនីស្តកម្ពុជាទេ។ បញ្ជីឈ្មោះនៃមន្ត្រីរដ្ឋាភិបាល និងមន្ត្រីបក្សជាន់ខ្ពស់ អាចនឹងមិនស៊ីសង្វាក់គ្នានឹងបញ្ជីឈ្មោះបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលនៅក្នុងបញ្ជីឈ្មោះនេះ មេដឹកនាំរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួន អាចនឹងត្រូវដកចេញពីការដឹង និងការធ្វើសេចក្ដីសម្រេច។ ហើយអ្នកផ្សេងទៀតដែលមិនមែនស្ថិតក្នុងតំណែងជាមេដឹកនាំជាន់ខ្ពស់ អាចនឹងមានតួនាទីសំខាន់ចំពោះអំពើឃោរឃៅនេះ។ ករណីនេះហាក់ដូចជាការពិត ជាពិសេសចំពោះមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ ព្រមទាំងមន្ត្រីនានារបស់មន្ទីរធ្វើទារុណកម្ម និងសួរចម្លើយដូចជាទួលស្លែងជាដើម[២៤]។

២០. អាស្រ័យហេតុនេះ ក្រុមអ្នកជំនាញបានផ្ដល់អនុសាសន៍ថា "តុលាការនេះ ផ្ដោតលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្សនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ដូចនេះ វារួមបញ្ចូលមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះការរំលោភបំពាន ព្រមទាំងជនទាំងឡាយណាដែលស្ថិតនៅថ្នាក់ក្រោម ប៉ុន្តែមានចំណងទាក់ទងផ្ទាល់ទៅនឹងអំពើព្រៃផ្សៃធ្ងន់ធ្ងរបំផុតនេះ"[២៥]។

---

[២៤] ឯកសារអង្គការសហប្រជាជាតិ A/53/850-S/1999/231 ឧបសម្ព័ន្ធ ("របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងផ្អែកតាមសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 52/135" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩) កថាខណ្ឌ១០៩។

[២៥] ឯកសារអង្គការសហប្រជាជាតិ A/53/850-S/1999/231 ឧបសម្ព័ន្ធ ("របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងផ្អែកតាមសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 52/135" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩) កថាខណ្ឌ១១០ (គូសបញ្ជាក់បន្ថែម)។

២១. អគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រើពាក្យពេចន៍ស្រដៀងគ្នានេះ នៅពេលដែលគាត់ដាក់របាយការណ៍របស់ក្រុមអ្នកជំនាញជូនទៅក្រុមប្រឹក្សាសន្តិសុខ និងមហាសន្និបាតអង្គការសហប្រជាជាតិ[២៦]។ គណៈកម្មាធិការផ្នែកសិទ្ធិមនុស្ស ដែលបានត្រួតពិនិត្យស្ថានការណ៍នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩៩ ក៏បានប្រើពាក្យដូចគ្នាដែរ[២៧]។

២២. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត ដែលបានពិនិត្យផងដែរអំពីអត្ថន័យនៃឃ្លា "មេដឹកនាំជាន់ខ្ពស់បំផុត ដែលត្រូវបានគេសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" បានពិចារណាទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[២៨]។ នៅពេលវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានផ្អែកលើកត្តានានាដូចជា ចំនួនជនរងគ្រោះ ដែនកំណត់ភូមិសាស្ត្រ និងពេលវេលា របៀបដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង។ ចំណែកឯកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃការពិចារណានានា ដូចជាកម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មនានា ឋានានុក្រម ឬមុខតំណែងរបស់ជនជាប់ចោទរួមបញ្ចូលទាំងចំនួននៃអ្នកក្រោមបង្គាប់ និងថ្នាក់លើរបស់គាត់ និងភាពអចិន្ត្រៃយ៍នៃមុខតំណែង

---

[២៦] ឯកសារអង្គការសហប្រជាជាតិ A/53/850-S/1999/231។

[២៧] គណៈកម្មាធិការផ្នែកសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ 1999/76 (២៨ មេសា ១៩៩៩) កថាខណ្ឌ១៤។

[២៨] ឯកសារអង្គការសហប្រជាជាតិ S2002/678, ឯកសារភ្ជាប់ ("របាយការណ៍ស្តីពីឋានៈតុលាការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងលទ្ធភាពផ្ទេររឿងក្តីមួយចំនួនទៅតុលាការជាតិ (ខែមិថុនា ឆ្នាំ ២០០២") កថាខណ្ឌ៤២។ ឯកសារអង្គការសហប្រជាជាតិ S/RES/1503 (២០០៣)។ ឯកសារអង្គការសហប្រជាជាតិ UN Doc. S/RES/1534 (២០០៤) កថាខណ្ឌ៥។ ការលើកឡើងនេះត្រូវបានប្រើប្រាស់ដំបូងនៅក្នុងឯកសារអង្គការសហប្រជាជាតិ S/RES/1503 (2003) បុព្វកថា (កថាខណ្ឌ៧) ដោយក្រុមប្រឹក្សាសន្តិសុខ។ សូមមើលផងដែរ វិធាននីតិវិធី និងភស្តុតាង របស់តុលាការ ICTY វិធាន១១ស្ទួន (គ) និង ២៨ (ក)។ (ប្រៀបធៀប មាត្រា១ នៃច្បាប់ អ.វ.ត.ក ដែលបានសំដៅលើប្រភេទជនសង្ស័យពីរដាច់ដោយឡែកពីគ្នា គឺ"មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើការផ្ទេររឿងក្តី អនុលោមតាមវិធាន ១១ស្ទួន ជាមួយនឹងឧបសម្ព័ន្ធ ក និង ខ ឯកសារសម្ងាត់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-98-32/1-PT) ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ២៦។

របស់គាត់[២៩]។ អង្គបុរេ-ជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") នៅក្នុងបរិបទនៃការសម្រេចអំពីភាពអាចទទួលយកបាននៃរឿងក្តី បានវាយតម្លៃលើកត្តាស្រដៀងគ្នានេះដែរ[៣០]។

[២៩] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Lukić និងអ្នកផ្សេងទៀត*សេចក្តីសម្រេចលើការផ្ទេរសមត្ថកិច្ចលើរឿងក្តី អនុលោមតាមវិធាន ១១*ស្ទួន* ជាមួយនឹងឧបសម្ព័ន្ធ ក និង ឧបសម្ព័ន្ធ ខ ជាសម្ងាត់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-98-32/1-PT) ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ២៧, ២៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kovačević* សេចក្តីសម្រេចលើការផ្ទេរសមត្ថកិច្ចលើរឿងក្តី អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី របស់តុលាការ ICTY (IT-01-42/2-1) ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង D. Milošević* សេចក្តីសម្រេចលើការផ្ទេរសមត្ថកិច្ចលើរឿងក្តី អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-98-29/1-PT) ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ២៣, ២៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Janković* សេចក្តីសម្រេចលើការផ្ទេរសមត្ថកិច្ចលើរឿងក្តី អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-96-23/2-PT) ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ១៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ademi និងអ្នកផ្សេងទៀត*សេចក្តីសម្រេចលើការផ្ទេរទៅឱ្យសមត្ថកិច្ចរបស់សាធារណរដ្ឋក្រូអាត អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-04-78-PT) ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ២៨, ២៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ljubičić* សេចក្តីសម្រេចឱ្យផ្ទេររឿងក្តីទៅ Bosnia និង Herzegovina អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-00-41-PT) ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ កថាខណ្ឌ១៨។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Lukić និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទងនឹងការផ្ទេរសមត្ថកិច្ច អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32/1-AR11*bis*.1) ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ២២ (កំណត់ភាពសំខាន់នៃវិសាលភាពភូមិសាស្ត្រ)។

[៣០] ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ntaganda*) សេចក្តីសម្រេចលើសំណើសុំដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា មាត្រា៥៨ អង្គបុរេជំនុំជម្រះ I របស់តុលាការ ICC (ICC-01/04-02/06-20-Anx2) ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ (ឯកសារសារធារណៈដែលបានប្រកាសនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ អនុលោមតាមសេចក្តីសម្រេច ICC-01/04-520) កថាខណ្ឌ ៥១-៦៤, ៦៨-៧១, ៧៤, ៧៨-៨៩។ (បដិសេធបណ្តឹងឧទ្ធរណ៍ដោយសារមូលហេតុផ្សេងគ្នា នៅក្នុង*ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើសុំដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា មាត្រា៥៨" អង្គជំនុំជម្រះតុលាការកំពូល ICC (ICC-01/04-169) ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ (ឯកសារសារធារណៈដែលបានប្រកាសនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ អនុលោមតាមសេចក្តីសម្រេច ICC-01/04-538) កថាខណ្ឌ ៧៣-៧៩)។

២៣. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែបានចោទប្រកាន់ថា ក្នុងនាមជាអនុលេខាមន្ទីរស២១ ជនជាប់ចោទបានដឹកនាំក្រុមសួរចម្លើយ និងបានចូលរួមនៅក្នុងការរៀបចំផែនការបង្កើតមន្ទីរស២១ និងបង្រៀនបុគ្គលិករបស់គាត់អំពីបច្ចេកទេសសួរចម្លើយ។ ក្នុងនាមជាប្រធានមន្ទីរស២១ តួនាទីរបស់គាត់គឺពិនិត្យមើលប្រតិបត្តិការទាំងមូល ដោយរួមបញ្ចូលទាំងការធ្វើចំណារលើចម្លើយសារភាព និងបញ្ជាឲ្យសម្លាប់។ មន្ទីរស២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញប្រទេស និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ។ មានមនុស្សយ៉ាងតិចចំនួន ១២.០០០ នាក់[៣១] ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ ជនរងគ្រោះត្រូវបានបញ្ជូនស្ទើរតែពីគ្រប់ទីកន្លែងទូទាំងប្រទេសទៅមន្ទីរស២១ ដែលមានន័យថា វិសាលភាពនៃសកម្មភាពរបស់មន្ទីរស២១ មានទូទាំងប្រទេស។ មន្ទីរស២១បានធ្វើប្រតិបត្តិការចាប់ពីខែតុលា ឆ្នាំ១៩៧៥ រហូតដល់ដើមខែមករា ឆ្នាំ១៩៧៩ ដូច្នេះវាគ្របដណ្តប់ស្ទើរតែទាំងមូលនៃអត្ថិភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ[៣២]។

២៤. ដោយសារតែទំហំនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក មិនបានដាក់កាតព្វកិច្ចឲ្យវិនិច្ឆ័យជនទាំងឡាយ ដែលអាចជាចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ[៣៣]។ ទោះបីជាមុខតំណែងឋានានុក្រម

---

[៣១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានធ្វើការកែប្រែ បង្ហាញថាមានមនុស្សមិនតិចជាង ១២.៣៨០ នាក់ទេដែលត្រូវបានឃុំខ្លួន ។ នៅក្នុងអំឡុងពេលនៃការពិភាក្សា អង្គជំនុំជម្រះពិនិត្យឃើញថាអតិបរមានៃអ្នកជាប់ឃុំគឺ ១២.២៧៣ ផ្នែក (២.៣.៣.៤.២) ។

[៣២] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ២០, ២១, ៣២, ៣៣, ៣៧, ៣៨, ៤២, ៤៣, ៤៧, ៩៧, ៩៨, ១០៧-១០៩។

[៣៣] សូមមើល របាយការណ៍ស្ថាពរជូនទៅព្រះរាជអាជ្ញា ដោយគណៈកម្មាធិការដែលបង្កើតឡើងដើម្បីពិនិត្យយុទ្ធនាការទម្លាក់គ្រាប់បែករបស់ NATO ប្រឆាំងនឹងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ៥ (បានទទួលស្គាល់ថា នៅក្នុងពេលសម្រេចថាតើបុគ្គលណាខ្លះសមនឹងចោទប្រកាន់នៅក្នុងកម្រិតអន្តរជាតិ រដ្ឋអាជ្ញាអាចតម្រូវឲ្យបំពេញចំណុចសំខាន់កម្រិតខ្ពស់ ជាជាងគ្រាន់តែអត្ថិភាពនៃភស្តុតាងជឿជាក់ដើម្បីស្នើសុំឲ្យ កាត់សេចក្តីឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ)។

គឺជាលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធក៏ដោយ ក៏តុលាការអន្តរជាតិជាទូទៅមិនអនុវត្តការប្រៀបធៀបតាមលក្ខណៈចង្អៀតលើឋានៈជាន់ខ្ពស់បុគ្គលដែលត្រូវបានវិនិច្ឆ័យទោសកន្លងមកចំពោះមុខតុលាការនៅពេលតុលាការធ្វើការសម្រេចផ្ទេរសមត្ថកិច្ចនោះ[៣៤]។ អង្គហេតុដែលថា បុគ្គលផ្សេងទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងអំឡុងពេលកាត់សេចក្តី អាចនឹងចូលរួមប្រព្រឹត្តបទល្មើសដូចគ្នាក៏ដោយ ក៏វាមិនបានធ្វើឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរ។

២៥. អង្គជំនុំជម្រះយល់ស្របជាមួយនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទគឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ជាលក្ខណៈបុគ្គលក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ដោយពិចារណាលើសំអាងហេតុទាំងនេះ អង្គជំនុំជម្រះមិនចាំបាច់ពិនិត្យលើបញ្ហាថាតើជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ឬយ៉ាងណានោះទេ។

### ១.៥ គោលការណ៍នីត្យានុកូលភាព

២៦. ថ្វីបើអង្គជំនុំជម្រះមានយុត្តាធិការលើរឿងក្តីចំពោះឧក្រិដ្ឋកម្មនានា និងទម្រង់នៃការទទួលខុស-ត្រូវក៏ដោយ ក៏ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ត្រូវតែអនុវត្តឱ្យស្របតាមគោល-ការណ៍នីត្យានុកូលភាព[៣៥]។

---

[៣៤] សូមមើល ឧទាហរណ៍ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Ademi and Norac សេចក្តីសម្រេចលើការផ្ទេរសមត្ថកិច្ចទៅឱ្យសាធារណរដ្ឋក្រូអាត អនុលោមតាមវិធាន១១*ស្ទួន* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY (IT-04-78-PT) ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ ៣០-៣១ (យល់ឃើញថា ឋានៈខ្ពស់របស់ជនជាប់ចោទ មិនបានរារាំងតាមរយៈអង្គហេតុមិនឱ្យផ្ទេរទៅយុត្តាធិការថ្នាក់ជាតិជំនុំជម្រះនោះទេ)។

[៣៥] មាត្រា៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងថា អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ឯកសារលេខ ៩៩៩ UNTS ១៧១ ("ICCPR")។ សូមមើលផងដែរ មាត្រា៣១(១) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២៧. មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬអកម្មណាមួយ ដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ"[៣៦]។ គោលការណ៍នេះ បានបញ្ជាក់នៅក្នុងមាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែងបន្ថែមថា "គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះ និងការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើសកម្ម ឬអកម្មណាមួយ ដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលអំពើសកម្ម ឬអកម្មជាបទល្មើសព្រហ្មទណ្ឌស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"[៣៧]។

២៨. យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ថា ការអនុវត្តគោលការណ៍នីត្យានុកូលភាពតម្រូវថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់ចំពោះជនជាប់ចោទ ត្រូវតែជាទង្វើដែលគេប្រមើលមើលឃើញច្បាស់ថាជាបទឧក្រិដ្ឋ ហើយច្បាប់ដែលចែងអំពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះត្រូវតែដឹងដោយជនជាប់ចោទនៅពេលគាត់ប្រព្រឹត្តបទឧក្រិដ្ឋនោះ[៣៨]។ ការអនុវត្តរបស់រដ្ឋមួយចំពោះ

---

ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ")។

[៣៦] មាត្រា១៥(១) នៃ ICCPR ចែងបន្ថែមថា "មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តិបទល្មើសហើយ ច្បាប់បានបញ្ញត្តឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ"។

[៣៧] គោលការណ៍នីត្យានុកូលភាព ត្រូវបានទទួលស្គាល់ដោយលិខិតុបករណ៍អន្តរជាតិផ្សេងៗជាច្រើន រួមមានមាត្រា១១(២) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ 217A ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) និងមាត្រា៧ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ETS 5 ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០) (ECHR)។

[៣៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើសុំរបស់ Dragolijub Ojdanovic ដែលតវ៉ាទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះចំពោះសហឧក្រិដ្ឋកម្មរួម របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៨។ *សូមមើលផងដែរ S.W. តទល់នឹង ចក្រភពអង់គ្លេស* សាលក្រមរបស់តុលាការ ECtHR (លេខ A-355-B(1995)) ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ កថាខណ្ឌ៣៥-៣៦

ការអត់ឱន ឬលើកទឹកចិត្តចំពោះអំពើមួយចំនួននឹងមិនអាចយកមកធ្វើជារនាំងក្នុងការនាំខ្លួនចារីមកកាត់សេចក្តី និងផ្តន្ទាទោស នៅពេលឧក្រិដ្ឋកម្មទាំងនោះមានចែងនៅក្នុងច្បាប់ជាតិ ឬអន្តរជាតិនោះទេ[៣៩]។ គោលការណ៍នីត្យានុកូលភាពអនុវត្តចំពោះឧក្រិដ្ឋកម្មផង និងទម្រង់នៃការទទួលខុសត្រូវផង[៤០]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវសម្រេចថា តើឧក្រិដ្ឋកម្ម និងទម្រង់នៃការចូលរួមដែលបានចោទ-ប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជា និងច្បាប់អន្តរជាតិក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែរ ឬយ៉ាងណា។

២៩. ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាច្បាប់ជាតិជាធរមាន ដែលគ្របដណ្តប់នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពីព្រោះក្រមនេះនៅតែនៅជាធរមានបន្ទាប់ពីការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញទាំងពីរ គឺរដ្ឋ-ធម្មនុញ្ញសាធារណរដ្ឋខ្មែរដែលប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ និងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលប្រកាសឲ្យប្រើនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។

(បានបង្ហាញថា ពាក្យ "ច្បាប់" នៅក្នុងមាត្រា៧ នៃតុលាការ ECHR "រួមមានច្បាប់ជាលាយលក្ខណ៍អក្សរ ព្រមទាំងច្បាប់ទំនៀមទម្លាប់ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ និងបង្កប់ន័យលក្ខខណ្ឌតម្រូវគុណសម្បត្តិ ជាពិសេស លក្ខខណ្ឌទាក់ទងនឹងភាពអាចដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ")។

[៣៩] *រឿងក្តី* Kononov *តទល់នឹង* Latvia សាលក្រមរបស់តុលាការ ECtHR (លេខ 3637/04) ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ១១៤(ង)

[៤០] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinović *និងអ្នកផ្សេងទៀត* សេចក្តីសម្រេចស្តីពីសំណើសុំរបស់ Dragolijub Ojdanovic ប្រឆាំងនឹងយុត្តាធិការលើសហឧក្រិដ្ឋកម្មរួមរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៤-៤៤ (ដែលអនុវត្តចំពោះសហឧក្រិដ្ឋកម្មរួម)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Aleksovski សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១២៦ (ដែលអនុវត្តចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩)។

៣០. ទាក់ទងទៅនឹងប្រភពពាក់ព័ន្ធនៃច្បាប់អន្តរជាតិដែលអនុវត្តក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះអាចផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ[៤១] ព្រមទាំងគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ[៤២]។

៣១. ការវាយតម្លៃអំពីលក្ខខណ្ឌទាំងមូលនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងលក្ខខណ្ឌនៃភាពអាចដឹងថាមានច្បាប់ចែង ដែលជាចំណុចសំខាន់នៃគោលការណ៍នីត្យានុកូលភាព គួរតែពិចារណាអំពីលក្ខណៈពិសេសនៃច្បាប់អន្តរជាតិ រួមទាំងទំនៀមទម្លាប់ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ[៤៣]។ អង្គជំនុំជម្រះតុលាការកំពូល ICTY បានកត់សម្គាល់ថា៖

> ចំពោះការប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ ទង្វើបែបនេះ គឺជាការប្រព្រឹត្តិពិតប្រាកដរបស់ជនជាប់-ចោទ។ គាត់ត្រូវតែអាចដឹងថា ការប្រព្រឹត្តិនោះគឺជាអំពើឧក្រិដ្ឋនៅក្នុងវិញ្ញាណដែលអាចដឹងជាទូទៅ ដោយគ្មានសំអាងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ។ ចំពោះការដឹងថាមានច្បាប់ចែងនៅក្នុង

---

[៤១] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០) កថាខណ្ឌ១២៦ (ផ្អែកលើប្រភពច្បាប់ទំនៀមទម្លាប់ និងអនុសញ្ញា)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង អ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៤១-៤២។

[៤២] *សូមមើល* មាត្រា១៥(២) នៃ ICCPR។ *សូមមើលផងដែរ* មាត្រា៣៨(១) នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ។

[៤៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើសុំរបស់ Dragolijub Ojdanovic ដែលតវ៉ាទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះចំពោះសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៨-៤២។ *សូមមើល Groppera Radio AG និងអ្នកផ្សេងទៀត តទល់នឹង ប្រទេសស្វីស* សេចក្តីសម្រេចរបស់តុលាការ ECtHR (លេខ A-173(1990)) ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩០ កថាខណ្ឌ៦៨ (លើកឡើងថា វិសាលភាពនៃទ្រឹស្តីភាពអាចប្រមើលមើលថាជាបទឧក្រិដ្ឋ គឺអាស្រ័យលើកម្រិតសំខាន់នៃខ្លឹមសារអត្ថបទដែលចោទបញ្ហា ផ្នែកដែលរៀបចំដើម្បីគ្របដណ្តប់ចំនួននិងស្ថានភាពនៃបុគ្គលទាំងឡាយដែលត្រូវយកមកដោះស្រាយ)។ រឿងក្តី Kononov v. Latvia សេចក្តីសម្រេចរបស់សភាពេញអង្គតុលាការ ECtHR ឯកសារលេខ (no.3637/04) ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ២៣៥ ។

ករណីតុលាការអន្តរជាតិ ដូចជាករណីតុលាការនេះជាដើម ការដឹងថាមានច្បាប់ចែងបានរួមបញ្ចូលទាំងបទប្បញ្ញត្តិច្បាប់ដែលផ្អែកលើទំនៀមទម្លាប់ផងដែរ[៤៤]។

៣២. បន្ថែមពីលើនេះ "ទោះបីជាអំពើដែលគ្មានសីលធម៌ ឬឃោរឃៅ មិនមាននូវកត្តាគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាឧក្រិដ្ឋភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏ប៉ុន្តែ ជាការពិតអំពើគ្មានសីលធម៌ ឬអំពើឃោរឃៅនោះដើរតួនាទីទាក់ទងនឹងឧក្រិដ្ឋភាពត្រឹមកម្រិតមួយដែលអាចបដិសេធការអះអាងរបស់មេធាវីការពារក្តី ដែលបានលើកឡើងថាជនជាប់ចោទមិនបានដឹងពីអំពើឧក្រិដ្ឋរបស់ខ្លួននោះទេ"[៤៥]។

៣៣. អង្គជំនុំជម្រះក៏អាចផ្អែកលើច្បាប់អនុសញ្ញាអន្តរជាតិ នៅពេលដែលសន្ធិសញ្ញាមួយ (i) ចងភ្ជាប់កាតព្វកិច្ចភាគីនានាយ៉ាងពិតប្រាកដ នៅពេលដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ និង (ii) មិនផ្ទុយ ឬមិនប៉ះពាល់ដល់បទដ្ឋានអាជ្ញាបញ្ញានៃច្បាប់អន្តរជាតិ[៤៦]។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ICTY គោលការណ៍នីត្យានុកូលភាព "ក៏ត្រូវបានបំពេញផងដែរនៅពេលដែលរដ្ឋមួយត្រូវបានចងភ្ជាប់ដោយអនុសញ្ញាជាក់លាក់មួយ ហើយតុលាការអន្តរជាតិអនុវត្តបទ-ប្បញ្ញត្តិនៃអនុសញ្ញានោះ ដោយមិនគិតថាតើអនុសញ្ញានោះជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬមិនមែននោះទេ"[៤៧]។ មិនតែប៉ុណ្ណោះ នៅក្នុងការអនុវត្តជាក់ស្តែង តុលាការអន្តរជាតិនានាបានបញ្ជាក់

---

[៤៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត* សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-AR72) ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៣៤។

[៤៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinović *និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើសុំរបស់ Dragolijub Ojdanović ដែលតវ៉ាទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះចំពោះសហឧក្រិដ្ឋកម្មរួមអង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៤២។

[៤៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Tadić សេចក្តីសម្រេចលើបណ្តឹងបន្ទាន់បង្ខំរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ១៤៣ (ដូចមាននៅក្នុងមាត្រា៣ នៃលក្ខន្តិកៈរបស់តុលាការ ICTY)។

[៤៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង អ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៤៤។

00573356



ថា តើបទប្បញ្ញត្តិរបស់សន្ធិសញ្ញាមួយគឺជាបទប្បញ្ញត្តិដែលត្រូវតែប្រកាសជាទំនៀមទម្លាប់ផងដែរ ឬយ៉ាងណា[៤៨]។

៣៤. គោលការណ៍នីត្យានុកូលភាព មិនបានហាមឃាត់ដល់អង្គជំនុំជម្រះក្នុងការកំណត់លើបញ្ហាណាមួយ តាមរយៈដំណើរការនៃការបកស្រាយ និងការបញ្ជាក់លើធាតុផ្សំនៃបទល្មើសណាមួយនោះទេ។ ហើយគោលការណ៍នេះក៏មិនបានហាមឃាត់អង្គជំនុំជម្រះមិនឲ្យផ្អែកលើសេចក្តីសម្រេចដែលសមស្រប ដែលសេចក្តីសម្រេចនោះបកស្រាយអំពីធាតុផ្សំជាក់លាក់នៃបទល្មើសណាមួយនោះដែរ[៤៩]។ ជាពិសេស ការពឹងផ្អែករបស់អង្គជំនុំជម្រះលើសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនានា ដែលសម្រេចក្រោយខែមករា ឆ្នាំ១៩៧៩ មិនផ្ទុយនឹងគោលការណ៍នីត្យានុកូលភាពទេ។ ប៉ុន្តែ សេចក្តីសម្រេចទាំងនេះផ្តល់នូវការណែនាំ បកស្រាយទាក់ទងនឹងស្ថានភាពវិវត្តន៍នៃឧក្រិដ្ឋកម្មមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ។ បន្ថែមពីលើនេះ ហេតុដែលថា អ.វ.ត.ក ត្រូវបានបង្កើត និងផ្តល់យុត្តាធិការឲ្យដោះស្រាយឧក្រិដ្ឋកម្ម ក្រោយពីឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត មិនបានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពនោះទេ[៥០]។

---

[៤៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Galić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-29-A) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ៨៥។

[៤៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១២៦។ *សូមមើលផងដែរ S.W. តទល់នឹង ចក្រភពអង់គ្លេស* សេចក្តីសម្រេចរបស់ ECtHR (លេខ A-335B (1995)) ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ កថាខណ្ឌ៣៥-៣៦។

[៥០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kallon និងអ្នកផ្សេងទៀត* សេចក្តីសម្រេចទាក់ទងនឹងធម្មនុញ្ញភាព និងភាពគ្មានយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន "SCSL" (SCSL-04-14- PT & SCSL-04-15- PT & SCSL-04-16- PT) ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ៨២ ("អង្គហេតុដែលថា មិនមានតុលាការមានយុត្តាធិការវិនិច្ឆ័យលើបទល្មើស ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ នៅពេលបទល្មើសបានប្រព្រឹត្តនោះមិនមានន័យថាជនជាប់ចោទអាចរួចផុតពីការចោទប្រកាន់ និងមិនអាចនិយាយបានថា ជាការរំលោភបំពានលើគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែងនោះទេ (nullum crimen sine lege)"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១៧៩-១៨០។ *រឿងក្តី cf. Streletz, Kessler និង Krenz តទល់នឹង ប្រទេសអាល្លឺម៉ង់* សេចក្តីសម្រេចរបស់តុលាការ ECtHR (No. 34044/96 & 35532/97 & 44801/98) ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១ កថាខណ្ឌ៧៩-៨១។

## ១.៦ វិធានផ្ទៃក្នុង និងគោលការណ៍នៃភស្តុតាងជាធរមាន

### ១.៦.១ ច្បាប់នីតិវិធីជាធរមាន

៣៥. អនុលោមតាមកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក[៥១] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រព្រឹត្តទៅស្របទៅតាមច្បាប់នីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយពេលបង្កើតអង្គជំនុំ-ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ.វ.ត.ក បានអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន[៥២]។ វិធានផ្ទៃក្នុងមានគោលបំណងចងក្រងនីតិវិធីជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ចែងថា វិធានបន្ថែមមួយចំនួនទៀតអាចនឹងត្រូវបានអនុម័ត ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ ក្នុងការបកស្រាយ ឬការអនុវត្តនីតិវិធីនោះ ឬក៏ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ[៥៣]។ ដូច្នេះហើយ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាគ្របដណ្តប់លើនីតិវិធីចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំ-ជម្រះក៏អាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិតាមករណីសមស្របបានផងដែរ។

---

[៥១] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា១២។ ច្បាប់ អ.វ.ត.ក មាត្រា៣៣(ថ្មី)។ *សូមមើល* ច្បាប់ អ.វ.ត.ក មាត្រា២០(ថ្មី) (ផ្នែកពាក់ព័ន្ធជាមួយសហព្រះរាជអាជ្ញា) និងមាត្រា២៣(ថ្មី) (ផ្នែកពាក់ព័ន្ធជាមួយសហចៅក្រមស៊ើបអង្កេត)។

[៥២] វិធានផ្ទៃក្នុង អ.វ.ត.ក លើកទីមួយ ត្រូវបានអនុម័តនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ហើយកំណែលើកទីមួយធ្វើឡើងនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ (ចូលជាធរមាននៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៨) កំណែលើកទីពីរធ្វើឡើងនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ (ចូលជាធរមាននៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨) កំណែលើកទីបីធ្វើឡើងនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ (ចូលជាធរមាននៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩) ហើយកំណែលើកទីបួនធ្វើឡើងនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ (ចូលជាធរមាននៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩) កំណែលើកទីប្រាំធ្វើឡើងនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០(ចូលជាធរមាននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០)។ ឯកសារយោងទាំងអស់នៅក្នុងសាលក្រមនេះ ចំពោះ "វិធានផ្ទៃក្នុង" ប្រសិនបើមិនបានបញ្ជាក់នោះទេ គឺមាននៅក្នុងវិធានមួយនៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលចូលជាធរមានបច្ចុប្បន្ននេះ។

[៥៣] កថាខណ្ឌទី ៥ នៃបុព្វកថារបស់វិធានផ្ទៃក្នុង ដែលបានលើកឡើងនូវមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា២០(ថ្មី) មាត្រា២៣(ថ្មី) និងមាត្រា៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក។

១.៦.២ សំណុំរឿង

៣៦. សំណុំរឿង គឺជាលទ្ធផលនៃការប្រមូលនូវសម្ភារៈទាំងឡាយនៅក្នុងដំណាក់កាលស៊ើបអង្កេតនៃរឿងក្តីបច្ចុប្បន្ន។ ឯកសារត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងជាបន្តបន្ទាប់ នៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក។

៣៧. អង្គជំនុំជម្រះបានទទួលសំណុំរឿងជាផ្លូវការ បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៥៤]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ បានអនុញ្ញាតឲ្យអង្គជំនុំជម្រះពិនិត្យមើលសំណុំរឿងក្នុងគោលបំណងរៀបចំឯកសារជាមុនសម្រាប់ការជំនុំជម្រះ ដែលការអនុវត្តបែបនេះមានចែងនៅក្នុងវិធាននផ្ទៃក្នុង[៥៥]។

៣៨. សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថាជាភស្តុតាង ហើយអង្គជំនុំជម្រះអាចធ្វើការសម្រេចសេចក្តីដោយយោងលើភស្តុតាងទាំងនោះបាន ដរាបណាសម្ភារៈដែលត្រូវបានចាត់ទុកថាជាភស្តុតាងទាំងនោះត្រូវបានឆ្លងកាត់ការដេញដោល និងមិនស្ថិតនៅក្រៅលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន៨៧(៣) នៃវិធាននផ្ទៃក្នុង។

១.៦.៣ ការទទួលយកភស្តុតាង

៣៩. វិធាន៨៧(១)នៃវិធាននផ្ទៃក្នុង បានចែងថា “លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធាននផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក”[៥៦]។ វិធាន៨៧(២)នៃវិធាននផ្ទៃក្នុង បានទទួលស្គាល់

---

[៥៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

[៥៥] “សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំការអនុញ្ញាតពិនិត្យសំណុំរឿង” ឯកសារ D99/3/5 ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨។ វិធាន៦៩(៣) នៃវិធាននផ្ទៃក្នុង ដែលចូលជាធរមាននៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩ ចែងថា “ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូងក្នុងការមើលសំណុំរឿងក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ”។

[៥៦] វិធាន២១(៣)នៃវិធាននផ្ទៃក្នុង ចែងជាពិសេសថា ចម្លើយដែលទទួលបានក្រោមការប្រើប្រាស់ការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬការគំរាមកំហែង មិនត្រូវទទួលយកជាភស្តុតាងនៅមុខអង្គជំនុំជម្រះនោះទេ។

វិសាលភាពនៃគោលការណ៍ទូទៅនេះ ដែលវិធាននេះចែងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការជជែកដេញដោល"។

៤០. ទោះបីជាការប្រើពាក្យពេចន៍នៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង សំដៅលើ "ភស្តុតាងដែលមាននៅក្នុងសំណុំរឿង" ក៏ដោយ ក៏ខ្លឹមសារទូទៅនៃអនុវិធានក្នុងវិធាននេះបង្ហាញឲ្យឃើញច្បាស់ថាសម្ភារៈដែលមាននៅក្នុងសំណុំរឿងមិនមែនជា "ភស្តុតាង" ទេ ប្រសិនបើសម្ភារៈទាំងនោះមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ដូចជាត្រូវបានសង្ខេប ត្រូវបានអាន ឬអាចត្រូវបានកំណត់អត្តសញ្ញាណ)[៥៧]។ អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មី ដែលមិនមាននៅក្នុងសំណុំរឿងតាមឆន្ទានុសិទ្ធិ ឬតាមសំណើរបស់ភាគី[៥៨]។

៤១. លើសពីនេះ ដើម្បីអាចយកមកប្រើជាភស្តុតាង សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវតែបំពេញលក្ខខណ្ឌច្បាស់លាស់នៃភាពពាក់ព័ន្ធ និងភាពអាចជឿបាននៃភស្តុតាង។ អង្គជំនុំជម្រះអាចបដិសេធមិនទទួលយកធ្វើជាភស្តុតាងនូវសម្ភារៈណាមួយ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង (ដូចជាភាពមិនជាប់ពាក់ព័ន្ធ ភាពមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលចោទប្រកាន់ ភស្តុតាងដែលមិនអាចរកបានក្នុងរយៈពេលសមស្រប ឬដោយសារអត្ថិភាពនៃការរំលោភបំពានលើបទដ្ឋានច្បាប់ជាសារវ័ន្ត ដែលពាក់ព័ន្ធនឹងវិធាននៃភស្តុតាង)។

៤២. ភាពដែលអាចជឿបាននៃភស្តុតាង និងទម្ងន់នៃភស្តុតាងទាំងនេះត្រូវបានអង្គជំនុំជម្រះវាយតម្លៃជាចុងក្រោយ។

[៥៧] *សូមមើល* "សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង" ឯកសារ E43/4 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៥-៧។

[៥៨] *សូមមើល* "សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់" ឯកសារ E5/10/2 ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ (ភាគីដែលធ្វើសំណើសុំបែបនេះ ត្រូវដាក់សំណើដោយមានមូលហេតុត្រឹមត្រូវ ហើយត្រូវបង្ហាញថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើ មិនអាចរកបាននៅមុនពេលបើកការជំនុំជម្រះ)។ *សូមមើលផងដែរ* វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង (អនុញ្ញាតឲ្យអង្គជំនុំជម្រះកោះហៅ ឬស្តាប់សាក្សីណាម្នាក់ ឬទទួលយកភស្តុតាងថ្មីក្នុងពេលជំនុំជម្រះ ដែលនាំឲ្យមានពន្លឺដល់ការស្វែងរកការពិត)។

៤៣. នៅក្នុងការអនុវត្តរបស់ខ្លួន អង្គជំនុំជម្រះបានអនុវត្តគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន ដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក ព្រមទាំងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ។ បើតាមយុត្តិសាស្ត្រនេះអង្គជំនុំជម្រះអាចពិចារណាទទួលយកភស្តុតាងចម្លង និងភស្តុតាងប្រយោល នៅពេលដែលភស្តុតាងទាំងនោះមានភាពពាក់ព័ន្ធ និងមានតម្លៃដែលអាចជឿបាន[៥៩]។ទាក់ទងនឹងភស្តុតាងចម្លង អង្គជំនុំជម្រះបានពិចារណាជាពិសេស ថាតើជនជាប់ចោទអាច ឬមិនអាចតទល់នឹងប្រភពនៃភស្តុតាងបែបនោះបានដែរ ឬទេ[៦០] ។ ស្របតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់សាក្សីម្នាក់អាចបញ្ជាក់លើអង្គហេតុបាន នៅពេលដែលសក្ខីកម្មនោះមានភាពពាក់ព័ន្ធ និងតម្លៃដែលអាចជឿបាន[៦១]។

---

[៥៩] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ICTR (ICTR-99-52-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៥០៩ ។ *រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៥៨ ។

[៦០] "សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង" ឯកសារ E43/4, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ១៤-១៦ (សេចក្តីថ្លែងការណ៍នោះមិនត្រូវបានរាប់បញ្ចូលទេ នៅពេលដែលជនជាប់ចោទមិនបានតទល់ជាមួយអ្នកដែលធ្វើសេចក្តីថ្លែងការនោះ ហើយក្នុងករណីដែលការតទល់នោះមិនអាចធ្វើកើត)។

[៦១] *សូមមើល ឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ៦២។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-16-T) ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ១០៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ១៣៥។

១.៦.៤ បន្ទុក និងបទដ្ឋាននៃភស្តុតាង

៤៤. វិធាន ២១(ឃ) នៃវិធានផ្ទៃក្នុងចែងអំពីសិទ្ធិរបស់ជនជាប់ចោទ ដែលគាត់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ[៦២]។ ការសន្មតបែបនេះ ដាក់បន្ទុកលើសហព្រះរាជអាជ្ញាឱ្យបញ្ជាក់នូវពិរុទ្ធភាពរបស់ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក[៦៣]។ វិធាន៨៧(១) នៃវិធានផ្ទៃក្នុងចែងបន្ថែម ថា "ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

៤៥. មូលដ្ឋាននៃសំអាងហេតុនេះត្រូវបានចែងខុសគ្នារវាងប្រព័ន្ធច្បាប់ (Common Law) និងប្រព័ន្ធច្បាប់(Civil Law) និងនៅក្នុងសំណៅភាសាផ្សេងៗគ្នានៃវិធាន៨៧(១) នៃវិធានផ្ទៃក្នុង។ ច្បាប់កម្ពុជាចេញមកពីច្បាប់ស៊ីវិល និងជាពិសេស ចេញពីសញ្ញាណនៃជំនឿស្មោះត្រង់ពិតប្រាកដរបស់ចៅក្រម (judge's *intime conviction*)[៦៤]។ សញ្ញាណនេះ ត្រូវបានលើកឡើងនៅក្នុងសំណៅជាភាសាបារាំងរបស់វិធាន៨៧(១)នៃវិធានផ្ទៃក្នុង ប៉ុន្តែទាំងសំណៅជាភាសាខ្មែរ និងភាសាអង់គ្លេសនៃវិធាននេះចែងថា ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យ[៦៥]។ ទោះបីជាមានភាពខុសគ្នានៅក្នុងអត្ថបទទាំងនេះ អង្គជំនុំជម្រះបានសម្រេចយកវិធីសាស្ត្ររួមមួយទៅវាយតម្លៃភាពគ្រប់គ្រាន់នៃភស្តុតាងនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ។ នៅពេលមានការវាយតម្លៃភស្តុតាងដែល

[៦២] *សូមមើលផងដែរ* មាត្រា១៣ កិច្ចព្រមព្រៀង អ.វ.ត.ក ។ ច្បាប់ អ.វ.ត.ក មាត្រា៣៥(ថ្មី)។ ការសន្មតជាមុនថាគ្មានទោសត្រូវបានសរសេរនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សជាច្រើន រួមទាំងមាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ 999 UNTS 171 ("ICCPR") និងមាត្រា៦(២) នៃអនុសញ្ញាអឺរុបសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ETS 5 ("ECHR")។

[៦៣] វិធាន៨៧(១) នៃវិធានផ្ទៃក្នុង។

[៦៤] *សូមមើលផងដែរ* មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧៖ "តុលាការថ្លឹងថ្លែងដោយសេរីបង្គ្រប់ភស្តុតាង អំពីតម្លៃភស្តុតាង ដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន" ។

[៦៥] វិធាន៨៧(១) នៃវិធានផ្ទៃក្នុងជាភាសាបារាំងសរសេរថា៖ "[p]our condamner l'accusé, la Chambre doit avoir *l'intime conviction* de sa culpabilité." (គូសបញ្ជាក់បន្ថែម) ផ្ទុយទៅវិញតុលាការ ICTY ICTR និង ICC បានធ្វើឱ្យពាក្យ "ដោយគ្មានវិមតិសង្ស័យ" ស្មើទៅនឹងពាក្យ "*au-delà de tout doute raisonnable.*" ។

មានសំអាងហេតុ ភាពសង្ស័យអំពីពិរុទ្ធភាព ត្រូវបានបកស្រាយនៅក្នុងន័យដែលផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ។

### ១.៦.៥ ប្រភពនៃភស្តុតាងនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ

#### ១.៦.៥.១ អង្គហេតុដែលបានព្រមព្រៀង និងការទទួលស្គាល់របស់ជនជាប់ចោទ

៤៦. អង្គជំនុំជម្រះបានណែនាំសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីឱ្យដាក់ឯកសារដែលបង្ហាញពីការព្រមព្រៀងរបស់ខ្លួនទៅលើអង្គហេតុនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែប្រសិនបើមាន[៦៦]។ សេចក្ដីសន្និដ្ឋានទាំងអស់នេះ ត្រូវបានដាក់កាលពីថ្ងៃទី១១ ខែកុម្ភៈ ២០០៩ និងថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ដាច់ដោយឡែកពីគ្នា[៦៧]។ នៅក្នុងអំឡុងពេលសវនាការថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានណែនាំសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីឱ្យប្រកាសជាសាធារណៈនូវអង្គហេតុនានាដែលបានព្រមព្រៀងគ្នា ឬអង្គហេតុនានាដែលមិនមានការតវ៉ា[៦៨]។

[៦៦] "សេចក្ដីណែនាំស្នើសុំព័ត៌មានបន្ថែមពីភាគីនិងសហចៅក្រមស៊ើបអង្កេត ដើម្បីត្រៀមរៀបចំបើកសវនាការបឋម" ឯកសារ E5/11 ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ៥។

[៦៧] "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការព្រមព្រៀងលើអង្គហេតុ" ឯកសារE5/11/2 ។ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ឯកសារE5/11/6.1 ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ១ ទៅនឹង "ការកំណត់សម្គាល់បន្ថែមរបស់ក្រុមមេធាវីការពារក្ដីទៅលើឯកសារដែលមានចំណងជើងថា៖ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6 ។ *សូមមើលផងដែរ* "ឧបសម្ព័ន្ធ២៖ ផ្នែកទី៣ ព័ត៌មានទាក់ទងនឹងបុគ្គលិកលក្ខណៈ" ឯកសារ E5/11/6.2 ។

[៦៨] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩, ទំព័រ១៣,៣៨-៧៧។ ឱកាសជាច្រើនត្រូវបានផ្ដល់ឱ្យជនជាប់ចោទក្នុងពេលសវនាការ ដើម្បីបន្ថបញ្ជាក់ពីគោលជំហររបស់គាត់ទាក់ទងនឹងអង្គហេតុជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ (*ឧទាហរណ៍ សូមមើល*ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទំព័រ៤២-៥៧។ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៥-៤២។ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៥៩-៦២, ៦៦-៦៧។ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩, ទំព័រ២៩-៣១)។

៤៧. និយាយតាមន័យទូលាយ ជនជាប់ចោទបានយល់ព្រម ឬមិនបានតវ៉ាទៅនឹងអង្គហេតុមួយចំនួនធំ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ[៦៩]។

៤៨. ខុសគ្នាពីក្របខណ្ឌច្បាប់របស់តុលាការអន្តរជាតិផ្សេងៗទៀត ច្បាប់ជាធរមានដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក មិនបានចែងអំពីនីតិវិធីចំពោះការទទួលយក និងកត់ត្រាជាផ្លូវការចំពោះការទទួលសារភាពអំពីពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ[៧០]។ ចំពោះមុខតុលាការអន្តរជាតិទាំងនេះ ជាធម្មតាការព្រមទទួលពិរុទ្ធភាព អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងដំណើរការដោយផ្ទាល់នូវការពិចារណាលើកត្តានានាដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស បន្ទាប់ពីដំណាក់កាលបង្ហាញភស្តុតាងដោយសង្ខេបរួចមក[៧១]។ នៅពេលដែលគ្មានយន្តការបែបនេះ អង្គជំនុំជម្រះត្រូវតែស្តាប់ និងធ្វើការវាយតម្លៃលើភស្តុតាងនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងភស្តុតាងដែលពាក់ព័ន្ធទៅនឹងបញ្ហានានាដែលមិនមានការតវ៉ាផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការព្រមព្រៀងទៅលើអង្គហេតុនានាបានជួយដល់អង្គជំនុំជម្រះ នៅក្នុងការកំណត់អត្តសញ្ញាណបញ្ហានានាដែលមានវិវាទខ្លាំងជាងគេបំផុតនៅពេលជំនុំជម្រះ និងធ្វើឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានល្អ។

---

[៦៩] *ឧទាហរណ៍ សូមមើល* "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៣, ៧, ៣៥, ៣៩, ៥៨-៦០, ១៦៩, ២០៣ និង ២១៣។

[៧០] *ឧទាហរណ៍ សូមមើល* វិធាន៦២ និងវិធាន៦២ *ស្ទួន* របស់ ICTR។ វិធាន៦២ និងវិធាន៦២ *ស្ទួន* នៃវិធាននីតិវិធី និងភស្តុតាង ICTY និងវិធាន៦១, ៦២ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការពិសេស SCSL។

[៧១] *ឧទាហរណ៍ សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Serugendo* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-2005-84-I) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៦ កថាខណ្ឌ៤-១១ (កត់សម្គាល់ឃើញថាការព្រមព្រៀងទទួលទោស ត្រូវបានដាក់ដោយភាគីនានា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦ និងអង្គជំនុំជម្រះសាលាដំបូងបានសម្រេចការផ្តន្ទាទោស បន្ទាប់ពីសវនាការលើការទទួលទោសកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bralo* សាលក្រមស្តីពីការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17-S) ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ៣ (កត់សម្គាល់ថា ការព្រមព្រៀងទទួលទោសត្រូវបានដាក់ដោយភាគី កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ និងអង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោសនៅក្នុងថ្ងៃជាមួយគ្នាបន្ទាប់ពីសវនាការ)។

00573364



៤៩. អនុលោមតាមវិធានផ្ទៃក្នុង ការព្រមព្រៀងលើអង្គហេតុមិនបានចងកាតព្វកិច្ចដល់អង្គជំនុំជម្រះ និងមិនបានសម្រាលកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញានៅក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកនោះទេ។ នៅពេលភស្តុតាងដែលមាននៅក្នុងការព្រមព្រៀងលើអង្គហេតុ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល អង្គជំនុំជម្រះនៅតែមានសិទ្ធិក្នុងការវាយតម្លៃអំពីទម្ងន់នៃភស្តុតាងនោះ ប្រសិនបើមាន[៧២]។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យអង្គជំនុំជម្រះទទួលយកអង្គហេតុទាំងនោះ ថាជាអង្គហេតុដែលបានបញ្ជាក់ដោយភស្តុតាងរួចហើយ[៧៣]។

#### ១.៦.៥.២ ការតាំងសំណួរដល់ជនជាប់ចោទ និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង

៥០. ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋាន ដែលជាសិទ្ធិមិនត្រូវបានគេបង្ខំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬឆ្លើយសារភាពអំពីពិរុទ្ធភាព[៧៤]។ ជនជាប់ចោទត្រូវបានជូនដំណឹងអំពីសិទ្ធិនេះ ប៉ុន្តែជនជាប់ចោទត្រូវបានតម្រូវឲ្យឆ្លើយសំណួរនៅពេលសវនាការ និងធ្វើការបញ្ជាក់អំពីអង្គហេតុជាច្រើនដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ[៧៥]។ ចម្លើយតបនានារបស់ជនជាប់ចោទបង្កើតបានជាភស្តុតាង ដែលតម្លៃនៃភស្តុតាងនេះ ត្រូវបានយកមកពិចារណាដោយអង្គជំនុំជម្រះ[៧៦]។

៥១. វិធាន៩០(១) នៃវិធានផ្ទៃក្នុង តម្រូវឲ្យអង្គជំនុំជម្រះសួរគ្រប់សំណួរដែលសមហេតុផល ទៅជន-ជាប់ចោទ ទោះបីជាសំណួរទាំងអស់នេះបង្ហាញភស្តុតាង ឬមិនបង្ហាញភស្តុតាងពាក់ព័ន្ធនឹងពិរុទ្ធភាព

---

[៧២] ប្រតិចារឹកចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ១២-១៤ (កត់សម្គាល់តួនាទីនៃការព្រមព្រៀងលើអង្គហេតុក្នុងកិច្ចដំណើរការនីតិវិធី)។

[៧៣] អនុវិធានថ្មី៨៧(៦) នៃវិធានផ្ទៃក្នុង ដែលចូលជាធរមាននៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩ បញ្ជាក់ថា "ក្នុងករណីដែលសហព្រះរាជអាជ្ញា និងជនជាប់ចោទព្រមព្រៀងគ្នាថា អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានជំទាស់ទេ នោះអង្គជំនុំជម្រះអាចចាត់ទុកថា អង្គហេតុនោះ ត្រូវបានបញ្ជាក់ដោយភស្តុតាង"។

[៧៤] *សូមមើល* ច្បាប់ អ.វ.ត.ក មាត្រា៣៥(ថ្មី)។ វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* មាត្រា១៤(៣)(ឆ) នៃ ICCPR ។

[៧៥] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ទំព័រ៥។

[៧៦] *សូមមើលផងដែរ* វិធាន៨៧(៥) នៃវិធានផ្ទៃក្នុង ("អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាពដូចគ្នានឹងប្រភេទនៃភស្តុតាងដទៃទៀតដែរ"។

របស់ជនជាប់ចោទក្តី។ នៅក្នុងកិច្ចដំណើរការសវនាការទាំងមូល អង្គជំនុំជម្រះ និងភាគីបានសួរ-សំណួរដល់ជនជាប់ចោទទាក់ទងទៅនឹងអង្គហេតុគោលចំនួនប្រាំពីរ ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី[៧៧]។

### ១.៦.៥.៣ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ

៥២. វិធានផ្ទៃក្នុងលើកលែងបុគ្គលមួយចំនួនចេញពីលក្ខខណ្ឌតម្រូវនៃការធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួន[៧៨] នៅពេលដែលបុគ្គលទាំងនោះផ្តល់សក្ខីកម្ម។ សក្ខីកម្ម និងសេចក្តីថ្លែង-ការណ៍របស់បុគ្គលទាំងនោះ អាចត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងវាយតម្លៃជាភស្តុតាងនៅពេលសក្ខីកម្ម និងសេចក្តីថ្លែងការណ៍មានភាពពាក់ព័ន្ធ និងមានតម្រុយ។

៥៣. ជាពិសេស បុគ្គលជាច្រើនដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១(ទួលស្លែង) និងស២៤។ ក្របខណ្ឌច្បាប់ អ.វ.ត.ក បែងចែករវាងអ្នកនៅរស់រាន

---

[៧៧] "សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ" ឯកសារ E26 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៩ (ចំណុចទាំងប្រាំពីរនេះមានដូចជា៖ បញ្ហាទាក់ទងទៅនឹងមន្ទីរម១៣ ការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ជម្លោះប្រដាប់អាវុធ ប្រតិបត្តិការរបស់មន្ទីរស២១ (ទួលស្លែង) រួមបញ្ចូលទាំងជើងឯកការបង្កើត និងប្រតិបត្តិការរបស់ស២៤ បញ្ហាទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ)។ ទោះជាយ៉ាងណាក៏ដោយដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យសួរសំណួរទៅកាន់ជនជាប់ចោទ ឬទៅកាន់សាក្សីលើបញ្ហាទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទនោះទេ។ *សូមមើល* សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះនៅក្នុងប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ៥៥ (ចៅក្រម Lavergne ជំទាស់) ។ "សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" ឯកសារE72/3 ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និង ក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩" ឯកសារ E169/1/2 ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។ ។

[៧៨] ត្រូវបានដាក់នៅក្នុងផ្នែកនេះមាន ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី លើកលែងពីការធ្វើដូច្នេះអនុលោមតាមវិធាន២៤(២) នៃវិធានផ្ទៃក្នុង។

មានជីវិត ដែលផ្តល់សក្ខីកម្មជាសាក្សី និងអ្នកនៅរស់រានមានជីវិតដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ បុគ្គលមួយចំនួននោះ ក៏បានផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះផងដែរ។ អនុលោមតាមវិធាន២៣(៦) នៃវិធានផ្ទៃក្នុង ជនរងគ្រោះនឹងក្លាយជាភាគីនៃដំណើរការនីតិវិធី នៅពេលជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ អ្នកនៅរស់រានមានជីវិតមិនអាចត្រូវគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ ហើយត្រូវបានលើកលែងដោយវិធានផ្ទៃក្នុងចេញពីលក្ខខណ្ឌតម្រូវនៃការធ្វើសក្ខីកម្ម ក្រោមសម្បថស្របតាមសាសនា ឬជំនឿ។

៥៤. សាក្សីសរុបចំនួន ២៤នាក់ ក្រោយពីបានធ្វើសម្បថ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលដំណើរការនីតិវិធី[៧៩]។ វិធានការការពារបានផ្តល់ឲ្យសាក្សីនៅក្នុងចំនួនមានកំណត់[៨០]។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២នាក់ បានផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

៥៥. អនុលោមតាមវិធាន៣១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានស្នើសុំមតិយោបល់របស់អ្នកជំនាញលើប្រធានបទជាច្រើនពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី[៨១]។ សក្ខីកម្មរបស់អ្នកជំនាញគឺផ្តោតទៅលើចំណេះដឹងផ្នែកជំនាញ ដែលវាជាជំនាញ ឬចំណេះដឹងដែលទទួលបានតាមរយៈការបណ្តុះបណ្តាល ឬតាមរយៈការស្រាវជ្រាវ ដែលមតិយោបល់របស់អ្នកជំនាញនេះជួយដល់អង្គជំនុំជម្រះឲ្យបានយល់ដឹងអំពីភស្តុតាងនានាដែលបានបង្ហាញ។ អង្គជំនុំជម្រះរក្សានូវការទទួលខុសត្រូវផ្តាច់មុខរបស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចលើបញ្ហាណាមួយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អ្នកជំនាញសរុប

---

[៧៩] វិធាន២៤(២) នៃវិធានផ្ទៃក្នុងមិនរាប់បញ្ចូលសាក្សីមួយចំនួន រួមមាន ឪពុក ម្តាយ និងបុព្វញាតិរបស់ជនត្រូវចោទ ជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់ធ្វើសម្បថ មុនពេលផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

[៨០] *សូមមើល* "សេចក្តីសម្រេចលើសំណើសុំវិធានការការពារ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី E2/62 និង E2/89 និងសាក្សី KW-10 និង KW-24" ឯកសារ E135, ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩។

[៨១] *សូមមើល* "សេចក្តីសម្រេចលើសំណើសុំវិធានការការពារ សម្រាប់សាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សីនិងអ្នកជំនាញ (សំអាងហេតុ)" ឯកសារ E40/1 ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ កថាខណ្ឌ២៦-២៨។ "សេចក្តីសម្រេចលើភារកិច្ចរបស់អ្នកជំនាញ" ឯកសារ E51 (ដាក់ជាឯកសារសម្ងាត់) ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩។

ចំនួន០៩នាក់ បានផ្តល់សក្ខីកម្ម ឬបានដាក់សេចក្តីសន្និដ្ឋាននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងដំណើរការសវនាការទាំងមូល។

### ១.៦.៥.៤ ឯកសារនានា

៥៦. នៅក្នុងដំណើរការសវនាការទាំងមូល ឯកសារប្រមាណជា ១.០០០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលឯកសារទាំងនោះត្រូវបានធ្វើការជេញដោល។

៥៧. តាមវិធានទូទៅ ឯកសារទាំងអស់តម្រូវឲ្យមានជាបីភាសាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ (ភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស) ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ[៨២]។ បើតាមលក្ខខណ្ឌតម្រូវវិធាន៨៧ នៃវិធានផ្ទៃក្នុង មានតែភស្តុតាងមួយចំនួនដែលត្រូវបានអានទាំងស្រុង ឬដោយសង្ខេប ឬត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របក្នុងពេលសវនាការ ហើយដែលភស្តុតាងត្រូវឆ្លងកាត់ការជេញដោល ទើបត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ការអនុវត្តដែលបានបង្កើតឡើងនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីធ្វើឲ្យកិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស ពាក់ព័ន្ធនឹងឯកសារនានាដែលមិនត្រូវបានជំទាស់នោះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុង[៨៣]។

---

[៨២] *សូមមើលផងដែរ* សេចក្តីសម្រេចដែលប្រកាសផ្ទាល់មាត់របស់អង្គជំនុំជម្រះក្នុងប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ទំព័រ២៥-២៧។

[៨៣] នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩ វិសោធនកម្មវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង បានចូលជាធរមាន ដែលបានបញ្ជាក់ថា៖ "ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្រប ក្នុងសវនាការ" (ជាការបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះក្នុងប្រតិចារឹក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៣-៥ (កត់សម្គាល់ថានៅពេលណាដែលការពិភាក្សាលើឯកសារមានវិសាលភាពលើសសេចក្តីសង្ខេបដំបូងរបស់វា ការពិភាក្សាទាំងមូលនឹងមានសម្រាប់អង្គជំនុំជម្រះធ្វើសេចក្តីសម្រេច។ លើសពីនេះ ភាគីមិនចាំបាច់ផ្តល់យោបល់ជាក់លាក់ទៅលើឯកសារ ដើម្បីឲ្យគេយកឯកសារទៅពិភាក្សានោះទេ ដោយសារឯកសារនឹងត្រូវយកទៅពិភាក្សាជេញដោលក្នុងតុលាការ)។

### ១.៦.៦ ការប្រកបឈ្មោះ និងទីកន្លែង

៩៨. ពេលខ្លះ ការប្រកបឈ្មោះមួយចំនួននៅក្នុងប្រតិចារឹក និងនៅក្នុងឯកសារនានា មានភាពខុសប្លែកគ្នាអាស្រ័យតាមកាលៈទេសៈមួយចំនួន ដូចជាទីកន្លែងកំណើតរបស់បុគ្គល ការបញ្ចេញសម្លេងឈ្មោះ ឬការបកប្រែផ្ទាល់មាត់នៃឈ្មោះទាំងនោះជាដើម។ ស្រដៀងគ្នានេះដែរ ការប្រកបឈ្មោះទីកន្លែងមួយចំនួន ពេលខ្លះមានភាពខុសប្លែកគ្នាតាមឯកសារយោងផ្សេងៗ។ អង្គជំនុំជម្រះបានទទួលស្គាល់ថា ទោះបីជាមានការប្រកបឈ្មោះ និងទីកន្លែងស្រដៀងគ្នា ប៉ុន្តែមិនប្រកបដូចគ្នាសុទ្ធសាធនោះទេ ទោះបីជាការប្រកបនេះអាចសំដៅលើបុគ្គលតែមួយ ឬទីកន្លែងតែមួយ។ តាមរយៈការអនុវត្តរបស់ប្រជាជនកម្ពុជាទាក់ទងនឹងការប្រើប្រាស់ឈ្មោះខុសៗគ្នា ព្រមទាំងភាពទូទៅនៃឈ្មោះហៅក្រៅ និងឈ្មោះបដិវត្តដែលស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាពេលនោះ អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា ពេលខ្លះបុគ្គលមួយចំនួន ត្រូវបានគេសំដៅទៅរកគាត់តាមរយៈការហៅឈ្មោះផ្សេងៗគ្នា។

## ២. ផ្នែកសំអាងហេតុ និងសំអាងច្បាប់

### ២.១ បរិបទប្រវត្តិសាស្ត្រ និងជម្លោះប្រដាប់អាវុធ

៩៩. សេចក្តីសង្ខេបអំពីបរិបទប្រវត្តិសាស្ត្រ ដែលក្នុងបរិបទនេះលើកឡើងអំពីរបបកម្ពុជាប្រជាធិប-តេយ្យដែលបានកាន់អំណាចនៅក្នុងប្រទេសកម្ពុជា ចង្អុលបង្ហាញថាស្ទើរតែពេញរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពកម្ពុជា និងកងទ័ពវៀតណាមមានអរិភាពនឹងគ្នាប្រកបដោយហិង្សាកាន់តែខ្លាំងឡើងៗ រហូតដល់មានការវាយលុករបស់កងទ័ពវៀតណាមកាន់តែជ្រៅទៅៗ ការដួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ និងការរត់គេចចេញពីទីក្រុងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ[៨៤]។

---

[៨៤] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ៣៨-៣៩, ៥២-៥៣។

៦០. ជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមកើតចេញពីកត្តាផ្សេងៗគ្នា ដែលកត្តាមួយចំនួនបានកើតឡើងតាំងពីរាប់សតវត្សរ៍មុនឯណោះ។ ការពង្រីកទឹកដីភាគខាងត្បូងវៀតណាម បានចាប់ផ្តើមក្នុងសតវត្សរ៍ទី១៥ ដែលជាផលវិបាកវាបានបង្កជាសត្រូវស្នូរពូជរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ បន្ថែមពីលើកំហឹងជាប្រវត្តិសាស្ត្រនេះ គឺវិវាទទាក់ទងនឹងការកំណត់បន្ទាត់ព្រំដែនដែលបារាំងជាអ្នកគូស។ ជារឿយៗបារាំងតែងតែគូសព្រំដែនលំអៀងទៅខាងប្រទេសវៀតណាម ជាពិសេសខ្សែបន្ទាត់ប្រេវីយេដែលគូសនៅឆ្នាំ១៩៣៩ ជាខ្សែបន្ទាត់ដែនទឹកសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងសណ្តាប់ធ្នាប់។ វិវាទទាំងនេះបានធ្វើឲ្យភាពតានតឹងកាន់តែធ្ងន់ធ្ងរឡើងមួយកម្រិតទៀត[៨៥]។

៦១. ជាពិសេស ជនកុម្មុយនីស្តកម្ពុជា បានបង្កើតភាពជូរចត់ទៅលើប្រទេសវៀតណាមចាប់តាំងពីក្រោយសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលនៅពេលនោះកម្ពុជាបានដឹងថាវៀតណាមដែលជា

[៨៥] ប្រតិចារឹកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ អ្នកជំនាញ Nayan CHANDA ទំព័រ ២៣-២៥, ២៦, ៤១, ៤២, ៤៧, ៥៩-៦២ ។ ប្រតិចារឹកចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ អ្នកជំនាញ Nayan CHANDA ទំព័រ១៨-១៩ ។ អ្នកជំនាញ Nayan CHANDA បានពិពណ៌នាអំពីជម្លោះ ដែលកើតឡើងពីផ្នែកមួយនៃ "ការប្រកាន់ពូជសាសន៍វៀតណាម" ប្រតិចារឹកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ២៦។ សូមមើលផងដែរ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*'" ឯកសារ E3/193, ទំព័រ ៤-៥, ៣៦-៣៧, ៥៦, ៦០-៦២ ERN (ភាសាខ្មែរ) 00191310,00191341-00191343, 00191361-00191362, 00191365-00191367 ហើយជាងនេះទៅទៀតគឺទំព័រ ៥៦-៦៣ ERN (ភាសាខ្មែរ) 00191361-00191367។ "របាយការណ៍រៀបចំតាមសំណើរបស់អនុគណៈកម្មាធិការស្តីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិអាស៊ីនិងប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា មានចំណង ជើងថា '*ជម្លោះវៀតណាម-កម្ពុជា*' ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៧៨" ឯកសារ E3/201, ទំព័រ ២-៣, ៣៧, ERN (ភាសាអង់គ្លេស) 00187381-00187382, 00187396 ។ "ក្រសួងការបរទេសសហរដ្ឋអាមេរិក 'ការសិក្សាពីព្រំប្រទល់អន្តរជាតិ លេខ១៥៥'" រួមទាំងឧបសម្ព័ន្ធ១២៖ ការបកប្រែលិខិតចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ ដោយលោក Brevié (ប្រេវីយេ) បង្កើតបានជាខ្សែបន្ទាត់ Brevié, E3/520 ជាពិសេសនោះ ERN (ភាសាខ្មែរ) 00324915-00324917។ *សូមមើលផងដែរ* "ផែនទីនាវាចរណ៍ធម្មជាតិមាត្រដ្ឋាន1:959,000 នៃឈូងសមុទ្រសៀម ដែលបង្ហាញពីកោះនានាស្ថិតនៅឆ្ងាយពីច្រាំងសមុទ្រទាក់ទងនឹងប្រទេសវៀតណាម កម្ពុជា និង ថៃ" E3/534, សម្រាប់ផែនទីបង្ហាញពីខ្សែបន្ទាត់ប្រេវីយេ និងសៀវភៅដែលមានចំណងជើងថា "សៀវភៅខ្មៅ បោះពុម្ពនៅខែកញ្ញា ឆ្នាំ១៩៧៨" ឯកសារ E3/199 ជំពូក១៖ "សារជាតិវៀតណាមលេបទឹកដីកម្ពុជា" ទំព័រ ៧-១៩ ERN (ភាសាខ្មែរ) 00289650-00289662 សម្រាប់ការរៀបរាប់ពីការ "ការនិយាយប្រឆាំងនឹងវៀតណាម"។

សមភាគីបានក្បត់នឹងខ្លួនហើយ[៨៦]។ អារម្មណ៍បែបនេះកាន់តែធ្ងន់ធ្ងរឡើងៗនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០។ ទោះបីជាវៀតណាម បានជួយខ្មែរក្រហមក្នុងការតស៊ូប្រឆាំងនឹងរបប លន់ នល់ ដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិក និងបានទម្លាក់សម្តេច សីហនុ ចេញពីអំណាចនៅខែមីនា ឆ្នាំ១៩៧០ក៏ដោយ ក៏ភាពតានតឹងនោះបានកើតឡើងសាជាថ្មីបន្ទាប់ពីការចរចានៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៧២-១៩៧៣ រវាងវៀតណាម និងសហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកទាមទារឲ្យខ្មែរក្រហមចូលចរចាជាមួយនឹងរដ្ឋាភិបាល លន់ នល់ ប៉ុន្តែខ្មែរក្រហមបានបដិសេធដោយជឿថាខ្លួនជិតឈានទៅសម្រេចជ័យជម្នះទៅហើយ។ វៀតណាម និងសហរដ្ឋអាមេរិកបានចុះហត្ថលេខាសន្ធិសញ្ញាសន្តិភាពមួយក្នុងឆ្នាំ១៩៧៣ ហើយសហរដ្ឋអាមេរិកបានចាប់ផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា។ ខ្មែរក្រហមចាត់ទុកសន្ធិសញ្ញាសន្តិភាពថា វៀតណាមបានក្បត់នឹងខ្លួន ដែលបណ្តោយឲ្យយន្តហោះអាមេរិកទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់មកលើទឹកដីកម្ពុជា។ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពភ្លាម ខ្មែរក្រហមបានវាយប្រហារទៅលើឃ្លាំងអាវុធ មន្ទីរពេទ្យ និងជំរំកងទ័ព ព្រមទាំងបានសម្លាប់កម្មាភិបាលវៀតណាមនៅក្នុងប្រទេសកម្ពុជា[៨៧]។

៦២. ភាពតានតឹងត្រូវបានធ្វើឲ្យកាន់តែធ្ងន់ធ្ងរទៅៗដោយសារខ្មែរក្រហម និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដែលកាលនោះជឿថាវៀតណាមមានបំណងចាប់បង្ខំ និងគ្រប់គ្រងសហព័ន្ធឥណ្ឌូចិន ដែល

---

[៨៦] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ២៤-២៥, ៦៤។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ៩-១០។ ខុសពីដៃគូវៀតណាម និងឡាវរបស់ខ្លួន ពួកកុម្មុយនីស្តកម្ពុជា ("ខ្មែរឥស្សរៈ") ត្រូវបានផាត់ចេញមិនឲ្យចូលរួមក្នុងការចរចារ។ បន្ថែមលើនេះទៀត ពួកកុម្មុយនីស្តវៀតណាម បានបដិសេធការទាមទាររបស់សហសេរិកខ្លួនចំពោះតំបន់ត្រួតត្រាដោយកុម្មុយនីស្តដោយប្រគល់តំបន់នោះទៅរាជរដ្ឋាភិបាលកម្ពុជាវិញ។ ទីបញ្ចប់ ពួកកុម្មុយនីស្តកម្ពុជាត្រូវបានរំសាយ និងដកហូតអាវុធ។ *សូមមើល* "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*'" ឯកសារ E3/193, ទំព័រ ៥៦-៦៣, ERN (ភាសាខ្មែរ) 00191368-00191370 ។

[៨៧] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ៣៩-៤១, ៦៤-៦៥។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ១៤ ។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*'" ឯកសារ E3/193, ទំព័រ ៥៤, ៧០, ៧៥, ៨០, ERN (ភាសាខ្មែរ) 00191360, 00191376-00191377, 00191380-00191381, 00191385-00191386។

អាចបណ្តាលឲ្យប្រទេសជិតខាងភាគខាងកើត“លេបត្របាក់”ទឹកដីកម្ពុជា[៨៨]។ ចំណែកឯវៀតណាមវិញមានការភ័យខ្លាចការត្រួតត្រាពីសំណាក់ប្រទេសចិន ដែលជាសម្ព័ន្ធមិត្តរបស់ខ្មែរក្រហម។ ដោយស្ថិតនៅក្នុងស្ថានភាពមិនទុកចិត្តគ្នា និងអរិភាពនឹងគ្នានេះហើយ ដែលបណ្តាលឲ្យមានការប៉ះទង្គិចគ្នានៅតាមព្រំដែនកម្ពុជា និងវៀតណាម ដែលកើតឡើងបន្ទាប់ពីកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាវាយបែកភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងកងទ័ពវៀតណាមខាងជើងវាយយកទីក្រុងសាយហ្គន ពីរសប្តាហ៍ក្រោយមក ពោលគឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥[៨៩]។

៦៣. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានសង្ខេបជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមដូចខាងក្រោម៖

> ១៦. ក្រោយពីបានកាន់កាប់ទីក្រុងភ្នំពេញ ដោយកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និងវៀត-ណាមក៏ផ្ទុះឡើងភ្លាមដែរ។ ការប្រឈមមុខដាក់គ្នានេះ បានអូសបន្លាយ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

---

[៨៨] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ២១-២២, ២៤-២៥, ៦១-៦៣។ “លិខិតចុះថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៩ ពីតំណាងកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិ ជូនចំពោះលោកអគ្គលេខាធិការ ឯកសារ E3/528 ERN (ភាសាខ្មែរ) 00234018។ ។ *សូមមើលផងដែរ* ការរៀបរាប់អំពីការយល់ឃើញនេះ និងយុទ្ធនាការដែលពាក់ព័ន្ធនៅក្នុង “សៀវភៅមានចំណងជើងថា ‘*សៀវភៅខ្មៅ*’ បោះពុម្ពក្នុងខែកញ្ញា ឆ្នាំ១៩៧៨” ឯកសារ E3/199, ទំព័រ ១៩-២០, ២៣-២៥, ERN (ភាសាខ្មែរ) 00289662-00289663, 00289666-00289668, ។ “សេចក្តីថ្លែងការណ៍ជាសាធារណៈពីស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប៉េកាំង មានចំណងជើងថា ‘ព័ត៌មានអំពីកម្ពុជាប្រជាធិបតេយ្យ លេខ០០៥’” E3/758។ “សេចក្តីប្រកាសព័ត៌មានរបស់អ្នកនាំពាក្យក្រសួងឃោសនាការ(និងព័ត៌មាន) នៃកម្ពុជាប្រជាធិបតេយ្យ” E3/761។ “របាយការណ៍សារព័ត៌មានអន្តរជាតិ ‘ការប្រមូលផ្តុំនៅក្រុងភ្នំពេញប្រារព្ធពិធីខួប១៧មេសា’” E3/783, ERN (ភាសាអង់គ្លេស) S00010558។

[៨៩] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ២៤-២៦, ៦៤-៦៥។ “សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា ‘*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*’” ឯកសារ E3/193, ទំព័រ ៤-៦, ERN (ភាសាខ្មែរ) 00191310-00191312។

១៧. ជាការពិតណាស់ ទោះបីជាកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទើបបានទទួលស្គាល់ជាផ្លូវការ អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ក៏ដោយ ក៏មានភស្តុតាងបង្ហាញថា អំពើហិង្សាប្រដាប់អាវុធ និងភាពតានតឹងរវាងប្រទេសទាំងពីរបានកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។ សង្គ្រាមបង្ហូរឈាមគ្នានេះត្រូវបានគេសង្កេតឃើញថាបានផ្អាកម្តងម្កាល តែនៅក្នុងអំឡុងពេលមានកិច្ចចរចាសន្តិភាព ឬការផ្លាស់ប្តូរទស្សនកិច្ចការទូត និងវប្បធម៌តែប៉ុណ្ណោះ។ ជាក់ស្តែង កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដែលបានប្តូរឈ្មោះជាកងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពប្រជាជនវៀតណាមបានប្រយុទ្ធគ្នាជាច្រើនលើកច្រើនសា នៅខេត្តរតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កណ្តាល តាកែវ កំពត និងនៅកោះមួយចំនួនដូចជា កោះពូលូវៃ កោះអាចម៍សេះ កោះត្រល់ កោះថ្មី កោះសំពោច កោះរ៉ុង និងកោះមុខរាម ជាដើម។

១៨. ក្រោយពីជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបានឈានដល់កម្រិតតានតឹងបំផុត នៅចុងឆ្នាំ១៩៧៧ ជម្លោះនោះបានឈានទៅដល់សង្គ្រាមមួយពិតប្រាកដ ហើយការប្រយុទ្ធគ្នានៅសមរភូមិបានរំកិលចូលមកយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា ជាហេតុធ្វើឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ លើកយកបញ្ហានេះទៅប្តឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨។ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញ។ គឺចាប់ពីពេលនោះហើយដែលរបបនេះបាត់បង់ការគ្រប់គ្រងទឹកដីកម្ពុជាចំនួនមួយភាគធំ[៩០]។

៦៤. ជនជាប់ចោទមិនបដិសេធចំពោះការអះអាងថា មានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ចាប់តាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។ ដំបូងឡើយ គាត់មិនបានបង្ហាញជំហរយ៉ាងណាចំពោះរយៈពេលមុននេះទេ។ នៅពេលគាត់ផ្តល់សក្ខីកម្មនៅថ្ងៃទី០៩ និងទី១០ ខែមិថុនា ឆ្នាំ២០០៩ គាត់បានទទួលស្គាល់អត្ថិភាពនៃការបន្តជម្លោះប្រដាប់អាវុធរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម ក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា

---

[៩០] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៦-១៨ (ជើងទំព័ររបស់កថាខណ្ឌទាំងនេះ ត្រូវបានលុប) ។

ឆ្នាំ១៩៧៩ ដោយបានអះអាងថាបានដឹងតិចតួចអំពីរឿងនេះនៅពេលនោះ។ នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ក្រុមមេធាវីការពារក្តីបានបញ្ជាក់ឡើងវិញនូវការទទួលស្គាល់របស់ពួកគាត់ថា ចាប់តាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ របបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាមស្ថិតក្នុងជម្លោះប្រដាប់អាវុធ ប៉ុន្តែបានអះអាងថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធមុនឆ្នាំ១៩៧៧ នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ[៩១]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា មានជម្លោះប្រដាប់អាវុធអន្តរជាតិក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[៩២]។

៦៥. ទំនាក់ទំនងរវាងវៀតណាមនិងកម្ពុជានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យអាចចែកជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទី១ គិតចាប់ពីពេលដែលកងទ័ពរំដោះជាតិខ្មែរចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ពេលកម្ពុជាប្រជាធិបតេយ្យផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ និងដំណាក់កាលទី២ គឺចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧[៩៣] រហូតដល់ការដួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរត់គេចចេញពីទីក្រុង។

---

[៩១] ប្រតិចារឹក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៥-៧៩, ៨៤-៨៩ ។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៩, ៧៥-៧៦។ ចំពោះព័ត៌មានលម្អិតស្តីពីការដឹងរបស់ជនជាប់ចោទនៅពេលនោះ *សូមមើលផងដែរ* គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ", ឯកសារ E5/11/6.1 កថាខណ្ឌ២៨(ក-ឃ)។ "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី" ឯកសារ E159/8 កថាខណ្ឌ ២៥-៣៤។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩, (សេចក្តីសន្និដ្ឋានបញ្ចប់របស់មេធាវីការពារក្តី) ទំព័រ ៨០-៨២។

[៩២] "សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ដោយមានឧបសម្ព័ន្ធពី១-៥", ឯកសារ E159/9 កថាខណ្ឌ៤៩-៦១, ២៩៥ ប្រតិចារឹក, ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា, ទំព័រ៤៨-៥០។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានធ្វើសេចក្តីសន្និដ្ឋានណាមួយទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិទេ។

[៩៣] "សេចក្តីប្រកាសតាមវិទ្យុរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ស្តីអំពីការផ្តាច់ទំនាក់ទំនងជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម" ឯកសារ E3/171។ "សេចក្តីប្រកាសរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ E3/756។

## ២.១.១ ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧

៦៦. នៅពេលឈានចូលដល់ខែមេសា ឆ្នាំ១៩៧៥ ជម្លោះទៅលើការកាន់កាប់កោះមួយចំនួននៅក្នុងតំបន់ឆ្នេរសមុទ្រ បានឈានដល់ការប្រឈមមុខគ្នាផ្នែកប្រដាប់អាវុធរវាងកងទ័ពនៃប្រទេសទាំងពីរ។ នៅខែឧសភា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តកម្ពុជាបានកាន់កាប់កោះ ភូហ្គុក (Phu Quoc) (កោះត្រល់) និង ថូ ជុ (Tho Chu) (កោះក្រចក) ដែលធ្វើឲ្យមានការស្លាប់និងរបួសមួយចំនួនមុនពេលដែលកោះទាំងពីរនេះ ត្រូវបានកងទ័ពវៀតណាមដណ្តើមកាន់កាប់វិញក្នុងរយៈពេល២សប្តាហ៍ក្រោយមក។ ការប្រឹងប្រែងកាន់កាប់កោះមួយចំនួន ដែលស្ថិតក្នុងតំបន់ជម្លោះ ជាពិសេសកោះកម្ពុជាឈ្មោះថា ពូលូវៃ (Puolo Wai) ធ្វើឲ្យមានការចាប់កប៉ាល់ដឹកទំនិញអាមេរិកមួយឈ្មោះថា *Mayaguez* នៅជិតកោះនេះដោយកងទ័ពបដិវត្តកម្ពុជា។ កោះពូលូវៃ ត្រូវបានកាន់កាប់ដោយកងទ័ពវៀតណាមនៅខែមិថុនា ឆ្នាំ១៩៧៥ ប៉ុន្តែត្រូវប្រគល់ត្រឡប់ទៅរបបកម្ពុជាប្រជាធិបតេយ្យវិញ ក្នុងរយៈពេលពីរខែក្រោយមក[៩៤]។

៦៧. កងទ័ពវៀតណាមក៏បានវាយឆ្មក់ជាច្រើនដងចូលទៅខេត្តរតនៈគីរី និងមណ្ឌលគីរីនៃប្រទេសកម្ពុជា។ ចាប់តាំងពីខែសីហា ដល់ខែធ្នូ ឆ្នាំ១៩៧៥ កងទ័ពបដិវត្តកម្ពុជាបានធ្វើការវាយលុកចូលទៅទឹកដីវៀតណាមជាច្រើនដង រួមទាំងខេត្ត ហា ទៀន (Ha Tien) តាយ និញ (Tay Ninh) កន្ទុំ (Kontum) និង ដា ឡាក់ (Darlac) ។ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យក៏ជឿថា ពួកគាត់គឺជា

---

[៩៤] ប្រតិចារឹកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ៨-៩, ៤៣-៤៤, ៥៨-៥៩, ៦៣, ៦៥, ។ ប្រតិចារឹកចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ១៧ ។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*'", ឯកសារ E3/193, ERN (ភាសាខ្មែរ) 00191310, 00191314-00191320។ "របាយការណ៍រៀបចំតាមសំណើរបស់ អនុគណៈកម្មាធិការស្តីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ អាស៊ីនិងប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា មានចំណងជើងថា '*ជម្លោះវៀតណាមកម្ពុជា*' ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨", ឯកសារ E3/201, ទំព័រ ១-២ ERN (ភាសាខ្មែរ) 00251353-00251354។ សូមមើលផងដែរ "របាយការណ៍របស់ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម មានចំណងជើងថា *អង្គហេតុ និងឯកសារ ស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម* ចុះខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/526 ទំព័រ ១០, ១៦, ERN (ភាសាខ្មែរ) 00283124-00283132 (សម្រាប់ទស្សនៈវិស័យរបស់វៀតណាម)។

ជនរងគ្រោះនៃរដ្ឋប្រហារ ឬការធ្វើឃាតដែលធ្វើឡើងដោយប្រទេសវៀតណាមដែលមិនបានសម្រេចនោះ[៥៥]។

៦៨. យោងតាមអ្នកជំនាញ Nayan CHANDA មានជនស៊ីវិលវៀតណាមច្រើនជាង ១៥០.០០០ នាក់ ដែលរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានបណ្តេញចេញប្រាំខែបន្ទាប់ពីខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជនជាតិវៀតណាមទាំងនោះ បានរស់នៅបណ្តោះអាសន្ននៅភាគខាងត្បូងនៃប្រទេសវៀតណាម[៥៦]។

៦៩. ឯកសារផ្ទៃក្នុងនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនបានបង្ហាញថា ការប៉ះទង្គិចគ្នានៅតាមព្រំដែនកើតមាននៅគ្រប់ពេលក្នុងឆ្នាំ១៩៧៦ និងថារបបកម្ពុជាប្រជាធិបតេយ្យនៅតែបន្តចាត់ទុកប្រទេសវៀតណាមថាជាសត្រូវនៅពេលនោះ។ ជាពិសេស របាយការណ៍ និងទូរលេខកងទ័ពជាច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យពីដើមឆ្នាំ១៩៧៦ បានរៀបរាប់អំពីព្រឹត្តិការណ៍ការវាយប្រហារ និងការសម្លាប់នៅព្រំដែនទាំងសងខាង ជាពិសេសនៅ ជិតភ្នំពូញ៉ក (អូរ៉េ) នៅខេត្តស្វាយរៀង (ស្រុកចន្ទ្រា) ខេត្តព្រៃវែង (ស្រុកព្រះស្តេច) និងខេត្តមណ្ឌលគីរី (អូររាំង និងដាក់ដាំ) ដោយកងទ័ពវៀតណាម និងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងបានស្នើសុំឲ្យមានការណែនាំខាងផ្នែកកងទ័ព។ នៅចន្លោះខែកុម្ភៈ

[៥៥] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៤៣-៤៣។ "របាយការណ៍រៀបចំតាមសំណើរបស់ អនុគណៈកម្មាធិការស្តីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ អាស៊ី និង ប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភាមានចំណងជើងថា '*ជម្លោះវៀតណាមកម្ពុជា*' ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨", ឯកសារ E3/201, ទំព័រ ១ ERN (ភាសាខ្មែរ) 00251353។ "របាយការណ៍របស់ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម មានចំណងជើងថា *អង្គហេតុ និងឯកសារ ស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម* ចុះខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/526, ទំព័រ ៧, ERN (ភាសាខ្មែរ) 00283124 (សម្រាប់ទស្សនៈវិស័យរបស់វៀតណាម)។ "សៀវភៅមានចំណងជើងថា '*សៀវភៅខ្មៅ* បោះពុម្ពក្នុងខែកញ្ញា ឆ្នាំ១៩៧៨", ឯកសារ E3/199, ERN (ភាសាខ្មែរ) 00289710-00289712។ "ព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ៖ សម្រង់ព័ត៌មានបានផ្សព្វផ្សាយនៅទីក្រុងភ្នំពេញ", ឯកសារ E3/755, ERN (ភាសាខ្មែរ) 00223153។

[៥៦] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ១០-១១, ៤៥។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ២។

និងខែ ឧសភា ឆ្នាំ១៩៧៦ យ៉ាងហោចណាស់មានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្ត កម្ពុជាចំនួនបួន ដែលបានពិភាក្សាអំពីស្ថានភាពនៅតាមព្រំដែន និងការប៉ះទង្គិចជាមួយប្រទេស វៀតណាម ជាពិសេសនៅខេត្តរតនៈគីរី ស្វាយរៀង កណ្ដាល (ក្អមសំណរ) និងមណ្ឌលគីរី (រួមទាំង ដាក់ដាំ) និងបានសម្រេចអំពីវិធានការផ្នែកយោធា ដែលត្រូវអនុវត្តដើម្បីឆ្លើយតបទៅនឹងស្ថានភាព នេះ។ កំណត់ហេតុកិច្ចប្រជុំយោធា និងសុន្ទរកថារបស់លោក អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស នៃរបបកម្ពុជា ប្រជាធិបតេយ្យនៅខែធ្នូ ឆ្នាំ១៩៧៦ ដែលក្នុងនោះគាត់បានបញ្ជាក់ថានឹងមានការវាយ តទល់នឹងការឈ្លានពានណាមួយមកលើកម្ពុជា ក៏បញ្ជាក់នូវការបន្តជម្លោះរវាងកម្ពុជា និងវៀតណាម នៅឆមាសទីពីរក្នុងឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៦ មានការពិភាក្សាមួយចំនួនអំពីព្រំដែន ប៉ុន្តែជាទូទៅគ្មាន ការសម្រេចអ្វីទេ[៩៧]។

[៩៧] ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៧ ។ សូមមើលផងដែរ “សៀវភៅមានចំណងជើងថា ‘*សៀវភៅខ្មៅ* បោះពុម្ពក្នុងខែកញ្ញា ឆ្នាំ១៩៧៨”, ឯកសារ E3/199, “ទូរលេខ កម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា ‘ទូរលេខតាម កូឡាំង ជូនអ៊ុំ ៨៩’ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៦”, ឯកសារ E3/806។ “សេចក្ដីរាយការណ៍កម្ពុជាប្រជាធិបតេយ្យមាន ចំណងជើងថា ‘សេចក្ដីរាយការណ៍ គណៈ អ.ច.ត តំបន់២៣ សូមគោរពជូន គណៈ អ.ច.ត ភូមភាគបូព៌ាទិស’ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦”, ឯកសារ E3/768។ “កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស កុម្មុយនីស្តកម្ពុជា មានចំណងជើងថា ‘កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍’ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦”, ឯកសារ E3/750 ។ “ទូរលេខ កម្ពុជាប្រជាធិបតេយ្យ ដោយ ឈិន មានចំណងជើងថា ‘ជំរាបជូនបង ៨៩ ជាទីស្នេហា’ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦”, ឯកសារ E3/809។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ដោយ យ៉ា មានចំណងជើងថា “ទូលេខលេខ ២៥ ជូនចំពោះបង” ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/791 ។ “សេចក្ដីរាយការណ៍យោធាកម្ពុជាប្រជាធិប-តេយ្យ មានចំណងជើងថា ‘ជូនបង៨៩ ជាទីស្នេហា’ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៦”, ឯកសារ E3/753។ “កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា ‘កំណត់ហេតុអង្គប្រជុំគណៈ អចិន្ត្រៃយ៍’ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦”, ឯកសារ E3/89។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ដោយ ឈូក មានចំណង ជើងថា“ទូរលេខ២១ វិទ្យុ៦៧៦ គោរពជូន ស.ម បង ប៉ុល ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/114 ។ “កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា ‘កំណត់ហេតុអង្គប្រជុំគណៈ អចិន្ត្រៃយ៍’ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦”, ឯកសារ E3/751។ “កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា ‘ពិនិត្យអំពីប្រតិកម្មវៀតណាម ក្នុងអង្គប្រជុំលើកទី៥’ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦”, ឯកសារ E3/752 ERN (ភាសាខ្មែរ) 00000810។ “កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ដោយកងពលលេខ ៩២០ មានចំណងជើងថា ‘ការប្រជុំពេញអង្គរបស់កងពល ៩២០’ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦”,

៧០. អ្នកជំនាញ Nayan CHANDA បានលើកឡើងពីភាពស្ងប់ស្ងាត់មិនមានការប្រយុទ្ធគ្នារវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម នៅក្នុងឆ្នាំ១៩៧៦ ប៉ុន្តែទទួលស្គាល់ថា គាត់មិនបានឃើញឯកសារផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ ដូចជាឯកសារមួយចំនួនដែលត្រូវបានដកស្រង់ខាងលើនោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា ប្រទេសទាំងពីរបានចាប់ផ្តើមអនុវត្តនយោបាយសម្ងាត់ទាក់ទងនឹងជម្លោះ បន្ទាប់ពីប្រទេសទាំងពីរបានផ្តាច់ទំនាក់ទំនងការទូត នៅខែធ្នូ ឆ្នាំ១៩៧៧។ វាហាក់ដូចជាមានមូលហេតុជាច្រើន ដែលបណ្តាលឲ្យប្រទេសទាំងពីរត្រូវរក្សាការសម្ងាត់យ៉ាងដូច្នេះ។ មូលហេតុសំខាន់គឺបណ្តាលមកពីឆន្ទៈនយោបាយចង់ជៀសផុតពីការជ្រៀតជ្រែកពីប្រទេសដទៃ[៥៨]។ អង្គជំនុំជម្រះយល់ឃើញថា ការស្ងប់ស្ងាត់ដែលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ១៩៧៦ គឺមិនមែនដោយសារ

ឯកសារ E3/145។ "កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ដោយកងពលលេខ ៨០១ មានចំណងជើងថា 'កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យរបស់កងពល ៨០១' ចុះថ្ងៃទ១៦ ខែធ្នូ ឆ្នាំ១៩៧៦", ឯកសារ E3/162។ របាយការណ៍ជាពត៌មានអន្តរជាតិចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៨ ដែលបង្ហាញពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ប៉ុល ពត ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨ ឯកសារលេខ E3/200 ERN (ភាសាខ្មែរ) 00224837-00224838។ "របាយការណ៍រៀបចំតាមសំណើររបស់អនុគណៈកម្មាធិការស្តីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ អាស៊ី និង ប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា មានចំណងជើងថា '*ជម្លោះវៀតណាមកម្ពុជា*' ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨", ឯកសារ E3/201, ទំព័រ ១-២, ERN (ភាសាខ្មែរ) 00251353-00251354។ *សូមមើលផងដែរ* "របាយការណ៍របស់ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម មានចំណងជើងថា '*អង្គហេតុ និងឯកសារស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម*' ចុះខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/526, ទំព័រ ៨, ១៨-១៩,២០-២១, ERN (ភាសាខ្មែរ), 00283125, 00283135-00283136, 00283137-00283138 (សម្រាប់ទស្សនវិស័យរបស់វៀតណាម) ។

[៥៨] ប្រតិចារឹកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ២១, ៧១, ៧៣, ៧៤, ៩០-៩១, ១០៥-១១០។ ប្រតិចារឹកចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ៦-៧ ។ ប្រតិចារឹកថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ១៧-១៨, ៩៩-១០០ ។ សៀវភៅនិពន្ធដោយ Nayan CHANDA ដែលមានចំណងជើងថា "សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម E3/193 ទំព័រ ៥-៦ ។ ប្រតិចារឹកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ១៦-១៧, ៥២, ៥៤-៥៥, ៦៦-៦៧, ៧៧-៧៩, ៨០-៨១។ ប្រតិចារឹកចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ០៤-០៥។ ប្រតិចារឹកថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១២-១៤, ៦៤-៦៥។ សៀវភៅនិពន្ធដោយ Nayan CHANDA ដែលមានចំណងជើងថា "សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម" E3/193 ទំព័រ៩៣, ១០២-១០៣, ២២៣-២២៤, ៣៥៤-៣៥៥, ERN (ភាសាខ្មែរ) 00191398, 00191407-00191408, 00191528-00191529, 00191659-00191660 ។

តែការបញ្ចប់អរិភាពនោះទេ ប៉ុន្តែដោយសារការបិទបាំងជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម នៅពេលនោះតែប៉ុណ្ណោះ។

៧១. អត្ថិភាពនៃជម្លោះរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម នៅឆ្នាំ១៩៧៦ ក៏ត្រូវបានបញ្ជាក់តាមរយៈវត្តមានអ្នកទោសជនជាតិវៀតណាមនៅមន្ទីរស២១ កាលពីដើមឆ្នាំនោះដែរ។ ជនជាប់ចោទមិនបានបដិសេធចំពោះការលើកឡើងថា កំណត់ត្រាដំបូងនៃអ្នកទោសនៅមន្ទីរស២១ ដែលជា "ជនជាតិវៀតណាម" មានតាំងពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ មកម្ល៉េះ។ គាត់ក៏បានទទួលស្គាល់ថា អ្នកទោសជនជាតិវៀតណាមត្រូវបានបញ្ជូនទៅមន្ទីរស២១ នៅចុងឆ្នាំ១៩៧៥ ហើយចំនួនអ្នកទោសវៀតណាមបានកើនឡើងរហូតដល់ចំនួន៣៤៥នាក់ គិតត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជាពិសេសនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលជម្លោះជាមួយប្រទេសវៀតណាមកាន់តែរីកធំឡើង។ អ្នកទោសជនជាតិវៀតណាមទាំងអស់នៅមន្ទីរស-២១ ត្រូវបានបែងចែកជាបីប្រភេទ (ទាហាន គិញ និងជនស៊ីវិល) ដែលទទួលរងការសួរចម្លើយ ពេលខ្លះមានការធ្វើទារុណកម្ម និងចុងក្រោយត្រូវរងការសម្លាប់ទាំងអស់គ្នា[៩៩]។

៧២. ចាប់ពីខែមករា ឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានបង្កើនការវាយឆ្មក់ចូលទៅក្នុងទឹកដីប្រទេសវៀតណាម ប៉ុន្តែគ្មានការផ្សព្វផ្សាយអំពីការវាយឆ្មក់នោះក្នុងប្រទេសណាមួយនោះទេ។ កម្ពុជាប្រជាធិបតេយ្យក៏បានរៀបចំកងកម្លាំងនៅទិសបូព៌ានៃផ្ទៃប្រទេស ដើម្បីវាយប្រហារទៅលើប្រទេសវៀតណាមផងដែរ[១០០]។

---

[៩៩] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ), ទំព័រ ៧២, ៨៦-៨៧ ។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ), ទំព័រ ២, ៣, ៥-១៩។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ", ឯកសារ E5/11/6.1 កថាខណ្ឌ ១០៨ (ក, ខ, គ)។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង), ទំព័រ ៧២-៧៣។ "ឧបសម្ព័ន្ធ២៧៖ អ្នកទោសវៀតណាមចូលមន្ទីរស២១" ឯកសារ E68.27។ "ឧបសម្ព័ន្ធ ៣០៖ អ្នកទោសស២១ដែលត្រូវបានបញ្ជាក់អត្តសញ្ញាណថាជាជនជាតិវៀតណាម", ឯកសារ E68.30 ។

[១០០] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ១៣, ៩១-៩៤, ១០៧-១០៨។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា 'សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម'", ទំព័រ ៨៧ ឯកសារ E3/193, ERN (ភាសាខ្មែរ) 00191402-00191403។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ១៦-១៨, ៩៩-១០០។ "សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា

៧៣. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ កងទ័ពបដិវត្តន៍កម្ពុជាបានផ្តួចផ្តើមការវាយប្រហារទ្រង់ទ្រាយធំមួយទៅលើទីប្រជុំជនវៀតណាមនៅ ទិញ បៀន (Tinh Bien) និងភូមិមួយចំនួននៅក្នុងខេត្ត អាន យ៉ាង (An Giang) នៅតាមដងទន្លេមេគង្គ ដោយបានសម្លាប់ជនស៊ីវិលជាច្រើននាក់។ ការឈ្លានពាននេះ បានបន្តរហូតច្រើនខែក្រោយមកទៀត។ បន្ទាប់ពីការទម្លាក់គ្រាប់បែករបស់វៀតណាមមកលើប្រទេសកម្ពុជា ដែលបានចាប់ផ្តើមនៅខែឧសភា ឆ្នាំ១៩៧៧ ដោយគ្មានការផ្សព្វផ្សាយ និងការព្យាយាមចរចារកសន្តិភាពមិនបានសម្រេចនៅខែមិថុនា ឆ្នាំ១៩៧៧ របបកម្ពុជាប្រជាធិបតេយ្យក៏បានបើកការវាយប្រហារធំទីពីរ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៧ នៅខេត្ត តាយ និញ ដោយបានសម្លាប់ជនស៊ីវិលរាប់រយនាក់[១០១]។

---

*សំឡេងពីមន្ទីរស២១ - ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ប៉ុល ពត*", ឯកសារ E3/427, ERN (ភាសាខ្មែរ) 00191897-00191897 ។ សូមមើលផងដែរ "របាយការណ៍របស់ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម មានចំណងជើងថា អង្គហេតុ និងឯកសារ ស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចុះខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/526, ERN (ភាសាខ្មែរ) 00283138-00283139 (សម្រាប់ទស្សនវិស័យ របស់វៀតណាម)។

[១០១] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ១១-១៨, ៤១, ៤៣-៤៤, ៤៦។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ១៨-១៩។"សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ៩៧-៩៨, ១០២-១០៤, ២១៣-២១៤, ២១៩-២២១, ២២៥-២២៦, ២២៨ (ភាសាខ្មែរ) 00191402-00191403, 00191407-00191409, 00191518-00191519, 00191524-00191526, 00191530-00191531, 00191533។ "របាយការណ៍រៀបចំតាមសំណើរបស់អនុគណៈកម្មាធិការស្តីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ អាស៊ី និងប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា មានចំណងជើងថា '*ជម្លោះវៀតណាមកម្ពុជា*' ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៧៨", ឯកសារ E3/201, ទំព័រ ១-៤, ERN (ភាសាខ្មែរ) 00251353-00251356។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យ ដោយ ឈាន មានចំណងជើងថា 'ទូរលេខ ៤៦ - ខ្ទង់ ៦០០- បង ជាទីគោរពស្នេហា' ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧", ឯកសារ E3/818។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យដោយ ឈាន មានចំណងជើងថា 'ទូរលេខ ៦២ - ខ្ទង់ ១៤៧៤ - គោរពជូន ម-៨១ ជាទីគោរពស្នេហា' ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៧", ឯកសារ E3/824។ ។ របាយការណ៍របស់ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម មានចំណងជើងថា *អង្គហេតុ និងឯកសារ ស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម*' ចុះខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/526, ERN (ភាសាខ្មែរ) 00283128-00283129, 00283138-00283140 (សម្រាប់ទស្សនវិស័យរបស់វៀតណាម)។

៧៤. កងទ័ពវៀតណាមបានសងសឹកនៅខែតុលា និងវិច្ឆិកា ឆ្នាំ១៩៧៧ ដោយធ្វើការវាយប្រហារផ្នែកកងទ័ពដ៏ធំមួយមកលើខេត្តស្វាយរៀងប្រទេសកម្ពុជា ដោយគ្មានការផ្សព្វផ្សាយ ដែលក្នុងការវាយប្រហារនោះមានការបាត់បង់ជីវិតកងទ័ពបដិវត្តកម្ពុជាមួយចំនួនតូច។ វៀតណាមក៏បានធ្វើការវាយប្រហារទ្រង់ទ្រាយធំមួយទៀតនៅខែធ្នូ ឆ្នាំ១៩៧៧ នៅចំណុចជាច្រើននៅតាមព្រំដែន ជាពិសេសនៅខេត្តកំពង់ចាម ស្វាយរៀង និងតាកែវ ហើយបានធ្វើឲ្យកងទ័ពកម្ពុជាប្រជាធិបតេយ្យបរាជ័យយ៉ាងធ្ងន់ធ្ងរ[១០២]។

២.១.២ ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩

៧៥. កម្ពុជាប្រជាធិបតេយ្យ និងវៀតណាមមិនបានបដិសេធចំពោះអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិពីដំណាច់ខែធ្នូ ឆ្នាំ ១៩៧៧ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នោះទេ[១០៣]។

---

[១០២] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ១៩-២១, ៤៤, ១០៦ ។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*'", ឯកសារ E3/193, ERN (ភាសាខ្មែរ) 00191528-00191529, 00191539-00191541។ "របាយការណ៍រៀបចំតាមសំណើរបស់អនុគណៈកម្មាធិការស្ដីពីគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ អាស៊ី និងប៉ាស៊ីហ្វិក ដោយអង្គភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា មានចំណងជើងថា '*ជម្លោះវៀតណាមកម្ពុជា*' ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៧៨", ឯកសារ E3/201,ERN (ភាសាខ្មែរ) 00251355-00251356។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យដោយ ឌុន មានចំណងជើងថា 'ទូរលេខ៥៦ - ខ្ទង់៣៤៨ - គោរពជូន ម៨៧០ ជាទីគោរពស្នេហា' ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧", ឯកសារ E3/834។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យដោយ ឌុន មានចំណងជើងថា 'ទូរលេខ៥៤ - ខ្ទង់ ៦៤២ - គោរពជូន ម៨៧០ ជាទីគោរពស្នេហា និងរលឹក' ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧", ឯកសារ E3/835។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យដោយ ឌុន មានចំណងជើងថា 'សេចក្ដីរាយការណ៍ សូមគោរព បងជាទីគោរព សូមជ្រាប សភាពការណ៍ខ្លាំងតាមផ្លូវលេខ២២-៧' ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧", E3/858។ "ទូរលេខកម្ពុជាប្រជាធិបតេយ្យដោយ ឌុន មានចំណងជើងថា 'ទូរលេខ ៩០៖ គោរពជូន ម៨៧០ ជាទីស្នេហា អំពីសភាពការណ៍ខ្លាំងនៅសមរភូមិ ផ្លូវលេខ២២' ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧", ឯកសារ E3/849។

[១០៣] "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ", ឯកសារ E5/11/6.1 កថាខណ្ឌ ២៨។

៧៦. នៅដំណាច់ខែធ្នូ ឆ្នាំ១៩៧៧ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានសម្រេចធ្វើការផ្សព្វផ្សាយពីសង្គ្រាមនេះ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ បន្ទាប់ពីការថ្លែងសុន្ទរកថារបស់លោក ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ បរិហារការឈ្លានពានរបស់វៀតណាម លោក អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីថ្លែង-ការណ៍មួយកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ហើយកងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា[១០៤]។

៧៧. នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ប៉ុល ពត បានបង្ហាញអំពីការវៀតណាមដកកងទ័ពចេញថាជា "ជោគជ័យដ៏ធំ" មួយលើកងទ័ពវៀតណាម និងបានចាប់ផ្តើមផ្សព្វផ្សាយចម្លើយសារភាពរបស់អ្នកទោសវៀតណាមនៅមន្ទីរស២១ ក្នុងគោលបំណងឃោសនា[១០៥]។

---

[១០៤] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ៤៤, ៤៧, ៤៩-៥០ ។ ប្រតិចារឹក ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER), ទំព័រ១០០។ "សេចក្តីរាយការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ", ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧, ឯកសារ E3/756។ "សេចក្តីថ្លែងការណ៍ក្រសួងការបរទេសស្តីពីការផ្តាច់ទំនាក់ទំនងជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម", ឯកសារ E3/171។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ERN (ភាសាខ្មែរ) 00191540-00191542, 00191548-00191549, 00191645។

[១០៥] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ), ទំព័រ៣, ៧-៨។ "សុន្ទរកថារបស់ ប៉ុល ពត មានចំណងជើងថា 'កងទ័ពបដិវត្តន៍កម្ពុជាដ៏ក្លាហាន និងខ្លាំងក្លា ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា' ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/757, ERN (ភាសាខ្មែរ) 00324824-00324825។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ២៤២-២៤៣ ។ ចម្លើយសារភាពរបស់អ្នកទោសជនជាតិវៀតណាមជាច្រើន ចាក់ផ្សាយនៅរវាងខែមករា និងខែធ្នូ ឆ្នាំ១៩៧៨ មាននៅក្នុងឯកសារជាច្រើន ចាប់ពីលេខ E3/665 ដល់ E3/747 *សូមមើល ឧទាហរណ៍* "ការចាក់ផ្សាយតាមវិទ្យុនៃចម្លើយសារភាពរបស់ SRV Lt. Tran Van Hay ដែលត្រូវបានធ្វើប្រតិចារឹកនៅក្នុង សេវាផ្សព្វផ្សាយព័ត៌មានបរទេស (កម្ពុជា), ផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៨", ឯកសារ E3/665។ "ការចាក់ផ្សាយតាមវិទ្យុនៃចម្លើយសារភាពរបស់ 'គិញ' វៀតណាម, អតីតអនុសេនីយ៍ត្រី ត្រាន ង៉ុក ទួង (Tran Ngoc Tuong) ត្រូវបានរាយការណ៍ក្នុងចំណោមសេចក្តីរាយការណ៍ព័ត៌មានបរទេសជាច្រើនទៀតនៅក្នុងសារព័ត៌មាន BBC SWB (ទំនាក់ទំនងចុងបូព៌ា), ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៨", ឯកសារ E3/716។ "ការចាក់ផ្សាយតាមវិទ្យុនៃចម្លើយសារភាពរបស់ស្ត្រីវៀតណាម 'គិញ' Le Thi Vinh

៧៨. ចាប់តាំងពីខែមករា ឆ្នាំ១៩៧៨ មានសកម្មភាពបោសសម្អាតនៅភូមិភាគបូព៌ា ហើយការប៉ះទង្គិចនៅតាមព្រំដែនក៏នៅបន្តមានក្នុងឆ្នាំនោះដែរ។ ជាពិសេស នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៨ កងទ័ពបដិវត្តកម្ពុជាបានបើកការវាយប្រហារយ៉ាងឃោរឃៅមួយនៅតំបន់ ចូវ ដុក (Chau Doc) ដែលបណ្ដាលឲ្យជនស៊ីវិលវៀតណាមជាច្រើនស្លាប់ និងរងរបួស។ នៅខែមេសា ឆ្នាំ១៩៧៨ វិទ្យុភ្នំពេញបានផ្សាយការដកស្រង់ពីសេចក្ដីសម្រេចដែលត្រូវបានអនុម័តនៅក្នុងការ "ជួបប្រជុំធំនៅភ្នំពេញ" ដែលក្នុងនោះអ្នកចូលរួមមានទាំងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ "បានប្ដេជ្ញាដាច់ខាត" ក្នុងការអនុវត្តការងារមួយចំនួន ក្នុងចំណោមការងារនានា ដូចជា "សម្លាប់បំផុតពូជភ្នាក់ងារអ្នកវាតទីនិយម បរិវារ និងជន-ឈ្លានពានវៀតណាមឲ្យអស់ចេញពីអង្គភាព និងទឹកដីកម្ពុជាជារៀងរហូត" ។ គោលនយោបាយនេះត្រូវបានបញ្ជាក់សារជាថ្មីនៅខែឧសភា ឆ្នាំ១៩៧៨ ដែលនៅពេលនោះ មានការអំពាវនាវតាមវិទ្យុភ្នំពេញឲ្យកងទ័ពកម្ពុជាសម្លាប់ប្រជាជនវៀតណាមទាំងអស់[១០៦]។

---

Sang ត្រូវបានរាយការណ៍ក្នុងចំណោម សេចក្ដីរាយការណ៍ព័ត៌មានបរទេសជាច្រើនទៀតនៅក្នុងសារព័ត៌មាន BBC SWB (ទំនាក់ទំនងចុងបូព៌ា), ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៨", ឯកសារ E3/746។

[១០៦] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ១៦-១៨, ២២, ២៦-២៧, ៦៦។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ២៤៣-២៤៥,២៥១-២៥៥, ២៨៧ ERN (ភាសាខ្មែរ) 00191548-00191550, 000191556-00191560, 00191592។ "ការចាក់ផ្សាយមានចំណងជើងថា 'ការប្រមូលផ្ដុំនៅទីក្រុងភ្នំពេញប្រារព្ធខួប១៧មេសា' ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨", ឯកសារ E3/783, ERN (ភាសាខ្មែរ) S00249989-S00249990។ "សេចក្ដីរាយការណ៍អំពីយុទ្ធសាស្ត្រការពាររបស់កម្ពុជាប្រឆាំងនឹងវៀតណាម ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨", រួមទាំងការចាក់ផ្សាយនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨, ឯកសារ E3/198, ERN (ភាសាខ្មែរ) 00225462-00225463។ *សូមមើលផងដែរ ការរៀបរាប់របស់អ្នកជំនាញ* Nayan CHANDA *អំពីដំណើរជីវិតរបស់ រស់ សារឿន ដែលបានរកឃើញការណែនាំអំពីកងពលលេខ* "870" ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ យ៉ាងហោចណាស់មានលេខាស្រុកកម្ពុជាប្រជាធិបតេយ្យម្នាក់ស្នើគាត់ឲ្យប្រគល់ជនជាតិវៀតណាម និង ខ្មែរដែលមានជាប់សាច់ឈាមវៀតណាមទាំងអស់នៅក្នុងស្រុកនោះទៅឲ្យ ផ្នែកសន្តិសុខរដ្ឋ និងការសន្និដ្ឋានរបស់គាត់ថា នេះគឺជាការចាប់ផ្ដើមនៃយុទ្ធនាការណ៍មួយដើម្បីសម្លាប់ជនជាតិវៀតណាមទាំងអស់ (ប្រតិចារឹកចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ ៦៦-៦៧, ១០៧-១០៨។ ("សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ៨៦-៨៧, ២១២-២១៣ ERN (ភាសាខ្មែរ) 00191401-00191402, 00191517-00191518។

៧៩. នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្តើមទម្លាក់គ្រាប់បែកក្នុងប្រទេសកម្ពុជា ហើយនៅខែកញ្ញា ឆ្នាំ១៩៧៨ បានចាប់ផ្តើមត្រៀមធ្វើការវាយប្រហារធំមួយដោយបានដាក់កងទ័ព និងកាំភ្លើងធំនៅតាមព្រំដែន។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលប្តេជ្ញាផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅពេលនោះ[១០៧]។

៨០. កងទ័ពវៀតណាមបានបើកការវាយប្រហារទ្រង់ទ្រាយធំមួយមកលើកម្ពុជានៅចុងខែធ្នូ ឆ្នាំ១៩៧៨។ បើទោះជាមានការទប់ទល់យ៉ាងស្វិតស្វាញដោយកងទ័ពបដិវត្តកម្ពុជាក៏ដោយ ក៏កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានវាយចូលមកក្នុងប្រទេសកម្ពុជា ហើយក្នុងរយៈពេលតែពីរ ឬបីថ្ងៃប៉ុណ្ណោះបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[១០៨]។

[១០៧] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ៤៨-៤៩។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ៣៥៤-៣៥៥, ៣៧១-៣៧៣, ៣៧៧-៣៧៨ ERN (ភាសាខ្មែរ) 00191659-00191660, 00191676-00191678, 00191682-00191683។ "សៀវភៅមានចំណងជើងថា '*ជម្លោះរវាងកម្ពុជា-វៀតណាម (កំណត់ត្រាប្រវត្តិសាស្ត្រ)*' កាលបរិច្ឆេទឆ្នាំ១៩៧៩", ឯកសារ E3/522, ERN (ភាសាខ្មែរ) 00239678-00239679។

[១០៨] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ៤៨, ៥២។ "សៀវភៅនិពន្ធដោយ Nayan CHANDA មានចំណងជើងថា '*សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម*", ឯកសារ E3/193, ទំព័រ ៣៧៩-៣៨០, ៣៨១-៣៨២,៣៨៣-៣៨៥ ERN (ភាសាខ្មែរ) 00191684-00191685, 00191686-00191687 ("កងពលប្រាំបួនក្នុងចំណោមកងពលធំទាំងដប់ពីររបស់វៀតណាមដែលគាំទ្រដោយកងទ័ពរណសិរ្សបីកងវរសេនាធំទៀត បានហ៊ុមព័ទ្ធទីក្រុងភ្នំពេញពីទិសអាគ្នេយ៍ និងទិសខាងជើង") ERN (ភាសាខ្មែរ) 00191688-00191690។ សូមមើលផងដែរ "ទូរលេខថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ របស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យផ្ញើរជូនទៅប្រធានក្រុមប្រឹក្សាសន្តិសុខ (UN S/13001)", ឯកសារ E3/785។ "សារទូរលេខចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩ របស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ផ្ញើរជូនប្រធានក្រុមប្រឹក្សាសន្តិសុខ", ឯកសារ E3/209។ ប្រតិចារឹក ចុះថ្ងៃ ទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ៤៨, ៥២។

៨១. ក្នុងពេលដែលកម្ពុជាប្រជាធិបតេយ្យមានជម្លោះជាមួយវៀតណាម កម្ពុជាក៏មានការប៉ះទង្គិចដោយអាវុធនៅតាមព្រំដែនជាមួយប្រទេសថៃផងដែរ។ ការប៉ះទង្គិចរយៈពេលខ្លីទាំងនេះមានកម្រិតទាបជាងច្រើនណាស់ បើប្រៀបធៀបទៅនឹងជម្លោះរវាងប្រទេសវៀតណាម និងកម្ពុជា[១០៩] ។

## ២.២ សេចក្តីសង្ខេបអំពីរយៈកាលកម្ពុជាប្រជាធិបតេយ្យ

៨២. ជនជាប់ចោទបានបញ្ជាក់ថា គាត់យល់ស្រប ឬមិនតវ៉ា[១១០] ទៅនឹងខ្លឹមសារនៅក្នុងកថាខណ្ឌ ១០ដល់ កថាខណ្ឌ១៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដែលកថាខណ្ឌទាំងនេះលើកឡើងអំពីសេចក្តីសង្ខេបនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យដូចតទៅៈ

> ១០. នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា បានចូលដល់ទីក្រុងភ្នំពេញ និងបានដណ្តើមកាន់កាប់អំណាចទាំងស្រុងនៅកម្ពុជា។ ជាមួយនឹងការបញ្ចប់សង្គ្រាមស៊ីវិលប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយមួយឆ្ពោះទៅ "*... ដំណាក់កាលបន្ទាប់នៃការកសាងបដិវត្តន៍សង្គមនិយម*"។ ក្នុងអំឡុងបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ បក្សកុម្មុយនីស្តកម្ពុជាបានប្រើអំណាចយ៉ាងមានប្រសិទ្ធភាពទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានដាក់ចេញនូវគោលនយោបាយ "*បំបែកចេញទាំងស្រុង*" នៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់របបសាធារណរដ្ឋខ្មែរ ហើយបង្កើតនូវ "*អំណាចរដ្ឋបដិវត្តន៍ថ្មីមួយ*"។
>
> ១១. អ្នកប្រវត្តិសាស្ត្រ និងអ្នកជំនាញ បានឯកភាពថា កម្មវិធីនយោបាយនេះត្រូវបានអនុវត្តតាមរយៈមធ្យោបាយមួយចំនួន ដែលរួមមានការជម្លៀសដោយបង្ខំ

[១០៩] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ២៦-២៧, ៧៣, ។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA), ទំព័រ ២៤ ។

[១១០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤១-៤២ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១០-២៧។

អ្នករស់នៅទីក្រុងភ្នំពេញ និងអតីតកងកម្លាំងដ៏រឹងមាំរបស់របបសាធារណរដ្ឋខ្មែរ ឱ្យទៅតាមជនបទ ការបង្កើតសហករណ៍ ក្រោមការគ្រប់គ្រងរបស់បក្សក្នុងគោលបំណងដើម្បីបង្កើនផលិតផលស្បៀង ហើយដែលនៅទីនោះប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការក្នុងស្ថានភាពលំបាកក្រៃលែង និងការលុបបំបាត់មន្ត្រី និងអ្នកគាំទ្ររបបចាស់។

គោលនយោបាយជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមានគោលដៅប្រែក្លាយ "*ប្រជាជនថ្មី*" ឱ្យទៅជាកសិករ។ "*ប្រជាជនថ្មី*" ទាំងនេះភាគច្រើនជាអ្នករស់នៅទីក្រុង ព្រមទាំងកសិករដែលរស់នៅក្រោមរបប លន់ នល់ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ខុសពី "*ប្រជាជនចាស់*" ឬ "*ប្រជាជនមូលដ្ឋាន*" ដែលភាគច្រើនជាកសិករស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលនៃរបបសាធារណរដ្ឋខ្មែរ។

១២. ការសម្លាប់ក្រៅច្បាប់ដែលមានចរិតលក្ខណៈនយោបាយបានកើតឡើងតាំងពីដំបូង ដោយអង្គភាពយោធា។ បន្ទាប់មកការសម្លាប់ទាំងនេះបានបន្តអនុវត្តនៅតាមមន្ទីរសន្តិសុខនានានៅទូទាំងប្រទេស។ ការសម្លាប់បែបនេះត្រូវបានគេប្រមើលឃើញទុកជាមុនរួចហើយ៖ ជាក់ស្តែង នាខែកុម្ភៈ ក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំ "មហាសន្និបាតជាតិរបស់រណសិរ្សរួបរួមជាតិកម្ពុជា" ហើយនៅពេលនោះ បានប្រកាសជាឱឡារិកតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួនថា "*ពួកមហាក្បត់*" ទាំង៧រូប របស់សាធារណរដ្ឋខ្មែរ នឹងត្រូវប្រហារជីវិតភ្លាមៗក្រោយថ្ងៃរំដោះពីបទក្បត់ជាតិ។

រដ្ឋាភិបាលនេះក៏បានប្រកាសអំពីជំហររបស់ខ្លួន ចំពោះមន្ត្រីថ្នាក់ទាបនៃរបបសាធារណរដ្ឋខ្មែរថា ពួកគេនឹងត្រូវបានកងកម្លាំងបដិវត្តន៍ស្វាគមន៍ "*ប្រសិនបើពួកគេឈប់បម្រើពួកក្បត់ទាំង៧នាក់ និងឈប់បន្តសហការជាមួយពួកទាំងនោះ*"។ ការប្រកាសដូច្នេះមានន័យថា មន្ត្រីណាដែលមិនទាន់បានចូលមកខាងពួកកុម្មុយនីស្ត ពួកគេនឹងត្រូវបានសម្លាប់ដូចអ្នកទាំងអស់នោះផងដែរ។ តាមការពិត នេះបានបង្ហាញថា អង្គការសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាមន្ទីរម១៣ ដែល ឌុច ជាប្រធានជាដើម បានធ្វើការប្រហារជីវិតមនុស្សចាប់តាំងពីដើមទស្សវត្សរ៍ឆ្នាំ៧០

រហូតមក។ ទង្វើទាំងអស់នេះបានបញ្ជាក់ច្បាស់ថា គោលនយោបាយសម្លាប់មនុស្ស ដែលបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថាជា "ខ្មាំង" បដិវត្តន៍នោះ មានតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។

១៣. បក្សកុម្មុយនីស្តកម្ពុជាបានបំផ្លាញរចនាសម្ព័ន្ធច្បាប់ និងតុលាការនៃរបបសាធារណរដ្ឋខ្មែរ។ ទោះបីជាការពិតថា កម្ពុជាប្រជាធិបតេយ្យបានអនុម័តរដ្ឋធម្មនុញ្ញមួយនាខែមករា ឆ្នាំ១៩៧៦ ក៏ដោយ ក៏ជំពូក ៧ នៃរដ្ឋធម្មនុញ្ញនេះ ដែលមានចំណងជើង *"អំពីតុលាការ"* បានបង្ហាញបញ្ហាជាអាទិភាពរបស់បក្សកុម្មុយនីស្តកម្ពុជាគឺ *"ការការពារប្រទេសពីរាល់សកម្មភាពរបស់ប្រជាជនដែលប្រឆាំងនឹងរដ្ឋ"*។ មាត្រា១០វិញ ចែងដោយមិនមានការបញ្ជាក់ឲ្យបានច្បាស់ថា *"ការផ្តន្ទាទោសកម្រិតខ្ពស់បំផុត"* ចំពោះ *"ប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញ ដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន"* [១១១] និងចែងទៀតថា *"ចំពោះប្រភេទបទល្មើសផ្សេងៗទៀត[...] ត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន"*។

ចំណែកឯ *"តុលាការប្រជាជន"* ដែលមានចែងនៅក្នុងមាត្រា៩ ដើម្បី *"តំណាង និងការពារយុត្តិធម៌របស់ប្រជាជន"* និង *"ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន"* វិញ គ្មានភស្តុតាងណាមួយបានបង្ហាញថា តុលាការនេះធ្លាប់ត្រូវបានបង្កើតឲ្យមានឡើយ។ ទោះបីជាសភាតំណាងប្រជាជន ដែលទំនងជាត្រូវបានបោះឆ្នោតជ្រើសតាំងនោះបានប្រជុំតែមួយលើកគត់ ហើយដែលត្រូវបានផ្តល់អំណាចឲ្យបង្កើតគណៈកម្មាធិការតុលាការក្នុងខែមេសា ឆ្នាំ១៩៧៦ ក៏ដោយ ក៏មិនមានភស្តុតាងណាមួយបានបង្ហាញថា មានការអនុវត្តតាមមាត្រា៩ នៃរដ្ឋធម្មនុញ្ញម្តងណាឡើយ។ នេះបង្ហាញឲ្យឃើញថា ទោសដែលមានចែងនៅក្នុងមាត្រា១០ ត្រូវបានយកមកអនុវត្តដោយរំលោភបំពាន។ បន្ថែមពីលើចំណុចនេះ គ្មានភស្តុតាងណាមួយបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតឲ្យមានបទប្បញ្ញត្តិ ដែលចាំបាច់

---

[១១១] អង្គជំនុំជម្រះកត់សម្គាល់ថា ភាសានេះមិនស៊ីសង្វាក់គ្នានឹងការបកប្រែជាភាសាអង់គ្លេសនៃ "រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ" នោះទេ ឯកសារ E3/27 ត្រង់ ERN 00089847 ដែលចែងថា៖ "សកម្មភាពប្រឆាំងហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសកំរិតខ្ពស់បំផុត"។

សម្រាប់ល្មើយសឹក ឬជនស៊ីវិល ឬយន្តការផ្លូវច្បាប់ណាមួយសម្រាប់តវ៉ានឹងការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ទោសទៅលើអ្នកទាំងនោះទេ។

១៤. ស្ថាប័នតុលាការរបស់សាធារណរដ្ឋខ្មែរត្រូវបានជំនួសដោយមន្ទីរអប់រំកែប្រែកន្លែងសួរចម្លើយ និងមន្ទីរសន្តិសុខសម្រាប់ឃុំខ្លួន និងប្រហារជីវិតអតីតរដ្ឋការ និងអ្នកគាំទ្ររបបសាធារណរដ្ឋខ្មែរ ព្រមទាំងមនុស្សឯទៀតដែលត្រូវបានចោទថាប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។

បណ្តាញ[[១១២]]មន្ទីរសន្តិសុខទាំងនេះបានត្រូវបន្ថែមដោយប្រព័ន្ធតាមដាននៅគ្រប់ជាន់ថ្នាក់ សំដៅវែកមុខ រាយការណ៍ និងកម្ទេចខ្មាំងចេញពីជួរថ្នាក់ដឹកនាំរបស់បក្ស។

១៥. ហេតុដូច្នេះហើយ ចាប់តាំងពីថ្ងៃរំដោះទីក្រុងភ្នំពេញរហូតដល់ពេលដែលរបបនេះត្រូវដួលរលំបក្សកុម្មុយនីស្តកម្ពុជាបានដាក់ទោស ឬសម្លាប់មនុស្សជាច្រើនដែលត្រូវបានចោទប្រកាន់ទាំងខុស ឬទាំងត្រូវ ថាមានជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ ឬមនុស្សសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរ[១១៣]។

៨៣. ការពិចារណាអំពីរចនាសម្ព័ន្ធ និងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសអំពីរចនាសម្ព័ន្ធ និងគោលនយោបាយដែលយកមកអនុវត្តសម្រាប់ប្រតិបត្តិការនៅមន្ទីរស២១ ត្រូវបានធ្វើឡើងនៅក្នុងបរិបទប្រវត្តិសាស្ត្រ និងនយោបាយដែលសុទ្ធតែជាបរិបទចោទប្រកាន់មកលើជនជាប់ចោទ។

[១១២] ជនជាប់ចោទមិនបានយល់ស្របថា មានទំនាក់ទំនងគ្នាដោយផ្ទាល់ រវាងមន្ទីរសន្តិសុខនោះទេ ហេតុដូច្នេះជនជាប់ចោទមិនទទួលយកការប្រើប្រាស់ពាក្យ "បណ្តាញ" ទេ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានយល់ស្របជាមួយនឹងផ្នែកផ្សេងៗទៀត នៅក្នុងសេចក្តីថ្លែងនោះ។ *សូមមើល* "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ២៥-២៦។ ប្រតិចារឹកចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤២។

[១១៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១០-១៥ (ជើងទំព័រត្រូវបានលុបចោល)។

## ២.២.១ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា

៨៤. ក្រោយពីរំដោះបានទីក្រុងភ្នំពេញ បក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នានៅក្នុងសន្និបាតបក្សក្នុងខែមករា ឆ្នាំ១៩៧៦ ដើម្បីបង្កើតលក្ខន្តិកៈ (“លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា”)[១១៤] ដែលជារចនា-សម្ព័ន្ធចាត់តាំងមជ្ឈិម និងមានលក្ខណៈស្មុគស្មាញ ក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រទេស។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា បរិធានរដ្ឋាភិបាលទាំងមូល និងកងទ័ពបដិវត្តកម្ពុជាគ្រប់ប្រភេទត្រូវស្ថិតនៅក្រោមការដឹកនាំផ្ដាច់មុខដាច់ខាតរបស់បក្សកុម្មុយនីស្តកម្ពុជា[១១៥]។ បទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ ឆ្លុះបញ្ចាំងអំពីគោលនយោបាយ និងរចនាសម្ព័ន្ធពីមុនដែលបង្កើតឡើងនៅសន្និបាតលើកទីមួយនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦០ ដែលរួមទាំងការបង្កើតគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍[១១៦]។

៨៥. នៅក្នុងការអនុវត្ត គណៈកម្មាធិការមជ្ឈិមកម្រជួបប្រជុំគ្នាណាស់។ អំណាចរបស់គណៈកម្មា-ធិការមជ្ឈិមត្រូវបានប្រគល់ឲ្យ និងអនុវត្តដោយផ្នែកប្រតិបត្តិគឺគណៈកម្មាធិការអចិន្ត្រៃយ៍។ សមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ រួមមាន ប៉ុល ពត ជាលេខាបក្ស និងជានាយករដ្ឋមន្ត្រី នួន ជា ជាអនុលេខាបក្ស និងជាឧបនាយរដ្ឋមន្ត្រី និងសមាជិកជាន់ខ្ពស់ប្រាំពីររូបផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ដែលជាសមាជិកពេញសិទ្ធិ ឬសមាជិកត្រៀម[១១៧]។ គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបប្រជុំគ្នា

[១១៤] “លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា” ឯកសារ E3/28 ទំព័រ១-៥៥។ “ទស្សនាវដ្តី ទង់បដិវត្ត” ចុះខែមិថុនា ឆ្នាំ១៩៧៦” ឯកសារ E3/36។

[១១៥] “លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា” ឯកសារ E3/28 មាត្រា២៧ ។ “សេចក្ដីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦” ឯកសារ E3/13, ERN (ភាសាខ្មែរ) 00000763។

[១១៦] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥៥-៥៦។ ការប្រជុំលើកមុនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក៏បានបង្ហាញអំពីរបៀបនៃការបែងចែកការងារ ដំណើរការប្រតិបត្តិ ការរៀបចំសម្រាប់ការរស់នៅក្នុងការរៀបចំការងារជាក់លាក់ និងការងាររួមចំពោះពាណិជ្ជកម្ម និងកងទ័ព។ សូមមើល “ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥” ឯកសារ E3/14។

[១១៧] “របាយការណ៍អ្នកជំនាញការ Craig C. Etcheson” E3/32 កថាខណ្ឌ ១២។ “សេចក្ដីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦” ឯកសារ E3/13, ERN (ភាសាខ្មែរ) 00000763។

ជាញឹកញាប់ ហើយការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការនេះត្រូវបានអនុវត្តដោយមន្ទីរ៨៧០ ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ[១១៨]។ មន្ទីរ៨៧០ និងគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានគេស្គាល់ថាជា "មជ្ឈិម"[១១៩] ឬ "អង្គការ"[១២០] (Angkar) ដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យ និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស[១២១]។ មន្ទីរ៨៧០ អនុវត្តភារៈកិច្ចរបស់ខ្លួនតាមរយៈបណ្តាញមន្ទីរក្រោមឱវាទ[១២២]។

៨៦. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គឺជាប្រភពចម្បងនៃឯកសារសម្រាប់រៀបចំគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា អនុវត្តដោយផ្ទាល់តែទៅលើជនទាំងឡាយណាដែលជាសមាជិករបស់បក្សប៉ុណ្ណោះ[១២៣]។ ប៉ុន្តែ បទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ មានឥទ្ធិពលគ្របដណ្តប់ពេញផ្ទៃប្រទេសទាំងមូល[១២៤]។ តាំងពីដំបូងមក ប្រជាជនស៊ីវិលទាំងអស់ត្រូវបានគ្រប់គ្រងដោយបណ្តាញអង្គភាព ដែលគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយគណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍។ ប្រទេសទាំងមូល

---

[១១៨] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៨។"ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥" ឯកសារ E3/14។

[១១៩] ត្រូវបានស្គាល់ផងដែរថា "មជ្ឈិមបក្ស"។ សូមមើល "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 ជើងទំព័រ ១៨។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥០, ៥៨។

[១២០] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣។ ទំព័រ១៣, ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥០។

[១២១] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥៨-៥៩។ "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13, ERN (ភាសាខ្មែរ) 00000758។

[១២២] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ២២-២៣។ សូមមើលផងដែរ "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥" ឯកសារ E3/14។

[១២៣] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៧-១៨។

[១២៤] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៧-១៨ ("[...] ដោយសារ លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា គឺជាឯកសារមគ្គុទេសក៍របស់អង្គការ ដែលនឹងត្រូវយកមក ដែលជាអង្គការអនុវត្តនូវភាពផ្តាច់ការនៅក្នុងប្រទេសកម្ពុជា ហើយបទប្បញ្ញត្តិភាគច្រើន ដែលមាននៅក្នុងលក្ខន្តិកៈនៃបក្សកម្មុយនីស្តកម្ពុជា គឺដាក់ឡើងសម្រាប់ប្រជាជនទាំងអស់នៅទូទាំងប្រទេស"។

ត្រូវបានចែកចេញជាភូមិភាគ ហើយភូមិភាគចែកចេញជាតំបន់ ស្រុក និង/ឬ ឃុំ[១២៥]។ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ជាទម្លាប់ ឃុំត្រូវបានបែងចែកចេញជាភូមិ ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ ភូមិត្រូវបាន "ដាក់ច្របាច់បញ្ចូលគ្នាជាអង្គភាពធំមួយ ហៅថាសហករណ៍ ដែលត្រូវបានគេចាត់ចែងឲ្យធ្វើការរួម និងហូបរួម"[១២៦]។ កងផ្សេងៗរបស់អង្គការដែលមាននៅក្នុងឃុំ មានដូចជា កងចល័ត កងឈ្លប និងកងរយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខាសាខាឃុំ[១២៧]។ ឃុំ ឬ សហករណ៍ដែលជាសាខាបក្សកុម្មុយនីស្តកម្ពុជាត្រូវស្ថិតនៅក្រោមការដឹកនាំរបស់លេខាសាខាឃុំ[១២៨]។

៨៧. ភូមិភាគ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការបក្សភូមិភាគ ដែលមានសមាសភាពបីនាក់ ម្នាក់ជាលេខា ម្នាក់ជាអនុលេខាទទួលបន្ទុកការងារសន្តិសុខ និងម្នាក់ជាសមាជិកទទួលបន្ទុកខាងសេដ្ឋកិច្ច ហើយដែលត្រូវបានតែងតាំងដោយគណៈកម្មាធិការអចិន្ត្រៃយ៍។ បន្ថែមពីលើភូមិភាគទាំងប្រាំមួយដែលមានរួចហើយនោះ ក៏មានតំបន់ស្វយ័ត និងភូមិភាគពិសេសដែលស្ថិតនៅក្រោមអាជ្ញាធរឃោធា ក្នុងនោះរួមមានរដ្ឋធានីភ្នំពេញរបស់កម្ពុជាប្រជាធិបតេយ្យ[១២៩]។ នៅតាមថ្នាក់នីមួយៗ រចនាសម្ព័ន្ធដឹកនាំបានឆ្លុះបញ្ចាំងអំពីអង្គភាពដែលគ្រប់គ្រងដោយភូមិភាគ។ ការគ្រប់គ្រងទៅលើអង្គភាពទាំងនោះត្រូវបានតែងតាំងដោយអង្គភាពថ្នាក់លើរបស់ខ្លួនផ្ទាល់ ហើយការតែងតាំងត្រូវបានយល់ព្រមជាចុងក្រោយ

---

[១២៥] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ៧-១០។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥៣។ "លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា" ឯកសារE3/28 មាត្រា ៧ ។

[១២៦] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ១០។ *សូមមើលផងដែរ* "ទស្សនាវដ្តីទង់បដិវត្ត, លេខពិសេស តុលា-វិច្ឆិកា ១៩៧៧", E3/29, ERN (ភាសាខ្មែរ) 00000268។ សូមមើលផងដែរ "ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា "ទង់បដិវត្ត" លេខពិសេស ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧"។

[១២៧] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ១០។ "លក្ខន្តិកៈបក្សកុម្មុយនីស្ត-កម្ពុជា", E3/28, មាត្រា ៩ ។

[១២៨] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា៩ ។

[១២៩] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ៧។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON), ទំព័រ ៥៣-៥៥ (ក្រោយមកទៀតមានការផ្លាស់ប្តូរជាច្រើន ចំពោះចំនួន និងសមាសភាពរបស់ភូមិភាគ និងតំបន់ស្វ័យយ័ត)។

ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ដោយផ្ទាល់។ អង្គភាព ឬ ផ្នែកនីមួយៗត្រូវរាយការណ៍ទៅអង្គភាពថ្នាក់លើរបស់ខ្លួន និងចុងក្រោយរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍[១៣០]។

៨៨. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បានចែងអំពីលក្ខណៈវិនិច្ឆ័យចំពោះសមាជិកភាព និងតម្រូវឱ្យគ្រប់បក្ខជនទាំងអស់ត្រូវ "ភ្ជាក់រឮកខ្លួនឯង" និង "ត្រូវកសាងប្រវត្តិរូបច្បាស់លាស់ និងស្អាតបរិសុទ្ធជាបន្តបន្ទាប់ជាប់ជានិច្ច"[១៣១]។ លក្ខន្តិកៈនេះក៏បានតម្រូវឱ្យមានកិច្ចប្រជុំជាប្រចាំនៅគ្រប់ជាន់ថ្នាក់នៃបក្សកុម្មុយនីស្តកម្ពុជា និងក្នុងចំណោមកម្មាភិបាលទាំងអស់ ហើយជំរុញឱ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជា "យកការទិតៀន និងស្វ័យទិតៀនជាមធ្យោបាយប្រចាំថ្ងៃ" និងត្រូវ "ប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនកាន់កាប់វាសនា"[១៣២]។

៨៩. បក្សកុម្មុយនីស្តកម្ពុជាបានណែនាំដោយផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិមឱ្យអនុវត្តនូវ "មាគ៌ា" របស់បក្ស ឬនយោបាយ នៅក្នុងប្រទេសទាំងមូល ណែនាំអង្គការភូមិភាគ តំបន់ យោធា និងអង្គការបក្ស ទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស គ្រប់គ្រង និងចាត់ចែង "កម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល [...] ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឱ្យច្បាស់ និងឱ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច"[១៣៣]។

៩០. គ្រប់អង្គភាពទាំងអស់ រួមទាំងអង្គភាពយោធា ត្រូវបានតម្រូវឱ្យរាយការណ៍ទៅគណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍ និងត្រូវបានហាមឃាត់មិនឱ្យអង្គភាពទាំងអស់ទំនាក់ទំនងជាមួយគ្នានោះទេ។ ដូចដែលជនជាប់ចោទបានរៀបរាប់អំពីកាតព្វកិច្ចរាយការណ៍ ការទំនាក់-

---

[១៣០] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson", ឯកសារ E3/32 កថាខណ្ឌ៨។

[១៣១] "ទស្សនទានអំពីឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ" បុព្វកថា ចំណុច៦ ។

[១៣២] ចំណុច ៧ និង ៨ នៃបុព្វកថារបស់ "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 ។

[១៣៣] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ ៤៩។ *សូមមើលផងដែរ* "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា២៣។ សូមមើលផងដែរ "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា២៣។

ទំនងត្រូវធ្វើឡើងតាមរយៈខ្សែបណ្តោយ មិនដែលធ្វើតាមរយៈខ្សែទទឹងនោះទេ[១៣៤]។ អនុលោមតាមសក្ខីកម្មរបស់ជនជាប់ចោទ គាត់បានទទួលការណែនាំពី សុន សេន ដែលជាថ្នាក់លើរបស់គាត់ និងក្រោយមក នួន ជា ប៉ុន្តែគាត់មិនបានទំនាក់ទំនងដោយផ្ទាល់ ជាមួយអង្គភាពផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ[១៣៥]។ បទបញ្ជាប្រឆាំងនឹងការទំនាក់ទំនងដោយផ្ទាល់រវាងអង្គភាពនៃបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តចំពោះអង្គភាពយោធា ព្រមទាំងថ្នាក់តំបន់ និងអង្គភាពក្រោមបង្គាប់របស់ពួកគេ ដើម្បីធានាថា គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រង និងត្រួតពិនិត្យរាល់ព័ត៌មាន និងណែនាំសកម្មភាពទាំងអស់របស់ប្រជាជនទាំងមូលចាប់ពីសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជារហូតដល់ប្រជាជនសាមញ្ញ[១៣៦]។

៩១. មិនមានរចនាសម្ព័ន្ធការិយាធិបតេយ្យដំណើរការនៅក្នុងក្រសួងផ្សេងៗនោះទេ។ ក្រសួងទាំងនោះគ្រាន់តែជាកន្លែងដែលចាត់តាំងបក្ខជនម្នាក់ឲ្យទទួលខុសត្រូវប៉ុណ្ណោះ[១៣៧]។ គណៈកម្មាធិការអចិន្ត្រៃយ៍បានរៀបចំការតែងតាំងមន្ត្រីជាន់ខ្ពស់ទាំងអស់ឲ្យកាន់តំណែងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងរដ្ឋាភិបាល និងអង្គភាពយោធា។ គណៈកម្មាធិការអចិន្ត្រៃយ៍ក៏បានតែងតាំងផងដែរនូវមន្ត្រីដឹកនាំទាំងឡាយឲ្យកាន់មុខតំណែងនៅក្នុងរដ្ឋាភិបាល និងបានតែងតាំង និងដកនាយទាហានជាន់ខ្ពស់ដែលជាសមាជិករបស់អគ្គសេនាធិការកងទ័ព[១៣៨]។ គ្រប់ផ្នែកទាំងអស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យត្រូវបាន

---

[១៣៤] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៦-៣៧ ។ "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ៥៦)។

[១៣៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៧។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ២៨-២៩។

[១៣៦] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ៣៦។

[១៣៧] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥១-៥២។ *សូមមើលផងដែរ* "សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13 ERN 00000763-00000764។ "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥", ឯកសារ E3/14, ERN (ភាសាខ្មែរ) 00019108-00019126។

[១៣៨] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ១៨។ *សូមមើលផងដែរ* "សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13។

គ្រប់គ្រងតាមរយៈរចនាសម្ព័ន្ធទាំងនេះ ចាប់តាំងពីផ្នែកសន្តិសុខខាងក្នុង និងខាងក្រៅ កិច្ចការបរទេស ថាមពល ពាណិជ្ជកម្ម រហូតដល់ផលិតកម្ម កសិកម្ម ការណែនាំខាងនយោបាយ ការថែទាំសុខភាព ការអប់រំ និងការទំនាក់ទំនងជាដើម[១៣៩]។

## ២.២.២ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ

៩២. ក្នុងពេលដំណាលគ្នានឹងការអនុម័តលក្ខន្តិកៈបក្ស បក្សកុម្មុយនីស្តកម្ពុជាក៏បានប្រកាសឱ្យប្រើផងដែរនូវរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ "រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ"[១៤០]។ រដ្ឋធម្មនុញ្ញនេះចែងថា "សភាតំណាងប្រជាជនកម្ពុជា" ត្រូវបានប្រជាជនជ្រើសតាំងឡើងដោយការបោះឆ្នោតទូទាំងប្រទេស ដោយផ្ទាល់ និងដោយសម្ងាត់ ។ អង្គការអនុវត្តច្បាប់ ឬរដ្ឋាភិបាល ត្រូវបានជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ។ តុលាការរបស់ប្រជាជនគ្រប់ជាន់ថ្នាក់ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង ។ គណៈប្រធានរដ្ឋត្រូវជ្រើសរើស និងតែងតាំងឡើង ដោយសភាតំណាងប្រជាជនកម្ពុជាក្នុងរយៈកាល ០៥ ឆ្នាំម្តង ។

៩៣. ផ្ទុយទៅវិញ សមាជិកសភាតំណាងប្រជាជនកម្ពុជាមិនដែលត្រូវបានជ្រើសតាំងឡើយ។ គណៈកម្មាធិការមជ្ឈិមបានតែងតាំងប្រធាន និងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតឱ្យកាន់មុខតំណែងនៅសភាតំណាងប្រជាជនកម្ពុជា និងគណៈប្រធានរដ្ឋ[១៤១]។ ផែនការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងប្រជាជនកម្ពុជាត្រូវបានគេលើកយកមកពិភាក្សា ប៉ុន្តែ តាមការពិតសមាជិកសភាតំណាង

---

[១៣៩] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ៣៥, *សូមមើលផងដែរ* "សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13 ERN (ភាសាខ្មែរ) 00000758, "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥" ឯកសារ E3/14។

[១៤០] "រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E3/27 ។

[១៤១] "សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13, ERN (ភាសាខ្មែរ) 00003141។

ប្រជាជនកម្ពុជាចំនួន២៥០រូប ត្រូវបានតែងតាំងឡើងដោយថ្នាក់លើប៉ុណ្ណោះ[១៤២]។ មានភស្តុតាងដែលបង្ហាញថា គណៈកម្មាធិការមជ្ឈិមមិនមានចេតនាក្នុងការបង្កើតនូវស្ថាប័នទាំងនេះ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឡើយ[១៤៣]។ ដូចដែលជនជាប់ចោទបានលើកឡើងថា រដ្ឋធម្មនុញ្ញគឺគ្រាន់តែជា "របាំងរនាំង"[១៤៤] តែប៉ុណ្ណោះ។

### ២.២.៣ ប្រព័ន្ធតុលាការ

៩៤. នៅក្នុងសៀវភៅរបស់អ្នកជំនាញ David CHANDLER គាត់បានសរសេរថា "បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាបានបាត់រលត់ បាត់ស្រមោលឈឹងតែម្តង[១៤៥] ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មានតុលាការ គ្មានចៅក្រម គ្មានច្បាប់ និងគ្មានការជំនុំជម្រះក្តីអ្វីឡើយ។ "តុលាការប្រជាជន" ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រា៩ មិនមានជារូបរាងទេ"[១៤៦] ។ សភាតំណាងប្រជាជនកម្ពុជាបានជួបប្រជុំគ្នាម្តងនៅខែមេសា ឆ្នាំ១៩៧៦ ប៉ុន្តែការទទួលខុសត្រូវផ្នែកច្បាប់ និងគោល-

---

[១៤២] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៤-១៥។

[១៤៣] "កំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន ថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/44 ERN (ភាសាខ្មែរ) 00017118 ("បើមានគេសួរ [...] កុំនិយាយលេងពីសភា នៅមុខប្រជាជន ឲ្យគេឃើញថា យើងបន្តឹមបន្តំ ហើយសភាយើងគ្មានតម្លៃ"។

[១៤៤] ប្រតិចារឹកចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩ ("ចំណែករដ្ឋធម្មនុញ្ញ ខ្ញុំបានជម្រាបលោកចៅក្រមរួចហើយ ថាវាជារបាំង រនាំង [...]ដាក់លំអប៉ុណ្ណឹងឯង")។ ប្រតិចារឹកចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៤-១៥ ("សភាតំណាងប្រជាជន [...] មិនជួបប្រជុំជាញឹកញាប់នោះទេ ហើយមិនបានធ្វើការអនុម័តច្បាប់ ហើយក៏មិនមានភារកិច្ចទាល់តែសោះក្រៅពីបម្រើជាការឃោសនា ដើម្បីធ្វើយ៉ាងណាបង្កើតឲ្យមានកេរ្តិ៍ឈ្មោះដល់កម្ពុជាប្រជាធិបតេយ្យនៅក្នុងពិភពលោក"។

[១៤៥] "សៀវភៅរបស់លោក David Chandler មានចំណងជើងថា "សំឡេងពីមន្ទីរស២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ប៉ុល ពត "២០០២" ឯកសារ E3/427 ទំព័រ១៣៥-១៣៦ ERN (ភាសាខ្មែរ) 00191975-00191976។

[១៤៦] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ២៣-២៤។ នៅក្នុងគំនិតរបស់អ្នកជំនាញ CHANDLER ផ្លូវតែមួយគត់នៃប្រព័ន្ធយុត្តិធម៌ គឺការសួរចម្លើយ ជាធម្មតាអ្នកមកឲ្យដំណឹងមុនទាក់ទងនឹងការចោទប្រកាន់ផ្នែកតុលាការ ប៉ុន្តែមិនមានអង្គភាពបង្កើតឡើងដោយរដ្ឋធម្មនុញ្ញណាមួយដោះស្រាយជាមួយនឹងការប្រមូលព័ត៌មាននោះទេ។ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ ៣៧ និង ៣៨។

នយោបាយនៃសភានេះ ត្រូវបានអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយគ្មានច្បាប់ ឬយន្តការក្នុងការអនុវត្តច្បាប់ដែលរួមមានទាំងតុលាការ ដែលអាចជំនុំជម្រះ ត្រូវបានបង្កើតឡើងនោះទេ[១៤៧]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានទូវដំណើរការនៃប្រព័ន្ធតុលាការដែលអាចផ្តល់នូវការធានាផ្នែកនីតិវិធីដល់អ្នកជាប់ឃុំឡើយ។

២.២.៤ កងទ័ព

៩៥. គណៈកម្មាធិការមជ្ឈិម ក៏អនុវត្តការគ្រប់គ្រងយ៉ាងតឹងរ៉ឹងលើកងទ័ពបដិវត្តកម្ពុជាផងដែរ។ កងទ័ពបដិវត្តកម្ពុជា ដែលបានតម្រូវដោយលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បានក្លាយទៅជា "កងទ័ពដ៏សំខាន់របស់មជ្ឈិម"[១៤៨]។ ចំពោះគោលបំណងក្នុងការគ្រប់គ្រង គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលបានប្រគល់អំណាចដោយគណៈកម្មាធិការមជ្ឈិម បានគ្រប់គ្រងកងទ័ពបដិវត្តកម្ពុជាទាំងបីប្រភេទដោយផ្ទាល់[១៤៩]។ គណៈកម្មាធិការកងទ័ពបដិវត្តកម្ពុជាត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការមជ្ឈិមដែលមាន ប៉ុល ពត ជាប្រធាន។ ដំបូងជនជាប់ចោទបានរាយការណ៍ទៅ សុន សេន និងក្រោយមកទៅ នួន ជា ដែលគាត់បន្តវេនពី សុន សេន ក្នុងនាមជាថ្នាក់លើរបស់ជនជាប់ចោទ។ សុន សេន និង នួន ជា គឺជាសមាជិករបស់គណៈកម្មាធិការកងទ័ពបដិវត្តកម្ពុជា[១៥០]។

៩៦. ភូមិភាគ និងតំបន់ ក៏ជាអ្នកបញ្ជាអង្គភាពកងទ័ព ដែលស្ថិតនៅក្រោមសេនាធិការកងទ័ពដែលចំណុះភូមិភាគ និងតំបន់ ហើយស្រុកគ្រប់គ្រងកងទ័ពស្រុក និងកងជីវពល។ ភូមិភាគ តំបន់ និងស្រុក

---

[១៤៧] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ ១៤៩-១៥១។ គណៈកម្មាធិការតុលាការ ត្រូវបានទទួលការឯកភាពពី សភាតំណាងប្រជាជនកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៦ ៖ "ឯកសារស្តីពីអង្គុគ-ប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា, ថ្ងៃទី១១ ដល់ ១៣ ខែមេសា ឆ្នាំ១៩៧៦" ឯកសារ E3/43។ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON), ទំព័រ ៣៦-៣៨។

[១៤៨] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28។ "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ១២។

[១៤៩] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា២៧: ផ្នែកទាំងបីរួមមាន: ស្រុច តំបន់ និងឈ្លប។

[១៥០] ប្រតិចារឹកចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ៥៨-៥៩ (Craig ETCHESON) ទំព័រ៥៩-៦០។ ប្រតិចារឹកចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤៤។

មានការទទួលខុសត្រូវចំពោះសន្តិសុខផ្ទៃក្នុងដែនដីរបស់ខ្លួន ដែលរួមបញ្ចូលទាំងអំណាចក្នុងការចាប់ និងសម្លាប់បុគ្គលិកនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន និងត្រូវរាយការណ៍តាមឋានានុក្រមរហូតដល់គណៈកម្មាធិការអចិន្ត្រៃយ៍។ យោងតាមអ្នកជំនាញ Craig ETCHESON ស្រុក គឺជាអង្គភាពដ៏សំខាន់មួយក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះស្រុកមាន "មន្ទីរសន្តិសុខ" ដែលបានកំណត់ដោយឡែកពីគ្នារវាង "ខ្មាំង" នៅតាមមូលដ្ឋាន និង "ខ្មាំង"ដែលត្រូវបញ្ជូនតាមខ្សែរយៈទៅអាជ្ញាធរថ្នាក់លើ[១៥១]។

### ២.២.៥ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលពាក់ព័ន្ធ

#### ២.២.៥.១ ការសម្ងាត់

៩៧. បក្សកុម្មុយនីស្តកម្ពុជា បានរក្សាការសម្ងាត់ស្ទើរតែទាំងស្រុង ទាក់ទងនឹងថ្នាក់ដឹកនាំ និងការអនុវត្តគោលនយោបាយរបស់ខ្លួន។ បក្ខជនត្រូវបានបង្គាប់ឲ្យ"ខិតខំរក្សាការសម្ងាត់របស់បក្សដាច់ខាតដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច"[១៥២]។ ការល្មើសនឹងការសម្ងាត់អាចនឹងនាំឲ្យមានការទទួលវិន័យរបស់បក្ស[១៥៣]។

៩៨. គោលនយោបាយរក្សាការសម្ងាត់បានចូលរួមធ្វើឲ្យរបបនេះមានលទ្ធភាពលាក់បាំងនូវអំពើខុសច្បាប់របស់ខ្លួននៅក្នុងប្រទេសកម្ពុជា និងរួចផុតពីការត្រួតពិនិត្យរបស់អន្តរជាតិ ។

---

[១៥១] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ៩, ៨៩។

[១៥២] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា២៖ ភារកិច្ចផ្ទៃក្នុង កថាខណ្ឌ ង។ *សូមមើលផងដែរ* ប្រតិចារិកចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៤៩-៥០ និង៦៣-៦៤។ ប្រតិចារិកចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦០-៦១។

[១៥៣] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ឯកសារ E3/28 មាត្រា៤៖ អំពីវិន័យបក្ស កថាខណ្ឌ២។

## ២.២.៥.២ ការ "កម្ទេច" ខ្មាំង

៩៩. ចំណុចសំខាន់បំផុតរបស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលពាក់ព័ន្ធនឹងការជំនុំជម្រះនេះ គឺជាគោលនយោបាយក្នុង ការ "កម្ទេច" ខ្មាំង ដែលជាគោលនយោបាយមួយបានអនុវត្តនៅមន្ទីរម១៣[១៥៤] ហើយបានបន្តអនុវត្តនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គោលនយោបាយនេះត្រូវបានអនុម័តដោយរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា១០ ជំពូក៧ ដែលមានចំណងជើងថា "អំពីតុលាការ" ហើយបានចែងថា "ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត" ។ យោងតាមអ្នកជំនាញ Craig ETCHESON ប៉ុល ពត ខ្លួនឯងបាននិយាយនៅក្នុងសន្និបាតក្នុងឆ្នាំ១៩៧៦ ពាក់ព័ន្ធទៅនឹងតម្រូវការដោះស្រាយជាមួយខ្មាំងនៅសហករណ៍ តាមរយៈ "វិធានការដាច់ខាតឥតឈប់ឈរដើម្បីកម្ទេចខ្មាំង"[១៥៥]។

១០០. ជនជាប់ចោទបានរៀបរាប់ថាគោលនយោបាយនេះមានលក្ខណៈជាសកល សម្រាប់ "មន្ទីរស២១ បក្សទាំងមូល កងទ័ព អាជ្ញាធរមូលដ្ឋាន និងផ្នែកសន្តិបាលទូទាំងប្រទេស"[១៥៦]។ ជនទាំងឡាយណាដែលចាត់ទុកថាជាខ្មាំង ត្រូវតែសម្លាប់ចោល។ និយមន័យខ្មាំង "មានការប្រែប្រួល និងពង្រីកទៅតាមការវិវត្តនៃស្ថានភាពក្នុងស្រុក និងជម្លោះប្រដាប់អាវុធជាអន្តរជាតិ រវាងកម្ពុជានិងវៀតណាម"[១៥៧]។ ពាក្យថា "កម្ទេច" មានន័យជ្រាលជ្រៅជាងពាក្យសម្លាប់ទៅទៀត។ ជនជាប់ចោទបានពន្យល់ពាក្យនេះថា "...កម្ទេចមានន័យថាចាប់ដោយសម្ងាត់... សួរចម្លើយដោយមានទារុណកម្ម ហើយសម្លាប់ដោយសម្ងាត់ មិនឲ្យដំណឹងដល់គ្រួសារ"។ វាក៏មានន័យថា "...កម្ទេច គឺមិនដោះលែង ... បើកម្ទេច ... គឺអត់ឆ្លងកាត់តុលាការទេ ព្រោះគ្មានច្បាប់ គ្មានតុលាការ អចិន្ត្រៃយ៍មជ្ឈិមបក្សប្រមូលផ្តុំអំណាចទាំងបី"[១៥៨]។ លើសពីនេះទៀត ពាក្យថាកម្ទេចត្រូវបានបកប្រែជាញឹកញាប់ថា

[១៥៤] ប្រតិចារឹកចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១២។

[១៥៥] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ២៦ ជើងទំព័រ ៥១។

[១៥៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៣៣ (ជើងទំព័រត្រូវបានលុប)។

[១៥៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៣៤

[១៥៨] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១។

"កម្ទេចឲ្យម៉ត់" ហើយនិងធ្វើឲ្យវាទៅជាកម្ទេចតូចៗ ... ពាក្យនេះ មិនពាក់ព័ន្ធត្រឹមតែការសម្លាប់តែប៉ុណ្ណោះនោះទេ គឺវាទាក់ទងទៅនឹងការកម្ទេចសម្លាប់ដោយផ្នែកចិត្តសាស្ត្រផងដែរ និងប្រព័ន្ធនៃការប្រព្រឹត្តិលើអ្នកទោសនៅមន្ទីរស២១ គឺវាមានលក្ខណៈធ្វើឲ្យមនុស្សអាប់ឱន និងវាបានបង្កទៅលើចិត្តបុគ្គល ... កម្ទេច មានន័យជ្រាលជ្រៅជាងពាក្យថាសម្លាប់ទៅទៀត"[១៥៩]។

១០១. នៅក្នុងជំពូកដែលមានចំណងជើងថា "អំពីតុលាការ" នៃរដ្ឋធម្មនុញ្ញនេះ ក៏បានចែងផងដែរថា "ចំពោះប្រភេទល្មើស ក្រៅពីសកម្មភាពគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន"[១៦០]។

### ២.២.៦ សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦

១០២. សេចក្តីសម្រេចដែលមានឥទ្ធិពល និងសំខាន់បំផុតមួយក្នុងចំណោមសេចក្តីសម្រេចផ្សេងៗទៀត សម្រាប់សមាជិកពេញសិទ្ធិរបស់បក្សដែលមកពីគណៈកម្មាធិការមជ្ឈិម គឺ "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ជនជាប់ចោទមិនបានឃើញឯកសារមួយនេះដោយខ្លួនគាត់ទេ រហូតដល់ការស៊ើបអង្កេតមុនពេលជំនុំជម្រះនេះ[១៦១]។ នៅក្នុងឯកសារនេះ អង្គភាពបក្សកុម្មុយនីស្តកម្ពុជាទាំងឡាយណាដែលមានសិទ្ធិសម្រេច "កម្ទេច" ឬសម្លាប់ខ្មាំង ត្រូវបានវាយឈ្មោះដូចខាងក្រោម៖

> ១. សិទ្ធិសម្រេចកម្ទេច ក្នុងជួរ និងក្រៅជួរ [...]
> - បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភូមិភាគសម្រេច។
> - ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។
> - តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។
> - កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច។

---

[១៥៩] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ២, ៣។

[១៦០] "រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E3/27 មាត្រា១០។

[១៦១] "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួនចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ឯកសារ E3/13។

១០៣. តាមអ្នកជំនាញ Craig ETCHESON ទោះបីជាឯកសារនេះចេញមកពីគណៈកម្មាធិការមជ្ឈិមក៏ដោយ ប៉ុន្តែឯកសារនេះទំនងជាព្រាងឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍។ សារៈសំខាន់នៃឯកសារនេះ គឺស្ថិតនៅត្រង់ការប្រគល់អំណាចឱ្យអង្គភាពចំនួនបួនដែលបានលើកឡើងខាងលើ មានសមត្ថកិច្ចឯករាជ្យក្នុងការសម្លាប់[១៦២]។ អ្នកជំនាញ David CHANDLER បានរៀបរាប់អំពីសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ថាជា "[...]អ្វីដែលយើងយល់គឺវាទាក់ទងទៅនឹងឯកសារដែលវាកំណត់ឱ្យធ្វើការកម្ទេចទៅលើខ្មាំងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះត្រូវបានរក្សាទុកជាសម្ងាត់បំផុត។ ទំនងជាមានឯកសារចម្លងចំនួន០៦ ឬ០៧ ច្បាប់ ប៉ុន្តែមានតែឯកសារ០១ច្បាប់ប៉ុណ្ណោះដែលនៅសល់ [...][១៦៣]"។

### ២.២.៧ ការផ្សព្វផ្សាយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

១០៤. គោលនយោបាយត្រូវបានផ្សព្វផ្សាយតាមវិធីផ្សេងៗ រួមទាំងតាមរយៈសេចក្តីណែនាំ[១៦៤] ទៅគ្រប់អង្គភាពទាំងអស់របស់អង្គការ តាមរយៈការជួបជុំគ្នានៅស្ពាត សាលាបណ្តុះបណ្តាលបក្សដែលកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានណែនាំ អំពីគោលនយោបាយរបស់បក្ស និងគោល-នយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងតាមរយៈការផ្សព្វផ្សាយតាមវិទ្យុជាតិដែលត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង។ គោលនយោបាយក៏ត្រូវបានផ្សព្វផ្សាយតាមរយៈការណែនាំតាមទូរលេខ ព្រមទាំងការជួបប្រជុំទល់មុខគ្នាផងដែរ។ បន្ថែមពីលើនេះ បក្សកុម្មុយនីស្តកម្ពុជាតម្រូវឱ្យមានកិច្ចប្រជុំជាប្រចាំក្នុងចំណោមបក្ខជន និងកម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់[១៦៥]។

---

[១៦២] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤៣។

[១៦៣] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៨-១៩។ "សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា 'សំឡេងពីមន្ទីរស២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត ២០០២" ឯកសារ E3/427 ទំព័រ៥១ ERN (ខ្មែរ) 00191887។

[១៦៤] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ២៧-២៨។

[១៦៥] "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" E3/28 មាត្រា១៨ និង២០។ "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ៥៧។

១០៥. “ទង់បដិវត្ត”របស់កម្ពុជាប្រជាធិបតេយ្យដែលចេញជាប្រចាំ គឺជាទម្រង់នៃការទំនាក់ទំនងដ៏សំខាន់ និងត្រូវបានចែកចាយជាទូទៅក្នុងចំណោមសមាជិកពេញសិទ្ធិរបស់បក្ស ដែលមានកាតព្វកិច្ចសិក្សាអំពីទង់បដិវត្តនេះ។ យោងតាមអ្នកជំនាញ Raoul JENNAR គេជឿថាគ្រប់អត្ថបទទាំងអស់នៃទង់បដិវត្តត្រូវបានសរសេរដោយ ប៉ុល ពត[១៦៦]។ ទង់បដិវត្តអាចលើកឡើងអំពីការណែនាំជាទូទៅដែលពាក់ព័ន្ធនឹងកសិផល ព្រមទាំងបទបញ្ជា ដែលនាំឱ្យមានការបោសសម្អាត “ខ្មាំងស៊ីរូងផ្ទៃក្នុង” និងផ្តោតការយកចិត្តទុកដាក់ទៅលើប្រជាជន“ថ្មី” ដែលមកពីទីក្រុងនានា ហើយដែលប្រជាជនទាំងនោះត្រូវបានចាត់ទុកថាមានឋានៈទាបជាងកសិករ[១៦៧]។ ការទំនាក់ទំនងគ្នាយ៉ាងហោចណាស់ធ្វើឡើងតាមរយៈរបាយការណ៍ពីភូមិភាគ ជូនទៅមន្ទីរ៨៧០ ដែលជាទូទៅរាយការណ៍អំពីសកម្មភាពរបស់ខ្លួនក្នុងការស្វែងរកខ្មាំង ហើយជារឿយៗមិនបានរាយការណ៍អំពីបញ្ហាសេដ្ឋកិច្ច និងការបង្កបង្កើនផលនោះទេ[១៦៨]។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេស ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៧ បានសរសេរថា រាល់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ទាំងអស់របស់ “បក្សត្រូវបានណែនាំឱ្យប្រកាន់តួនាទីក្នុងការដឹកនាំកងទ័ព និងប្រជាជនដើម្បីវាយខ្មាំង បោសសម្អាតខ្មាំងទាំងនេះ បោសហើយ បោសទៀត បោសហើយ បោសទៀត បោសឥតឈប់ឈរ ដើម្បីឱ្យកម្លាំងបក្សរបស់យើងស្អាត កម្លាំងដឹកនាំរបស់យើងគ្រប់ថ្នាក់ គ្រប់ផ្នែក និងគ្រប់ពេលវេលាស្អាត”[១៦៩]។ ឯកសារដែលនៅសល់ ក៏បានបង្ហាញអំពីការរាយការណ៍ជាប្រចាំអំពីការសម្លាប់ ដែលបញ្ជាដោយថ្នាក់ដឹកនាំតំបន់[១៧០]។

១០៦. ការស្វែងរកខ្មាំងផ្ទៃក្នុង ក្នុងអង្គភាពកងទ័ពរហូតដល់មជ្ឈិមបក្ស វាបានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងកងទ័ព ដូចមានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ អ្នកជំនាញ Craig ETCHESON ដែលបានយោងលើលិខិតរបស់ ស៊ូ ម៉េត មេបញ្ជាការកងពលធំ៥០២ ដែលបញ្ជូនទៅឱ្យជនជាប់ចោទ

[១៦៦] “ការដាក់តម្កល់សេចក្តីពិគ្រោះយោបល់ដែលបានរៀបចំធ្វើដោយលោក Raoul M. Jennar ជាបណ្ឌិតខាងការសិក្សាអំពីខ្មែរ និងជាអ្នកពិគ្រោះយោបល់ផ្នែកវិទ្យាសាស្ត្រនយោបាយ” ឯកសារ E3/511 ទំព័រ៤ ERN (អង់គ្លេស) 00283026។

[១៦៧] “ទស្សនាវដ្តីទង់បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា លេខ៦ ខែមិថុនា ឆ្នាំ១៩៧៧” ឯកសារ E3/82។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៣២-៣៣។

[១៦៨] ប្រតិចារឹកចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៣៥-៣៦។

[១៦៩] “ទង់បដិវត្ត” លេខពិសេស ខែឧសភា-មិថុនា ឆ្នាំ១៩៧៨” ឯកសារ E3/35 ERN (ភាសាខ្មែរ) 00064579។

[១៧០] “របាយការណ៍អ្នកជំនាញការ Craig C. Etcheson” ឯកសារ E3/32 កថាខណ្ឌ៦៤-៦៨ ។

ដែលក្នុងលិខិតនេះពន្យល់ពីមូលហេតុនៃការចាប់សមាជិកកងពលធំរបស់គាត់បញ្ជូនទៅមន្ទីរស២១ បានសន្និដ្ឋានថា ពួកគេបានបង្ហាញនូវវិធីដ៏ល្អមួយនៃ "ការអនុវត្តជំហរដាច់ខាតចំពោះការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង" ដូចបានជំរុញនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលបានបោះពុម្ពផ្សាយ[១៧១] ។

១០៧. ទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" គឺជាការបោះពុម្ពផ្សាយដ៏សំខាន់មួយផ្សេងទៀត ដែលមានគោលដៅចំពោះកម្មាភិបាលក្មេងៗ។ ទស្សនាវដ្តីនេះត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែដោយអង្គការឃោសនាអប់រំរបស់ "ស.យុវកក" និងមានអត្ថបទជំរុញឲ្យយុវជន "ត្រៀមសង្គ្រាមជាប់ជានិច្ច"[១៧២]។ ចំណុចសំខាន់នៃការបោះពុម្ពផ្សាយនេះ គឺដើម្បីលើកទឹកចិត្តកម្មាភិបាលក្មេងៗឲ្យម្ចាស់ការខ្លួនទីពឹងខ្លួន ខិតខំប្រឹងប្រែងធ្វើការងារ និងគាំទ្របដិវត្តន៍។ ការគូសបញ្ជាក់ពិសេស គឺការដាក់ឲ្យចូលរួមនៅក្នុងការងារពលកម្ម និងផលិតផលស្បៀង ដើម្បីឲ្យសម្រេចបានទិន្នផលស្រូវបីតោនក្នុងមួយហិកតា[១៧៣]។ កម្មាភិបាលជាច្រើនត្រូវបានគេប្រាប់ឲ្យ "ពង្រឹងជំហរវាយខ្មាំងដាច់ខាតទោះខ្មាំងនោះជាខ្មាំងអ្វីក៏ដោយ" ត្រូវ "វាយកំចាត់កម្មសិទ្ធិ បុគ្គលសួនតួ គ្រប់បែបយ៉ាងទាំងអស់" និងត្រូវ "រៀនសូត្រមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្សជាប់ជាប្រចាំ...ដើម្បីបង្កើនសមត្ថភាពនយោបាយ"។ ក្នុងពេលជាមួយគ្នា ពួកគេត្រូវបានលើកទឹកចិត្តឲ្យ "គោរពអង្គការវិន័យរបស់បក្សដោយភ្ញាក់រលឹក និងដោយឥតលក្ខខណ្ឌគ្រប់ពេលវេលា"[១៧៤]។

១០៨. មកដល់ត្រឹមឆ្នាំ១៩៧៨ ទស្សនាវដ្តីរៀបរាប់លម្អិតអំពីអំពើក្បត់របស់ជនជាតិវៀតណាម និងជនជាតិអាមេរិក និងជំរុញឲ្យយុវជន "យកចិត្តទុកដាក់តាមដាន និងបោសសម្អាតសមាសភាពខ្មាំង

---

[១៧១] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 កថាខណ្ឌ១២៣។ ប្រតិចារឹកចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥-៦។ ប្រតិចារឹកចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ ៤៥ ។

[១៧២] "ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តបក្សកុម្មុយនីស្តកម្ពុជា ខែកុម្ភៈ ឆ្នាំ១៩៧៨" ឯកសារ E3/532 ទំព័រ២០ ERN (ភាសាខ្មែរ) 00063495។

[១៧៣] "យុវជន និងយុវនារីបដិវត្ត" លេខ៥ ខែឧសភា ឆ្នាំ១៩៧៦" ឯកសារ E3/136 ទំព័រ៤-៥ ERN (ភាសាខ្មែរ) 00064007។

[១៧៤] "ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តបក្សកុម្មុយនីស្តកម្ពុជា" ខែកុម្ភៈ ឆ្នាំ១៩៧៨" ឯកសារ E3/532 ទំព័រ១០ ERN (ភាសាខ្មែរ) 00063495។

ស៊ីរូងបង្កប់ផ្ទៃក្នុងយ៉ាងសកម្មជាបន្តទៀត ដើម្បីសម្រិតសម្រាំងអង្គភាព ក្រសួង មន្ទីរ សហករណ៍ និងសង្គមជាតិយើងទាំងមូលឲ្យបានស្អាតល្អផូរផង់" ដោយឆ្លុះបញ្ចាំងអំពីភាសាដែលបានប្រើប្រាស់នៅក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេស ដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៧[១៧៥]។

### ២.២.៨ រចនាសម្ព័ន្ធសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា

១០៩. ធាតុផ្សំសំខាន់មួយនៃរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យគឺផ្នែកសន្តិសុខ។ សន្តិសុខផ្ទៃក្នុងដំបូងត្រូវបានប្រគល់ឲ្យ សុន សេន ដែលពីដំបូងគាត់គឺជាសមាជិកត្រៀមរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយដែលត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងអំឡុងឆ្នាំ១៩៧៨ និងបានក្លាយជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកការពារជាតិ[១៧៦]។ បន្ថែមពីលើនេះ គាត់ជាអគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា ដូចនេះគាត់បានកាន់មុខតំណែងសំខាន់ខាងស៊ីវិល និងកងទ័ពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[១៧៧]។ ដូចបានរៀបរាប់ដោយអ្នកជំនាញ Raoul JENNAR ថា សុន សេន ជា "គ្រូរបស់ជនជាប់ចោទ"[១៧៨] និងជាមនុស្សដែលបណ្តុះបណ្តាល និងការពារជនជាប់ចោទមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩។ សុន សេន បានសិក្សានៅប្រទេសបារាំង ហើយគឺជាសមាជិកម្នាក់នៃបក្សកុម្មុយនីស្តបារាំង និងបានចូលរួមនៅក្នុងចលនានៃលទ្ធិម៉ាក្សនិយមរបស់និស្សិតខ្មែរ។ អ្នកជំនាញ Raoul JENNAR បានផ្តល់មតិយោបល់ថា សុន សេន បានផ្សព្វផ្សាយមនោគមវិជ្ជាដែលគាត់បានរៀននៅក្នុងអំឡុងពេលនោះ ដែលគាំទ្រវិន័យយ៉ាងតឹងរ៉ឹង និងការកាត់បន្ថយតម្លៃជាមនុស្ស ហើយគោលនយោបាយនេះ ត្រូវបានគាត់ដាក់ឲ្យប្រើប្រាស់នៅមន្ទីរស២១ និងបន្តអនុវត្តនៅពេល ឌួច ជាចាប់ផ្តើមទទួលខុសត្រូវក្នុងនាមជាថ្នាក់លើរបស់ជនជាប់ចោទនៅឆ្នាំ១៩៧៧[១៧៩]។

---

[១៧៥] "ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តបក្សកុម្មុយនីស្តកម្ពុជា" ខែកុម្ភៈ ឆ្នាំ១៩៧៨" ឯកសារ E3/532 ទំព័រ៦៦-៦៧ ERN (ភាសាខ្មែរ) 00063520។

[១៧៦] ប្រតិចារឹកចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥១-៥២។

[១៧៧] "របាយការណ៍អ្នកជំនាញការ Craig C. Etcheson" ឯកសារ E3/32 ERN (ភាសាខ្មែរ) 00314834។

[១៧៨] ប្រតិចារឹកចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR) ទំព័រ៣៩។

[១៧៩] ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR) ទំព័រ ៤០ និង ៤១។

១១០. ប្រព័ន្ធសន្តិបាលត្រូវបានបង្កើតឡើងយ៉ាងល្អមុនពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច[១៨០]។ ដោយសារតែតំបន់មួយចំនួននៃប្រទេសកម្ពុជាត្រូវបានកាន់កាប់នៅក្នុងអំឡុងរបប លន់ នល់ ដែលចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧១ នោះ មន្ទីរសន្តិបាលនានាត្រូវបានបង្កើតនៅក្នុង "តំបន់រំដោះ"។ មន្ទីរម១៣ ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ គឺជាមន្ទីរសន្តិបាលដំបូងមួយនៃមន្ទីរសន្តិបាលជាច្រើន (ផ្នែក ២.៣.២)។ ក្រោយមក មន្ទីរសន្តិបាលទាំងនេះត្រូវបានបង្កើតឡើងនៅគ្រប់ផ្នែកទាំងអស់ទូទាំងប្រទេស ហើយរហូតមកទល់បច្ចុប្បន្ននេះមជ្ឈមណ្ឌលឯកសារកម្ពុជា បានកំណត់អត្តសញ្ញាណមន្ទីរសន្តិបាលទាំងនោះមានចំនួន ១៩៦ កន្លែង។ គោលបំណងចម្បងរបស់មន្ទីរទាំងនោះគឺ "កំណត់អត្តសញ្ញាណ និងកម្ទេចខ្មាំងសត្រូវខាងក្នុង" លើកទឹកចិត្តឲ្យរាយការណ៍ពីគ្នា និងដើម្បីទទួលបានចម្លើយសារភាព[១៨១]។ អ្នកជំនាញ Raoul JENNAR បានលើកឡើងថា គោលនយោបាយទាំងនេះ ផ្អែកតាមគោលនយោបាយស្តាលីន។ ជនទាំងឡាយណាដែលកំណត់អត្តសញ្ញាណថាជា "សត្រូវ" ត្រូវតែសម្លាប់ ឬ "កម្ទេច" ពាក្យនេះត្រូវបានប្រើនៅក្នុងសំណេររបស់ លេនីន[១៨២]។

---

[១៨០] "ការដាក់តម្កល់សេចក្តីពិគ្រោះយោបល់ដែលបានរៀបចំធ្វើដោយលោក Raoul JENNAR" ឯកសារ E3/511 ទំព័រ៨-១០ ERN (ភាសាខ្មែរ) 00187703។ សូមមើលផងដែរ ប្រតិចារឹកចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR) ទំព័រ៣៩-៤០។ យោងតាមអ្នកជំនាញ David CHANDLER ពាក្យ "សន្តិបាល" គឺជាពាក្យផ្សំខ្មែរ ដែលបានមកពីការផ្សំពាក្យ "សន្តិសុខ" និងពាក្យ "នគរបាល"។ *សូមមើល* "សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា 'សំឡេងពីមន្ទីរស២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត '២០០២" ឯកសារ E3/427 ទំព័រ៣ ERN (ភាសាខ្មែរ) 00191831។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៨ ("ពាក្យសន្តិបាល ប្រែមកថា អ្នកថែរក្សាសន្តិភាព សន្តិសុខនៅក្នុងប្រទេស")។

[១៨១] "ការដាក់តម្កល់សេចក្តីពិគ្រោះយោបល់ដែលបានរៀបចំធ្វើដោយលោក Raoul JENNAR" ឯកសារ E3/511 ទំព័រ៩-១០ ERN (ភាសាខ្មែរ) 00187704-00187705។ ប្រតិចារឹកចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR) ទំព័រ៥៣-៥៤។

[១៨២] ការដាក់តម្កល់សេចក្តីពិគ្រោះយោបល់ដែលបានរៀបចំធ្វើដោយលោក Raoul JENNAR" ឯកសារ E3/511 ទំព័រ៩-១០ ERN (ភាសាខ្មែរ) 00187704-00187705។ ប្រតិចារឹកចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR) ទំព័រ៥៨-៥៩។

## ២.៣ មន្ទីរស២១ និងតួនាទីរបស់ជនជាប់ចោទ

១១១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ឌុច មានមុខតំណែងជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ ដែលជាមន្ទីរសន្តិសុខមួយបំពេញការងារខាងសួរចម្លើយ និងសម្លាប់អ្នកដែលប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ហើយជនជាប់ចោទក៏បានទទួលស្គាល់ផងដែរ[១៨៣]។ ផ្នែក (២.៣) រៀបរាប់យ៉ាងសង្ខេបអំពីសាវតារបស់ជនជាប់ចោទ មុនពេលគាត់កាន់មុខតំណែងទាំងនេះ និងរៀបរាប់អំពីរចនាសម្ព័ន្ធចាត់តាំងមន្ទីរស២១ ដែលរួមបញ្ចូលទាំងទីតាំងជើងឯក និង ស២៤ ព្រមទាំងតួនាទីរបស់ជនជាប់ចោទនៅក្នុងមន្ទីរទាំងនោះ។ ផ្នែក (២.៤) បង្ហាញពីបទល្មើសដែលបានប្រព្រឹត្តនៅក្នុងមន្ទីរស២១ ។ សំអាងហេតុផ្នែកច្បាប់របស់អង្គជំនុំជម្រះ ទាក់ទងនឹងបទល្មើសនានាដែលបានប្រព្រឹត្តនៅមន្ទីរស២១ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទចំពោះអំពើដែលបានប្រព្រឹត្ត នឹងរៀបរាប់នៅក្នុងផ្នែក (២.៥-២.៧)។

### ២.៣.១ ព័ត៌មានទាក់ទងនឹងសាវតាររបស់ជនជាប់ចោទ

១១២. ជនជាប់ចោទកើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅខេត្តកំពង់ធំ ក្នុងគ្រួសារកសិករក្រីក្រ និងមានដើមកំណើតជាជនជាតិចិន។ គាត់គឺជាកូនច្បង និងជាកូនប្រុសទោលក្នុងចំណោមបងប្អូនប្រាំនាក់។ គាត់គឺជាសិស្សល្អម្នាក់ ហើយបានបញ្ចប់ការសិក្សារបស់គាត់ជាបន្តបន្ទាប់នៅអនុវិទ្យាល័យកំពង់ធំ នៅវិទ្យាល័យសៀមរាប និងនៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ជាកន្លែងដែលគាត់ទទួលបានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ[១៨៤]។ ជនជាប់ចោទបានចូលរួមជាមួយខ្មែរក្រហមនៅខែតុលា ឆ្នាំ១៩៦៤។ ក្រោយពីបញ្ចប់ការសិក្សានៅឆ្នាំ១៩៦៥ គាត់ត្រូវបានតែងតាំងជាគ្រូបង្រៀនគណិតវិទ្យា

---

[១៨៣] *សូមមើលជាទូទៅ* ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង); "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1។

[១៨៤] "ផ្នែកទី៣ ៖ ព័ត៌មានទាក់ទងនឹងបុគ្គលិកលក្ខណៈ" ឯកសារE5/11/6.2 កថាខណ្ឌ ៣៣០, ៣៣១, ៣៣៥, ៣៣៧។

នៅវិទ្យាល័យស្គន់ ខេត្តកំពង់ចាម[១៨៥]។ គាត់បានចាប់ផ្តើមចូលបម្រើចលនាបដិវត្តកាន់តែស៊ីបទៅៗ ហើយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៦៧ គាត់បានបោះបង់ចោលការងារជាគ្រូគណិតវិទ្យា ដើម្បីចូលរួមការតស៊ូនៅក្នុងព្រៃ[១៨៦]។

១១៣. ជនជាប់ចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦៨ និងត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ពីបទបង្កគ្រោះថ្នាក់ដល់សន្តិសុខជាតិ[១៨៧]។ ក្រោយពីការឃុំខ្លួនគាត់នៅទួលគោក និងក្រុងភ្នំពេញ ជនជាប់ចោទត្រូវបានគេបញ្ជូនទៅគុកឃោធានៅព្រៃស ក្នុងខែឧសភា ឆ្នាំ១៩៦៨ ដែលនៅទីនោះជនជាប់ចោទបានឃើញការសម្លាប់ និងការធ្វើទារុណកម្មក្រៅច្បាប់ ប៉ុន្តែគាត់មិនបានទទួលរងនូវការធ្វើទារុណកម្មបែបនោះទេ[១៨៨]។ ក្រោយមកជនជាប់ចោទត្រូវបានចូលជាសមាជិកពេញសិទ្ធិនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា[១៨៩] ហើយគាត់បានជ្រើសរើសយកឈ្មោះ "ឌុច" ជាឈ្មោះបដិវត្តរបស់គាត់[១៩០]។

១១៤. ក្រោយពីរដ្ឋប្រហារដែលដឹកនាំដោយ លន់ នល់ ប្រឆាំងនឹងសម្តេច នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ជនជាប់ចោទត្រូវបានដោះលែងចេញពីគុកនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៧០ នៅពេលនោះហើយ ដែលគាត់បានចាប់ផ្តើមបន្តនូវសកម្មភាពរបស់គាត់ក្នុងនាមជាខ្មែរក្រហម[១៩១]។

---

[១៨៥] "ផ្នែកទី៣៖ ព័ត៌មានទាក់ទងនឹងបុគ្គលិកលក្ខណៈ" ឯកសារ E5/11/6.2 កថាខណ្ឌ៣៣៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ (ទេព សែម) ទំព័រ៣០-៤០។ "ពេជ្ឈឃាដបាត់ខ្លួន" (សៀវភៅ) ដោយ Nic DUNPOP ឯកសារ E160.1 ទំព័រ៤៨-៥០, ERN (ភាសាខ្មែរ) 00370329-00370331។

[១៨៦] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៤។

[១៨៧] ប្រតិចារឹក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤០។

[១៨៨] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ២៦-៣៤។

[១៨៩] អង្គជំនុំជម្រះកត់សម្គាល់ថា មានភាពស៊ីសង្វាក់គ្នាមួយចំនួនទាក់ទងនឹងកាលបរិច្ឆេទពិតប្រាកដ ដែលជនជាប់ចោទត្រូវបានគេបញ្ចូលជាសមាជិកបក្ស។ *ប្រៀបធៀបនឹង* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-២៩ *នឹង* ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១។

[១៩០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៦-៣៩។

[១៩១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤០ ។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ១៤-១៥, ២៨-៣០។

២.៣.២ មន្ទីរម១៣

១១៥. នៅខែកក្កដា ឆ្នាំ១៩៧១ ជនជាប់ចោទបានទទួលភារកិច្ចគ្រប់គ្រងមន្ទីរម១៣[១៥២] ដែលជាមន្ទីរសន្តិសុខសម្រាប់សួរចម្លើយជនទាំងឡាយណាដែលត្រូវបានគេសង្ស័យថាជា "គិញ" ឬខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា[១៥៣]។ ក្នុងតួនាទីជាប្រធានមន្ទីរម១៣ ដំបូង ជនជាប់ចោទបានបំពេញការងារក្រោមការបញ្ជារបស់ វន វេត ចាប់ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧១ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ និងក្រោយមកក្រោមការបញ្ជារបស់ សុន សេន រហូតដល់ខែមករា ឆ្នាំ១៩៧៥[១៥៤]។

១១៦. ជនជាប់ចោទបានចែកមន្ទីរម១៣ ជាពីរផ្នែកដាច់ដោយឡែកពីគ្នា។ មន្ទីរម១៣"ក" ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ជនជាប់ចោទ ហើយមន្ទីរម១៣"ខ" ស្ថិតក្រោមការគ្រប់គ្រងរបស់អនុប្រធានរបស់គាត់។ ជនទាំងឡាយដែលបញ្ជូនមកមន្ទីរម១៣"ក" ត្រូវបានគេសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់។ ចំណែកមនុស្សដែលបញ្ជូនមកមន្ទីរម១៣"ខ" អាចគ្រាន់តែជាអ្នកដែលត្រូវ "អប់រំ" និងដោះលែងទៅវិញ[១៥៥]។

១១៧. ក្នុងនាមជាប្រធានមន្ទីរម១៣ ជនជាប់ចោទទទួលខុសត្រូវក្នុងការធានាអំពីការអនុវត្តគោលនយោបាយនៃការសួរចម្លើយ និង "កម្ទេច" អ្នកជាប់ឃុំនៅមន្ទីរម១៣ "ក"។ ជនជាប់ចោទបានជ្រើសរើសបុគ្គលិករួមទាំងក្មេងជំទង់ៗក្នុងចំណោមកូនកសិករ និងបានបណ្តុះបណ្តាលក្មេងៗទាំងនោះអំពី

---

[១៥២] ព្រឹត្តិហេតុដែលទាក់ទងនឹងមន្ទីរម១៣ មិនស្ថិតនៅក្នុងយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក ទេ។ *សូមមើល* មាត្រា ២(ថ្មី) នៃច្បាប់ អ.វ.ត.ក (យុត្តាធិការរបស់ អ.វ.ត.ក កំណត់ត្រឹមតែបទឧក្រិដ្ឋទាំងឡាយណាដែលប្រព្រឹត្តឡើង "នៅក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"។ ដោយយល់ឃើញថា នៅក្នុងលក្ខណៈជាច្រើន ម១៣ ជាមន្ទីរដែលកើតមុនមន្ទីរស២១ អង្គជំនុំជម្រះស្តាប់សក្ខីកម្មដែលទាក់ទងនឹងដំណើរការរបស់មន្ទីរម១៣ និងតួនាទីរបស់ជនជាប់ចោទនៅមន្ទីរម១៣។

[១៥៣] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦, ៤៩-៥១។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០៩ (ចាន់ ខន) ទំព័រ៦៨។

[១៥៤] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៦។

[១៥៥] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨, ៥៣-៥៤, ៦០។ ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៣, ១០-១១, ១៧-១៩, ៧០-៧១, ៧៧-៧៨។

វិធីសាស្ត្រនៃការសួរចម្លើយ[១៩៦]។ គាត់បានត្រួតពិនិត្យការសួរចម្លើយអ្នកជាប់ឃុំនៅមន្ទីរម១៣ "ក" ដែលជារឿយៗ បុគ្គលិករបស់គាត់បានប្រើអំពើហិង្សា[១៩៧] ជាទូទៅគឺវាយនឹងគល់ឫស្សី[១៩៨]។ ចម្លើយសារភាពរបស់អ្នកជាប់ឃុំត្រូវបានជនជាប់ចោទបញ្ជូនទៅថ្នាក់លើរបស់គាត់ ទោះបីជាគាត់សង្ស័យថាព័ត៌មានជាច្រើននៅក្នុងចម្លើយសារភាពជាព័ត៌មានប្រឌិតក៏ដោយ។ នៅពេលដែលគាត់យល់ថាការសួរ-ចម្លើយអ្នកជាប់ឃុំចប់សព្វគ្រប់ហើយ គាត់បានបញ្ជាឲ្យសម្លាប់អ្នកជាប់ឃុំទាំងនោះចោល[១៩៩]។ អ្នក-ជាប់ឃុំនៅមន្ទីរម១៣"ក" បានស្លាប់ដោយសារតែស្ថានភាពនៃការឃុំខ្លួន ដែលរួមមានការអត់អាហារ ការខ្វះការថែទាំវេជ្ជសាស្ត្រ និងទឹកជំនន់ជន់លិចរណ្ដៅឃុំឃាំង[២០០]។

១១៨. បទពិសោធន៍របស់ជនជាប់ចោទនៅមន្ទីរម១៣ បានធ្វើឲ្យគាត់មានសមត្ថភាពបំពេញការងារជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១[២០១]។ ជាពិសេស គាត់បានប្រើប្រាស់វិធីសាស្ត្រ និងគោលនយោបាយ ដូចគ្នាជាច្រើននៅក្នុងការបំពេញការងាររបស់គាត់ទាំងនៅមន្ទីរម១៣ "ក" និងមន្ទីរ

---

[១៩៦] ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-២១, ៣៨-៣៩, ៤៩-៥២, ៧១-៧២, ៨៣-៨៤។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៣, ៧-៨ ។

[១៩៧] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤, ១៦-១៧។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ (François BIZOT) ទំព័រ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ (ចាន់ ខន) ទំព័រ៧៤។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ (ចាន់ ខន) ទំព័រ១៦-១៧។

[១៩៨] ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៨-៤៩។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩ (អ៊ុច ស៊ិន) ទំព័រ៤៩។

[១៩៩] ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦-១៩, ៦២-៦៤។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែមេសាឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៦-៧៧។

[២០០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨, ៥៩-៦០, ៦៧-៦៩។

[២០១] "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៣៥, ២០២។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៩-៤០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤១-៤៣។

ស២១ ដែលរួមបញ្ចូលទាំងការប្រើប្រាស់ការធ្វើទារុណកម្មនៅក្នុងអំឡុងពេលសួរចម្លើយ[២០២] ការជ្រើសរើសបុគ្គលិក និងការបំពាក់បំប៉នមនោគមវិជ្ជាដល់ក្មេងជំទង់ៗដែលជាសមាជិក[២០៣] និងការសម្លាប់អ្នកជាប់ឃុំជាប្រព័ន្ធក្រោយពីបញ្ចប់ការសួរចម្លើយពួកគេ[២០៤]។ បន្ថែមពីលើនេះ បុគ្គលិករបស់ជនជាប់ចោទជាច្រើននាក់ដែលមកពីមន្ទីរម១៣ បានធ្វើការជាមួយគាត់នៅមន្ទីរស២១ ដែលពួកគេបន្តបម្រើការងារជាអ្នកក្រោមបង្គាប់របស់ជនជាប់ចោទ[២០៥]។

### ២.៣.៣ មន្ទីរស២១

#### ២.៣.៣.១ ការបង្កើតមន្ទីរស២១

១១៩. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ២០.នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ សុន សេន បានកោះហៅ ឌុច និង អ៊ិន លន ហៅ ណាត មកពីកងពលធំ៧០៣ នៃកងទ័ពបដិវត្តន៍កម្ពុជាឲ្យទៅប្រជុំនៅស្ថានីយរថភ្លើងក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីរៀបចំផែនការបង្កើតមន្ទីរ ស២១។ នៅក្នុងដីកាដំណោះស្រាយនេះ ពាក្យ ស២១ រាប់បញ្ចូលនូវមន្ទីរឃុំឃាំងទួលស្លែង និងបរិវេណជុំវិញ (ដែលតទៅនេះហៅថា៖ "ទួលស្លែង") ព្រមទាំងទីកន្លែងសម្រាប់សម្លាប់អ្នកទោស និងជំរំអប់រំកែប្រែនៅឯជាយក្រុងភ្នំពេញ គឺជើងឯក និងព្រៃស ឬហៅថា ស២៤ ផងដែរ។ ក្នុងចំណោមមន្ទីរសន្តិសុខនានា មានតែមន្ទីរ ស២១ តែមួយគត់ ដែលមានលក្ខណៈពិសេស ដោយសារមានទំនាក់ទំនងផ្ទាល់ជាមួយនឹង

---

[២០២] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៣៥ និង ២០២។ ប្រតិចារឹក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥២។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៩។

[២០៣] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨-៦៩។

[២០៤] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៥-៥៧។

[២០៥] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។

គណៈកម្មាធិការមជ្ឈិម និងមានតួនាទីក្នុងការឃុំខ្លួន និងការសម្លាប់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា។

២១.សុន សេន បានតែងតាំង ណាត ជាប្រធានមន្ទីរ ស២១ និងជាលេខាគណៈកម្មាធិការរបស់មន្ទីរនេះ[២០៦] ហើយ ឌុច ជាអនុប្រធានទទួលបន្ទុកក្រុមអ្នកសួរចម្លើយ។ ក្រោយពីកិច្ចប្រជុំនោះមក ឌុច បាននាំអតីតបុគ្គលិកមន្ទីរ ម១៣ មួយចំនួន មកទីក្រុងភ្នំពេញដើម្បីចូលរួមជាមួយកម្លាំងកងពលធំ៧០៣ ដែលធ្លាប់បានធ្វើប្រតិបត្តិការប្រឆាំងនឹងអាជ្ញាធររបប លន់ នល់។ មន្ទីរ ស២១ បានចាប់ធ្វើប្រតិបត្តិការពេញលេញ ក្នុងខែតុលា ឆ្នាំ១៩៧៥។

១២០. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្ដីថ្លែងទាំងនេះ ប៉ុន្តែគាត់បានជំទាស់ទៅនឹងការលើកឡើងថា មន្ទីរស២១អាចចាត់ទុកថាជាមន្ទីរ "តែមួយគត់ដែលមានលក្ខណៈពិសេស"[២០៧]។

១២១. ជនជាប់ចោទបានបន្តស្ថិតនៅក្នុងទីក្រុងភ្នំពេញ ក្រោយពីកិច្ចប្រជុំនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ និងបានប្រមូលឯកសារជាច្រើនពីស្ថាប័ននានានៃអតីតរដ្ឋាភិបាល លន់ នល់។ នៅខែតុលា ឆ្នាំ១៩៧៥ ជនជាប់ចោទក្នុងនាមជាអនុប្រធានរបស់ អ៊ិន លន ហៅ ណាត បានបង្កើត និងចាប់ផ្ដើមគ្រប់គ្រងអង្គភាពសួរចម្លើយនៃមន្ទីរស២១[២០៨]។

១២២. ជនជាប់ចោទបានបញ្ជាក់ថា ពីដើមឡើយ គាត់រារែកមិនចង់ទទួលតួនាទីជាអនុប្រធានមន្ទីរស២១នោះទេ ហើយគាត់បានព្យាយាមសុំទៅបម្រើការងារនៅក្រសួងឧស្សាហកម្មជំនួសវិញ។ នៅពេលដែលសំណើនេះត្រូវបានបដិសេធ ជនជាប់ចោទមិន "ហ៊ាន" ប្រឆាំងនឹងការចាត់តាំងនេះឡើយ

---

[២០៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ២០-២១ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[២០៧] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៣៣។

[២០៨] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៥-៥៧។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤-៦។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧" ឯកសារ E3/23, ERN (ភាសាខ្មែរ) 00146478-00146479។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧" ឯកសារ E3/15, ERN (ភាសាខ្មែរ) 00153566។

ពីព្រោះតាមពាក្យសំដីរបស់គាត់ "ការងាររបស់ខ្ញុំផ្សេង ការងារគេផ្សេង"[២០៩]។ គាត់បានរៀបការនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៥ ដោយមានការឯកភាពពីថ្នាក់លើរបស់គាត់ ហើយគាត់មានកូនចំនួន៤នាក់ ដែលក្នុងនោះកូនពីរនាក់បានចាប់កំណើតនៅពេលដែលគាត់គ្រប់គ្រងមន្ទីរស២១[២១០]។

### ២.៣.៣.២ ទីតាំងដំបូងរបស់មន្ទីរស២១

១២៣. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ២៦. ដំបូងឡើយ បរិវេណមន្ទីរ ស២១ ស្ថិតនៅទីក្រុងភ្នំពេញក្នុងសង្កាត់បឹងកេងកង ៣ (ខណ្ឌចំការមន) ចំណែកឯមន្ទីរឃុំឃាំង និងសួរចម្លើយស្ថិតនៅក្នុងផ្ទះមួយប្លុក ត្រង់កាច់ជ្រុងផ្លូវលេខ១៦៣ និងលេខ៣៦០។ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ មន្ទីរ ស២១ បានរើទៅអគ្គស្នងការដ្ឋាននគរបាលជាតិតាមបណ្ដោយផ្លូវ៥១ (ផ្លូវប៉ាស្ទ័រ) ជិតផ្សារថ្មី។ ក៏ប៉ុន្តែក្នុងខែមករា ឆ្នាំ១៩៧៦ បានរើត្រឡប់មកទីតាំងចាស់វិញ[២១១]។

១២៤. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្តីថ្លែងទាំងនេះ[២១២]។

---

[២០៩] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៩-៣០, ៣១-៣២។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៣៥។

[២១០] "ផ្នែកទី៣ ៖ ព័ត៌មានទាក់ទងនឹងបុគ្គលិកលក្ខណៈ" ឯកសារE5/11/6.2 កថាខណ្ឌ ៣៤១, ៣៤២។ ជនជាប់ចោទបានពន្យល់ថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏នៅក្រោយរបបនេះភ្លាមៗ ប្អូនថ្លៃប្រុសរបស់គាត់ពីរនាក់ ត្រូវបានគេបោសសម្អាត ដែលម្នាក់ក្នុងចំណោមអ្នកទាំងពីរត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរស២១។ ប្អូនស្រីពីរនាក់ និងក្មួយប្រុស-ស្រី ចំនួនប្រាំមួយនាក់របស់គាត់ ក៏ត្រូវស្លាប់ដែរ (ប្រតិចារឹក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ), ទំព័រ ៣៤ និង ៣៥។

[២១១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ២៦ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[២១២] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៤-៤៦, ៤៧-៤៨។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៦-៥៧។ ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០, ១៤-១៦។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៣-៣៥។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៧។

00573411



### ២.៣.៣.៣ ការតែងតាំង និងតួនាទីជាអនុប្រធានមន្ទីរស២១

១២៥. ក្នុងនាមជាអនុប្រធានមន្ទីរ ស២១ ជនជាប់ចោទទទួលខុសត្រូវអង្គភាពសួរចម្លើយ ដែលមានអតីតអ្នកក្រោមបង្គាប់របស់គាត់មកពីមន្ទីរម១៣ ប្រហែល២០នាក់ និងសមាជិកមួយចំនួនទៀតនៃកងទ័ពបដិវត្តកម្ពុជាដែលមកពីកងពលធំ ៧០៣[២១៣]។ អ្នកជាប់ឃុំត្រូវបាននាំពីមន្ទីរពេទ្យឆ្កតតាខ្មៅទៅអង្គភាពសួរចម្លើយនៃមន្ទីរស២១។ អ៊ិន លន ហៅ ណាត និងបុគ្គលិកកងពលធំ ៧០៣ របស់គាត់បានប្រែក្លាយមន្ទីរពេទ្យឆ្កួតតាខ្មៅទៅជាមន្ទីរឃុំឃាំងមួយ[២១៤]។

១២៦. ក្នុងនាមជាប្រធានអង្គភាពសួរចម្លើយ ជនជាប់ចោទមានតួនាទីសំខាន់ចំនួនបួន៖ (i) ចងក្រងឯកសារដែលប្រមូលបានពីស្ថាប័នរបស់រដ្ឋាភិបាល លន់ នល់ (ii) រៀបចំរបាយការណ៍ឲ្យថ្នាក់លើរបស់គាត់ដោយផ្អែកតាមឯកសារទាំងនេះ (iii) បង្រៀនអំពីវិធីសាស្ត្រនៃការសួរចម្លើយដល់បុគ្គលិកនៃអង្គភាពសួរចម្លើយ និង (iv) រាយការណ៍អំពីចម្លើយសារភាពរបស់អ្នកជាប់ឃុំទៅថ្នាក់លើ[២១៥]។

១២៧. ជនជាប់ចោទបានទទួលស្គាល់ថា ក្នុងនាមគាត់ជាអនុប្រធានមន្ទីរស២១ គាត់បានអនុញ្ញាតឲ្យអ្នកសួរចម្លើយប្រើប្រាស់ការធ្វើទារុណកម្ម[២១៦]។ ក្រោយពីបញ្ចប់ការសួរចម្លើយសព្វគ្រប់ហើយ ជនជាប់ចោទក៏បានដឹងថា អ្នកជាប់ឃុំត្រូវបានគេយកចេញ និងសម្លាប់ចោល[២១៧]។

---

[២១៣] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១២។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥២។

[២១៤] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៥-៥៧, ៦១-៦២។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៩, ១២-១៤។

[២១៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៩-៣០។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥១។

[២១៦] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៥។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៥-៣៦។

[២១៧] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៣-៦៤។

## ២.៣.៣.៤ ការតែងតាំង និងតួនាទីជាប្រធានមន្ទីរស២១

១២៨. កថាខណ្ឌ២២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ២២. នៅក្នុងខែមីនា ឆ្នាំ១៩៧៦ ណាតត្រូវបានផ្លាស់ទៅសេនាធិការ ហើយតួនាទីជាប្រធាន និងជាលេខាមន្ទីរ ស២១ របស់ណាតត្រូវបានធ្លាក់ទៅលើឌុច។ ឌុច បានរក្សាទុកនូវតួនាទីជាអនុប្រធានទទួលបន្ទុកប្រតិបត្តិការប្រចាំថ្ងៃរបស់ យឹម វ៉ាត [វ៉ាក] ហៅហ៊ ដែលជាអតីតកម្មាភិបាលកងពលធំ ៧០៣ ឲ្យនៅដដែល។ ទោះជាយ៉ាងដូច្នេះ ឌុចបានសារភាពថា គាត់បានបន្តមើលខុសត្រូវដោយខ្លួនឯងផ្ទាល់ទៅលើការសួរចម្លើយអ្នកទោសសំខាន់ៗ និង ជាចុងក្រោយព្រមទទួលខុសត្រូវគ្រប់យ៉ាងចំពោះរាល់អ្វីៗដែលបានកើតឡើងក្នុងមន្ទីរ ស២១។ សមាជិកទីបីនៃគណៈកម្មាធិការ មន្ទីរ ស២១ មានឈ្មោះថា នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ [...][២១៨]។

១២៩. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្ដីថ្លែងទាំងនេះ[២១៩]។

១៣០. ជនជាប់ចោទបានលើកឡើងថា គាត់បានសុំ សុន សេន ដែលជាថ្នាក់លើរបស់គាត់ តែងតាំងអតីតគ្រូបង្រៀនរបស់គាត់ឈ្មោះ ឆាយ គឹមហ៊ា ជំនួស អ៊ិន លន ហៅ ណាត ក្នុងនាមជាប្រធានមន្ទីរ ស២១។ នៅពេលសំណើនេះត្រូវបានបដិសេធ ជនជាប់ចោទលែងតវ៉ាចំពោះការតែងតាំងនេះទៀតហើយ ហើយគាត់បានចាប់ផ្ដើមបម្រើការងារជាប្រធានមន្ទីរស២១ នៅខែមីនា ឆ្នាំ១៩៧៦។ យោងតាមជនជាប់ចោទ គាត់ត្រូវបានតែងតាំងជំនួស ណាត ដោយសារតែគាត់ "ស្មោះត្រង់នឹងថ្នាក់លើរបស់គាត់" ចំណែកណាត និងបុគ្គលិកកងពលធំ ៧០៣ មិនត្រូវបានគេជឿទុកចិត្តនោះទេ។ ជនជាប់-

---

[២១៨] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ២២ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[២១៩] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។ *សូមមើលផងដែរ* "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1, កថាខណ្ឌ៣៤-៣៧។

ចោទក៏បានចាត់ទុកខ្លួនឯងថាជាអ្នកសួរចម្លើយពូកែជាងណាត ដោយសារតែបទពិសោធន៍របស់គាត់ក្នុងពេលបំពេញការងារនៅមន្ទីរម១៣[២២០]។

១៣១. ជនជាប់ចោទបានបញ្ជាក់ថា ក្នុងនាមជាប្រធានមន្ទីរស២១ គាត់បានរាយការណ៍ទៅ សុន សេន ចាប់ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ នៅពេល សុន សេន ត្រូវបានបញ្ជូនឲ្យទៅទទួលភារកិច្ចក្នុងការបញ្ជាកងទ័ពបដិវត្តកម្ពុជាដោយផ្ទាល់ នៅពេលដែលមានការកើនឡើងនូវអរិភាពជាមួយប្រទេសវៀតណាម និងក្រោយមកជនជាប់ចោទរាយការណ៍ទៅ នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាវិញ[២២១]។

១៣២. ស្របពេលជាមួយនឹងការតែងតាំងជាប្រធានមន្ទីរស២១ ជនជាប់ចោទក៏មានតួនាទីជាលេខារបស់គណៈកម្មាធិការមន្ទីរស២១[២២២] ផងដែរ។ ក្នុងនាមជាប្រធាន និងជាលេខា ជនជាប់ចោទមានអំណាចពេញលេញលើបុគ្គលិកមន្ទីរស២១ទាំងអស់ ដែលរួមទាំងសមាជិកពីររូបផ្សេងទៀតរបស់គណៈកម្មាធិការ មន្ទីរស២១ គឺ យឹម វ៉ាក ហៅ ហ៊ី និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ[២២៣]។ តួនាទីរបស់ជនជាប់ចោទក្នុងនាមជាប្រធានមន្ទីរស២១ ដែលមិនត្រូវបានគេជំទាស់ ត្រូវបានបញ្ជាក់ដោយចម្លើយ

---

[២២០] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៩-៧២។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០, ៤៥។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៩។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ៣៥។

[២២១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៧-៤៨។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧" ឯកសារ E3/23, ERN (ភាសាខ្មែរ) 00146480-00146481។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៦៣-៦៤។

[២២២] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៩-៦១។

[២២៣] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥១។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៣-៣៥, ៥៨។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ១៥-១៧, ៤៩-៥០។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៧-៤៨។

សារភាពរបស់ជនជាប់ចោទខ្លួនឯង សក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងឯកសារផ្សេងៗដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី[២២៤]។

[២២៤] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៥, ៤៨។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ២៩-៣០ (“ចំពោះការដែលយកអ្នកទោសចេញ គឺអ្នកទោសចូលគឺទាល់តែមានការអនុញ្ញាតពី ឌុច ដែលជាប្រធានរបស់មន្ទីរស-២១។ គឺអ្វីៗទាំងអស់អ្នកដែលធ្វើគឺគ្មានសិទ្ធិអ្វីទាំងអស់ទាល់តែមានបញ្ជាពី ឌុច បានអ្វីៗធ្វើទៅកើត”)។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ)ទំព័រ៣៤ (“បាទ, ខ្ញុំសុំជម្រាបថានៅស-២១ នេះ គឺអ្នកធំជាងគេគឺ ឌុច អ៊ីចឹងមានតែគាត់ទេអ្នកបញ្ជាចាប់ខ្លួនបាន”)។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥ (“ពេលដែលអ្នកទោសយកទៅជើងឯកហ្នឹង តាឌុច អត់បានមកឈរមើលទេ តែឈ្មោះដែលអ្នកត្រូវយកទៅហ្នឹង គឺគាត់អ្នកសម្រេច អ្នកបញ្ជាឲ្យគេឲ្យគេដឹកយកទៅ”) ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៨ (“បាទ, នៅ ស-២១ នេះគ្មាននរណាបញ្ជា[ជនជាប់ចោទ]ទេ មានតែគាត់បញ្ជាគេ [...] គាត់ធ្វើបានទាំងអស់ ព្រោះកន្លែងហ្នឹងសេចក្ដីសម្រេច គឺនៅលើគាត់ធំជាងគេ គឺគាត់ហើយ បាទ”) ។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៣ (“បាទ, ស-២១ គឺ តាឌុច ប្រធានធំជាងគេ បន្ទាប់មកបង ហ៊ី ខ្វាក់ភ្នែកម្ខាង ហើយបានបង ហ៊ុយ សមាជិកនៅធ្វើស្រែព្រៃសហ្នឹង”) ។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៩ (“ជាបុគ្គលមួយរូបទទួលខុសត្រូវស-២១ ឌុច ធ្វើការងារយ៉ាងហ្មត់ចត់នៅក្នុងការដឹកនាំប្រតិបត្តិការស-២១”) ។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៦១, (“ស-២១ ជាទីតាំងរបស់[ជនជាប់ចោទ] គាត់ធំជាងគេនៅទីនោះ”)។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៥ (“ជាវិន័យនៅកន្លែងហ្នឹង គឺធម្មតាអ្នកទោសយកមក គឺអត់មានសិទ្ធិ ធ្វើទារុណកម្មមុនទេ ទាល់តែសួរដេញដោលអស់ចិត្តអស់ចង់ហើយ បានមានរបាយការណ៍ឲ្យទៅ ឌុច។ ទាល់តែ ឌុច មានបទបញ្ជាមកថា បើសួរមិនចេញត្រូវធ្វើទារុណកម្មខ្លះធ្វើទៅ អាហ្នឹងបានហ៊ានធ្វើ”)។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ដន) ទំព័រ១២ (“ខ្ញុំថាមានតែឈ្មោះ ឌុច ហ្នឹងឲ្យចាប់តែពេទ្យចាស់ៗ ពេទ្យធំៗ”) ។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ១៨ (“ដែលគេប្រជុំហ្នឹងៗ គេមានផែនការចេញមកពីតែបង ឌុច ទេ។ បើថាខុសពី បងឌុច មិនដឹងថាមានផែនការពីណាដែរ បន្តៗគ្នាមក តាមតា ហ៊ី តាមបង ហ៊ុយ ស្រែ ហ្នឹងទេ”) ។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ចៀម សឿ) ទំព័រ៣៧ (“បាទ, ខ្ញុំសូមជម្រាប! ច្បាប់នៅ តាឌុច គាត់ដាក់ផែនការមក្រោមៗ។ ប៉ុន្តែ ដូចកាលគាត់ទទួលពីផែនលើមក ខ្ញុំអត់ដឹង ប៉ុន្តែឃើញគាត់ដាក់បញ្ជាឲ្យកូនចៅក្រោមៗហ្នឹង សម្លាប់គេ។ ក៏ចំណែកគាត់អត់មានឃើញថា សម្លាប់គេដែរទេ។ ប៉ុន្តែ ច្បាប់នេះ គាត់ដាក់ក្រោមបទបញ្ជាថា យប់ៗ ថ្ងៃៗ។ ហ្នឹងដូចពាក្យថា បញ្ជាដូចជាសម្លាប់អ៊ីចឹង”)។ “កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩” ឯកសារ E3/17, ERN (ភាសាខ្មែរ) 00154228-00154229 ។

១៣៣. អនុប្រធានរបស់ជនជាប់ចោទឈ្មោះ ឃឹម វ៉ាក ហៅ ហ៊ី បានទទួលភារកិច្ចគ្រប់គ្រងដំណើរការប្រចាំថ្ងៃរបស់មន្ទីរស២១ និងត្រួតពិនិត្យមើលការងាររបស់កងការពារ និងអ្នកសួរចម្លើយនៅមន្ទីរស២១។ ជនជាប់ចោទបានប្រើ ហ៊ី ព្រមទាំងជំនួយការរបស់គាត់ផ្ទាល់ ដោយចេញបញ្ជាទៅបុគ្គលិកមន្ទីរស២១[២២៥]។ ជនជាប់ចោទបានជួបជាមួយ ហ៊ី ជារឿយៗដើម្បីទទួលព័ត៌មានអំពីសកម្មភាពថ្មីៗ ហើយគាត់បានបញ្ជាក់ថា "គាត់[ជនជាប់ចោទ]បានដឹងយ៉ាងច្បាស់នូវកិច្ចការប្រតិបត្តិ-ការប្រចាំថ្ងៃនូវអ្វីដែលបានកើតឡើងនៅមន្ទីរស២១"[២២៦]។

១៣៤. ជនជាប់ចោទកម្រជួបជាមួយសមាជិកទីបីរបស់គណៈកម្មាធិការមន្ទីរស២១ ឈ្មោះ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាអ្នកគ្រប់គ្រងដំណើរការរបស់ ស២៤[២២៧] ។

### ២.៣.៣.៤.១ ការផ្លាស់ប្តូរទីតាំងមន្ទីរស២១

១៣៥. ជនជាប់ចោទបានយល់ស្របថា នៅខែមេសា ឆ្នាំ១៩៧៦ តាមសេចក្តីសម្រេចរបស់គាត់ អ្នក-ជាប់ឃុំនៅមន្ទីរស២១ ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ដែលមានទីតាំងស្ថិតនៅចន្លោះផ្លូវលេខ១១៣, ១៣១, ៣២០ និង៣៥០ ក្នុងទីក្រុងភ្នំពេញ។ មន្ទីរស២១ បានដំណើរការនៅលើទីតាំងនេះរហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាបរិវេណនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃនេះ[២២៨]។ សេចក្តីសម្រេចឲ្យផ្លាស់ប្តូរទីតាំងដែលត្រូវបាន

---

[២២៥] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២៣។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៥-៥៦។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ១៥-១៨។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ១៣-១៤, ២១-២២។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤-៧, ១២-១៣។

[២២៦] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។

[២២៧] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៧។ *សូមមើលផងដែរ*ផ្នែក (២.៣.៣.៧)។

[២២៨] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៥-៤៦, ៤៧-៤៨។

យល់ព្រមដោយ សុន សេន ដែលជាថ្នាក់លើរបស់ជនជាប់ចោទ មានគោលបំណងជួយសម្រួលដល់ការសួរចម្លើយអ្នកជាប់ឃុំ និងការពារមិនឲ្យមានការលួចរត់[២២៩]។

១៣៦. ក្រោយពីមានការផ្លាស់ប្តូរទីតាំងមន្ទីរស២១ ភាពសម្ងាត់នៃប្រតិបត្តិការរបស់មន្ទីរស២១ បានក្លាយជាចំណុចសំខាន់បំផុត[២៣០]។ បុគ្គលិកមន្ទីរស២១ មិនត្រូវបានអនុញ្ញាតឲ្យដើរហើរដោយសេរី ឬទំនាក់ទំនងជាមួយអ្នកផ្សេងទៀតនៅខាងក្រៅបរិវេណដោយគ្មានការអនុញ្ញាតឡើយ[២៣១]។

១៣៧. អគារនៃវិទ្យាល័យពញាយ៉ាតនៅពេលនោះ (ដែលបានបង្ហាញក្នុងពេលសវនាការគឺសំដៅទៅលើអគារ ក ដល់ ខ) បានប្រែក្លាយទៅជាកន្លែងដែលប្រើប្រាស់សម្រាប់គោលបំណងរបស់មន្ទីរស២១[២៣២]។ ជាពិសេស អ្នកជាប់ឃុំ ត្រូវបានសួរចម្លើយនៅអគារ ក និងត្រូវបានឃុំខ្លួននៅអគារ ខ គ និង ឃ។ អ្នកជាប់ឃុំភាគច្រើន ត្រូវបានដាក់នៅតាមបន្ទប់ឃុំឃាំងរួមគ្នា ដែលក្រៅពីបន្ទប់ទាំងនេះ ជនជាប់ចោទបានបញ្ជាឲ្យសាងសង់បន្ទប់ឃុំឃាំងដាច់ដោយឡែកសម្រាប់ដាក់អ្នកជាប់ឃុំខាន់ៗ[២៣៣]។

---

[២២៩] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤-៣៥។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧។

[២៣០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៣០-៣២។

[២៣១] ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៨០-៨១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥៦-៥៧។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ ចេស) ទំព័រ៥៥-៥៦។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ៤៩-៥០ និង ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ៧។ *សូមមើលផងដែរ* ប្រតិចារឹក "ការដាក់តម្កល់ការអត្ថាធិប្បាយជាភាសាខ្មែររបស់លោក កាំង ហ្កេកអ៊ាវ ស្តីពីសៀវភៅដែលមានចំណងជើងថា "S21 ou le crime impuni des Khmer rouges" ដោយលោក David Chandler ឯកសារ E108/1.1, ERN (ភាសាខ្មែរ) 00188745។

[២៣២] *សូមមើលជាទូទៅ* ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៥-៤៦, ៤៧-៤៨។សូមមើលផងដែរឧបសម្ព័ន្ធ (II)។

[២៣៣] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-២៦។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២។ *សូមមើលផងដែរ* ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩

អគារ ខ ត្រូវបានប្រើប្រាស់សម្រាប់ទុកដាក់ឯកសារ ថតរូបអ្នកជាប់ឃុំទើបចូលថ្មី និងជារោងជាងគូរផ្ទាំងក្រណាត់ដើម្បីផលិតសម្ភារៈបម្រើឲ្យការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា[២៣៤]។ ជនជាប់ចោទបានលើកឡើងថា ទោះបីជាគាត់បានទៅពិនិត្យមើលអគារ ខ ជាច្រើនលើកច្រើនសារក៏ដោយ ក៏គាត់មិនបានទៅពិនិត្យមើលអគារ ខ គ និង ឃ ទេ[២៣៥]។

១៣៨. បន្ថែមពីលើអគារដែលស្ថិតនៅក្នុងរបងនៃវិទ្យាល័យពញាយ៉ាត មន្ទីរស២១បានប្រើប្រាស់អគារជាច្រើនផ្សេងទៀតនៅក្បែរៗនោះ។ អគារទាំងនោះរួមមាន ផ្ទះសម្រាប់សួរចម្លើយ ទីកន្លែងសម្រាប់សម្លាប់ រោងបាយសម្រាប់បុគ្គលិកមន្ទីរស២១ កន្លែងដាក់ឱសថ ផ្ទះបុគ្គលិក ផ្ទះនិងការិយាល័យរបស់ជនជាប់ចោទ និងផ្ទះសម្រាប់ទទួលអ្នកទោស។ អគារទាំងអស់នេះ ស្ថិតនៅខាងក្នុងបរិវេណទីពីរ ដោយមានការយាមកាមពីអ្នកយាមដែលមានកាន់កាំភ្លើងផងដែរ[២៣៦]។

១៣៩. អ្នកជាប់ឃុំសំខាន់ៗរួមទាំងជនបរទេស និងអតីតបុគ្គលិកមន្ទីរស២១ ក៏ត្រូវបានសួរចម្លើយ និងឃុំខ្លួនផងដែរនៅក្នុងគុកពិសេស ដែលស្ថិតនៅខាងក្រៅរបងវិទ្យាល័យពញាយ៉ាត។ ក្រោយមក

---

(ប្រាក់ ខន) ទំព័រ៣៤។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៥-១៦, ២០ ។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ឯកសារE5/11/6.1 កថាខណ្ឌ ៤៨។

[២៣៤] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៩-៥០។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ ៦ ។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៧-២៨។

[២៣៥] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៩-៥០, ៦៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៥៩-៦១, ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៨-២៩។

[២៣៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៧-៤៨។ *សូមមើលផងដែរ* "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧" ឯកសារ E3/15, ERN (ភាសាខ្មែរ) 00153458-00153461, 00153467។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤-៥, ៤៩-៥០។(នៅក្នុងសំណៅជាភាសាខ្មែរ) អង្គជំនុំជម្រះសំដៅជារួមចំពោះអគារទាំងឡាយដែលស្ថិតនៅក្នុង ឬក្បែរទីតាំងវិទ្យាល័យពញាយ៉ាត ថាជា "មន្ទីរស២១ (ទួលស្លែង)"។

កន្លែងសួរចម្លើយទាំងនេះ ត្រូវបានផ្លាស់ទៅអគារ ត វិញ។ ជនជាប់ចោទបានទទួលស្គាល់ម្តងហើយម្តងទៀតអំពីការទៅមើលគុកពិសេសនេះ[២៣៧]។

### ២.៣.៣.៤.២ ទិដ្ឋភាពទូទៅរបស់អ្នកជាប់ឃុំនៅមន្ទីរស២១

១៤០. អ្នកជាប់ឃុំនៅមន្ទីរស២១ មានអតីតអ្នករដ្ឋការ និងទាហាននៃរបប លន់ នល់ យុទ្ធជនរបស់កងទ័ពបដិវត្តកម្ពុជា កម្មាភិបាលជាន់ខ្ពស់ និងជាន់ទាបនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជាជាច្រើន សមាជិកគ្រួសារ និងអ្នកដែលធ្លាប់មានទំនាក់ទំនងជាមួយអ្នកទាំងនោះ ស្ត្រី កុមារ ជនបរទេសមកពីប្រទេសនានា ជាពិសេសទាហាន និងជនស៊ីវិលវៀតណាម ព្រមទាំងបុគ្គលិកមន្ទីរស២១ និងសាច់ញាតិរបស់ពួកគេផងដែរ[២៣៨]។

១៤១. បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល បានបង្ហាញថា មានមនុស្សមិនតិចជាង១២.២៧៣នាក់ទេ ដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១[២៣៩]។ បញ្ជីនេះគឺជាការពិនិត្យឡើងវិញលើបញ្ជីដំបូង ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដោយបានបង្ហាញថាមានមនុស្សមិនតិចជាង ១២.៣៨០ នាក់ទេ ដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១[២៤០]។ បញ្ជីឈ្មោះ

---

[២៣៧] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៣។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៩-៥០, ៦៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១០-១១។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥-៦។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៧០-៧១។

[២៣៨] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៩, ២៤-២៥។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៩-៦០។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៧១។

[២៣៩] "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល" ឯកសារ E68.1 ។

[២៤០] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១០៧, ១៤០។ "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស២១ (១៩៧៥-១៩៧៨)" E3/38 ឧបសម្ព័ន្ធ ក។ ការិយាល័យសហព្រះរាជអាជ្ញាបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីនេះដែលបានមកពីបញ្ជីពីមុនៗដែលចងក្រងដោយ DC-Cam ដោយផ្អែកលើបញ្ជីអ្នកទោសដើម និងបញ្ជីសម្លាប់មន្ទីរស២១។ បញ្ជីឈ្មោះអ្នកទោស ស២១ ដែលរួមបញ្ចូលគ្នា មានឈ្មោះចំនួន១០៧ ដែលដូចគ្នា ហើយត្រូវបានដកចេញដោយ

អ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល មានឈ្មោះមនុស្សប្រុសចំនួន ៥.៩៩៤ នាក់ ស្រីចំនួន ១.៦៩៨ នាក់ និងកុមារចំនួន៨៩នាក់[២៤១]។ ឈ្មោះចំនួន៥.៦០៩ នាក់ គឺជាសមាជិករបស់កងទ័ពបដិវត្តកម្ពុជា និងឈ្មោះចំនួន ៤.៣៧១ នាក់ គឺជាកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ចំណែកឯឈ្មោះចំនួន ១.៧៥១ នាក់ មិនមែនជាសមាជិករបស់កងទ័ពបដិវត្តកម្ពុជា ឬកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យទេ[២៤២]។ លើសពីនេះទៀត បញ្ជីនេះមានឈ្មោះចំនួន ៨៧៦ នាក់ ជាសាច់ញាតិរបស់អ្នកផ្សេងទៀត[២៤៣]។ ឈ្មោះក្នុងបញ្ជីចំនួន៣២៨ នាក់ ជាទាហាននៃរបបសាធារណរដ្ឋខ្មែរ[២៤៤]។ ឈ្មោះចំនួន ២៧៩ នាក់ ជាគ្រូបង្រៀន សាស្ត្រាចារ្យ សិស្ស គ្រូពេទ្យ មេធាវី ឬវិស្វករ[២៤៥]។ ឈ្មោះចំនួន ៣៤៥ នាក់ ជាជនជាតិវៀតណាម ដែលក្នុងនោះមាន ១២២ នាក់ ត្រូវបានកំណត់អត្តសញ្ញាណថាជាទាហានវៀតណាម ១៤៤ នាក់ ជា "គិញ" វៀតណាម និងចំនួន ៧៩ នាក់ ជាជនស៊ីវិលវៀតណាម[២៤៦]។ ជាចុងក្រោយ បញ្ជីនេះមានឈ្មោះ ១៥៥ នាក់ ជាអតីតបុគ្គលិកមន្ទីរស២១ និង

---

ការិយាល័យសហព្រះរាជអាជ្ញាពីបញ្ជីអ្នកទោសដែលត្រូវបានកែសម្រួល។ *សូមមើល* "ញត្តិរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៩២ ស្នើសុំបង្ហាញជូននូវសេចក្ដីវិភាគលើបញ្ជីឈ្មោះអ្នកទោស ស២១ ដែលពិនិត្យឡើងវិញ" E68 ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៣-៥។

[២៤១] "បញ្ជីអ្នកទោសមន្ទីរស២១ បញ្ជាក់អត្តសញ្ញាណថាជាបុរស" ឯកសារ E68.5។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ បញ្ជាក់អត្តសញ្ញាណថាជាស្ត្រី" ឯកសារ E68.6។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ បញ្ជាក់អត្តសញ្ញាណថាជាកុមារ" ឯកសារ E68.7។

[២៤២] "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ មកពីកងទ័ពបដិវត្តកម្ពុជា" ឯកសារ E68.9។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ មកពីមន្ទីររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E68.10។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលមិនមែនមកពីកងទ័ពបដិវត្តកម្ពុជា ឬ មន្ទីររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E68.11។

[២៤៣] "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវកំណត់អត្តសញ្ញាណថាជាសាច់ញាតិរបស់អ្នកផ្សេងទៀត"។ ឈ្មោះដែលមានចំនួនច្រើនបំផុត មានអត្តសញ្ញាណជាប្រពន្ធ (៥៨៣) កូនស្រី (១១២) និងកូនប្រុស (១០៧) ព្រមទាំងប្ដី ម្ដាយ និងឪពុក។

[២៤៤] "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលបានរៀបរាប់ថាជាអតីតទាហានសាធារណរដ្ឋខ្មែរ" ឯកសារ E68.24។

[២៤៥] "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលបានរៀបរាប់ថាជា គ្រូបង្រៀន សាស្ត្រាចារ្យ សិស្ស ពេទ្យ មេធាវី ឬ វិស្វករ" ឯកសារ E68.26។

[២៤៦] "បញ្ជីឈ្មោះអ្នកទោសជនជាតិវៀតណាមដែលបានចាប់បញ្ជូនមកមន្ទីរស២១" ឯកសារ E68.27។ "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស២១ ដែលគេស្គាល់ថាជាកងទ័ពជាតិវៀតណាម" ឯកសារ E68.28។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១

ឈ្មោះចំនួន ៥៩០ នាក់ ជាជនទាំងឡាយដែលត្រូវបានចាប់ខ្លួនពីស២៤[២៤៧]។ ឈ្មោះមួយចំនួននៅក្នុងបញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល មានព័ត៌មានបន្តិចបន្តួចតែប៉ុណ្ណោះ[២៤៨]។

១៤២. ថ្វីបើមានការពិនិត្យល្អិតល្អន់លើកំណត់ត្រារដ្ឋបាលដែលរក្សាទុកនៅមន្ទីរស២១ក៏ដោយ ក៏បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល មិនមែនជាបញ្ជីឈ្មោះដែលមានឈ្មោះអ្នកជាប់-ឃុំទាំងអស់នោះទេ។ ករណីនេះកើតឡើងដោយសារគោលនយោបាយមួយចំនួនរបស់មន្ទីរស២១ ដូចជាការមិនចុះឈ្មោះកុមារក្នុងបញ្ជីដែលត្រូវបានគេនាំមកជាមួយឪពុកម្តាយ និងដោយហេតុថាឯកសារមួយចំនួនអាចត្រូវបានបាត់បង់ដោយសារតែជនជាប់ចោទ និងបុគ្គលិករបស់គាត់បានបោះបង់ចោលមន្ទីរស២១ភ្លាមៗនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[២៤៩]។ ឧទាហរណ៍ បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល មិនមានឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង សាក្សី វ៉ាន់ ណាត ម្តាយរបស់

---

ដែលបានរៀបរាប់ថាជាតិញវៀតណាម" ឯកសារ E68.29។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលបានបញ្ជាក់អត្តសញ្ញាណថាជាជនជាតិ វៀតណាម" ឯកសារ E68.30។ *សូមមើលផងដែរ* ផ្នែក (២.៥.២.៣) ។

[២៤៧] *សូមមើល* "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលជាអតីតបុគ្គលិកមន្ទីរស២១" ឯកសារ E68.39។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលបានចាប់មកពី ស២៤ (ព្រៃស)" ឯកសារ E68.41។ បញ្ជីនេះមានអ្នកទោសចូលចំនួន៤៧នាក់ ដែលជាអតីតបុគ្គលិកមន្ទីរ ស២៤ មានអ្នកជាប់ឃុំ៣៤២អ្នក កំពុងធ្វើការលុតដំខ្លួននៅស២៤ និងអ្នកជាប់ឃុំ២០១នាក់ ដែលមិនអាចបញ្ជាក់បានថាពួកគេជាបុគ្គលិកស២៤ ឬជាអ្នកជាប់ឃុំដែលកំពុងលុតដំខ្លួននៅស២៤។ *សូមមើល* "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានបញ្ជាក់អត្តសញ្ញាណថាជាអតីតបុគ្គលិកស២៤" ឯកសារ E68.42។ "អ្នកទោសមន្ទីរស២១ ដែលពីមុនជាអ្នកទោសនៅស២៤" ឯកសារ E68.43។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ចាប់មកពីស២៤ ប៉ុន្តែមិនបានបញ្ជាក់ច្បាស់ថាជាអតីតបុគ្គលិកស២៤ ឬជាអ្នកទោសស២៤" ឯកសារ E68.44។

[២៤៨] *សូមមើលឧទាហរណ៍* "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលអត្តសញ្ញាណមិនអាចកំណត់បាន" ឯកសារ E68.12។

[២៤៩] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៩-៦១។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៩-១០, ១៤-១៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ (នង ចាន់ផល) ទំព័រ៥៨-៥៩។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៨" ឯកសារ E3/378, ERN (ភាសាខ្មែរ) 00185495។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ១០២។ "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427, ទំព័រ ៤១-៤២ ERN (ភាសាខ្មែរ) 00191869-00191870។

សាក្សី នង ចាន់ផល ឈ្មោះ មុំ យ៉ូវ ឬប្អូនថ្លៃរបស់ជនជាប់ចោទ ដែលអ្នកទាំងអស់នេះ សុទ្ធតែត្រូវបាន ឃុំខ្លួននៅមន្ទីរស២១នោះដែរ[២៥០]។

១៤៣. ហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបាន កែសម្រួល គ្រាន់តែបង្ហាញចំនួនអប្បបរមារបស់ជនរងគ្រោះមន្ទីរស២១ ប៉ុណ្ណោះ ប៉ុន្តែចំនួនជនរង-គ្រោះពិតប្រាកដទំនងជាច្រើនជាងចំនួនដែលមាននៅក្នុងបញ្ជីនេះ។

២.៣.៣.៤.៣ រចនាសម្ព័ន្ធមន្ទីរស២១

១៤៤. ជនជាប់ចោទបានរៀបចំមន្ទីរ ស២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធនៃការរាយការណ៍ គ្រប់ជាន់ថ្នាក់ ដើម្បីធានាថា រាល់បទបញ្ជារបស់គាត់ពិតជាត្រូវបានអនុវត្តភ្លាមៗ និងដាក់លាក់[២៥១]។ អង្គភាពនានាដូចខាងក្រោម បានប្រតិបត្តិការនៅមន្ទីរ ស២១ ក្រោមការបញ្ជារបស់ជនជាប់ចោទ។

២.៣.៣.៤.៣.១ អង្គភាពឯកសារ

១៤៥. អង្គភាពឯកសារ ត្រូវបានគេស្គាល់ផងដែរថាជា "អង្គភាពរដ្ឋបាល និងបុគ្គលិក" ទទួលបន្ទុក ចុះឈ្មោះ និងរក្សាកំណត់ហេតុរបស់បុគ្គលិក និងអ្នកជាប់ឃុំនៅមន្ទីរស២១។ សាក្សី សួស ធី ជាប្រធានអង្គភាពឯកសារ និងបានរាយការណ៍ទៅឲ្យជនជាប់ចោទតាមរយៈ ឃឹម វ៉ាក ហៅ ហ៊ី[២៥២]។

---

[២៥០] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1, កថាខណ្ឌ១៧០, ២២៩។ ប្រតិចារិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ១-៣។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៨", E3/378, ERN (ភាសាខ្មែរ) 00185495។

[២៥១] ប្រតិចារិក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៤-៤៥, ៤៧-៤៨។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២៥។ ប្រតិចារិក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៨-៤០។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ E3/17, ERN ERN (ភាសាខ្មែរ) 00154228-00154229។

[២៥២] ប្រតិចារិក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។ សូមមើលផងដែរ ប្រតិចារិក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-៣០។ ប្រតិចារិក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ២៣-២៥។

១៤៦. អង្គភាពពិសេសបាននាំយកអ្នកត្រូវជាប់ឃុំដោយដាក់ខ្នោះដៃ និងចងមុខទៅកាន់អង្គភាពឯកសារ។ បន្ទាប់ពីបានកត់ត្រាឈ្មោះ មុខងារ និងទីកន្លែងកំណើតរបស់អ្នកជាប់ឃុំរួចរាល់ហើយ អ្នកជាប់ឃុំ ក៏ត្រូវបានគេនាំយកទៅអង្គភាពថតរូបដែលនៅជិតទីនោះ ដើម្បីថតរូប ដោយមានពាក់លេខសម្គាល់រៀងៗខ្លួន។ កុមារដែលត្រូវបានឃុំខ្លួនជាមួយឪពុកម្ដាយរបស់ពួកគេ មិនត្រូវបានចុះឈ្មោះក្នុងបញ្ជី និងមិនត្រូវបានថតរូបឡើយ។ បន្ទាប់ពីថតរូបរួចហើយ អ្នកជាប់ឃុំត្រូវបានអ្នកយាមនាំយកទៅដាក់ក្នុងបន្ទប់ឃុំខ្លួន ហើយកន្លែងឃុំខ្លួនរបស់ពួកគេត្រូវបានទំនាក់ទំនងជាមួយអង្គភាពឯកសារ[២៥៣]។

១៤៧. អ្នកត្រូវជាប់ឃុំត្រូវបានបញ្ជូនទៅមន្ទីរស២១ នៅគ្រប់ពេលវេលាទាំងអស់ក្នុងមួយថ្ងៃៗ។ ជាធម្មតាអ្នកត្រូវជាប់ឃុំមកដល់មន្ទីរស២១ជាក្រុមៗ ដែលមានគ្នាតិចជាង២០នាក់ ប៉ុន្តែ យូរៗម្ដង ពួកគេត្រូវបានបញ្ជូនមកជាក្រុមដែលមានចំនួនច្រើនជាង១០០នាក់ ជាពិសេសនៅចុងឆ្នាំ១៩៧៨។ នៅពេលដែលក្រុមដែលមានចំនួនច្រើនទាំងនោះបានមកដល់ អ្នកត្រូវជាប់ឃុំត្រូវបានគេដឹកតាមរថយន្តយកទៅអគារឃុំខ្លួន ដែលនៅទីនោះអង្គភាពឯកសារបានចុះឈ្មោះពួកគេក្នុងបញ្ជី។ អ្នកជាប់ឃុំដែលជាអតីតបុគ្គលិកមន្ទីរ ស២១ ឬ អ្នកទាំងឡាយណា ដែលត្រូវបានឃុំខ្លួននៅក្នុងគុកពិសេស មិនត្រូវបាននាំទៅបង្ហាញខ្លួនដោយផ្ទាល់នៅអង្គភាពឯកសារនោះទេ។ ប៉ុន្តែ យឹម វ៉ាក ហៅ ហ៊ី បានបញ្ជូនព័ត៌មានរបស់ពួកគេឲ្យទៅអង្គភាពឯកសារ ដើម្បីឲ្យគេចុះឈ្មោះក្នុងបញ្ជីឲ្យបានត្រឹមត្រូវ។ អង្គភាពឯកសារក៏បានអនុវត្តផងដែរទៅលើជនស៊ីវិល និងទាហានវៀតណាមដែលជាប់ឃុំនៅមន្ទីរស២១។ បញ្ជីឈ្មោះនៃអ្នកត្រូវជាប់ឃុំនៅមន្ទីរស២១ វាយដោយអង្គុលីលេខ ដែលទើបតែចុះឈ្មោះថ្មីទាំងអស់ត្រូវបានបញ្ជូនទៅឲ្យ ហ៊ី ជារៀងរាល់ថ្ងៃតាមរយៈអង្គភាពឯកសារ[២៥៤]។

---

[២៥៣] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៦-៥៧, ៥៩-៦១, ៦៦-៦៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ញៀម អេន) ទំព័រ៨២-៨៤។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៨-៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៨-៩, ១៥-១៦, ៣៥-៣៦។ ប្រតិចារឹក ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩ (នង ចាន់ផល) ទំព័រ៥៨-៥៩។

[២៥៤] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៩-៦០, ៦១-៦៥, ៦៨-៦៩, ៨០-៨១។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៦-៧។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ញៀម អេន) ទំព័រ៨៦-៨៧។

១៤៨. អង្គភាពឯកសារក៏បានអនុវត្តតាមការណែនាំយ៉ាងហ្មត់ចត់ ក្នុងការយកអ្នកជាប់ឃុំចេញពីបញ្ជីមន្ទីរស២១ ដែលត្រូវយកទៅសម្លាប់។ សាក្សី សួស ធី បានបញ្ជាក់ថា "ទាក់ទងទៅនឹងការយកអ្នកទោសចេញ នៅពេលដែលមានចំណារពី ឌុច គឺ ឌុច យកបញ្ជីមួយមកប្រគល់ឲ្យ ហ៊ី ហើយ ហ៊ី បញ្ជូនបញ្ជីនោះមកឲ្យខ្ញុំដើម្បីស្រង់ដាក់លេខបន្ទប់ លេខអគារ ដើម្បីឲ្យងាយស្រួលដល់កងការពារយកពួកគេចេញ"[២៥៥]។ សាក្សី សួស ធី បានបញ្ជាក់ថា "មានតែ ឌុច ប៉ុណ្ណោះដែលហ៊ានចារលើឈ្មោះអ្នកទោសណាដែលត្រូវកម្ទេច ហើយចំណារនោះគឺគាត់សរសេរអក្សរ "កំ១" ដែលមានន័យថា "កម្ទេច"[២៥៦]។ អ្នកជាប់ឃុំដែលមានឈ្មោះនៅក្នុងបញ្ជីត្រូវបានគេនាំយកចេញទៅតាមច្រកទ្វារខាងមុខ។ អង្គភាពឯកសារបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេសាជាថ្មី ហើយបន្ទាប់មកពួកគេត្រូវបានដឹកយកទៅជើងឯកដើម្បីសម្លាប់ចោល។ អង្គភាពឯកសារធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីឈ្មោះអ្នកជាប់ឃុំ ដែលបានសម្លាប់រួចហើយនៅត្រឹមម៉ោង ៧ ព្រឹក ថ្ងៃបន្ទាប់[២៥៧]។

១៤៩. ភាពល្អិតល្អន់នៃការថែរក្សាឯកសារទុកនៅមន្ទីរស២១ ត្រូវបានបង្ហាញតាមរយៈការធ្វើសក្ខីកម្មបន្ថែមទៀត នៅពេលសវនាការ។ អ្នកជំនាញ David CHANDLER បានបញ្ជាក់ថា បណ្ណសាររបស់មន្ទីរស២១ គឺទំនងជាបណ្ណសារដ៏ធំបំផុតនៅក្នុងមន្ទីរសន្តិបាល ក្រោមការដឹកនាំរបស់ជនជាប់ចោទ និងត្រូវបានរក្សាទុកតាមរបៀបមួយដែលមានជំនាញ និង ល្អិតល្អន់បំផុត។ បណ្ណសារដែលត្រូវបានរកឃើញនៅមន្ទីរស២១ មានចម្លើយសារភាពជាង ៤.០០០ ឯកសារ រដ្ឋបាលរាប់រយទំព័រ បញ្ជីឈ្មោះអ្នកជាប់ឃុំ បញ្ជីឈ្មោះអ្នកដែលត្រូវបានសម្លាប់ ឯកសារ សម្រាប់វគ្គសិក្សារៀនសូត្រ និងឯកសារស្វ័យទិតៀនជាច្រើន។ នៅក្នុងទស្សនៈរបស់លោក CHANDLER ប្រសិទ្ធភាពនៃការទុកដាក់ឯកសារ

---

*សូមមើលផងដែរ* "បញ្ជីឈ្មោះអ្នកទោសមានឈ្មោះអ្នកទោសជនជាតិវៀតណាមដែលបានចូលនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨" ឯកសារ E3/435, ERN (ភាសាខ្មែរ) 00087039 ។

[២៥៥] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៧។

[២៥៦] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៧៦-៧៨។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១៧-១៨។

[២៥៧] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥៧, ៧២-៧៦, ៧៨-៧៩។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១២-១៣។ *សូមមើលផងដែរ* ផ្នែក (២.៣.៣.៦)។

នៅមន្ទីរស២១ បានឆ្លុះបញ្ចាំងអំពីបំណងប្រាថ្នារបស់ជនជាប់ចោទក្នុងការបង្ហាញនូវគុណភាពការងារដែលកំពុងត្រូវបានអនុវត្តក្រោមការត្រួតពិនិត្យរបស់គាត់ ព្រមទាំងការខិតខំព្យាយាមក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា[២៥៨]។ គាត់បានបន្ថែមទៀតថា "គុកប្រភេទនេះគឺមិនមានកើតឡើងតាំងពីមុនក្នុងប្រទេសកម្ពុជា ដែលខ្ញុំធ្លាប់បានដឹងនោះទេ ហើយអង្គភាពសួរចម្លើយដែលអាចបង្កើតនូវឯកសារចម្លើយសារភាពជាច្រើន ក៏មិនមានកើតឡើងក្នុងប្រទេសកម្ពុជាកាលពីមុនឡើយ"[២៥៩]។

## ២.៣.៣.៤.៣.២ អង្គភាពសួរចម្លើយ

១៥០. អង្គភាពសួរចម្លើយមានភារកិច្ចទាញយកចម្លើយសារភាពជាលាយលក្ខណ៍អក្សរពីបុគ្គលដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) ដោយមានរៀបរាប់លម្អិតអំពី "សកម្មភាពក្បត់របស់ពួកគេ" ព្រមទាំងឈ្មោះរបស់បុគ្គលដែលត្រូវបានគេឆ្លើយដាក់[២៦០]។

១៥១. អង្គភាពសួរចម្លើយត្រូវបានបែងចែកជាក្រុមផ្សេងៗពីគ្នា ដោយប្រធានក្រុមនីមួយៗ "ត្រូវមានភារកិច្ចទទួលខុសត្រូវ ឬត្រូវទទួលខុសត្រូវ" ចំពោះមុខជនជាប់ចោទ[២៦១]។ ក្រុមសួរចម្លើយទាំងនេះរួមមាន "ក្រុមត្រជាក់" (ក្រុមនេះមិនប្រើអំពើហិង្សាទៅលើរាងកាយនោះទេ) "ក្រុមក្តៅ" (ក្រុមនេះ

[២៥៨] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៦-១៨, ៣៤-៣៥, ៤១-៤៣, ៤៦-៤៧, ៦៤-៦៥។ "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427 ទំព័រ១៧២-១៧៣, ERN (ភាសាខ្មែរ) 00192012-00192013។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៥, ៦៦-៦៧។

[២៥៩] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៣១-៣២។

[២៦០] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤១-៤២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦៤។

[២៦១] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៥-៦៧។ ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៦-១៧។

ប្រើអំពើហិង្សាលើរាងកាយភ្លាមៗ) និង "ក្រុមអង្កៀម" (ក្រុមនេះប្រើទាំងវិធីសាស្ត្រត្រជាក់ និងវិធីសាស្ត្រក្តៅលាយចូលគ្នា និងចំណាយពេលយូរ)។ អ្នកជាប់ឃុំតែងតែត្រូវបានគេយកចេញពីក្រុមមួយទៅក្រុមមួយរហូតដល់ចម្លើយសារភាពរបស់ពួកគេទទួលបានចប់សព្វគ្រប់[២៦២]។

១៥២. បន្ថែមពីលើនេះទៀត ក្នុងឋានៈជាប្រធានមន្ទីរស២១ ជនជាប់ចោទបានបង្កើតក្រុមសួរចម្លើយមួយផ្សេងទៀត ដែលមានប្រពន្ធរបស់បុគ្គលិកមន្ទីរស២១ ដែលគេជឿទុកចិត្តដើម្បីសួរចម្លើយអ្នកជាប់ឃុំស្ត្រី។ ជនជាប់ចោទក៏បានបង្កើត និងបណ្តុះបណ្តាលមនុស្សមួយក្រុមដែលដឹកនាំដោយហឿង សុងហ៊្លួ ហៅ ប៉ុន ទទួលភារកិច្ចសួរចម្លើយអ្នកជាប់ឃុំដែលមានឋានៈខ្ពស់តែប៉ុណ្ណោះនៅមន្ទីរស២១[២៦៣]។

១៥៣. ភាគច្រើននៃអ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) ត្រូវបានសួរចម្លើយលក្ខណៈជាប្រព័ន្ធ[២៦៤]។ អ្នកសួរចម្លើយមិនអាចជ្រើសរើសអ្នកជាប់ឃុំណាមួយដែលពួកគេចង់សួរនោះបានទេ ប៉ុន្តែត្រូវបានគេចាត់តាំងឲ្យសួរ[២៦៥]។ អ្នកជាប់ឃុំត្រូវបានអ្នកយាមនាំយកចេញពីបន្ទប់ឃុំខ្លួនរបស់ពួកគេ ដោយដាក់ខ្នោះដៃ និងចងមុខ ហើយប្រគល់ទៅឲ្យអ្នកសួរចម្លើយ[២៦៦]។ ជាធម្មតាសម្រាប់ការ

---

[២៦២] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១-១២, ១៣-១៦។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៨-១៩។

[២៦៣] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៥។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣, ៥៧។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣, ៣៩។ អ្នកសួរចម្លើយជាស្ត្រីក្រោយមកត្រូវបានសម្លាប់ដោយការបោសសំអាតផ្ទៃក្នុងនៅមន្ទីរ ស២១។

[២៦៤] ទោះបីជាយ៉ាងណាក៏ដោយ សូមមើលប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ២៤ (សក្ខីកម្មបានបញ្ជាក់ថា ចំនួនអ្នកទោសពី ហាទៅ ហុកសិបភាគរយ មិនត្រូវបានសួរយកចម្លើយ)។

[២៦៥] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៥-៦៧។

[២៦៦] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៦៨-៧០។ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ១៦-១៧។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២០-២១។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ២៣-២៤។

សួរចម្លើយអ្នកជាប់ឃុំម្នាក់មានតែអ្នកសួរចម្លើយម្នាក់ប៉ុណ្ណោះ[២៦៧] ប៉ុន្តែ សម្រាប់អ្នកជាប់ឃុំជនជាតិវៀតណាមវិញ ជួនកាលត្រូវបានសួរចម្លើយដោយមានជំនួយពីអ្នកបកប្រែម្នាក់[២៦៨]។ ជាទម្លាប់ អ្នកសួរ-ចម្លើយបានប្រើអំពើហិង្សាបន្ថែមទៅលើ "ការធ្វើនយោបាយ"[២៦៩] ដើម្បីទទួលបានចម្លើយសារភាពជាលាយលក្ខណ៍អក្សរពីអ្នកជាប់ឃុំ[២៧០]។ អ្នកជាប់ឃុំដែលមិនចេះសរសេរអក្សរ បានឆ្លើយសារភាពដើម្បីឲ្យបុគ្គលិកមន្ទីរស២១ ធ្វើការកត់ត្រានូវចម្លើយសារភាពនោះ[២៧១]។ អ្នកជាប់ឃុំខ្លះត្រូវបានគេនាំយកទៅឃុំខ្លួននៅក្នុងបន្ទប់ដាច់ដោយឡែកនៅក្នុងអំឡុងពេលនៃការសួរចម្លើយមិនទាន់ចប់[២៧២]។

១៩៤. តាមការអនុវត្ត អ្នកសួរចម្លើយនឹងបញ្ជូនរបាយការណ៍របស់ពួកគេជាមួយនឹងចម្លើយសារភាពដែលទទួលបានទៅឲ្យជនជាប់ចោទ[២៧៣]តាមរយៈប្រធានក្រុមរបស់ពួកគេ[២៧៤]។ ក្នុងករណីអ្នកជាប់ឃុំ

---

[២៦៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦០-៦១។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៩-២០។

[២៦៨] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ១៥-១៦, ១៨-២០។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ២៨-២៩។

[២៦៩] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៩-២១ ("ចំណុចនេះគឺជាការងារដែលគេធ្វើឡើងគឺការធ្វើទារុណកម្ម ការញុះញង់ ឬក៏ជំរុញឲ្យគេនិយាយ ហើយធ្វើការនិយាយផ្ទុយទៅនឹងចម្លើយរបស់អ្នកទោស ។ ដូច្នេះហើយ ទារុណកម្មមួយចំនួន គឺគាត់មានលក្ខណៈចេះធ្វើការរបស់គាត់ តាមវិធីរបស់គាត់ ជាវិធីដែលគាត់ទាញយកចម្លើយផ្សេងៗ ។ *[ការធ្វើនយោបាយមានលក្ខណៈស្មុគស្មាញជាង ដោយមិនចាំបាច់ប្រើទារុណកម្ម។ ការធ្វើនយោបាយនេះគឺ សួរ លួងលោម ជជែកគ្នាលេងដើម្បីស្គាល់គ្នា ព្យាយាមធ្វើឱ្យចាញ់ប្រាជ្ញ ព្យាយាមរាប់អាន ព្យាយាមនិយាយផ្គាញ់ផ្គាល។ ទាំងនេះគឺជាវិធីសួរចម្លើយ ដែលវិធីខ្លះមានលក្ខណៈវិជ្ជាជីវៈ ហើយវិធីដទៃទៀតធ្វើឡើងដោយមិនមានលក្ខណៈវិជ្ជាជីវៈ ដើម្បីយកចម្លើយសារភាព ដោយមិនចាំបាច់ប្រើទារុណកម្ម។ ]*។

[២៧០] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៩-៥០។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ២៤។ "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427 ទំព័រ១៤៦-១៤៧, ERN (ភាសាខ្មែរ) 00191986-00191987។

[២៧១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០។

[២៧២] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៣-២៤។

[២៧៣] ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ១៧-១៨, ២០។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៣-៥៤។

សំខាន់បំផុត ឯកសារទាំងនេះត្រូវបានបញ្ជូនដោយផ្ទាល់ទៅឱ្យជនជាប់ចោទតាមរយៈនីរសារផ្ទាល់របស់គាត់[២៧៥]។ ការសួរចម្លើយអ្នកជាប់ឃុំនីមួយៗនឹងបន្តធ្វើជួនកាលចំណាយពេលជាច្រើនដងក្នុងមួយថ្ងៃ រហូតដល់ជនជាប់ចោទយល់ឃើញថា ចម្លើយសារភាពរបស់អ្នកជាប់ឃុំទាំងនោះចប់សព្វគ្រប់អស់ហើយ[២៧៦]។

១៥៥. ដោយសារតែអ្នកជាប់ឃុំទាំងអស់ត្រូវបានគេចាត់ទុកថាមានកំហុសរួចហើយ ដូច្នេះតួនាទីរបស់អ្នកសួរចម្លើយគឺ "ធ្វើឱ្យត្រឹមត្រូវទៅតាមសេចក្តីសម្រេចរបស់បក្សក្នុងការស្រង់យកចម្លើយឱ្យបានពេញលេញ"[២៧៧]។ ដូច្នេះ ខ្លឹមសារនៃចម្លើយសារភាពជាច្រើនត្រូវបានអ្នកសួរចម្លើយកំណត់មុនរួចជាស្រេចទៅតាមការណែនាំពីជនជាប់ចោទ ដើម្បីបង្កើតឱ្យមានទំនាក់ទំនងរវាងអ្នកជាប់ឃុំជាមួយនឹងសេអ៊ីអា (CIA) កាហ្សេបេ (KGB) និង/ឬ ជនជាតិវៀតណាម ហើយបានបង្ខំឱ្យអ្នកជាប់ឃុំទាំងនោះផ្តល់នូវចម្លើយដែលពួកគេបានប្រឌិតឡើង[២៧៨]។ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង ដែលបានទទួលរងនូវការសួរចម្លើយបានបញ្ជាក់ថា៖

---

[២៧៤] ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦៨-៦៩។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២១។

[២៧៥] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២១។

[២៧៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៥-៦៦។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២២។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦៨-៧០។

[២៧៧] "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" សៀវភៅនិពន្ធដោយ David CHANDLER ឯកសារ E3/427 ទំព័រ៨៩-៩០, ERN (ភាសាខ្មែរ) 00191929-00191930។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៨-១៩។

[២៧៨] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៩-២០។ "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427 ទំព័រ៩៣-៩៤, ១០៧-១០៨, ERN (ភាសាខ្មែរ) 00191933-00191934, 00191947-00191948។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៥។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦៣-៦៤។

គេឱ្យដាក់ដេកផ្កាប់មុខ ដេកផ្កាប់មុខហើយគេចាប់ផ្ដើមវ៉ៃ។ វ៉ៃមួយឆ្អែតអីចឹងគេសួរ គេសួរថា "អ្នែងចូល *សេអ៊ីអា* ថ្ងៃណា? ខែណា? ឆ្នាំណា? អ្នកណានាំចូលឈ្មោះអី?" ហើយ ខ្ញុំមិនដឹងឆ្លើយថាម៉េច ពីព្រោះមនុស្សធ្វើការសុខៗ មិនដែលទៅចូល *សេអ៊ីអា* ឯណា ខំបម្រើ អង្គការពេលនោះហ្នឹង ការចាត់តាំងរបស់អង្គការហ្នឹងវា ដូចថាវាគ្មានពេលណានឹងដឹងខ្សែ រយៈឯណា ចូលឯណា ខ្ញុំអត់ដឹង *សេអ៊ីអា* ហ្នឹងយ៉ាងម៉េចផង[២៧៩]។

## ២.៣.៣.៤.៣.៣ អង្គភាពការពារ

១៥៦. អង្គភាពការពារ ដែលត្រូវបានគេហៅផងដែរថាជាអង្គភាពយោធា មានអង្គភាពតូចៗចំនួនពីរ[២៨០] ។

១៥៧. អង្គភាពទីមួយ គឺអង្គភាពកងការពារ ដែលមានបុគ្គលិកបំពេញតួនាទីយាមកាមអ្នកជាប់ឃុំ នៅក្នុងមន្ទីរស២១(ទួលស្លែង) បញ្ជូនអ្នកជាប់ឃុំឱ្យអ្នកសួរចម្លើយ និងទុកពួកគេឱ្យនៅរស់រហូត ដល់ការសួរចម្លើយពួកគេបានចប់សព្វគ្រប់[២៨១]។ ជាធម្មតា អង្គភាពនេះត្រូវបានចែកចេញជាបួនក្រុម ដែលមានអ្នកយាម១០ ទៅ២០នាក់ក្នុងមួយក្រុមៗរួមមានក្មេងជំទង់ៗផងដែរ[២៨២]។ ឃឹម វ៉ាក ហៅ ហ៊ី និងអ្នកក្រោមបង្គាប់របស់គាត់ឈ្មោះ ផល បានគ្រប់គ្រងអង្គភាពនេះ[២៨៣]។

១៥៨. អង្គភាពទីពីរ គឺជាអង្គភាពកងពិសេស ដែលទទួលបន្ទុកក្នុងការទទួលអ្នកជាប់ឃុំ និងនាំពួក គេចូលទៅក្នុងមន្ទីរស២១(ទួលស្លែង)។ ជាទូទៅ អ្នកជាប់ឃុំត្រូវបានចាប់ខ្លួន និងនាំខ្លួនយកទៅ មន្ទីរស២១តាមរយៈអង្គភាពរបស់ពួកគេផ្ទាល់ ប៉ុន្តែ អ្នកជាប់ឃុំខ្លះត្រូវបានគេកុហកថាឱ្យទៅពិនិត្យ

---

[២៧៩] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២១-២២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២០។

[២៨០] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៧។

[២៨១] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦-១៧, ១៧-១៨។

[២៨២] ប្រតិចារឹក ចុះ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ខៀវ ចេស) ទំព័រ៥៣-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ១៥-១៦។

[២៨៣] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៧។

មើលអង្គភាពពិសេស ប៉ុន្តែនៅពេលដែលទៅដល់ទីនោះពួកគេត្រូវបានចាប់ខ្លួន[២៨៤]។ ពេលខ្លះអង្គភាពកងពិសេសត្រូវបានប្រើប្រាស់ដើម្បីដឹកជញ្ជូន និងចាប់ខ្លួនមនុស្សនៅខាងក្រៅមន្ទីរស២១ ។ អង្គភាពកងពិសេសនេះក៏ត្រូវបានគេចាត់ឲ្យទៅដឹកជញ្ជូនអ្នកត្រូវជាប់ឃុំជនជាតិវៀតណាម នៅតាមព្រំដែនកម្ពុជាវៀតណាមមកកាន់មន្ទីរស២១ផងដែរ[២៨៥]។ អង្គភាពកងពិសេសក៏មានភារកិច្ចយាមកាមនៅខាងក្រៅមន្ទីរស២១ (ទួលស្លែង) និងធ្វើអន្តរាគមន៍ក្នុងករណីបន្ទាន់ផងដែរ[២៨៦]។ លើសពីនេះទៀត សមាជិករបស់អង្គភាពពិសេសនេះគឺទទួលបន្ទុកដឹកជញ្ជូនអ្នកជាប់ឃុំទៅជើងឯកដើម្បីសម្លាប់ចោល[២៨៧]។ ដំបូងឡើយអង្គភាពពិសេសនេះដឹកនាំដោយ ប៉េង ក្រោយមកដឹកនាំដោយសាក្សីឈ្មោះ ហ៊ឹម ហ៊ុយ[២៨៨]។

### ២.៣.៣.៤.៣.៤ អង្គភាពផ្សេងៗទៀតរបស់មន្ទីរស២១

១៥៩. អង្គភាពផ្សេងៗមួយចំនួនទៀត ក៏បានប្រតិបត្តិការនៅក្នុងមន្ទីរស២១ ផងដែរ។ អង្គភាពទាំងនេះរួមមាន អង្គភាពវាយអង្គុលីលេខ (អង្គភាពនេះវាយបញ្ចូលនូវចម្លើយសារភាពរបស់អ្នកជាប់ឃុំ) អង្គភាពទូរស័ព្ទ (សម្រាប់ទូរស័ព្ទចេញនិងទទួលទូរស័ព្ទចូលមន្ទីរស២១) អង្គភាពថតរូប (អង្គភាពនេះ

---

[២៨៤] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៤, ២៥-២៦។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (ស្លួស ធី) ទំព័រ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៩-១០, ១៨។ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤៣-៤៤។

[២៨៥] ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៩-១០, ២៣-២៤, ២៩-៣០។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ១៩។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ សោម សំអុល) ទំព័រ៥២-៥៣។

[២៨៦] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៣៨(ឃ)។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-២០។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៣-៣៤។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥-៨។

[២៨៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៨-៥៤, ៦៦-៦៧។ *សូមមើលផងដែរ* ផ្នែក (២.៣.៣.៦) ។

[២៨៨] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៣៨(ឃ)។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥៦-៥៩។

ថតរូបអ្នកជាប់ឃុំ នៅពេលដែលពួកគេមកដល់មន្ទីរស២១) អង្គភាពពេទ្យ (អង្គភាពនេះមានភារកិច្ចព្យាបាលបុគ្គលិកមន្ទីរស២១ និងថែទាំអ្នកជាប់ឃុំនៅមន្ទីរស២១ ឲ្យនៅរស់រហូតដល់ចម្លើយសារភាពរបស់ពួកគេបានចប់សព្វគ្រប់) អង្គភាពដាំស្ល (អង្គភាពនេះមានរោងបាយមួយសម្រាប់បុគ្គលិកមន្ទីរស២១ និង មានរោងបាយមួយទៀតសម្រាប់អ្នកជាប់ឃុំ) អង្គភាពនីរសារ និងអង្គភាពផែនទី[២៨៩]។

១៦០. អ្នកជាប់ឃុំនៅមន្ទីរស២១ មួយចំនួនត្រូវបានគេជ្រើសរើសយ៉ាងសម្រិតសម្រាំង ហើយឲ្យធ្វើការនៅក្នុងរោងជាងមន្ទីរស២១ ដើម្បីផលិតសម្ភារៈសម្រាប់ការឃោសនាផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងជួសជុលឧបករណ៍ផ្សេងៗ[២៩០]។

### ២.៣.៣.៥ ការទទួលខុសត្រូវក្នុងឋានៈជាប្រធានមន្ទីរស២១

១៦១. ក្រៅពីការគ្រប់គ្រងអង្គភាពនានាដែលបានលើកឡើងខាងលើ ជនជាប់ចោទបានបំពេញភារកិច្ចពិសេសៗមួយចំនួនទៀតនៅក្នុងមន្ទីរស២១។ ភារកិច្ចសំខាន់បំផុតក្នុងចំណោមភារកិច្ចទាំងនោះមានដូចខាងក្រោមនេះ ៖

#### ២.៣.៣.៥.១ ការជ្រើសរើសបុគ្គលិក

១៦២. ជនជាប់ចោទបានទទួលស្គាល់ថា បុគ្គលិកមន្ទីរស២១មួយចំនួនគឺជាអតីតអ្នកក្រោមបង្គាប់របស់គាត់នៅមន្ទីរម១៣[២៩១]។ លើសពីនេះទៀត គាត់បានយល់ស្របថា ក្នុងនាមជាប្រធានមន្ទីរស២១

---

[២៨៩] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៤-៤៥, ៤៧-៤៨។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២៣, ២៩-៣០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៨-២៩។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៩-៣០, ៦៩-៧០។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម អេន) ទំព័រ៨១។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ដន) ទំព័រ៦-៧។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ក់ ស៊ីធីម) ទំព័រ៣០-៣១។

[២៩០] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ១៣-១៥, ៣៨-៣៩។ *សូមមើលផងដែរ* ផ្នែក (២.៤.២)។

[២៩១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៣-៤៤, ៤៧-៤៨។

គាត់បានបន្តការអនុវត្តវិធីសាស្ត្រដែលបានអនុវត្តនៅមន្ទីរម១៣ក្នុងការជ្រើសរើសក្មេងជំទង់ៗ និង បុគ្គលិកដែលងាយនឹងធ្វើការអប់រំឲ្យធ្វើជាអ្នកក្រោមបង្គាប់របស់គាត់។ ជាពិសេស គាត់បានសុំការអនុញ្ញាតពី សុន សេន ដើម្បីជ្រើសរើសយុវជនដែលជាកូនកសិករក្រីក្រនិងមិនមានការអប់រំចំនួនប្រហែល ៦០ នាក់ មកពីខេត្តកំពង់ឆ្នាំង[២៥២]។ ដូចដែលបានបញ្ជាក់ដោយជនជាប់ចោទទាក់ទងនឹងសាក្សី ឈុន ផល ៖

> ស្ថិតនៅក្នុងជម្រើសដែលយើងខ្ញុំទៅសុំពីមូលដ្ឋានពិតមែនហើយ។ ហើយវណ្ណៈភាពគាត់ជាវណ្ណៈភាពកសិករក្រ។ ម្ល៉ោះហើយ កម្រិតវប្បធម៌ក៏តិច ដូចអង្គសវនាការឃើញស្រាប់ហើយ ប្រហែលជាអាចបានមួយម៉ាត់ពីរទាំងត្រដាប់ត្រដួសផង។ នេះជាជម្រើសហើយ ដែលខ្ញុំទៅសុំយកពីមូលដ្ឋានមក ហើយអាយុ១៥ ១៦ នេះ ក៏ជាជម្រើសរបស់ខ្ញុំដែរ ខ្ញុំអត់ចង់បានបុគ្គលិកដែលមានអ្នកផ្សេងទៀត គេអប់រំរួចទៅហើយទេ។ ខ្ញុំចង់បានបុគ្គលិក ដែលមានលក្ខណៈថ្មោងថ្មី ទាំងខាងនយោបាយ ទាំងខាងចាត់តាំង។ នេះខ្ញុំសុំរៀបរាប់ ប៉ុណ្ណោះ[២៥៣]។

### ២.៣.៣.៥.២ ការបណ្តុះបណ្តាលបុគ្គលិក

១៦៣. ការបង្រៀន ជាពិសេសការបណ្តុះបណ្តាលផ្នែកនយោបាយ គឺជាភារកិច្ចមួយដ៏ចម្បងបំផុតក្នុងចំណោមភារកិច្ចសំខាន់ៗជាច្រើននៅមន្ទីរស២១ របស់ជនជាប់ចោទ ហើយគាត់បានកត់សម្គាល់ថា គាត់តែម្នាក់ឯងប៉ុណ្ណោះដែលទទួលបន្ទុកក្នុងការអប់រំបុគ្គលិកដែលធ្វើការនៅទីនោះ។ គាត់បានបង្រៀនរៀងរាល់ឆ្នាំ នៅក្នុងអង្គប្រជុំកម្មាភិបាលរបស់មន្ទីរស២១ នៅសាលាបណ្តុះបណ្តាល

---

[២៥២] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-២៩, ៦៨-៦៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៧-១៨។

[២៥៣] ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៤-៦៥។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៧-១៨។

មួយដែលបានបង្កើតឡើងនៅក្បែរផ្ទះរបស់គាត់[២៥៤]។ គាត់បានបង្រៀនអ្វីដែលគាត់បានរៀនសូត្រនៅសាលានយោបាយរបស់នាយសេនាធិការ ឬនៅសមាជបក្សប្រចាំឆ្នាំ នៅពេលមានកិច្ចប្រជុំអប់រំជាទៀងទាត់ និងចាំបាច់[២៥៥] ដែលចូលរួមដោយថ្នាក់ដឹកនាំនៃអង្គភាពនានារបស់មន្ទីរស២១[២៥៦]។

១៦៤. វគ្គបណ្តុះបណ្តាលបន្ថែមជាប្រចាំនៅសាលាបណ្តុះបណ្តាល រួមបញ្ចូលនូវការបណ្តុះបណ្តាលអំពីវិធីសាស្ត្រសួរចម្លើយ ដែលវគ្គបណ្តុះបណ្តាលនោះបានកើនឡើងពីការបណ្តុះបណ្តាលប្រចាំឆ្នាំក្នុងឆ្នាំ១៩៧៧ ទៅជាការបណ្តុះបណ្តាលប្រចាំខែ និងប្រចាំសប្តាហ៍វិញក្នុងឆ្នាំ១៩៧៨[២៥៧]។ ជនជាប់-ចោទបានបណ្តុះបណ្តាលអ្នកសួរចម្លើយរបស់គាត់ឲ្យប្រើអំពើហិង្សាលើរូបរាងកាយ និងផ្លូវចិត្ត ប៉ុន្តែបានណែនាំពួកគេទុកអ្នកជាប់ឃុំឲ្យនៅរស់រហូតដល់គាត់យល់ថា ចម្លើយសារភាពរបស់ពួកគេបានធ្វើចប់សព្វគ្រប់[២៥៨]។ ជនជាប់ចោទបានបញ្ជាក់ថា ការបណ្តុះបណ្តាលអំពីការសួរចម្លើយគឺជាវិធីមួយជៀសវាងកុំឲ្យបុគ្គលិកមន្ទីរស២១ សម្លាប់អ្នកជាប់ឃុំ[២៥៩]។ គាត់ទទួលស្គាល់ថា ការបង្រៀន និងការណែនាំរបស់គាត់ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកំណត់ត្រារបស់អ្នកសួរចម្លើយមន្ទីរស២១ ដែលត្រូវបាន

---

[២៥៤] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤-៣៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦-១៨។

[២៥៥] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៨-៣៩។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣។

[២៥៦] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣៣។

[២៥៧] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤១-៤៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩០-៩១។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៣-១៥។

[២៥៨] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៥-៦៧, ៦៩-៧១។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ១៤, ៥២-៥៣។

[២៥៩] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៧-៤៨។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ១៤, ៥២-៥៣។

ដាក់នៅចំពោះមុខអង្គជំនុំជម្រះ[៣០០]។ កំណត់ត្រាទាំងនេះរួមមានការណែនាំដូចជា៖ "ប្រសិនបើអង្គការប្រាប់ថាកុំឲ្យវាយ កុំវាយដាច់ខាត។ ប្រសិនបើបក្សបញ្ជាយើងវាយ យើងត្រូវដោយម្ចាស់ការវាយពួកវាឲ្យទាល់តែនិយាយ កុំឲ្យរួចខ្លួនដោយសេចក្តីស្លាប់ កុំឲ្យពួកវាអស់កម្លាំងដល់ថ្នាក់ធ្លាក់ខ្លួនឈឺ ហើយស្លាប់"[៣០១]។

១៦៥. ជនជាប់ចោទបានទទួលស្គាល់អំពីលទ្ធផលនៃការបណ្តុះបណ្តាលនោះថា បុគ្គលិកមន្ទីរស២១ រួមទាំងក្មេងជំទង់ដែលគាត់បានជ្រើសរើសយ៉ាងពិសេសនោះ ត្រូវបានបង្រៀនឲ្យស្តាប់តាមបញ្ជាមានភាពឃោរឃៅ ចេះឃុំឃាំងមនុស្ស ចេះសួរចម្លើយ ចេះធ្វើទារុណកម្ម និងសម្លាប់មនុស្ស។ ដូចដែលជនជាប់ចោទបានបញ្ជាក់ ៖ "ពួកគេប្រែធាតុអស់ហើយ។ ពួកគេប្រែពីស្លូតបូតទៅជាឃោរឃៅដាច់ខាតក្នុងរឿង [...]។ ពួកគេមានជំហរវណ្ណៈ [...] ក៏ប៉ុន្តែអ្នកណាអប់រំ គឺខ្ញុំអ្នកអប់រំជាទូទៅឲ្យគេទៅអីចឹង ឲ្យគេដាច់ខាតអីចឹង"[៣០២]។

### ២.៣.៣.៥.៣ តួនាទីក្នុងការចាប់ខ្លួន

១៦៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

---

[៣០០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៧, ៦៨-៦៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩, ២៩-៣០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៧-៧៨។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ១៥-១៨។ *សូមមើលផងដែរ* "បញ្ជីស្ថិតិរបស់សាខាពិសេសនៃមន្ទីរស២១ -នយោបាយ មនោគមវិជ្ជា និងរចនាសម្ព័ន្ធ" ឯកសារ E3/426។ "សៀវភៅកំណត់ហេតុមន្ទីរ ស២១ របស់ ឌុយ និង ហឿង សុងហួ ហៅ ប៊ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ – ១៧ ខែធ្នូ ឆ្នាំ១៩៧៨" ឯកសារ E3/73។ "សៀវភៅកំណត់ហេតុមន្ទីរស២១ របស់ ម៉ម ណៃ ហៅ ចាន់"ឯកសារ E3/231។

[៣០១] *សូមមើល* "បញ្ជីស្ថិតិរបស់សាខាពិសេសនៃមន្ទីរស២១ -នយោបាយ មនោគមវិជ្ជា និងរចនាសម្ព័ន្ធ" ឯកសារ E3/426 ERN (ភាសាខ្មែរ) 00007487-00007488 ។ ។

[៣០២] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨-៦៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៨។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦។ ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ ទំព័រ២៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥៨។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ១៥-១៦។

៥១. ឌុច បានឲ្យដឹងថា គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរ ស២១ ដោយគ្មានសេចក្តីសម្រេចរបស់បក្សទេ។ ឌុច បានពន្យល់ថា ចំពោះការចាប់ខ្លួនសមាជិកគណៈកម្មាធិការមជ្ឈិម សេចក្តីសម្រេចត្រូវធ្វើដោយគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស។ ចំពោះអ្នកដទៃទៀត ឌុច បាននិយាយថាគឺ នួន ជា ដែលជាថ្នាក់លើរបស់គាត់ កោះហៅ ប្រធានអង្គភាពដែលពាក់ព័ន្ធមកពិភាក្សាដើម្បីធ្វើសេចក្តីសម្រេចរួម។ ឌុច បានអះអាង ហើយ ម៉ម ណៃ ក៏បានសន្មតដែរថា ចំពោះមនុស្សដែលមកពីតំបន់ដទៃ ការសម្រេចចាប់ខ្លួន តែងតែត្រូវធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ដោយធ្វើការទាក់ទងជាមួយភូមិភាគ តំបន់ តែងតែ ត្រូវធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ដោយធ្វើការទាក់ទងជាមួយភូមិភាគ តំបន់ ឬស្រុក នានាដែលពាក់ព័ន្ធ ដើម្បីចាប់ខ្លួនអ្នកដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព។ ឌុច បានបញ្ជាក់ថា លើកលែងតែអ្នកទោសសំខាន់ៗមួយចំនួន ជាទូទៅគាត់មិនបានដឹងអំពីហេតុផល ដែលនៅពីក្រោយការចាប់ខ្លួនអ្នកទាំងនោះមកមន្ទីរ ស២១ ឡើយ។

៥២. លើសពីនេះទៀត ឌុច ទទួលថា "មន្ទីរ ស២១ មិនមានសិទ្ធិអំណាចក្នុងការចាប់ខ្លួននរណាម្នាក់ឡើយ" ដោយគាត់បានបញ្ជាក់ថា ជាទូទៅ *"ថ្នាក់លើ"* គ្រាន់តែប្រាប់ឲ្យគាត់ត្រៀមខ្លួនទទួលអ្នកទោសតែប៉ុណ្ណោះ។ ភាគច្រើនអ្នកទោសត្រូវបានអង្គភាពរបស់ពួកគេនាំយកមកតែម្តង។ ប៉ុន្តែ ភស្តុតាងមួយចំនួនបានបង្ហាញថា បុគ្គលិកមន្ទីរ ស២១ ជួនកាលបានធ្វើការចាប់ខ្លួនដោយផ្ទាល់[៣០៣]។

១៦៧. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្តីថ្លែងទាំងនេះ[៣០៤]។

១៦៨. ជាទូទៅ ថ្នាក់លើរបស់ជនជាប់ចោទជាអ្នកសម្រេចថា តើអ្នកណាត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស២១[៣០៥]។ ម្តងម្កាល ជនជាប់ចោទបានបញ្ជាទៅបុគ្គលិករបស់គាត់នៅមន្ទីរស២១ ដើម្បី

---

[៣០៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៥១-៥២ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[៣០៤] ប្រតិចារិក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៤-៥៨។ *សូមមើលផងដែរ* "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1, កថាខណ្ឌ១១១-១១៥។

ឲ្យអនុវត្តនូវបញ្ជាចាប់ខ្លួននៅខាងក្រៅមន្ទីរស២១[៣០៦]។ ជនជាប់ចោទតែងតែទទួលបានការជូនដំណឹងនៅពេលមានការចាប់ខ្លួន ហើយគាត់បានប្រាប់ដំណឹងនេះទៅអ្នកនៅក្រោមបង្គាប់របស់គាត់អំពីការមកដល់នៃអ្នកត្រូវជាប់ឃុំ[៣០៧]។

១៦៩. យ៉ាងណាក៏ដោយ មានភស្តុតាងបញ្ជាក់ថា ជនជាប់ចោទដើរតួនាទីយ៉ាងសកម្មក្នុងការរៀបចំឲ្យមានការចាប់ខ្លួនលើកដំបូង ហើយមតិយោបល់របស់គាត់ត្រូវបានថ្នាក់លើរបស់គាត់អនុវត្តតាម។ នៅពេល សុន សេន ចូលរួមក្នុងកិច្ចប្រជុំមួយដែលនិយាយអំពីការអនុវត្តគោលនយោបាយបក្សកុម្មុយ-នីស្តកម្ពុជា ជនជាប់ចោទបានបង្ហាញអំពីអត្តសញ្ញាណរបស់ជនសង្ស័យ ហើយបានពិភាក្សា និងសហ-ការអំពីវិធីសាស្ត្រនៃការចាប់ខ្លួន[៣០៨]។ កិច្ចប្រជុំនោះបានផ្តល់សិទ្ធិឲ្យមានកិច្ចសហការគ្នារវាងមន្ទីរស២១ និងអង្គភាពផ្សេងទៀតដើម្បីអនុវត្តការចាប់ខ្លួននោះ។ ជនជាប់ចោទបង្ខំចិត្តទទួលស្គាល់ថា គាត់ពិតជាមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ប៉ុន្តែគាត់បានជំទាស់ដែលថា គាត់គឺជាសមាជិកពេញសិទ្ធិដែលមានសិទ្ធិក្នុងការបញ្ចេញមតិ។ គាត់បានលើកឡើងថា តួនាទីរបស់គាត់ គឺគ្រាន់តែកត់ត្រាឈ្មោះ ហើយបញ្ជូនឈ្មោះអ្នកទាំងនោះទៅអង្គប្រជុំដើម្បីធ្វើសេចក្តីសម្រេចចិត្តតែប៉ុណ្ណោះ[៣០៩]។

១៧០. លើសពីនេះទៀត នៅក្នុងលិខិតដែល ស៊ូ ម៉េត (មេបញ្ជាការកងពលធំ៥០២) ផ្ញើរឲ្យជនជាប់ចោទ ស៊ូ ម៉េត បានស្នើសុំឲ្យមានចំណាត់ការមួយចំនួនលើអ្នកជាប់ឃុំដែលគាត់បានបញ្ជូន

---

[៣០៥] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩-១១, ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៩-១០, ១៣-១៤។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៦៥-៦៦។

[៣០៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៦-៥៨។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៤៩, ៥០-៥១។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៧៩-៨១។

[៣០៧] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៤។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ១៨។

[៣០៨] ប្រតិចារឹក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៧៨-៧៩។ "កំណត់ហេតុនៃការប្រជុំសមមិត្តតាល់ កងពល២៩០ និងកងពល១៧០" ឯកសារ E3/160, ERN (ភាសាខ្មែរ) 00002233។

[៣០៩] ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៨-៤៣។

ទៅមន្ទីរស២១[៣១០]។ ជនជាប់ចោទមិនបានកែប្រែជំហររបស់គាត់ដែលគាត់បានលើកឡើងថា គាត់គ្មានទំនាក់ទំនងផ្ទាល់ជាមួយ ស៊ូ ម៉េត ទេ ហើយការទំនាក់ទំនងរបស់គាត់មិនបានរំលោភវិន័យ ដែលហាមឃាត់មិនឲ្យមានការទំនាក់ទំនងគ្នាផ្ទាល់រវាងតំបន់ ឬអង្គភាពនោះទេ។ រាល់ទំនាក់ទំនងទាំងអស់ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរតាមការណែនាំ និងការដឹងរបស់ថ្នាក់លើគាត់គឺ សុន សេន ឬ នួន ជា។ ជនជាប់ចោទបាន អះអាងថា ឈ្មោះរបស់ សុន សេន និងក្រោយមកឈ្មោះរបស់ នួន ជា មិនត្រូវបានបញ្ចូលក្នុងការឆ្លើយឆ្លងនោះទេ ព្រោះដើម្បីលាក់បាំងពីការចូលរួមរបស់ពួកគេ។ ប៉ុន្តែគាត់បានអះអាងទៀតថា រាល់ការទំនាក់ទំនងទាំងអស់ត្រូវបានពួកគាត់ដឹង ឬណែនាំ ហើយគាត់ទទួលបានលិខិតឆ្លើយឆ្លងនេះដោយផ្ទាល់ពីថ្នាក់លើរបស់គាត់។ ការពន្យល់របស់ជនជាប់ចោទដែលថាលិខិតទាំងអស់នេះត្រូវបានប្រគល់មកឲ្យគាត់ផ្ទាល់តាមរយៈ សុន សេន នោះគឺមិនអាចជឿបានទេ ព្រោះថាជនជាប់ចោទបានទទួលដំណឹងពី ស៊ូ ម៉េត តាមរយៈសំបុត្រមួយចំនួនថា អ្នកជាប់ឃុំនឹងត្រូវបញ្ជូនទៅឲ្យគាត់នៅល្ងាចនោះ[៣១១]។ ការពិតដែលថាគាត់រង់ចាំទទួលអ្នកជាប់ឃុំ ហើយត្រៀមខ្លួនជាស្រេចដើម្បីទទួលអ្នកទាំងនោះ បញ្ជាក់ថា សំបុត្រទាំងនោះត្រូវបានផ្ញើរផ្ទាល់ទៅឲ្យគាត់ ហើយជនជាប់ចោទ និង ស៊ូ ម៉េត ទំនាក់ទំនងគ្នាដោយផ្ទាល់អំពីការចាប់ខ្លួន ទោះបីជាការចាប់ខ្លួនទាំងនោះសុទ្ធតែធ្វើឡើងដោយមានការឯកភាពពីថ្នាក់លើរបស់គាត់។

១៧១. លើសពីនេះទៀត ជនជាប់ចោទមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការចាប់ខ្លួនបុគ្គលិកមន្ទីរស២១។ ទីមួយ ការសម្រេចថាតើត្រូវបញ្ជូនបុគ្គលិកមន្ទីរស២១ ទៅស២៤ ដើម្បី "កសាងខ្លួន" គឺត្រូវធ្វើឡើង

---

[៣១០] "របាយការណ៍អ្នកជំនាញការ Craig ETCHESON" ឯកសារ E3/32, ERN (ភាសាខ្មែរ) 00314827-00314828។ "របាយការណ៍ពី ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៧៧" ឯកសារ E3/40 ។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៧" ឯកសារ E3/210 ។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧" ឯកសារ E3/211 ។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៧" ឯកសារ E3/212 ។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៧" ឯកសារ E3/213 ។ "របាយការណ៍ពី ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៧" ឯកសារ E3/214។ លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧" ឯកសារ E3/215 ។ លិខិតរបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៧៧" ឯកសារ E3/216 ។

[៣១១] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-៣១។

ដោយគណៈកម្មាធិការមន្ទីរស២១ មិនមែនធ្វើឡើងដោយថ្នាក់លើរបស់ជនជាប់ចោទនោះទេ[៣១២]។ ទីពីរ ទោះបីជាការសម្រេចចុងក្រោយថាតើត្រូវចាប់ខ្លួនបុគ្គលិកមន្ទីរស២១រូបណា អាចជាការសម្រេចរបស់ថ្នាក់លើគាត់ក៏ដោយ ក៏ជនជាប់ចោទបានទទួលស្គាល់ថា ថ្នាក់លើរបស់គាត់ចាំតែធ្វើតាមមតិយោបល់របស់គាត់តែប៉ុណ្ណោះ។ ជនជាប់ចោទបានលើកឡើងថា "មនុស្សដែលខ្ញុំ និងមិត្ត ហ៊ឹងកភាពគ្នាស្រួលបួល ហើយរាយការណ៍ទៅលើ មិនដែលឃើញអ្នកណាមួយ ខ្ញុំមិនចាំ ពិតជាមិនចាំថាមានអ្នកណាមួយរួចខ្លួន ដែលខាងលើសម្រេចបដិសេធសេចក្ដីរាយការណ៍របស់ខ្ញុំនោះទេអត់មាន"[៣១៣]។ ជនជាប់ចោទបានអនុវត្តនូវសិទ្ធិមួយចំនួននៅក្នុងបញ្ហាទាំងអស់នេះ ហើយគាត់បានបញ្ជាក់ថា គាត់មិនបានរាយការណ៍អំពីបុគ្គលិករបស់គាត់ទាំងអស់នោះទេ ឬបានរាយការណ៍ដែរ តែមិនបានលើកយោបល់ឲ្យចាប់ខ្លួនពួកគេនោះទេ[៣១៤]។

១៧២. ជនជាប់ចោទក៏មានវត្តមានផងដែរក្នុងអំឡុងពេលនៃការចាប់ខ្លួនអ្នកជាប់ឃុំសំខាន់ៗមួយចំនួនរួមទាំងការចាប់ខ្លួន កុយ ធួន (លេខាភូមិភាគឧត្តរ និងក្រោយមកជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម)។ ឈឹម សំអោក ហៅ ប៉ង់ (អតីតលេខា ម៨៧០) នៃ សាវ៉ាន ហៅ ម៉ែន សាន ហៅ យ៉ា (លេខាភូមិភាគព្រៃសាន្ត) និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ (សមាជិកគណៈកម្មាធិការមន្ទីរស២១)។ ការចាប់ខ្លួនមួយចំនួនត្រូវបានធ្វើឡើងនៅផ្ទះរបស់ជនជាប់ចោទតែម្ដង[៣១៥]។

---

[៣១២] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៤។

[៣១៣] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៦។

[៣១៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៣។

[៣១៥] *សូមមើលឧទាហរណ៍* ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ១១-១២, ១៣-១៤, ១៥។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៨។ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១២៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤៣-៤៤។

១៧៣. លើសពីនេះទៀត ដូចដែលបានរៀបរាប់យ៉ាងពិស្តារខាងក្រោមនេះ ជនជាប់ចោទបានពិនិត្យ និងបញ្ជូនទៅឱ្យថ្នាក់លើរបស់គាត់នូវចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងបញ្ជីឈ្មោះ "ជនក្បត់" ដែលជាបញ្ជីប្រើសម្រាប់ការផ្តល់ដំណឹង និងសម្រួលដល់ការចាប់ខ្លួនជាបន្តបន្ទាប់ទៀត។

### ២.៣.៣.៥.៤ តួនាទីក្នុងការពិនិត្យចម្លើយសារភាព

១៧៤. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ៤៣. [...] ក្រៅពីការសម្លាប់អ្នកទោសដែលត្រូវបានចោទជាមុនថាជាជនក្បត់ មន្ទីរ ស២១ មានតួនាទីយ៉ាងសំខាន់ក្នុងការយកចម្លើយសារភាពពីអ្នកទោសដើម្បីរែកមុខបណ្តាញក្បត់ផ្សេងទៀត។ ឌុច បានអះអាងថា "*អត្ថន័យនៃចម្លើយសារភាព គឺជាការងារចម្បងរបស់មន្ទីរស-២១*"។ ចម្លើយសារភាពភាគច្រើនមានទំរង់ជាប្រវត្តិនយោបាយដែលសរសេរដោយអ្នកទោសខ្លួនឯង ហើយដោយទទួលរងនូវការបង្ខិតបង្ខំ ចម្លើយសារភាពនេះក្លាយទៅជាការបរិហារអំពីខ្លួនឯង និងការចោទប្រកាន់អ្នកដទៃថាក្បត់ ព្រោះបានបម្រើឱ្យចារកម្មបរទេស ដែលជាសត្រូវរបស់បដិវត្តន៍កម្ពុជា ដូចពួកសេអ៊ីអា (CIA) កាហ្សេបេ (KGB) និងភ្នាក់ងារបក្សកុម្មុយនីស្តវៀតណាម។ ចម្លើយសារភាពខ្លះមានកម្រាស់រហូតដល់រាប់រយទំព័រ ដែលមិនត្រឹមតែធ្វើការពណ៌នាលំអិតអំពីការចោទប្រកាន់អំពីអំពើក្បត់ប៉ុណ្ណោះទេ ថែមទាំងបរិយាយយ៉ាងលំអិតផងដែរអំពីរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់អង្គការបក្សគ្រប់ជាន់ថ្នាក់ និងគ្រប់អង្គភាពរដ្ឋបាលទាំងអស់។ ឌុច បានអាន វិភាគ ធ្វើចំណារ និងសង្ខេបយ៉ាងល្អិតល្អន់លើចម្លើយសារភាពភាគច្រើន ដើម្បីរាយការណ៍ជូនថ្នាក់លើ[...][៣១៦]។

១៧៥. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្តីថ្លែងទាំងនេះ[៣១៧]។

---

[៣១៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៤៣ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[៣១៧] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥២-៥៣។

១៧៦. ជនជាប់ចោទយល់ថាតួនាទីរបស់គាត់ជាប្រធានមន្ទីរស២១ គឺគ្រាន់តែធ្វើតាមបញ្ជាថ្នាក់លើរបស់គាត់ដើម្បី៖ សួរចម្លើយ តាមដាន "ប្រវត្តិក្បត់ ប្រវត្តិក្បត់ពីមុន ប្រវត្តិក្បត់បច្ចុប្បន្ន [...] ដើម្បីសម្រួលដល់ការអាន អ្នកទោសត្រូវតែដកស្រង់ឈ្មោះដែលខ្លួនឆ្លើយដាក់"[៣១៨]។ ដើម្បីធ្វើដូច្នេះ ជនជាប់-ចោទបានពិនិត្យចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងផ្ដល់ការណែនាំជាប់ជាប្រចាំទៅអ្នកសួរចម្លើយរហូតទាល់តែគាត់គិតថា ចម្លើយសារភាពបានចប់សព្វគ្រប់អស់ហើយ[៣១៩]។ ចម្លើយសារភាពមិនទាន់ពេញលេញនោះទេ ប្រសិនបើព័ត៌មានដែលទទួលបានមិនទាន់លម្អិតគ្រប់គ្រាន់ ឬមិនបានឆ្លើយដាក់ឈ្មោះ"ជនក្បត់"[៣២០] ផ្សេងៗទៀត។ ដូចជនជាប់ចោទបានលើកឡើង "បើកាលណាអ្នកឆ្លើយគេឆ្លើយមិនពេញចិត្តយើងទេ មានចំណារនៅសល់ ដែលខ្ញុំចារទៅទារុណកម្មកម្រិតនេះថែមទៀតយ៉ាងម៉េចអីនៅមានសល់ចំណារខ្ញុំជាភស្តុតាង។ ដូច្នេះ ខ្ញុំជាអ្នកតម្រូវអ្នកបញ្ជាឱ្យគេធ្វើទារុណកម្មថែមទៀត"[៣២១]។ ក្នុងករណី អ្នកជាប់ឃុំសំខាន់ៗរបស់មន្ទីរ ស២១ ជនជាប់ចោទត្រូវរង់ចាំការណែនាំជាក់លាក់ពីថ្នាក់លើរបស់គាត់ ថាតើត្រូវធ្វើទារុណកម្មកម្រិតណា នៅពេលសួរចម្លើយអ្នកជាប់ឃុំសំខាន់ៗទាំងអស់នោះ[៣២២]។

១៧៧. ចំណាររបស់ជនជាប់ចោទលើចម្លើយសារភាពដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ សុទ្ធតែបានបង្ហាញអំពីបញ្ជារបស់គាត់ទៅអ្នកសួរចម្លើយ។ នៅលើចម្លើយសារភាពរបស់អ្នកជាប់ឃុំ ដាញ់ ស៊ីយ៉ាន ជនជាប់ចោទបានសរសេរថា "សួរឱ្យច្បាស់ + ទារុណកម្មឱ្យធ្ងន់មធ្យម ទិសដៅគឺរក

[៣១៨] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៨។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤៤។

[៣១៩] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣, ៣២-៣៣, ៤៣។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៣៣-៣៤។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២១-២៤, ៥០-៥១។

[៣២០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៩-៧១។

[៣២១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៥-៦៦។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៥-២៦។

[៣២២] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៤, ១៧។

ខ្សែសង្វាក់។ វាយឲ្យឈប់និយាយថាទៅស្រុកយួន ឲ្យជីតាព្យាបាលរោគម្រេញ+ រាំងថ្ងៃ ខែ"[៣២៣]។ ចំណាររបស់គាត់លើចម្លើយសារភាពរបស់អ្នកជាប់ឃុំ អ៊ុម សឿន ថា "មិនទាន់សារភាពទេ! ទារុណ-កម្ម"[៣២៤] ហើយចំណាររបស់គាត់លើចម្លើយសារភាពរបស់អ្នកជាប់ឃុំ ព្រុំ សំនៀង ថា "មេនេះវានិយាយតិចណាស់! មិនបាច់សង្ខេបអ្វីទេ! ខ្ញុំពុំពន្យល់អ្វីទេ ហើយវាយវា ៤០ រំពាត់ + ជំរុញឲ្យវាសរសេរទៀត។ ល្ងាចនេះ បើពុំពេញចិត្តទេ។ បងចាត់ឲ្យគេធ្វើទារុណកម្មទៀត ហើយឲ្យសរសេរទៀត។ វាមិនស្រួលខ្លួនឥឡូវនេះ"[៣២៥]។ អ្នកសួរចម្លើយក៏បានប្រើចំណារលើចម្លើយសារភាពដែរ ដើម្បីឲ្យជនជាប់ចោទពិនិត្យមើលអំពីការរីកចម្រើនរបស់ខ្លួនក្នុងការសួរចម្លើយ និងស្ថានភាពរបស់អ្នកជាប់-ឃុំ[៣២៦]។

១៧៨. បន្ទាប់ពីការពិនិត្យមើលទៅលើចម្លើយសារភាពរួចហើយ ជនជាប់ចោទគឺជាមនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវចំពោះការផ្ញើរចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងបញ្ជីឈ្មោះអ្នកដែលត្រូវបានគេឆ្លើយដាក់ទៅឲ្យថ្នាក់លើរបស់គាត់[៣២៧]។ ដើម្បីជួយសម្រួលការងារថ្នាក់លើរបស់គាត់ ជនជាប់-

---

[៣២៣] *សូមមើល* "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៨" ឯកសារ E3/378, ERN (English) 00185491-00185492។ *សូមមើលផងដែរ* "សម្រង់របាយការណ៍ចម្លើយសារភាពរបស់ ដាញ់ ស៊ីយ៉ាន" ឯកសារ E3/368, ERN (ភាសាខ្មែរ) 00172772។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។

[៣២៤] *សូមមើល* "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៨" ឯកសារ E3/378, ERN (ភាសាខ្មែរ) 00185491-00185492។ *សូមមើលផងដែរ* "សម្រង់ចម្លើយសារភាពរបស់ អ៊ុំ សឿន" ឯកសារ E3/24, ERN (ភាសាខ្មែរ) 00172779-00172863។

[៣២៥] "សម្រង់ចម្លើយសារភាពរបស់ ព្រុំ សំនៀង" ឯកសារ E5/2.3, ERN (ភាសាខ្មែរ) 00227192។ *សូមមើលផងដែរ* "សម្រង់ចម្លើយសារភាពរបស់ ស ភន" ឯកសារ E5/2.1, ERN (ភាសាខ្មែរ) 00227633។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦-១៧, ៣០-៣១ ។ "ចម្លើយសារភាពមន្ទីរ ស២១ របស់ សាន ហៅ យ៉ា" ឯកសារ E3/372, ERN (ភាសាខ្មែរ) 00009538។

[៣២៦] *សូមមើលឧទាហរណ៍* "សម្រង់ចម្លើយសារភាពរបស់ អ៊ុំ សឿន" ឯកសារ E3/24, ERN (English) 00223146 ។ "សម្រង់ចម្លើយសារភាពរបស់ លី ផែល ហៅ សំរិត" ឯកសារ E3/234, ERN (ភាសាខ្មែរ) 00172668-00672771។

[៣២៧] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៥៩-៦០ ។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១០១, ១២៤។

ចោទបានបញ្ចូលចំណាររបស់គាត់ និងសេចក្តីសង្ខេបចំពោះឯកសារទាំងនេះផងដែរ[៣២៨]។ យោងតាមអ្នកជំនាញ David CHANDLER ជនជាប់ចោទខិតខំប្រឹងប្រែងធ្វើការឲ្យមានប្រសិទ្ធភាពអស់ពីកម្លាំងកាយចិត្តតាមដែលគាត់អាចធ្វើបាន និងដើម្បីបង្ហាញការងារវិជ្ជាជីវៈរបស់គាត់ និងក៏ "ដើម្បីជាការបង្ហាញមេដឹកនាំជាន់ខ្ពស់ឲ្យបានលម្អិតបំផុតតាមដែលអាចធ្វើបាន តាមរបៀបណាមួយដែលថា ការសង្ស័យមានមូលហេតុដែរ ឬទេ? ចំពោះអ្នកទោសមួយចំនួននោះ ហើយដើម្បីនឹងលាក់កំបាំងលាត-ត្រដាងនូវខ្សែខ្មាំង គឺគិញយួនត្រូវបានផ្តល់ព័ត៌មាន"[៣២៩] ផងដែរ។

១៧៩. ជនជាប់ចោទបានដឹងថា ព័ត៌មានភាគច្រើននៅក្នុងចម្លើយសារភាព ដែលគាត់បានផ្ញើរទៅឲ្យថ្នាក់លើរបស់គាត់គឺជាព័ត៌មានប្រឌិតទេ[៣៣០]។ ទោះបីជាយ៉ាងនេះក្តី ចម្លើយសារភាពមន្ទីរស២១ត្រូវបានប្រើប្រាស់ដើម្បីសម្រេចចាប់ខ្លួនអ្នកដែលត្រូវបានឆ្លើយដាក់ថាជាភ្នាក់ងារខ្មាំង ហើយជាញឹកញាប់ចម្លើយសារភាពទាំងនោះត្រូវបានគេប្រើប្រាស់ដើម្បីចាប់ខ្លួនអ្នកផ្សេងជាច្រើនទៀត ដោយសារតែមានការឆ្លើយដាក់ថាជាជនក្បត់[៣៣១]។ ចម្លើយសារភាពបានបម្រើផលប្រយោជន៍នយោបាយរបស់អ្នកដែល

---

[៣២៨] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៩។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១២។ *សូមមើលផងដែរ* "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ១២៤។

[៣២៩] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៦-១៧។

[៣៣០] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ១០១។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៦-៤៧។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣, ៥៥-៥៦។

[៣៣១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៣-៥៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៨-៣៩។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៩-១០ ។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ១៥, ៦៦-៦៧។

គ្រប់គ្រងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដោយបានផ្តល់យុត្តិកម្មសម្រាប់ការចាប់ខ្លួន និងអ្នកដែលជាប់ទាក់ទងនឹងខ្សែបណ្តាញជាមួយអ្នកដែលបានបញ្ជូនទៅមន្ទីរស២១[៣៣២] រួចហើយ។

## ២.៣.៣.៥.៥ តួនាទីក្នុងការសម្លាប់

១៨០. ជនគ្រប់រូបដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) សុទ្ធតែរង់ចាំការសម្លាប់ទាំងអស់[៣៣៣]។ យោងតាមលោក David CHANDLER

> អាណត្តិការងារដែលជនជាប់ចោទ ការងាររបស់គាត់នៅមន្ទីរស២១ នោះ គឺពិនិត្យមើល។ គាត់យល់ថា ម្នាក់ៗដែលគេបញ្ជូនមកមន្ទីរស២១ គឺត្រូវតែសម្លាប់។ នេះគឺជាអាណត្តិការងារ គឺមិនអាចដកវិញបានដោយថ្នាក់លើនោះទេ។ ដូច្នេះហើយគាត់មិនចាំបាច់ស្វែងរកអំណាចពីខាងលើ ដើម្បីគ្រប់គ្រងលើប្រព័ន្ធហ្នឹងដែលគាត់មិនមានជម្រើសថា តើអ្នកណាត្រូវសម្លាប់? អ្នកណាត្រូវទុកនោះទេ? ពីព្រោះគាត់យល់ថាម្នាក់ៗត្រូវតែស្លាប់។ [...] កុមារតូចៗ ហើយនិងអ្នកដែលបញ្ជូនមកទាំងអស់នោះ គឺត្រូវមានវាសនាដូចគ្នានោះឯង[៣៣៤]។

១៨១. ពីដំបូង ជនជាប់ចោទបានអនុញ្ញាតឲ្យ ឃឹម វ៉ាក ហៅ ហ៊ី ចាត់ចែងពេលវេលានៃការសម្លាប់អ្នកជាប់ឃុំ។ ប៉ុន្តែក្រោយពីមានហេតុការណ៍មួយដែលអ្នកជាប់ឃុំម្នាក់ត្រូវបានសម្លាប់មុនពេលគាត់ផ្តល់ចម្លើយសារភាពចប់សព្វគ្រប់មក ជនជាប់ចោទបានតម្រូវថា គាត់ត្រូវតែបានដឹងថា ការសួរចម្លើយ

---

[៣៣២] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៥៨។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧-៣៩។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧០-៧១ ។ "សំឡេងពីមន្ទីរស២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" សៀវភៅនិពន្ធដោយ David CHANDLER ឯកសារ E3/427 ទំព័រ៨៩, ១៧២-១៧៣, ERN (English) 00191929, 00192012-00192013។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ២០-២១, ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៤១-៤២។

[៣៣៣] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៦០។

[៣៣៤] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ៦៥-៦៧។

ត្រូវបានចប់សព្វគ្រប់ មុននឹងយកអ្នកជាប់ឃុំទៅសម្លាប់[៣៣៥]។ ដូចដែលជនជាប់ចោទបានលើកឡើង "តាំងពីពេលនោះមក មុននឹងយកទៅត្រូវតែសុំយោបល់ខ្ញុំសិន សួរចប់ហើយ ឬនៅ? បើសួរចប់ហើយ អាហ្នឹងគេចាត់ចែងហើយ [...]"[៣៣៦]។ នៅក្នុងករណីខ្លះទៀត ការសម្លាប់ទ្រង់ទ្រាយធំបានកើតមានឡើងនៅពេលដែលជនជាប់ចោទបានទទួលបញ្ជា និងអនុវត្តបញ្ជាឲ្យមានការសម្លាប់ដោយមិនចាំបាច់មានការសួរចម្លើយនោះទេ[៣៣៧]។ ដោយមានការឯកភាពពីជនជាប់ចោទ ហ៊ី អាចចាត់ចែងការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស២១ ដោយមានជំនួយពីអ្នកនៅក្រោមបង្គាប់របស់គាត់[៣៣៨]។

១៨២. ជនជាប់ចោទបានអះអាងបញ្ជាក់ថា ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួមមាន ចំណាររបស់គាត់បញ្ជាឲ្យមានការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស២១។ នៅក្នុងបញ្ជីមួយដែលមានឈ្មោះអ្នកទោសចំនួន១៧នាក់ (ក្មេងជំទង់៨នាក់ និងកុមារ៩នាក់) ជនជាប់ចោទបានសរសេរចំណារដែលបញ្ជាថា "វាយចោលឲ្យហួត់"[៣៣៩]។ នៅក្នុងបញ្ជីដែលមានឈ្មោះអ្នកជាប់ឃុំជាច្រើន ចំណាររបស់ជនជាប់ចោទបានសរសេរថា "កំទេច ១១៥ នាក់ ទុក ៤៤ នាក់"។ ចំណារដែលស្ថិតនៅខាងក្រោមអត្ថបទនេះសរសេរថា "សមមិត្ត ឌុច ស្នើអង្គការហើយ។ អង្គការបានយល់ព្រម"[៣៤០]។ នៅ

---

[៣៣៥] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៦, ៧-៩, ១៦-១៩, ២៤, ៤៩-៥០។

[៣៣៦] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៧៦-៧៨។

[៣៣៧] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧២-៧៤។

[៣៣៨] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤, ២៩។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៩-៥៦។

[៣៣៩] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០។ *សូមមើលផងដែរ* "បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស២១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨" ឯកសារ E3/367, ERN (ភាសាខ្មែរ) 00001890។

[៣៤០] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ២១-២២។ *សូមមើលផងដែរ* "បញ្ជីឈ្មោះអ្នកទោសដែលបានផ្អាកក្នុងខែមករា ឆ្នាំ១៩៧៧" ឯកសារ E3/370, ERN (ភាសាខ្មែរ) 00106315។

ក្នុងបញ្ជីដែលមានអ្នកជាប់ឃុំស្ត្រីចំនួន២០នាក់ ជនជាប់ចោទបានសរសេរចំណារលើបញ្ជីឈ្មោះនីមួយៗ ដែលបញ្ជាឲ្យយកទៅសម្លាប់ "វាយចោល" "ទុកសួរ" ឬ "ពិសោធន៍ថ្នាំ"[៣៤១]។

១៨៣. ជនជាប់ចោទមានសិទ្ធិអំណាចក្នុងការពន្យារការសម្លាប់អ្នកជាប់ឃុំ ដោយរួមបញ្ចូលទាំងអ្នកបកប្រែភាសា ជាងម៉ាស៊ីន អ្នកគូរផ្ទាំង ដែលសុទ្ធតែជាអ្នកមានជំនាញសំខាន់ៗសម្រាប់ប្រើប្រាស់នៅមន្ទីរស២១[៣៤២]។

២.៣.៣.៦ ជើងឯក

១៨៤. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ២៩. កាលពីដំបូងអ្នកទោសត្រូវបានគេសម្លាប់នៅក្នុង ឬនៅជុំវិញបរិវេណមន្ទីរស២១។ ដោយមិនបានដឹងពីថ្ងៃខែច្បាស់លាស់ ពីចន្លោះឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ម្យ៉ាងដើម្បីបញ្ចៀសជំងឺឆ្លង ឌុច បានជ្រើសរើសយកជើងឯកធ្វើជាទីកន្លែងសម្រាប់សម្លាប់អ្នកទោស។ ជើងឯកស្ថិតនៅប្រមាណ១៥គីឡូម៉ែត្រ ភាគនិរតីនៃក្រុងភ្នំពេញក្នុងខេត្តកណ្តាល។ សព្វថ្ងៃ ជើងឯកបានក្លាយជាបូជនីយដ្ឋានមួយទៅហើយ។ នៅឯវាលពិឃាតជើងឯក មានផ្ទះឈើមួយខ្នង សម្រាប់ដាក់អ្នកទោសមុនពេលសម្លាប់ និងរណ្តៅដែលនៅមាត់រណ្តៅនោះ ជាកន្លែងសម្រាប់វាយសម្លាប់អ្នកទោស។ ទោះបីជាជើងឯក បានក្លាយទៅជាកន្លែងសម្លាប់អ្នកទោសក៏ដោយក៏នៅមានអ្នកទោសខ្លះនៅតែត្រូវបានគេសម្លាប់ និងកប់នៅក្នុងបរិវេណមន្ទីរស២១ ឬក្បែរបរិវេណនោះ[៣៤៣]។

១៨៥. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្តីថ្លែងនេះ[៣៤៤]។

---

[៣៤១] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២៤។ *សូមមើលផងដែរ* "បញ្ជីឈ្មោះអ្នកទោសផ្នែកនារី" ឯកសារ E3/371, ERN (ភាសាខ្មែរ) 00171139-00171144។

[៣៤២] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៥។

[៣៤៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ២៩ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[៣៤៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៦-៤៨។

00573445



១៨៦. ជនជាប់ចោទបានជ្រើសរើសទីកន្លែងសម្រាប់ផ្លាស់ប្តូរកន្លែងសម្លាប់ និងកប់សាកសពពីមន្ទីរ ស២១ ទៅជើងឯក ដោយខ្លួនឯង ហើយបានជូនដំណឹងអំពីការសម្រេចនេះទៅថ្នាក់លើរបស់គាត់[៣៤៥]។ បន្ទាប់ពីជើងឯកត្រូវបានរៀបចំរួចហើយ ថ្នាក់លើរបស់ជនជាប់ចោទបានស្នើថា កន្លែងសម្លាប់ និងកប់សាកសពគួរតែផ្លាស់ទៅកន្លែងផ្សេង ដែលបានជ្រើសរើសពីមុនរួចហើយ។ ជនជាប់ចោទបានជម្រាបជូនថ្នាក់លើរបស់គាត់ថា គាត់មិនអាចផ្លាស់ប្តូរកន្លែងបានទេ ដោយគាត់ភ័យខ្លាចថា អាចមានអ្នកផ្សេងឃើញសាកសពអ្នកដែលត្រូវបានសម្លាប់រួចនៅជើងឯក។ ថ្នាក់លើរបស់គាត់បានឯកភាពទាំងទើសទាល់ ហើយកន្លែងសម្លាប់ និងកប់សាកសពត្រូវបានរក្សានៅជើងឯកដដែល[៣៤៦]។

១៨៧. អ្នកយាមមួយចំនួនតូចត្រូវបានចាត់តាំងឲ្យប្រចាំការនៅជើងឯក ហើយទទួលខុសត្រូវរក្សាការសម្ងាត់ចំពោះទីកន្លែងសម្លាប់ ការដឹករណ្តៅ និងកប់សាកសពអ្នកជាប់ឃុំ[៣៤៧]។

១៨៨. អ្នកជាប់ឃុំមន្ទីរស២១ ត្រូវបានបញ្ជូនទៅជើងឯកទាំងដៃជាប់ខ្នោះ និងចងមុខហើយដឹកជញ្ជូនតាមរថយន្តដែលដឹកជញ្ជូនដោយអង្គភាពកងពិសេស។ អ្នកជាប់ឃុំទាំងនោះត្រូវបានគេប្រាប់ថា ត្រូវផ្លាស់ទៅនៅផ្ទះថ្មី។ អ្នកជាប់ឃុំណាដែលខ្សោយខ្លាំងពេក ហើយមិនអាចដើរដោយខ្លួនឯងបាន ត្រូវបានគេលើកដាក់លើរថយន្ត[៣៤៨]។ បន្ទាប់ពីបានមកដល់ជើងឯកហើយ អ្នកជាប់ឃុំទាំងនោះត្រូវបាន

---

[៣៤៥] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧។ ប្រតិចារឹកចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣, ៣១-៣៤។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៥១-៥២។

[៣៤៦] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៦។

[៣៤៧] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩, ២៦-២៧, ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៨-៥៤, ៧៥-៧៦។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ តយ តេង) ទំព័រ៤១-៤៣។

[៣៤៨] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៤។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០-៣២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៩-១០, ៤៨-៥៤, ៧៥-៧៦។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣-៤។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩ (ការស្តាប់ចម្លើយរបស់សាក្សី មាស ប៉េងគ្រី) ទំព័រ៧២-៧៥។

គេដាក់នៅក្នុងផ្ទះឈើមួយ ដើម្បីផ្ទៀងផ្ទាត់ឈ្មោះឡើងវិញ។ បន្ទាប់មក អ្នកជាប់ឃុំត្រូវបានគេនាំម្តងម្នាក់ៗ ដោយដៃនៅជាប់ខ្នោះ និងចងមុខដដែល សំដៅទៅកាន់រណ្តៅដែលទើបតែជីកថ្មីៗ ជាកន្លែងដែលពួកគេត្រូវគេសម្លាប់យ៉ាងប្រញាប់ប្រញាល់ជាទីបំផុត[៣៤៩]។

១៨៩. ទោះបីជាជើងឯកត្រូវបានបង្កើតក្តី ក៏នៅមានអ្នកជាប់ឃុំមួយចំនួន រួមមានកុមារ អតីតបុគ្គលិកមន្ទីរស២១ និងអ្នកទោសសំខាន់ៗ ត្រូវបានបន្តសម្លាប់ និងកប់នៅជិត ឬនៅមន្ទីរស២១ (ទួលស្លែង) ដដែល[៣៥០]។ បុគ្គលមួយចំនួនដែលជាប់ឃុំនៅស២៤ ក៏ត្រូវបានបញ្ជូនទៅជើងឯកដើម្បីសម្លាប់ផងដែរ[៣៥១]។

### ២.៣.៣.៧ ស២៤

១៩០. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ៣០. ឌុច បានទទួលស្គាល់ថា ស២៤ ជាផ្នែកមួយរបស់មន្ទីរស២១។ ជាគោលការណ៍ ស២៤ នេះមានភារកិច្ចកែប្រែ និងកសាងយុទ្ធជន ព្រមទាំងធ្វើស្រែដើម្បីផ្គត់ផ្គង់មន្ទីរស២១ និងសាខានានា។ [...]
>
> ៥០. មានបញ្ជីឈ្មោះតិចតួចណាស់ដែលត្រូវបានរកឃើញជាហេតុនាំឱ្យមានការលំបាកក្នុងការកំណត់ឱ្យបានច្បាស់នូវចំនួនមនុស្ស ដែលត្រូវបានគេបញ្ជូនទៅ ស២៤។ តែទោះបីជាយ៉ាងណាក៏ដោយ ចំនួនអ្នកជាប់ឃុំជាចិន្ត្រៃយ៍នៅទីនោះអាចមានរហូត

---

[៣៤៩] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ៣៤-៣៥, ៤២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥១-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ តយ គេង) ទំព័រ៤១-៤៤។

[៣៥០] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤០-៤២, ៥៥-៥៦។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៩-៥០។

[៣៥១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៤-៦៥។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៩-៤១។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៩។

ដល់រាប់រយនាក់ ហើយ ឌុច ក៏បានយល់ស្របលើចំនួននេះដែរ។ សាក្សីជាច្រើនបាន អះអាងថា ទាំងបុរស ទាំងស្ត្រី និងកុមារ ត្រូវបានគេឃុំខ្លួននៅ ស២៤ នោះ។ ឌុច បានឲ្យដឹងថា ជនជាប់ឃុំឃាំងនៅព្រៃសមានពីរប្រភេទ៖ ទីមួយ ជនជាប់សង្ស័យ ដោយសារតែទំនាក់ទំនងសារលោហិតរបស់ពួកគេ និងទីពីរអ្នកក្រោមបង្គាប់របស់ កម្មាភិបាលថ្នាក់លើដែលត្រូវបានចាប់ខ្លួន។ ស២៤ ក៏ទទួលផងដែរនូវយុទ្ធជនមក ពីបណ្តាអង្គភាពនានា បុគ្គលិកមកពីបណ្តាក្រសួងស្ថាប័នដែលនៅជុំវិញក្រុងភ្នំពេញ និងសមាជិកក្រុមគ្រួសាររបស់ពួកគេ។ [...]

៧២. [...] [ស-២៤] ត្រូវបានប្រតិបត្តិការដោយយុទ្ធជន និងកម្មាភិបាលរបស់មន្ទីរ ស២១។ ឌុចបាន អះអាងថាមនុស្សទាំងនេះមិនមែននៅក្នុង "គុក" ដូចអ្នកទោស ដែលនៅទួលស្លែងឡើយ ហើយ សោម ម៉េត ដែលខ្លួនគាត់ផ្ទាល់ត្រូវបានបញ្ជូនទៅ កសាងខ្លួននៅស២៤ ក៏បានអះអាងយ៉ាងដូច្នោះដែរ។ ឌុចបាន បញ្ជាក់ថា អ្នកទោស និងបុគ្គលិកនៅព្រៃស មិនអាចដើរហើរសេរីដោយគ្មានការអនុញ្ញាតឡើយ (សាក្សី ជាច្រើនទៀតក៏បានអះអាងបែបនេះដែរ) ហើយច្បាប់នេះក៏ត្រូវបានអនុវត្តចំពោះ រូបគាត់ផងដែរ[៣៥២]។

១៩១. ជនជាប់ចោទបានយល់ស្របជាមួយនឹងសេចក្តីថ្លែងទាំងនេះ[៣៥៣]។

១៩២. ស២៤ ត្រូវបានគេស្គាល់ថា ព្រៃស ស្ថិតនៅខាងក្រៅទីក្រុងភ្នំពេញ ក្បែរវាលពិឃាដជើងឯក "ស្ថិតនៅម្តុំវត្តក្តុល ក្នុងខណ្ឌដង្កោ ខេត្តកណ្តាល[៣៥៤]។ ស២៤ គឺជា "មណ្ឌលលត់ដំខ្លួន" នៅក្នុងអំឡុង ពេលដែល អ៊ិន លន ហៅ ណាត ធ្វើជាប្រធានមន្ទីរស២១[៣៥៥]។ បន្ទាប់ពីជនជាប់ចោទត្រូវបានតែង

---

៣៥២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៣០, ៥០, ៧២ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

៣៥៣ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៦, ៤៧-៤៨, ៥៤-៥៥, ៥៦។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១៧៣។

៣៥៤ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៦-៤៨។

៣៥៥ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣-៤, ៣៥-៣៧។

តាំងជាប្រធានមន្ទីរស២១ ស២៤ ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ផងដែរ[៣៥៦]។ ជនជាប់ចោទបានលើកឡើងថា នៅពេលដែលស២៤ "ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ទាំងស្រុង" គាត់បានចាត់ ឃឹម វ៉ាក ហៅ ហ៊ិ និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាសមាជិកពីរនាក់ផ្សេងទៀតរបស់គណៈកម្មាធិការមន្ទីរស២១ ឱ្យរាយការណ៍ទៅឱ្យគាត់អំពីកិច្ចការប្រចាំថ្ងៃនៅទីនោះ[៣៥៧]។

១៩៣. នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ធ្វើការតែនៅស២៤ តែប៉ុណ្ណោះ ជាអ្នកមើលប្រតិបត្តិការការងារប្រចាំថ្ងៃនៅទីនោះដោយផ្ទាល់។ ប៉ុន្តែបន្ទាប់ពីការចាប់ខ្លួន ហ៊ុយ ស្រែ នៅខែធ្នូ ឆ្នាំ១៩៧៨ ផលត្រូវបានតែងតាំងឱ្យទៅមើលការខុសត្រូវស២៤ រហូតដល់ពេលបោះបង់មន្ទីរនេះចោលនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងអំឡុងពេលនោះ ជនជាប់ចោទបានទទួលរបាយការណ៍ជាទៀងទាត់អំពីប្រតិបត្តិការ ស២៤ ដែលរួមបញ្ចូលទាំងព័ត៌មានអំពីការងាររបស់អ្នកជាប់ឃុំ និងអត្តសញ្ញាណរបស់អ្នកដែលត្រូវបញ្ជូនពី ស២៤ ទៅមន្ទីរស២១ ឬជើងឯក។ ជនជាប់ចោទក៏បានបញ្ជាក់ថា គាត់បានទៅពិនិត្យមើល ស២៤ ចំនួន៤ដង[៣៥៨]។

១៩៤. យោងតាមជនជាប់ចោទ សុន សេន ជាអ្នកធ្វើការសម្រេច ថាទាហានរូបណាដែលត្រូវបញ្ជូនទៅ ស២៤ ចំណែកឯថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជាជាអ្នកសម្រេចទាក់ទងនឹងសមាជិកនៅក្នុងអង្គភាព

---

[៣៥៦] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៣-៤ ។

[៣៥៧] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១-១២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤១-៤២។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ៤៩-៥០។ ។

[៣៥៨] ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២១, ២៦។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧, ១២-១៤, ៣៣-៣៤។

00573449



ស៊ីវិល។ គណៈកម្មាធិការមន្ទីរស២១ មានសិទ្ធិអំណាចក្នុងការបញ្ជូនបុគ្គលិកពីមន្ទីរស២១ ទៅ ស២៤ ដើម្បី "ធ្វើការអប់រំ"[៣៥៩]។

១៩៥. អ្នកដែលត្រូវបញ្ជូនទៅស២៤ត្រូវបានចុះឈ្មោះដំបូងនៅកន្លែងមួយក្បែរមន្ទីរស២១(ទួលស្លែង) គឺនៅលើផ្លូវលេខ ៣៦០ ជាមុនសិន ហើយបន្ទាប់មកពួកគេត្រូវបានដឹកជញ្ជូនដោយអង្គភាពកងពិសេសទៅ ស២៤ ដែលជាកន្លែងពួកគេធ្វើប្រវត្តិរូប និងថតរូប និងដាក់ឲ្យធ្វើការនៅទីនោះ[៣៦០]។

១៩៦. អ្នកជាប់ឃុំនៅ ស២៤ ភាគច្រើនជាសាច់ញាតិ ឬអ្នកនៅក្រោមបង្គាប់របស់អ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) ជាយុទ្ធជន និងបុគ្គលិកមកពីក្រសួងមន្ទីរ ឬស្ថាប័នសាធារណៈនានា។ បុរស និងស្ត្រីត្រូវបានបំបែកចេញពីគ្នា ហើយជួនកាលកុមារដែលមាន ឬមិនមានឪពុកម្តាយមកជាមួយ ក៏ត្រូវបានឃុំគ្រងនៅ ស២៤ ផងដែរ។ យោងតាមសម្តីរបស់ជនជាប់ចោទ មិនមានជនជាតិវៀតណាម ឬពួកបស្ចិមប្រទេសត្រូវបានឃុំខ្លួននៅ ស២៤ នោះទេ [៣៦១]។ ទោះបីជាអ្នកយាម ស២៤ មើលការខុសត្រូវ និងធ្វើការជាមួយគ្នានឹងអ្នកជាប់ឃុំក៏ដោយ ក៏ពួកគេមិនមែនជាអ្នកជាប់ឃុំ

---

[៣៥៩] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៥។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៨-២៩, ៤៦-៤៧។

[៣៦០] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ២៩-៣០។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៨-២៩។

[៣៦១] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១០៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៤-៥៦។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៩, ៣២-៣៣។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១-២, ២១។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៧៣។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ធុន) ទំព័រ៧-៨។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ៤៨, ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ប៉ាន់) ទំព័រ៥៦-៥៧។

ដែរ លើកលែងតែអ្នកយាមទាំងនេះត្រូវបានចាប់ខ្លួននិងឃុំខ្លួនជាផ្លូវការ ដោយសារតែពួកគេបានប្រព្រឹត្តខុសនឹងតួនាទីរបស់ខ្លួន[៣៦២]។

១៩៧. អ្នកជាប់ឃុំត្រូវបានគេហៅថាជា "ពួកសមាសភាព"[៣៦៣] ហើយត្រូវបានចែកចេញជាបីក្រុមៈ ក្រុមទី១ គឺជាពួកសមាសភាពល្អ ដែលត្រូវលត់ដំស្រាលៗ។ ក្រុមទី២ ជាពួកសមាសភាពមធ្យម ហើយត្រូវលត់ដំមធ្យម ចំណែកឯក្រុមទី៣ ជាពួកសមាសភាពអាក្រក់ ដែលត្រូវលត់ដំឱ្យខ្លាំងជាងគេ[៣៦៤]។ ជនជាប់ចោទមិនបានជំទាស់នឹងអំណះអំណាងទាំងនេះទេ[៣៦៥]។

១៩៨. យោងតាមអ្នកជំនាញ David CHANDLER លក្ខណៈមួយដែលធ្វើឱ្យ ស២៤ ខុសពីមន្ទីរ ស២១ គឺថាអ្នកដែលត្រូវបានឃុំគ្រងនៅ ស២៤ អាចត្រូវបានដោះលែង[៣៦៦]។ ទោះបីជាយ៉ាងនេះក្តី ជនជាប់ចោទបានបញ្ជាក់ថា អ្នកជាប់ឃុំកម្រនឹងត្រូវបានគេដោះលែងណាស់ ហើយពួកគេទាំងអស់ត្រូវបានគេឃុំខ្លួនដើម្បីសម្លាប់ចោលប៉ុណ្ណោះ មិនថាពួកគេត្រូវបានចាត់ទុកក្នុងក្រុមទី១ ទី២ ឬទី៣ នោះទេ។ ជនជាប់ចោទបានផ្តល់សក្ខីកម្មថា គាត់បានដាក់បញ្ជាដល់បុគ្គលិកដែលធ្វើការនៅស២៤ ឱ្យសម្លាប់អ្នកជាប់ឃុំ ដោយផ្អែកតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ អ្នកជាប់ឃុំនៅ

---

[៣៦២] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១៧២-១៧៣, ១៨០។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ១២-១៣។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨" ឯកសារ E3/380, ERN (ភាសាខ្មែរ) 00178022។

[៣៦៣] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៩ (ជនជាប់ចោទ) ទំព័រ៥៦ (ប្រើប្រាស់ពាក្យជាភាសាបារាំង *"composant"*)។

[៣៦៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៤។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១២, ១៥-១៦, ២៧-២៨។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៤, ៣៣-៣៥។

[៣៦៥] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១៧៥ ។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៤។

[៣៦៦] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៨។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤២។

00573451



ស២៤ ដែលត្រូវបានកំណត់ថាត្រូវសម្លាប់ ហើយប្រសិនបើត្រូវការចម្លើយសារភាពរបស់អ្នកទាំងនោះ ដំបូងត្រូវតែបញ្ជូនពួកគេទៅមន្ទីរស២១ (ទួលស្លែង) ជាមុនសិន ចំណែកអ្នកដែលគេមិនត្រូវការចម្លើយសារភាពទេ អ្នកទាំងនោះត្រូវបានគេបញ្ជូនទៅជើងឯកផ្ទាល់ដើម្បីសម្លាប់ចោល។ ជាធម្មតា ជនជាប់ចោទជាអ្នកធ្វើសេចក្តីសម្រេចនេះ ទោះបីជាអ្នកនៅក្រោមបង្គាប់របស់គាត់អាចបញ្ជូនអ្នកជាប់ឃុំទៅជើងឯកផ្ទាល់ នៅពេលដែលអ្នកទាំងនោះមិនត្រូវការម្លើយសារភាពក៏ដោយ ករណីនេះមានដូចជាកុមារជាដើម[៣៦៧]។

១៩៩. ជនជាប់ចោទមិនបានប្រគល់ភារកិច្ចឲ្យបុគ្គលិក ស២៤ ក្នុងការសួរចម្លើយ និងទទួលចម្លើយសារភាពនោះទេ។ ទោះបីជាយ៉ាងនេះក្តី ជនជាប់ចោទបានទទួលស្គាល់ថាបុគ្គលិក ស២៤ ពិតជាបានសួរចម្លើយអ្នកជាប់ឃុំ ទោះបីជាពួកគេបានធ្វើដោយគ្មានការអនុញ្ញាតពីគាត់ក៏ដោយ។ ជនជាប់ចោទបានយល់ស្របថា បុគ្គលិក ស២៤ បានធ្វើបាបអ្នកទោសក្នុងពេលសួរចម្លើយ ដោយរួមមានទាំងការកោរសក់ ការធ្វើឲ្យរលាត់ស្បែកដោយការឆក់ខ្សែភ្លើង និងការវាយនឹងរំពាត់ ឬដំបង[៣៦៨]។

២០០. គ្មានការបញ្ជាក់ច្បាស់លាស់អំពីចំនួននៃអ្នកជាប់ឃុំនៅស២៤ទេ។ ភស្តុតាងបានបង្ហាញច្បាស់ថា មានបុគ្គលិក ព្រមទាំងអ្នកជាប់ឃុំជាច្រើននៅស២៤ ប៉ុន្តែមិនមានភស្តុតាងនៅសេសសល់ជាលាយលក្ខណ៍អក្សរណាមួយបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីបញ្ជាក់អំពីចំនួនអ្នកជាប់ឃុំសរុបដែលត្រូវបានជាប់ឃុំនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានបង្ហាញថាមានមនុស្សរាប់រយនាក់ធ្វើការនៅ

---

[៣៦៧] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១-១២, ១៣-១៤, ២២-២៥, ៣៧-៤២, ៤៨-៥០, ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៨, ១៥-១៧, ២៧។

[៣៦៨] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩, ២៩-៣០, ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧១។

ស២៤ នៅក្នុងពេលតែមួយ ដែលការប៉ាន់ស្មានបែបនេះជនជាប់ចោទក៏បានយល់ស្របផងដែរ[៣៦៩]។ ស្ថិតិសង្ខេបកម្លាំងកងទ័ពជាលាយលក្ខណ៍អក្សរ បានបង្ហាញថា នៅក្នុងខែមីនា ឆ្នាំ១៩៧៧ មានបុគ្គលិកមន្ទីរស២១ ចំនួន ២.៣២៧ នាក់ និង"ពួកសមាសភាព" មានចំនួន ១.៣០០ នាក់ នៅ ស២៤។ ជនជាប់ចោទក៏បានយល់ស្របចំពោះចំនួនទាំងនេះដែរ[៣៧០]។ ចំណែកអ្នកផ្សេងទៀត ដូចជា សាក្សី ផាច សៀក ដែលជាអ្នកបានជាប់ឃុំនៅ ស២៤ អស់រយៈពេលពីរឆ្នាំនោះ បាននិយាយថា "អ្នកទោសនៅព្រៃសមានប្រហែល៥០០ ទៅ ៦០០នាក់ ទាំងប្រុសទាំងស្រី"[៣៧១]។ សាក្សី តយ តេង ដែលបានជាប់ឃុំខ្លួននៅ ស២៤ អស់រយៈពេលពីរខែមុនពេលបែកទីក្រុងភ្នំពេញបាននិយាយថា "សរុបមនុស្សដែលរស់នៅទីនោះមានប្រហែល២០០នាក់ [...] បែងចែកជាក្រុមៗ ក្នុងមួយក្រុមមានគ្នាប្រហែល២០ ទៅ២៥នាក់"[៣៧២]។

២០១. ទោះបីជាអ្នកជាប់ឃុំ និងបុគ្គលិកស២៤ ដែលត្រូវបានចាប់ខ្លួនជាច្រើននាក់ ត្រូវបានបញ្ជូនទៅមន្ទីរស២១ (ទួលស្លែង) ដែលអ្នកទាំងនោះត្រូវបានសន្មតថាត្រូវបានសួរចម្លើយ បន្ទាប់មកសម្លាប់ចោលអស់នៅទីនោះក្តី ក៏ការពិនិត្យមើលបញ្ជីឈ្មោះអ្នកទោសដែលបានចងក្រងនៅមន្ទីរស២១បានបង្ហាញថា ចំនួនអ្នកទោសទាំងនេះមិនមានភាពច្បាស់លាស់ទេ។ ជនជាប់ចោទបានយល់ស្របផងដែរនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការចោទប្រកាន់ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែថា "យ៉ាងហោចណាស់" មានមនុស្សចំនួន ៥៧១ នាក់ ត្រូវបានបញ្ជូនទៅ

---

[៣៦៩] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៥០។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១១០។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៤-៥៥។

[៣៧០] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤២។ " ស្ថិតិកំលាំងរួមរបស់ កងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៧" ឯកសារ E3/146, ERN (English) 00183956។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥៥-៥៦។

[៣៧១] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ផាច សៀក) ទំព័រ៤៩-៥០។

[៣៧២] ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ តយ តេង) ទំព័រ៤១។

ទីនោះ[៣៧៣]។ នៅក្នុងបញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល ចំនួនអ្នកជាប់ឃុំសរុប ដែលត្រូវបានបញ្ជូនពី ស២៤ ទៅមន្ទីរស២១ (ទួលស្លែង) មានចំនួនមិនច្បាស់លាស់ទេ (ផ្នែក (២.៣.៣.៤.២) ។ អ្នកជាប់ឃុំដែលត្រូវបានគេបញ្ជូនផ្ទាល់ពីស២៤ ទៅសម្លាប់នៅជើងឯក រួមមានទាំងស្ត្រី និងកុមារផងដែរ[៣៧៤]។

២០២. អង្គជំនុំជម្រះយល់ឃើញថា ឯកសារផ្សេងៗពីគ្នា ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញនូវភាពមិនពេញលេញនៃចំនួនអ្នកជាប់ឃុំដែលត្រូវបានបញ្ជូនទៅសម្លាប់ ឬនៅរស់រានមាន ជីវិតបន្ទាប់ពីការឃុំខ្លួននៅ ស២៤។ ផ្អែកលើមូលហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា ចំនួនអ្នកជាប់ឃុំសរុបនៅ ស២៤ មានមិនតិចជាង១.៣០០ នាក់ឡើយ។

### ២.៣.៣.៨ ការបោះបង់ចោលមន្ទីរស២១

២០៣. បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានដួលរលំ (ផ្នែក ២.១) ជនជាប់ចោទ និងបុគ្គលិករបស់គាត់ ជាមួយនឹងអ្នកជាប់ឃុំប្រហែលជា១៥នាក់ផ្សេងទៀត ដែលកំពុងធ្វើការនៅក្នុងមន្ទីរស២១(ទួលស្លែង)

---

[៣៧៣] ប្រតិចារឹក ចុះថ្ងៃទី០១ ខែសីហា ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៤។ *សូមមើលផងដែរ* "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១៩០។

[៣៧៤] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៤-៦៥។ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះ-ស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១៨៩។ សូមមើលផងដែរ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨" ឯកសារ E3/380, ERN (ភាសាខ្មែរ) 00178024-00178025។

បានរត់គេចខ្លួនចេញពីទីនោះ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[៣៧៥]។បុគ្គលិកនៅស៤ ជាមួយនឹងអ្នក-ជាប់ឃុំដែលនៅរស់រានមានជីវិតនៅស២៤ក៏បានរត់គេចខ្លួននៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ដែរ[៣៧៦]។

## ២.៤ អង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅមន្ទីរស២១

២០៤. នៅក្នុងអំឡុងពេលសវនាការ មានភស្តុតាងជាច្រើនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅមន្ទីរស២១។ អង្គហេតុជាក់លាក់ផ្សេងៗទៀតដែលទាក់ទងនឹងឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកដែលមានស្វាមីភក្តិនឹងវៀតណាម ដែលបានឃុំខ្លួននៅមន្ទីរស២១ ក៏ត្រូវបានលើកយកមកបង្ហាញនៅចំពោះមុខអង្គជំនុំ-ជម្រះទាក់ទងនឹងបទល្មើសការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ផងដែរ (ផ្នែក ២.៦) ។

### ២.៤.១ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

២០៥. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៣៨. បុគ្គលិកនៅមន្ទីរស-២១ បានបង្កឲ្យមានការស្លាប់អ្នកទោសជាច្រើនដោយផ្ទាល់ ឬដោយប្រយោល។ ក្នុងករណីជាច្រើន អ្នកទោសត្រូវបានសម្លាប់ដោយចេតនាដោយវិធីខុសៗគ្នា។ ក្នុងករណីផ្សេងទៀត ទោះបីជាចារីអាចគ្មានចេតនាសម្លាប់ ក៏ពួកគេដឹងថា ទង្វើរបស់ពួកគេអាចបណ្តាលឲ្យអ្នកទោសស្លាប់ ឧទាហរណ៍នៅពេលពួកគេវាយដំ ឬធ្វើទារុណកម្មលើអ្នកទោស។

---

[៣៧៥] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៤២។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២៣។ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៣២-៣៣, ៦២-៦៣។ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៨២-៨៤។

[៣៧៦] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ១៣-១៥។

១៣៩. លក្ខខណ្ឌនៃការរស់នៅដែលត្រូវបានអនុវត្តចំពោះអ្នកទោសនៅស-២១ ត្រូវបានរៀបចំឡើងដើម្បីធ្វើយ៉ាងណាបង្កឱ្យមានការស្លាប់។ លក្ខខណ្ឌនៃការរស់នៅទាំងនេះរាប់បញ្ចូលផងដែរជាអាទិ៍ ការបង្អត់អាហារ និងកង្វះខាតថ្នាំសង្កូវសមស្រប។

១៤០. ការសម្លាប់ដោយខុសច្បាប់នៃអ្នកទោសចំនួនលើសពី១២៣៨០នាក់ ដែលបណ្តាលមកពីការសម្លាប់ ឬលក្ខខណ្ឌនៃការរស់នៅ បង្កើតបានជាការសម្លាប់រង្គាលនៃជនស៊ីវិល។ ការសម្លាប់រង្គាលនេះត្រូវបានបង្ហាញតាមរយៈឯកសារ ឬសក្ខីកម្មជាច្រើន ព្រមទាំងសាកសពជាច្រើន ដែលត្រូវបានរកឃើញនៅក្នុងរណ្តៅរួម[៣៧៧]។

២០៦. ផ្អែកតាមគោលនយោបាយក្នុងការ "កម្ទេច" ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា អ្នកជាប់ឃុំទាំងឡាយដែលបានជាប់ឃុំនៅមន្ទីរស២១ (ទួលស្លែង) ត្រូវតែសម្លាប់ទាំងអស់ គ្មានអ្នកជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ[៣៧៨]។ ដូចជនជាប់ចោទបានលើកឡើងថា “ការងាររបស់វាសំខាន់របស់គណៈ-កម្មាធិការមន្ទីរស២១ គឺឃុំឃាំងមនុស្សដែលអចិន្ត្រៃយ៍គេបញ្ជូនមកមួយរយៈដើម្បីធ្វើទារុណកម្ម ហើយយកចម្លើយ រួចហើយយកទៅកម្ទេច”[៣៧៩]។

---

[៣៧៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៣៨-១៤០ (ជើងទំព័រខាងក្នុងត្រូវបានលុប)។

[៣៧៨] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៥។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៩។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៣៥-៣៧។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៧-៣៩។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៧-២៨។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៦៣-៦៤។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៣៩-៤០។ សូមមើលផងដែរ ផ្នែក (២.២.៥.២)។

[៣៧៩] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥-១៦។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦-២៨។

២០៧. ក្រៅពីអ្នកជាប់ឃុំដែលយកទៅសម្លាប់ មានអ្នកជាប់ឃុំជាច្រើននៅមន្ទីរស២១ (ទួលស្លែង) និងស២៤ បានស្លាប់ដោយសារតែស្ថានភាពនៃការឃុំខ្លួន[៣៨០]។ ជនជាប់ចោទបានគូសបញ្ជាក់ថា អ្នកជាប់ឃុំបានទទួលរបបអាហារមិនគ្រប់គ្រាន់ទាល់តែសោះ ដែលជាហេតុធ្វើឱ្យពួកគេរស់នៅក្នុងភាពស្រេកឃ្លានជាប់ជានិច្ច ចំណែកឯថ្នាំសម្រាប់ព្យាបាលវិញក៏មានតែបន្តិចបន្តួចប៉ុណ្ណោះ[៣៨១]។ មានអ្នកជាប់ឃុំខ្លះបានស្លាប់ដោយការធ្វើទារុណកម្មក្នុងពេលសួរចម្លើយ[៣៨២]។

២០៨. ជនជាប់ចោទបានយល់ស្របទៅលើភាពត្រឹមត្រូវជាទូទៅនៃព័ត៌មានដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល ប៉ុន្តែគាត់បានទទួលស្គាល់ថា ចំនួនអ្នកជាប់ឃុំដែលបានស្លាប់ ឬត្រូវបានសម្លាប់គឺមានចំនួនច្រើនជាងចំនួននៅក្នុងបញ្ជី (កែសម្រួល) ដែលមានត្រឹមតែចំនួន ១២.២៧៣ នាក់ទៅទៀត[៣៨៣]។

[៣៨០] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៧-៣៨។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ឌន) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ ១១, ១៨-១៩។

[៣៨១] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៣-៦៥, ៦៩។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ៥៧-៥៩។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ក់ ស៊ីធីម) ទំព័រ៣០-៣៣។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ឌន) ទំព័រ៨-៩។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១១, ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១១-១២។

[៣៨២] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ហាន អៀម) ទំព័រ៨០។ សូមមើលផងដែរ ផ្នែក (២.៤.៤)។

[៣៨៣] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤-៥។ "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០០៨" ឯកសារ E3/378, ERN (ភាសាខ្មែរ) 00185495។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ១-៣។ សូមមើលផងដែរ ផ្នែក (២.៣.៣.៤.២)។

00573457



### ២.៤.១.១ ការសម្លាប់ជនបរទេស

២០៩. ជនជាប់ចោទបានបញ្ជាក់ថា មានជនបរទេសដែលមកពីប្រទេសផ្សេងៗជាច្រើនត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស២១ (ទួលស្លែង) ដែលក្នុងនោះរួមមាន៖ប្រទេសវៀតណាម ថៃ ប៉ាគីស្ថាន ឡាវ ឥណ្ឌា ចិន បារាំង អង់គ្លេស អាមេរិក នូវែលហ្សេឡង់ និងអូស្ត្រាលី[៣៨៤]។ ទោះបីជាមានការចោទប្រកាន់ថា មានអ្នកជាប់ឃុំជនបរទេសខ្លះត្រូវបានគេសម្លាប់ដោយដុតទាំងរស់ក្តី[៣៨៥] ក៏អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមិនមានភស្តុតាងបង្ហាញទៅតាមបទដ្ឋានតម្រូវនោះទេ។

២១០. ជនជាតិវៀតណាមជាច្រើននាក់ និងបុគ្គលមួយចំនួនដែលត្រូវបានគេចាត់ទុកថាជា "គិញ" វៀតណាមត្រូវបានសម្លាប់នៅមន្ទីរស២១ ជាពិសេសចាប់ពីឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ អង្គជំនុំជម្រះយល់ឃើញថា ការសម្លាប់បុគ្គលទាំងនោះ ដែលភាគច្រើនត្រូវបានចាប់ខ្លួននៅក្នុងអំឡុងពេលមានជម្លោះជាមួយវៀតណាម គឺជាផ្នែកមួយនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការបោសសម្អាតខ្មាំងរបស់ខ្លួនទាំងអស់។

### ២.៤.១.២ ការសម្លាប់អ្នកជាប់ឃុំដែលជាកម្មាភិបាលជាន់ខ្ពស់

២១១. តួនាទីមួយក្នុងចំណោមតួនាទីផ្សេងៗទៀតរបស់មន្ទីរស២១ ដែលបានកំណត់ឲ្យអនុវត្តនៅក្នុងការគ្រប់គ្រងសន្តិបាល គឺការសួរចម្លើយ និងការសម្លាប់កម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា

---

[៣៨៤] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៩-៤២។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨។ *សូមមើលផងដែរ* "ឯកសារមួយចំនួនទាក់ទងនឹងជនបរទេស ដែលត្រូវខ្មែរក្រហមឃុំខ្លួន ឬសម្លាប់ចោលនៅមន្ទីរស២១", E52/4.62។ ប្រតិចារឹក ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ (គក ស្រស់) ទំព័រ៦៨-៦៩។

[៣៨៥] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១២២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥, ២០-២២, ២៨-២៩។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤២-៤៣។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៦២-៦៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៦-៤៨, ៧២-៧៣។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ចៀម សឿ) ទំព័រ១២-១៧, ៣១-៣៤, ៤០-៤២។

ដែលជាទូទៅត្រូវបានឃុំខ្លួននៅក្នុងគុកពិសេស[៣៨៦]។ ក្នុងចំណោមកម្មាភិបាលជាន់ខ្ពស់ទាំងនោះមាន កុយ ធួន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាសមាជិកគណៈកម្មាធិការមជ្ឈិម និងជាសមាជិកគណៈ-កម្មាធិការអចិន្ត្រៃយ៍ ចាន់ ចក្រី លេខាតំបន់២៤នៃភូមិភាគបូព៌ា ម៉ែន សាន ហៅ យ៉ា លេខាភូមិ-ភាគព្រៃសាន សួស នៅ ហៅ ឈូក អនុប្រធានសេនាធិការ វន វ៉េត ហៅ ពេញ ធួក សមាជិកគណៈ-កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ឆាយ គឹមហ៊័រ ហៅ ហុក ប្រធានគណៈកម្មាធិការ ថាមពល គង់ សុផល លេខាភូមិភាគពាយព្យ ស៊ួ សុផាន ហៅ ប៉ង់ សមាជិកគណៈកម្មាធិការ មជ្ឈិម និង អ៊ុន លន ហៅ ណាត អតីតប្រធានមន្ទីរស២១[៣៨៧]។

### ២.៤.១.៣ ការសម្លាប់បុគ្គលិកមន្ទីរស២១

២១២. បុគ្គលិកមន្ទីរ ស២១ មួយចំនួនបានស្លាប់ ឬត្រូវបានសម្លាប់ បន្ទាប់ពីត្រូវបានឃុំខ្លួន ដោយសារ តែមិនបានបំពេញភារកិច្ចរបស់ខ្លួន ឬមានជាប់ពាក់ព័ន្ធនៅក្នុងចម្លើយសារភាពរបស់អ្នកជាប់ឃុំ[៣៨៨]។ បុគ្គលិកមន្ទីរស២១ ត្រូវបានដាក់ឲ្យឋិតនៅក្នុងស្ថានភាពរស់នៅមួយប្រកបដោយការភ័យខ្លាចជាប់ជា

[៣៨៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ ៤១-៤១ ។ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ ៥៤ ។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៣៤-៣៥ ។

[៣៨៧] *សូមមើលឧទាហរណ៍* ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១-១២, ១៣-១៤, ១៨-១៩, ២០-២២, ៣៤-៣៥។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៥៧-៥៨, ៥៩-៦២, ៦៨-៧០។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ២២-២៤, ៣៩-៤០។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៥-៧០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-៣២។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៨៣-៨៤ ។ "កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧" ឯកសារ E3/17, ERN (ភាសាខ្មែរ) 00154224។

[៣៨៨] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ ៥៥-៥៧, ៧៤-៧៩។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣៧-៣៩។ "បុគ្គលិក ស-២១ ដែលជាប់គុកនៅ ស-២១" ឯកសារ E68.40។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ១៣-១៤។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយ របស់ ខៀវ ចេស) ទំព័រ៥៤-៥៥។

ប្រចាំ ដែលគ្រាន់តែជាការឃុំខ្លួនដើម្បីសម្លាប់តែប៉ុណ្ណោះ។ អតីតបុគ្គលិកមន្ទីរស២១មួយចំនួនបានផ្តល់សក្ខីកម្មអំពីការបាត់ខ្លួនដោយគ្មានមូលហេតុទាល់តែសោះចំពោះសមាជិកក្នុងក្រុមរបស់ពួកគេ[៣៨៩]។

២១៣. នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ក៏ដូចជាសមាជិកអង្គភាពពេទ្យចំនួន២១នាក់ សមាជិកអង្គភាពកងការពារចំនួន៤៨នាក់ សមាជិកអង្គភាពសួរចម្លើយចំនួន៣៤នាក់ រួមទាំងអ្នកសួរចម្លើយជាស្ត្រីផងដែរ ត្រូវស្ថិតនៅក្នុងក្រុមអតីតបុគ្គលិកមន្ទីរស២១ ដែលត្រូវបានឃុំខ្លួន និងសម្លាប់[៣៩០]។ នៅក្នុងករណីខ្លះទៀត សមាជិកក្រុមគ្រួសាររបស់ពួកគេក៏ត្រូវបានឃុំខ្លួន និងសម្លាប់ជាមួយពួកអ្នកជាប់ឃុំទាំងនោះផងដែរ។ កត់សម្គាល់ថា បុគ្គលិកមន្ទីរស២១ ជាច្រើននាក់ដែលត្រូវបានសម្លាប់ រួមទាំង អ៊ិន លន ហៅ ណាត ផងនោះ សុទ្ធតែធ្លាប់បានបម្រើការងារនៅកងពល ៧០៣ នៃកងទ័ពបដិវត្តកម្ពុជា ដែលកងពលនេះត្រូវបានគេបោសសម្អាតជាបណ្តើរៗនៅក្នុងអំឡុងពេលប្រតិបត្តិការមន្ទីរស២១[៣៩១]។

---

[៣៨៩] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៧៩-៨៣។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ១៣-១៥។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៧៧-៧៩។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៥៦-៥៧។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៤២។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម អេន) ទំព័រ៨១-៨២។

[៣៩០] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២២។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (កាំង ប៉ាន់) ទំព័រ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម អេន) ទំព័រ៨១-៨២, ៩០-៩១។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ១៦-១៨។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤២-៤៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ ៥៦-៥៧ ។ ដើម្បីដឹងព័ត៌មានលម្អិតអំពីចំនួនបុគ្គលិកមន្ទីរស២១ នៅតាមអង្គភាពនីមួយៗ ដែលត្រូវបានគេចាប់ខ្លួន *សូមមើល* "បុគ្គលិកស២១ ដែលជាប់គុកនៅ ស-២១" ឯកសារ E68.40។

[៣៩១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣១-៣៥, ៥៧-៥៨, ៧៧-៧៩។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ១៣-១៥។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៧-២៩។

00573460



### ២.៤.១.៤ ការសម្លាប់កុមារ

២១៤. កុមារដែលបានបញ្ជូនទៅមន្ទីរស២១ត្រូវបានសម្លាប់នៅមន្ទីរស២១ (ទួលស្លែង) និងនៅជើងឯក។ ជាធម្មតា កុមារតូចៗដែលមានអាយុតិចត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ ប៉ុន្តែ កុមារខ្លះត្រូវបានគេឃុំខ្លួនមួយរយៈខ្លីមុនពេលយកទៅសម្លាប់។ ជនជាប់ចោទបានបញ្ជាក់ថា បុគ្គលិកមន្ទីរស២១ ឈ្មោះ ប៉េង ជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់កុមារទាំងនោះ[៣៥២]។

២១៥. កុមារធំៗដែលអាចថែទាំខ្លួនឯងបាន ត្រូវបានបញ្ជូនទៅ ស២៤។ កុមារទាំងនោះមួយចំនួនត្រូវបានបញ្ជូនទៅសម្លាប់នៅជើងឯកនៅពេលក្រោយមក។ នៅក្នុងកំណត់ត្រាមួយដែលបានបញ្ជាក់ដោយជនជាប់ចោទថាមានកុមារប្រហែល១៦០ នាក់ ដែលបានឃុំគ្រងនៅស២៤ ត្រូវបានគេបញ្ជូនទៅសម្លាប់នៅជើងឯក ជាមួយនឹងក្មេងជំទង់ៗចំនួន១៨នាក់ផ្សេងទៀតនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧[៣៥៣]។ សាក្សី កាំង ប៉ាន់ គឺជាប្រធានកងនារីមួយក្រុម ដែលគ្រប់គ្រងអ្នកជាប់ឃុំចំនួន១២នាក់នៅស២៤ ព្រមទាំងមើលថែទាំក្មេងៗដែលមានអាយុពី៨ឆ្នាំទៅ១០ឆ្នាំ ចំនួនប្រហែលពី៧០ ទៅ៨០នាក់ ដែលសុទ្ធតែជាក្មេងដែលត្រូវបានគេបំបែកចេញពីឪពុកម្តាយរបស់ពួកគេ។ គាត់បានលើកឡើងថា "កុមារត្រូវបានគេយកទៅចាក់ចោល" ហើយក្មេងៗជាង៣០នាក់ បានបាត់ខ្លួននៅក្នុងអំឡុងពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[៣៥៤]។ សាក្សី ប៊ូ ធុន បានកត់សម្គាល់ថា មានទារក១០នាក់ ដែលគេយកទៅទុក

---

[៣៥២] ប្រតិចារឹក ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩, ២០។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១៣, ១៨-២០។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥១, ៥០-៥២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៣-៤៤។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១៤-១៦, ៣៤-៣៥។

[៣៥៣] "ឈ្មោះអ្នកទោសកម្ទេចផ្នែក បង ហ៊ុយ ស្រែ" ឯកសារ E3/405។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៧-៥១។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៣-៧៤។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៧០-៧២។

[៣៥៤] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ប៉ាន់) ទំព័រ៥៥-៥៩។

នៅឯមណ្ឌលថែទាំកុមារនៅស២៤នោះ គឺដោយសារតែម្ដាយរបស់ទារកទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យមើលថែទាំកូនរបស់ខ្លួន ទារកខ្លះបានឈឺ និងខ្លះទៀតបានស្លាប់[៣៥៥]។

២១៦. ទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ថា មានហេតុ-ការណ៍មួយនៃការទម្លាក់កូនប្រុសរបស់អ្នកទោសស្ត្រីជនជាតិវៀតណាមម្នាក់ ពីលើអគារកម្ពស់បីជាន់នៅក្នុងបរិវេណមន្ទីរស២១ (ទួលស្លែង)[៣៥៦] ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមិនមានភស្តុតាងបង្ហាញទៅតាមបទដ្ឋានតម្រូវនោះទេ។

### ២.៤.១.៥ ការសម្លាប់ទ្រង់ទ្រាយធំ

២១៧. ការសម្លាប់អ្នកជាប់ឃុំជាទ្រង់ទ្រាយធំ ត្រូវបានបញ្ជាដោយគណៈកម្មាធិការមជ្ឈិម និងបានធ្វើឡើងជាច្រើនដង។ ការសម្លាប់ទ្រង់ទ្រាយធំទាំងនេះត្រូវបានធ្វើឡើងនៅជើងឯក ហើយចំណាយពេលជាច្រើនថ្ងៃ។ ដោយសារតែជនរងគ្រោះមានចំនួនច្រើន ជាទូទៅ ការសម្លាប់គឺធ្វើឡើងភ្លាមៗក្រោយពេលអ្នកត្រូវជាប់ឃុំមកដល់មន្ទីរស២១ (ទួលស្លែង) ដោយមិនមានការសួរចម្លើយអ្វីនោះទេ[៣៥៧]។

---

[៣៥៥] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ធុន) ទំព័រ២៨-២៩។

[៣៥៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១២៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១០-១១, ៤០, ៦៣-៦៤។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤-៦។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-២០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦។

[៣៥៧] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤-២៥។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៨-៥០។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១២-១៤, ៣៥-៣៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤៨-៥៤, ៨០-៨៣។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ២៤-២៥, ៤៣-៤៥, ៥១-៥៣។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ គង់ ផៃ) ទំព័រ៧១-៧២។ *សូមមើលផងដែរ* "បញ្ជីឈ្មោះអ្នកទោសដែលបានផ្ដាកក្នុងខែមករា ឆ្នាំ១៩៧៧" ឯកសារ E3/370។ "បញ្ជីឈ្មោះអ្នកទោសផ្នែកនារី មកពីរោងចក្រស៊ីម៉ង់ត៍ និង ក-១៥" ឯកសារ E3/371។

២១៨. ការសម្លាប់ទ្រង់ទ្រាយធំខ្លះត្រូវបានធ្វើឡើងដោយសារតែការបោសសម្អាតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា។ តាមសម្តីរបស់ជនជាប់ចោទ កម្មាភិបាលជាច្រើនដែលមកពីភូមិភាគឧត្តរ ភ្នំពេញ និងភូមិភាគបូព៌ា ត្រូវបានគេសម្លាប់នៅដើមឆ្នាំ១៩៧៧ ។ បន្ទាប់ពីរយៈពេលនោះបន្តិច កម្មាភិបាលយុទ្ធជននៃកងពលលេខ ៩២០ នៃកងទ័ពបដិវត្តកម្ពុជា ក៏ត្រូវបានគេសម្លាប់ផងដែរ។ នៅដើមឆ្នាំ១៩៧៨ កម្មាភិបាលដែលមកពីភូមិភាគបស្ចិម ត្រូវបានគេសម្លាប់ ហើយក្រោយមកកម្មាភិបាលដែលមកពីភូមិភាគពាយព្យ ក៏ត្រូវបានគេសម្លាប់ដែរ។ ការបោសសម្អាតទ្រង់ទ្រាយធំបំផុតមួយក្នុងចំណោមការបោសសម្អាតទ្រង់ទ្រាយធំនានា ដែលពាក់ព័ន្ធនឹងកម្មាភិបាលមកពីភូមិភាគបូព៌ាត្រូវបានធ្វើឡើង[៣៥៨] នៅចុងឆ្នាំ១៩៧៨ ។

២១៩. នៅខែមករា ឆ្នាំ១៩៧៩ អ្នកជាប់ឃុំស្ទើរតែទាំងអស់នៅមន្ទីរស២១ (ទួលស្លែង) ត្រូវបានសម្លាប់តាមបញ្ជាថ្នាក់លើរបស់ជនជាប់ចោទ។ នៅពេលដែលទីក្រុងភ្នំពេញបានដួលរលំនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ អ្នកជាប់ឃុំដែលនៅរស់រានមានជីវិតមានចំនួនតិចតួចប៉ុណ្ណោះ[៣៥៩] នៅមន្ទីរស២១ (ទួលស្លែង)។

---

[៣៥៨] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១២-១៣, ៣៥-៤០, ៦១-៦៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៤-១៦។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ២៤-២៥។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១៨-១៩។ បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល បង្ហាញថាឈ្មោះចំនួន១.១៦៥ ត្រូវបានចាប់ខ្លួនមកពីភូមិភាគបូព៌ា ឈ្មោះចំនួន៣៦០ ត្រូវបានចាប់ខ្លួនមកពីភូមិភាគកណ្តាល និងភូមិភាគឧត្តរ និងឈ្មោះចំនួន១.២១១ ត្រូវបានចាប់ខ្លួនពីភូមិភាគពាយ័ព្យ។ *សូមមើល* "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ចាប់មកពីភូមិភាគបូព៌ា" ឯកសារ E68.45។ បញ្ជីឈ្មោះអ្នកទោសមកពីភូមិភាគឧត្តរចាស់ និងបញ្ជីឈ្មោះអ្នកទោសដែលមកពីភូមិភាគឦសាន ឯកសារ E68.47 ។ បញ្ជីឈ្មោះអ្នកទោសមកពីភូមិភាគឧត្តរ ឯកសារ E68.49 ។

[៣៥៩] ប្រតិចារឹក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦-៦៨។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤៦-៤៧។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៩-១១។ ប្រតិចារឹក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ (នង ចាន់ផល) ទំព័រ២៧-៣១។ ពួកអ្នកជាប់ឃុំដែលត្រូវបានគេសម្លាប់ចុងក្រោយ ត្រូវបានសន្មតថាជាសមាជិករបស់អង្គភាព យ៨ ដែលត្រូវបានឃុំខ្លួនពីមុនដោយសារជាប់ទាក់ទងនឹងមរណភាពរបស់ Malcom CALDWELL។ យោងតាមជនជាប់ចោទ

## ២.៤.១.៦ វិធីសាស្ត្រក្នុងការសម្លាប់

២២០. ជាធម្មតាអ្នកជាប់ឃុំត្រូវបានគេសម្លាប់ដោយវាយត្រង់កញ្ចឹងក ដោយដែកគោល់រទេះ ឬវត្ថុផ្សេងទៀតដែលមាននៅទីនោះ ។ បន្ទាប់មកសាកសពត្រូវបានគេធាក់ទម្លាក់ទៅក្នុងរណ្ដៅ បន្ទាប់ពីអាករ ឬវះពោះ និងដោះខ្នោះដៃ ហើយបន្ទាប់មកលប់រណ្ដៅនោះទៅ[៤០០]។

២២១. នៅក្នុងករណីដែលពាក់ព័ន្ធនឹងការសម្លាប់អ្នកជាប់ឃុំសំខាន់ៗ បុគ្គលទាំងនោះត្រូវបានគេវះពោះ និងថតរូបធ្វើជាភស្តុតាងដើម្បីបង្ហាញពីការស្លាប់របស់ពួកគេដល់ថ្នាក់លើរបស់ជនជាប់-ចោទ[៤០១]។

២២២. នៅក្នុងអំឡុងពេលដែល អ៊ិន លន ហៅ ណាត ធ្វើជាប្រធានមន្ទីរស២១ អ្នកជាប់ឃុំត្រូវបានគេសម្លាប់ដោយការចាក់ត្រង់បំពង់ក។ ជនជាប់ចោទបានគូសបញ្ជាក់ថា អ្វីដែលសំខាន់បំផុតគឺត្រូវ "ធ្វើម៉េចឲ្យតែច្បាស់លាស់ថាបានកម្ទេចហើយ"[៤០២] ចំពោះវិធីសាស្ត្រនៃការសម្លាប់យ៉ាងណានោះមិនមែនជាបញ្ហានោះទេ។ អង្គជំនុំជម្រះបានសួរទៅជនជាប់ចោទថា តើគាត់មានបានបង្ហាត់បង្រៀនបុគ្គលិកមន្ទីរស២១ អំពីវិធីសាស្ត្រក្នុងការសម្លាប់អ្នកជាប់ឃុំដែរ ឬទេ ជនជាប់ចោទបានឆ្លើយតប

---

ពួកអ្នកជាប់ឃុំទាំងនោះត្រូវបានសម្លាប់ដោយចំពុះទុង នៅពេលដែលអ្នកទាំងនោះជាប់ខ្នោះជើងនៅនឹងគ្រែ។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៦។

[៤០០] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៤២-៤៤។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ តយ តេង) ទំព័រ៤២-៤៥។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥២-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៥-៣៦។

[៤០១] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៥៧-៦២។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨៤-៨៥។ គេបានថតរូបភាពអ្នកជាប់ឃុំទាំងឡាយ ដែលបានស្លាប់នៅពេលជាប់ឃុំនៅមន្ទីរស២១ ដើម្បីជាភស្តុតាងបង្ហាញថា អ្នកជាប់ឃុំទាំងនោះមិនត្រូវបានដោះលែងទេ។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ញ៉ែម អេន) ទំព័រ៨៤-៨៥។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ញ៉េប ហ្វ) ទំព័រ៥៨-៦០។

[៤០២] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩, ៥៧។

ដោយលើកសុភាសិតខ្មែរថា "ខ្ញុំអត់ទៅបង្រៀនក្រពើឲ្យចេះហែលទឹកទេ ឲ្យហែលទេ។ នេះគេចេះហែលហើយ"[៤០៣]។

២២៣. ជនជាប់ចោទបានបញ្ជាក់ថា យ៉ាងហោចណាស់ក៏មានអ្នកជាប់ឃុំ១០០នាក់ បានស្លាប់បន្ទាប់ពីការបូមឈាមដោយអង្គភាពពេទ្យរបស់មន្ទីរស២១ដែរ[៤០៤]។ សាក្សី ប្រាក់ ខន បានផ្តល់សក្ខីកម្មថា អ្នកជាប់ឃុំត្រូវបានគេ "ដាក់ឲ្យដេកលើគ្រែ ដោះខ្នោះដៃ ចងជាប់នឹងមេគ្រែសងខាង ហើយដាក់ខ្នោះជើង"។ អ្នកជាប់ឃុំទាំងនោះត្រូវបានចងមុខ ហើយត្រូវបានគេចាក់ម្ជុលចូលទៅក្នុងសរសៃឈាម ហើយបូមយកឈាមរហូតទាល់តែស្លាប់[៤០៥]។ ឈាមទាំងនោះត្រូវបានផ្តល់ទៅឲ្យមន្ទីរពេទ្យសេនាធិការ ដើម្បីបញ្ចូលឲ្យកងទ័ពបដិវត្តកម្ពុជាដែលបានរងរបួសនៅក្នុងអំឡុងពេលដែលមានជម្លោះជាមួយវៀតណាម[៤០៦]។ ដំបូង ជនជាប់ចោទបានលើកឡើងថា ការអនុវត្តបែបនេះត្រូវបានផ្តួចផ្តើមឡើងដោយ អ៊ិន លន ហៅ ណាត ហើយគាត់មិនបានដឹងអំពីរឿងនេះទេ។ ប៉ុន្តែក្រោយមក គាត់បានប្តូរមកនិយាយថា ការអនុវត្តបែបនេះត្រូវបានផ្តួចផ្តើមឡើងក្រោមបញ្ជារបស់ សុន សេន ហើយ វាបានបញ្ចប់នៅពេលដែលបុគ្គលិកនៅអង្គភាពពេទ្យទាំងអស់របស់មន្ទីរស២១ត្រូវបានសម្លាប់[៤០៧]។

២២៤. ជនជាប់ចោទក៏បានគូសបញ្ជាក់ផងដែរថា ការវះកាត់ទៅលើអ្នកជាប់ឃុំត្រូវបានធ្វើឡើងទៅតាមបញ្ជារបស់ សុន សេន។ គោលបំណងនៃការវះកាត់នេះគឺដើម្បីបណ្តុះបណ្តាលបុគ្គលិកពេទ្យ។ វាមានលក្ខណៈមិនច្បាស់លាស់នោះទេ ថាតើអ្នកជាប់ឃុំនៅរស់រានមានជីវិតដែរ ឬទេ មុនពេលដែល

---

[៤០៣] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩។

[៤០៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៤, ៧២។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៦៩-៧៣។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ២៩-៣១។

[៤០៥] ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៨-៣០។

[៤០៦] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៤។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨៦-៨៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៩-៣១។

[៤០៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៣, ៦៩-៧១។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២១។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា (ជនជាប់ចោទ) ទំព័រ៨៦-៨៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ៦៩-៧៣, ២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ ២៩-៣១។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-២៩។

មានការវះកាត់នោះ[៤០៨]។ ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមិនមានភស្តុតាងបង្ហាញទៅតាមបទដ្ឋានតម្រូវ ដែលថាការស្លាប់របស់អ្នកជាប់ឃុំបានកើតមានឡើងបណ្តាលមកពីការវះកាត់នោះទេ។

២.៤.២ ការធ្វើឲ្យទៅជាទាសករ

២២៥. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៣៥. អ្នកទោសមួយចំនួននៅមន្ទីរស២១ និងព្រៃស ត្រូវគេបង្ខំឲ្យធ្វើការ។ គ្រប់ទិដ្ឋភាពនៃការរស់នៅរបស់ពួកគេត្រូវបានឃ្លាំមើលយ៉ាងតឹងរ៉ឹង និងត្រូវបានចាត់ទុកជាវត្ថុផ្តាច់មុខ ដែលត្រូវបានបង្ហាញតាមរយៈការកម្រិតការដើរហើរ និងកន្លែងរស់នៅ ការចាត់វិធានការ ទប់ស្កាត់ ឬធ្វើឲ្យពួកគេញញើតនឹងការរត់គេច និងតាមរយៈការអនុវត្តដែលនាំឲ្យពួកគេប្រឈមនឹងអំពើឃោរឃៅ។ ជាលទ្ធផលនៃអំពើទាំងនេះ អ្នកទោសត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេ[៤០៩]។

២២៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានកំណត់ចរិតលក្ខណៈនៃគោលបំណងចម្បងរបស់ ស២៤ ថាមានភារៈកិច្ច "កែប្រែ និងកសាងយុទ្ធជន ព្រមទាំងធ្វើស្រែដើម្បីផ្គត់ផ្គង់មន្ទីរស២១ និងសាខានានា"[៤១០]។ ការងារនៅទីនោះត្រូវបានរៀបរាប់ថាជា "ការងារដោយបង្ខំ" ឬក៏ "លត់ដំខ្លួន"[៤១១]។ ជនជាប់ចោទបានយល់ស្របចំពោះការលើកឡើងនេះ ហើយក៏មិនបានតវ៉ានឹងការរៀបរាប់ទាំងនេះដែរ។ ជនជាប់ចោទបានរៀបរាប់អំពីគោលបំណងចម្បងនៃការធ្វើការងាររបស់អ្នកជាប់ឃុំនៅ ស២៤ ថា "ឲ្យគេខំធ្វើការងារពលកម្មឲ្យបានចម្រើនមកខាងបក្សក្នុងការបង្កបង្កើន

---

[៤០៨] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៣, ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨៦-៨៩។

[៤០៩] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៣៥ (លេខយោងខាងក្នុងត្រូវបានលុប)។

[៤១០] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ៣០ (លេខយោងខាងក្នុងត្រូវបានលុប)។

[៤១១] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ ៥៥-៥៧, ១៧២-១៧៣។

ផលផង ... ហើយក៏ឲ្យគេរៀនចេះស្ដាប់មេរបស់គេ -- កុំឲ្យគេច្រឡើសបើសប្រឆាំងនឹងបក្ស"[៦១២]។ ជនជាប់ចោទក៏បានយល់ស្របថាស២៤ គឺជាកន្លែងដែលធ្វើឲ្យទៅជាទាសករនៅពេលដែល "ពួកសមាសភាព" ត្រូវបានលត់ដំខាងការងារ "ពលកម្ម"[៦១៣]។

### ២.៤.២.១ លក្ខខណ្ឌនៃការរស់នៅ និងការងារនៅស២៤

២២៧. ជនជាប់ចោទក៏បានយល់ស្របផងដែរថា ពាក្យ "សមាសភាព" សម្រាប់បក្សកុម្មុយនីស្តកម្ពុជាមានន័យថា អ្នកដែលត្រូវគេឃុំគ្រង ហើយប្រើចំពោះជនទាំងឡាយណាដែលបក្សសង្ស័យថាជាខ្មាំង។ អ្នកទាំងនោះត្រូវបានឃុំខ្លួននិងតម្រូវឲ្យលត់ដំការងារពលកម្ម ដើម្បី "ធ្វើម៉េចកុំឲ្យពួកនេះមានលទ្ធភាពបំផ្លាញគេបាន ហើយគេប្រើដូចគោ ដូចក្របីទៅ"[៦១៤]។ ពួកគេក៏ត្រូវបានតម្រូវឲ្យចូលរួមនៅក្នុងការប្រជុំស្វ័យទិតៀន ដែលហៅថាជា "ការលត់ដំខ្លួន"[៦១៥]។

២២៨. សាក្សី ប៊ូ ថុន ត្រូវបានជាប់ឃុំនៅ ស២៤ ក្រោយពីការបាត់ខ្លួនប្ដីរបស់គាត់។ គាត់មិនមានសេរីភាពក្នុងការនិយាយជាមួយអ្នកផ្សេង ដែលធ្វើការនៅទីនោះ (រួមទាំងកុមារ) និងមានភាពភ័យខ្លាចមិនហ៊ានរិះគន់ ឬត្អូញត្អែរអំពីបញ្ហានានា ដូចជា របបអាហារ ឬការថែទាំសុខភាពមិនគ្រប់គ្រាន់ឡើយ។ គាត់ត្រូវបានគេតម្រូវឲ្យធ្វើការច្រើនម៉ោង និងត្រូវនៅតែក្នុងផ្ទះនៅពេលយប់។ គាត់បានរៀបរាប់អំពីស្ថានភាពនៃការរស់នៅរបស់គាត់ថាជា "គុកឥតជញ្ជាំង" ។ គាត់មិនមានសិទ្ធិ ឬសេរីភាព

---

[៦១២] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣។

[៦១៣] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៥។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦-២៨, ៤៤-៤៥, ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៣-២៥។

[៦១៤] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤២-៤៤។

[៦១៥] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦-២៨ និង៥៦-៥៧ ។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៧០-៧១។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ចៀម សឿ) ទំព័រ៣៥-៣៦។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ តយ តេង) ទំព័រ៣៧-៣៨, ៤១។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ប៉ាន់) ទំព័រ៥៧-៥៨។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ ៤៤-៤៥ ។

ហើយមិនត្រូវបានអនុញ្ញាតឲ្យធ្វើការសម្រេចណាមួយដោយខ្លួនឯងឡើយ។ គាត់ត្រូវបានគេប្រាប់ឲ្យទៅធ្វើការនៅកន្លែងណាមួយ និងត្រូវបានគេតម្រូវឲ្យ “មិត្តឯងទៅធ្វើនោះទៅ យើងទៅតាមគេទៅ” ដោយ “មិនដែលហ៊ានតវ៉ាជជែកវែកញែកជើងនោះទេ”[៤១៦]។

២២៩. សាក្សី មាស ប៉េងគ្រី ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស២៤ នៅឆ្នាំ១៩៧៧ បាននិយាយអំពីការធ្វើការងារច្រើនម៉ោង និងការធ្វើការងារដោយប្រើកម្លាំងយ៉ាងលំបាកដែលរួមមានការលើកទំនប់ និងជីកប្រឡាយ និងស្ទូងស្រូវ ហើយកត់សម្គាល់ថា បរិមាណអាហារសម្រាប់ប្រជាជនដែលធ្វើការក្រោមស្ថានភាពទាំងនេះ មិនគ្រប់គ្រាន់ទេ[៤១៧]។

២៣០. ដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត ត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៧ នៅពេលដែលគាត់មានអាយុ១៩ឆ្នាំ[៤១៨]។ ក្រោយពីការឃុំខ្លួនអស់មួយរយៈមក គេបានបញ្ជូនគាត់ទៅស២៤ ដើម្បី“កសាងខ្លួន”។ គាត់បានរៀបរាប់អំពីការធ្វើការងារជាច្រើនម៉ោង ដោយមានគេត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ដើម្បីធានាថា ទិសដៅការងារត្រូវបានបំពេញ។ គាត់បានធ្វើស្រែ លើកទំនប់ និងជីកប្រឡាយដោយប្រើចប និងបង្គី។ នៅពេលផ្តល់សក្ខីកម្មដោយផ្ទាល់ក្នុងអំឡុងពេលសវនាការ គាត់បានរៀបរាប់ថា គេបានបង្ខំឲ្យគាត់អូសនង្គ័លជាមួយមនុស្សបីនាក់ផ្សេងទៀត។ គេវាយដំគាត់ នៅពេលដែលគាត់អស់កម្លាំងដួល

---

[៤១៦] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ជុន) ទំព័រ ២-៣, ១១-១២, ២៩-៣១។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១។

[៤១៧] ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ មាស ប៉េងគ្រី) ទំព័រ៧៤-៧៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ ៤៨-៤៩។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ប៉ាន់) ទំព័រ៥៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៤។

[៤១៨] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៣៤។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែកក្កដា (ជិន ម៉េត) ទំព័រ ១២។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦-១៧។ “ឧបសម្ព័ន្ធ២៖ ប្រវត្តិរូប ឃឹម [ជិន] ម៉េត” ឯកសារ E2/80/4.2, ERN (ភាសាខ្មែរ) 00343200។ “ឧបសម្ព័ន្ធ១៖ រូបថតរបស់ ជិន ម៉េត” ឯកសារ E2/80/4.1, ERN (ភាសាខ្មែរ) 00343199។ “ឧបសម្ព័ន្ធ១៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ ជិន ម៉េត ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១” ឯកសារ E2/80.1, ERN (ភាសាខ្មែរ) 00281155។

00573468



ហើយគេបានព្រមានគាត់ថា "មិត្តឯងត្រូវតែប្រឹង បើមិនប្រឹងទេប្រយ័ត្នបាត់ខ្លួន"[៤១៩]។ គេនឹងបន្ថែមកម្លាំង នៅពេលមាននរណាម្នាក់ក្នុងចំណោមអ្នកធ្វើការជាមួយគ្នាឈឺ ឬបាត់ខ្លួន។ គាត់បាននិយាយអំពីភាពអស់សង្ឃឹម ដែលធ្វើឱ្យគាត់ព្យាយាមធ្វើអត្តឃាត និងនិយាយជាប់ជានិច្ច អំពីការភ័យខ្លាច ការនឿយហត់ ការខ្សោយដោយសារធ្វើការច្រើនពេក និងសុខភាពទ្រុឌទ្រោម ដែលទាំងអស់នេះបន្សល់ទុកឱ្យគាត់នូវបញ្ហាអារម្មណ៍ និងការភ័យខ្លាចជាប់ខ្លួនជានិច្ច។ គាត់បានឃើញ គេបង្ខំកុមារឱ្យធ្វើការ "ខ្ញុំឃើញ ខ្ញុំអាណិតដល់ក្មេងទាំងនោះណាស់" ហើយក្មេងទាំងនោះភាគច្រើន បានស្លាប់ដោយសារអត់អាហារ និងជំងឺ[៤២០]។

២៣១. ជាទូទៅ ជនជាប់ចោទយល់ស្របថា ស្ថានភាពនៅ ស២៤ គឺដូចអ្វីដែលបានរៀបរាប់ ហើយបានបញ្ជាក់ថា អ្នកជាប់ឃុំមិនអាចដើរដោយសេរីក្នុងបរិវេណ ស២៤ ដោយគ្មានការអនុញ្ញាតឡើយ។ "ពួកសមាសភាពអាក្រក់" ត្រូវបានដាក់ខ្នោះជើង នៅពេលយប់ ហើយមិនត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងផ្ទះធម្មតាឡើយ។ អ្នកជាប់ឃុំទាំងអស់ ត្រូវបានយាមកាមយ៉ាងតឹងរ៉ឹងទាំងយប់ទាំងថ្ងៃ ហើយត្រូវបានអ្នកយាមឃ្លាំមើលនៅកន្លែងធ្វើការផងដែរ។ អ្នកយាមបានបង្ខំ និងជេរប្រមាថដើម្បីឱ្យអ្នកជាប់ឃុំខិតខំធ្វើការងារ[៤២១]។ ជនជាប់ចោទបានរៀបរាប់អំពីការធ្វើការងារជាច្រើនម៉ោង ដែលរួមមានពីពេលព្រលឹមស្រាងៗ និងរហូតដល់ពេលយប់នៅពេលដែលមានខែភ្លឺ និងនិយាយអំពីស្ថានភាពការងារធ្ងន់ធ្ងរ។ ជនជាប់ចោទបានយល់ស្របថា ប្រហែលជាអាចមានករណីមួយចំនួន ដែលអ្នកជាប់-ឃុំត្រូវបានគេប្រើជំនួសសត្វពាហនៈដើម្បីភ្ជួររាស់ដី[៤២២]។

[៤១៩] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៤៩-៥១។

[៤២០] ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ ៤៣-៤៤, ៤៨-៤៩, ៦០-៦១, ៧៣-៧៤។

[៤២១] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ៥៥-៥៧, ១៧២-១៧៣, ១៧៦, ១៨១-១៨២។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៣-៦៥។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៥។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ថុន) ទំព័រ២៨-៣០។

[៤២២] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥, ៣១។

00573469



## ២.៤.២.២ ការធ្វើឱ្យអ្នកជាប់ឃុំទៅជាទាសករនៅក្នុងមន្ទីរស២១ (ទួលស្លែង)

២៣២. មានអ្នកជាប់ឃុំតិចតួចបំផុត ដែលត្រូវបានបង្ខំឱ្យធ្វើការនៅមន្ទីរស១ (ទួលស្លែង)[៤២៣]។ អ្នកជាប់ឃុំទាំងនោះរួមមានសាក្សី វ៉ាន់ ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង និង ជុំ ម៉ី ដែលអ្នកទាំងនោះ ដំបូងត្រូវបានចាប់ខ្លួន ដាក់ខ្នោះជើង និងដាក់ឃុំឃាំងនៅមន្ទីរស២១ (ទួលស្លែង) មុនពេលដោះលែងឱ្យធ្វើការនៅទីនោះ។ អ្នកទាំងអស់នេះ បានរៀបរាប់អំពីស្ថានភាពដ៏គួរឱ្យរន្ធត់នៃការចាប់ខ្លួន ការឃុំខ្លួន ការរំលោភបំពានលើផ្លូវចិត្ត និងផ្លូវកាយ ការធ្វើទារុណកម្ម និងភាពភ័យខ្លាចជានិច្ច។ នៅពេលអ្នកជាប់ឃុំ ត្រូវបានគេជ្រើសរើសទុកឱ្យធ្វើការ "បណ្តោះអាសន្ន"[៤២៤] ពួកគេបានចាប់ផ្តើមធ្វើការនៅរោងជាង "គូរ ឆ្លាក់ ឬរោងជាងជួសជុលម៉ាស៊ីន"[៤២៥]។ នៅពេលនោះអ្នកទាំងពីរ ប៊ូ ម៉េង និង វ៉ាន់ ណាត អាចដេកនៅក្នុង ឬក្បែរកន្លែងធ្វើការរបស់គាត់បានតែមានអ្នកយាម និងចាក់សោរពីខាងក្រៅ ប៉ុន្តែមិនមានដាក់ខ្នោះជើងទេ[៤២៦]។ ផ្ទុយទៅវិញ ជុំ ម៉ី ត្រូវត្រឡប់ទៅបន្ទប់ឃុំឃាំងអ្នកទោសវិញជារៀងរាល់យប់ដែលនៅទីនោះគេបានដាក់ខ្នោះជើងគាត់ជាប់ជាមួយអ្នកជាប់ឃុំផ្សេងៗទៀត[៤២៧]។

២៣៣. អ្នកទាំងនោះបានធ្វើការជាច្រើនម៉ោងស្ថិតក្រោមការឃាមកាមជានិច្ចដោយគ្មានសិទ្ធិសេរីភាពដើរហើរទេ។ អ្នកទាំងនោះបានដឹងថា ប្រសិនបើពួកគាត់មិនបានបំពេញការងារតាមផែនការតម្រូវនោះ

---

[៤២៣] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥, ៣៨-៣៩។ ជនជាប់ចោទបានគណនាឃើញថាមានអ្នកទោសសរុបចំនួន១៥នាក់ "ដែលយកមកប្រើបណ្តោះអាសន្ននៅមន្ទីរស២១"។

[៤២៤] វ៉ាន់ ណាត បានឃើញចំណារ "ទុកសិន ទុកប្រើសិន" ត្រង់ឈ្មោះរបស់គាត់ ក្នុងបញ្ជីមានឈ្មោះប្រហែលជា១០នាក់ ចុះកាលបរិច្ឆេទក្នុងអំឡុងខែកុម្ភៈ ឆ្នាំ១៩៧៨។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៥៥។

[៤២៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ២០-២២។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ១១-១២។

[៤២៦] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ២៨-២៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៨។

[៤២៧] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២៥-២៦។

ទេ ពួកគាត់នឹងត្រូវទទួលទណ្ឌកម្មតាមវិធីផ្សេងៗដែលគ្មានកំណត់[៤២៨]។ ប៊ូ ម៉េង ត្រូវបានគេគំរាមថា ប្រសិនបើគាត់មិនអាចគូររូបឲ្យដូចរូប ប៉ុល ពត នោះទេ គាត់នឹងត្រូវទទួលទណ្ឌកម្ម[៤២៩]។ ជនជាប់-ចោទ បានមកពិនិត្យមើលការងាររបស់ "ជាងគូរ ឆ្លាក់" ជាញឹកញាប់ ហើយនៅពេលមួយនោះ វ៉ាន់ ណាត បានឃើញជនជាប់ចោទបង្ខំឲ្យ ប៊ូ ម៉េង វាយគ្នាជាមួយអ្នកជាប់ឃុំម្នាក់ទៀតឈ្មោះ អៀម ចាន់ ដោយប្រើទុយោរជ័រពណ៌ខ្មៅ[៤៣០]។ អ្នកទាំងនោះបានទទួលរបបអាហារប្រសើរជាងមុន ហើយស្ថានភាពជាទូទៅមានលក្ខណៈល្អប្រសើរបន្តិច ជាងពេលដែលពួកគាត់ត្រូវបានឃុំខ្លួនពីដំបូង។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ទាំងអស់នោះបានរស់នៅក្នុងភាពភ័យខ្លាចជាប់ជានិច្ច ដោយសារតែមានការឃាមកាមយ៉ាងតឹងរ៉ឹង ការដាក់គុកដ៏មានប្រសិទ្ធភាព និងដោយសារអាចមើលឃើញការប្រព្រឹត្តិអំពើនានាទៅលើអ្នកជាប់ឃុំផ្សេងទៀត[៤៣១]។

### ២.៤.៣ ការដាក់ក្នុងមន្ទីរឃុំឃាំង

២៣៤. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៣៤. បុគ្គលជាច្រើនត្រូវបានឃុំឃាំងដោយចេតនានៅមន្ទីរស២១។ ការចាប់ខ្លួនពួកគេពុំមានមូលហេតុត្រឹមត្រូវ និងមូលដ្ឋានច្បាប់ទេ។ បន្ថែមលើនេះទៀត អ្នកទោសទាំងនោះត្រូវបានដកហូតនូវសិទ្ធិជាមូលដ្ឋាន ដូចជាសិទ្ធិទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួនពួកគេ។ គ្មានភស្តុតាងណាមួយដែលបានបង្ហាញ

---

[៤២៨] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ២១-២២។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៣៩-៤០។

[៤២៩] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៥១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៤៥-៤៧។

[៤៣០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៨-២៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៤៥-៤៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៧-៦៩។

[៤៣១] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៥៣-៥៤, ៧៧-៧៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៧-២៨, ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ១២-១៣, ៦២-៦៤។

ថា មានប្រព័ន្ធច្បាប់ ឬតុលាការនៅកម្ពុជាក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ។ គ្មានការធានាផ្នែកនីតិវិធីណាមួយ ទោះជានីតិវិធីរដ្ឋបាល ឬនីតិវិធីតុលាការ ដែលតាមរយៈនេះ អ្នកទោសទាំងនោះអាចតទល់ប្រឆាំងនឹងការឃុំឃាំងខ្លួនរបស់ពួកគេឡើយ[៨៣២]។

### ២.៤.៣.១ ការដកហូតសេរីភាពដោយបំពាន

២៣៥. ជនជាប់ចោទបានយល់ស្របថា យ៉ាងហោចណាស់ក៏មានមនុស្សចំនួន១២.២៧៣នាក់ ដែលក្នុងនោះរួមមានទាំងបុរស ស្ត្រី និងកុមារ ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ អ្នកទោសមួយចំនួនដែលត្រូវបានគេកំណត់មុខសញ្ញាឲ្យនាំខ្លួនមកមន្ទីរស២១ ត្រូវបានគេចាប់ខ្លួនជាសម្ងាត់ ចំណែកឯអ្នកផ្សេងទៀត ត្រូវបានគេដាក់ខ្នោះដៃ ចងមុខ បង្ខំឲ្យបំពេញបែបបទមួយចំនួនមុននឹងត្រូវបានគេយកទៅឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងតូចៗ ឬបន្ទប់ឃុំខ្លួនរួមដែលជាកន្លែងអ្នកជាប់ឃុំទាំងនោះត្រូវបានគេដាក់ខ្នោះជើងជារនងបន្តជាប់ៗគ្នា[៨៣៣]។

២៣៦. ស២៤ ក៏បានឃុំខ្លួនមនុស្សរាប់រយនាក់ដែលរួមមានទាំងបុរស ស្ត្រី និងកុមារនៅក្នុងពេលតែមួយផងដែរ។ អ្នកជាប់ឃុំនៅ ស២៤ ភាគច្រើនត្រូវបានគេយកទៅការដ្ឋាន និងតម្រូវឲ្យធ្វើការ។ មានតែពួកសមាសភាពអាក្រក់ប៉ុណ្ណោះ ដែលត្រូវបានគេដាក់ច្រវាក់ជើង និងបង្ខាំងខ្លួន។ អ្នកទាំងឡាយណាដែលមិនត្រូវបានគេបង្ខាំងទុក ក៏មិនមានសិទ្ធិសេរីភាពដើរហើរ និងត្រូវបានគេឃាមកាមទាំងយប់ទាំងថ្ងៃផងដែរ[៨៣៤]។

---

[៨៣២] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៣៤ ។

[៨៣៣] "គោលជំហរបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ១០២, ១០៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៧-៥៨, ៥៩។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១១-១២, ៦០-៦៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ១៦-១៩។

[៨៣៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៤-៥៥។

២៣៧. អ្នកជាប់ឃុំត្រូវបានគេដាក់ខ្នោះ និងចងមុខ ហើយដឹកជញ្ជូនពីមន្ទីរស២១ (ទួលស្លែង) ទៅជើងឯក។ នៅពេលដែលរថយន្តទៅដល់ជើងឯក អ្នកជាប់ឃុំត្រូវបានគេដាក់ចូលទៅក្នុងផ្ទះឈើមួយ ហើយបន្ទាប់មកគេបណ្ដើរម្ដងម្នាក់ៗ ឬជាក្រុមតូចៗឲ្យដើរទៅកាន់រណ្ដៅដើម្បីសម្លាប់[៤៣៥]។

២៣៨. ក្នុងចំណោមអ្នកជាប់ឃុំទាំងអស់ រួមទាំង កុមារ និងទារកផងដែលតាមការវិនិច្ឆ័យដោយសត្យានុម័តពួកគេមិនមានកំហុសអ្វីឡើយ។ អ្នកទាំងនោះរួមមានសមាជិកគ្រួសារ និងអ្នកនៅក្រោមបង្គាប់បុគ្គលដែលត្រូវបានចាប់ខ្លួន ដែលអ្នកទាំងអស់នោះត្រូវបានឃុំខ្លួនដោយសារតែពួកគាត់មានទំនាក់ទំនងជាមួយអ្នកដែលត្រូវបានគេឃុំខ្លួនតែប៉ុណ្ណោះ[៤៣៦]។

### ២.៤.៣.២ មិនមានការអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់

២៣៩. លក្ខណៈដូចគ្នានៃទីកន្លែងទាំងបីនេះ គឺការមិនអនុវត្តនីតិវិធីតាមផ្លូវច្បាប់នៅពេលចាប់ខ្លួន ឬឃុំខ្លួន ដើម្បីប្រាប់ដល់អ្នកទាំងនោះអំពីមូលហេតុនៃការចាប់ខ្លួន និងការឃុំខ្លួន[៤៣៧]។ អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះមិនបានទទួលការជំនុំជម្រះ[៤៣៨] ពុំបានទទួលការប្រឹក្សាផ្នែកច្បាប់ ឬពុំមានលទ្ធភាពតវ៉ានឹងការចាប់ខ្លួន ការឃុំខ្លួន ឬប្រហារជីវិត ដោយចៀសមិនផុតនោះឡើយ។ អ្នកជាប់ឃុំកម្រនឹងត្រូវបានគេដោះលែងណាស់[៤៣៩]។ ជនជាប់ចោទយល់ស្របថា ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ដោយគ្មានការ

---

[៤៣៥] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤-៣៥, ៤២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥១-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ គយ តេង) ទំព័រ៤២-៤៣។

[៤៣៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៩-៥០។

[៤៣៧] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៨-៩, ១៣-១៤។

[៤៣៨] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៣-២៤។

[៤៣៩] "កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយ ស.ច.ស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨" ឯកសារ E3/380, ERN (ភាសាខ្មែរ) 00178026-00178027។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២។

ជំនុំជម្រះគឺជា "[...] វិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី"[៤៤០]។ នត្ថិភាពនៃនីតិវិធីតុលាការ និងច្បាប់ដើម្បីឲ្យអ្នកជាប់ឃុំអាចតវ៉ាចំពោះការឃុំខ្លួនរបស់ពួកគេបាន គឺជាការរំលោភសិទ្ធិរបស់ពួកគេយ៉ាងព្រៃផ្សៃ ហើយនាំឲ្យមានការរំលោភគោលការណ៍មូលដ្ឋាននៃយុត្តិធម៌។

### ២.៤.៤ ការធ្វើទារុណកម្ម ដោយរួមទាំងការរំលោភលើផ្លូវភេទ

២៤០. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៣៦. អ្នកទោសនៅមន្ទីរ ស២១ ភាគច្រើនដែលត្រូវបានសួរចម្លើយទទួលរងការសួរចម្លើយតាមរបៀបឃោរឃៅ ដែលត្រូវបានប្រព្រឹត្តដោយចេតនា និងជាច្រើនលើកច្រើនសារ ហើយជាញឹកញាប់ វិធីទាំងនេះបណ្តាលឲ្យមានរបួសដល់រូបរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ។ វិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជាក់លាក់ ដើម្បីប្រមូលយកព័ត៌មាន ឬចម្លើយសារភាពពីអ្នកទោស។ ប្រសិនបើមានការទាមទារឲ្យបង្ហាញថា ចារីនៃឧក្រិដ្ឋកម្មទាំងនេះបានប្រព្រឹត្តនៅក្នុងការអនុវត្តតួនាទីផ្លូវការរបស់ខ្លួន ក៏មានភស្តុតាងបង្ហាញថា ពួកគេបានប្រព្រឹត្តអំពើទាំងនោះក្នុងតួនាទីផ្លូវការ ដូចបានកំណត់ក្នុងរចនាសម្ព័ន្ធបញ្ជាដ៏ច្បាស់លាស់មួយ។
>
> ១៣៧. ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបង្ហាញថាយ៉ាងហោចណាស់មានករណីមួយនៃការស៊កបញ្ចូលក្នុងប្រដាប់ភេទដោយបង្ខំ ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ នោះគឺករណីដែលអ្នកសួរចម្លើយម្នាក់បានយកឈើទៅស៊កក្នុងប្រដាប់ភេទអ្នកទោសស្ត្រីម្នាក់[៤៤១]។

---

[៤៤០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៣-៥៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ២៣-២៤។

[៤៤១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៣៦-១៣៧ ។

00573474



## ២.៤.៤.១ ការប្រើទារុណកម្មនៅក្នុងមន្ទីរស២១ (ទួលស្លែង)

### ២.៤.៤.១.១ បច្ចេកទេសធ្វើទារុណកម្ម

២៤១. បច្ចេកទេសធ្វើទារុណកម្មជាច្រើនត្រូវបានអនុវត្តនៅក្នុងមន្ទីរស២១ (ទួលស្លែង) ដែលបណ្ដាលឱ្យមានការឈឺចាប់ផ្នែករូបរាងកាយ និង/ឬ ស្មារតីយ៉ាងខ្លាំង។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកសួរចម្លើយត្រូវបានអនុញ្ញាតឱ្យប្រើបច្ចេកទេសសួរចម្លើយដោយប្រើហិង្សាចំនួនបួនគឺ ការវាយ ការឆក់ខ្សែភ្លើង ការច្រកក្បាលក្នុងថង់ប្លាស្ទិក និងការ"បន្តក់ទឹកចូលក្នុងច្រមុះ"[៤៤២]។ ជនជាប់ចោទបានទទួលស្គាល់ថា ការវាយគឺជាបច្ចេកទេសធ្វើទារុណកម្មជាទូទៅនៅមន្ទីរស២១[៤៤៣]។ អង្គជំនុំជម្រះយល់ឃើញថា ការវាយដោយប្រើរយៈពេលយូរ ឬដោយកំលាំងខ្លាំង ឬដោយបច្ចេកទេសសួរចម្លើយដោយប្រើហិង្សាដទៃទៀតដែលបានទទួលស្គាល់ គឺជាការធ្វើទារុណកម្ម។ ការវាយបែបនេះអាចបណ្ដាលឱ្យហូរឈាម និងរបួសជាច្រើនផ្នែកដូចជាបាក់ដៃ ជើង ស្ពាប់លែងឮ បាក់ធ្មេញ ស្លាកស្នាម និងពេលខ្លះរហូតដល់ស្លាប់[៤៤៤]។ បច្ចេកទេសសួរចម្លើយមួយទៀត ដែលគេប្រើជាទូទៅគឺការឆក់ខ្សែភ្លើង[៤៤៥] ដែលបណ្ដាល

[៤៤២] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ៣៥។ "កំណត់ហេតុនៃការសួរចម្លើយ ឌុចដោយ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨" ឯកសារ E3/11, ERN (ភាសាខ្មែរ) 00158840-00158841។

[៤៤៣] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៩-៧០។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ៤២-៤៤។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ គង់ ផៃ) ទំព័រ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៨-៦៩។

[៤៤៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១០, ២៥-២៦, ៤៩-៥០, ៥៧, ៤៩-៥០ ។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ០៩។ "រូបថតចំនួនពីរសន្លឹក ដែលត្រូវបានគេថតខ្នងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ ម៉េង ក្រោយពីសវនាការនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩" ឯកសារ E174។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩-១០។

[៤៤៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៤; ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ៣៥។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់

ឱ្យអ្នកជាប់ឃុំសន្លប់ និងនៅក្នុងករណីខ្លះទៀតក្លាយទៅជាពិការ វង្វេងវង្វាយ ឬរហូតដល់ស្លាប់។ ការយកថង់ប្លាស្ទិកមកច្រកក្បាលអ្នកជាប់ឃុំ បានធ្វើឱ្យគាត់ថប់ដង្ហើមស្ទើរស្លាប់[៤៤៦]។ យ៉ាងហោចណាស់ក៏មានការបាត់បង់ជីវិតមួយករណីដែរដោយសារតែការធ្វើដូច្នេះ។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកជាប់ឃុំត្រូវបានទទួលរងនូវការបន្តក់ទឹកចូលក្នុងច្រមុះដែលធ្វើឱ្យថប់ដង្ហើម និងឈ្លក់ទឹក[៤៤៧]។

២៤២. បន្ថែមពីលើបច្ចេកទេសសួរចម្លើយចំនួនបួន ដែលមានការអនុញ្ញាតដូចបានលើកឡើងខាងលើ ជនជាប់ចោទបានទទួលស្គាល់ថា បច្ចេកទេសសួរចម្លើយមួយចំនួនទៀតត្រូវបានអនុវត្តដោយអ្នកសួរ-ចម្លើយដូចជា៖ ការប្រើដង្កាប់សម្រាប់ដកក្រចកដៃ និង/ឬក្រចកជើង ការយកម្ជុលចាក់ចូលក្នុងសាច់ក្រោមក្រចក និងការចាក់ទម្លុះក្រចកដៃ និង/ឬក្រចកជើង[៤៤៨]។ យោងតាមសម្ដីរបស់ជនជាប់ចោទ ការអនុវត្តទាំងនេះគឺជាការល្មើសនឹងវិន័យនៃការធ្វើទារុណកម្ម ហើយគាត់បានប្រាប់ទៅអ្នកសួរចម្លើយឱ្យ

---

គង់ ផៃ) ទំព័រ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៨-៦៩, ៧៥-៧៦។ "កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ E3/413, ERN (ភាសាខ្មែរ) 00146595-00146596។។

[៤៤៦] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២២-២៣ ។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៣-២៤, ៥៧-៥៨ ។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៩-៣០ ។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ២១។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែ មិថុនាឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ទំព័រ៧៩ ។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៥-៤៦។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៤០-៤១ ។"ចម្លើយសារភាពរបស់ កែ គឹមហួត" ឯកសារ E3/369, ERN (ភាសាខ្មែរ) 00014096។ *សូមមើលផងដែរ* "សំឡេងពីមន្ទីរ ស-២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427, ERN (ភាសាខ្មែរ) 00191989។

[៤៤៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១, ១៧-២១, ៣៥-៣៦, ៤១-៤៣។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩(ជនជាប់ចោទ) ទំព័រ៩-១០; "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ២១៨។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៧៥-៧៦។ "កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ខន" E3/413, ERN (ភាសាខ្មែរ) 00146595-00146596 ។

[៤៤៨] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២១-២៣, ៥៥-៥៦។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៩-៦១។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦-៦៨។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥៣-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៧៥-៧៦។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៤-៦។ "កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ E3/413, ERN (ភាសាខ្មែរ) 00146595-00146596 ។

បញ្ឈប់នូវសកម្មភាពទាំងនោះនៅពេលដែលគាត់បានដឹងអំពីការអនុវត្តដូច្នោះ[៤៤៩]។ ការអុជនឹងភ្លើងបារីក៏ត្រូវបានប្រើប្រាស់ផងដែរ ទោះបីជាអំពើនេះមិនត្រូវបានជនជាប់ចោទបញ្ជាឲ្យធ្វើ ឬអនុញ្ញាតឲ្យធ្វើ[៤៥០] ក៏ដោយ។

២៤៣. ការអនុវត្តដោយបង្ខំឲ្យអ្នកជាប់ឃុំថ្វាយបង្គំរូបថតែ្ក ដែលរូបភ្ញែមួយមានក្បាលហូជីមិញ និងរូបផ្ដែមួយទៀតមានក្បាល Lyndon B. Johnson ដែលធ្វើឲ្យជនរងគ្រោះបាត់បង់តម្លៃជាមនុស្ស និងទទួលនូវការឈឺចាប់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ[៤៥១]។ ជនជាប់ចោទបានទទួលស្គាល់ថា គាត់បានជំរុញឲ្យមានការធ្វើបែបនេះ ដោយសារតែគាត់យល់ថា វាជាវិធីមួយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបានចម្លើយសារភាព[៤៥២]។ ករណីនេះ បញ្ជាក់អំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ផ្លូវចិត្តនៅក្នុងបរិបទវប្បធម៌ប្រទេសកម្ពុជា ដែលបង្កឡើងដោយបច្ចេកទេសនេះ[៤៥៣]។ ជនជាប់ចោទជឿជាក់ថា អ្នកជាប់ឃុំត្រូវបានបង្ខំឲ្យលុតជង្គង់ថ្វាយបង្គំវត្ថុមួយចំនួន ដូចជា តុ និងកៅអីជាដើម ប៉ុន្តែបានបញ្ជាក់ថា ការធ្វើបែបនេះមិនសូវអាម៉ាស់ និងធ្ងន់ធ្ងរនោះទេ[៤៥៤]។

---

[៤៤៩] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៩-៦០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦១-៦២។

[៤៥០] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៦-៦៧, ៨០-៨១។

[៤៥១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៥-៤៦។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៨-២៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥៥-៥៦។ "សៀវភៅកំណត់ហេតុមន្ទីរ ស២១ របស់ ឌុយ និង ហឿង សុងហួ ហៅ ប៊ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ – ១៧ ខែធ្នូ ឆ្នាំ១៩៧៨" ឯកសារ E3/73, ERN (ភាសាខ្មែរ) 00077473។ "សំឡេងពីមន្ទីរ ស-២១ – ភាពព្រឺខ្លាចនិងប្រវត្តិនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត" (សៀវភៅ) ដោយ David CHANDLER ឯកសារ E3/427, ERN (ភាសាខ្មែរ) 00191989-00191992។

[៤៥២] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៩-៧០។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧-៦៨។

[៤៥៣] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ (ឈឹម សុធារ៉ា) ទំព័រ៦-៨,២៤-២៥, ៣៥-៣៦,៣៧-៣៨។

[៤៥៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨-៦៨។

00573477



២៤៤. ជនជាប់ចោទបានទទួលស្គាល់ថា ការបង្ខំឱ្យស៊ីលាមកក៏ត្រូវបានប្រើជាបច្ចេកទេសនៃការសួរ-ចម្លើយដែរ[៤៥៥]។ ប៉ុន្តែ គាត់បាននិយាយថាវិធីបែបនេះគឺជាការល្មើសនឹងវិន័យនៃការធ្វើទារុណកម្មប៉ុណ្ណោះ ដូច្នេះគាត់មិនបានដាក់ទណ្ឌកម្មទៅលើអ្នកសួរចម្លើយដែលបានប្រើបច្ចេកទេសនេះទៅលើអតីតគ្រូរបស់គាត់ឈ្មោះ កែ គីម ហួត ហៅ សុត[៤៥៦] នោះទេ។ អ្នកជាប់ឃុំមួយចំនួនក៏ត្រូវបានគេបង្ខំឱ្យផឹកទឹកនោមផងដែរ[៤៥៧]។

២៤៥. វិធីបន្ថែមមួយចំនួនទៀតក៏ត្រូវបានគេប្រើប្រាស់ដើម្បីគំរាមកំហែង និងបំបាក់ស្មារតីរបស់អ្នក-ជាប់ឃុំ និងទុកពួកគេឱ្យស្ថិតនៅក្នុងស្ថានភាពភ័យខ្លាចជាប់ជាប្រចាំដើម្បីងាយស្រួលទទួលបានចម្លើយសារភាព។ ជនជាប់ចោទ និងអ្នកសួរចម្លើយបានប្រើប្រាស់ "ការឃោសនា" ការសម្លុត និងការគំរាមកំហែងដើម្បីបំភ័យអ្នកជាប់ឃុំ និងធ្វើឱ្យអ្នកជាប់ឃុំសារភាព[៤៥៨]។ អ្នកជាប់ឃុំត្រូវបានគេចាត់ទុកថាជាខ្មាំង និងត្រូវបានគេប្រាស្រ័យទាក់ទងក្នុងរបៀបជាការមើលងាយ មើលថោក[៤៥៩]។ អ្នកសួរចម្លើយក៏ត្រូវបានគេបង្រៀនឱ្យទាញយកផលប្រយោជន៍ពីការភ័យខ្លាចរបស់អ្នកជាប់ឃុំ ដោយនិយាយអំពីការគំរាម និងគ្រោះថ្នាក់ដល់ជីវិតសមាជិកគ្រួសាររបស់ពួកគេផងដែរ[៤៦០]។ ការបង្ហាញ

---

[៤៥៥] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ"ឯកសារ E5/11/6.1 កថាខណ្ឌ២២២។

[៤៥៦] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៦, ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧។ *សូមមើលផងដែរ* "ចម្លើយសារភាពរបស់ កែ គីមហួត" ឯកសារ E3/369, ERN (ភាសាខ្មែរ) 0014091, 00014093-00014095។

[៤៥៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧។

[៤៥៨] *សូមមើល* "បញ្ជីស្ថិតិរបស់សន្តិបាល ស២១" ឯកសារ E3/426, ERN (ភាសាខ្មែរ) 00007465-00007466, 00007482-00007483។

[៤៥៩] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៥។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥៦-៥៧។

[៤៦០] "សៀវភៅកំណត់ហេតុមន្ទីរ ស២១ របស់ ទុយ និង ហឿង សុងហួ ហៅ ប៊ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ – ១៧ ខែធ្នូ ឆ្នាំ១៩៧៨" ឯកសារ E3/73, ERN (ភាសាខ្មែរ) 00077523-00077525។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៨-២៩។

ឧបករណ៍ធ្វើទារុណកម្មមួយចំនួនដូចជា អង្គំ ដំបង កាំបិត និងពូថៅនៅក្នុងបន្ទប់សួរចម្លើយ[៤៦១] ក៏ជាបច្ចេកទេសសម្រាប់បំភិតបំភ័យអ្នកជាប់ឃុំដែរ។

២៤៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ក៏បានបង្ហាញផងដែរថា មានភស្តុតាងយ៉ាងហោចណាស់ក៏មួយករណីដែរ អំពីការរំលោភលើផ្លូវភេទដែលត្រូវបានគេប្រព្រឹត្តនៅមន្ទីរស២១[៤៦២]។ ជនជាប់ចោទបានទទួលស្គាល់ថា នៅក្នុងពេលសួរចម្លើយ បុគ្គលិកមន្ទីរស២១ ម្នាក់បានយកឈើរុកចូលទៅក្នុងប្រដាប់ភេទរបស់អ្នកជាប់ឃុំម្នាក់[៤៦៣]។ ជនជាប់ចោទបាននិយាយថា គាត់មានប្រតិកម្មអារម្មណ៍យ៉ាងខ្លាំងអំពីហេតុការណ៍នេះ ប៉ុន្តែគាត់មិនចង់បង្ហាញអំពីការខឹងសម្បារបស់គាត់ទៅថ្នាក់លើ និងអ្នកក្រោមបង្គាប់គាត់ទេ។ លើសពីនេះ គាត់បាននិយាយថា គាត់មិនបានដឹងថាអំពើនេះគឺជាបទល្មើសនោះទេ និងបានចាត់ទុកថាហេតុការណ៍នេះជា "ការល្មើសនឹងវិន័យនៃការធ្វើ-ទារុណកម្ម"។ គាត់បានរាយការណ៍អំពីឧប្បត្តិហេតុនេះជូនទៅថ្នាក់លើ ប៉ុន្តែមិនបានទទួលការឆ្លើយ-តបណាមួយនោះទេ[៤៦៤]។ ជាលទ្ធផលគាត់បានបញ្ឈប់មិនឱ្យមានអ្នកសួរចម្លើយជាបុរសសួរចម្លើយអ្នកជាប់ឃុំស្ត្រីទៀត និងបានបង្កើតក្រុមអ្នកសួរចម្លើយស្ត្រីសម្រាប់សួរចម្លើយអ្នកជាប់ឃុំស្ត្រីជំនួសវិញ[៤៦៥]។ ផ្ទុយទៅវិញ អ្នកដែលបានប្រព្រឹត្តនោះមិនត្រូវបានដាក់ទណ្ឌកម្មឡើយ[៤៦៦]។ អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមាន ភស្តុតាងបញ្ជាក់តាមបទដ្ឋានតម្រូវពិតប្រាកដមែន។

---

[៤៦១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥៧-៥៨។

[៤៦២] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៣៧។

[៤៦៣] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ២៣១។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៩-៦១។ "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ E3/413, ERN (ភាសាខ្មែរ) 00146596-00146597 ។

[៤៦៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៣, ៦០-៦១។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣២-៣៣។

[៤៦៥] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ២៣១។ ប្រតិចារឹក ចុះថ្ងៃទី២៣ មេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤-២៥។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣, ៦០-៦២។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣២។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៦-១៨។

២៤៧. ទោះបីជាជនជាប់ចោទបាននិយាយថា មានហេតុការណ៍នៃការរំលោភលើផ្លូវភេទតែមួយគត់ ដែលបានកើតមាននៅមន្ទីរស២១[៦៦៧] ក៏ដោយ ក៏មានសាក្សីបីបួននាក់បាននិយាយអំពីហេតុការណ៍នៃការរំលោភផ្លូវភេទមួយផ្សេងទៀត ដែលបានប្រព្រឹត្តដោយអ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច ទៅលើអ្នកជាប់ឃុំស្ត្រីម្នាក់[៦៦៨]។ ក្រោយមកឈ្មោះ ទូច ត្រូវបានគេចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរស២១[៦៦៩]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមិនមានភស្តុតាងបញ្ជាក់ទៅតាមបទដ្ឋានតម្រូវឡើយ។

២៤៨. ជនជាប់ចោទបានទទួលស្គាល់ថា អ្នកជាប់ឃុំនៅ ស២៤ ពិតជាបានទទួលរងនូវអំពើហិង្សានៅក្នុងពេលសួរចម្លើយ ប៉ុន្តែ អំពើហិង្សាទាំងនោះបានប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាតពីគាត់ឡើយ។

#### ២.៤.៤.១.២ ហេតុការណ៍ជាក់លាក់នៃការធ្វើទារុណកម្ម

២៤៩. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃ ចំនួនពីរសប្តាហ៍ជាប់ៗគ្នា។ គេបានដាក់ខ្នោះជើងគាត់ និងបានបង្ខំគាត់ឲ្យដេកផ្កាប់មុខទៅលើឥដ្ឋ ហើយគេប្រើសម្តីអសុរោះមកលើគាត់។ អ្នកសួរចម្លើយបង្ហាញគាត់នូវឧបករណ៍ធ្វើទារុណកម្ម និងបានប្រាប់គាត់ឲ្យជ្រើសរើសនូវឧបករណ៍ណាមួយដែលនឹងត្រូវប្រើសម្រាប់ធ្វើទារុណកម្មលើរូបគាត់។ អ្នកសួរចម្លើយបានប្តូរវេនគ្នាវាយខ្នងគាត់នឹងខ្សែតី រំពាត់ផ្តៅ ដែលបណ្តាលមានឲ្យឈាមហូរពាសពេញលើឥដ្ឋ។ អ្នកសួរចម្លើយក៏បានប្រើខ្សែភ្លើងឆក់គាត់ រហូតដល់សន្លប់ផងដែរ។ ដើមបណ្តឹង-

---

[៦៦៦] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥២-៥៣។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣២។ “កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨” ឯកសារ E3/378, ERN (ភាសាខ្មែរ) 00185493-00185494។

[៦៦៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៩-៦១។ “គោលជំហរបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ” ឯកសារ E5/11/6.1 កថាខណ្ឌ២៣១។

[៦៦៨] ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣២-៣៣។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៦១-៦២ ។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៣២-៣៣។

[៦៦៩] ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣២-៣៣។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៦១។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៣២-៣៣។

រដ្ឋប្បវេណី ប៊ូ ម៉េង នៅមានសន្លាកដោយសារតែការវាយដំទាំងនោះ។ គ្រប់ពេលដែលគេវាយគាត់ គេបានសួរសំណួរគាត់ទាក់ទងនឹងការពាក់ព័ន្ធរបស់គាត់ជាមួយសេអ៊ីអា(CIA)និងកាហ្សេបេ(KGB)។ ជនជាប់ចោទមិនបានជំទាស់នឹងអង្គហេតុទាំងនេះទេ[៤៧០]។

២៥០. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បាននិយាយថា គេបានសួរចម្លើយគាត់អស់រយៈពេល ១២ថ្ងៃ និង១២យប់។ នៅក្នុងអំឡុងពេលសួរចម្លើយ គេបានដាក់ខ្នោះជើងគាត់ និងប្រមាថមើលងាយគាត់។ គេបានវាយគាត់នឹងរំពាត់ខ្សែតីជាច្រើនលើកច្រើនសា ហើយម្រាមដៃមួយរបស់គាត់បានបាក់ដោយសារតែគាត់យកដៃរងនៅពេលគេវាយគាត់។ នៅពេលគាត់ព្យាយាមបដិសេធចំពោះការចោទប្រកាន់ថាគាត់មានការពាក់ព័ន្ធជាមួយ សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB)នោះ អ្នកសួរចម្លើយម្នាក់បានដកក្រចកជើងគាត់ទាំងសងខាង ដែលបណ្តាលឲ្យគាត់ "ឈឺញ័រតតាក់"។ ក្រោយមកគាត់មិនអាចដើរបានទេ។ គាត់បានទទួលរងនូវការឆក់ខ្សែភ្លើងចំនួនពីរលើក ហើយគាត់បានដួលសន្លប់បន្ទាប់ពីការឆក់មួយលើកៗ។ ការសួរចម្លើយបានបញ្ចប់ក្រោយពេលដែលគាត់ "បានសារភាព" ថាពិតជាបានចូលរួមជាមួយសេអ៊ីអា (CIA) និងកាហ្សេបេ (KGB) មែន។ ជនជាប់ចោទបានទទួលស្គាល់អង្គហេតុទាំងនេះ[៤៧១]។ អង្គជំនុំជម្រះយល់ឃើញថា ការអះអាងអំពីការធ្វើទារុណកម្មដោយ ប៊ូ ម៉េង និងជុំ ម៉ី បានបង្ហាញទៅតាមបទដ្ឋានតម្រូវ។

២៥១. ជនជាប់ចោទបានបដិសេធអំពីការប្រើប្រាស់បច្ចេកទេសមួយចំនួនដូចជា ការជ្រមុជក្បាលអ្នកជាប់ឃុំចូលក្នុងទឹកពាង ដោយចងជើងព្យួរឡើងលើដៃជាប់ចំណងស្លាបសេក[៤៧២] ដូចដែលបានបង្ហាញ

---

[៤៧០] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧០។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៩-១១, ២០-២៣, ២៤-២៥, ៥៧-៦១។ *សូមមើលផងដែរ* "រូបថតពីរសន្លឹកនៃ(ស្លាកស្នាម)ខ្នងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង ដែលបានថតមុនពេលសវនាការរបស់គាត់នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩" ឯកសារ E174។

[៤៧១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧០-៧១។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៦។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៩, ១១-១២, ១៨-២២, ២៤, ៥៤-៥៦, ៥៩-៦០។

[៤៧២] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨-៦៩, "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1, កថាខណ្ឌ២២៥-២២៧។

នៅក្នុងគំនូរមួយក្នុងចំណោមគំនូរដទៃទៀតរបស់សាក្សី វ៉ាន់ ណាត[៤៧៣]។ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់សាក្សី វ៉ាន់ ណាត ដែលបានឃើញ និងបានគូររូបភាពនេះមានភាពស៊ីសង្វាក់គ្នា និងអាចជឿបាន ហើយការធ្វើទារុណកម្មបានបង្ហាញទៅតាមបទដ្ឋានតម្រូវ។

២.៤.៤.២ គោលបំណងនៃការធ្វើទារុណកម្ម

២៥២. យោងតាមសំដីរបស់ជនជាប់ចោទ គោលបំណងនៃការធ្វើទារុណកម្មនៅមន្ទីរស២១ គឺ ៖

> "នេះពិតជាការធ្វើទុក្ខធ្វើបាបបន្ថែមទៅលើជនរងគ្រោះបង្ខំឲ្យឆ្លើយ។ ដូច្នេះ វាជាការចាប់បង្ខំទាំងផ្លូវកាយ ដោយមានការឈឺចាប់ខាងសាច់ ខាងឈាម ហើយក៏វារួមផ្សំនឹងការស្តី ការជេរទៅទៀត វាទៅជាការចាប់បង្ខំខាងផ្លូវចិត្ត ខាងផ្លូវគំនិតឲ្យអ្នកសារភាព គេសុខចិត្តសារភាព"[៤៧៤]។

២៥៣. ស្រដៀងគ្នានេះដែរ កំណត់ត្រារបស់អ្នកសួរចម្លើយដែលមានចំណងជើង "បញ្ញើស្តិតិ" បញ្ជាក់ថា "គោលបំណងនៃការធ្វើទារុណកម្ម គឺយកចម្លើយរបស់វា ពុំមែនធ្វើដើម្បីសប្បាយទេ។ ដូច្នេះ ត្រូវធ្វើឲ្យវាឈឺដើម្បីឲ្យវាឆាប់ឆ្លើយ។ គោលបំណងម៉្យាងទៀត គឺកាច់វាឲ្យខ្លាច ឲ្យបាក់ស្បាត"[៤៧៥]។ ការធ្វើទារុណកម្មនេះត្រូវបានបញ្ជាក់តាមរយៈកំណត់ត្រារបស់ ប៉ុន និង ទុយ ដែលណែនាំថា ការវាយដំគឺដើម្បីធ្វើឲ្យឈឺ[៤៧៦]។

---

[៤៧៣] "រូបគំនូររបស់អ្នកទោសមន្ទីរស២១ ដែលវ៉ាន់ ណាត ពិពណ៌នាអំពីការធ្វើទារុណកម្មនៅទីធ្លារបស់មន្ទីរស២១", E3/260។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ២៧-២៨, ៣៨-៣៩ ("គំនូរលេខ១២")។

[៤៧៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១។

[៤៧៥] "បញ្ញើស្តិតិរបស់សន្តិបាល ស២១", E3/426, ERN (ភាសាខ្មែរ) 00007471-00007472។

[៤៧៦] "សៀវភៅកំណត់ហេតុមន្ទីរស២១ របស់ ទុយ និង ហឿង សុងហួ ហៅ ប៉ុន ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ – ១៧ ខែធ្នូ ឆ្នាំ១៩៧៨" ឯកសារ E3/73, ERN (ភាសាខ្មែរ) 00077473។

២៥៤. ការប្រើប្រាស់បច្ចេកទេសនានាក្នុងការសួរចម្លើយ គឺដើម្បីទទួលបានចម្លើយសារភាពពីអ្នក-ជាប់ឃុំ ដោយមិនគិតថាអំពើនោះនាំឱ្យមានការឈឺចាប់លើរូបកាយ ឬឈឺចាប់ផ្នែកផ្លូវចិត្តឡើយ[៤៧៧] ចម្លើយសារភាពដែលទទួលបានមានរៀបរាប់លម្អិតអំពីជីវប្រវត្តិអ្នកជាប់ឃុំ ចរិតលក្ខណៈនៃអំពើ និងសកម្មភាព"ក្បត់"ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធដោយផ្ទាល់រវាងអ្នកជាប់ឃុំក្នុងអំពើនោះនិងបណ្តាញ "ជនក្បត់"[៤៧៨] ដទៃទៀត។ ការសួរចម្លើយអាចបញ្ចប់ទៅបាន តែនៅពេលដែលគេយល់ឃើញថាចម្លើយសារភាពនោះគ្រប់គ្រាន់ និងចប់សព្វគ្រប់។ បន្ទាប់មកចម្លើយសារភាពត្រូវបានពិនិត្យដោយថ្នាក់លើ និងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសំខាន់ៗចំនួនពីរ៖ ទីមួយ ដើម្បីធ្វើយុត្តិកម្មចំពោះការសម្រេចចាប់ខ្លួនអ្នកជាប់ឃុំ ដែលបានសរសេរចម្លើយសារភាពនោះ និងទីពីរ ដើម្បីទទួលបានព័ត៌មានសម្រាប់តាមដាន និងឈានទៅរកការចាប់ខ្លួនមនុស្សដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព។

២៥៥. គោលបំណងមួយទៀតនៃការធ្វើទារុណកម្មនៅមន្ទីរស២១ គឺការដាក់ទណ្ឌកម្ម[៤៧៩]។ ការធ្វើទារុណកម្មនៅ ស២៤ ក៏ត្រូវបានគេប្រើផងដែរដើម្បីដាក់ទណ្ឌកម្មអ្នកជាប់ឃុំ ដែលមិនគោរពតាមវិន័យ ឬមិនធ្វើការតាមបទដ្ឋានដែលបានដាក់ឱ្យអនុវត្ត។ ទណ្ឌកម្មក៏ត្រូវបានប្រើផងដែរដើម្បី

[៤៧៧] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៣។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៧២-៧៣។ "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ E3/413 ERN (ភាសាខ្មែរ) 00146601 ។ "បញ្ជីស្ថិតិរបស់សន្តិបាល ស២១" ឯកសារ E3/426, ERN (ភាសាខ្មែរ) 00007486-00007486។

[៤៧៨] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩-២០, ៣៨-៣៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៥-១៦, ២១-២២, ៥១-៥៣។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៤-១៥។ "បញ្ជីស្ថិតិរបស់សន្តិបាល ស២១" ឯកសារ E3/426, ERN (ភាសាខ្មែរ) 00007446-00007449។

[៤៧៩] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ ២៧-២៨, ៣៨-៣៩, ៥៣-៥៤ យោងទៅនឹង "រូបគំនូររបស់អ្នកទោសមន្ទីរស២១ ដែលវ៉ាន់ ណាត ពិពណ៌នាអំពីការធ្វើទារុណកម្មនៅទីធ្លាររបស់មន្ទីរស២១" ("រូបគំនូរលេខ១២") ឯកសារ E3/260។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៩។

ការពារកុំឲ្យអ្នកជាប់ឃុំធ្វើការប្រឆាំងតវ៉ា ឬលួចរត់ និងនៅពេលសួរចម្លើយផ្សេងៗដោយគ្មានបញ្ជាពីជនជាប់ចោទនៅ ស២៤[៤៨០]។

២.៤.៤.៣ សមត្ថកិច្ចផ្លូវការរបស់ចារី

២៥៦. បុគ្គលិកមន្ទីរស២១ និងបុគ្គលិកស២៤ រួមទាំងអ្នកសួរចម្លើយ បានបំពេញតួនាទីតាមឋានានុក្រមដែលត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ ក្រោមបញ្ជា ឬអំណាចរបស់ជនជាប់ចោទដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានបំពេញតួនាទីនេះ តាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ដោយពិចារណាអំពីតួនាទីរបស់បុគ្គលិកទាំងអស់នោះនៅក្នុងរដ្ឋមួយដែលមានការគ្រប់គ្រង អង្គជំនុំជម្រះសន្និដ្ឋានថាអ្នកសួរចម្លើយនៅមន្ទីរស២១ និងបុគ្គលិកស២៤ដែលបានប្រព្រឹត្តអំពើទារុណកម្មទាំងឡាយបានអនុវត្តសមត្ថកិច្ចជាផ្លូវការរបស់ខ្លួន។

២.៤.៥ អំពើអមនុស្សធម៌ផ្សេងៗទៀត

២៥៧. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ១៤៣. អ្នកទោសនៅមន្ទីរ ស-២១ បានទទួលរងនូវការប៉ះពាល់ដល់រូបរាងកាយ និងផ្លូវចិត្ត ដែលបណ្តាលមកពីអំពើអមនុស្សធម៌ ដែលពួកគេទទួលរង ក្នុងនោះរួមមាន ៖ ការមិនផ្តល់ឲ្យ ដោយចេតនានូវអាហារគ្រប់គ្រាន់ បរិក្ខារអនាម័យ និងការព្យាបាលជំងឺសមរម្យ។ ក្នុងពេលជាប់ឃុំឃាំង អ្នកទោសត្រូវបានវាយដំ និងប្រឈមមុខទៅនឹងការរឹតត្បឹតដ៏តឹងរឹង។ ភាពធ្ងន់ធ្ងរដែលទទួលរងជាលក្ខណៈរួម ឬបុគ្គល ធ្វើឲ្យអ្នកទោសខ្សោយកម្លាំងចិត្ត អស់តម្លៃ និងអស់លក្ខណៈជាមនុស្សជាតិ។ ទាំងនេះជាស្ថានភាពដែលធ្វើឲ្យពួកគេស្ថិតក្នុងការភ័យខ្លាចជានិច្ច[៤៨១]។

---

[៤៨០] ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា (ជនជាប់ចោទ) ទំព័រ១៨-៣២។ ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា (ជនជាប់ចោទ) ទំព័រ៤-៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧១។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៥៩-៦០។

[៤៨១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៤៣ ។

២៥៨. ជនជាប់ចោទបានយល់ស្របថា ស្ថានភាពរស់នៅដែលរួមបញ្ចូលទាំងការឃុំខ្លួន ការសួរចម្លើយ និងការបាត់ខ្លួនអ្នកជាប់ឃុំ បានធ្វើឲ្យចុះខ្សោយដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តអ្នកជាប់ឃុំ ហើយថា ពួកគេទាំងអស់នោះបានរស់នៅក្នុងស្ថានភាពភ័យខ្លាចជានិច្ច[៤៨២]។

២៥៩. អ្នកជាប់ឃុំទាំងអស់នៅមន្ទីរស២១ និង ស២៤ ត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយត្រូវបានគេដកហូតសិទ្ធិជាមូលដ្ឋានទាំងអស់។ ជនជាប់ចោទបានបញ្ជាក់ថា ដោយសារតែអ្នកទាំងនោះត្រូវបានគេកំណត់សម្លាប់ចោល ដូច្នេះមិនចាំបាច់ប្រព្រឹត្តអំពើមនុស្សធម៌ចំពោះអ្នកជាប់ឃុំទាំងនោះទេ[៤៨៣]។ អ្នកជំនាញ David CHANDLER បានលើកបន្ថែមទាក់ទងនឹងស្ថានភាពនៃអ្នកជាប់ឃុំ ដោយបញ្ជាក់ថា "អ្នកទាំងអស់នោះដែលដឹកតាមឡានគឺ[...]មិនមែនជាមនុស្សទេ។ ហើយវត្ថុបំណងនោះគឺដើម្បីធ្វើយ៉ាងណាទុកឲ្យពួកគេនៅក្នុងស្ថានភាពអាក្រក់ ហើយធ្វើឲ្យពួកគេបាក់ស្មារតី។ ហើយអ៊ីចឹងមែន គឺថាពួកគេត្រូវបានដឹកតាមឡាន ហើយយកមកដាក់ក្នុងស្ថានភាពហ្នឹង"[៤៨៤]។

### ២.៤.៥.១ លក្ខខណ្ឌនៃការឃុំខ្លួននៅក្នុងមន្ទីរស២១ (ទួលស្លែង)

២៦០. លើកលែងតែអ្នកជាប់ឃុំសំខាន់ៗមួយចំនួនប៉ុណ្ណោះ អ្នកជាប់ឃុំដែលចូលមកមន្ទីរស២១ (ទួលស្លែង) ត្រូវបានគេដោះសម្លៀកបំពាក់ចេញ និងដកហូតរបស់របរផ្សេងៗទៀត ដោយទុកតែខោក្នុង ឬ ខោខ្លី[៤៨៥]ប៉ុណ្ណោះ។ បន្ទាប់មកអ្នកជាប់ឃុំទាំងនោះត្រូវបានឃុំខ្លួននៅក្នុងបន្ទប់តូចៗដាច់

---

[៤៨២] "គោលជំហរបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ ១៦៩-១៧១។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨-៦៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៦។

[៤៨៣] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៥-៦៦។

[៤៨៤] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៣៣-៣៤, ៦៧-៦៨។

[៤៨៥] ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ១៩-២០។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ២៣-២៤។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ២៤, ៧៥-៧៦។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៣៥។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៦-

00573485



ដោយឡែក ឬនៅក្នុងបន្ទប់ឃុំខ្លួនរួមដែលមានចំនួនយ៉ាងហោចណាស់ ២០ ទៅ៣០ នាក់ ឬច្រើនជាងនេះ[៤៨៦]។ បន្ទប់ឃុំខ្លួនតូចៗដាច់ដោយឡែក គឺជាបន្ទប់តូចៗបណ្ដោះអាសន្នដែលមិនមានបង្អួច ឬពន្លឺគ្រប់គ្រាន់ឡើយ ដោយឡែកបន្ទប់ឃុំខ្លួនរួម គឺជាបន្ទប់ធំដែលមានបង្អួចដាក់របា។ អ្នកជាប់ឃុំត្រូវបានគេដាក់ច្រវាក់ និងដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនងដែកនៅក្នុងបន្ទប់ឃុំខ្លួន[៤៨៧]។ បន្ទប់ឃុំខ្លួនទាំងនោះមិនមានគ្រែ ពូក ឬមុងឡើយ។ គេតម្រូវឲ្យអ្នកជាប់ឃុំទាំងនោះដេកផ្ទាល់លើឥដ្ឋ និងត្រូវស្ថិតនៅក្រោមការឃាមកាមពីសំណាក់អ្នកយាមប្រដាប់ដោយអាវុធជាប់ជាប្រចាំ[៤៨៨]។

២៦១. ប្ដី ប្រពន្ធ និងសមាជិកគ្រួសារត្រូវបានគេបំបែកចេញពីគ្នា និងមិនត្រូវបានអនុញ្ញាតឲ្យទាក់ទងគ្នាឡើយ។ ស្ត្រីខ្លះដែលមានគភ៌ត្រូវបានឃុំក្នុងបន្ទប់ឃុំខ្លួនរួមគ្នា ប៉ុន្តែមិនត្រូវបានដាក់ច្រវាក់ ឬដាក់ខ្នោះជើងឡើយ។ កុមារក៏ត្រូវបានគេបំបែកចេញពីឪពុកម្ដាយ ឬសាច់ញាតិរបស់ពួកគេផងដែរ[៤៨៩]។

---

២៧។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៣៤។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩, (ជនជាប់ចោទ) ទំព័រ៣៤-៣៥។

[៤៨៦] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៣៨-៣៩។

[៤៨៧] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៥៨-៥៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៦-១៧។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៩-៣១។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ២៦-២៧។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៤-៣៥។

[៤៨៨] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៥-៦៧។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ខៀវ ចេស) ទំព័រ៥៧។

[៤៨៩] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣២-៣៤, ៤៩-៥០, ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៩។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥០-៥១, ៥៤-៥៥។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ ៧៨-៧៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៤០-៤១, ៦២-៦៣។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ១៨។

២៦២. អ្នកជាប់ឃុំនៅក្នុងបន្ទប់ឃុំខ្លួន ឬអ្នកធ្វើការនៅរោងជាងអាចឮសំឡេងស្រែក និងសំឡេងស្រែកយំចេញពីអគារឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង)[៤៥០]។

២៦៣. នៅពេលដែលអ្នកជាប់ឃុំត្រូវបានគេយកចេញពីបន្ទប់ឃុំខ្លួន គេបានដាក់ខ្នោះដៃ និងចងមុខអ្នកជាប់ឃុំជានិច្ច ដើម្បីឱ្យពួកគេភ័យខ្លាច និងមិនអាចចំណាំទីតាំងបាន[៤៥១]។ សាក្សី វ៉ាន់ ណាតបានរៀបរាប់អំពីភាពភ័យខ្លាចរបស់គាត់ នៅពេលគាត់បានឃើញអ្នកយាមក្មេងៗសែងអ្នកជាប់ឃុំម្នាក់ដែលមានរូបរាងស្គមកំព្រឹង ដោយចងដៃចងជើងស៊កទៅនឹងឈើសែងមួយ។ អ្នកជាប់ឃុំ នោះត្រូវបានគេចងមុខ ប៉ុន្តែគាត់នៅរស់និងអាចនិយាយបាន នៅពេលដែលគេបោះគាត់ទៅលើរថយន្ត ហើយដឹកយកចេញទៅ[៤៥២]។

២៦៤. អ្នកជាប់ឃុំបានឃើញ អ្នកជាប់ឃុំផ្សេងទៀតដែលត្រឡប់ពីកន្លែងសួរចម្លើយវិញ មានស្នាមវាយ ស្នាមរបួស ស្នាមជាំ និងស្នាមដាច់រលាត់។ អ្នកជាប់ឃុំខ្លះបានស្លាប់នៅក្នុងបន្ទប់ឃុំខ្លួនរបស់ខ្លួនដោយសារតែការវាយពេលសួរចម្លើយ ឬដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន ហើយសាកសពត្រូវបានទុកចោលនៅទីនោះយ៉ាងយូរ[៤៥៣]។ ក្នុងករណីជាច្រើន អ្នកជាប់ឃុំដែលត្រូវបានគេយកចេញពីបន្ទប់ឃុំ

---

[៤៥០] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៦៦-៦៧។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២៤-២៥, ៤៥, ៦៣-៦៤។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៦៤-៦៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ គយ តេង) ទំព័រ៤០-៤១។

[៤៥១] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២០-២១។ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ២២-២៣។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ២១។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៥។

[៤៥២] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៣៩ ។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៣៨-៣៩។

[៤៥៣] ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ ចេស) ទំព័រ៥៧។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ហាន អៀម) ទំព័រ៧៩-៨១។ ប្រតិចារឹកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣៤-៣៥។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៥-៣៦។ ប្រតិចារឹក ចុះថ្ងៃទី៣០

ខ្លួនរួមមិនដែលឃើញត្រឡប់មកវិញឡើយ។ ស្ថានភាពនៃការឃុំខ្លួនដែលត្រូវបានអនុវត្តទៅលើអ្នក-ជាប់ឃុំគឺទុកឲ្យពួកគេរស់នៅដោយគ្មានក្ដីសង្ឃឹមដែលជានិច្ចកាលស្ថិតក្នុងភាពភ័យខ្លាចគេយកចេញទៅ ភ័យខ្លាចគេវាយ ធ្វើទារុណកម្ម និងសម្លាប់[៥៥៥]។

២៦៥. ផលប៉ះពាល់ដែលបណ្ដាលមកពីស្ថានភាពនៃការឃុំខ្លួន បានធ្វើឲ្យអ្នកជាប់ឃុំខ្លះប៉ុនប៉ងធ្វើអត្តឃាត។ សាក្សី វ៉ាន់ ណាត បានរៀបរាប់អំពីហេតុការណ៍ដែលគាត់បានឃើញស្ត្រីជាអ្នកជាប់ឃុំ

---

ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៦៣។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣២-៣៣។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ម៉ក់ ស៊ីធីម) ទំព័រ៣១-៣៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៨-១៩។

[៥៥៥] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៣៦-៣៧, ៦៣-៦៤។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៦០-៦១។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៥១-៥២ ("តាមអារម្មណ៍ខ្ញុំបាទនៅពេលនោះ ខ្ញុំឆ្លងកាត់គុកបីនេះ គឺធ្វើដំណើរមកដល់ក្នុងបរិវេណស-២១ ពេលដែលគេថតរូបហ្នឹង ខ្ញុំបាទមានអារម្មណ៍ថាទីនេះ ជាកន្លែងគុកមន្ទីរឃុំឃាំងដែរ ប៉ុន្ដែ ហាក់ដូចជាជិតៗថ្នាក់ដឹកនាំកំពូលៗនៅទីនេះ។ សង្ឃឹមក្នុងចិត្តថា ប្រហែលជាមានយុត្តិធម៌ច្រើនណាស់ ហើយប្រសិនដូចជារូបខ្ញុំមិនបានធ្វើខុស មិនបានប្រព្រឹត្តអ្វីខុស បើសិនជាអង្គការរកទៅឃើញថាមិនមានកំហុសទេ ប្រហែលជាគេនឹងដោះលែងត្រឡប់ទៅផ្ទះវិញ។ នេះជាក្នុងចិត្តខ្ញុំបានគិតអ៊ីចឹង។ តែដល់ពេលក្រោយដែលខ្ញុំបានឡើងទៅដល់លើមន្ទីរឃុំឃាំងនៃអគារ "D" ជាន់ទីពីរបានពីរថ្ងៃ។ មួយនឹងពីរថ្ងៃ បានអ្វីដែលខ្ញុំបានសង្ឃឹមពីក្រោមទាំងប៉ុន្មាន គឺត្រូវរលាយអស់ ពីព្រោះតាមចរិតៗរបស់ឆ្មាំគុកក្មេងៗដែលធ្វើការនៅទីនោះ គឺធ្វើឲ្យយើងបាត់បង់ក្ដីសង្ឃឹមទាំងស្រុង តាំងពីពាក្យគេមើលងាយមើលថោក ប្រមាថ ដូចថា អ្នកទោសហ្នឹងវាក្រែណានឹងជម្រាបជូនកើត។ ឧទាហរណ៍ពេលខ្លះដែលយើងសម្រាកដេក គេដាស់គឺថា កំពុងតែដេកស្រួលៗ គេថា "អេ៎! ងើបៗជួនយើងងើបទាន់ បើថាងើបមិនទាន់ទេ អាស្បែកជើងកង់ឡានគេដើរឈ្លូសអ៊ីចឹងទៅ ហើយអ្នកណាងើបទាន់ស្មុះ ងើបទៅងើបមិនងើប ងើបមិនទាន់ត្រូវគេឈ្លូលក្បាលអ៊ីចឹងទៅ។ ដូច្នេះ ខ្ញុំឃើញសភាពការណ៍ហ្នឹង កើតឡើងចំពោះខ្ញុំរយៈពេលមួយថ្ងៃពីរថ្ងៃដែលទើបមកដល់ ខ្ញុំបាត់បង់ភាពសង្ឃឹមអស់រលីង នឹកឃើញថាខ្ញុំនៅគុកតំបន់ នៅគុកភូមិភាគ គឺខ្ញុំអត់បានទទួលរងអំពើដល់ថ្នាក់ហ្នឹងដែរ គឺខ្ញុំដេកតែបន្ទប់មួយបួននាក់ ឆ្មាំគុកនៅពីក្រៅ គេគ្រាន់តែប្រាប់ថាកុំឲ្យនិយាយគ្នាឡូឡាអីប៉ុណ្ណឹងៗ ប៉ុន្ដែមកដល់ទីនេះ ស-២១ នេះបានស្គាល់រស់ជាតិ ឃើញថាក្ដីសង្ឃឹមទាំងប៉ុន្មានដែលសង្ឃឹមថាមកជិតអង្គការមកជិតថ្នាក់ដឹកនាំគឺថា សូន្យ នៅពេលនុំងដែរ")។

ម្នាក់បានគេចចេញពីអ្នកយាម ហើយបានលោតសម្លាប់ខ្លួនពីលើអគារដែលជាទីកន្លែងសម្រាប់ឃុំខ្លួនគាត់[៤៥៥]។

២៦៦. អតីតអ្នកជាប់ឃុំ និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស២១ មាន សាក្សី វ៉ាន់ ណាត ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី និង ប៊ូ ម៉េង បានរៀបរាប់អំពីស្ថានភាពដ៏អាក្រក់ដែលអ្នកជាប់ឃុំទាំងអស់ទទួលរង និងអំពីរបៀបដែលគេប្រព្រឹត្តចំពោះអ្នកទាំងនោះដូចជា"សត្វ"[៤៥៦]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ដែលបានជាប់ឃុំនៅក្នុងបន្ទប់ឃុំខ្លួនដាច់ដោយឡែក បាននិយាយយ៉ាងដូច្នេះថា៖

> "ខ្ញុំបាទសូមជម្រាបប្រសាសន៍ព្រះរាជអាជ្ញា! គឺថាខ្ញុំចូលទៅដល់កន្លែងហ្នឹង ខ្ញុំនឹកក្នុងខ្លួនថា ខ្ញុំអត់មានរស់រានមានជីវិតដល់ថ្ងៃនេះទេ។ ពេលនោះខ្ញុំដេកចាំតែថ្ងៃស្លាប់ទេ។ ខ្ញុំតាំងពីណា ពីណីមក ខ្ញុំមិនដែលដេកខ្លួនទទេនៅលើឥដ្ឋអ៊ីចឹងទេ ហើយគេមិនដែលជះទឹក ឲ្យខ្ញុំអ៊ីចឹងដែរ។ បើសត្វជ្រូកទៅគេឲ្យបាយស៊ី តែចំពោះខ្ញុំគេឲ្យទឹកបបរមួយវែកៗ"[៤៥៧]។

---

[៤៥៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៨១-៨២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ៣៧-៣៨។ ជនជាប់ចោទ បានទទួលស្គាល់ថាបានដឹងពីស្ថានភាពទាំងនេះ ហើយជាពិសេសនៅក្នុងករណីអ្នកជាប់ឃុំសំខាន់ៗដូចជា កុយ ធួន ដែលគាត់បានដាក់នៅកន្លែងដែលអាចធានាថាអ្នកជាប់ឃុំមិនអាចធ្វើអត្តឃាតខ្លួនឯង មុនពេលចប់សព្វគ្រប់នៅការសួរចម្លើយ។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ 87-88។

[៤៥៦] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៦-១៧។ *សូមមើលផងដែរ* ទំព័រ៧២-៧៣ ("ជម្រាបលោកចៅក្រម! អានេះគ្រាន់តែជាការដែលយើង -- លោកមេធាវី (សូមទោស) នេះជាការដែលយើងប្រៀបធៀប។ ព្រោះមនុស្សបើយើងមានៗសិទ្ធិជាមនុស្សមាន ឋានៈជាមនុស្ស គេ យើងជាប់ទោសមែន ក៏យើងមានរបៀបផ្សេង ហើយបើសត្វ បើគេចិញ្ចឹមគេមានរបបហូបចុកត្រឹមត្រូវ ពេលបាយគេឲ្យបាយទៅ គេមិនដែលទៅវ៉ៃ ទៅទាត់ទៅធាក់ នឹកឃើញទាត់ព្រឹក ទាត់ល្ងាចទេ។ ដូច្នេះ យើងជាមនុស្សដែរ ប៉ុន្តែយើងជាប់នៅមួយកន្លែង ដែលយើងមិនអាចឃ្លាតចាកពីកន្លែងហ្នឹងបាន ហើយយើងទទួលរងទារុណកម្ម ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត នៅតែមួយកន្លែងហ្នឹងទាំងអស់គ្នាហ្នឹង។ បានខ្ញុំកំណត់ខ្លួនឯងថា បើសិនជាមនុស្ស ក៏ទៅមិនកើត បើទៅជាសត្វក៏មិនកើត មិនដឹងជាស្អី"។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៦០។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២៨-២៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៥។

[៤៥៧] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៥២-៥៣។

២៦៧. អ្នករស់រានមានជីវិតពីមន្ទីរស២១ ទាំងអស់បាននិយាយអំពីព្យសនកម្មលើរូបរាងកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដែលអ្នកជាប់ឃុំទាំងអស់បានទទួលរងក្នុងអំឡុងពេលជាប់ឃុំឃាំង និងអំពីផលប៉ះពាល់នៃព្យសនកម្មនេះដែលកើតមានពេញមួយជីវិតរបស់ពួកគាត់[៤៥៨]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់អំពីរបៀបដែលគាត់នៅតែទទួលរងការឈឺចាប់ ដោយសារតែការជាប់ឃុំ៖

> “ឲ្យតែនិយាយពីរឿងគុកទួលស្លែងឡើងគឺថា ខ្ញុំទឹកភ្នែកហូរមកឯង ឲ្យតែគេនិយាយរឿងគុកទួលស្លែងហ្នឹង ទឹកភ្នែកហូរមកឯង គឺអត់ដែលខានថ្ងៃណាទេ ឲ្យតែឮគេនិយាយរឿង ស-២១ រឿងគេធ្វើទារុណកម្មអីហ្នឹង វាមិនដឹងជារឿងរ៉ាវអី ខ្ញុំចេះតែហូរទឹកភ្នែកមកឯកឯងតែម្ដង ហើយអារម្មណ៍របស់ខ្ញុំហ្នឹង ខ្ញុំនឹកថាខ្ញុំទៅថ្ងៃមុខទៅ អារម្មណ៍របស់ខ្ញុំប្រហែលជា មិនមែនជាមនុស្សទេមិនដឹងបានជាទឹកភ្នែកហូរមកមិនចេះ[ចប់]មិនចេះហើយ ហើយខ្ញុំក៏ទៅសួរខាងអង្គការចិត្តសង្គម អន្តរវប្បធម៌ (“TPO”) គាត់តែងតែនិយាយប្រាប់ខ្ញុំថា “មកពីអីឯងមានការក្រេវក្រោធ ខឹងច្រើន អីច្រើន ក្នុងរបបខ្មែរក្រហមហ្នឹង”

---

[៤៥៨] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៤៣-៤៤ (“ស៖ យើងបានពិនិត្យឃើញថា លោកបាន [...] ត្រឡប់មកវិញមិនយូរប៉ុន្មានទេ ក្រោយពីចេញពីភ្នំពេញ គឺថាពេលដែលចូលមកវិញលោកបានចាប់ផ្ដើមគូរគំនូរ ហើយនិងបាន -- មានការថតភាពយន្តឯកសារ មានជាសរសេរសៀវភៅជាដើមហ្នឹង។ អ៊ីចឹង តើលោកអាចពន្យល់បានទេថា តើហេតុអ្វីបានជាលោកយល់ទុកថាជាសារសំខាន់ដែលលោកសុខចិត្តមកផ្ដល់សក្ខីកម្មបំភ្លឺតុលាការនៅពេលនេះ? ឆ៖ បាទ, ជម្រាបប្រសាសន៍លោកចៅក្រម! គឺថានេះជាការដែលខ្ញុំបាទគិតទុកចិញ្ចឹមចិត្តទុកមកតាំងពីខ្ញុំបាទនៅក្នុង ស២១ នៅឡើយ។ ខ្ញុំបាទតាំងចិត្តថា បើសិនជាថ្ងៃក្រោយ ថ្ងៃណាមួយក៏ដោយ ខ្ញុំបាទបានមានសេរីភាពរួចចាកចេញពីកន្លែងនេះ ខ្ញុំបាទនឹងចងក្រង នឹងលាតត្រដាងរឿងដើម្បីឲ្យកូនចៅជំនាន់ក្រោយ គឺមនុស្សជំនាន់ក្រោយបានយល់ បានដឹងអំពីទុក្ខវេទនារបស់មនុស្សជំនាន់ខ្ញុំនេះ [...]។ ដូច្នេះខ្ញុំត្រូវតែលាតត្រដាង ត្រូវតែសរសេរ ត្រូវតែចងក្រងទុកដើម្បីជាកញ្ចក់ឆ្លុះបញ្ចាំងទៅក្មេងឲ្យយល់ដឹងអំពីជីវិតមនុស្សដែលត្រូវគេចោទប្រកាន់ដោយអត់មានហេតុមានផល ដែលអត់បានប្រព្រឹត្តនូវបទល្មើសអ្វីដែលគួរឲ្យយើងជាប់ទោសដល់នោះ នោះ។ ដូច្នេះ វាជារឿងមួយឈឺចាប់បំផុត ហើយយើងនិយាយប្រាប់ពាក្យពិតទៅគេ គេមិនជឿយើងទេ មិនស្ដាប់យើង ដូច្នេះ គ្មានរឿងអ្វីពិបាកជាងរឿងហ្នឹងទៀតទេ។ ដូច្នេះ បានខ្ញុំបាទខំប្រឹងចងក្រង ខំប្រឹងសរសេរ ខំប្រឹងពន្យល់ក្មេងសព្វថ្ងៃខ្ញុំបាទត្រូវមានកម្មវិធីសម្រាប់ណែនាំសិស្សនិស្សិតដែលគាត់អញ្ជើញទៅ។ ប្រាប់គាត់ពីបទពិសោធន៍ដែលខ្ញុំបាទនៅស២១ នេះ ឲ្យក្មេងជំនាន់ក្រោយបានយល់ដឹង ហើយនិងវិភាគនិងពិចារណាដើម្បីជាមធ្យោបាយគេចវេសពីអ្វីដែលវាកើតឡើង ដែលយើងមិនចង់ឲ្យវាកើតជាលើកទីពីរតទៅទៀត។ បាទ សូមជម្រាបលោកចៅក្រម”)។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៤៨-៥០, ៥៦-៥៩, ៦៧-៦៩។

> គាត់ថា ឲ្យយើងរំសាយខ្លះទៅ ហើយខ្ញុំចេះតែ យកពាក្យសំដីគាត់ហ្នឹងទៅនេះទៅ[នោះ] ដូចជានៅតែដដែល ទេលោកក្តួយ វានៅតែទឹកភ្នែកហូរមករាល់តែយប់អីចឹង"[៤៩៩]។

### ២.៤.៥.២ ការមិនឲ្យអាហារហូបគ្រប់គ្រាន់

២៦៨. របបអាហារតិចតួចបំផុត ជាទូទៅគឺមានតែបបររាវៗ បាយលាយសម្លរ ឬសម្លរដើមចេកដែលត្រូវបានផ្តល់ពីរដងក្នុងមួយថ្ងៃ។ អ្នកយាមបានដួសអាហារពីចានធំមួយដាក់ក្នុងបោយទឹក ឬចានបាយ ហើយបញ្ជាឲ្យអ្នកជាប់ឃុំនៅក្នុងបន្ទប់ឃុំខ្លួនរួមយកទៅចែកគ្នា[៥០០]។ដោយសារតែហូបមិនឆ្អែតអ្នកជាប់-ឃុំបានស៊ីសត្វល្អិតដែលបានធ្លាក់នៅលើឥដ្ឋ ហើយប្រសិនបើអ្នកយាមឃើញពួកគេស៊ីសត្វល្អិតទាំងនោះ អ្នកយាមនឹងវាយពួកគេ[៥០១]។ សាក្សី វ៉ាន់ ណាត បានរៀបរាប់ថា នៅពេលដែលគាត់ឃ្លានខ្លាំងប្រសិនបើ "ដាក់សាច់មនុស្សឲ្យ ក៏ត្រូវតែហូបដែរ ឃ្លានណាស់ ព្រោះក្នុងខ្លួនអត់មានអីសោះ [...]"[៥០២]។

---

[៤៩៩] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៥៥-៥៧។

[៥០០] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៦, ២៣។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១១-១២, ១៧-១៨។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡូច មាន) ទំព័រ៥៩-៦០។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៨ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉េប ហូ) ទំព័រ៥៥-៥៧។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈន់ ផល) ទំព័រ២០, ៤៦-៤៧។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ហាម អៀម) ទំព័រ៧៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣៦-៣៧។

[៥០១] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៩-២០, ៥៥-៥៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៥២-៥៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១០-១១។

[៥០២] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៩-២០។

00573491



២៦៩. ដូច្នេះ អ្នកជាប់ឃុំស្រកទម្ងន់យ៉ាងច្រើន និងខ្សោយមែនទែន[៥០៣]។ ជនជាប់ចោទបានទទួលស្គាល់ថាការបង្អត់អាហារមិនឲ្យហូបគ្រប់គ្រាន់គឺជាចេតនាធ្វើឲ្យអ្នកជាប់ឃុំចុះខ្សោយកម្លាំង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងលើអ្នកជាប់ឃុំ ការពារមិនឲ្យមានចលាចល និងងាយស្រួលដល់ការទាញយកចម្លើយសារភាព[៥០៤]។

### ២.៤.៥.៣ ការខ្វះអនាម័យ

២៧០. អ្នកជាប់ឃុំមិនត្រូវបានគេអនុញ្ញាតឲ្យងូតទឹកតាមលក្ខណៈអនាម័យឡើយ។ អ្នកយាមបានបាញ់ទឹកនឹងទុយោពីបង្អួច ឬពីទ្វារបន្ទប់ឲ្យអ្នកជាប់ឃុំងូត។ ការបាញ់ទឹកឲ្យអ្នកជាប់ឃុំងូតមិនត្រូវបានធ្វើឡើងដោយទៀងទាត់នោះទេ ពោលគឺត្រូវបានធ្វើឡើងតែនៅពេលពួកអ្នកយាមត្រូវបាញ់ទឹកសម្អាតបន្ទប់ឃុំខ្លួនតែប៉ុណ្ណោះ។ អ្នកជាប់ឃុំត្រូវបានអនុញ្ញាតឲ្យក្រោកឈរ ប៉ុន្តែដោយសារតែជើងជាប់ខ្នោះ ពួកគាត់ពិបាកណាស់ក្នុងការដោះសម្លៀកបំពាក់ដែលទទឹកចេញពីខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង បានរម្លឹកថានៅពេលដែលអ្នកជាប់ឃុំស្រាតនននលគក អ្នកយាមបានសើចចំអក និយាយលេងសើចចំពោះរូបរាងកាយពួកគាត់[៥០៥]។

---

[៥០៣] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១១-១២។ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១០, ១៧។

[៥០៤] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៣-៦៤, ៦៩។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៥៧-៥៨។

[៥០៥] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៨-១៩, ២៤-២៥។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៩-២០, ៦០-៦១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០-៣១។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (ឈុន ផល) ទំព័រ២០-២២។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ ចេស) ទំព័រ៥៤។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦០-៦១។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៧។

២៧១. អ្នកជាប់ឃុំបុរសមានពុកមាត់ និងសក់វែង ហើយអ្នកជាប់ឃុំជាច្រើនបានឡើងស្នាមកន្ទួលរោលលើស្បែក ដោយសារតែដេកផ្ទាល់លើឥដ្ឋ។ មូស និងសត្វល្អិតដទៃទៀតបានខាំពួកគេជាប់ជាប្រចាំ[៥០៦]។

២៧២. អ្នកជាប់ឃុំត្រូវបានបង្ខំឱ្យនោមដាក់ប៊ីដុងទឹក[ធុងជ័រ] និងបន្ទោរបង់ដាក់កេះ[ឡាំង]គ្រាប់ ក្នុងបន្ទប់ឃុំខ្លួនរបស់ពួកគេ[៥០៧]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានចាត់ទុករឿងនេះថាជាបទពិសោធន៍មួយដ៏គួរឱ្យអាម៉ាស់បំផុត ដោយសារគាត់ត្រូវសុំកេះ[ឡាំង]គ្រាប់សម្រាប់បន្ទោរបង់ពីអ្នកយាម ហើយត្រូវបន្ទោរបង់នៅនឹងកន្លែងដេក និងកន្លែងហូបបាយ និងនៅចំពោះមុខអ្នកយាម និងអ្នកជាប់ឃុំដទៃទៀត[៥០៨]។

### ២.៤.៥.៤ ការខ្វះសេវាព្យាបាលផ្នែកវេជ្ជសាស្ត្រ

២៧៣. អ្នកជាប់ឃុំបានទទួលការព្យាបាលវេជ្ជសាស្ត្រតិចតួចបំផុត ឬមិនបានទទួលការព្យាបាលទាល់តែសោះ។ ស្នាមដាច់រលាត់ ស្នាមជាំ និងរបួសផ្សេងៗទៀត ក្រោយពីការធ្វើទារុណកម្ម ត្រូវបានព្យាបាលដោយប្រើទឹកអំបិល ដោយឱសថមិនគ្រប់គ្រាន់ ឬឱសថផ្សេងៗទៀតដែលផលិតក្នុងស្រុកមានចំនួនតិចតួច ឬមិនមានប្រសិទ្ធភាព។ ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួនដ៏អាក្រក់បែបនេះហើយ អ្នកជាប់ឃុំបានឡើងកន្ទួលរមាស់លើស្បែក មានជំងឺគ្រុនចាញ់ ជំងឺរាគរូស និងខ្សោះជាតិទឹកក្នុងខ្លួនធ្ងន់ធ្ងរ

---

[៥០៦] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ១៨-១៩។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៦, ៦០។

[៥០៧] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ១៦-១៧។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣២។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៦១។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉េប ហូ) ទំព័រ៤៩-៥០។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៦-៦៧។

[៥០៨] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២៨-២៩, ៥៨។

00573493



ដែលជាទូទៅត្រូវបានគេទុកចោលមិនថែទាំ ឬផ្តល់ការព្យាបាលតិចតួច[៥០៩]។ បន្ទាប់ពីអង្គភាពពេទ្យមន្ទីរស២១ ត្រូវបានបោសសម្អាត អ្នកជាប់ឃុំពុំបានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រឡើយ[៥១០]។

២៧៤. ជនជាប់ចោទបានបង្ហាញថា គោលបំណងតែមួយគត់នៃការផ្តល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ គឺដើម្បីទុកឲ្យអ្នកជាប់ឃុំនៅរស់សម្រាប់តែការសួរយកចម្លើយតែប៉ុណ្ណោះ[៥១១]។

### ២.៤.៥.៥ ការបូមឈាម និងការពិសោធន៍វេជ្ជសាស្ត្រ

២៧៥. អង្គជំនុំជម្រះបានកត់សម្គាល់អំពីការបូមឈាមដោយបង្ខំនៅមន្ទីរស២១ (ផ្នែក២.៤.១.៦) ។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកជាប់ឃុំស្ថិតនៅក្រោមការពិសោធន៍វេជ្ជសាស្ត្រដែលធ្វើឲ្យពួកគាត់ភិតភ័យយ៉ាងខ្លាំង ពីព្រោះពួកគាត់មិនដឹងអំពីលក្ខណៈនៃឱសថដែលត្រូវបានប្រើទៅលើពួកគាត់នោះទេ[៥១២]។ អង្គជំនុំជម្រះយល់ឃើញថា អំពើបែបនេះបានបង្កឲ្យអ្នកជាប់ឃុំទទួលរងការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ បន្ថែមទៅនឹងការឈឺចាប់ផ្លូវកាយដែលពួកគាត់បានទទួល។

### ២.៤.៥.៦ ការប្រព្រឹត្តចំពោះអ្នកជាប់ឃុំនៅជើងឯក និង ស២៤

២៧៦. អង្គជំនុំជម្រះបានកត់សម្គាល់ថា របៀបដែលអ្នកជាប់ឃុំនៅមន្ទីរស២១ ត្រូវបានគេដឹកទៅកាន់ជើងឯក និងទុកនៅទីនោះមុនពេលសម្លាប់ (ផ្នែក ២.៣.៣.៦) ពិតជាបានបណ្តាលឲ្យប៉ះទង្គិច

[៥០៩] ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ដន) ទំព័រ៨-៩, ១៤-១៥។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ក់ ស៊ីធីម) ទំព័រ៣៣។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ ៣៥-៣៦។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២២-២៣។

[៥១០] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧០។ ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (សេក ដន) ទំព័រ៥-៧។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ក់ ស៊ីធីម) ទំព័រ៣០។

[៥១១] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៩, ៦៩-៧០។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨។

[៥១២] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៣-៧៤ "តាមពិតជនជាប់ចោទយកថ្នាំប៉ារ៉ាសេតាម៉ុលមកប្រើជំនួសដោយសារគាត់ដឹងថាថ្នាំនោះមិនមានផលប៉ះពាល់ទេ" ។

ផ្លូវចិត្តពួកគាត់យ៉ាងធ្ងន់ធ្ងរ។អង្គជំនុំជម្រះកត់សម្គាល់ទៀតថា អ្នកជាប់ឃុំខ្លះទំនងជាដឹងអំពីមូលហេតុដែលពួកគាត់ត្រូវបានដឹកយកទៅជើងឯក[៥១៣]។

២៧៧. អង្គជំនុំជម្រះបានកត់សម្គាល់អំពីស្ថានភាពធ្វើការរបស់អ្នកជាប់ឃុំនៅ ស២១ (ផ្នែក ២.៣.៣.៧ និង ផ្នែក ២.៤.២.១) ។ អតីតអ្នកជាប់ឃុំនៅ ស២១ បានផ្តល់សក្ខីកម្មផងដែរអំពីការធ្វើបាប ដែលពួកគេបានទទួលរងនៅទីនោះ។ សាក្សី ប៊ូ មេង ត្រូវបានគេវាយរហូតដល់មានស្លាកស្នាមនៅលើមុខ និងមានអារម្មណ៍ថា "ដឹងគេទុកយើងស្មើហ្នឹងសត្វផង កាលនោះមិនដឹងថាជីវិតខ្ញុំហ្នឹងវាបើនិយាយរួម ថាចង់គេសម្លាប់ថ្ងៃណា បានថ្ងៃហ្នឹង ម៉្លោះហើយយើងនិយាយរួមថានៅថ្ងៃនោះដេកចាំតែថ្ងៃស្លាប់"[៥១៤]។ សាក្សី ផាច សៀក ត្រូវបានឃុំខ្លួននៅស២១ ក្នុងខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីមេរបស់គាត់ត្រូវបានគេចាប់ខ្លួន។ គាត់ត្រូវបានគេប្រាប់ថា ប្រសិនបើ "មេក្បត់ កូនចៅក៏ក្បត់ដែរ"[៥១៥]។ ប៉ុន្តែថា "បើកសាងបានល្អ គឺនៅរស់ បើមិនបានល្អទេ គឺស្លាប់"[៥១៦]។ គាត់បានដឹងយ៉ាងច្បាស់ថា កំហុសណាមួយក៏ដោយ ដូចជា ការហូបក្តាម ខ្យង អំពៅ ឬផ្លែឈើ នឹងទទួលទណ្ឌកម្មយ៉ាងព្រៃផ្សៃ។ នៅក្នុងពេលមួយនោះ គាត់បានសង្កេតឃើញមាននារីម្នាក់ដែលបានចេញពីការឃុំខ្លួននៅពេលយប់ដោយមានហើមមុខ ហើមមាត់ និងត្រូវបានគេនាំដើរបង្ហាញដល់អ្នកដទៃទៀតថាជាខ្មាំង។ សាក្សី ផាច សៀក ត្រូវបានចាត់តាំងឲ្យដុតសម្លៀកបំពាក់អ្នកទាំងឡាយណាដែលត្រូវបានគេនាំយកចេញទៅ ហើយមិនឃើញវិលត្រឡប់មកវិញ[៥១៧]។

២៧៨. អ្នកជាប់ឃុំផ្សេងទៀតមានភាពភ័យខ្លាច និងរូបរាងស្គមស្គាំងយ៉ាងខ្លាំង។ ទោះបីជាពួកគាត់បានច្រូតកាត់ប្រមូលផលស្រូវ និងពោតបានទិន្នផលយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ដោយ ក៏ពួកគាត់មិនត្រូវ

---

[៥១៣] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ៣៥-៣៧ និង ៦៤-៦៥ ។

[៥១៤] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ មេង) ទំព័រ២៩-៣០។

[៥១៥] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ៥១-៥២។

[៥១៦] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ៤៧-៤៨។

[៥១៧] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ផាច សៀក) ទំព័រ៤៩។

បានអនុញ្ញាតឲ្យហូបផលដំណាំដែលពួកគាត់ប្រមូលបានឡើយ[៥១៨]។ ម្ហូបអាហារមានដូចជា បាយបបររាវៗ ត្រូវបានគេចែកឲ្យពីរដងក្នុងមួយថ្ងៃ ប៉ុន្តែអ្នកទាំងឡាយណាដែលជាសមាសភាពអាក្រក់ទទួលបានរបបអាហារតិចជាងនេះ[៥១៩]។ ជនជាប់ចោទបានទទួលស្គាល់ថា ការវាយត្រូវបានគេអនុវត្តទៅលើអ្នកជាប់ឃុំដែលអាចត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំងផងដែរ ចំពោះការមិនគោរពតាមវិន័យ។ ការសួរចម្លើយ និងការធ្វើទារុណកម្មក៏បានកើតមានផងដែរនៅស២៤ ប៉ុន្តែមិនមានការអនុញ្ញាតផ្ទាល់ពីគាត់ឡើយ[៥២០]។ ជនជាប់ចោទបានកត់សម្គាល់ថា ការបង្អត់អាហារគឺជាគោលនយោបាយដោយចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយទទួលស្គាល់ថា គាត់បានប្រគល់ផលស្រូវ "ដែលលើស" ដែលដាំនៅស២៤ ទៅឲ្យគណៈកម្មាធិការមជ្ឈិម[៥២១]។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានប្រៀប-ធៀបម្ហូបអាហារ និងការថែទាំផ្នែកវេជ្ជសាស្ត្រនៅស២៤ ថាមានលក្ខណៈល្អប្រសើរជាងអ្វីដែលមានសម្រាប់អ្នកជាប់ឃុំនៅមន្ទីរស២១[៥២២]។

### ២.៤.៦ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

២៧៩. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

---

[៥១៨] ប្រតិចារិក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ធុន) ទំព័រ២៥, ៣០-៣១។ ប្រតិចារិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៤៩-៥០។

[៥១៩] "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ធុន" ឯកសារ E3/493 ERN (ភាសាខ្មែរ) 00163758-00163759។ "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយឯកសារ E5/11/6.1 កថាខណ្ឌ១៧៧។ ប្រតិចា-រឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៤។ ប្រតិចារិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ៤៩-៥១។

[៥២០] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ ២៣២-២៣៤។ ប្រតិចារិក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៧១-៧២។ ប្រតិចារិក ចុះថ្ងៃទី២៤ ខែមិថុនា (ជនជាប់ចោទ) ទំព័រ១៨-១៩, ២៩-៣០, ៣១-៣២។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦។ *សូមមើលផងដែរ* ផ្នែក (២.៣.៣.៧) ។

[៥២១] "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ ១៧៧-១៧៨។

[៥២២] ប្រតិចារិក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨។

> ១៤១. ការស៊ើបសួរបានបង្ហាញថា អ្នកទោសនៅមន្ទីរស២១ ត្រូវបានដកហូតនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ក្នុងនោះមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព សិទ្ធិមានសុវត្ថិភាពបុគ្គល សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសេរីភាពដើរហើរ។ សិទ្ធិជាមូលដ្ឋានទាំងនេះត្រូវបានដកហូត ឬបំពានចាប់តាំងពីពេលដែលពួកគេត្រូវបានចាប់ខ្លួន និងអំឡុងពេលជាប់ឃុំឃាំង រួមទាំងពេលសួរចម្លើយ ពេលកសាងខ្លួន ហើយរហូតដល់ពេលសម្លាប់។ អ្នកទោសត្រូវបានដកហូតនូវសិទ្ធិទាំងនេះដោយមូលហេតុទស្សនៈនយោបាយ ពិតប្រាកដ ឬតាមការសន្មតរបស់ពួកគេ ឬការប្រឆាំងទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ អ្នកទាំងនោះត្រូវបានឃុំឃាំងដោយបំពារបំពាន ត្រូវបានធ្វើឲ្យទៅជាទាសករ និងជាជនរងគ្រោះនៃអំពើទារុណកម្ម ការកាប់សម្លាប់ និងអំពើអមនុស្សធម៌ផ្សេងទៀត។
>
> ១៤២. **ឌុច** បានដឹងអំពីគោលនយោបាយរើសអើងទាំងនេះ ដែលមន្ទីរស២១បានអនុវត្ត ហើយចេតនារបស់គាត់នៅក្នុងការប្រព្រឹត្តិស្របតាមគោលនយោបាយនេះត្រូវបានបង្ហាញ តាមរយៈអំពើរបស់គាត់ មុខតំណែងដែលគាត់បានកាន់នៅក្នុងមន្ទីរនេះ ឋានៈរបស់គាត់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងរបស់គាត់ជាមួយថ្នាក់ដឹកនាំរបស់បក្ស[៥២៣]។

២៨០. សិទ្ធិជាមូលដ្ឋានដែលត្រូវបានដកហូតពីអ្នកជាប់ឃុំនៅមន្ទីរស២១ និងត្រូវបានចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ រួមមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ អង្គជំនុំជម្រះក៏បានពិពណ៌នាអំពីប្រភេទនៃបទល្មើសនានាដែលបានប្រព្រឹត្តនៅមន្ទីរស២១នៅក្នុងផ្នែកខាងលើផងដែរ និងធ្វើការកំណត់ថាតើអំពើទាំងអស់នោះនឹងបង្កើតបានជាបទល្មើសការធ្វើទុក្ខបុកម្នេញដែរ ឬទេ នៅក្នុងផ្នែក (២.៥.៣.១៤)។

---

[៥២៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៤១-១៤២ ។

## ២.៥ ច្បាប់ជាធរមាន និងសំអាងហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

២៨១. អង្គជំនុំជម្រះមានយុត្តាធិការលើរឿងក្តី ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក[៥២៤]។ មាត្រា៥ នៃច្បាប់ អ.វ.ត.ក បានចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។
>
> ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលជាឧក្រិដ្ឋកម្មគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា៖
>
> -ការធ្វើមនុស្សឃាត
> -ការសម្លាប់រង្គាល
> -ការធ្វើឱ្យទៅជាទាសករ
> - ការនិរទេស
> -ការដាក់ក្នុងមន្ទីរឃុំឃាំង
> -ការធ្វើទារុណកម្ម
> -ការរំលោភលើផ្លូវភេទ
> -ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
> -អំពើអមនុស្សធម៌ផ្សេងៗទៀត។

---

[៥២៤] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២.២ [*កត់សម្គាល់ - ខណៈពេលមាត្រា៩ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមាន [...] ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ១៩៩៨" មាត្រា៥ នៃច្បាប់ អ.វ.ត.ក បានអនុម័តយកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលខុសគ្នាពីនិយមន័យនៃលក្ខន្តិកៈទីក្រុងរ៉ូម។ ដោយពិចារណាថា ច្បាប់ អ.វ.ត.ក អនុម័តក្រោយគេ និងដោយសារមាត្រា២.២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក បង្ហាញថា កិច្ចព្រមព្រៀងត្រូវតែអនុម័តតាមច្បាប់ អ.វ.ត.ក ដូចដែលបានអនុម័តនិងវិសោធនកម្ម និយមន័យនៅក្នុងច្បាប់ អ.វ.ត.ក ត្រូវតែយកមកប្រើប្រាស់។ មានការស្នើសុំថា ការបកស្រាយផ្សេងពីនេះនឹងបង្កើតឱ្យមាននូវបញ្ហាជាច្រើន។*]

២៨២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅ៖ (i) ការធ្វើមនុស្សឃាត (ii) ការសម្លាប់រង្គាល (iii) ការធ្វើឱ្យទៅជាទាសករ (iv) ការដាក់ក្នុងមន្ទីរឃុំឃាំង (v) ការធ្វើទារុណកម្ម (vi) ការរំលោភលើផ្លូវភេទ (vii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[៥២៥] និង (vii) អំពើអមនុស្សធម៌ផ្សេងៗទៀត[៥២៦]។

២៨៣. ជាបញ្ហាបឋម និងអនុលោមតាមគោលការណ៍នីត្យានុកូលភាពដែលបានពិភាក្សានៅក្នុង (ផ្នែក ១.៥) អង្គជំនុំជម្រះត្រូវបង្ហាញថា ឧក្រិដ្ឋកម្មទាំងនេះជាឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

២៨៤. ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាមិនមានចែងនូវបទប្បញ្ញត្តិណាមួយ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ហើយប្រទេសកម្ពុជាក៏មិនមែនជាសមាជិកនៃសន្ធិសញ្ញាណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មនេះដែរក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវការកំណត់ថាតើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ឬទេ ក្នុងអំឡុងពេលខាងលើ ។

២៨៥. សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាទស្សនាទានឯករាជ្យរបស់តុលាការនិងការចាប់បង្ខំឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនេះ ត្រូវបានទទួលស្គាល់ជាដំបូង នៅក្នុងមាត្រា៦(គ)នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗ។ ធម្មនុញ្ញនេះបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងឡុង ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥ ("ធម្មនុញ្ញ Nuremberg" និង "តុលាការ Nuremberg"[៥២៧] ដែលបានផ្តល់ឱ្យតុលាការ

---

[៥២៥] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទចំពោះការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយតែប៉ុណ្ណោះ ដែលចង្អៀតជាងបទល្មើសការធ្វើទុក្ខបុកម្នេញ ដូចមានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក។

[៥២៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ទំព័រ៧២-៧៣ ។

[៥២៧] កិច្ចព្រមព្រៀងសម្រាប់ការកាត់សេចក្តី និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋជនសង្គ្រាមធំៗរបស់ក្រុមអឺរ៉ុប និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥ (៨២ UNTS ២៧៩)។ មាត្រា៦ (គ) នៃធម្មនុញ្ញNuremberg បានចែងថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជា "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ

Nuremberg នូវយុត្តាធិការលើឧក្រិដ្ឋកម្មនេះ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបញ្ចូលទៅក្នុងប្រភេទឧក្រិដ្ឋកម្មមួយដោយឡែកនៅក្នុងធម្មនុញ្ញ Nuremberg ដើម្បីកុំឱ្យអំពើរបស់ចារីប្រឆាំងនឹងប្រជាជាតិខ្លួនឯងអាចគេចផុតពីការចោទប្រកាន់ដោយតុលាការ Nuremberg ទោះបីជាចារីប្រឆាំងនឹងប្រជាជាតិខ្លួនឯងមិនអាចនឹងត្រូវបានចោទប្រកាន់បាន បើអនុលោមតាមទម្រង់ទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ[៥២៨]។

២៨៦. យុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏មានចែងនៅក្នុងមាត្រា៥(គ) នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ("ធម្មនុញ្ញតូក្យូ")[៥២៩] និងនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអាល្លឺម៉ង់ ("ច្បាប់លេខ១០របស់ក្រុម

---

ការនិរទេស ឬអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយពីមុន ឬក្នុងអំឡុងពេលសង្គ្រាម [,] ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនានៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាអំពើទាំងនេះរំលោភបំពានឬមិនរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក៏ដោយ"។ *សូមមើលផងដែរ* ពិធីសារដែលកែតម្រូវភាពមិនស៊ីសង្វាក់គ្នានូវអត្ថបទរបស់ធម្មនុញ្ញខាងលើ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៤៥ ដែលបោះពុម្ពនៅក្នុង *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗចំពោះមុខតុលាការយោធាអន្តរជាតិ៖ Nuremberg ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៤៥ ដល់ ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦* ភាគទី១ (១៩៤៧) ទំព័រ១៧-១៨ ។

[៥២៨] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់និងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-94-1-T) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦១៨-៦១៩។

[៥២៩] ឧបសម្ព័ន្ធទៅនឹងសេចក្តីប្រកាសពិសេសចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ដោយមេបញ្ជាការជាន់ខ្ពស់របស់ប្រទេសមហាអំណាចសម្ព័ន្ធភាពនៅចុងបូព៌ា។ មាត្រា៥(គ) នៃធម្មនុញ្ញតូក្យូ រៀបរាប់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជា "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ពីមុនឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬពូជសាសន៍ នៅក្នុងការអនុវត្ត ឬការជាប់ទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្តីក៏ដោយ។

ប្រឹក្សាគ្រប់គ្រង")[៥៣០] ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការចោទប្រកាន់បន្ថែមចំពោះអំពើព្រៃផ្សៃ ដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ។

២៨៧. ការហាមឃាត់នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបញ្ជាក់ទទួលស្គាល់ជាបន្តបន្ទាប់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ[៥៣១] និងដោយគោលការណ៍នៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការ Nuremberg និងនៅក្នុងសេចក្តីសម្រេចរបស់តុលាការ ("គោលការណ៍ Nuremberg") ដែលបានអនុម័តដោយគណៈកម្មាធិការច្បាប់អន្តរជាតិឆ្នាំ១៩៥០ និងត្រូវបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ[៥៣២]។ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសបន្ថែមអំពីតម្រូវការសម្រាប់សហប្រតិបត្តិការអន្តរជាតិនៅក្នុងការស៊ើបអង្កេត ការចាប់ខ្លួន ការធ្វើបត្យាប័ន និងការផ្តន្ទាទោសចំពោះបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៥៣៣]។

២៨៨. ក្រោយពីសម័យតុលាការ Nuremberg ការចងក្រងច្បាប់អន្តរជាតិទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ដែលជាបទល្មើសពីរក្នុងចំណោមបទល្មើសដែល

---

[៥៣០] ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៤៥) បានបោះពុម្ពនៅក្នុង *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង* ភាគ I ទំព័រXVI-XIX។ មាត្រា II នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង បានរៀបរាប់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជា "អំពើឃោរឃៅ និងជាឧក្រិដ្ឋកម្ម ដែលរួមមានអំពើជាច្រើនដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ទោះបីជាអំពើទាំងនេះរំលោភបំពាន ឬមិនរំលោភបំពានច្បាប់ជាតិនៃប្រទេសដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក៏ដោយ"។

[៥៣១] ការបញ្ជាក់អះអាងអំពីគោលការណ៍នៃច្បាប់អន្តរជាតិ ទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nuremberg, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៩៥(I) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦។

[៥៣២] របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិលើគោលការណ៍ Nuremberg, 5 UN GAOR, ឯកសារបន្ថែមលេខ១២ ឯកសារអង្គការសហប្រជាជាតិលេខ A/១៣១៦ (១៩៥០)។

[៥៣៣] គោលការណ៍នៃសហប្រតិបត្តិការអន្តរជាតិនៅក្នុងការស៊ើបអង្កេត ការចាប់ខ្លួន ការធ្វើបត្យាប័ន និងការផ្តន្ទាទោសចំពោះបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៣០៧៤ (XXVIII) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៧៣។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ២៧១២ (XXV) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧០។

មានលក្ខណៈធ្ងន់ធ្ងរបំផុតរបស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានបញ្ជាក់អំពីលក្ខណៈទំនៀមទម្លាប់ដែលហាមឃាត់មិនឲ្យមាននូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៥៣៤]។ ការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ត្រូវបានបន្តអនុវត្តជាច្រើនទសវត្សរ៍ក្នុងបណ្តាប្រទេសជាច្រើនបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ[៥៣៥]។

២៨៩. ថ្មីៗនេះយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានចែងនៅក្នុងលក្ខន្តិកៈនៃតុលាការ ICTY[៥៣៦] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (“តុលាការ ICTR”)[៥៣៧] តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (“តុលាការ SCSL”)[៥៣៨] និង តុលាការ ICC[៥៣៩]។

---

[៥៣៤] អនុសញ្ញាស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨, ៧៨ UNTS ២៧៧ មាត្រា១។ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៣, 1015 UNTS 243 មាត្រា I។

[៥៣៥] *សូមមើលឧទាហរណ៍ រឿងក្តី អគ្គរដ្ឋអាជ្ញារបស់រដ្ឋាភិបាលអ៊ីស្រាអែល តទល់នឹង Adolph Eichmann* (១៩៦២) ៣៦ ILR ២៧៧។

[៥៣៦] មាត្រា៥ នៃលក្ខន្តិកៈតុលាការ ICTY (“[តុលាការ ICTY] ត្រូវមានអំណាចដើម្បីកាត់សេចក្តីលើបុគ្គលនានាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម នៅពេលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធ ទោះបីជាមានចរិតលក្ខណៈជាអន្តរជាតិ ឬជាជម្លោះផ្ទៃក្នុង និងសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ៖ (ក) ការធ្វើមនុស្សឃាត (ខ) ការសម្លាប់រង្គាល (គ) ការធ្វើឲ្យទៅជាទាសករ (ឃ) ការដាក់ក្នុងមន្ទីរឃុំឃាំង (ង) ការធ្វើទារុណកម្ម (ច) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា (ឆ) អំពើអមនុស្សធម៌ផ្សេងទៀត”)។

[៥៣៧] មាត្រា៣នៃលក្ខន្តិកៈរបស់តុលាការ ICTR (“[តុលាការ ICTR] ត្រូវមានអំណាចដើម្បីកាត់សេចក្តីលើបុគ្គលនានាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម នៅពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តជាផ្នែកនៃការវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ៖ (ក) ការធ្វើមនុស្សឃាត (ខ) ការសម្លាប់រង្គាល (គ) ការធ្វើឲ្យទៅជាទាសករ (ឃ) ការនិរទេស (ង) ការដាក់ក្នុងមន្ទីរឃុំឃាំង (ច) ការធ្វើទារុណកម្ម (ឆ) ការរំលោភលើផ្លូវភេទ (ជ) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា (ឈ) អំពើអមនុស្សធម៌ផ្សេងទៀត”)។

[៥៣៨] មាត្រា២នៃលក្ខន្តិកៈ SCSL (“[តុលាការ SCSL] មានអំណាចដើម្បីកាត់សេចក្តីលើបុគ្គលនានាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោម ដែលជាផ្នែកនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ៖ (ក) ការធ្វើមនុស្សឃាត (ខ) ការសម្លាប់រង្គាល (គ) ការធ្វើឲ្យទៅជាទាសករ (ឃ) ការនិរទេស (ង) ការដាក់ក្នុងមន្ទីរឃុំឃាំង (ច) ការធ្វើទារុណកម្ម (ឆ) អំពើរំលោភលើផ្លូវភេទ ទាសករផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយបង្ខំ

តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនេះ បានបញ្ជាក់ឡើងវិញនូវការបន្តលក្ខណៈទំនៀមទម្លាប់នូវឧក្រិដ្ឋ-កម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់អន្តរជាតិ[៥៤០]។ ដូចបានលើកឡើងដោយអង្គជំនុំជម្រះសាលា-ដំបូង ICTY នៅក្នុងសាលក្រមរឿងក្តី *Tadic* "ចាប់តាំងពីពេលមានធម្មនុញ្ញNuremberg លក្ខណៈទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការកំណត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះការប្រព្រឹត្តិរបស់ពួកគេ លែងជាបញ្ហាធ្ងន់ធ្ងរទៀតហើយ"[៥៤១]។

២៩០. នៅពេលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្លាយជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីពេលមានធម្មនុញ្ញ Nuremberg ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានគេឲ្យនិយមន័យផ្សេងៗគ្នា ហើយធាតុផ្សំរបស់ឧក្រិដ្ឋកម្មនេះក៏ត្រូវបានធ្វើឲ្យកាន់តែច្បាស់លាស់ជាបន្តបន្ទាប់ជាច្រើនឆ្នាំមកហើយ។ ករណីនេះ ផ្ទុះបញ្ជាំងឲ្យឃើញទាំងការវិវត្តលក្ខណៈទំនៀមទម្លាប់របស់ឧក្រិដ្ឋកម្ម និងហេតុដែលយុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្ម មិនមែនសុទ្ធតែត្រូវបានកំណត់ដូចគ្នាដោយវិសាលភាពពេញលេញដែលអនុញ្ញាតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[៥៤២]។ គោលការណ៍

---

ការមានគភ៌ដោយបង្ខំ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទ (ជ) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា (ឈ) អំពើអមនុស្សធម៌ផ្សេងទៀត")។

[៥៣៩] មាត្រា៧ នៃលក្ខន្តិកៈតុលាការ ICC ("សម្រាប់គោលបំណងនៃលក្ខន្តិកៈនេះ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" មានន័យថាជាអំពើណាមួយដូចខាងក្រោម ដែលបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលណាមួយ ដោយមានការដឹងពីការវាយប្រហារនោះ [...]")។

[៥៤០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់ និងសាលក្រម អង្គជំនុំជម្រះសាលាដំបូង (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦២៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-96-4-A) ថ្ងៃទី០១ ខែ មិថុនា ឆ្នាំ២០០១ កថាខណ្ឌ៤៦៥-៤៦៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៥៧-៥៩។ *សូមមើលផងដែរ* មាត្រា៧ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) សេចក្តីផ្តើមនៃ "ធាតុផ្សំបទល្មើស" របស់ ICC (ICC-ASP/1/3 (ផ្នែកII-B) ចូលជាធរមានថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២) កថាខណ្ឌ១។

[៥៤១] *រឿងក្តី រដ្ឋអាជ្ញា តទល់ Tadić* មតិយោបល់និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦២៣។

[៥៤២] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTR (ICTR-96-4-A) ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០១ កថាខណ្ឌ៤៦៥ (កត់សម្គាល់ថា លក្ខខណ្ឌជាមូលដ្ឋាននៃការ

នីត្យានុកូលភាពមិនបានហាមឃាត់អង្គជំនុំជម្រះ ក្នុងការយោងទៅលើច្បាប់ទំនៀមទម្លាប់ដែលពុំមានសរសេរជាលាយលក្ខណ៍អក្សរ ឬការសម្រេចណាមួយធ្វើឡើងតាមរយៈដំណើរការនៃការបកស្រាយ និងការស្រាយបំភ្លឺចំពោះធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយនោះទេ។ ទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដូចគ្នានឹងទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលនឹងរៀបរាប់លម្អិតខាងក្រោមនេះ។

២៩១. ជាពិសេស អង្គជំនុំជម្រះកត់សម្គាល់ថាមាត្រា៥ នៃច្បាប់ អ.វ.ត.ក មិនតម្រូវឲ្យមាននូវទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នឹងជម្លោះប្រដាប់អាវុធនោះទេ។ ទោះបីជាមាត្រា៦(គ) នៃធម្មនុញ្ញ Nuremberg តម្រូវឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងជម្លោះប្រដាប់អាវុធក៏ដោយ[៥៤៣] ក៏ទំនាក់ទំនងបែបនេះ មិនមានរួមបញ្ចូលក្នុងច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង[៥៤៤] អនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការទប់ស្កាត់និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្ម

---

រើសអើងនៅក្នុងមាត្រា៣ នៃលក្ខន្តិកៈតុលាការ ICTR និងលក្ខខណ្ឌជម្លោះប្រដាប់អាវុធនៅក្នុងមាត្រា៥ នៃលក្ខន្តិកៈតុលាការ ICTY គឺជាប្រភេទយុត្តាធិការ និងមិនមែនជាផ្នែកនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ)។

[៥៤៣] *សូមមើល* កិច្ចព្រមព្រៀងសម្រាប់ការកាត់សេចក្តី និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាមធំៗនៅសម្ព័ន្ធមិត្តអឺរ៉ុប (European Axis) និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ថ្ងៃទី០៨ ខែ សីហា ឆ្នាំ១៩៤៥ ៨២ UNTS ២៧៩ មាត្រា៦(គ) (ចែងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវតែអនុវត្ត "ដោយប្រតិបត្តិតាម ឬជាប់ទាក់ទងជាមួយ [ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព]")។

[៥៤៤] *សូមមើល រឿងក្តី Ohlendorf និងរឿងក្តីផ្សេងទៀត ("រឿងក្តី Einsatzgruppen")* សេចក្តីសម្រេចចុះថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ១៩៤៨ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង* ភាគ IV ទំព័រ៤៩៩ (យល់ឃើញថា ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនត្រូវបានកម្រិតត្រឹមតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ឬជាប់ទាក់ទងនឹងសង្គ្រាមនោះទេ)។ *ប៉ុន្តែសូមមើលផងដែរ រឿងក្តី Flick និងអ្នកផ្សេងទៀត* សេចក្តីសម្រេចចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៤៧ *ការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមចំពោះមុខតុលាការយោធាNuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង* ភាគទី VI ទំព័រ១២១២-១២១៤។

ប្រល័យពូជសាសន៍[៥៤៥] សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិឆ្នាំ១៩៥៤[៥៤៦] អនុសញ្ញាឆ្នាំ១៩៦៨ ស្ដីពីការមិនអនុវត្តច្បាប់អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៥៤៧] និងអនុសញ្ញាអន្តរជាតិឆ្នាំ១៩៧៣ ស្ដីពីការបង្ក្រាបនិងការផ្ដន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍[៥៤៨]។ ទស្សនាទាន "ជម្លោះប្រដាប់អាវុធ" មិនមែនជាផ្នែកនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនាពេលបច្ចុប្បន្ននេះទេ[៥៤៩]។

២៩២. តុលាការអន្តរជាតិនានា ដែលបានពិចារណាជាបន្តបន្ទាប់អំពីបញ្ហានេះ ក៏បានយល់ឃើញផងដែរថា សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែកពីសញ្ញាណនៃជម្លោះប្រដាប់អាវុធក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូល ICTY បានលើកឡើងថា លក្ខខណ្ឌជម្លោះប្រដាប់អាវុធនៅក្នុងមាត្រា ៦ (គ) នៃធម្មនុញ្ញ Nuremberg គឺជាបញ្ហាយុត្តាធិការប៉ុណ្ណោះ ហេតុដូច្នេះមានន័យថា ជម្លោះប្រដាប់អាវុធមិនតម្រូវឲ្យមានក្រោមច្បាប់ទំនៀម

---

[៥៤៥] អនុសញ្ញាស្ដីពីការទប់ស្កាត់ និងការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨ ៧៨ UNTS ២៧៧, មាត្រា១។

[៥៤៦] ឯកសារអង្គការសហប្រជាជាតិ A/២៦៩៣ (១៩៥៤)។ *សូមមើលផងដែរ* សំណៅឆ្នាំ១៩៩១ និងឆ្នាំ១៩៩៦នៃសេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងនិងសន្តិភាពនិងសន្តិសុខមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ (ឯកសារអង្គការសហប្រជាជាតិ A/46/10 (១៩៩១) និង A/51/10 (១៩៩៦)) ដែលមិនមាននូវចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធ។

[៥៤៧] អនុសញ្ញាស្ដីពីការមិនអនុវត្តច្បាប់អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ២៣៩១ (XXVIII) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ឧបសម្ព័ន្ធ មាត្រា I (ខ) (ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ទោះបីជាត្រូវបានប្រព្រឹត្តនៅក្នុងពេលសង្គ្រាម ឬនៅក្នុងពេលសន្តិភាព")។

[៥៤៨] អនុសញ្ញាអន្តរជាតិស្ដីពីការបង្ក្រាប និងការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ១០១៥ UNTS ២៤៣ មាត្រា I។

[៥៤៩] *សូមមើល រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ២៤៩ ។ *សូមមើល* លក្ខន្តិកៈរបស់តុលាការ ICTR តុលាការ SCSL និងតុលាការ ICC ដែលតុលាការទាំងនេះមិនភ្ជាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅនឹងជម្លោះប្រដាប់អាវុធទេ។

ទម្លាប់អន្តរជាតិ សូម្បីតែនៅឆ្នាំ១៩៤៥ ក៏ដោយ[៥៥០]។ សភាពេញអង្គរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបកត់សម្គាល់ឃើញថា តាំងពីដំបូងនៃទំនៀមទម្លាប់អន្តរជាតិ ទំនាក់ទំនងជម្លោះប្រដាប់អាវុធជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តែទំនាក់ទំនងនេះលែងជាលក្ខខណ្ឌតម្រូវទៀតហើយចាប់ពីឆ្នាំ១៩៥៦ មក[៥៥១]។ ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានតែងតាំងតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥២/១៣៥ បានសន្និដ្ឋានស្រដៀងគ្នាថា "ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងជម្លោះប្រដាប់អាវុធ ហាក់ដូចជាមានភាពធូរធូរត្រឹមតែឆ្នាំ១៩៧៥ ប៉ុណ្ណោះ"[៥៥២]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នត្ថិភាពទំនាក់ទំនងជម្លោះប្រដាប់អាវុធក្នុងមាត្រា៥នៃច្បាប់ អ.វ.ត.ក ស្របគ្នានឹងនិយមន័យទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

២៩៣. លើសពីនេះ បទល្មើសជាក់លាក់មួយចំនួនដែលបានចោទប្រកាន់ជនជាប់ចោទ អនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានគេទទួលស្គាល់ចាប់តាំងពីសម័យតុលាការ Nuremberg ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយត្រូវផ្តន្ទាទោសផងដែរ នៅពេលដែលលក្ខខណ្ឌទូទៅ នៃឧក្រិដ្ឋកម្មនេះត្រូវបានបំពេញ។ បទល្មើសការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានរួមបញ្ចូលយ៉ាងច្បាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា៦(គ) នៃធម្មនុញ្ញ Nuremberg មាត្រា ៥(គ) នៃធម្មនុញ្ញតូក្យូ និងមាត្រា II នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង។ បទល្មើសការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ ត្រូវបានរួមបញ្ចូលយ៉ាងច្បាស់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា II នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង និងត្រូវ

---

[៥៥០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកាលើបណ្តឹងរបស់មេធាវីការពារក្តីស្នើសុំប្តឹងឧទ្ធរណ៍បន្ទាន់បង្អំលើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ១៤០ ។

[៥៥១] *រឿងក្តី Korbely តទល់នឹង ប្រទេសហុងគ្រី* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះជាន់ខ្ពស់តុលាការ ECtHR (no. 9174/02) ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ៨២ ។

[៥៥២] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥២/១៣៥ (ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ A/53/850- S/1999/231) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ៧១ ។

បានដាក់បញ្ចូលជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងមាត្រា៦(គ) នៃធម្មនុញ្ញ Nuremberg និង មាត្រា៥(គ) នៃធម្មនុញ្ញតូក្យូ។ លក្ខន្តិកៈរបស់តុលាការ ICTY តុលាការ ICTR តុលាការ SCSL និង តុលាការ ICC រួមបញ្ចូលនូវបទល្មើសជាក់លាក់ទាំងនេះថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

២៩៤. ហេតុដូច្នេះ គេអាចប្រមើលឃើញថាក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជនជាប់ចោទ អាចត្រូវបានបង្ខំឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ អនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក។ ច្បាប់ដែលចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទមានលក្ខណៈគ្រប់គ្រាន់ បើពិចារណាលើមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

២៩៥. លើសពីនេះ លក្ខណៈឃោរឃៅនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ជនជាប់ចោទអនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក អាចបដិសេធចំពោះការអះអាងរបស់ជនជាប់ចោទដែលថា ខ្លួនមិនបានដឹងអំពីលក្ខណៈឧក្រិដ្ឋនៃអំពើទាំងនោះ[៥៩៣]។

២៩៦. អង្គជំនុំជម្រះយល់ឃើញថា រាល់បទឧក្រិដ្ឋដែលបានចោទប្រកាន់ជនជាប់ចោទ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ អនុលោមតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ។

### ២.៥.១. លក្ខខណ្ឌទូទៅសម្រាប់មាត្រា៥ នៃច្បាប់ អ.វ.ត.ក

២៩៧. បទល្មើសមួយចំនួនដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក អាចចាត់ទុកថាជាបទល្មើសប្រឆាំងនឹងមនុស្សជាតិបាន ប្រសិនបើធាតុផ្សំទូទៅដែលតម្រូវឲ្យមានជាមុនត្រូវបានបង្កើតឡើងដើម្បីបំពេញតាមនិយាមដែលតម្រូវឲ្យមាន៖ (i) ត្រូវតែមានការវាយប្រហារ (ii) ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ (iii) ការវាយប្រហារសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល

[៥៩៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* សាលដីកាលើសំណើសុំរបស់ Dragolijub Odjanovic ប្រឆាំងនឹងយុត្តាធិការ - សហឧក្រិដ្ឋកម្មរួមរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៤២ (កត់សម្គាល់ថា ចរិតអសីលធម៌ ឬចរិតអាក្រក់នៃអំពើមួយ អាចដើរតួនាទីក្នុងការបដិសេធលើការលើកឡើងណាមួយដែលថា ចារីមិនបានដឹងអំពីចរិតលក្ខណៈព្រហ្មទណ្ឌនៃអំពើនេះ)។

(iv) ការវាយប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា (v) ត្រូវតែមានទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងការវាយប្រហារ និង (vi) ជនជាប់ចោទត្រូវមានការដឹងជាចាំបាច់[៥៥៤]។

២.៥.១.១ ការវាយប្រហារ

២៩៨. ការវាយប្រហារគឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើន[៥៥៥]។ អំពើទាំងឡាយ ដែលបង្កើតបានជាការវាយប្រហារ មិនចាំបាច់ត្រូវយកអំពើនោះមកផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ផ្ទុយទៅវិញ អំពើទាំងនោះ ជាទូទៅ គឺជាប្រភេទនៃការប្រព្រឹត្តិមិនត្រឹមត្រូវ ដូចមានចែងជាបទល្មើសនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក។ ជនជាប់ចោទមិនចាំបាច់ប្រព្រឹត្តអំពើហិង្សាទាំងអស់ ដែលបង្កើតបានជាការវាយប្រហារនោះទេ(អំពើរបស់ជនជាប់ចោទគ្រាន់តែជាផ្នែកនៃការវាយប្រហារទូទៅប៉ុណ្ណោះក៏បានដែរ)។ នៅក្នុងការវាយប្រហារតែមួយ វាអាចកើតមានអំពើហិង្សាច្រើន ឧទាហរណ៍ អំពើមនុស្សឃាត រំលោភលើផ្លូវភេទ និងទារុណកម្ម[៥៥៦]។

---

[៥៥៤] មាត្រា៥ នៃច្បាប់ អ.វ.ត.ក ក៏បានតម្រូវថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (ផ្នែក ១.៤.១)។

[៥៥៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-52-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៩១៨។

[៥៥៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-52-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៩១៧-៩១៨ ដកស្រង់អំពី *រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-95-1-T) ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ១២២។

២៩៩. ទោះបីជាសញ្ញាណនៃការវាយប្រហារ មានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធក៏ដោយ ការវាយប្រហារសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលអាចកើតមានឡើងមុន អាចអូសបន្លាយពេលយូរ ឬបន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ[៥៥៧]។

២.៥.១.២ លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ

៣០០. អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ[៥៥៨]។ ពាក្យ "លក្ខណៈជាទូទៅ" គឺសំដៅទៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន ហើយពាក្យថា "ជាប្រព័ន្ធ" គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ ហើយដែលអំពើនោះមិនអាចកើតមានឡើងដោយចៃដន្យនោះទេ[៥៥៩]។ ដោយសារលក្ខខណ្ឌតម្រូវនៃការវាយប្រហារលក្ខណៈជាទូទៅ ក៏អាចជាលក្ខខណ្ឌតម្រូវនៃការវាយប្រហារជាប្រព័ន្ធនោះ ក្នុងការអនុវត្តជាក់ស្តែង ការបែងចែកលក្ខណៈវិនិច្ឆ័យនៃការវាយប្រហារទាំងពីរទម្រង់នេះឲ្យដាច់ពីគ្នាគឺជាការលំបាកណាស់។ ការវាយប្រហារលក្ខណៈជាទូទៅ ដែលកំណត់គោលដៅលើចំនួនជនរងគ្រោះជាច្រើន ជាទូទៅត្រូវផ្អែកលើទម្រង់មួយចំនួននៃការរៀបចំផែនការ ឬការចាត់ចែង។

---

[៥៥៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៨៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៧៧ ៩៤៩។

[៥៥៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦៤៦-៦៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៧៩ ជើងទំព័រ១៤៤។

[៥៥៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-52-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៩២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៧៨។

ការវាយប្រហារលក្ខណៈជាទូទៅអាចសំដៅទៅលើ "ទាំងអានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអានុភាពនៃអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ"[៥៦០]។

៣០១. ដើម្បីអាចកំណត់បានថាតើការវាយប្រហារកើតមានឡើងជាលក្ខណៈទូទៅ ឬជាប្រព័ន្ធ ឬការវាយប្រហារនោះមានលក្ខណៈទាំងពីរ គឺត្រូវពិចារណាទៅលើផលវិបាកដែលកើតចេញពីការវាយប្រហារទៅលើប្រជាជនដែលបានកំណត់ថាជាគោលដៅ មានចំនួនជនរងគ្រោះច្រើន លក្ខណៈនៃអំពើទាំងនោះ លទ្ធភាពនៃការចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬគំរូនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលអាចកត់សម្គាល់បាន[៥៦១]។ ទោះបីជាអត្ថិភាពនៃគោលនយោបាយ ឬផែនការអាចជាភស្តុតាងមួយទាក់ទងនឹងការបង្កើតឱ្យមាននូវការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធក៏ដោយ ក៏អត្ថិភាពនៃគោលនយោបាយ និងផែនការទាំងនោះមិនមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ[៥៦២]។ មានតែការវាយប្រហារប៉ុណ្ណោះ ដែលចាំបាច់តម្រូវឱ្យមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ចំណែកបទល្មើសជាក់-លាក់ មិនតម្រូវឱ្យមានលក្ខខណ្ឌទាំងនេះទេ[៥៦៣]។

---

[៥៦០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ២០៦។

[៥៦១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០២ កថាខណ្ឌ៩៥។

[៥៦២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩៨ ជើងទំព័រ១១៤ (ស្វែងរកប្រភពជាតិ និងអន្តរជាតិដែលមានមុនធម្មនុញ្ញ Nuremberg និងរកឱ្យឃើញថា ប្រភពទាំងនោះ "បានគាំទ្រយ៉ាងខ្លាំង" នូវសំអាងហេតុដែលថា ផែនការ ឬគោលនយោបាយ មិនត្រូវបានតម្រូវក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០០៦ កថាខណ្ឌ៨៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៧៩។

[៥៦៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១០២។ *រឿងក្តី រដ្ឋ*

### ២.៥.១.៣ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល

៣០២. ការវាយប្រហារត្រូវតែសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល។ ធាតុផ្សំនៃពាក្យថា"ប្រជាជន" គឺសំដៅទៅលើឧក្រិដ្ឋកម្មដែលមានលក្ខណៈប្រមូលផ្តុំ ហើយមិនរាប់បញ្ចូលនូវអំពើតែមួយ ឬដោយឡែក បើទោះបីជាអំពើទាំងនោះអាចបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មតាមច្បាប់ព្រហ្មទណ្ឌជាតិក៏ដោយ ក៏មិនទាន់ឡើងដល់កម្រិតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅឡើយទេ[៥៦៤]។

៣០៣. ការប្រើពាក្យ "ប្រជាជន" មិនមែនមានន័យថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយដែលមានការវាយប្រហារ ទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះទេ។ "វាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថា ប្រជាជននៅក្នុងក្រុមនោះមួយចំនួនល្មមត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ ឬវាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថា ប្រជាជនទាំងនោះត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះជឿថា ការវាយប្រហារមានគោលដៅប្រឆាំងទៅលើ "ប្រជាជន" ស៊ីវិល។ ប៉ុន្តែវាមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ប្រសិនបើការវាយប្រហារនោះសំដៅប្រឆាំងទៅលើតែបុគ្គលមួយចំនួនតិចតួចដែលបានកំណត់ ឬត្រូវបានជ្រើសរើសខ្លះៗនោះ"[៥៦៥]។

៣០៤. ឋានៈជាជនស៊ីវិលត្រូវបានគេកំណត់តាមរយៈបទប្បញ្ញត្តិនៃច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ជាពិសេសមាត្រា៥០ នៃពិធីសារបន្ថែម I និងមាត្រា៤ A នៃអនុសញ្ញាទីក្រុងហ្សឺណែវ III ដែលបានចែងថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងអ្នកប្រយុទ្ធផ្សេងទៀត (កងជីវពល ទាហានស្ម័គ្រចិត្ត និងសមាជិករបស់ក្រុមចលនាតស៊ូដែលមានការចាត់តាំង) មិនអាចត្រូវបានចាត់ទុកថាជាជនស៊ីវិល

---

*អាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨៩។

[៥៦៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦៤៦-៦៤៨។

[៥៦៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-15-A) ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ៧១៩។

ទេ។ ហេតុដូចនេះ ប្រជាជនស៊ីវិល រាប់បញ្ចូលនូវបុគ្គលទាំងឡាយដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវបានទទួលស្គាល់ថាជាអ្នកប្រយុទ្ធ[៥៦៦]។ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ ក៏មិនត្រូវបានចាត់ទុកថាជា "ជនស៊ីវិល" ដោយគ្រាន់តែសមាជិកទាំងនេះ មិនបានចូលរួមនៅក្នុងការប្រយុទ្ធ នៅពេលដែលពួកគេត្រូវបានចាប់ខ្លួន។ ហេតុដូច្នេះ ទាហានដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ មិនត្រូវបានចាត់ទុកថាជាជនស៊ីវិលទេផ្អែកតាមគោលបំណងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[៥៦៧]។ ការសន្មតជាទូទៅ ភ្ជាក់ងារអនុវត្តច្បាប់សង្គ្រាមរបស់រដ្ឋមួយ ត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកតាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ[៥៦៨]។ បុគ្គលមួយរូបត្រូវបានចាត់ទុកថាជាជនស៊ីវិល ប្រសិនបើឋានៈរបស់បុគ្គលនោះមិនមានលក្ខណៈច្បាស់លាស់[៥៦៩]។

---

[៥៦៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១១០-១១៣។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨២។

[៥៦៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៣៥ (បដិសេធចោលនិយមន័យជនស៊ីវិលក្នុងន័យទូលាយរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកតាមមូលដ្ឋាននៃការទទួលយកគោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១១០។ *សូមមើល* មាត្រា ៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានចែងថា "បុគ្គលនានាដែលមិនបានចូលរួមជាសកម្មនៅក្នុងអរិភាព រួមទាំងសមាជិកនៃជម្លោះប្រដាប់អាវុធដែលបានទម្លាក់អាវុធរបស់ខ្លួន និងសមាជិកដែលជា "ជនអសមត្ថភាពក្នុងការប្រយុទ្ធ" ដោយសារការឈឺ ការរងរបួស ការឃុំឃាំងខ្លួន ឬមូលហេតុផ្សេងទៀត បុគ្គលទាំងនេះត្រូវតែប្រព្រឹត្តដោយក្តីមេត្តា នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ដោយគ្មានការបែងចែកជាសត្រូវដោយសារពូជសាសន៍ ពណ៌សម្បុរ សាសនា ឬជំនឿ ភេទ កំណើត ឬទ្រព្យសម្បត្តិ ឬលក្ខខណ្ឌស្រដៀងផ្សេងណាមួយទៀត"។ បុគ្គលទាំងនេះដែលត្រូវបានទទួលការការពារនៅក្នុងជម្លោះប្រដាប់អាវុធ មានកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (*ដូចខាងលើដែរ* កថាខណ្ឌ១១៣ ជើងទំព័រ២២០)។

[៥៦៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨៧ (កត់សម្គាល់ថា ការសន្មតដូចគ្នានេះ មិនបានកំណត់ចំពោះកងកម្លាំងដែលប្រតិបត្តិក្រោមការគ្រប់គ្រងរបស់យោធាទេ)។

[៥៦៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១១១។

៣០៥. យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍នានា បានបញ្ជាក់ថា ប្រជាជនទាំងនោះត្រូវតែជា "ជនស៊ីវិលច្រើនលើសលុប" និង"ជាគោលដៅចំបងនៃការវាយប្រហារ"[៩៧០]។ យុត្តិសាស្ត្រនេះមិនបានបង្កប់ន័យថា ប្រជាជនទាំងនេះត្រូវតែមានតែជនស៊ីវិលនោះទេ។ វត្តមានរបស់បុគ្គលមួយចំនួនក្នុងចំណោមប្រជាជនស៊ីវិល ហើយដែលបុគ្គលទាំងនោះមិនស្ថិតនៅក្រោមនិយមន័យនៃជនស៊ីវិល មិនអាចដកហូតចរិតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនេះបានទេ[៩៧១]។ ឋានៈជាជនស៊ីវិលរបស់ជនរងគ្រោះ ចំនួនជនស៊ីវិល និងសមាមាត្រជនស៊ីវិលនៅក្នុងប្រជាជន គឺជាកត្តានានាដែលពាក់ព័ន្ធទៅនឹងការកំណត់អំពីលក្ខខណ្ឌតម្រូវនៃការវាយប្រហារទៅលើ "ប្រជាជនស៊ីវិល" [៩៧២]។

៣០៦. ចំពោះគោលបំណងនៃលក្ខខណ្ឌតម្រូវនេះ យុត្តិសាស្ត្រតុលាការមិនអចិន្ត្រៃយ៍ បានវាយតម្លៃអំពីស្ថានភាពដែលជនស៊ីវិល និងយោធានៅលាយឡំគ្នានៅក្នុងទីតាំងភូមិសាស្ត្រតែមួយ ដែលជាទីតាំងនៃការវាយប្រហារ ហើយប្រសិនបើជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានទាំងជនស៊ីវិល និងយោធា[៩៧៣]។ អង្គជំនុំជម្រះតុលាការកំពូល ICTY បានកត់សម្គាល់នៅពេលពិភាក្សា

---

[៩៧០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩១។

[៩៧១] មាត្រា៥០(៣) នៃពិធីសារបន្ថែម I។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ២៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨៧។

[៩៧២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៣២-៣៣ និង៣៦ (យល់ឃើញថា មនុស្សចំនួន១៩៤នាក់ ដែលត្រូវបានគេយកចេញពីមន្ទីរពេទ្យ Vukovar និងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១ ត្រូវបានសម្លាប់កងកម្លាំងស៊ែប មានមនុស្សចំនួន ១៨១នាក់ ក្នុងចំណោមនោះ ត្រូវបានគេស្គាល់ថាជាជនសកម្មនៅក្នុងកងកម្លាំងក្រូអាតនៅក្នុងទីក្រុង Vukovar ដូច្នេះចំនួនលើសលុបមិនមែនជាជនស៊ីវិល)។

[៩៧៣] *សូមមើលឧទា រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល (IT-98-29/1-A) ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៥០, ១៣៩ (កំណត់ប្រជាជននៃ Sarajevo ថាជាឋានៈជនស៊ីវិល ទោះបីជាមានការឈរជើងរបស់កងទ័ព ឬសន្តិ ប្រហែល៤០.០០០ ទៅ៤៥.០០០ នៅក្នុងទីក្រុង និងការបន្តហូរចូលជនស៊ីវិល និងអ្នកប្រយុទ្ធដោយសារតែស្ថានភាពពេលសង្គ្រាម)។

00573513



"អំពីថាតើប្រជាជនគឺជាជនស៊ីវិល ដោយផ្អែកតាមសមាមាត្រនៃជនស៊ីវិល និងអ្នកប្រយុទ្ធដែលស្ថិតនៅក្នុងចំណោមប្រជាជន ប្រសិនបើឋានៈនៃប្រជាជនទាំងនោះមិនទាន់ត្រូវបានកំណត់ទេ ឬអាចត្រូវបានផ្លាស់ប្តូរដោយសារតែលំហូរនៃជនស៊ីវិល និងយោធា"នោះ វាមិនអាចជៀសបានទេនៅពេលសង្គ្រាមដែលថា អ្នកប្រយុទ្ធអាចឡូកឡំចូលគ្នាជាមួយនឹងប្រជាជនស៊ីវិលនោះ។ ទោះបីជាយ៉ាងណាក៏ដោយ "ឲ្យតែអ្នកប្រយុទ្ធទាំងនោះមិនមែនជាកងត្រឹមត្រូវតាមច្បាប់ និងមិនមានចំនួនច្រើននោះ វត្តមានរបស់កងនេះមិនអាចផ្លាស់ប្តូរចរិតលក្ខណៈប្រជាជនស៊ីវិលបានទេ"[៥៧៤]។

៣០៧. ទោះបីជាយុត្តិសាស្ត្រនេះ មិនបានពិចារណាដោយផ្ទាល់អំពីស្ថានភាពដែលប្រជាជនទាំងអស់នៃទឹកដីមួយ ដោយរាប់បញ្ចូលទាំងប្រជាជនស៊ីវិល និងយោធាដែលស្ថិតនៅក្នុងការវាយប្រហារក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា គោលការណ៍ពាក់ព័ន្ធនានាអាចទាញចេញមកពីយុត្តិសាស្ត្រនេះនៅពេលកំណត់អំពីថាតើការវាយប្រហារបែបនោះ អាចចាត់ទុកបានថា "សំដៅប្រឆាំង" លើប្រជាជនស៊ីវិល សម្រាប់គោលបំណង មាត្រា៥ នៃច្បាប់ អ.វ.ត.ក។

៣០៨. នៅពេលពិចារណាអំពីលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ច្បាប់ស្តីពីជម្លោះប្រដាប់អាវុធដើរតួយ៉ាងសំខាន់នៅក្នុងការវាយតម្លៃអំពីនីត្យានុកូលភាពនៃអំពើនានា ដែលបានប្រព្រឹត្ត

[៥៧៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-29-A) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ១៣៧។ ជាផលវិបាក "ដើម្បីកំណត់ថាតើវត្តមានរបស់យោធានៅក្នុងចំណោមប្រជាជនស៊ីវិល អាចផ្លាស់ប្តូរចរិតលក្ខណៈនៃប្រជាជនស៊ីវិល នៅក្នុងករណីនេះ យើងត្រូវពិនិត្យមើលចំនួនយោធា ព្រមទាំងថាតើពួកយោធាទាំងនេះចាកចេញដែរ ឬយ៉ាងណា" (*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១១៥)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-13/1-T) ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ៤៦៨-៤៧២ (ទោះបីជាមិនអាចរបស់ឲ្យបានច្បាស់លាស់អំពីចំនួនជនស៊ីវិល និងអ្នកប្រយុទ្ធ ក៏ការវាយប្រហាររបស់កងកម្លាំងស៊ែប ត្រូវបានចាត់ទុកថាជាការវាយប្រហារលើជនជាតិក្រូអាត និងប្រជាជនស៊ីវិលផ្សេងទៀតដែលមិនមែនជាជនជាតិស៊ែប នៅពាសពេញតំបន់Vukovar ដែលការវាយប្រហារនេះត្រូវបានចាត់ទុកថាមានចរិតលក្ខណៈខុសច្បាប់យ៉ាងច្បាស់ ការបង្កឲ្យមានព្យសនកម្មយ៉ាងខ្លាំងដល់ទ្រព្យសម្បត្តិជនស៊ីវិល និងចំនួនជនស៊ីវិលជាច្រើនត្រូវបានសម្លាប់ រងរបួស ឬគ្មានទីជម្រក)។

នៅពេលមានជម្លោះ និងថាតើប្រជាជនអាចត្រូវបានចាត់ទុកថាជាគោលដៅដែរ ឬយ៉ាងណា[៩៧៥]។ ហេតុដូច្នេះ យុត្តិសាស្ត្រពាក់ព័ន្ធបានគូសបញ្ជាក់ថា នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រជាជនស៊ីវិលត្រូវតែជាគោលដៅចំបងនៃការវាយប្រហារ[៩៧៦]។ នៅក្នុងករណីនេះ ពាក្យថា "សំដៅប្រឆាំង" លើប្រជាជនស៊ីវិល ចង់បញ្ជាក់ថា "ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឲ្យភាគីនានានៃជម្លោះញែកឲ្យដាច់ពីគ្នាគ្រប់ពេលទាំងអស់ រវាងប្រជាជនស៊ីវិល និងអ្នកប្រយុទ្ធ និងតម្រូវមិនឲ្យវាយប្រហារលើគោលដៅយោធា ប្រសិនបើការវាយប្រហារទំនងជាបង្កឲ្យចំនួនអ្នកស្លាប់ ឬរបួសនកម្មជនស៊ីវិលលើសលុបពីផលប្រយោជន៍យោធាដែលគេអាចប៉ាន់ស្មានទុកមុន"[៩៧៧]។

៣០៩. កត្តាទាំងឡាយដែលពាក់ព័ន្ធ ដើម្បីកំណត់ថាតើការវាយប្រហារនោះមានគោលដៅ ឬគ្មានរួមមាន ៖ មធ្យោបាយ និងវិធីសាស្ត្រដែលប្រើប្រាស់ នៅក្នុងការវាយប្រហារ ឋានៈរបស់ជនរងគ្រោះ ចំនួនជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងការវាយប្រហារ និងការបង្ក្រាបដល់អ្នកតស៊ូនាពេលនោះ និងទំហំនៃកម្លាំងវាយប្រហារដែលអាច

[៩៧៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សាលក្រមរបស់អង្គជំនុំសាលាដំបូង ICTY (IT-98-29-T) ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ១៤៤ (កត់សម្គាល់ថា នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ការកំណត់ដែលថាការវាយប្រហារមានភាពខុសច្បាប់ផ្អែកតាមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ គឺមានសារសំខាន់យ៉ាងខ្លាំងនៅក្នុងការកំណត់ថាតើលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបំពេញដែរ ឬទេ។ ចំនួនអ្នកស្លាប់ជាជនស៊ីវិលដែលកើតចេញមកពីការវាយប្រហារត្រឹមត្រូវតាមច្បាប់លើគោលដៅយោធាស្របច្បាប់ នឹងបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងលែងចាត់ទុកជាការវាយប្រហារស្របច្បាប់ទៀតហើយ)។

[៩៧៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩១ ("នៅក្នុងករណីដែលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តនៅក្នុងពេលជម្លោះប្រដាប់អាវុធ ច្បាប់សង្គ្រាមបានចែងអំពីកម្រិតបទដ្ឋានដែលអង្គជំនុំជម្រះអាចយកមកប្រើប្រាស់ដើម្បីវាយតម្លៃអំពីលក្ខណៈនៃការវាយប្រហារ និងភាពស្របច្បាប់នៃអំពើដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលនោះ")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ២៣។

[៩៧៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23/1-T និងIT-96-23/1-T) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤២៦។

និយាយបានថា បានគោរពតាម ឬមានចេតនាគោរពតាម លក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម[៥៧៨]។

៣១០. ការហាមឃាត់មិនឱ្យវាយប្រហារលើប្រជាជនស៊ីវិល រាប់បញ្ចូលទាំងលទ្ធភាពនៃការបាត់បង់អាយុជីវិតប្រជាជនស៊ីវិលដោយចៃដន្យ ចំពោះការវាយប្រហារដែលមានចេតនាលើគោលដៅទៅលើយោធាស្របច្បាប់ផងដែរ។ ការវាយប្រហារដោយមិនរើសមុខ ដែលជាការវាយប្រហារដែលប៉ះពាល់ដល់ជនស៊ីវិល ឬគោលដៅជនស៊ីវិល និងគោលដៅយោធាដោយគ្មានការបែងចែកឱ្យដាច់ពីគ្នានោះក៏អាចត្រូវបានចាត់ទុកថាជាការវាយប្រហារផ្ទាល់ប្រឆាំងលើជនស៊ីវិលដែរ[៥៧៩]។ នៅពេលដែលប្រជាជនស៊ីវិលគឺជាគោលដៅនៃការវាយប្រហារដោយចេតនា យុត្តិសាស្ត្រនេះមិនបានតម្រូវថាប្រជាជនស៊ីវិលត្រូវតែជាគោលដៅតែមួយ ឬផ្ដាច់មុខនៃការវាយប្រហារនោះទេ។

៣១១. នៅពេលដែលប្រជាជនស៊ីវិលគឺជាគោលដៅនៃការវាយប្រហារ អង្គជំនុំជម្រះតុលាការកំពូល ICTY បានបញ្ជាក់បន្ថែមថា “មិនតម្រូវឱ្យមាននូវលក្ខខណ្ឌ ឬបង្ហាញនូវធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលថាជនរងគ្រោះនៃបទល្មើសជាក់លាក់ណាមួយនោះត្រូវតែជា“ជនស៊ីវិល”ឡើយ[៥៨០]។

---

[៥៧៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ២៥។

[៥៧៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-11-A) ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ២៥៥, ២៥៩-២៦១ (ដំកល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបាញ់កាំភ្លើងធំរបស់ Zagreb បង្កើតបានជាការវាយប្រហារជាលក្ខណៈប្រព័ន្ធសំដៅប្រឆាំងលើប្រជាជនស៊ីវិល “ដោយសារតែចរិតលក្ខណៈនៃអាវុធដែលប្រើប្រាស់ និងលក្ខណៈធំទូលាយនៃការវាយប្រហារ”។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សាលក្រមរបស់អង្គជំនុំសាលាដំបូង ICTY (IT-98-29-T) ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ៦០ (“ជាការពិត ការវាយប្រហារដោយវិសមាមាត្រ អាចធ្វើឱ្យលើកយកជាសំអាងថា ជនស៊ីវិលគឺពិតជាគោលដៅនៃការវាយប្រហារ”) ហើយ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Strugar* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល (IT-01-42-A) ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ២៧៥ (“ចរិតលក្ខណៈនៃការវាយប្រហារមិនរើសមុខ អាចបង្ហាញអង្គហេតុដែលថាការវាយប្រហារពិតជាសំដៅយ៉ាងច្បាស់លើប្រជាជនស៊ីវិល”)។

[៥៨០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៣២ (គូសបញ្ជាក់បន្ថែម)។ *សូមមើលខទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង*

00573516



ហេតុដូចនេះ យោធាណាម្នាក់*ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដ៏រាបណាលក្ខខណ្ឌចាំបាច់ផ្សេងទៀតត្រូវបានបំពេញ[៥៨១]។

៣១២. ការនិយាយយោងទៅលើប្រជាជនស៊ីវិល "ណាមួយ" គឺមិនពាក់ព័ន្ធទៅនឹងសញ្ជាតិ ឬជាតិពន្ធុនៃប្រជាជនស៊ីវិលនោះទេ។ ប្រសិនបើជនរងគ្រោះដែលជាគោលដៅត្រូវគេវាយប្រហារ ជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល ដូចនេះវាមិនចាំបាច់បង្ហាញថា ជនរងគ្រោះទាំងនោះជាប់ទាក់ទងជាមួយក្រុមពិសេសណាមួយ ខាងនយោបាយ ជាតិពន្ធុ ឬអ្វីផ្សេងឡើយ[៥៨២]។ ហេតុដូច្នេះ ឧក្រិដ្ឋកម្ម

---

*Dragomir Milošević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល (IT-98-29/1-A) ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៥៦ (អង្គជំនុំជម្រះយល់ឃើញថា មិនចាំបាច់បង្ហាញភស្តុតាងថា ជនស៊ីវិលទាំងអស់នៃបទល្មើសនីមួយៗ គឺជាជនស៊ីវិលទេ ប្រសិនអាចរកឃើញថា ការវាយប្រហារសំដៅប្រឆាំងលើប្រជាជនស៊ីវិលហើយនោះ)។

[៥៨១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Martić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-11-A) ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ៣០៩-៣១៣។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨២ (ត្រូវបានបញ្ជាក់នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-15-A) ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ១០៦៩)។ *ប្រៀបធៀប រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Mrkšić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៣៦, ៤២-៤៣ (ការសម្រេចឱ្យរួចខ្លួនពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលដែលការវាយប្រហារនោះសំដៅប្រឆាំងលើក្រុមជាក់លាក់មួយ ដែលជ្រើសរើសផ្អែកតាមការយល់ឃើញថាមានការពាក់ព័ន្ធនៅក្នុងកងកម្លាំងប្រដាប់អាវុធក្រូអាត។ ដូច្នេះ អ្នកទាំងនោះ ត្រូវបានចាត់ទុកខុសគ្នាពីប្រជាជនស៊ីវិល Vukovar ហើយឧក្រិដ្ឋកម្មទាំងនេះ មិនមានចេតនាបង្កើតឱ្យមានការវាយប្រហារជាលក្ខណៈទូលាយលើប្រជាជនស៊ីវិលទេ។ អាស្រ័យហេតុនេះ អំពើរបស់ជនជាប់-ចោទមិនមានទំនាក់ទំនងគ្នាជាមួយនឹងការវាយប្រហារនោះទេ ឬបទល្មើសដែលប្រព្រឹត្តប្រឆាំងនឹងអ្នកទោសនៅ Ovčara មិនមានទំនាក់ទំនងគ្នាជាមួយការវាយប្រហារជាលក្ខណៈទូទៅ ឬប្រព័ន្ធលើប្រជាជនស៊ីវិលរបស់ Vukovar ទេ)។

[៥៨២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23/1-T និងIT-96-23/1-T) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤២៣។ *សូមមើលផងដែរ រឿងក្តី អគ្គមេធាវីរបស់រដ្ឋអ៊ីស្រាអែល តទល់នឹង* Enigster តុលាការតំបន់របស់ Tel Aviv ថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៥២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រមនិងការផ្តន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៣០ ("ជនរងគ្រោះនៃអំពើដែលបានរៀបរាប់ មិនត្រូវការចាំបាច់ឱ្យមានលក្ខណៈភូមិសាស្ត្រ ឬលក្ខណៈកំណត់ផ្សេងទៀតជាមួយប្រជាជនស៊ីវិលដែលបង្កើតជាគោលដៅចំបងនៃការវាយប្រហារជាក់លាក់ ប៉ុន្តែ ចរិត-

ប្រឆាំងនឹងមនុស្សជាតិ អាចរួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយលើប្រជាជនរបស់រដ្ឋខ្លួនឯងផងដែរ[៥៨៣]។

## ២.៥.១.៤ មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

៣១៣. ក្រៅពីនេះ មាត្រា៥ នៃច្បាប់ អ.វ.ត.ក ចែងថា អំពើទាំងនោះ"ត្រូវតែបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ"[៥៨៤]។ អង្គជំនុំជម្រះបកស្រាយមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ថាជាលក្ខខណ្ឌយុត្តាធិការបន្ថែម ដែលចែងទាក់ទងនឹងលក្ខណៈនៃការវាយប្រហារ មិនមែនចែងទាក់ទងនឹងបទល្មើសជាក់លាក់នោះទេ[៥៨៥]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា រាល់ធាតុផ្សំជាមូលដ្ឋាននៃការរើសអើងណាមួយក្រោមធម្មនុញ្ញ Nuremberg ធម្មនុញ្ញ Tokyo និងច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង ត្រូវបានកំណត់ត្រឹមបទល្មើសដែលជាការធ្វើទុក្ខបុកម្នេញ ដែលក្នុងនោះធាតុចេតនានៃការរើសអើងតម្រូវឱ្យមានជាចាំបាច់។ រាល់បទល្មើសផ្សេងទៀត

---

លក្ខណៈបែបនេះអាចប្រើប្រាស់ដើម្បីបង្ហាញឱ្យឃើញថា អំពើដែលបានរៀបរាប់នោះ បានចូលរួមចំណែកការវាយប្រហារ")។

[៥៨៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-13/1-T) ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ៤៤១ (កត់សម្គាល់ថា កត្តាខុសគ្នាមួយក្នុងចំណោមកត្តាចំបងនានា រវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺត្រង់ថា ឧក្រិដ្ឋកម្មសង្គ្រាម អាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងតែនឹងប្រជាជនរបស់សត្រូវ ចំណែកឯឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនរបស់រដ្ឋខ្លួនឯង)។

[៥៨៤] គូសបញ្ជាក់បន្ថែម ។

[៥៨៥] ទោះបីជាយ៉ាងណាក៏ដោយ សូមមើល ភាពខុសគ្នាបន្តិចបន្តួចក្នុងការប្រើប្រាស់ពាក្យរវាងភាសាអង់គ្លេស បារាំង និងខ្មែរនៃមាត្រា៥ នៃច្បាប់ អ.វ.ត.ក ។ *សូមមើលមាត្រា៧* នៃកិច្ចព្រមព្រៀង (យោងទៅលើ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឆ្នាំ១៩៩៨" ដែលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងលក្ខន្តិកៈនេះ ក៏កំណត់ផងដែរអំពីលក្ខខណ្ឌរើសអើងចំពោះបទល្មើសជាក់លាក់នៃការធ្វើទុក្ខបុកម្នេញ)។

ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងឯកសារទាំងនេះមានធាតុផ្សំដោយឡែក ទោះបីជាមានទំនាក់-ទំនងជាមួយនឹងមូលដ្ឋាននៃការរើសអើងក៏ដោយ។

៣១៤. ក្រៅពីច្បាប់ អ.វ.ត.ក មានតែលក្ខន្តិកៈរបស់តុលាការ ICTR តែប៉ុណ្ណោះ ដែលតម្រូវឱ្យមានលក្ខខណ្ឌនៃការរើសអើងទាក់ទងទៅនឹងលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ [៥៨៦]។ ទោះបីជាមានការប្រើ ពាក្យពេចន៍ផ្សេងគ្នានៃបទប្បញ្ញត្តិទាំងពីរនេះ ធាតុផ្សំនៃការរើសអើងដែលមានចែងនៅក្នុងបទប្បញ្ញត្តិទូទៅនៃមាត្រា៥ ច្បាប់ អ.វ.ត.ក មានលក្ខណៈស្រដៀងគ្នាទៅនឹងបទ-ប្បញ្ញត្តិមាត្រា៣ នៃលក្ខន្តិកៈ ICTR។ បទប្បញ្ញត្តិស្រដៀងគ្នានេះ បង្កើតជាលក្ខខណ្ឌយុត្តាធិការ ដែលកំណត់នូវវិសាលភាពដែលមានលក្ខណៈចង្អៀតអំពីយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាងអ្វីដែលចាំបាច់ ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ យុត្តិសាស្ត្រជាបន្តបន្ទាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ព្រមទាំងលក្ខន្តិកៈរបស់តុលាការ ICC បានបញ្ជាក់ច្បាស់ថា ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ធាតុផ្សំចេតនានៃការរើសអើងមិនមែនជាធាតុផ្សំផ្លូវច្បាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លើកលែងតែការធ្វើទុក្ខបុកម្នេញដែលតម្រូវឱ្យមានធាតុចេតនានៃការរើសអើងនេះ[៥៨៧]។ ការបកស្រាយផ្សេងពីនេះនឹងបន្ថែមលក្ខខណ្ឌចេតនារើសអើងទាក់ទងនឹងរាល់បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលធ្វើឱ្យ

---

[៥៨៦] មាត្រា៣នៃលក្ខន្តិកៈរបស់តុលាការ ICTR ចែងថា ("តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ្វ៉ាន់ដា ត្រូវមានអំណាចដើម្បីកាត់សេចក្តីលើបុគ្គលនានាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម នៅពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តជាផ្នែកនៃការវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល *ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយៈ...*" (គូសបញ្ជាក់បន្ថែម)។

[៥៨៧] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ៣០៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ២១៦៦, ២២០៨ (កត់សម្គាល់ថាលក្ខខណ្ឌទូទៅបន្ថែមដែលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្ត "ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ" មិនមានន័យថាធាតុផ្សំចេតនារើសអើងត្រូវតែរកឱ្យឃើញនោះទេ) និងមាត្រា៧(១)(ជ) នៃលក្ខន្តិកៈរបស់ ICC។

ការប្រើពាក្យរើសអើងមានលក្ខណៈច្រំដែល ដែលធាតុផ្សំរើសអើងត្រូវបានបញ្ចូលក្នុងបទល្មើសធ្វើទុក្ខបុកម្នេញរួចហើយ ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក[៥៨៨]។

៣១៥. មូលដ្ឋានធាតុផ្សំនៃការរើសអើងត្រូវបានបកស្រាយក្នុងន័យទូលាយ ហើយបានរាប់បញ្ចូលនូវក្រុម ឬបុគ្គលដែលមិនបានកំណត់ ឧទាហរណ៍ដូចជាយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ICTY ដូចជាជនរងគ្រោះនៃអំពើនានា "ដែលជាផ្នែកនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ (ដោយកងទ័ពស៊ែប) ដែលវាយប្រហារលើប្រជាជនស៊ីវិលដែលមិនមែនជាជនជាតិស៊ែបនៃទីក្រុងហ្វូចា (Foca)"[៥៨៩]។

៣១៦. រឿងក្តី *Josef Altstotter និងអ្នកផ្សេងទៀត* បានកំណត់ថា ការប្រឆាំងនឹងគំនិតនយោបាយជាមូលដ្ឋាននៃការរើសអើងដែលជាប់ពាក់ព័ន្ធ ហើយដែលទាក់ទងទៅនឹងបទល្មើសធ្វើទុក្ខបុកម្នេញ។ នៅពេលបកស្រាយជាទូទៅចំពោះសញ្ញាណនៃការរើសអើងដោយមូលហេតុនយោបាយ តុលាការព្រហ្មទណ្ឌ Nuremberg បានកត់សម្គាល់ដូចតទៅ៖

> នៅពេលលើកឡើងអំពីប្រភេទនៃរឿងក្តីទាក់ទងនឹងមូលហេតុនយោបាយ យើងត្រូវតែចងចាំថា ពាក្យ "នយោបាយ" នៅក្នុងច្បាប់លេខ១០ ដែលចែងសម្រាប់អនុវត្តទៅលើ Third Reich មិនអាចយកមកអនុវត្តចំពោះពាក្យ "នយោបាយ" នៃប្រទេសដែលប្រើប្រាស់ប្រព័ន្ធទ្វេបក្ស ឬពហុបក្សទេ។ ពាក្យ "នយោបាយ" ដែលកំណត់ដោយចៅក្រម Nazi ទាំងអស់ និងចុងចោទ Cuhorst មានន័យថា បុគ្គលណាក៏ដោយឲ្យតែប្រឆាំងនឹងគោលនយោបាយរបស់ Third Reich។ ដោយសារតែពួកទាំងនេះប្រឆាំងនឹងគោលនយោបាយរបស់ Third Reich ដូចនេះពួកទាំងនេះ

[៥៨៨] លក្ខខណ្ឌទូទៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក សំដៅលើការរើសអើង "ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា" នៅពេលបទល្មើសធ្វើទុក្ខបុកម្នេញដែលរាយនាមក្រោមមាត្រានេះ សំដៅចំពោះការរើសអើង "ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា"។

[៥៨៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៥០។

ត្រូវបានកំណត់ថាបានប្រព្រឹត្តអំពើមួយដែលប្រឆាំងនឹងកិច្ចជោគជ័យនៃសង្គ្រាម[៥៥០]។

៣១៧. ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូង ICTY យល់ឃើញថា ក្រុមគោលដៅនៃការវាយប្រហាររួមបញ្ចូលនូវបុគ្គលទាំងឡាយដែល "ត្រូវបានចារីកំណត់ថាជាអ្នកស្ថិតនៅក្នុងក្រុមជនរងគ្រោះ ដោយសារតែបុគ្គលទាំងនោះមានជាប់ទាក់ទងគ្នាជិតស្និត ឬមានសមានចិត្តចំពោះក្រុមជនរងគ្រោះ" ដោយផ្អែកលើមូលដ្ឋានថា "ចារីគឺជាអ្នកកំណត់ថាតើអ្នកណាជាជនរងគ្រោះ ខណៈដែលជនរង-គ្រោះដែលជាក្រុមគោលដៅនៃការវាយប្រហារ មិនមានឥទ្ធិពលនៅក្នុងការកំណត់អំពីឋានៈរបស់ពួកគេបាន"[៥៥១]។ បុគ្គលទាំងឡាយ "ដែលសង្ស័យថាជាសមាជិកនៃក្រុមសាសនា នយោបាយ ឬជាតិពន្ធុក៏អាចជាជនរងគ្រោះនៃការរើសអើងផងដែរ" ហើយធាតុផ្សំនៃការរើសអើងត្រូវបានបំពេញ "ទោះបីជាមានភស្តុតាងបង្ហាញថា ការសង្ស័យនោះមិនត្រឹមត្រូវក៏ដោយ"[៥៥២]។ នៅពេលការសន្មតរបស់ចារីត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការរើសអើង ផលវិបាកគឺពិតជាមានសម្រាប់ជនរងគ្រោះ ទោះបីជាចំណាត់ថ្នាក់ជនស៊ីវិលដោយចារីអាចនឹងមិនត្រឹមត្រូវផ្អែកតាមលក្ខខណ្ឌសត្យានុម័តក្ដី[៥៥៣]។

---

[៥៥០] *សាលក្រម/សាលដីកាលើរឿងក្ដី Josef Altstotter និងអ្នកផ្សេងទៀត* របាយការណ៍ច្បាប់នៃការកាត់សេចក្ដីឧក្រិដ្ឋជនសង្គ្រាម ភាគ៦ ទំព័រ៨១ជើងទំព័រ១ (កត់សម្គាល់ថា ការផ្ដន្ទាទោសប្រហារជីវិតលើបុរសចាស់វង្វេងវង្វាន់ដែលមានអាយុ៦៥ឆ្នាំ ដោយសារតែយកបារីពីកញ្ចប់របស់ប្រៃសណីយ៍ គឺជាអំពើសម្លាប់រង្គាលដោយមូលហេតុនយោបាយ ដោយសារកត់សម្គាល់ឃើញថា ជនរងគ្រោះ "អ្នកទទួលទានដោយឥតបានការម្នាក់ ហើយដោយសារតែមូលហេតុនេះ គាត់ត្រូវបានកំណត់ថាជាបុគ្គលម្នាក់នៅក្នុងសហគមន៍ដែលគួរតែត្រូវសម្លាប់ដោយបទដ្ឋានរបស់ Cuhorst...។ បន្ថែមពីលើនេះ ការយកបារីរបស់គាត់សម្រាប់ឱ្យទៅយោធា បានបង្កើតយ៉ាងច្បាស់នូវការប្រឆាំងផ្នែកនយោបាយចំពោះគោលបំណងរបស់Reich ដោយសារតែ Cuhorst បានឃើញការយកនោះ ដូច្នេះបានផ្ដល់យុត្តិកម្មដាក់ទោសប្រហារជីវិតដោយផ្អែកលើមូលដ្ឋាននោះ")។

[៥៥១] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Naletilic និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-34-T) ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ៦៣៦។

[៥៥២] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kvočka* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៩៥។

[៥៥៣] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Naletilic និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-34-T) ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ៦៣៦, ជើងទំព័រលេខ ១៥៧១៖ "ការបកស្រាយនេះស្របគ្នានឹងមូលដ្ឋាននៃ

### ២.៥.១.៥ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងការវាយប្រហារ

៣១៨. អំពើរបស់ជនជាប់ចោទ ត្រូវតែជាផ្នែកមួយនៃការវាយប្រហារជាសត្យានុម័ត ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ដរាបណាអំពើទាំងនោះមិនត្រូវបានកាត់ផ្តាច់ទាំងស្រុងចេញពីបរិបទនៃការវាយប្រហារ[៥៥៤]។ ឧក្រិដ្ឋកម្មមួយដែលត្រូវបានប្រព្រឹត្តឡើងមុន ឬក្រោយការវាយប្រហារជាចម្បងប្រឆាំងទៅលើប្រជាជនស៊ីវិល ឬមិនសំដៅទៅលើប្រជាជនស៊ីវិល ក៏អាចនៅតែជាផ្នែកនៃការវាយប្រហារដដែល ប្រសិនបើឧក្រិដ្ឋកម្មនោះមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងការវាយប្រហារនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ឧក្រិដ្ឋកម្មមិនអាចជាអំពើដាច់ដោយឡែកបាននោះទេ។ ឧក្រិដ្ឋកម្មមួយ អាចចាត់ទុកថាជាអំពើដាច់ដោយឡែកបាន នៅពេលដែលឧក្រិដ្ឋកម្មនោះនៅដាច់ឆ្ងាយពីការវាយប្រហារ ដែលមិនមានហេតុផលសមស្របណាមួយអាចនិយាយបានថា ឧក្រិដ្ឋកម្មនោះគឺជាផ្នែកមួយនៃការវាយប្រហារ ក្រោយពីបានពិចារណាលើបរិបទ និងកាលៈទេសៈដែលបទល្មើសនោះត្រូវបានប្រព្រឹត្តឡើង[៥៥៥]។

### ២.៥.១.៦ លក្ខខណ្ឌដឹង

៣១៩. លក្ខខណ្ឌដឹងនេះអាចត្រូវបានយោងពីមាត្រា៥ នៃច្បាប់ អ.វ.ត.ក ក្នុងគោលបំណងដើម្បីផ្តន្ទាទោស ជនជាប់ចោទត្រូវតែបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងដឹងថា

---

បទប្បញ្ញត្តិដែលហាមឃាត់ការធ្វើទុក្ខបុកម្នេញ ដោយសារតែចារីជាអ្នកកំណត់ក្រុមជនរងគ្រោះប៉ុន្តែជនរងគ្រោះទាំងនោះមិនមានឥទ្ធិពលលើការកំណត់និយមន័យនៃឋានៈរបស់ពួកគេទេនោះទេ...។ នៅក្នុងករណីបែបនេះ ការរើសអើងតាមអង្គហេតុ ត្រូវបានចាត់ទុកថាជនរងគ្រោះត្រូវបានរើសអើងតាមព្រឹត្តិហេតុ ដោយផ្អែកតាមការយល់ឃើញរបស់ចារី"។

[៥៥៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩៩។

[៥៥៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០២ កថាខណ្ឌ១០០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-13/1-A) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ៤១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រមនិងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣២៦។

អំពើរបស់ខ្លួនជាផ្នែកមួយនៃការវាយប្រហារនោះ[៥៥៦]។ ជនជាប់ចោទត្រូវដឹងអំពីបរិបទទាំងមូលដែលអំពើនោះកើតឡើង ប៉ុន្តែមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារនោះទេ[៥៥៧]។ វាមិនមានភាពពាក់ព័ន្ធនោះទេ ដែលថាជនជាប់ចោទមានចេតនាចង់ឲ្យអំពើរបស់ខ្លួនសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដែលបានកំណត់ជាគោលដៅ ឬមួយគ្រាន់តែប្រឆាំងទៅលើជនរងគ្រោះ[៥៥៨]។ ភស្តុតាងនៃការដឹងអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ។ ជាលទ្ធផល ការបង្ហាញធាតុផ្សំតាមផ្លូវច្បាប់ថាយ៉ាងណានោះគឺអាស្រ័យតាមកាលៈទេសៈជាក់ស្តែងនីមួយៗ[៥៥៩]។

## ២.៥.២ សំអាងហេតុទាក់ទងនឹងលក្ខខណ្ឌទូទៅសម្រាប់មាត្រា៥ នៃច្បាប់ អ.វ.ត.ក

### ២.៥.២.១ ការវាយប្រហារ

៣២០. អង្គជំនុំជម្រះបានពិពណ៌នានូវព្រឹត្តការណ៍យ៉ាងទូលំទូលាយក្នុងប្រទេសកម្ពុជា ដែលនៅក្នុងព្រឹត្តិការណ៍ទាំងនោះ រួមទាំងជោគវាសនាដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាទូទាំងប្រទេសនៅចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ បន្ថែមទៅលើប្រវត្តិនៃស្ថានភាពជម្លោះប្រដាប់-

---

[៥៥៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១២៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ៨៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៩០។

[៥៥៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១០២-១០៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៨៧។

[៥៥៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១០៣។

[៥៥៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១២៦។

00573523



អាវុធអន្តរជាតិ (ផ្នែក ២.១.) ព្រឹត្តិការណ៍ទាំងនេះរួមមាន ការចូលមកទីក្រុងភ្នំពេញ និងការកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របស់កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ការជម្លៀសដោយបង្ខំអ្នករស់នៅទីក្រុងភ្នំពេញ និងកងកម្លាំងដ៏រឹងមាំរបស់របបសាធារណរដ្ឋខ្មែរឲ្យទៅរស់នៅតាមជនបទ ការធ្វើការដោយបង្ខំក្រោមស្ថានភាពដ៏លំបាកក្រៃលែង ការរំលាយចោលនូវប្រព័ន្ធតុលាការ និងស្ថាប័នរដ្ឋដទៃទៀត និងការបង្កើតស្របគ្នានៃស្ថាប័ន និងរចនាសម្ព័ន្ធក្នុងគោលបំណងដើម្បីបង្រួបបង្រួម និងពង្រឹងការត្រួតត្រាប្រទេសទាំងស្រុងពីសំណាក់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.២)។ មន្ទីរស២១ ត្រូវបានបង្កើតឡើង និងប្រតិបត្តិការ (ផ្នែក ២.៣) ក្នុងបរិបទ នេះ។

### ២.៥.២.២ មានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ

៣២១. កថាខណ្ឌ១៣២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានកំណត់បទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរស២១ ថាបង្កើតបានជា "ការវាយប្រហារមួយដាច់ដោយឡែកដែលមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធ ប្រឆាំងទៅនឹងជនស៊ីវិលដែលឃុំខ្លួននៅទីនោះ"។ អង្គជំនុំ-ជម្រះ យល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ភាពធំធេង និងបទឧក្រិដ្ឋដ៏ច្រើនដែលបានប្រព្រឹត្តនៅមន្ទីរស២១ និងលក្ខណៈនៃការរៀបចំដែលមានរយៈពេលយូរ ដើម្បីធានាថាបទឧក្រិដ្ឋទាំងនេះមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវលក្ខខណ្ឌតម្រូវអំពីលក្ខណៈជាទូទៅ ឬជាប្រព័ន្ធសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

### ២.៥.២.៣ សំដៅប្រឆាំងទៅលើប្រជាជនជនស៊ីវិល

៣២២. ទោះបីជាការវាយប្រហារលើប្រជាជនកម្ពុជាបានកើតឡើង ស្របគ្នាជាមួយនឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិរវាងកម្ពុជានិងវៀតណាមក៏ដោយ តាមពិតបក្សកុម្មុយនីស្តកម្ពុជាដំបូងឡើយមានគោលដៅប្រឆាំងទៅលើប្រជាពលរដ្ឋខ្លួនឯងផ្ទាល់។ ការវាយប្រហារនេះបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងមន្ទីរស២១ គឺប្រឆាំងទៅនឹង "ខ្មាំង" របស់របបនោះ មិនថាពួកគេជាជនស៊ីវិល ឬជាសមាជិកនៃអតីតទាហាន លន់ នល់ ឬកងទ័ពបដិវត្តកម្ពុជាខ្លួនឯងនោះទេ (ផ្នែក ២.២.៥.២) (ផ្នែក២.២.៦) (ផ្នែក ២.៣.៣.៤.២) និង(ផ្នែក២.៥.៣.១៤.១)។

៣២៣. អង្គជំនុំជម្រះយល់ឃើញថា អ្នកទាំងឡាយដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ ត្រូវបាននាំយកមកស្ទើរពីគ្រប់តំបន់ និងគ្រប់ផ្នែកទាំងអស់នៃប្រទេសកម្ពុជា (ផ្នែក ២.៣.៣.៤.២)។ សក្ខីកម្មរបស់អ្នកដែលនៅរស់រានមានជីវិត ដែលមានចំនួនយ៉ាងតិចតួច និងការពិនិត្យមើលបញ្ជីឈ្មោះអ្នក-ទោសបញ្ជាក់ថា ប្រជាជនកម្ពុជាដែលត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១ រួមមានមន្ត្រីដែលមកពីមន្ទីរនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងប្រជាជនធម្មតា ដូចជា កសិករ គ្រូបង្រៀន សាស្ត្រាចារ្យ សិស្សានុសិស្ស វេជ្ជបណ្ឌិត អ្នកច្បាប់ និងវិស្វករ។ សាច់ញាតិ និងអ្នកក្រោមបង្គាប់របស់អ្នកទាំងនោះក៏ត្រូវបានឃុំខ្លួនផងដែរ។ អ្នកដែលបានផ្តល់សក្ខីកម្មនៅពេលសវនាការ ដូចជា សាក្សី វ៉ាន់ ណាត នង ចាន់ផល និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង និង ជុំ ម៉ី បានបញ្ជាក់ដូចអ្វីដែលបានលើកឡើងខាងលើនេះ[៦០០]។

៣២៤. ទោះបីជាទាហានខ្មែរមានចំនួនដ៏ច្រើនក្នុងចំណោមអ្នកជាប់ឃុំទាំងនោះក៏ដោយ ការកំណត់ឲ្យបានច្បាស់លាស់នូវចំនួនប្រហាក់ប្រហែល និងភាគរយពិតប្រាកដនៃទាហានទាំងនោះគឺមិនអាចធ្វើបានឡើយ (ផ្នែក ២.៣.៣.៤.២)។ អតីតទាហាន លន់ នល់ (និងសមាជិកគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ) ត្រូវបានគេសន្មតថាប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។ កងទ័ពបដិវត្តកម្ពុជាត្រូវបានគេកំណត់គោល-ដៅមិនមែនជាផ្នែកនៃការវាយប្រហារយោធាឡើយ ប៉ុន្តែជាលទ្ធផលនៃការបោសសម្អាតផ្ទៃក្នុងដែលសំដៅទាំងជនស៊ីវិល និងយោធាដែលគេចាត់ទុកថាជា "ខ្មាំង"របស់របបនោះ (ផ្នែក ២.២.៥.២) និង(ផ្នែក២.៥.៣.១៤.១)។

៣២៥. អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារគឺសំដៅទៅលើប្រជាជនកម្ពុជាទាំងមូល និងមិនបានញែកឲ្យបានដាច់ពីគ្នារវាងជនស៊ីវិល និងទាហានឡើយ។ ដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស-ជាតិត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្សទូទៅនៅមន្ទីរស២១ និងគ្រប់ដណ្តប់ទាំងយោធា និងស៊ីវិល ដោយមិនញែកចេញពីគ្នានោះទេ។ ហេតុដូច្នេះ គេអាចនិយាយបានថា ការវាយប្រហារគឺសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល។

---

[៦០០] សូមមើល *ជាទូទៅ* ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត)។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី)។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង)។ ប្រតិចារឹក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ (នង ចាន់ផល)។

### ២.៥.២.៤ ដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ និងសាសនា

៣២៦. ឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេ និងជនបរទេសមួយចំនួនក៏ត្រូវបានឃុំខ្លួននៅមន្ទីរស២១ផងដែរ(ផ្នែក២.៣.៣.៤.២) និង(ផ្នែក ២.៤.១.១)។ អ្នកជាប់-ឃុំជនជាតិវៀតណាមត្រូវបានចាត់ទុកថាជាខ្មាំងខាងក្រៅដែលបានគំរាមកំហែងដល់បក្សកុម្មុយនីស្តកម្ពុជា ដោយសារហេតុផលនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាម (ផ្នែក ២.១) ដែលក្នុងពេលនោះដែរ ជនជាតិបរទេសផ្សេងៗទៀតក៏ត្រូវបានឃុំខ្លួនដោយសង្ស័យថាពួកគេមកយកការណ៍ឲ្យរដ្ឋាភិបាលបរទេស ដូចជាសមាជិករបស់សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB) (ផ្នែក ២.៥.៣.១៤.១)។

៣២៧. មិនមានភស្តុតាងបញ្ជាក់ដែលអាចឲ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានថា មានកត្តាពាក់ព័ន្ធគ្នាជារួមក្នុងចំណោមអ្នកទាំងឡាយដែលត្រូវបានឃុំខ្លួននោះឡើយ ក្រៅតែពីអ្វីដែលគេយល់ថាជាការប្រឆាំងទៅនឹងបក្សកុម្មុយនីស្តកម្ពុជានោះ (ផ្នែក២.៥.៣.១៤.១)។ ពួកគេទាំងអស់ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជា "ខ្មាំង" ទោះបីជាការពិតពួកគេមិនបានប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ-នោះក៏ដោយ (ផ្នែក២.៥.៣.១៤.២)។ យុត្តិកម្មចំពោះការវាយប្រហារគឺផ្តើមចេញពីមនោគមវិជ្ជាដែលធ្វើឡើងក្នុងគោលបំណងឃុំខ្លួន និងដើម្បីធ្វើការកែទម្រង់ ឬលុបបំបាត់ចោលនូវសត្រូវពិត-ប្រាកដ ឬអ្នកទាំងឡាយណាដែលគេយល់ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.២.៥.២) និង(ផ្នែក២.២.៦)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារដែលបានកើតមានឡើងនោះ គឺដោយសារមូលហេតុនយោបាយ។

### ២.៥.២.៥ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារ

៣២៨. ភស្តុតាងបង្ហាញយ៉ាងច្បាស់ថា មន្ទីរស២១គឺជាផ្នែកដ៏សំខាន់មួយនៃរចនាសម្ព័ន្ធយោធា និងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងត្រូវបានចាត់ទុកថាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចឲ្យបាននូវទិសដៅនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក២.២.៥) និង(ផ្នែក២.៣.៣.១)។ មន្ទីរស២១បានអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដូចជា"កម្ទេច"ខ្មាំងរបស់បក្សកុម្មុយនីស្ត-កម្ពុជា (ផ្នែក ២.២.៥.២)។ តួនាទីរបស់ជនជាប់ចោទជាប្រធានមន្ទីរស២១ ដែលរាយការណ៍ដោយ-

ផ្ទាល់ទៅសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ បានផ្តល់ឲ្យគាត់នូវឱកាសពិសេសតែមួយគត់ដើម្បីអនុវត្តគោលនយោបាយនេះ។ អង្គជំនុំជម្រះ សន្និដ្ឋានថា ជនជាប់ចោទបានដឹងនូវកម្មវត្ថុនៃគោល-នយោបាយនេះ ហើយអង្គជំនុំជម្រះក៏សន្និដ្ឋានផងដែរថា មន្ទីរស២១ គឺជាសមាសភាពមួយដ៏សំខាន់ក្នុងការអនុវត្តន៍គោលនយោបាយនេះ។

២.៥.២.៦ ការដឹងរបស់ជនជាប់ចោទ

៣២៩. ជនជាប់ចោទក៏បានដឹងផងដែរអំពីការវាយប្រហារ ដែលមានលក្ខណៈទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិលកម្ពុជា ហើយថា ការសម្លាប់ក្រៅច្បាប់ ឬដោយហេតុផលជំរុញផ្នែកនយោបាយ ត្រូវបានប្រព្រឹត្តឡើងដោយអង្គភាពយោធាទូទាំងប្រទេសកម្ពុជា និងបន្តធ្វើឡើងនៅតាមមន្ទីរសន្តិសុខ ដែលក្នុងចំណោមមន្ទីរសន្តិសុខទាំងនោះមានមន្ទីរស២១ជាឧទាហរណ៍ដ៏សំខាន់មួយ(ផ្នែក ២.២.៥.២)។ គាត់បានអនុវត្ត នូវទម្រង់ការដែលបានអនុវត្តនៅមន្ទីរម១៣ ក្នុងការឃុំខ្លួន សួរចម្លើយ និងសម្លាប់រាល់បុគ្គលទាំងឡាយណាដែលបានឆ្លងកាត់ទ្វារបងមន្ទីរស២១(ផ្នែក២.៣.២) និង(ផ្នែក ២.២.៥.២)។ គាត់បានដឹងអំពីការចោទប្រកាន់ប្រឆាំងនឹងអ្នកជាប់ឃុំ ដោយបានដឹងថាភាគច្រើននៃការចោទប្រកាន់នោះគឺមិនពិត ប៉ុន្តែគាត់នៅតែអនុវត្តយ៉ាងតឹងរ៉ឹងនូវគោលនយោបាយក្នុងការឃុំខ្លួន និងសម្លាប់ (ផ្នែក ២.៤.១) (ផ្នែក ២.៤.៣) និង(ផ្នែក ២.៥.៣.១៤.១)។ ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា ជនជាប់-ចោទបានដឹងអំពីគោលបំណងដែលមន្ទីរស២១បានដំណើរការក្នុងការជួយគាំទ្រ និងអនុវត្តការវាយ-ប្រហារ និងមានចេតនាធ្វើសកម្មភាពដើម្បីរួមចំណែកសម្រេចគោលបំណងនោះ។

២.៥.៣ ច្បាប់ និងសំអាងហេតុទាក់ទងនឹងបទល្មើសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៣៣០. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចោទប្រកាន់ជនជាប់ចោទអំពីឧក្រិដ្ឋ-កម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅ៖ (i) ការធ្វើមនុស្សឃាត (ii) ការសម្លាប់រង្គាល (iii) ការធ្វើឲ្យទៅជាទាសករ (iv) ការដាក់ក្នុងមន្ទីរឃុំឃាំង (v) ការធ្វើទារុណកម្ម (vi) ការរំលោភលើផ្លូវភេទ (vii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង (viii) អំពើអមនុស្សធម៌ផ្សេងៗទៀត។

## ២.៥.៣.១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

៣៣១. ការធ្វើមនុស្សឃាតគឺជាបទល្មើសដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៦០១] ដែលបទល្មើសនេះតម្រូវឲ្យមានជនរងគ្រោះបាត់បង់ជីវិត ដែលកើតចេញមកពីអំពើសកម្ម ឬ អកម្មដោយខុសច្បាប់របស់ចារី[៦០២]។ អំពើរបស់ចារីត្រូវតែបានចូលរួមចំណែកយ៉ាងពិតប្រាកដ ក្នុងការធ្វើឲ្យបាត់បង់ជីវិតជនរងគ្រោះ[៦០៣]។

៣៣២. ធាតុផ្សំនៃបទមនុស្សឃាតអាចនឹងត្រូវបំពេញ ទោះបីជាសាកសពរបស់ជនរងគ្រោះត្រូវបានរកឃើញ ឬមិនត្រូវបានរកឃើញក្តី[៦០៤]។ អង្គហេតុនៃការបាត់បង់ជីវិតជនរងគ្រោះអាចត្រូវបានសន្និដ្ឋានពីកាលៈទេសៈ រួមទាំងការសន្និដ្ឋានពីភស្តុតាងដូចខាងក្រោម៖ ឧប្បត្តិហេតុនៃការធ្វើបាប

---

[៦០១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-32-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ២០៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៣៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៨៧។

[៦០២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Fofana និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-14-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ១៤៣។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ២៦១។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៨៩។

[៦០៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brdjanin* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-99-36-T) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៣៨២។

[៦០៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadic* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ២៤០ (លក្ខណៈពិសេសនៃជម្លោះ Balkan គឺជាការសម្លាប់ដែលមានលក្ខណៈរីករាលដាល ព្រមទាំងការប្រព្រឹត្តិដ៏សាហាវ និងគ្មានធម៌មេត្តាដល់អ្នកស្លាប់។ ដោយសារតែការប្រព្រឹត្តិទាំងនេះមិនមែនស្ថិតក្នុងស្ថានភាពប្រក្រតី ការអនុវត្តវិធាននៃប្រព័ន្ធច្បាប់ជាតិខ្លះដែលតម្រូវឲ្យមានការបង្ហាញសាកសពដើម្បីជាភស្តុតាងនៃការស្លាប់នោះគឺជាការប្រព្រឹត្តមិនត្រឹមត្រូវនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវតែមានភស្តុតាងដើម្បីភ្ជាប់ការរងរបួសដែលបានកើតមានដែលបណ្តាលឲ្យមានការបាត់បង់ជីវិត)។

ដោយផ្ទាល់លើជនរងគ្រោះ វិធីនៃការធ្វើបាប និងការបាត់ខ្លួននៃបុគ្គលផ្សេងៗ "បរិយាកាសទូទៅនៃភាពគ្មានច្បាប់"នៅកន្លែងដែលប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ រយៈពេលកន្លងផុតទៅចាប់តាំងពីពេលដែលបុគ្គលបានបាត់ខ្លួន និងអង្គហេតុដែលជនរងគ្រោះខកខានមិនបានទាក់ទងជាមួយបុគ្គលផ្សេងៗទៀត ដែលគាត់ត្រូវទាក់ទង ដូចជាសមាជិកគ្រួសារជាដើម[៦០៥]។ ការបាត់បង់ជីវិតជនរងគ្រោះដែលបណ្តាលមកពីអំពើសកម្ម ឬអកម្មរបស់ចារីត្រូវតែអាចសន្និដ្ឋានដោយសមហេតុសមផលចេញពីភស្តុតាង[៦០៦]។

៣៣៣. ត្រូវតែបង្ហាញថាអំពើសកម្ម ឬអកម្មរបស់ចារីត្រូវបានប្រព្រឹត្តដោយចេតនាសម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនេះមុខជានាំឱ្យមានការបាត់បង់ជីវិតមនុស្ស[៦០៧]។

៣៣៤. ការសម្លាប់រង្គាល ដែលជាបទល្មើសមួយមានចែងនៅក្នុងទំនៀមទម្លាប់អន្តរជាតិ[៦០៨] ត្រូវបានកំណត់ចរិតលក្ខណៈដោយអំពើសកម្ម អកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[៦០៩]។

---

[៦០៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៣២៧។

[៦០៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៣២៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ២៦០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Fofana និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-14-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ១៤៤។

[៦០៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៥៥៦។

[៦០៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៤៩២។

៣៣៥. តួនាទីរបស់ចារីទាក់ទងនឹងការស្លាប់របស់បុគ្គលក្នុងទ្រង់ទ្រាយធំ អាចប្រព្រឹត្តពីចម្ងាយ ឬដោយប្រយោល[៦១០]។ អំពើទាំងឡាយដែលចាត់ទុកថាជាការសម្លាប់រង្គាល រួមមាន ការបង្កើតនូវស្ថានភាពនៃការរស់នៅដែលមានបំណងបំផ្លិចបំផ្លាញប្រជាជនដោយផ្នែក ដូចជាការមិនផ្គត់ផ្គង់ម្ហូបអាហារ ឬថ្នាំពេទ្យ[៦១១] ជាដើម។

៣៣៦. គ្មានការកំណត់អំពីចំណុចអប្បបរមានៃចំនួនជនរងគ្រោះ ដែលជាគោលដៅក្នុងការសម្លាប់រង្គាលនោះទេ[៦១២]។ ប៉ុន្តែ បញ្ហាថាតើលក្ខខណ្ឌនៃ "ការស្លាប់ទ្រង់ទ្រាយធំ" ត្រូវបានបំពេញ ឬយ៉ាងណានោះគឺត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើស្ថានភាពពាក់ព័ន្ធទាំងអស់[៦១៣]។ យ៉ាងណាក៏ដោយ ការសម្លាប់មនុស្សម្នាក់ ឬការសម្លាប់មនុស្សក្នុងចំនួនកំណត់ណាមួយនោះ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាការសម្លាប់រង្គាលទេ[៦១៤]។

---

[៦០៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Blagojević *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៥៧២។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Seromba* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-66-A) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ១៨៩។

[៦១០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៣០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Seromba* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-66-A) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ១៨៩។

[៦១១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Brdjanin* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៣៨៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Krstić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥៩៨។

[៦១២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Ntakirutimana និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-96-10-A និង ICTR-96-17-A) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៥១៦។ រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង* *Stakić* សាលដីការបស់អង្គជំនុំជម្រះតុលាកាកំពូល ICTY (IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ២៦០។

[៦១៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Stakić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៦៤០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៥៧៣។

[៦១៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Vasiljević* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-32-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ២២៧។

៣៣៧. ការសម្លាប់រង្គាលគឺជាអំពើសកម្ម ឬអកម្ម ដែលមានលក្ខណៈរួម ជាជាងសំដៅចំពោះបុគ្គលជាក់លាក់ណាមួយ[៦១៥]។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានលក្ខខណ្ឌដែលតម្រូវថា ចារីមានចេតនាបំផ្លាញក្រុម ឬផ្នែកនៃក្រុមណាមួយដែលជនរងគ្រោះជាសមាជិកនៃក្រុមនោះឡើយ[៦១៦]។ ការដឹងអំពី "គម្រោងការដ៏ធំនៃការធ្វើមនុស្សឃាតរួមគ្នា" មិនមែនជាធាតុផ្សំនៃការសម្លាប់រង្គាលទេ[៦១៧]។

៣៣៨. ត្រូវតែបង្ហាញឲ្យឃើញថាចារីបានប្រព្រឹត្ត "ដោយចេតនាក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយ-ធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឲ្យមានការស្លាប់ដោយមានហេតុផលដឹងថាអំពើសកម្ម ឬអកម្មនោះមុខជាបង្កឲ្យមានការបាត់បង់ជីវិតមនុស្សជាច្រើន"[៦១៨]។

---

[៦១៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-32-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ២២៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៦៣៩។

[៦១៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-32-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ២២៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Musema* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-96-13-A) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ៣៦៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៦៣៩។

[៦១៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ២៥៩។

[៦១៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ២១៩១។ សាលក្រមដំបូងរបស់តុលាការ ICTR សម្រេចថា ការសម្លាប់បំផុតពូជ អាចរួមបញ្ចូលនូវអំពើសកម្ម ឬអកម្ម ដោយចេតនា ធ្វេសប្រហែស ឬមិនអើពើយ៉ាងជាក់ស្តែង : រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kayishema* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១៤៦។ ក្រោយមក តុលាការ ICTY សម្រេចថា ចេតនា មិនអាចជាចំណុចចាប់ផ្តើមមួយទាបជាងចំណុចចាប់ផ្តើម ដែលតម្រូវសម្រាប់ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ហើយដូច្នេះ ការបង្ហាញភស្តុតាង អំពីភាពធ្វេសប្រហែស ឬភាពមិនអើពើយ៉ាងជាក់ស្តែង គឺមិនគ្រប់គ្រាន់ដើម្បីឲ្យជនជាប់-ចោទទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់បំផុតពូជឡើយ : រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៦៤២។

## ២.៥.៣.២ សំអាងហេតុទាក់ទងនឹងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

៣៣៩. អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរស២១ និងស២៤ ត្រូវបានសម្លាប់ដោយបុគ្គលិកមន្ទីរស២១ តាមរយៈអំពើដោយចេតនា និងអំពើខុសច្បាប់នានានៅមន្ទីរស២១ (ទួលស្លែង) និងនៅជើងឯក នៅក្នុងអំឡុងពេលប្រតិបត្តិការមន្ទីរស២១ (ផ្នែក ២.៤.១)។ អង្គជំនុំ-យល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរស២១ និងស២៤ បានស្លាប់ដោយសារតែអំពើអកម្មដោយខុសច្បាប់ ដែលអាចជាហេតុនាំឱ្យមានការស្លាប់អ្នកជាប់ឃុំ និងដោយសារតែស្ថានភាពនៃការឃុំខ្លួន ដែលគេបានដាក់កំហិតទៅលើអ្នកជាប់ឃុំទាំងនោះ (ផ្នែក ២.៤.៥.១-២.៤.៥.៤)។

៣៤០. ដោយសារតែភាពមិនច្បាស់លាស់នៃកំណត់ត្រា អង្គជំនុំជម្រះយល់ឃើញថា តួលេខនៃអ្នកជាប់ឃុំដែលបានស្លាប់ និងត្រូវបានគេសម្លាប់មិនអាចកំណត់ចំនួនឱ្យបានច្បាស់លាស់ឡើយ។ តាមរយៈបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស២១ ដែលត្រូវបានកែសម្រួល អង្គជំនុំជម្រះអាចកំណត់បានថា ចំនួនអ្នកជាប់ឃុំមានមិនតិចជាង ១២.២៧២ នាក់នោះឡើយ[៦១៩]។

៣៤១. ដោយសារតែការស្លាប់មានវិសាលភាពធំធេង អង្គជំនុំជម្រះយល់ឃើញថា ការស្លាប់ និងការសម្លាប់ ដែលបានប្រព្រឹត្តឡើងដោយខុសច្បាប់ទៅលើអ្នកជាប់ឃុំនៅមន្ទីរស២១ទាំងមូល បង្កើតបានជាការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលផងដែរ។

---

[៦១៩] អង្គជំនុំជម្រះកត់សម្គាល់ថា បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួលមានឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ដែលរួចជីវិតពីការឃុំខ្លួននៅមន្ទីរស២១ ក្នុងចំណោមអ្នកជាប់ឃុំ ១២.២៧៣នាក់ ដែលមានឈ្មោះនៅក្នុងបញ្ជី ដែលអ្នកទាំងនោះត្រូវបានឃុំខ្លួន និងក្រោយមកត្រូវបានសម្លាប់ លើកលែងតែមនុស្សមួយចំនួនប៉ុណ្ណោះ។ *សូមមើល* "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល" ឯកសារ E68.1 លេខរៀង ១៥៨៣។ សូមមើលផងដែរ (ផ្នែក (២.៣.៣.៤.២) ។

### ២.៥.៣.៣ ការធ្វើឱ្យទៅជាទាសករ

៣៤២. ការហាមឃាត់នៃការធ្វើទាសភាពគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិយ៉ាងច្បាស់-លាស់[៦២០]។ ការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមនុស្ស[៦២១]។ សញ្ញាណនៃការធ្វើឱ្យទៅជាទាសកររួមមាន "ការគ្រប់គ្រងលើការដើរហើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងជារូបវន្តលើកន្លែងរស់នៅ ការគ្រប់-គ្រងលើផ្លូវចិត្ត ការចាត់វិធានការនានាដើម្បីទប់ស្កាត់ ឬរារាំងមិនឱ្យគេចខ្លួន ការប្រើកម្លាំង ការគំរាមកំហែងនឹងប្រើកម្លាំង ឬការបង្ខិតបង្ខំ រយៈពេលនៃការធ្វើជាទាសករ ការអះអាងជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យស្ថិតនៅក្រោមការប្រព្រឹត្តិយ៉ាងព្រៃផ្សៃ និងការរំលោភបំពាន ការគ្រប់គ្រងលើផ្លូវភេទ និងការធ្វើពលកម្មដោយបង្ខំ"[៦២២]។

៣៤៣. មិនចាំបាច់មានភស្តុតាងបង្ហាញថា ជនរងគ្រោះមិនបានយល់ព្រមធ្វើជាទាសករនោះទេ ពីព្រោះ ការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់ដោយការអនុវត្តអំណាចរបស់ចារី[៦២៣]។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាថាតើជនរងគ្រោះបានព្រមព្រៀង ឬមិនបានព្រមព្រៀងអាចពាក់ព័ន្ធក្នុងការ

---

[៦២០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៣៥៣។

[៦២១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១១៦។

[៦២២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១១៩។

[៦២៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២០។

កំណត់ថាតើចារីបានអនុវត្ត ឬមិនបានអនុវត្តអំណាចទាំងនេះលើជនរងគ្រោះដែរឬទេ[៦២៤]។ នៅក្នុងស្ថានភាពដែលមិនអាចបង្ហាញការយល់ព្រមបាន គេសន្មតថាពុំមានការយល់ព្រមឡើយ[៦២៥]។

៣៤៤. ការធ្វើការងារដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្តអាចជាការធ្វើឱ្យទៅជាទាសករ[៦២៦]។ អង្គជំនុំជម្រះសាលាដំបូង ICTY យល់ឃើញថា "អ្វីដែលត្រូវបង្ហាញគឺថា បុគ្គលពាក់ព័ន្ធមិនមានជម្រើសច្បាស់លាស់ ថាតើពួកគាត់ត្រូវធ្វើការងារ ឬមិនត្រូវធ្វើការងារនោះទេ"[៦២៧]។ អង្គជំនុំជម្រះត្រូវសម្រេចថាតើ ការធ្វើពលកម្មត្រូវបានបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្តដោយផ្អែកលើមូលដ្ឋាននៃកត្តាដែលទទួលស្គាល់ដូចបានគូសបញ្ជាក់ខាងលើ[៦២៨]។ ធាតុផ្សំនៃបទល្មើសនៃការធ្វើឱ្យទៅជាទាសករអាចនឹងត្រូវបានបំពេញដោយមិនចាំបាច់មានភស្តុតាងនៃការធ្វើបាបបន្ថែមនោះទេ[៦២៩]។

---

[៦២៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២០។

[៦២៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២០។

[៦២៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២០២។

[៦២៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ៣៥៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២០២។

[៦២៨] សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២០២។

[៦២៩] រឿងក្តី *Pohl និងអ្នកផ្សេងទៀត* សាលក្រមចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧ បោះពុម្ពឡើងវិញ នៅក្នុងការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា *Nuremberg ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* ភាគ៥ ទំព័រ៩៧០ *ដកស្រង់នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២៣។
រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២០៣។

៣៤៥. ត្រូវតែមានការបង្ហាញថា ចារីបានប្រើប្រាស់ដោយចេតនានូវអំណាចមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលម្នាក់ទៀត[៦៣០]។

### ២.៥.៣.៤ សំអាងហេតុទាក់ទងនឹងការធ្វើឲ្យទៅជាទាសករ

៣៤៦. អង្គជំនុំជម្រះយល់ឃើញថា បុគ្គលិកមន្ទីរស២១ បានអនុវត្តអំណាចដោយចេតនា និងគ្រប់គ្រងទាំងស្រុងលើអ្នកជាប់ឃុំនៅស២៤ និងក្រុមអ្នកជាប់ឃុំមួយចំនួនទៀតនៅក្នុងមន្ទីរស២១ (ទួលស្លែង)។ អ្នកជាប់ឃុំទាំងនេះ មិនមានសិទ្ធិបដិសេធមិនធ្វើការងារដែលគេចាត់តាំងឲ្យធ្វើនោះទេ និងមិនបានយល់ព្រមជាមួយនឹងលក្ខខណ្ឌនៃការឃុំខ្លួនពួកគេនោះទេ (ផ្នែក២.៤.២)។ ហេតុដូច្នេះអង្គជំនុំជម្រះយល់-ឃើញថា ពលកម្មដោយបង្ខំ ឬមិនមានការស្ម័គ្រចិត្តដែលបូករួមជាមួយនឹងការឃុំខ្លួនរបស់ពួកគេ បង្កើតបានជាការធ្វើឲ្យទៅជាទាសករ។

### ២.៥.៣.៥ ការដាក់ក្នុងមន្ទីរឃុំឃាំង

៣៤៧. ការដាក់ក្នុងមន្ទីរឃុំឃាំង សំដៅទៅលើការដកហូតសេរីភាពរបស់បុគ្គលតាមទំនើងចិត្តដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់[៦៣១]។ ឋានៈទំនៀមទម្លាប់នៃការហាមឃាត់ការដាក់ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្តក្រោមច្បាប់អន្តរជាតិ កើតចេញដំបូងពីច្បាប់សង្គ្រាម និងត្រូវបានគាំទ្រដោយលិខិតុ-បករណ៍សិទ្ធិមនុស្ស[៦៣២]។

---

[៦៣០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១១៦។

[៦៣១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Simić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-9-T) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៦៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៣០២។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៣។

[៦៣២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១០៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៩៩-៣០០។

៣៤៨. ការដកហូតសេរីភាពនៅពេលដំបូងនឹងក្លាយជាអំពើតាមទំនើងចិត្ត ប្រសិនបើគ្មានមូលដ្ឋាន-ច្បាប់ក្នុងការធ្វើយុត្តិកម្មដកហូតសេរីភាពតាំងពីដំបូង[៦៣៣]។ ប្រសិនបើ មានការពឹងផ្អែកលើច្បាប់ជាតិជាយុត្តិកម្មនៅក្នុងបញ្ហានេះ ត្រូវបង្ហាញថា បទប្បញ្ញត្តិច្បាប់ជាតិដែលពាក់ព័ន្ធ មិនបានរំលោភបំពានច្បាប់អន្តរជាតិទេ[៦៣៤]។ ប្រសិនបើ មូលដ្ឋានច្បាប់ចំពោះការដកហូតពីដំបូងពិតជាមានអត្ថិភាព មូលដ្ឋាន ច្បាប់នេះត្រូវតែបន្តមានពេញរយៈពេលនៃការដាក់ក្នុងមន្ទីរឃុំឃាំង[៦៣៥]។ នៅពេលដែលមូលដ្ឋានស្រប ច្បាប់នៃការដាក់ក្នុងមន្ទីរឃុំឃាំងឈប់យកមកអនុវត្ត ដូចនេះការបន្តដាក់ក្នុងមន្ទីរឃុំឃាំងអាចនឹងត្រូវចាត់ទុកថាជាអំពើតាមទំនើងចិត្ត[៦៣៦]។

៣៤៩. មិនមែនរាល់ការរំលោភបំពានបន្តិចបន្តួចនៃសិទ្ធិសេរីភាព បង្កើតជាធាតុផ្សំសម្ភារៈនៃការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ការដកហូតសិទ្ធិសេរីភាពត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មនានា ដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក[៦៣៧]។

---

[៦៣៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៣-១១៤។

[៦៣៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ntagerura* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-99-46-T) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ៧០២។

[៦៣៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៤។

[៦៣៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៤។

[៦៣៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ntagerura និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-99-46-T) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ៧០២។ សំអាងហេតុនេះ ផ្ទុយជាមួយនឹងសាលក្រមលើកមុនលើរឿងក្តី Krnojelac ដែលអង្គជំនុំជម្រះសាលាដំបូង ICTY សម្រេចថា "ទម្រង់ណាមួយនៃការដកហូតសេរីភាពរូបវន្តតាមតែអំពើចិត្ត ពីបុគ្គលណាម្នាក់ អាចចាត់ទុកថាជាការដាក់ក្នុងមន្ទីរឃុំឃាំង អនុលោមតាមមាត្រា៥(ង) នៃច្បាប់លក្ខន្តិកៈ [ICTY] ដរាបណា លក្ខខណ្ឌតម្រូវផ្សេងៗទៀតនៃបទឧក្រិដ្ឋ ត្រូវបានបំពេញ"។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង*

00573536



៣៥០. គេត្រូវតែបង្ហាញថា ចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬចារីបានប្រព្រឹត្តដោយការដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឲ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល[៦៣៨]។

២.៥.៣.៦ សំអាងហេតុទាក់ទងនឹងការដាក់ក្នុងមន្ទីរឃុំឃាំង

៣៥១. អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរស២១ ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងដោយចេតនា និងដោយបំពាន ដោយគ្មានមូលដ្ឋានច្បាប់ឡើយ។ ការដែលគ្មានប្រព័ន្ធតុលាការ ឬប្រព័ន្ធច្បាប់សោះនោះ គឺជាហេតុធ្វើឲ្យអ្នកទាំងឡាយដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងមិនអាចទទួលបាននូវការធានាផ្នែកនីតិវិធី ដែលអាចឲ្យពួកគេជំទាស់ទៅនឹងការចាប់ខ្លួន ការឃុំខ្លួន និងជាចុងក្រោយត្រូវសម្លាប់ដោយចៀសមិនផុតនោះទេ (ផ្នែក ២.៤.៣)។ ការយកអ្នកជាប់ឃុំជាច្រើនដាក់ក្នុងមន្ទីរឃុំឃាំង គឺជាការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិសេរីភាពរបស់អ្នកទាំងនោះ ដែលទំហំនៃភាពធ្ងន់ធ្ងររបស់វាស្រដៀង-គ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀតដែរ។

២.៥.៣.៧ ការធ្វើទារុណកម្ម

៣៥២. ការហាមឃាត់ចំពោះការធ្វើទារុណកម្ម បានទទួលឋានៈជា ច្បាប់ចាប់បង្ខំ ឬជាគោលការណ៍ដែលគ្មានអ្នកណាម្នាក់អាចគេចបាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៦៣៩]។ ដូច្នេះ ការផ្តល់សិទ្ធិអំណាចក្នុងការធ្វើទារុណកម្មតាមរយៈនីតិប្បញ្ញត្តិ រដ្ឋបាល ឬតុលាការ គឺជាទង្វើមិនអាចកើតមាននោះទេ[៦៤០]។

---

*Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១២។

[៦៣៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Simić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-9-T) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៦៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១១៥។

[៦៣៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៥១-១៥៣។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៨២។

៣៥៣. បទឧក្រិដ្ឋនៃការធ្វើទារុណកម្មមានចែង និងកំណត់និយមន័យ ដោយលិខិតុបករណ៍អន្តរជាតិជាច្រើន រួមមាន សេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៧៥ ស្តីពីការធ្វើទារុណកម្មត្រូវបានអនុម័តជាឯកច្ឆន្ទ[៦៤១] និងអនុសញ្ញាឆ្នាំ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្ម[៦៤២]។ និយមន័យនៅក្នុងអនុសញ្ញាឆ្នាំ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្ម[៦៤៣] ដែលឆ្លុះបញ្ចាំងអំពីសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៧៥ ស្តីពីការធ្វើទារុណកម្មត្រូវបានទទួលយកដោយតុលាការ ICTY ថាជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីពេលចាប់ផ្តើមទទួលយកអនុសញ្ញានេះដំបូងមកម្ល៉េះ[៦៤៤]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់និយមន័យនេះត្រូវបានទទួលយកជាទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។

---

[៦៤០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៥៥-១៥៦។

[៦៤១] សេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបមិនឱ្យទទួលរងនូវការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តិដ៏ឃោរឃៅ បន្ទាបបន្ថោក ឬអមនុស្សធម៌ផ្សេងៗទៀត សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 3452 (XXX) ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៥។

[៦៤២] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤, 1465 UNTS 85។ *សូមមើលផងដែរ* សេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 217 (III) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ មាត្រា៥។

[៦៤៣] សាលដីកាមុនៗក្នុងរឿងក្តី Akayesu និង Furundzija បានសម្រេចពីលើកមុនថា យ៉ាងហោចណាស់ជនដែលបានជាប់ទាក់ទងនឹងអំពើសកម្ម ឬ អកម្ម ត្រូវតែជាមន្ត្រីសាធារណៈ ឬកំពុងបំពេញកិច្ចក្នុងស្ថាប័នមិនឯកជនណាមួយ៖ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Furundzija សាលដីកាបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-17/1-A) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១១១។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៩៣។

[៦៤៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៥៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១៤៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-17/1-A) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១១១។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលក្រមរបស់

៣៥៤. ការធ្វើទារុណកម្ម រួមមាន ការបង្កឲ្យមានការឈឺចាប់ ឬរងទុក្ខធ្ងន់ធ្ងរលើរាងកាយ ឬស្មារតី ដោយអំពើសកម្ម ឬអកម្ម[៦៤៥]។

៣៥៥. ដើម្បីកំណត់អំពីអំពើសកម្ម ឬអកម្ម គឺជាអំពើធ្វើឲ្យឈឺចាប់ ឬរងទុក្ខធ្ងន់ធ្ងរ នោះអង្គជំនុំជម្រះត្រូវពិចារណាកត្តាសត្យានុម័ត និងកត្តាអត្តនោម័តិទាំងអស់[៦៤៦]។ កត្តាសត្យានុម័ត រួមមានការបង្កព្យសនកម្មធ្ងន់ធ្ងរ។ លក្ខណៈវិនិច្ឆ័យអត្តនោម័តិ អាចរួមមាន អាយុ ភេទ ស្ថានភាពសុខភាពរបស់ជនរងគ្រោះ ឬផលប៉ះពាល់ផ្នែករាងកាយ ឬស្មារតី ពីការប្រព្រឹត្តិលើជនរងគ្រោះជាក់លាក់[៦៤៧]។ លើសពីនេះ ប្រភេទ និងបរិបទនៃការបង្កការឈឺចាប់ ការគិតទុកជាមុន និងការបង្កើតនូវការធ្វើបាបលក្ខខណ្ឌរាងកាយរបស់ជនរងគ្រោះ របៀប និងវិធីសាស្ត្រដែលត្រូវបានប្រើ និងភាពទន់ខ្សោយរបស់ជនរងគ្រោះត្រូវបានពិចារណាជាកត្តាពាក់ព័ន្ធ[៦៤៨]។ ផលវិបាកនៃអំពើសកម្ម ឬអកម្មមិនចាំបាច់មើលឃើញនៅលើជនរងគ្រោះ ទើបចាត់ទុកជាការធ្វើទារុណកម្មនោះទេ[៦៤៩]។ គ្មានលក្ខខណ្ឌដែលតម្រូវថា

---

អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៦០-១៦១។ *សូមមើលផងដែរ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៦-៦៧។

[៦៤៥] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៤២។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* Ntagerura *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-99-46-T) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ៧០៣។

[៦៤៦] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៤៣។

[៦៤៧] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៤៣។

[៦៤៨] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៨២។

[៦៤៩] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៥០។

ការរងរបួសត្រូវតែអចិន្ត្រៃយ៍ឡើយ[៦៥០]។ លើសពីនេះមិនមានចំណាត់ថ្នាក់ច្បាស់លាស់ចំពោះអំពើនានាដែលអាចចាត់ទុកថាជាការធ្វើទារុណកម្មទេ[៦៥១]។ អំពើនានាដែលចាត់ទុកថាមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ជាការធ្វើទារុណកម្មរួមមាន ការវាយដំ ការរំលោភបំពានលើផ្លូវភេទ ការបដិសេធមិនឱ្យដេក មិនឱ្យចំណីអាហារ គ្មានអនាម័យ និងជំនួយផ្នែកពេទ្យ មានរយៈពេលវែងព្រមទាំងការគំរាមធ្វើទារុណកម្ម ការគំរាមរំលោភលើផ្លូវភេទ ឬការគំរាមសម្លាប់សាច់ញាតិ[៦៥២]។ ប្រភេទនៃអំពើមួយចំនួន ត្រូវបានចាត់ទុកថាជាអំពើដែលនឹងនាំឱ្យមានការឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ[៦៥៣]។ អំពើទាំងនេះរួមមាន ការរំលោភលើផ្លូវភេទ[៦៥៤] និងការធ្វើឱ្យមានកាយវិកលកម្ម[៦៥៥]។

៣៥៦. ការធ្វើទារុណកម្ម តម្រូវថា អំពើសកម្ម ឬអកម្ម ត្រូវតែបង្កឡើងដើម្បីសម្រេចឱ្យបានលទ្ធផល ឬគោលបំណងជាក់លាក់មួយ[៦៥៦]។ គោលបំណងនៃការធ្វើទារុណកម្ម គឺដើម្បីទទួលព័ត៌មាន ឬ

---

[៦៥០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៤៨។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brdjanin* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-99-36-T) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៤៨៤។

[៦៥១] សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៦៩។

[៦៥២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៦៧។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៥១។

[៦៥៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៥០។

[៦៥៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brdjanin* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ៤៨៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៥០។

[៦៥៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៤៤។

[៦៥៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៨០។ អនុលោមតាមច្បាប់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនមានលក្ខខណ្ឌ

ចម្លើយសារភាព ឬដាក់ទណ្ឌកម្ម គំរាមកំហែង ឬបង្ខិតបង្ខំជនរងគ្រោះ ឬតតីយជន ឬរើសអើង ផ្អែកលើមូលហេតុណាមួយប្រឆាំងនឹងជនរងគ្រោះ ឬតតីយជន[៦៥៧]។ គោលបំណងទាំងនេះមិនមែនមានក្នុងច្បាប់ទំនៀមទម្លាប់តែប៉ុណ្ណឹងនោះទេ ប៉ុន្តែវាគ្រាន់តែជាតំណាងខ្លះៗប៉ុណ្ណោះ[៦៥៨]។ គ្មានលក្ខខណ្ឌតម្រូវថាអំពើត្រូវបានប្រព្រឹត្តយ៉ាងច្បាស់សម្រាប់គោលបំណងជាក់លាក់ណាមួយនោះឡើយ[៦៥៩]។ គោលបំណងជាក់លាក់ណាមួយ ត្រូវតែ "ជាផ្នែកនៃការលើកទឹកចិត្តចំពោះការប្រព្រឹត្តិរបស់ខ្លួន ហើយវាមិនចាំបាច់ជាគោលបំណងច្បាស់លាស់ ឬតែមួយនោះទេ"[៦៦០]។

៣៥៧. អនុសញ្ញាឆ្នាំ១៩៨៤ ប្រឆាំងនឹងការធ្វើទារុណកម្មតម្រូវថា អំពើទារុណកម្មត្រូវបានប្រព្រឹត្តដោយមានការញុះញង់ពីមន្ត្រីសាធារណៈ ឬ"បុគ្គលផ្សេងទៀតដែលបានបំពេញភារកិច្ចក្នុងសមត្ថកិច្ចផ្លូវការ" ឬដោយមានការយល់ព្រម ឬស្រុះស្រួលពីបុគ្គលនោះ[៦៦១]។ តុលាការ ICTY បានបញ្ជាក់

---

តម្រូវឡើយថា ចារីបានប្រព្រឹត្តដោយមានគោលបំណងជាក់លាក់ណាមួយក៏ដោយ៖ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ (ចូលជាធរមានថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២) 2187 UNTS 90 មាត្រា៧(១)(ច), (៧)(២)(ង)។

[៦៥៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T និង IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៨៥។ ដូច្នេះ គោលបំណងជាក់លាក់មិនចាំបាច់ផ្ទុយនឹងច្បាប់ឡើយ ដរាបណាវិធីសាស្ត្រត្រឹមត្រូវ ត្រូវបានប្រើប្រាស់ដើម្បីសម្រេចបាននូវគោលបំណងនោះ។ សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Krnojelac សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៨៤។ គោលបំណងជាក់លាក់នៃការបង្ខិតបង្ខំលើបុគ្គល ឬតតីយជន "សម្រាប់ហេតុផលណាមួយដោយផ្អែកទៅលើការរើសអើងគ្រប់ប្រភេទ" មាននៅក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឆ្នាំ១៩៨៤ ដោយឡែកវាមិនមាននៅក្នុងសេចក្តីប្រកាសមហាសន្និបាតឆ្នាំ១៩៧៥ ឡើយ៖ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ 1465 UNTS 85 មាត្រា១(១)។

[៦៥៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៧២។

[៦៥៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T និង IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៨៦។

[៦៦០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T និង IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៨៦។

[៦៦១] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ 1465 UNTS 85 មាត្រា១(១)។

យ៉ាងច្បាស់ថា ក្នុងពេលបច្ចុប្បន្ន គ្មានលក្ខខណ្ឌតាមច្បាប់មនុស្សធម៌អន្តរជាតិចំពោះការពាក់ព័ន្ធនៃមន្ត្រីរដ្ឋនៅក្នុងអំពើនានា ដែលចាត់ទុកថាជាការធ្វើទារុណកម្មទេ[៦៦២] បើទោះជាមានអង្គហេតុដែលថារីបានបំពេញភារកិច្ចក្នុងសមត្ថកិច្ចផ្លូវការអាចជាស្ថានទម្ងន់ដែលពាក់ព័ន្ធនៅក្នុងការផ្តន្ទាទោសក៏ដោយ[៦៦៣]។ ប៉ុន្តែអង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌបែបនេះមិនអាចទាន់ចាត់ទុកថាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥ នៅឡើយទេ។

---

[៦៦២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T និង IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៩៦។ កត់សម្គាល់នូវគោលបំណងខុសគ្នានៃច្បាប់សិទ្ធិមនុស្ស (ជាការបញ្ឈប់ការប្រព្រឹត្តិខុសឆ្គងផ្ទុយនឹងច្បាប់របស់រដ្ឋ) និងច្បាប់មនុស្សធម៌ (ជាមធ្យោបាយក្នុងការកាត់បន្ថយហិង្សាក្នុងអំឡុងអរិភាព) អង្គជំនុំជម្រះសម្រេចថា មិនមានលក្ខខណ្ឌតម្រូវក្រោមច្បាប់មនុស្សធម៌អន្តរជាតិឡើយ ចំពោះការជាប់ពាក់ព័ន្ធរបស់មន្ត្រីរដ្ឋ ក្នុងអំពើដែលចាត់ទុកជាការធ្វើទារុណកម្ម ទោះបីជា លក្ខខណ្ឌនេះអាចត្រូវបានតម្រូវឲ្យមានក្រោមច្បាប់សិទ្ធិមនុស្សក៏ដោយ។ សូមមើល កថាខណ្ឌ៤៧០។ អង្គជំនុំជម្រះ តុលាការកំពូលលើរឿងក្តី Kunarac បានអះអាងអំពីទស្សនៈនេះ ដោយបានបញ្ជាក់ថា "និយមន័យនៅក្នុងអនុសញ្ញា ប្រឆាំងនឹងការធ្វើទារុណកម្មឆ្លុះបញ្ចាំងចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដរាបណាកាតព្វកិច្ចរបស់រដ្ឋមានការជាប់ពាក់ព័ន្ធ" ប៉ុន្តែមិនឆ្លុះបញ្ចាំងទាំងស្រុងចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ទាក់ទងទៅនិងអត្ថន័យនៃបទល្មើស ធ្វើទារុណកម្មជាទូទៅ : *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៤៧។ សាលដីកាមុនៗក្នុងរឿងក្តី Akayesu និង Furundzija បានសម្រេចពីលើកមុនថា យ៉ាងហោចណាស់ជនដែលបានជាប់ទាក់ទងនឹង អំពើសកម្ម ឬ អកម្ម ត្រូវតែជាមន្ត្រីសាធារណៈ ឬកំពុងបំពេញកិច្ចក្នុងស្ថាប័នមិនឯកជនណាមួយ៖ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Furundzija* សាលដីកាបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-17/1-A) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៩៣។

[៦៦៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T និង IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤៩៤។

៣៥៨. ការឈឺចាប់ និងការរងទុក្ខដែលមានកម្រិតស្មើនឹងការធ្វើទារុណកម្ម ត្រូវតែប្រព្រឹត្តដោយចេតនា[៦៦៤]។

## ២.៥.៣.៨ សំអាងហេតុទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត

៣៥៩. អង្គជំនុំជម្រះយល់ឃើញថា បុគ្គលិកមន្ទីរស២១ បានប្រើប្រាស់បច្ចេកទេសសួរចម្លើយទៅលើអ្នកជាប់ឃុំ ក្នុងគោលបំណងធ្វើឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ (ផ្នែក ២.៤.៤១.១)។ បច្ចេកទេសទាំងនេះត្រូវបានអនុវត្តក្នុងស្ថានភាពដែលពោរពេញទៅដោយការភ័យខ្លាចយ៉ាងខ្លាំង ដែលជាទូទៅមានការគំរាមកំហែង និងធ្វើឱ្យអ្នកជាប់ឃុំមានការឈឺចាប់ធ្ងន់ធ្ងរ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ ផ្អែកទៅលើតួនាទីនៅក្នុងបរិធានរដ្ឋាភិបាល អង្គជំនុំជម្រះយល់ឃើញថា អ្នកសួរចម្លើយនៅមន្ទីរស២១ និងបុគ្គលិកស២៤ ដែលបានប្រព្រឹត្តនូវការធ្វើទារុណកម្ម គឺបានបំពេញតួនាទីជាផ្លូវការរបស់ពួកគេតែប៉ុណ្ណោះ។

៣៦០. អង្គជំនុំជម្រះយល់ឃើញថា បច្ចេកទេសសួរចម្លើយដែលត្រូវបានអនុវត្តនៅមន្ទីរស២១ បានបង្កឱ្យមានរបួស និងការឈឺចាប់ធ្ងន់ធ្ងរ ទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានចម្លើយសារភាព ឬក្នុងគោលបំណងដាក់ទណ្ឌកម្ម ហើយអំពើទាំងនេះបង្កើតបានជាបទល្មើសការធ្វើទារុណកម្ម។ បច្ចេកទេសទាំងនោះរួមមាន ការវាយ ការឆក់ខ្សែភ្លើង ការធ្វើឱ្យថប់ដង្ហើមដោយច្រកក្បាលក្នុងថង់ប្លាស្ទិក ការបន្តក់ទឹកចូលក្នុងច្រមុះ ការចាក់ទម្លុះក្រចក ការចាក់ម្ជុលចូលក្នុងសាច់ក្រោមក្រចក ឬការដកក្រចកដៃ និងក្រចកជើង ការអុជនឹងភ្លើងបារី ការបង្ខំឱ្យអ្នកជាប់-ឃុំថ្វាយបង្គំរូបភ្លើ ឬវត្ថុផ្សេងៗ ការបង្ខំឱ្យស៊ីលាមក និងការបង្ខំឱ្យផឹកទឹកនោម ការគំរាមធ្វើទារុណកម្ម ឬសម្លាប់ដោយផ្ទាល់ ឬដោយប្រយោលចំពោះអ្នកជាប់ឃុំ ឬសមាជិកគ្រួសាររបស់ពួកគេ ការប្រើភាសាប្រមាថមើលងាយ ការជ្រមុជក្បាលអ្នកជាប់ឃុំទៅក្នុងទឹកពាង និងការចងដៃអ្នកជាប់ឃុំទៅក្រោយរួចព្យួរឡើងលើ និងការរំលោភលើផ្លូវភេទ។ អង្គជំនុំជម្រះយល់ឃើញទៀតថា បច្ចេកទេស

---

[៦៦៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១៣០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៦២។

ដែលគេបានប្រើប្រាស់ដូចបានរៀបរាប់ខាងលើនេះគឺមិនទាន់អស់នៅឡើយទេ ហើយអង្គជំនុំជម្រះយល់ឃើញថា អាចមានការអនុវត្តបច្ចេកទេសធ្វើទារុណកម្មផ្សេងៗជាច្រើនទៀត។

២.៥.៣.៩ ការរំលោភលើផ្លូវភេទ

៣៦១. ការរំលោភលើផ្លូវភេទត្រូវបានហាមឃាត់ជាយូរយារណាស់មកហើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយត្រូវបានចាត់ទុកជា"ការឈឺចាប់មួយក្នុងចំណោមការឈឺចាប់បំផុតដែលមនុស្សម្នាក់អាចប្រព្រឹត្តទៅលើមនុស្សម្នាក់ទៀត"[៦៦៥]។

៣៦២. ការរំលោភលើផ្លូវភេទគឺជាការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារីនៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[៦៦៦]។

---

[៦៦៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Kunarac* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-23-T& IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៦៥៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Sesay* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៤៤។ *សូមមើល ឧទាហរណ៍* មាត្រាII (១)(គ) នៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៤៥) ដែលត្រូវបានបោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង លេខ I ទំព័រ៧*។ មាត្រា៤៤ នៃ*សេចក្តីណែនាំចំពោះអ្នកគ្រប់គ្រងកងទ័ពសហរដ្ឋអាមេរិកនៅសមរភូមិ* (Lieber Code) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៨៦៣។ មាត្រា២៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[៦៦៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Kunarac* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 និង IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Semanza* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៤៤-៣៤៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Sesay* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៤៥-១៤៦។ និយមន័យនៃទស្សនទានម្យ៉ាងទៀតត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ICTR នៅក្នុងរឿងក្តី *Akayesu* ជា "ការឈ្លានពានរាងកាយនៃផ្លូវភេទដែលប្រព្រឹត្តឡើងទៅលើបុគ្គលម្នាក់ ក្រោមកាលៈទេសៈបង្ខំ"៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Akayesu* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៩៨។ ទោះបី

៣៦៣. ករណីភាគច្រើននៃការរំលោភលើផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងដោយបង្ខំដែលផ្ទុយពីឆន្ទៈពិតប្រាកដរបស់ជនរងគ្រោះ[៦៦៧]។ ការមិនយល់ព្រមអាចត្រូវបានបង្ហាញតាមរយៈភស្តុតាងថាមានការប្រើកម្លាំង។ ការប្រើកម្លាំង ឬការគំរាមកំហែងថានឹងប្រើកម្លាំងរបស់ចារីមិនមែនជាធាតុផ្សំនៃបទរំលោភតែមួយមុខនោះទេ ហើយក៏មិនមានលក្ខខណ្ឌតម្រូវសម្រាប់ការតតាំងពីជនរងគ្រោះដែរ (មានកត្តាជាច្រើនក្រៅពីការប្រើកម្លាំងផ្សេងទៀតដែលជាអំពើបញ្ចូលអង្គជាតដោយមិនមានការយល់ព្រម)[៦៦៨]។

៣៦៤. ស្ថានភាពមនុស្សដែលជិតដាមជាប់នឹងជនរងគ្រោះដោយការរំលោភលើផ្លូវភេទនៅក្នុងសង្គមមួយចំនួន មានការពិបាកក្នុងការបង្ហាញនូវភស្តុតាងនៃឧក្រិដ្ឋកម្មនេះ។ យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់ថា គេអាចប្រើប្រាស់ភស្តុតាងប្រយោលដើម្បីបង្ហាញថាមានការរំលោភលើផ្លូវភេទ[៦៦៩]។

---

ជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះសាលាដំបូង ICTY ក្នុងរឿងក្តី *Furundžija* បានសម្រេចថា និយមន័យដ៏ច្បាស់លាស់ជាងនេះ នឹងកាន់តែត្រូវគ្នាជាមួយនឹង "គោលការណ៍ច្បាប់ព្រហ្មទណ្ឌស្តីពីភាពជាក់លាក់" ហើយដូច្នេះបានអនុម័តនិយមន័យ ដែលមានលក្ខណៈបច្ចេកទេសជាងនេះ ដែលត្រូវបានយកមកប្រើនៅខាងលើផងដែរ៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundžija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1-T) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៧៧។ ការកំណត់និយមន័យនៅក្នុងរឿងក្តី *Furundžija* ត្រូវបានយកមកប្រើជារឿយៗនិងត្រូវបានអនុម័តដោយអង្គជំនុំជម្រះតុលាការកំពូល ICTY ។ អង្គជំនុំជម្រះសាលាដំបូង ICTR ក្នុងរឿងក្តី *Muhimana* បានយល់ឃើញថា ការកំណត់និយមន័យទាំងពីរនេះ គឺ "មិនខុសគ្នាច្រើន ឬមិនមែនមិនដូចគ្នានោះទេ នៅក្នុងការអនុវត្តការកំណត់និយមន័យទាំងពីរនេះ"៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muhimana* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-95-1B-T) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ កថាខណ្ឌ៥៥០។

[៦៦៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៣០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ១៧៨។

[៦៦៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២៨-១២៩។

[៦៦៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muhimana* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-95-1B-A) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ៤៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-01-64-A) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១១៥។ រឿងក្តី *រដ្ឋអាជ្ញា*

៣៦៥. លក្ខខណ្ឌអត្តនោម័តិនៃការរំលោភលើផ្លូវភេទគឺថា ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការបញ្ចូលអង្គជាត និងដឹងថា ការបញ្ចូលអង្គជាត កើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ"[៦៧០]។

### ២.៥.៣.១០ សំអាងហេតុទាក់ទងនឹងការរំលោភលើផ្លូវភេទ ដែលជាទម្រង់នៃការធ្វើទារុណកម្ម

៣៦៦. ទោះបីជាបទល្មើសការរំលោភលើផ្លូវភេទ គឺជាបទល្មើសដាច់ដោយឡែក និងត្រូវបានគេទទួលស្គាល់ទាំងនៅក្នុងច្បាប់ អ.វ.ត.ក និងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏មិនមានការជំទាស់នោះទេ ដែលថាការរំលោភលើផ្លូវភេទ អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលដែលធាតុផ្សំផ្សេងៗទៀតនៃបទល្មើសការធ្វើទារុណកម្មត្រូវបានបំពេញ (ផ្នែក ២.៥.៣.៧)។ អង្គជំនុំជម្រះយល់ឃើញថា អំពើដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដែលបង្កើតបានជាការរំលោភលើផ្លូវភេទ គឺវាបានបំពេញយ៉ាងច្បាស់នូវធាតុផ្សំផ្លូវច្បាប់ទាំងបទល្មើសការរំលោភលើផ្លូវភេទ និងការធ្វើទារុណកម្ម[៦៧១]។ លើសពីនេះទៀត អង្គជំនុំជម្រះ ក៏បានវាយតម្លៃទៅលើភស្តុតាងដែលអាចជឿជាក់បាន ដើម្បីគាំទ្រចំពោះការចោទប្រកាន់នេះផងដែរ (ផ្នែក ២.៤.៤.១.១)។ អង្គជំនុំជម្រះយល់ឃើញថា ករណីការរំលោភលើផ្លូវភេទនេះ បង្កើតឲ្យមាននូវភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្មរយៈពេលយូរ និងមានភាពព្រៃផ្សៃមុនពេលដែលគាត់ត្រូវបានគេយកទៅសម្លាប់ ដូច្នេះចរឹតលក្ខណៈនៃអំពើនេះបង្កើតបានជាបទល្មើសការធ្វើទារុណកម្ម ។

---

*គទល់នឹង Sesay* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៤៥។

[៦៧០] រឿងក្តី *រដ្ឋអាជ្ញា គទល់នឹង Kunarac* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១២៧-១២៨។ រឿងក្តី *រដ្ឋអាជ្ញា គទល់នឹង Bagosora* និងអ្នកផ្សេងទៀត សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ២២០០។

[៦៧១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៣៦, ១៣៧។

### ២.៥.៣.១១ អំពើអមនុស្សធម៌ផ្សេងៗទៀត

៣៦៧. អំពើអមនុស្សធម៌ផ្សេងៗទៀត រួមមានបទល្មើសដែលនៅសេសសល់ផ្សេងៗទៀត ដែលមានបំណងចាត់ទុកអំពើនោះថាជាបទល្មើស នៅពេលដែលអំពើនោះបំពេញលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សនឹងមនុស្សជាតិ ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌតម្រូវនៃបទល្មើសមួយក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតឡើយ[៦៧២]។ អំពើសកម្ម ឬអកម្មត្រូវតែមាន "ស្ថានទម្ងន់ស្រដៀងគ្នាគ្រប់គ្រាន់ទៅនឹងបទល្មើសជាក់លាក់ផ្សេងៗទៀត" ដើម្បីចាត់ទុកថាជាអំពើអមនុស្សធម៌[៦៧៣]។ ឋានៈទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មនេះក៏មានចែងយ៉ាងច្បាស់ផងដែរ[៦៧៤]។

៣៦៨. ដើម្បីបង្កើតបានជាអំពើអមនុស្សធម៌មួយ វាត្រូវតែបង្ហាញថា ជនរងគ្រោះបានទទួលរងព្យសនកម្មលើរូបរាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយការឈឺចាប់នេះគឺជាលទ្ធផលនៃអំពើសកម្ម ឬអកម្មរបស់ចារី[៦៧៥]។

៣៦៩. ភាពធ្ងន់ធ្ងរនៃអំពើ គឺត្រូវបានធ្វើការវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាទៅលើកាលៈទេសៈបុគ្គលនីមួយៗ[៦៧៦]។ កាលៈទេសៈទាំងនេះអាចរួមបញ្ចូល "ប្រភេទនៃអំពើសកម្ម ឬ

---

[៦៧២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១១៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ២២១៨។

[៦៧៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Naletilić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-34-T) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ២៤៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Niyitegeka* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-14-T) ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៤៦០។

[៦៧៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥១៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-16-A) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ១៨៣។

[៦៧៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល* ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១១៧។

អកម្ម បរិបទដែលវាបានកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ រាប់បញ្ចូលទាំង អាយុ ភេទ និងសុខភាព ព្រមទាំងផលប៉ះពាល់ផ្នែកសីលធម៌ ផ្នែកផ្លូវកាយ និងផ្លូវចិត្តនៃអំពើនោះមកលើជនរងគ្រោះ"[៦៧៧]។ មិនមានលក្ខខណ្ឌតម្រូវថា ការរងទុក្ខនោះមានផលប៉ះពាល់រយៈពេលយូរឡើយទោះបីជាការរងទុក្ខនេះអាចពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចអំពីភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[៦៧៨]។

៣៧០. ឧទាហរណ៍នៃអំពើអមនុស្សធម៌ ដែលត្រូវបានរកឃើញថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រាប់បញ្ចូលទាំងការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងការជម្លៀសដោយបង្ខំ[៦៧៩] ព្យសនកម្មលើរូបរាង

---

[៦៧៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាកាកំពូល ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១១៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kayishema និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ១៤៨-១៥១។

[៦៧៧] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ១៦៥។

[៦៧៨] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ១៦៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦២៧។

[៦៧៩] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦២៩-៦៣០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥២៣។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-24-T) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៧២៣។

កាយធ្ងន់ធ្ងរ[៦៨០] ការឃុំខ្លួនក្នុងស្ថានភាពរស់នៅដែលមិនអាចទទួលយកបាន និងយ៉ាងព្រៃផ្សៃ[៦៨១] ព្រម-ទាំងការវាយដំ និងអំពើហិង្សាផ្សេងៗទៀត[៦៨២]។

៣៧១. លក្ខខណ្ឌអត្តនោម័តិដើម្បីបង្កជាអំពើអមនុស្សធម៌ត្រូវបានបំពេញនៅពេលដែលចារីមានចេតនាបង្កឲ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ឬប្រព្រឹត្តការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ជនរងគ្រោះ ឬក៏ចារីបានដឹងថា អំពើសកម្ម ឬអកម្ម ទំនងជាបង្កឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬផ្លូវចិត្ត ឬការវាយប្រហារដ៏ធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[៦៨៣]។ ចេតនានេះត្រូវតែរកឲ្យឃើញថាមានអត្ថិភាពនៅពេលដែលប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ[៦៨៤]។

### ២.៥.៣.១២ សំអាងហេតុទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត

៣៧២. អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរស២១ បានទទួលរងព្យសនកម្មទាំងផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរពីស្ថានភាពដ៏អាក្រក់នៃការឃុំខ្លួន ដែលបុគ្គលិកមន្ទីរស២១បានអនុវត្តដោយ

---

[៦៨០] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ២០៨។

[៦៨១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៣៣។

[៦៨២] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ២០៨។

[៦៨៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Niyitegeka* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-14-T) ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៤៦០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១១៧។

[៦៨៤] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦២៨។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៣២។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Fofana al.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-14-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ១៥០។

ចេតនាមកលើអ្នកជាប់ឃុំទាំងនោះ។ ស្ថានភាពទាំងនោះរួមមានទាំងការដាក់ខ្នោះជើង ការដាក់ច្រវាក់ ការចងមុខ និងការដាក់ខ្នោះដៃ នៅពេលដែលគេនាំយកចេញពីបន្ទប់ឃុំខ្លួន ការវាយ និងការធ្វើទណ្ឌកម្មលើរាងកាយយ៉ាងធ្ងន់ធ្ងរ ការឃុំខ្លួនក្នុងបន្ទប់ឃុំខ្លួនដែលមានមនុស្សច្រើន និងមានទំហំតូចចង្អៀត ការខ្វះម្ហូបអាហារ អនាម័យ និងការថែទាំផ្នែកវេជ្ជសាស្ត្រ (ផ្នែក ២.៤.៥)។ អ្នកជាប់ឃុំក៏បានប្រឈមនឹងការបូមឈាម និងការពិសោធន៍ផ្នែកវេជ្ជសាស្ត្រផងដែរ (ផ្នែក ២.៤.៥.៥)។

៣៧៣. អំពើសកម្ម និងអកម្មទាំងនេះជានិច្ចកាលបានបន្ទាបបន្ថោក និងធ្វើឱ្យអាប់ឱនដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់អ្នកជាប់ឃុំ ដោយទុកឱ្យពួកគេរស់នៅក្នុងភាពភ័យខ្លាចជាប្រចាំ ។ អំពើទាំងនោះមានស្ថានទម្ងន់ដូចគ្នាទៅនឹងបទល្មើសផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងមានលក្ខណៈគ្រប់គ្រាន់ជាអំពើដាច់ដោយឡែកដែលស្ថិតនៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗ។

### ២.៥.៣.១៣ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៣៧៤. ការធ្វើទុក្ខបុកម្នេញត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាយូរមកហើយ[៦៨៥]។ នៅក្នុងយុត្តិសាស្ត្រនៃតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ បទល្មើសការធ្វើទុក្ខបុកម្នេញត្រូវបានពិពណ៌នាថា ជាការប្រព្រឹត្តិបទល្មើសទ្រង់ទ្រាយធំ និងមានការរើសអើង ប៉ុន្តែគ្មានការបំផ្លិចបំផ្លាញផ្នែករូបវ័ន្ត ឬចេតនាសម្លាប់រង្គាល ដែលជាធាតុផ្សំចាំបាច់សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[៦៨៦] នោះទេ។

---

[៦៨៥] *សូមមើល ឧទាហរណ៍* កិច្ចព្រមព្រៀងស្តីពីការធ្វើទុក្ខបុកម្នេញ និងការដាក់ទោសទណ្ឌចំពោះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃសម្ព័ន្ធមិត្តអឺរ៉ុប និងធម្មនុញ្ញតុលាការយោធាអន្តរជាតិចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ៨២ UNTS ២៧៩ មាត្រា៦(គ)។ ធម្មនុញ្ញទីក្រុងតូក្យូ ឧបសម្ព័ន្ធនៃសេចក្តីប្រកាសពិសេសនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ចេញដោយឧត្តមសេនីជាន់ខ្ពស់នៃសម្ព័ន្ធមិត្តមានអំណាចនៅចុងបូព៌ាមាត្រា៥(គ)។ ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៤៥) មាត្រា៥(គ) *បោះពុម្ពសាជាថ្មី* នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមដោយតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង *បោះពុម្ពលើកទី* I ទំព័រ XVI-XIX។

[៦៨៦] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kupreškić *និងអ្នកផ្សេងទៀត* សាលក្រមរបស់សាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ៦៣៦៖ ("ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជា*ប្រភេទ*បទល្មើសដូចគ្នានឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ទាំងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រល័យ ពូជសាសន៍

៣៧៥. បើទោះបីជាបទល្មើសនេះត្រូវបានចោទប្រកាន់នៅតុលាការ Nuremberg និង Tokyo រួចហើយក៏ដោយ ក៏ធាតុផ្សំនៃបទល្មើសនេះត្រូវបានពន្យល់បញ្ជាក់តិចតួចប៉ុណ្ណោះនៅមុនពេលបង្កើតតុលាការអន្តរជាតិ *មិនអចិន្ត្រៃយ៍*ទាំងនេះ[៦៨៧]។ ប៉ុន្តែការកំណត់ប្រភេទនៃបទល្មើសនេះមាននៅក្នុងយុត្តិ-សាស្ត្រតុលាការអន្តរជាតិក្រោយឆ្នាំ១៩៩២។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY នៅក្នុងរឿងក្តី *Kordic* បានកត់សំគាល់ថា:

> ទាំងច្បាប់សន្ធិសញ្ញាអន្តរជាតិ ទាំងយុត្តិសាស្ត្ររបស់តុលាការនានាសុទ្ធតែមិនបានផ្តល់ធាតុផ្សំចាំបាច់ឲ្យបានក្បោះក្បាយស្តីពីអំពើខុសច្បាប់ ដែលត្រូវចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញនោះទេ ហើយការធ្វើទុក្ខបុកម្នេញនេះមិនត្រូវបានទទួលស្គាល់ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌសំខាន់ៗក្នុងពិភពលោកនៅឡើយទេ។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របថា បទល្មើសនៃការធ្វើទុក្ខបុកម្នេញ

---

គឺជាបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្សនៅក្នុងក្រុមជាក់លាក់មួយ និងមនុស្សដែលត្រូវបានគេកំណត់គោលដៅដោយសារតែអ្នកទាំងនោះស្ថិតនៅក្នុងក្រុមនោះ។ នៅក្នុងប្រភេទឧក្រិដ្ឋកម្មទាំងនេះ អ្វីដែលជាបញ្ហានោះគឺធាតុចេតនារើសអើង [...]។ ចំពោះការធ្វើទុក្ខបុកម្នេញ ធាតុចេតនារើសអើងអាចមានទម្រង់ ជាអមនុស្សធម៌ច្រើនយ៉ាង និងរួមមានសកម្មភាពច្រើន ដែលរួមបញ្ចូលទាំងការធ្វើមនុស្សឃាត ចំណែកឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ធាតុចេតនាត្រូវកំណត់តាមរយៈការបង្ហាញឲ្យឃើញអំពីបំណងបំផ្លាញក្រុមមួយទាំងមូល ឬដោយផ្នែក ដែលជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ស្ថិតនៅក្នុងក្រុមនោះ។ ដូច្នេះ យើងអាចនិយាយបានថា ផ្អែកលើទស្សនាទាន*ធាតុផ្សំអត្តនោម័ត* ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជាការធ្វើទុក្ខបុកម្នេញក្នុងទម្រង់ធ្ងន់ធ្ងរ និងអមនុស្សធម៌បំផុត)។

[៦៨៧] *សូមមើល សាលក្រមចំពោះ Josef Alstotter និងអ្នកផ្សេងទៀត* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមដោយតុលាការយោធា Nuremberg ផ្អែកតាមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (1950), Vol. VI, ទំព័រ ៩៥៤។ សូមមើលសាលក្រមនៃ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* នៅសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ ៦៩៩ ដល់ ៧១០ និង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៨៦ ដល់ ៦១៤ ដើម្បីអាចមើលយុត្តិសាស្ត្រពាក់ព័ន្ធនឹងតុលាការព្រហ្មទណ្ឌ Nuremberg និងយុត្តិសាស្ត្របន្តបន្ទាប់ដែលចេញដោយតុលាការជាតិ។

តម្រូវឲ្យមានការវិវត្ត ដោយប្រយ័ត្នប្រយែង និងគិតគូរឲ្យបានច្បាស់លាស់ផ្អែកតាមគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង*[៦៨៨]។

៣៧៦. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ការធ្វើទុក្ខបុកម្នេញពិតជារួមបញ្ចូលយ៉ាងច្បាស់ទាំង "អំពើសកម្ម ឬអកម្មដែល [...] ពិតជារើសអើង ហើយដកហូត ឬរំលោភទៅលើសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់សន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[៦៨៩] នៅដើមឆ្នាំ១៩៧៥ ប្រាកដមែន។

៣៧៧. អំពើសកម្ម ឬអកម្មនេះ ត្រូវតែមានការរើសអើងដោយពិតប្រាកដ។ ចេតនានៃការរើសអើងតែមួយមិនទាន់គ្រប់គ្រាន់ទេ ហើយអំពើសកម្ម ឬអកម្មនេះ ត្រូវតែជាបច្ច័យដែលបណ្តាលមកពីការរើសអើងនោះ[៦៩០]។ អំពើមួយអាចចាត់ទុកថាជាអំពើរើសអើង នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅដោយសារតែគាត់ជាសមាជិកនៅក្នុងក្រុមមួយដែលចារីកំណត់ដោយមូលហេតុជាក់លាក់ ពោលគឺដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[៦៩១]។ នៅក្នុងរឿងក្តីនេះ

---

[៦៨៨] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១៩២ (សូមកត់សំគាល់ថា ឧក្រិដ្ឋកម្មអន្តរជាតិស្តីពីការធ្វើទុក្ខបុកម្នេញ មិនដែលត្រូវបានកំណត់ឲ្យបានទូលំទូលាយទេ)។ *ដកស្រង់ចេញពីក្នុងចំណោម រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦៩៤។

[៦៨៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រមនិងការផ្តន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ២២០៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ruggiu* សាលក្រមនិងការផ្តន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-32-1) ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០០ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Simic និងអ្នកផ្សេងទៀត* សាលដីការបស់តុលាការកំពូល ICTY (IT-95-9-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៧៧។

[៦៩០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៥៨៣។

[៦៩១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៥៨៣។ *សូមមើលផងដែរ សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-30/1-T) ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ ១៩៥ និង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka* សាលដីការបស់អង្គជំនុំជម្រះ

ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[៦៥២] តែប៉ុណ្ណោះ។

៣៧៨. អំពើធ្វើទុក្ខបុកម្នេញមិនកំណត់ត្រឹមតែ បទល្មើសជាក់លាក់ផ្សេងៗទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៦៥៣] ឧទាហរណ៍ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម[៦៥៤] នោះទេ ប៉ុន្តែរួមបញ្ចូលទាំងអំពើផ្សេងៗទៀតផងដែរ។ បើទោះជាគេមិនអាចកំណត់ដោយទូលំទូលាយថា អំពើផ្សេងៗទៀតអាចបង្កើតបានជាការធ្វើទុក្ខបុកម្នេញក៏ដោយ ក៏អំពើមួយចំនួនដូចខាងក្រោមនេះអាចពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដែរ ដូចជា ការឃាយី ការបន្ទាបបន្ថោក និងការធ្វើបាបផ្លូវចិត្ត ការឃុំខ្លួនក្រោមលក្ខខណ្ឌអមនុស្សធម៌ ការធ្វើបាបដោយអមនុស្សធម៌និងឃោរឃៅ ការនិរទេស ការផ្លាស់ប្តូរទីលំនៅ និងការជម្លៀសដោយ

---

តុលាការកំពូល ICTY (IT-98-30/1-A) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៣៦៣ ៖ (“អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អ្នកជាប់ឃុំទាំងអស់នៅជំរំ Omarska មិនមែនជាជនជាតិស៊ែប ឬជនដែលសង្ស័យថាជួយគាំទ្រជនដែលមិនមែនជាជនជាតិស៊ែបទេ។...ត្រង់នេះវាបង្ហាញច្បាស់ថាបទល្មើសជាក់លាក់ត្រូវបានប្រព្រឹត្តដោយសារមូលហេតុនៃការរើសអើង និងមានផលវិបាកចេញពីការរើសអើងនេះ)។

[៦៥២] “ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៤១។

[៦៥៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រមនិងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៤៧-៣៤៩។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ៦០៩-៦១៤ (ដែលសន្និដ្ឋានថា អត្ថន័យនៃការធ្វើទុក្ខបុកម្នេញនៅតុលាការ Nuremberg រាប់បញ្ចូលទាំងបទល្មើសផ្សេងទៀតក្រៅពីបទល្មើសដែលកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។

[៦៥៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៥៨៣-៥៨៥។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១១៤ និង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦១៥។

បង្ខំ និងការធ្វើពលកម្មដោយបង្ខំ[៦៥៥]។ អំពើទាំងនេះត្រូវតែមាន "ភាពធ្ងន់ធ្ងរស្មើគ្នា" ទៅនឹងបទល្មើសជាក់លាក់មួយចំនួនដែលជាការធ្វើទុក្ខបុកម្នេញ[៦៥៦] ហើយត្រូវតែធ្វើការថ្លឹងថ្លែងដោយពិនិត្យទៅលើអានុភាពនៃការត្រួតគ្នារបស់អំពើទាំងនោះ[៦៥៧] ដោយមិនគ្រាន់តែពិនិត្យទៅលើអំពើនីមួយៗដាច់ដោយឡែកពីគ្នានោះទេ។ គ្រប់ការដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់ មិនមែនសុទ្ធតែបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ហើយដើម្បីឈានដល់កម្រិតធ្ងន់ធ្ងរដែលជាធាតុផ្សំចាំបាច់

---

[៦៥៥] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Kvočka *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30/1-A) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៣២៥-៣៣៥។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Blagojević *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៥៨៦។ *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង* Blaškić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៥៣។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Simic *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-9-T) ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៨៥។ ការពិភាក្សាទូទៅលើអំពើផ្សេងៗដែលចាត់ទុកជាការធ្វើទុក្ខបុកម្នេញ និងការពិនិត្យមើលលើយុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការព្រហ្មទណ្ឌ Nuremberg និងយុត្តាធិការបន្តបន្ទាប់របស់តុលាការជាតិ *សូមមើល រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Tadić សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ ៦៩៩-៧១០។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Kupreškić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៨៦-៦១៥។

[៦៥៦] *សូមមើល រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Kordić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៦៧១។ *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង* Blaškić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ១៣១។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Krnojelac សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-97-25-A) ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ១៩៩។

[៦៥៧] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Kupreškić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦២២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម និងការផ្ដន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣៤៩។ ទោះបីជាការធ្វើទុក្ខបុកម្នេញជារឿយៗសំដៅចំពោះការប្រព្រឹត្តដោយអំពើជាច្រើន ប៉ុន្តែអំពើតែមួយក៏អាចគ្រប់គ្រាន់ថាជាការធ្វើទុក្ខបុកម្នេញផងដែរ។ *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង* Blaškić សាលដីការបស់អង្គជំនុំជម្រះតុលាការ កំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៣៥។

នៅក្នុងការកំណត់បទល្មើសនេះ ជាទូទៅអំពើសកម្ម ឬអកម្មតម្រូវឱ្យមានការដកហូតនូវសិទ្ធិមនុស្ស ជាមូលដ្ឋានដោយកម្រោល ឬដោយឥតលាក់លៀម[៦៩៨]។

៣៧៩. ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម "ដោយមានចេតនារើសអើង ដោយសារមូលហេតុមួយ ក្នុងចំណោមមូលហេតុនានាដែលបានកំណត់"[៦៩៩]។ "ភស្តុតាងនៃចេតនាជាក់លាក់នៃការរើសអើងដោយ មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"[៧០០]ត្រូវតែមានជាចាំបាច់។ ច្បាប់មិនបានតម្រូវឱ្យចារី ត្រូវតែមាន "ចេតនានៃការធ្វើទុក្ខបុកម្នេញ" ដែលលើសពីចេតនានៃការរើសអើងនោះឡើយ។ អត្ថិភាព នៃ "ចេតនាជាក់លាក់ដែលធ្វើឱ្យបុគ្គលណាម្នាក់រងរបួសដោយសារតែគាត់ស្ថិតនៅក្នុងសហគមន៍ ឬ ក្រុមជាក់លាក់ណាមួយ" គឺគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានធាតុចេតនាដែលជាធាតុផ្សំចាំបាច់សម្រាប់ បទល្មើសនៃការធ្វើទុក្ខបុកម្នេញ[៧០១]ហើយ។ ធាតុចេតនាជាក់លាក់នេះមិនមែនជាធាតុផ្សំផ្នែកច្បាប់នៃ បទល្មើសជាក់លាក់មួយចំនួនដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ[៧០២]។

---

[៦៩៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-02-60-T) ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៥៨០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ruggiu* សាលក្រមនិងការផ្តន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-32-1) ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ ២១។

[៦៩៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រមនិងការផ្តន្ទាទោស របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-41-T) ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ២២០៨។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៣១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១០១។

[៧០០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30/1-A) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៤៦០។

[៧០១] *រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៦៥។

[៧០២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ៣០៥។

៣៨០. ចេតនានៃការរើសអើង ដែលជាធាតុផ្សំចាំបាច់ចំពោះបទល្មើសនេះមិនអាចទាញចេញផ្ទាល់ពីលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារនោះទេ ប៉ុន្តែអាចទាញចេញពីបរិបទនេះប្រសិនបើ "ពិចារណាទៅលើអង្គហេតុនៃរឿងក្តី កាលៈទេសៈជុំវិញការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់បញ្ជាក់អំពីអត្ថិភាពនៃចេតនាដូច្នោះ"[៧០៣]។

### ២.៥.៣.១៤ សំអាងហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៣៨១. បទល្មើសដែលបានចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញនៅក្នុងរឿងក្តីនេះ គឺត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មអន្តរជាតិដែលមានកម្រិតធ្ងន់ធ្ងរ ដែលបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់អ្នកជាប់ឃុំនៅមន្ទីរស២១ ដូចបានពិភាក្សាខាងលើ ហើយនៅតុលាការអន្តរជាតិនានា បទល្មើសទាំងនេះគឺជាធាតុផ្សំនៃបទល្មើសការធ្វើទុក្ខបុកម្នេញ (ផ្នែក ២.៥.៣.១៣)។ បទល្មើសនានានៅក្នុងរឿងក្តីនេះត្រូវបានចោទ-ប្រកាន់ត្រួតគ្នានៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋានថាជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះដោយមានចេតនារើសអើងជាក់លាក់ខាងមូលហេតុនយោបាយ។

#### ២.៥.៣.១៤.១ គោលនយោបាយរើសអើងនៃបទល្មើសជាក់លាក់ទាំងនេះ

៣៨២. ជនជាប់ចោទបានទទួលស្គាល់ថា បុគ្គលទាំងឡាយណាដែលត្រូវបានបញ្ជូនទៅមន្ទីរស២១ ត្រូវបានគេសន្មតថាជាអ្នកប្រឆាំងនឹងគោលនយោបាយបក្ស ហើយកំណត់ថាជាខ្មាំង និងរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ[៧០៤]។ គាត់បានលើកឡើងទៀតថា មជ្ឈិមបក្សជាអ្នកសម្រេចថាអ្នកណាជាខ្មាំង និង

---

[៧០៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-97-25-A) ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ១៨៤។ *រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៦៤។

[៧០៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧១-៧២។

អ្នកណាត្រូវបោសសម្អាតដោយមិនគិតថាការវាយតម្លៃនេះត្រូវ ឬខុសនោះទេ[៧០៥]។ ភស្តុតាងបានបង្ហាញថា មន្ទីរស២១បានព្យាយាមស្វែងរកអ្នកទាំងឡាយណាដែលរួមគំនិតក្បត់ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា និងផ្តល់នូវភស្តុតាងដើម្បីបញ្ជាក់នូវការសង្ស័យរបស់មេដឹកនាំទាំងនោះ។ ស២៤ បំពេញភារកិច្ចស្រដៀងគ្នាក្នុងការ "កសាងខ្លួន" អ្នកជាប់ឃុំ ជាពិសេស ទាក់ទងនឹងជំហរអ្នកទាំងនោះចំពោះបក្សកុម្មុយនីស្តកម្ពុជា[៧០៦]។

៣៨៣. ទាក់ទងទៅនឹងមូលដ្ឋាននៃគោលនយោបាយដែលបានអនុវត្តនៅមន្ទីរស២១(ទួលស្លែង) អង្គជំនុំជម្រះកត់សម្គាល់ថា អ្នកជាប់ឃុំដំបូងនៅមន្ទីរស២១ (ទួលស្លែង) គឺជាអតីតអ្នករដ្ឋការ និងទាហាននៃរបប លន់ នល់ ដែលត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីរបបខ្មែរក្រហមបានឡើងកាន់អំណាច ហើយអ្នកជាប់ឃុំទាំងនោះត្រូវបានសម្លាប់ដោយសារតែពួកគេមានស្វាមីភក្តិចំពោះរបបមុន[៧០៧]។ បញ្ញវន្តនិស្សិត និងមន្ត្រីការទូតនៅបរទេស ដែលត្រូវបានអំពាវនាវឲ្យត្រឡប់មកមាតុប្រទេសវិញ ត្រូវបានគេបញ្ជូនទៅមណ្ឌលកសាងខ្លួន ឬទៅមន្ទីរស២១ (ទួលស្លែង) នៅពេលដែលអ្នកទាំងនោះបានមកដល់ប្រទេសកម្ពុជា។ យោងតាមអ្នកជំនាញ David CHANDLER បក្សមានការសង្ស័យទៅលើអ្នកទាំងនោះថាមានទំនាក់ទំនងជាមួយជនបរទេស ឬថាបានបង្កើតសម្ព័ន្ធមិត្តជាមួយរដ្ឋបរទេស[៧០៨]។ បញ្ញវន្ត

[៧០៥] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៣-៦៤។ *សូមមើលផងដែរ* "រូបភាព" ឯកសារ E3/379។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤២។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៩។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ១៦-១៧។

[៧០៦] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៥, ១៦-១៧, ៣០-៣១។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា (ជនជាប់ចោទ) ទំព័រ១៥-១៦។ ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១២-១៣។

[៧០៧] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័៥-៦។

[៧០៨] ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣៨។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ១៥-១៨។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៥-៧។ ប្រតិចារឹក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ (ប៊ូ ធុន) ទំព័រ៣២-៣៤។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ៥២។

ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានបញ្ជូនជាដំបូងទៅភូមិភាគពាយ័ព្យ ហើយទីបំផុតត្រូវបានបោសសម្អាត នៅមន្ទីរស២១ (ទួលស្លែង)[៧០៩]។

៣៨៤. មូលដ្ឋានគ្រឹះសម្រាប់អនុវត្តគោលនយោបាយកម្ពុជាប្រជាធិបតេយ្យគឺ "សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦" ដែលបានផ្តល់សិទ្ធិអំណាចក្នុងការសម្លាប់អ្នកដែលត្រូវសង្ស័យថាជាខ្មាំងរបស់បក្ស (ផ្នែក ២.២.៦)។ ដោយសារមានការកើនឡើងនូវចលនាបដិវត្ត មជ្ឈិមបក្សបានចាប់ផ្តើមសង្ស័យថាមានខ្មាំងគ្រប់ទីកន្លែងនិងចាប់ផ្តើមព្រួយបារម្ភចំពោះខ្មាំងផ្ទៃក្នុងជាងខ្មាំងខាងក្រៅ[៧១០]។ នៅមន្ទីរស២១ ពាក្យថា "ខ្មាំង" សំដៅទៅអ្នកទាំងឡាយណាដែលគេសង្ស័យថាក្បត់នឹងបក្ស[៧១១]។

៣៨៥. ចាប់តាំងពីឆ្នាំ១៩៧៦មក ចំនួនអ្នកជាប់ឃុំភាគច្រើននៅមន្ទីរស២១ គឺជាយុទ្ធជន និងកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានជាប់សង្ស័យ ដោយសារតែប្រវត្តិរូប ឬទំនាក់ទំនងរបស់អ្នកទាំងនោះជាមួយនឹងអ្នកដែលបក្សយល់ថាជាខ្មាំង[៧១២]។ បុគ្គលិកមន្ទីរស២១ ដែលត្រូវបានឃុំខ្លួន និងបោសសម្អាតមានចំនួនកាន់តែច្រើនឡើងៗ បន្ទាប់ពីបុគ្គលិកទាំងនោះត្រូវបានចោទប្រកាន់ថាបានបង្កវិទ្ធង្សនាប្រឆាំងនឹងបក្ស ក្រោយពេលអ្នកទាំងនោះមានជាប់ពាក់ព័ន្ធនៅក្នុងចម្លើយសារភាព ឬគ្រាន់តែមានកំហុសតិចតួចនៅពេលធ្វើការតែប៉ុណ្ណោះ[៧១៣]។ បុគ្គលសំខាន់ៗដែលភាគច្រើនជាសមាជិកកម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាត្រូវបានចាប់ខ្លួន ឬសម្លាប់បន្ទាប់ពីមានបញ្ជាផ្ទាល់ពីគណៈកម្មាធិការអចិន្ត្រៃយ៍[៧១៤]។

---

[៧០៩] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៣-១៤។

[៧១០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១០-១១។

[៧១១] ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ១៥-១៦។

[៧១២] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥-៧។

[៧១៣] ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ១៣-១៥។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៣៦-៣៨។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣៦-៣៩។ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧។

[៧១៤] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២១-២២។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៥១-៥២។

៣៨៦. ជនបរទេស រួមទាំងជនជាតិវៀតណាម ព្រះសង្ឃ និងជនជាតិភាគតិចមួយចំនួន ក៏ត្រូវបានឃុំខ្លួននៅមន្ទីរស២១ ដោយសារតែពួកគេទាំងនោះត្រូវបានគេសន្មតថាជាអ្នកគំរាមកំហែងពិតប្រាកដដល់បក្សកុម្មុយនីស្តកម្ពុជា។ ទោះបីជាជនជាតិវៀតណាមខ្លះត្រូវបានចាប់ខ្លួន និងឃុំខ្លួនដំបូងដោយសារតែជម្លោះប្រដាប់អាវុធជាមួយវៀតណាម ជនជាប់ចោទបានគូសបញ្ជាក់ថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងជនជាតិវៀតណាម និងជនជាតិភាគតិច ឬក្រុមសាសនាផ្សេងៗទៀតចាត់ទុកបុគ្គលទាំងនេះថាជា "គិញ" ដែលប្រឆាំងនឹងបក្ស[៧១៥]។ យ៉ាងណាក៏ដោយ ក្នុងករណីមួយដែលជាការប្រាសចាកដ៏កម្រពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈប្រតិភូនៃរណសិរ្សសាមគ្គីរំដោះជនជាតិដែលត្រូវគេជិះជាន់ (FULRO) ត្រូវបានគេដោះលែងពីមន្ទីរស២១ បន្ទាប់ពីមានបញ្ជាពីមជ្ឈិមបក្សដែលចារថាអ្នកទាំងនោះគឺជាអ្នកគាំទ្រគោលនយោបាយបក្សនោះទេ[៧១៦]។ ប៉ុន្តែបុគ្គលដទៃទៀតដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយយល់ច្រឡំ ក៏ត្រូវបានគេសម្លាប់ដើម្បីរក្សាការសម្ងាត់នៃប្រតិបត្តិការមន្ទីរស២១ផងដែរ[៧១៧]។

៣៨៧. ជាធម្មតាអ្នកជាប់ឃុំត្រូវបានចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយនឹងភ្នាក់ងារស៊ើបការណ៍សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB) ឬជាមួយនឹងរដ្ឋការវៀតណាម[៧១៨]។ ប៉ុន្តែ ពាក្យទាំងនេះត្រូវបានគេប្រើជាញឹកញាប់នៅមន្ទីរស២១ សម្រាប់ចាប់ខ្លួនអ្នកដែលជាខ្មាំងរបស់បក្សកុម្មុយនីស្ត កម្ពុជា[៧១៩]។ ពាក្យទាំងនេះមានសារៈសំខាន់តែនៅពេលដែលអ្នកជាប់ឃុំបានសារភាពថាជាខ្មាំង និងប្រាប់ឈ្មោះ "ខ្សែក្បត់ផ្សេងៗទៀត"[៧២០] តែប៉ុណ្ណោះ។

---

[៧១៥] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-២១, ៣៩-៤៣។

[៧១៦] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២០-២៣។

[៧១៧] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៧-២០, ៧៣-៧៤។

[៧១៨] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៤-៥៧។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ២០។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២០-២២។

[៧១៩] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៣-៥៦។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១២, ១៩-២០។

[៧២០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ២២-២៣, ៣៥-៣៧។

៣៨៨. នៅចុងបញ្ចប់នៃរបបខ្មែរក្រហម បុគ្គលទាំងអស់ដែលមិនគាំទ្ររបបរបស់ខ្លួនត្រូវបានគេចាត់ទុកថាជាខ្មាំងរបស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានចាត់ទុកថាមានកំហុស និងជាប់ទោសដោយគ្រាន់តែត្រូវបានគេចោទប្រកាន់តែប៉ុណ្ណោះ[៧២១]។ ដំណើរការបោសសម្អាតខ្មាំងរបស់បក្ស បានធ្វើឱ្យបុគ្គលមួយចំនួនមានការភ័យខ្លាច មិនទុកចិត្តគ្នា និងកាប់សម្លាប់គ្នាពាសពេញប្រទេស ដែលទីបំផុតរួមចំណែកបំផ្លាញបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង[៧២២]។ អ្នកជំនាញ David CHANDLER បានយល់ស្របថា ប្រតិបត្តិការមន្ទីរស២១មានសារៈសំខាន់យ៉ាងខ្លាំងចំពោះគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការគ្រប់គ្រងខ្មាំងរបស់ខ្លួន[៧២៣]។ អ្នកជំនាញ David CHANDLER ក៏បានគិតផងដែរថា ការធ្វើបដិវត្តតម្រូវឱ្យមាន "ការពេញចិត្តពេញថ្លើមខ្លួនឯង" និងមិនផ្តល់ឱកាសណាមួយឱ្យមានការស្ទាក់ស្ទើរ ឬធ្វើការប្រឆាំងនឹងមេដឹកនាំរបស់ខ្លួននោះទេ[៧២៤]។

### ២.៥.៣.១៤.២ ផលវិបាកនៃគោលនយោបាយរើសអើងទាំងនេះ

---

[៧២១] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៤-១៦, ១៨-១៩, ៧៣-៧៤។

[៧២២] សៀវភៅរបស់លោក David CHANDLER មានចំណងជើងថា *សំឡេងពីមន្ទីរស២១ - ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត* (សៀវភៅ) ឯកសារ E3/427, ERN (ភាសាខ្មែរ) 00191914 ទំព័រ៨៦៖ "របបដែលពោរពេញទៅដោយភេរវកម្មនិងបដិវត្តមិនចេះចប់ (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវការខ្មាំងមកធ្វើជាចំណីជាបន្តបន្ទាប់។ នៅពេលដែលខ្មាំងទាំងនេះបង្កប់ជាក្រុមតូចមួយនៅក្នុងបក្សនយោបាយដែលគ្មានបទពិសោធន៍ និងមិនអាចចែកដាច់ពីប្រជាជនភាគច្រើននៃប្រជាជនទាំងអស់ក្នុងការប៉ុនប៉ងបោសសំអាតខ្មាំងទាំងអស់របស់ខ្លួន អាចជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់។ ដូចជា ឌុច និងបក្សពួកដែលធ្វើអ្វីតាមការបញ្ជាអ៊ីចឹងដែរ ពោលគឺអ្នកទាំងនេះបានធ្វើឱ្យអន្តរាយដល់ប្រសិទ្ធ-ភាពផ្នែកកងទ័ពរបស់កម្ពុជា រំសាយរចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេស និងកម្ទេចបក្ស។ ក្បាលម៉ាស៊ីនដែលត្រូវសម្លាប់នៅមន្ទីរស២១ បានប្រព្រឹត្តទៅឥតឈប់ឈរដោយសារការសង្ស័យ និងមិនទុកចិត្តគ្មានព្រំដែនរបស់មជ្ឈិមបក្ស"។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៥-១៦។

[៧២៣] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៥-១៦ (យោង "សៀវភៅរបស់លោក David CHANDLER មានចំណងជើងថា *សំឡេងពីមន្ទីរស២១ - ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត*" (សៀវភៅ) ឯកសារ E3/427, ERN (ភាសាខ្មែរ) 00191914 ទំព័រ៨៦ )។

[៧២៤] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ៤៩-៥១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦១-៦២, ៦៣-៦៤។

៣៨៩. អង្គជំនុំជម្រះយល់ឃើញថា បុគ្គលគ្រប់រូបដែលបានជាប់ឃុំនៅមន្ទីរស២១ ត្រូវបានចាត់ទុកដោយត្រឹមត្រូវ ឬដោយមានកំហុសថាមានជាប់ពាក់ព័ន្ធជាមួយនឹងក្រុមបក្សនយោបាយណាមួយផ្សេងទៀតក្រៅពីបក្សកុម្មុយនីស្តកម្ពុជា ហើយជាធម្មតាមានប្រវត្តិស្ថិតនៅក្នុងវណ្ណៈណាមួយដែលជាគោលដៅនៃការរើសអើង។ អង្គជំនុំជម្រះបានរកឃើញពីមុនថា គោលបំណងចម្បងនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងអ្វីដែលតុលាការអន្តរជាតិផ្សេងៗទៀតយល់ឃើញថាបង្កើតបានជាគោលនយោបាយនៃការរើសអើងដោយមូលហេតុនយោបាយ (ផ្នែក ២.៥.១.៤)។

៣៩០. មជ្ឈិមបក្សគឺជាអ្នកកំណត់ប្រភេទក្រុមគោលដៅ និងសមាសភាពក្រុមគោលដៅដោយបញ្ចូលទាំងអ្នកប្រឆាំងនឹងគោលនយោបាយបក្សពិតប្រាកដ និងតាមការសន្មតដោយរួមទាំងសាច់ញាតិជិតស្និទ្ធ ឬអ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀត (ផ្នែក ២.២.៥.២ ផ្នែក ២.២.៦ និងផ្នែក ២.៥.៣.១៤.១)។ បើទោះបីជា បទល្មើសជាច្រើនត្រូវបានប្រព្រឹត្តឡើងដោយចារីប្រឆាំងជាមួយនឹងបុគ្គលដែលត្រូវបានគេសន្មតថាជា ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះទាំងអស់បានទទួលរងនូវផលវិបាកនៃការរើសអើងធ្ងន់ធ្ងរដូចៗគ្នា ពីអំពើដែលបានប្រព្រឹត្តដើម្បីសម្រេចចេតនារើសអើងជាក់លាក់ទាំងនោះ។

### ២.៥.៣.១៤.៣ ចេតនាជាក់លាក់របស់ជនជាប់ចោទ

៣៩១. អង្គជំនុំជម្រះត្រូវតែកំណត់ថា តើការពាក់ព័ន្ធទៅនឹងអំពើទាំងនោះ ជនជាប់ចោទមានចេតនានៃការរើសអើងដែលជាធាតុផ្សំចាំបាច់ដើម្បីគាំទ្រដល់ការកំណត់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដែរ ឬទេ។

៣៩២. អង្គជំនុំជម្រះដោយមតិភាគច្រើន (ចៅក្រម Cartwright មានមតិជំទាស់) យល់ឃើញថាជនជាប់ចោទមានចេតនាចូលរួមយ៉ាងពេញទំហឹង ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបោសសម្អាតរាល់ខ្មាំងនយោបាយរបស់បក្សទាំងអស់ដែលបានកំណត់អត្តសញ្ញាណដោយមជ្ឈិមបក្ស ក្នុងការឃុំខ្លួន ធ្វើទារុណកម្ម សម្លាប់ និងធ្វើបាបដោយអមនុស្សធម៌ទៅលើអ្នកជាប់ឃុំនៅមន្ទីរស២១ដោយមូលហេតុនយោបាយ។

### ២.៥.៣.១៤.៤ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ

៣៩៣. ភស្តុតាងនៅពេលសវនាការបានបង្ហាញថា ជនជាប់ចោទបានព្យាយាមដោយមានសម្បជញ្ញៈ មានឆន្ទៈ និងដក់ចិត្តដក់អារម្មណ៍ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើការបោសសម្អាតរាល់ខ្មាំងនយោបាយរបស់បក្សទាំងអស់ ដែលបានកំណត់អត្តសញ្ញាណដោយមជ្ឈិមបក្ស ហើយឃុំខ្លួន ធ្វើទារុណកម្ម សម្លាប់ និងធ្វើបាបដោយអមនុស្សធម៌ទៅលើអ្នកជាប់ឃុំនៅមន្ទីរស២១ ដោយមូលហេតុនយោបាយ ហើយដែលជនជាប់ចោទខ្លួនឯងបានយល់ស្របផងដែរ[៧២៥]។

៣៩៤. ជនជាប់ចោទបានដឹងថា ជាការពិត អ្នកជាប់ឃុំទាំងអស់នៅមន្ទីរស២១ មិនមែនសុទ្ធតែជាខ្មាំងរបស់បក្សនោះទេ ប៉ុន្តែអ្នកជាប់ឃុំភាគច្រើនសុទ្ធតែត្រូវបានគេឃុំខ្លួន សួរចម្លើយ និងសម្លាប់[៧២៦]។ បើទោះជាយ៉ាងនេះក្តី ជនជាប់ចោទបានអនុវត្តការងារដែលគាត់បានទទួលដោយមិនបានគិតពិចារណាអ្វីទាំងអស់ និងបានគ្រប់គ្រងប្រតិបត្តិការមន្ទីរស២១ ដោយធានាថាអ្នកជាប់ឃុំទាំងអស់ រួមទាំងអ្នកដែលគ្រាន់តែត្រូវបានគេសន្មតថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា បានទទួលរងផលវិបាកយ៉ាងខ្លាំងពីអំពើរើសអើងនានាដែលបានប្រព្រឹត្ត ដើម្បីសម្រេចនូវចេតនានៃការរើសអើងជាក់លាក់ទាំងនោះ។

៣៩៥. តាមរយៈការប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ រួមទាំងការធ្វើទារុណកម្មផង ជនជាប់ចោទបានប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ ក្នុងការអនុវត្តនូវមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ ជនជាប់ចោទបានផ្តល់ជាបន្តបន្ទាប់ទៅថ្នាក់លើរបស់គាត់នូវឈ្មោះមនុស្សទាំងអស់ដែលគាត់ដឹងច្បាស់ថា នឹងពិតជាត្រូវបានគេចាត់ទុកថាជាជនក្បត់ និងជាខ្មាំងនយោបាយ។ ការធ្វើបែបនេះ គាត់មិនត្រឹមតែអនុវត្តគោលនយោបាយនៃការរើសអើងរបស់បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងមាន

---

[៧២៥] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០-៣២ (សារភាពថាបានអនុវត្ត "ក្នុងលក្ខណៈប្រឹងប្រែង និងគ្មានការអាណិតអាសូរ" ការធ្វើទុក្ខបុកម្នេញដោយបក្សកុម្មុយនីស្តកម្ពុជាទៅលើអ្នកជាប់ឃុំនៅមន្ទីរស២១)។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៨-៥០។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧-១៨, ៣៦-៣៨។

[៧២៦] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៨។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ២៨-២៩។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៧-២០។

00573562



ឥទ្ធិពលទៅលើការកំណត់ក្រុមគោលដៅដែលត្រូវកម្ទេចក្រោមគោលនយោបាយនេះផងដែរ។ ជនជាប់-ចោទបានទទួលស្គាល់ថា គាត់បានណែនាំបុគ្គលិករបស់គាត់ឱ្យចាត់ទុកអ្នកដែលអង្គការបានចាប់ខ្លួនថាជាខ្មាំង[៧២៧] និងបានរៀបរាប់តួនាទីរបស់គាត់ថា "កម្ចាត់ ទស្សនៈត្រឹមត្រូវ កសាងទស្សនៈឧក្រិដ្ឋទៅឱ្យគេ"[៧២៨]។ គាត់ក៏បានបញ្ជាដោយគ្មានការអាណិតអាសូរឱ្យសម្លាប់អ្នកជាប់ឃុំទាំងអស់បន្ទាប់ពីគាត់បានទទួលចម្លើយសារភាពគ្រប់គ្រាន់អំពីកំហុស ក្នុងការប្រឆាំងនឹងបដិវត្តន៍។ គាត់បានដឹងយ៉ាងច្បាស់ថា ចម្លើយសារភាពទាំងនេះនឹងត្រូវបានប្រើប្រាស់ដើម្បីចាប់ខ្លួនខ្មាំងនយោបាយបន្ថែមទៀត និងប្រើក្នុងគោលបំណងសម្រាប់ការឃោសនា។ គាត់បានប្រើសិទ្ធិអំណាចរបស់គាត់ក្នុងនាមជាលេខារបស់គណៈ-កម្មាធិការមន្ទីរស២១ ក្នុងការបញ្ជាឱ្យមានការចាប់បញ្ជូនបុគ្គលិករបស់គាត់ទៅស២៤ដើម្បី "កសាងខ្លួន" និងក្នុងនាមជាប្រធានមន្ទីរស២១ធ្វើឱ្យមានឥទ្ធិពល ឬជួយសម្រួលដល់មេរបស់គាត់ក្នុងការសម្រេចចាប់ខ្លួន និងកម្ទេចបុគ្គលិកមន្ទីរស២១ ដែលគាត់គិតថា អ្នកទាំងនោះជាខ្មាំង ដោយផ្អែកលើអាកប្បកិរិយាប្រវត្តិរូប និងការឆ្លើយដាក់ក្នុងចម្លើយសារភាពរបស់អ្នកជាប់ឃុំ។ គាត់ក៏បានជ្រើសរើសក្មេងជំទង់ៗ និងបុគ្គលមួយចំនួនដែលជាកូនកសិករក្រីក្រ និងមិនមានការអប់រំ ដែលអ្នកទាំងនោះងាយស្រួលក្នុងការបណ្តុះបណ្តាលមនោគមន៍វិជ្ជា[៧២៩]។

៣៩៦. មតិភាគច្រើននៃចៅក្រមអង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តិរបស់ជនជាប់ចោទបង្ហាញពីចេតនាជាក់លាក់របស់គាត់ក្នុងការកំណត់ទិសដៅចំពោះជនរងគ្រោះ ព្រោះថាជនរងគ្រោះទាំងនោះស្ថិតក្នុងក្រុមគោលដៅនៃការអនុវត្តគោលនយោបាយនៃការរើសអើងរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១។ ការសន្និដ្ឋានចេញពីភស្តុតាងជាច្រើននៅអំឡុងពេលសវនាការបង្ហាញថា ជនជាប់ចោទមាន

---

[៧២៧] ប្រតិចារិក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៤-៦៥។ ប្រតិចារិក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៧។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៧-២៨។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៥។ ប្រតិចារិក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ១៥-១៦។

[៧២៨] ប្រតិចារិក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៤-៦៦។

[៧២៩] សូមមើលប្រតិចារិកចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៤-៦៥ (ដោយទទួលស្គាល់ថា ចំណែកមកពីខាងម១៣ អត់មានប៉ះម្នាក់សោះ ឬអ្នកទាំងឡាយដែលជ្រើសរើសដោយគាត់ និងមានប្រវត្តិរូបស្អាតស្អំ គឺមិនត្រូវបានបោសសំអាតនោះទេ)។ សូមមើលផងដែរផ្នែក ២.៣.៣.៥.១ ។

ចេតនាជាក់លាក់ដែលជាលក្ខខណ្ឌតម្រូវនៃបទល្មើសការធ្វើទុក្ខបុកម្នេញ។ អង្គជំនុំជម្រះរម្លឹកឡើងវិញថា ច្បាប់មិនតម្រូវថាចារីត្រូវតែមានចេតនាធ្វើទុក្ខបុកម្នេញលើសពីចេតនារើសអើងដែលជាធាតុផ្សំចាំបាច់ខាងលើនេះឡើយ (ផ្នែក ២.៥.៣.១៣)។

### ២.៥.៣.១៤.៥ មតិជំទាស់របស់ចៅក្រម CARTWRIGHT

៣៩៧. ខ្ញុំសូមឯកភាពជាមួយសហការីរបស់ខ្ញុំចំពោះការវិភាគអង្គច្បាប់ និងអង្គហេតុទាក់ទងទៅនឹងបរិបទដែលជនជាប់ចោទ ក្នុងនាមជាប្រធានមន្ទីរស២១ គ្រប់គ្រងប្រតិបត្តិការនៅទីនោះ។ ខ្ញុំសូមជំទាស់នៅពេលដែលខ្ញុំពិចារណាអំពីសេចក្តីសន្និដ្ឋាន ដែលទាញចេញអំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជារបស់ជនជាប់ចោទនៅមន្ទីរស២១។

៣៩៨. ខ្ញុំយល់ស្របទាំងស្រុងថា ជនជាប់ចោទបានអនុវត្តដោយយកចិត្តទុកដាក់នូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការឃុំខ្លួន សួរចម្លើយ និងនៅពេលដែលគាត់យល់ថាសមស្របក្នុងការធ្វើទារុណកម្ម និងបន្ទាប់មកសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស២១។ ខ្ញុំក៏ឯកភាពផងដែរថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា មានការរើសអើងដោយមូលហេតុនយោបាយ។ ជនជាប់ចោទបានដឹងថា គ្រប់អ្នកជាប់ឃុំទាំងអស់នៅមន្ទីរស២១ ពិតជាមិនមែនសុទ្ធតែជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ ប៉ុន្តែអ្នកជាប់ឃុំភាគច្រើនត្រូវបានឃុំខ្លួន សួរចម្លើយ និងសម្លាប់[៧៣០]។ គាត់ក៏បានដឹងថា ចម្លើយសារភាពជាច្រើនដែលអ្នកជាប់ឃុំបានផ្តល់ឱ្យមានភាពមិនត្រឹមត្រូវនៅផ្នែកខ្លះ ឬមិនត្រឹមត្រូវទាល់តែសោះ និងថាអ្នកជាប់ឃុំជាច្រើនបានសារភាពអំពីសកម្មភាពមិនពិតចំពោះចលនានានា ឬសមាជិកភាពនៃក្រុមសង្ស័យ ដូចជា សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB)។

៣៩៩. មតិរបស់ខ្ញុំចំពោះអង្គហេតុទាំងនោះគឺថា ខ្ញុំផ្តោតជាសំខាន់ទៅលើសំអាងហេតុច្បាស់លាស់ដែលថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកកំណត់អត្តសញ្ញាណ "ខ្មាំង" និងជាញីកញាប់ ជាអ្នកបញ្ជាឱ្យធ្វើ

[៧៣០] ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៨-៧៩។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ២៨-២៩ និង ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១៧-២១។

ការចាប់ខ្លួន។ ខ្ញុំក៏បានកត់សំគាល់ថា ជនជាប់ចោទមិនបានដឹងអំពីសេចក្ដីសម្រេចសម្ងាត់បំផុត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នោះទេ ដូច្នេះហើយមិនអាចនិយាយបានថា គាត់បានចូលរួមចំណែករៀបចំគោលនយោបាយទាំងនេះនោះទេ[៧៣១]។ ភារកិច្ចរបស់គាត់ ដែលគាត់បានទទួលគឺជាសមាជិកដែលមានភក្ដីភាព និងមានប្រសិទ្ធភាពចំពោះបក្ស ដែលបានអនុវត្តដោយមិនបានពិចារណានូវរាល់កិច្ចការផ្សេងៗដែលបានតម្រូវឲ្យគាត់ធ្វើនោះទេ។ ដូច្នេះគាត់គ្រាន់តែបានជួយឲ្យបានសម្រេចក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជាប្រឆាំងនឹងអ្នកជាប់ឃុំនៅមន្ទីរស២១តែប៉ុណ្ណោះ។ បើទោះបីជារកឃើញថា ជនជាប់ចោទបានដឹងអំពីមូលដ្ឋាននៃការរើសអើងចំពោះគោលនយោបាយទាំងនោះក៏ដោយ ខ្ញុំបានទាញសេចក្ដីសន្និដ្ឋានចេញពីភស្តុតាងថា ពុំឃើញមានភស្តុតាងគ្រប់គ្រាន់តាមបទដ្ឋានតម្រូវដែលបង្ហាញថា គាត់មានចេតនានៃការរើសអើងដោយផ្ទាល់ ដែលជាធាតុផ្សំចាំបាច់សម្រាប់គាំទ្រការចោទប្រកាន់ចំពោះបទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយឡើយ។

## ២.៦ ច្បាប់ និងសំអាងហេតុទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

៤០០. អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើរឿងក្ដី ចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក។ មាត្រា៦ ច្បាប់ អ.វ.ត.ក ចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្ត អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវទទួលបានការការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩៖

---

[៧៣១] ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៣-១៧។

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឲ្យឈ្លើយសឹក ឬជនស៊ីវិលបម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់
- ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង[៧៣២]

៤០១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចខាងក្រោម៖ (i) ការធ្វើមនុស្សឃាតដោយចេតនា (ii) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ (iii) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព (iv) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ (v) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[៧៣៣]។

---

[៧៣២] មាត្រា៦ នៃច្បាប់អ.វ.ត.ក ឆ្លុះបញ្ចាំងជាសំខាន់ចំពោះបទប្បញ្ញត្តិទាក់ទងនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដោយមានករណីលើកលែងចំនួនពីរ៖ (១) បទប្បញ្ញត្តិការរំលោភបំពានធ្ងន់ធ្ងរ រួមបញ្ចូលយ៉ាងច្បាស់អំពី "ការពិសោធជីវសាស្ត្រ" ថាជាទម្រង់នៃការធ្វើទារុណកម្ម ឬការប្រព្រឹត្តិអមនុស្សធម៌ និង (២) បទប្បញ្ញត្តិការរំលោភបំពានធ្ងន់ធ្ងរ តម្រូវថា ការបំផ្លិចបំផ្លាញ និងការដកហូតទ្រព្យសម្បត្តិ "ត្រូវបានគ្របដណ្តប់ផងដែរ"។

[៧៣៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ទំព័រ៧២-៧៣ (ភាសាខ្មែរ)។

៤០២. បញ្ហាជាបឋម អង្គជំនុំជម្រះត្រូវរកឲ្យឃើញថា ឧក្រិដ្ឋកម្មទាំងនេះជាឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៤០៣. ប្រទេសកម្ពុជា និងប្រទេសវៀតណាមបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ចំនួនបួន (ហៅជារួមថា"អនុសញ្ញាទីក្រុងហ្សឺណែវ")[៧៣៤]។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨ ហើយប្រទេសវៀតណាមបានផ្តល់សច្ចាប័ននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥៧[៧៣៥]។ អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួននេះ មាននូវបទប្បញ្ញត្តិដែលចែងអំពី "ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ" ដែលអនុវត្តចំពោះអំពើប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិ "ដែលត្រូវទទួលបានការការពារ"នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលមានលក្ខណៈជាអន្តរជាតិ[៧៣៦]។ ជាពិសេសបទប្បញ្ញត្តិនីមួយៗនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរចែងពីបទល្មើសមួយចំនួនដែលមាននៅក្នុងយុត្តាធិការចាំបាច់ជាសកលលើបទល្មើសព្រហ្មទណ្ឌរបស់រដ្ឋភាគីនៃអនុសញ្ញានោះរួចទៅហើយ[៧៣៧]។

---

[៧៣៤] អនុសញ្ញាទីក្រុងហ្សឺណែវ I ស្តីពីការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌនៃកងកម្លាំងប្រដាប់អាវុធដែលមានជំងឺ និងរបួសក្នុងសមរភូមិ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ៣១ ("អនុសញ្ញាទីក្រុងហ្សឺណែវ I")។ អនុសញ្ញាទីក្រុងហ្សឺណែវ II ស្តីពីការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌនៃកងកម្លាំងប្រដាប់អាវុធដែលមានរបួស មានជំងឺ និងគ្រោះថ្នាក់ក្នុងការប៉ះទង្គិចកប៉ាល់នៅក្នុងដែនសមុទ្រ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ៨៥ ("អនុសញ្ញាទីក្រុងហ្សឺណែវ II")។ អនុសញ្ញាទីក្រុងហ្សឺណែវ III ទាក់ទងនឹងការប្រព្រឹត្តិសង្គ្រាម ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ១៣៥ ("អនុសញ្ញាទីក្រុងហ្សឺណែវ III")។ អនុសញ្ញាទីក្រុងហ្សឺណែវ IV ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ២៨៧ ("អនុសញ្ញាទីក្រុងហ្សឺណែវ IV" និងជារួមហៅថា "អនុសញ្ញាទីក្រុងហ្សឺណែវ")។

[៧៣៥] *សូមមើល*ICRC *រដ្ឋជាភាគី/រដ្ឋជាហត្ថលេខី៖ អនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។*

[៧៣៦] មាត្រា៥០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ I។ មាត្រា៥១ នៃអនុសញ្ញាទីក្រុងហ្សឺណែវ II។ មាត្រា១៣០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III។ មាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Tadić* សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់មេធាវីការពារក្តីលើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៨០-៨១, ៨៤។

[៧៣៧] មាត្រា៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ I។ មាត្រា៥០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ II។ មាត្រា១២៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III។ មាត្រា១៤៦ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV (មាត្រានីមួយៗបានលើកឡើងនៅក្នុងផ្នែកពាក់ព័ន្ធថា "រដ្ឋជាភាគីត្រូវអនុម័តច្បាប់ណាមួយចាំបាច់ ដើម្បីផ្តល់នូវការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដ៏មានប្រសិទ្ធភាពចំពោះបុគ្គល

អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ហាមឃាត់ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ និងការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព[៧៣៨]។ ក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ III ទាក់ទងនឹងការប្រព្រឹត្តិចំពោះអ្នកទោសសង្គ្រាម ("អនុសញ្ញាទីក្រុងហ្សឺណែវ III") និងអនុសញ្ញាទីក្រុងហ្សឺណែវ IV ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ("អនុសញ្ញាទីក្រុងហ្សឺណែវ IV") បទប្បញ្ញត្តិនៃការបំពារបំពានធ្ងន់ធ្ងរក៏បានចែងអំពីការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់[៧៣៩]។ បន្ថែមពីលើនេះ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ត្រូវបានចាត់ទុកថាជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរមួយក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ IV[៧៤០]។

៤០៤. បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលហាមឃាត់និងកំណត់យ៉ាងច្បាស់ថាជាបទឧក្រិដ្ឋ ដូចដែលមានចែងនៅក្នុងមាត្រា៦ នៃច្បាប់ អ.វ.ត.ក បានចងភ្ជាប់កាតព្វកិច្ចប្រទេសកម្ពុជានាពេលនោះ។ អង្គជំនុំជម្រះរំលឹកឡើងវិញថា គោលការណ៍នីត្យានុកូលភាពក៏ត្រូវបានបំពេញផងដែរ នៅពេលរដ្ឋមួយត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយអនុសញ្ញាជាក់លាក់ណាមួយ[៧៤១]។

---

ដែលប្រព្រឹត្ត ឬបញ្ជាឲ្យប្រព្រឹត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរណាមួយ នៃអនុសញ្ញាបច្ចុប្បន្នដែលមានចែងនៅក្នុងមាត្រាខាងក្រោម។ រដ្ឋជាភាគីនីមួយៗ ត្រូវមានកាតព្វកិច្ចស្វែងរកបុគ្គលដែលចោទប្រកាន់ថាបានប្រព្រឹត្ត ឬបញ្ជាឲ្យគេប្រព្រឹត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរនេះ និងត្រូវបញ្ជូនបុគ្គលដែលបានប្រព្រឹត្តនោះ ដោយមិនគិតអំពីសញ្ជាតិ ទៅចំពោះមុខតុលាការរបស់ខ្លួន។ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់របស់ខ្លួន ប្រសិនបើរដ្ឋជាភាគីយល់ថាសមស្រប រដ្ឋជាភាគីនោះអាចបញ្ជូនជននោះទៅជំនុំជម្រះ នៅរដ្ឋភាគីដែលពាក់ព័ន្ធម្ខាងទៀតបាន ឲ្យតែរដ្ឋជាភាគីនោះបានបង្ហាញជូននូវការវាយតម្លៃបឋម")។

[៧៣៨] មាត្រា៥០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ I។ មាត្រា៥១ នៃអនុសញ្ញាទីក្រុងហ្សឺណែវ II។ មាត្រា១៣០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III។ មាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[៧៣៩] មាត្រា១៣០ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III។ មាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[៧៤០] មាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[៧៤១] *សូមមើលផងដែរ* របាយការណ៍របស់ក្រុមជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើង ផ្អែកតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ (ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ

៤០៥. បន្ថែមពីលើនេះ អនុសញ្ញាទីក្រុងហ្សឺណែវ និងជាពិសេសបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ បានចងក្រងនូវគោលការណ៍សំខាន់ៗនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៧៤២]។ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរជាក់លាក់មួយចំនួន ត្រូវបានរួមបញ្ចូលនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ដែលភាគច្រើនផ្អែកលើមូលដ្ឋានឧក្រិដ្ឋកម្ម ដែលបានកំណត់ដោយតុលាការព្រហ្មទណ្ឌ Nuremberg និងត្រូវបានទទួលស្គាល់នៅពេលអនុម័តជាឧក្រិដ្ឋកម្ម ដោយអនុលោមតាមគោលការណ៍ទូទៅនៃច្បាប់ដែលមាននៅក្នុងប្រព័ន្ធច្បាប់ជាតិ[៧៤៣]។ យុត្តិសាស្ត្រជាបន្តបន្ទាប់របស់តុលាការអន្តរជាតិនានា បានបញ្ជាក់ជាថ្មីនូវច្បាប់ទំនៀមទម្លាប់នៃអនុសញ្ញាទីក្រុងហ្សឺណែវ រួមមានបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ[៧៤៤] ព្រមទាំងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលជាប់ទាក់ទងនឹងការរំលោភបំពានបទដ្ឋានទាំងនេះ[៧៤៥]។

---

A/53/850-S/1999/231) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ៧៣ (ដោយបានបញ្ជាក់ថា ក្នុងអំឡុងពេលមានវិវាទ "ប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម គឺជាភាគីនៃអនុសញ្ញាទីក្រុងហ្សឺណែវទាំង៤ ឆ្នាំ១៩៤៧ នៃអំឡុងពេលពាក់ព័ន្ធ ទោះបីជាមិនមានប្រទេសណាមួយក្លាយជាភាគីនៃពិធីសារបន្ថែមឆ្នាំ១៩៧៧ មុនឆ្នាំ១៩៨០ ក៏ដោយ។ ដូច្នេះហើយ ការបំពារបំពានធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃអនុសញ្ញាទាំងនេះគឺត្រូវយកមកអនុវត្ត ទោះបីជាឧក្រិដ្ឋភាពត្រូវបានពន្លាតហួសពីការបំពារបំពានធ្ងន់ធ្ងរ តាមច្បាប់ទំនៀមទម្លាប់នាពេលនោះក៏ដោយ ។) (ជើងទំព័រត្រូវបានលុប) ។ សូមមើលផងដែរផ្នែក ១.៥។

[៧៤២] *សូមមើល* សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ II របស់ ICRC (Piclet ed. 1960) ជាពិសេស មាត្រា៦២ ទំព័រ២៨១-២៨៣ ("អំណាចដែលប្រកាសបដិសេធអនុសញ្ញា នៅតែចងភ្ជាប់កាតព្វកិច្ចដោយគោលការណ៍ ដែលមាននៅក្នុងអនុសញ្ញា នៅក្នុងកម្រិតដែលគោលការណ៍នោះបានលើកឡើងនូវវិធានជាសកល និងមិនអាចលុបបំបាត់បាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។ សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ III (Piclet ed. 1960) ជាពិសេស មាត្រា១៤២ ទំព័រ៦៤៦-៦៤៨។ ICRC សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ IV (Piclet ed. 1958) ជាពិសេស មាត្រា១៥៨ ទំព័រ៦២៣-៦២៦។

[៧៤៣] *សូមមើល* ICRC ច្បាប់មនុស្សធម៌នៃទំនៀមទម្លាប់អន្តរជាតិ ភាគ ១៖ *វិធាន* (J-M. Henckaerts និង L Doswald-Beck eds. 2005) ទំព័រ៥៧៤ សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ I (Pictet ed. 1952) ជាពិសេសមាត្រា៥០ ទំព័រ៣៧១។

[៧៤៤] *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Delatić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១១២-១១៣ (ទទួលស្គាល់លក្ខណៈទំនៀមទម្លាប់របស់អនុសញ្ញាទីក្រុងហ្សឺណែវ)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Simic និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-9-T) ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៨៦។ *សូមមើលផងដែរ សកម្មភាពកងទ័ព និងកងទ័ពប្រតិព័ទ្ធនៅក្នុង*

៤០៦. អាស្រ័យហេតុនេះ យើងអាចមើលឃើញថា ក្នុងអំឡុងពេលនោះជនជាប់ចោទអាចនឹងត្រូវបង្ខំឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើទាំងឡាយណាដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ជនជាប់ចោទក៏អាចដឹងអំពីការទទួលខុសត្រូវទាំងនេះ ដោយយោងទៅលើមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ។ ច្បាប់ស្តីអំពីការទទួលខុសត្រូវពិតជាមានថ្វីបើអនុសញ្ញាទីក្រុងហ្សឺណែវមិនបានចែងអំពីទោសប្បញ្ញត្តិ ចំពោះការរំលោភបំពានលើបទប្បញ្ញត្តិទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរក៏ដោយ[៧៤៦]។

---

*និងប្រឆាំងនឹងប្រទេសនីការ៉ាហ្គ័រ (ប្រទេសនីការ៉ាហ្គ័រ តទល់នឹង សហរដ្ឋអាមេរិក)* សាលក្រមអង្គសេចក្តី របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) (របាយការណ៍ ICJ ឆ្នាំ១៩៨៦) ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៦ ទំព័រ១១៤ កថាខណ្ឌ២១៨ ("ចំណុចខ្លះនៃអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានវិវត្តន៍ និងចំណុចខ្លះទៀតមិនមានលើសពីការលើកឡើងនូវគោលការណ៍ [ទូទៅជាមូលដ្ឋាន][នៃច្បាប់មនុស្សធម៌]")។ *នីត្យានុកូលភាពនៃការគម្រាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ* មតិយោបល់ណែនាំ ICJ (របាយការណ៍ ICJ ឆ្នាំ១៩៩៦) ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៦ ទំព័រ២២៦ កថាខណ្ឌ៧៩ ("វិធានជាមូលដ្ឋាន [ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ] ត្រូវបានអង្កេតដោយរដ្ឋទាំងអស់ថាតើរដ្ឋទាំងនោះបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងនោះដែរ ឬទេ [...] ពីព្រោះគោលការណ៍ទាំងនោះជាគោលការណ៍មិនអាចបំពាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។

[៧៤៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត* សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-AR72) ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៣៤។ ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់មេធាវីការពារក្តីលើយុត្តាធិការ*របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ១៣៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៥៧៧។

[៧៤៦] *សូមមើលការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗចំពោះមុខតុលាការយោធាអន្តរជាតិ៖ តុលាការ Nuremberg ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៤៦ ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦* (១៩៤៨) ភាគ២២ ទំព័រ៤៦៣-៤៦៤ (លើកឡើងថា ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល ក៏មិនអាចរួចខ្លួន ដោយគ្រាន់តែគ្មានបទប្បញ្ញត្តិសន្និសញ្ញាស្តីពីការផ្តន្ទាទោសចំពោះការបំពារបំពាននោះទេ)។

៤០៧. លើសពីនេះ លក្ខណៈឃោរឃៅនៃឧក្រិដ្ឋកម្មដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អាចបដិសេធចំពោះការអះអាងរបស់ជនជាប់ចោទ ដែលថាខ្លួនមិនបានដឹងអំពីប្រភេទនៃបទឧក្រិដ្ឋទាំងនោះ[៧៨៧]។

៤០៨. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា រាល់បទឧក្រិដ្ឋដែលបានចោទប្រកាន់លើជនជាប់-ចោទតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌតាមច្បាប់អន្តរជាតិ អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ។

២.៦.១ លក្ខខណ្ឌទូទៅសម្រាប់មាត្រា៦ នៃច្បាប់ អ.វ.ត.ក

៤០៩. មាត្រា៦ នៃច្បាប់ អ.វ.ត.ក រួមបញ្ចូលនូវលក្ខខណ្ឌនៃការអនុវត្តដូចមានចែងនៅក្នុងអនុសញ្ញានេះ។ អាស្រ័យហេតុនេះ ជនជាប់ចោទអាចត្រូវបានរកឃើញថាជាអ្នកទទួលខុសត្រូវចំពោះការបំពារ-បំពានយ៉ាងធ្ងន់ធ្ងរ នៅពេលដែលការបំពារបំពានយ៉ាងធ្ងន់ធ្ងរទាំងនេះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិដែល "ត្រូវទទួលបានការការពារ" ដោយអនុសញ្ញាទីក្រុងហ្សឺណែវ និងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលមានលក្ខណៈជាអន្តរជាតិតែប៉ុណ្ណោះ។

៤១០. លក្ខខណ្ឌដំបូងទាក់ទងនឹងយុត្តាធិការទាំងអស់នេះ ត្រូវបានកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យចំនួនប្រាំដោយតុលាការ ICTY ដែលលក្ខន្តិកៈរបស់តុលាការនេះផ្តល់យុត្តាធិការស្រដៀងគ្នាទៅលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[៧៨៨]។ លក្ខខណ្ឌទូទៅដូចខាងក្រោមត្រូវបាន

---

[៧៨៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* សេចក្តីសម្រេចស្តីពីសំណើសុំរបស់ Dragolijub Odjanovic ប្រឆាំងនឹងយុត្តាធិការ - សហឧក្រិដ្ឋកម្មរួម របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៤២ (កត់សម្គាល់ថា ចរិតគ្មានសីលធម៌ ឬឃោរឃៅនៃអំពើមួយ អាចដើរតួនាទីក្នុងការបដិសេធលើការលើកឡើងណាមួយដែលថា ចារីមិនបានដឹងអំពីលក្ខណៈឧក្រិដ្ឋនៃអំពើនោះ)។

[៧៨៨] យុត្តិសាស្ត្ររបស់តុលាការ ICTY មានលក្ខណៈទូលំទូលាយជាងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ផ្សេងទៀត ស្តីពីបញ្ហានៅពេលដែលលក្ខន្តិកៈរបស់តុលាការ ICTR និងតុលាការ SCSL មិនបានផ្តល់ដល់តុលាការទាំងអស់នោះនូវយុត្តាធិការលើបទល្មើសនានា ដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលបានផ្តល់នូវលក្ខណៈមិនមែនអន្តរជាតិនៃជម្លោះនានាដែលពាក់ព័ន្ធនឹងជម្លោះទាំងនោះ។

00573571



បង្កើតឡើង ដើម្បីបំពេញតាមនិយាមដែលតម្រូវឲ្យមាន៖ (i) អត្ថិភាពនៃជម្លោះប្រដាប់អាវុធ (ii) លក្ខណៈជាអន្តរជាតិនៃជម្លោះប្រដាប់អាវុធ (iii) ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងជម្លោះប្រដាប់អាវុធ (iv) ឋានៈរបស់ជនរងគ្រោះដែលជា "បុគ្គលដែលត្រូវទទួលបានការការពារ" តាមអនុសញ្ញាទីក្រុងហ្សឺណែវ និង (v) ការដឹងរបស់ជនជាប់ចោទ[៧៤៩]។

### ២.៦.១.១ អត្ថិភាពនៃជម្លោះប្រដាប់អាវុធ

៤១១. មាត្រា២ នៃអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន ("មាត្រា២រួម") ចែងថា បទប្បញ្ញត្តិនានារបស់អនុសញ្ញា រួមទាំងបទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អនុវត្តចំពោះ៖

> គ្រប់ករណីដែលសង្គ្រាមត្រូវបានប្រកាស ឬក្នុងករណីជម្លោះប្រដាប់អាវុធផ្សេងទៀតដែលអាចកើតមានឡើងរវាងរដ្ឋជាភាគីចំនួនពីរ ឬច្រើន ទោះបីជាស្ថានភាពនៃសង្គ្រាមមិនត្រូវបានទទួលស្គាល់ដោយភាគីមួយក្នុងចំណោមរដ្ឋជាភាគីនានាក៏ដោយ។ អនុសញ្ញាក៏ត្រូវអនុវត្តផងដែរ ចំពោះគ្រប់ករណីនៃការកាន់កាប់ទឹកដីមួយផ្នែក ឬទាំងស្រុងរបស់រដ្ឋជាភាគី ទោះបីជាការកាន់កាប់នោះមិនបានប្រើប្រាស់កម្លាំងប្រដាប់អាវុធក៏ដោយ។

៤១២. ចំពោះការបកស្រាយលើមាត្រា២ រួម យុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់ថា នៅពេលដែលគ្មានការប្រកាសសង្គ្រាមនោះទេ "ជម្លោះប្រដាប់អាវុធ" កើតមានឡើងនៅពេលណាដែលមានការដោះស្រាយដោយប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋនានា (នៅពេលដែលជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ) ឬមានអំពើហិង្សាប្រដាប់អាវុធអូសបន្លាយរវាងអាជ្ញាធររដ្ឋាភិបាល

[៧៤៩] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Naletilić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលICTY (IT-98-34-A) ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១១០ ដោយរៀបរាប់*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ៨០។ វាមិនដូចគ្នាទេ រវាងមាត្រា២ នៃលក្ខខណ្ឌន្តិកៈ របស់តុលាការ ICTY និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក ដែលមាត្រា៦នេះតម្រូវផងដែរថា អំពើនោះត្រូវប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះដឹងលក្ខខណ្ឌតម្រូវទាំងនេះ ដែលលក្ខខណ្ឌទាំងនេះត្រូវយកមកអនុវត្តចំពោះបទចោទទាំងអស់ នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងបទល្មើសដែលបានចោទប្រកាន់តាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក។

និងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធ ឬរវាងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធទាំងនោះនៅក្នុងរដ្ឋមួយ (នៅពេលដែលជម្លោះប្រដាប់អាវុធជាជម្លោះផ្ទៃក្នុង)[៧៥០]។

២.៦.១.២ លក្ខណៈជាអន្តរជាតិនៃជម្លោះប្រដាប់អាវុធ

៤១៣. មាត្រា២ រួម បានកំណត់បន្ថែមថា ជម្លោះប្រដាប់អាវុធត្រូវមានលក្ខណៈជាអន្តរជាតិ[៧៥១]។

៤១៤. ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិដោយមិនអាចប្រកែកតវ៉ាបានក្នុងករណីដែលជម្លោះនោះកើតមានឡើងរវាងរដ្ឋចំនួនពីរ ឬច្រើន។ ទោះបីជាមិនមានការទទួលស្គាល់ជាផ្លូវការពីរដ្ឋដែលមានសង្គ្រាមក៏ដោយ ក៏បទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៅតែអាចយកមកអនុវត្តបានផងដែរ។ ដូចគ្នានេះដែរ ការប្រយុទ្ធគ្នាដែលកើតមានឡើងតាមព្រឹត្តហេតុ (*de facto*) រវាងរដ្ឋពីរ ឬច្រើនអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវលក្ខខណ្ឌជាអន្តរជាតិក្នុងករណីដែលការប្រយុទ្ធគ្នានោះកើតមានឡើងរវាងកងកម្លាំងរបស់រដ្ឋរៀងៗខ្លួន។ ដូចមានបញ្ជាក់ក្នុងសេចក្តីអធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវIV ៖

> ជម្លោះដែលកើតមានឡើងរវាងរដ្ឋពីរ ហើយឈានដល់មានអន្តរាគមន៍ពីសមាជិកនៃកម្លាំងប្រដាប់អាវុធរៀងៗខ្លួន គឺជាជម្លោះប្រដាប់អាវុធនៅក្នុងអត្ថន័យនៃមាត្រា២

---

[៧៥០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ១៨៣-១៨៤ ដោយរៀបរាប់*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីកាលើសំណើរបស់មេធាវីការពារក្តីសុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។ ផ្ទុយទៅវិញ បទប្បញ្ញត្តិនៃមាត្រា៣រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមាន ចរិតលក្ខណៈមិនមែនអន្តរជាតិ។

[៧៥១] នេះជាលក្ខខណ្ឌចាំបាច់នៃមាត្រា២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Tadić សាលដីកាលើសំណើរបស់មេធាវីការពារក្តីសុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើយុត្តាធិការរបស់អង្គជំនុំជម្រះរបស់តុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Naletilić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-34-A) ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១១៧។

ទោះបីជាភាគីមួយបដិសេធអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធនោះក៏ដោយ។ វាមិនមាននូវភាពខុសប្លែកគ្នា ថាតើជម្លោះនោះមានរយៈពេលយូរប៉ុណ្ណា ឬការកាប់សម្លាប់បានកើតមានច្រើនប៉ុណ្ណានោះទេ។ ការគោរពគ្នាក្នុងនាមជាមនុស្សជាតិក្នុងពេលមានសង្គ្រាម មិនចាំបាច់ទាល់តែជនរងគ្រោះមានចំនួនច្រើននោះទេ។

អនុសញ្ញាចែងតែពីករណីដែលភាគីមួយ ក្នុងចំណោមភាគីនានាបដិសេធអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ។ គេអាចឆ្ងល់ថា តើនឹងមានគោលជំហរយ៉ាងណា ប្រសិនបើភាគីទាំងពីរដែលមានជម្លោះប្រដាប់អាវុធ ធ្វើការបដិសេធអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធនោះ។ ទោះបីជានៅក្នុងស្ថានភាពនោះក៏ដោយ វានឹងមិនបង្ហាញឱ្យឃើញថា តាមរយៈកិច្ចព្រមព្រៀងតុល្យភាព ភាគីទាំងនោះអាចរារាំងមិនឱ្យមានការអនុវត្តអនុសញ្ញានោះឡើយ។ គេមិនត្រូវភ្លេចទេថា អនុសញ្ញាត្រូវបានធ្វើសេចក្តីព្រាងជាដំបូង និងភាគច្រើនគឺដើម្បីការពារបុគ្គលមិនមែនដើម្បីបម្រើផលប្រយោជន៍របស់រដ្ឋនោះទេ[៧៥២]។

៤១៥. បទប្បញ្ញត្តិមួយចំនួនរបស់អនុសញ្ញាទីក្រុងហ្សឺណែវចង្អុលបង្ហាញថា ការអនុវត្តបទប្បញ្ញត្តិទៅតាមភូមិសាស្ត្រ និងពេលវេលាដែលមានជម្លោះប្រដាប់អាវុធ បានលាតសន្ធឹងហួសពីតំបន់ និងពេលវេលាដែលមានជម្លោះពិតប្រាកដ[៧៥៣]។ នៅពេលដែលគេអាចបញ្ជាក់បានថា អត្ថិភាពនៃជម្លោះ-ប្រដាប់អាវុធដែលមានលក្ខណៈជាអន្តរជាតិបានកើតមានឡើងនៅកន្លែង និងក្នុងអំឡុងពេលដែលជាប់

[៧៥២] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សេចក្តីអធិប្បាយលើអនុសញ្ញាទីក្រុងហ្សឺណែវ IV (ការបោះពុម្ព ឆ្នាំ១៩៥៨) ជាពិសេស មាត្រា២ ទំព័រ២០-២១។ សូមមើលផងដែររឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Kordić* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣៧៣ ("[មាត្រា២ រួម] មិនអាចធ្វើការបកស្រាយដើម្បីកំណត់អំពីលក្ខណៈនៃជម្លោះថាជាអន្តរជាតិបាននោះទេ បើករណីដែលពុំមានភាគីដែលមានជម្លោះប្រដាប់អាវុធណាមួយទទួលស្គាល់ស្ថានភាពនៃសង្គ្រាមនោះ។ គោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ដូចជា ការការពារជនដែលត្រូវទទួលបានការការពារ នឹងមិនធ្វើឱ្យមានគ្រោះថ្នាក់នោះទេ ប្រសិនបើរដ្ឋនានាត្រូវបានអនុញ្ញាតឱ្យគេចចេញពីកាតព្វកិច្ចរបស់ខ្លួនតាមរយៈការបដិសេធ ចំពោះស្ថានភាពនៃជម្លោះប្រដាប់អាវុធ")។

[៧៥៣] សូមមើលឧទាហរណ៍ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៥ (ដែលផ្តល់តាមការស្នើសុំដល់ឈ្លើយសឹកសង្គ្រាមចាប់ពីពេលដែលពួកគេបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ រហូតទាល់តែមានការដោះលែងចុងក្រោយ និងការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ)។

00573574



ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនោះ ច្បាប់មនុស្សធម៌អន្តរជាតិនឹងត្រូវយកមកអនុវត្តនៅលើដែនដីទាំងមូលរបស់រដ្ឋដែលជាប់ពាក់ព័ន្ធ ទោះបីជាការប្រយុទ្ធគ្នានោះកើតមានឡើងនៅទីនោះ ឬមិនមានក៏ដោយ ហើយនឹងបន្តអនុវត្តទោះបីជាក្រោយពេលនៃការឈប់បាញ់គ្នារហូតទទួលបានសន្តិភាព[៧៥៤]។

២.៦.១.៣ ទំនាក់ទំនងរវាងការប្រព្រឹត្តិរបស់ជនជាប់ចោទនឹងជម្លោះប្រដាប់អាវុធ

៤១៦. ត្រូវតែមានទំនាក់ទំនងជិតស្និទ្ធរវាងការប្រព្រឹត្តិរបស់ជនជាប់ចោទនឹងជម្លោះប្រដាប់អាវុធដែលនាំឲ្យមានការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ។ ដើម្បីបញ្ជាក់ថាទំនាក់ទំនងនេះកើតមានឡើង អំពើប្រព្រឹត្តរបស់ជនជាប់ចោទត្រូវតែមាន “ភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធ” ទៅនឹងជម្លោះប្រដាប់អាវុធទាំងមូល[៧៥៥]។ វាមិនមានភាពចាំបាច់ក្នុងការបញ្ជាក់ថា មាននូវសកម្មភាពនៃការវាយប្រហារគ្នានៅក្នុងតំបន់ដែលបានចោទប្រកាន់ថាអំពើរបស់ជនជាប់ចោទបានកើតឡើងនៅទីនោះ ឬមួយអំពើដែលប្រព្រឹត្តដោយជនជាប់ចោទគឺជាផ្នែកមួយនៃការអនុវត្តគោលនយោបាយ ឬជាការអនុវត្តដែលបានធ្វើឡើងដោយភាគីម្ខាងដែលមានជម្លោះនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលការប្រព្រឹត្តិនានាបានកើតមានឡើងនៅក្នុងជុំរំអ្នកទោសដោយគ្មានការអើពើ ឬការប្រព្រឹត្តនោះបានទទួលការអនុញ្ញាតពីអាជ្ញាធរដែលគ្រប់គ្រងជំរំនោះ ហើយការប្រព្រឹត្តនោះគឺជាគោលនយោបាយដែលគេបានទទួលយកមកអនុវត្តចំពោះអ្នកទោស អំពើទាំងនោះនឹងត្រូវមើលឃើញថាមានទំនាក់ទំនង “យ៉ាងជិតស្និទ្ធ” ទៅនឹងជម្លោះ-ប្រដាប់អាវុធ[៧៥៦]។

---

[៧៥៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកាលើសំណើរបស់មេធាវីការពារក្តីសុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំលើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ២០៨-២១១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង* អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣២១។

[៧៥៥] *រឿងក្តី រដ្ឋអាជ្ញា និង Tadić* សាលដីកាលើសំណើរបស់មេធាវីការពារក្តីសុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំលើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-AR72) ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។

[៧៥៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់ និងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៥៧២ -៥៧៥។

### ២.៦.១.៤ ឋានៈជា "បុគ្គលដែលត្រូវទទួលបានការការពារ" ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

៤១៧. មាត្រា៦ នៃច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការដល់អង្គជំនុំជម្រះទៅលើ "អំពើប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវទទួលបានការការពារស្របតាមបទប្បញ្ញត្តិ" នៃអនុសញ្ញាទីក្រុងហ្សឺណែវ[៧៥៧]។ សេចក្តីយោងនេះគ្របដណ្តប់លើ "បុគ្គលដែលត្រូវទទួលបានការការពារ" ដូចមានចែងស្របតាមមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III (ដែលពាក់ព័ន្ធនឹងឈ្លើយសឹក) និងអនុសញ្ញាទីក្រុងហ្សឺណែវ IV (ដែលពាក់ព័ន្ធនឹងជនស៊ីវិល)[៧៥៨]។

៤១៨. អនុលោមតាមមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III ឈ្លើយសឹកគឺជាជនទាំងឡាយរួមទាំង "សមាជិកនានានៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីដែលមានជម្លោះ" ដែលបាន "ធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ"។ មាត្រា៤(១) នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV កំណត់បុគ្គលដែលត្រូវទទួលបានការការពារថា ជាជនទាំងឡាយណាដែល "ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះ ឬដែលកាន់កាប់អំណាច ដែលពួកគេមិនមែនជាប្រជាជាតិដូចគ្នា"។

៤១៩. អង្គជំនុំជម្រះតុលាការកំពូល ICTY បានអនុម័តនូវការបកស្រាយមួយដែលមានលក្ខណៈទន់ភ្លន់អំពីលក្ខខណ្ឌកំណត់អំពីសញ្ជាតិដែលបានគូសបញ្ជាក់នៅក្នុងមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។ ដោយការប្រើប្រាស់កម្មវត្ថុ និងគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ គេបានរកឃើញថា ជនណាម្នាក់ក៏អាចត្រូវបានចាត់ទុកថាជាជនដែលត្រូវទទួលបានការការពារដែរ ទោះបីជា

---

[៧៥៧] ទោះបីជាទ្រព្យសម្បត្តិត្រូវទទួលបាន "ការការពារ" ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវក៏ដោយ ក៏បទល្មើសដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទគឺពាក់ព័ន្ធតែនឹងជនដែលត្រូវទទួលបានការការពារតែប៉ុណ្ណោះ អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក។

[៧៥៨] មាត្រា១៣, ២៤, ២៥ និង២៦ នៃអនុសញ្ញាទីក្រុងហ្សឺណែវ I និង មាត្រា១៣, ៣៦, ៣៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ II ក៏បានកំណត់អំពីអ្នកទាំងឡាយណាដែលត្រូវទទួលបានការការពារស្របតាមបទប្បញ្ញត្តិទាំងអស់នេះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះជាដំបូងមានការពាក់ព័ន្ធតែនឹងអនុសញ្ញាទីក្រុងហ្សឺណែវ III និង IV ប៉ុណ្ណោះ ដោយសារតែអនុសញ្ញាទាំងនេះទាក់ទិននឹងអ្នកទោសសង្គ្រាម និងជនស៊ីវិល។

គាត់មានសញ្ជាតិដូចគ្នានឹងភាគីដែលមានជម្លោះក៏ដោយ[៧៥៩]។ អង្គជំនុំជម្រះតុលាការកំពូល ICTY យល់ឃើញថា ស្ថានភាពរបស់បុគ្គលដែលត្រូវទទួលបានការការពារគឺមិនត្រូវពឹងផ្អែកលើចំណងជាផ្លូវការ និងទំនាក់ទំនងផ្លូវច្បាប់សុទ្ធសាធនោះទេ ប៉ុន្តែ ត្រូវពឹងផ្អែកលើសារធាតុនៃទំនាក់ទំនងដែលមានរវាងបុគ្គល និងរដ្ឋ[៧៦០]។ ការពិចារណាដ៏សំខាន់នៅពេលធ្វើការវិភាគលើទំនាក់ទំនងដ៏សំខាន់ទាំងនេះគឺភក្តីភាព ឬការខ្វះភក្តីភាព ដែលបុគ្គលមានចំពោះភាគីដែលមានជម្លោះ[៧៦១]។ ដូចនេះ ជនស៊ីវិលអាចត្រូវបានចាត់ទុកថាជា "បុគ្គលដែលត្រូវទទួលបានការការពារ" សម្រាប់គោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV នៅពេលដែលពួកគេត្រូវបានយល់ឃើញពីសំណាក់រដ្ឋដែលពួកគេស្ថិតនៅក្នុងកណ្តាប់ដៃ "ថាជាកម្មសិទ្ធិរបស់ភាគីប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធ និងដែលបានដាក់ការគំរាមកំហែងដល់រដ្ឋនោះ"[៧៦២]។

---

[៧៥៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦៦ ("មិនត្រឹមតែអត្ថបទ និងសេចក្តីព្រាងប្រវត្តិនៃអនុសញ្ញាប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៀត កម្មវត្ថុនិងគោលបំណងរបស់អនុសញ្ញាលើកឡើងថា ភក្តីភាពចំពោះភាគីដែលមានជម្លោះ និងការគោរពតបវិញ ការគ្រប់គ្រងលើជនទាំងឡាយដោយរដ្ឋនេះនៅក្នុងដែនដីដែលបានផ្តល់ឲ្យ អាចត្រូវបានយល់ឃើញថាជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីកា របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៥៨-៧៣ (លើកឡើងថាវិធីសាស្រ្តនៃការបកស្រាយនេះស្របទៅនឹងវិធាននៃការបកស្រាយសន្ធិសញ្ញាដែលបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងវីយែន)។

[៧៦០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦៦, ១៦៨។

[៧៦១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង* អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣៣១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥១។

[៧៦២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៨៤។

### ២.៦.១.៥ ការដឹងរបស់ជនជាប់ចោទ

៤២០. អង្គជំនុំជម្រះតុលាការកំពូល ICTY បានផ្តល់សម្អាងហេតុថា ប្រសិនបើទង្វើមួយចំនួនក្លាយជាបទល្មើសតែក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ អត្ថិភាពនៃជម្លោះនោះមិនគ្រាន់តែជាតម្រូវការជាមុននៃយុត្តាធិការនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាធាតុផ្សំដ៏សំខាន់នៃបទល្មើសនានាដែលបានចោទប្រកាន់ផងដែរ។ ហេតុនេះ គេបានរកឃើញថា ជនជាប់ចោទត្រូវតែបានដឹងថាអំពើឧក្រិដ្ឋរបស់ខ្លួនមានការទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ "ឬក៏យ៉ាងហោចណាស់គាត់បានដឹងអំពីកាលៈទេសៈជាក់ស្តែង ដែលក្រោយមកបានធ្វើឲ្យចៅក្រមធ្វើការសន្និដ្ឋានបានថា ជម្លោះប្រដាប់អាវុធនោះគឺជាជម្លោះអន្តរជាតិ"[៧៦៣]។

៤២១. ការដឹងរបស់ជនជាប់ចោទចំពោះហេតុការណ៍ទាំងពីរនេះ៖ ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធលក្ខណៈជាអន្តរជាតិ និងស្ថានភាពរបស់ជនរងគ្រោះ ដែលត្រូវទទួលបានការការពារ ទើបតែត្រូវបានផ្សព្វផ្សាយទូលំទូលាយដោយតុលាការអន្តរជាតិនៅប៉ុន្មានឆ្នាំថ្មីៗនេះប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ការដឹងអំពីហេតុការណ៍ទាំងពីរខាងលើ គឺកើតចេញពីការអនុវត្តនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយត្រូវតែអនុវត្តដូចគ្នាចំពោះអ្វីដែលបានកើតឡើងនៅក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៤២២. ដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋកម្ម អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ជនជាប់ចោទត្រូវមានការដឹងយ៉ាងពេញលេញ អំពីជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ និងឋានៈរបស់ជនរងគ្រោះ ដែលត្រូវទទួលបានការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ។ ការដឹងរបស់ជនជាប់ចោទថា រដ្ឋបរទេសមានការពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធ និងថាជនរងគ្រោះដែលគ្រប់-

---

[៧៦៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Naletilić* និងអ្នកផ្សេងទៀត សាលដីកា របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-34-A) ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១១០-១១៨ ។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣១១។ សូមមើលផងដែរមាត្រា៨ (ឧក្រិដ្ឋកម្មសង្គ្រាម) នៃ "ធាតុផ្សំនៃបទឧក្រិដ្ឋ" របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC-ASP/1/3 (ផ្នែក II-B) ចូលជាធរមានថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២។

គ្រងដោយភាគីបដិបក្ខក្នុងជម្លោះប្រដាប់អាវុធនោះ នឹងមានលក្ខណៈគ្រប់គ្រាន់សម្រាប់បំពេញនូវលក្ខខណ្ឌដឹង។

### ២.៦.២ សំអាងហេតុទាក់ទងនឹងលក្ខខណ្ឌទូទៅសម្រាប់មាត្រា៦ នៃច្បាប់ អ.វ.ត.ក

#### ២.៦.២.១ អត្ថិភាពនៃជម្លោះប្រដាប់អាវុធ

៤២៣. អង្គជំនុំជម្រះយល់ឃើញថា អរិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាមបានកើតមានពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (ផ្នែក ២.១) ។ ការប្រយុទ្ធគ្នារវាងកម្ពុជាប្រជាធិបតេយ្យនិងប្រទេសវៀតណាម ទោះបីជាមានតិចតួចក្តីនៅតាមព្រំដែន ឬការវាយលុកចូលកាន់តែជ្រៅទៅៗក្នុងទឹកដីកម្ពុជា និងវៀតណាម បានបន្តកើតមានពេញរយៈកាលខាងលើ បើទោះបីជា កម្ពុជាប្រជាធិបតេយ្យនិងប្រទេសវៀតណាម ដំបូងឡើយមានបំណងលាក់-បាំងនូវស្ថានភាពនោះក៏ដោយ (ផ្នែក ២.១.១) ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតមានឡើងគ្រប់ពេលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានធ្វើការកែប្រែ ។

#### ២.៦.២.២ ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ

៤២៤. ភស្តុតាងលើសលុបបានបញ្ជាក់ថា អំពើនានារបស់ជនជាប់ចោទប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារនៅមន្ទីរស២១ មានចំណងទាក់ទងយ៉ាងជិតស្និតជាមួយនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម[៧៦៤]។ អ្នកជាប់ឃុំជនជាតិវៀតណាម គឺជាអ្នកជាប់ឃុំបរទេសដែលមានចំនួនច្រើនជាងគេបំផុតនៅមន្ទីរស២១ (ទួលស្លែង) ហើយចំនួនអ្នកជាប់ឃុំជនជាតិ

---

[៧៦៤] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៤ (ទទួលស្គាល់ថាបុគ្គលទាំងនោះត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១ ដោយសារតែជម្លោះប្រដាប់អាវុធ)។

វៀតណាមមានកាន់តែច្រើនឡើង នៅពេលមានជម្លោះកាន់តែខ្លាំង ជាពិសេសពេញមួយឆ្នាំ១៩៧៨[៧៦៥]។ ទាហានវៀតណាមដែលជាប់ឃុំនៅមន្ទីរ ស២១ (ទួលស្លែង) ត្រូវបានបង្ខំឲ្យផ្ដល់ចម្លើយសារភាពទាក់ទងនឹងចេតនារបស់វៀតណាមក្នុងការឈ្លានពានកម្ពុជា និងត្រូវបានសួរចម្លើយទាក់ទងនឹងបញ្ហាស៊ើបយកការណ៍របស់យោធា។ ចម្លើយសារភាពទាំងនេះត្រូវបានផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យក្នុងគោលបំណងសម្រាប់ឃោសនាចាប់តាំងពីខែមករា ឆ្នាំ១៩៧៨[៧៦៦] រហូតមក។

### ២.៦.២.៣ ឋានៈជា "បុគ្គលដែលត្រូវទទួលបានការការពារ" ផ្អែកតាម អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

៤២៥. ឈ្លើយសឹក និងជនស៊ីវិលវៀតណាមមិនតិចជាង៣៤៥នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) និងត្រូវបានចាត់ទុកថាជាបុគ្គលដែលត្រូវទទួលបានការការពារ ផ្អែកតាមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[៧៦៧]។ អ្នកជាប់ឃុំជនជាតិវៀតណាមត្រូវបានចុះក្នុងបញ្ជី ក្នុងនោះរួមមាន ទាហាន (១២២ នាក់) ជនស៊ីវិលវៀតណាម (៧៩នាក់) និងគិញ (១៤៤នាក់)[៧៦៨]។ ឆ្លើយសឹក

---

[៧៦៥] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧១។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤-៦។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៩-៥០។ *សូមមើលផងដែរ* "ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួនតាមខែនីមួយៗ" ឯកសារ E68.32។

[៧៦៦] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧, ៣៥-៣៦។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០។ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ២០។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៤-២៥។

[៧៦៧] *សូមមើល* "បញ្ជីឈ្មោះអ្នកទោសជនជាតិវៀតណាមដែលបានចូលមកមន្ទីរស២១" ឯកសារ E68.27។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧២។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៣, ៤-៥។ សូមមើលផងដែរផ្នែក ២.៣.៣.៤.២ ។

[៧៦៨] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានចាត់ទុកថាជាទាហានវៀតណាម" ឯកសារ E68.28។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានចាត់ទុកថាជាគិញវៀតណាម" ឯកសារ E68.29។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកំណត់ថាជាជនជាតិវៀតណាម" ឯកសារ E68.30។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម" ឯកសារ E68.31។ *សូមមើលផងដែរ* យោបល់របស់ជនជាប់ចោទចំពោះបញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលបានកែសម្រួល៖ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៦។

ជនជាតិវៀតណាម ដែលភាគច្រើនត្រូវបានគេចាប់ខ្លួនបាននៅសមរភូមិ ត្រូវបានបញ្ជូនទៅមន្ទីរស២១ (ទួលស្លែង) ក្នុងសម្លៀកបំពាក់ឯកសណ្ឋានយោធា[៧៦៩]។ ក្នុងចំណោមជនស៊ីវិលវៀតណាម ក្នុងនោះ ក៏មានស្ត្រី និងកុមារផងដែរ ដែលត្រូវបាននាំខ្លួនមកមន្ទីរស២១ (ទួលស្លែង) ជាមួយនឹងឪពុកម្តាយរបស់ពួកគេ[៧៧០]។ ជនជាប់ចោទបានលើកឡើងថា "គិញ" ដែលពាក្យនេះត្រូវបានចាត់ថ្នាក់តាមបញ្ជាថ្នាក់លើរបស់គាត់ ប៉ុន្តែតាមពិតអ្នកទាំងអស់នោះអាចជាជនស៊ីវិល ឬទាហាន[៧៧១]។

៤២៦. បន្ថែមពីលើនេះ ជនកម្ពុជាមួយចំនួនដែលមកពីភូមិភាគបូព៌ា ទោះបីមានភក្តីភាពពិតប្រាកដ ឬមានទំនាក់ទំនងទៅរកវៀតណាម អ្នកទាំងនោះត្រូវបានឃុំខ្លួន ឬសម្លាប់ចោលដូចអ្នកគាំទ្រវៀតណាមផងដែរ[៧៧២]។ ទោះបីជាប្រជាជនខ្មែរក្តី ក៏បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ពួកគេមានស្វាមីភក្តិជាមួយវៀតណាម ដូចនេះវាគម្រាមកំហែងដល់កម្ពុជាប្រជាធិបតេយ្យ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំជនជាតិខ្មែរទាំងនេះគឺជាបុគ្គលត្រូវទទួលបានការការពារ ដែលស្ថិតនៅក្នុងបទប្បញ្ញត្តិនៃមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវIV។

---

[៧៦៩] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧៣-៧៤។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦, ១៣-១៤។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ២៩-៣០។

[៧៧០] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥, ៣៥-៣៦។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៥។ ប្រតិចារឹក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ប៉េស ម៉ាត់) ទំព័រ៦៧-៦៨។ ចំពោះគោលនយោបាយរបស់មន្ទីរស២១ កុមារមិនត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកទោសទេ ។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។

[៧៧១] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨, ៤២។

[៧៧២] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ (Nayan CHANDA) ទំព័រ១៧។ ប្រតិចារឹក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ១២-១៣។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៤៩-៥០។ *សូមមើលផងដែរ* "ចំនួននៃការចាប់ខ្លួនមកពីភូមិភាគបូព៌ាតាមខែនីមួយៗ" ឯកសារ E68.46 បង្ហាញពីចំនួននៃការចាប់ខ្លួនដែលកើនឡើងខ្ពស់ក្នុងឆ្នាំ១៩៧៨។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលអ្នកទាំងនោះត្រូវបានចាប់មកពីភូមិភាគបូព៌ា" ឯកសារ E68.45 បង្ហាញពីចំនួនអ្នកទោសសរុបចូលមកចំនួន១១៦៥នាក់។

### ២.៦.២.៤ ការដឹងរបស់ជនជាប់ចោទ

៤២៧. ទោះបីជាមានការទទួលស្គាល់ថា ជម្លោះរវាងប្រទេសកម្ពុជា និងវៀតណាមចាប់ផ្ដើមមុនថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៨ ក៏ដោយ ប៉ុន្តែជនជាប់ចោទបានបញ្ជាក់ថា គាត់ទើបតែបានដឹងអំពីជម្លោះនេះ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ[៧៧៣]។

៤២៨. មិនមានការតវ៉ាទេដែលថាកំណត់ត្រាលើកដំបូងនៃអ្នកជាប់ឃុំនៅមន្ទីរស២១ ដែលត្រូវបាន ចាត់ទុកថាជា "ជនជាតិវៀតណាម" បានចុះកាលបរិច្ឆេទចាប់តាំងពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ជនជាប់ចោទបានរំឭកថា អ្នកជាប់ឃុំវៀតណាម ដែលរួមមាន ជនស៊ីវិល និងទាហាន ត្រូវបានគេយក មកមន្ទីរស២១ (ទួលស្លែង) នៅចុងឆ្នាំ១៩៧៥ ទោះបីជាពេលនោះ ចំនួនអ្នកជាប់ឃុំនៅមាន តិចតួចក្ដី[៧៧៤]។ ពេលខ្លះ ជនជាប់ចោទបានបញ្ជាឲ្យបុគ្គលិកមន្ទីរស២១ យករថយន្តទៅដឹកជញ្ជូនអ្នក-ជាប់ឃុំជនជាតិវៀតណាមពីសមរភូមិទៅមន្ទីរស២១(ទួលស្លែង) និងបានបញ្ជូនឈាមរបស់អ្នកជាប់ឃុំ នៅមន្ទីរស២១ ទៅមន្ទីរពេទ្យសេនាធិការ ដើម្បីបញ្ចូលឲ្យទាហានរបស់កងទ័ពបដិវត្តកម្ពុជា ដែល រងរបួសនៅឆ្នាំ១៩៧៧ ឬ១៩៧៨[៧៧៥]។ ជនជាប់ចោទបានដឹងអំពីការបន្តបោសសម្អាតប្រជាជនកម្ពុជា ដោយសារតែយល់ថាពួកគាត់មានស្វាមីភក្ដិជាមួយវៀតណាម ព្រមទាំងការពង្រាយកម្លាំងនៅសមរភូមិ

---

[៧៧៣] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥១-៥២, ៥៤-៥៦, ៦២-៦៣, ៦៥-៦៧។

[៧៧៤] ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៥៥។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១។

[៧៧៥] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧២-៧៣។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣១-៣៣។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦២-៦៤។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៣០ ។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៨៧-៨៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ១៣, ២៩-៣០។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ១៥-១៦, ៤៩។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៩-៣០។

00573582



របស់ សុន សេន នៅខែសីហា ឆ្នាំ១៩៧៧[៧៧៦]។ ជនជាប់ចោទក៏បានពិនិត្យ សង្ខេប និងកែសម្រួល នូវចម្លើយសារភាពរបស់អ្នកជាប់ឃុំជនជាតិវៀតណាមចាប់តាំងពីខែមេសា ឆ្នាំ១៩៧៦មក[៧៧៧]។

៤២៩. អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទបានដឹងអំពីជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម យ៉ាងហោចណាស់ ក៏ចាប់តាំងពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ មកដែរ។ បន្ថែមពីលើនេះ ជនជាប់ចោទ បានដឹងថា អ្នកជាប់ឃុំនៅមន្ទីរស២១ រួមមានបុគ្គលដែលត្រូវទទួលបានការការពារ ពោលគឺជនស៊ីវិល និងឈ្លើយសឹកជនជាតិវៀតណាម ក៏ដូចជាជនជាតិខ្មែរដែលចាត់ទុកថាជាអ្នកគាំទ្រវៀតណាមផង ដែរ។

### ២.៦.៣ ច្បាប់ និងសំអាងហេតុទាក់ទងនឹងបទល្មើសជាក់លាក់មួយចំនួនដែលជាការបំពារ បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩

៤៣០. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចោទប្រកាន់ជនជាប់ចោទពីបទ បំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចខាងក្រោម៖

(i) ការធ្វើមនុស្សឃាតដោយចេតនា (ii) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ (iii) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព (iv) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់ (v) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[៧៧៨]។

---

[៧៧៦] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៨។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៣, ៤៣-៤៤, ៤៧, ៥៦។

[៧៧៧] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦-៧, ៨, ៩-១០, ១១-១៣, ៣៦។ "ចម្លើយសារភាពរបស់អ្នកទោសជនជាតិវៀតណាម ឈ្មោះ ត្រឹង យ៉ាំងឡាក នៅមន្ទីរ ស២១" ឯកសារ E5/2.13, ERN (ភាសាខ្មែរ) 00284002។

[៧៧៨] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ទំព័រ៧២-៧៣ ។ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាបញ្ជូន រឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ប្រើពាក្យ "ការធ្វើបាបដោយអមនុស្សធម៌" ជាភាសាអង់គ្លេស "inhumane

00573583



### ២.៦.៣.១ ការធ្វើមនុស្សឃាតដោយចេតនា

៤៣១. ធាតុផ្សំបទល្មើសនៃការធ្វើមនុស្សឃាតដោយចេតនាតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក គឺដូចគ្នាទៅនឹងធាតុផ្សំនៃការធ្វើមនុស្សឃាតតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) (ផ្នែក ២.៥.៣.១)។

### ២.៦.៣.២ សំអាងហេតុទាក់ទងនឹងការធ្វើមនុស្សឃាតដោយចេតនា

៤៣២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ១៥១. បុគ្គលិកមន្ទីរស២១ បង្កដោយចេតនាឲ្យមានការស្លាប់បុគ្គលដែលត្រូវទទួលបានការការពារយ៉ាងហោចណាស់៤០០នាក់ ដោយផ្ទាល់ និងដោយប្រយោល តាមរយៈវិធីសាស្ត្រផ្សេងៗ[៧៧៩]។

៤៣៣. ជនជាប់ចោទបានបញ្ជាក់ថា ឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកគាំទ្រវៀតណាម ដែលបានឃុំខ្លួននៅមន្ទីរស២១បានស្ថិតនៅក្រោមស្ថានភាពនៃការឃុំខ្លួនដូចគ្នាទៅនឹងអ្នក-ជាប់ឃុំដទៃទៀតដែរ និងចុងបញ្ចប់ត្រូវបានសម្លាប់ចោលដោយជៀសមិនផុត ដោយមិនមានលក្ខខណ្ឌអនុគ្រោះចំពោះឈ្លើយសឹក និងជនស៊ីវិលទាំងនោះ ដោយសារសញ្ជាតិរបស់ពួកគាត់ ឬឋានៈដែលត្រូវបានទទួលការការពារនោះឡើយ[៧៨០]។

---

treatment” ដោយឡែក អនុសញ្ញាទីក្រុងហ្សឺណែវប្រើពាក្យ “ការធ្វើបាបដោយអមនុស្សធម៌” ជាភាសាអង់គ្លេស “inhuman treatment”។ អង្គជំនុំជម្រះ យល់ឃើញថា ពាក្យទាំងពីរនេះមានន័យដូចគ្នា។

[៧៧៩] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៥១។

[៧៨០] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤០-៤១ (“មនុស្សដែលគេបញ្ជូនចូល ស២១ សុទ្ធតែជាខ្មាំងដែលត្រូវកម្ទេច។ ដូច្នេះ រួមទាំងអស់នោះ វាពិតជាមានជនជាតិវៀតណាម ទាហាន ជនស៊ីវិល ចារបុរសដូចគ្នា គេបញ្ជូនចូលមកហើយ យើងខ្ញុំត្រូវតែកម្ទេចដោយខានមិនបាន”)។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧-៣៨។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ ៤៣-៤៤។

00573584



៤៣៤. ការសម្លាប់បុគ្គលដែលត្រូវទទួលបានការការពារត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈដូចគ្នាទៅនឹងការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស២១ដទៃទៀតដែរ[៧៨១]។ ដូចគ្នាទៅនឹងអ្នកជាប់ឃុំដទៃទៀតដែរ ជាទូទៅបុគ្គលដែលត្រូវទទួលបានការការពារ ត្រូវបានសម្លាប់នៅជើងឯក និងនៅមន្ទីរស២១ (ទួលស្លែង)[៧៨២]បន្ទាប់ពីពួកគេបានផ្តល់ចម្លើយសារភាពរួចហើយប្រសិនបើមាន[៧៨៣]។ កុមារជនជាតិវៀតណាមក៏ត្រូវបានសម្លាប់នៅមន្ទីរស២១ (ទួលស្លែង) ឬនៅជើងឯកផងដែរ បន្ទាប់ពីកុមារទាំងនោះត្រូវបានគេបំបែកចេញពីឪពុកម្តាយរបស់ពួកគេ[៧៨៤]។

៤៣៥. ក្រៅពីអ្នកជាប់ឃុំដែលត្រូវបានសម្លាប់ លក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរស២១ ក៏បានធ្វើឲ្យអ្នកជាប់ឃុំជាច្រើនបានស្លាប់ នៅក្នុងអំឡុងពេលនៃការឃុំខ្លួនពួកគេផងដែរ (ផ្នែក ២.៤.៥.១) ។

---

[៧៨១] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៦៨-៧០។ សូមមើលផងដែរផ្នែក២.៤.១.១។

[៧៨២] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧-៦៨។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៥៤, ៦៧-៧០។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៤០-៤១។

[៧៨៣] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៨, ១៤-១៥។ ភាគច្រើននៃបុគ្គលដែលត្រូវទទួលបានការការពារនៅមន្ទីរស២១ (ទួលស្លែង) ត្រូវបានសម្លាប់ចោលក្រោយថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ ជាថ្ងៃដែលប៉ុល ពត អំពាវនាវឲ្យមានការប្រារព្ធនូវជ័យជំនះរបស់កងទ័ពបដិវត្តន៍កម្ពុជាលើកងទ័ពវៀតណាម (ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧១-៧២។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១-១៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ (ឡាច មាន) ទំព័រ៥៥-៥៧។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ែស ម៉ាត់) ទំព័រ៦៧-៦៨)។ ក្នុងអំឡុងពេលការសម្លាប់ជារួមនៃអ្នកជាប់ឃុំប្រហែល២០០ នាក់ នៅមន្ទីរស២១ ក្នុងខែមករា ឆ្នាំ១៩៧៨ អ្នកជាប់ឃុំជាជនជាតិវៀតណាម ដែលត្រូវបានរក្សាទុកឲ្យនៅរស់ក្នុងបរិវេណមន្ទីរឃុំឃាំង ក្នុងគោលបំណងសម្រាប់សួរចម្លើយ ក៏ត្រូវបានសម្លាប់ចោលផងដែរ តាមបញ្ជាពីថ្នាក់លើរបស់ជនជាប់ចោទ។ (ប្រតិចារឹក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦១-៦៣។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ១៩។

[៧៨៤] ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១២-១៣។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៤-១៥។ បើទោះបីជាមិនមានព័ត៌មានគ្រប់គ្រាន់ទាក់ទងទៅនឹងការសម្លាប់កុមារក៏ដោយ ជនជាប់ចោទមិនបានបដិសេធអង្គហេតុទាំងនេះទេ។

៤៣៦. ដោយសារតែភាពមិនច្បាស់លាស់នៃកំណត់ហេតុដែលមាន ដូច្នេះគេមិនអាចកំណត់ចំនួនឲ្យបានពិតប្រាកដនូវបុគ្គលដែលត្រូវទទួលបានការការពារដែលបានស្លាប់ ឬត្រូវបានសម្លាប់នៅមន្ទីរស២១ បានឡើយ។ ដោយផ្អែកទៅលើបញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកែសម្រួល អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំជនជាតិវៀតណាមមានមិនតិចជាងចំនួន ៣៤៥នាក់ ឡើយ ដែលបានស្លាប់ ឬត្រូវបានសម្លាប់នៅមន្ទីរស២១ បន្ថែមទៅនឹងចំនួនដ៏ច្រើននោះ ប៉ុន្តែមិនអាចកំណត់ឲ្យបានចំនួនពិតប្រាកដនៃជនជាតិខ្មែរដែលគេចាត់ទុកថាជាអ្នកគាំទ្រវៀតណាមនោះបានទេ[៧៨៥]។

៤៣៧. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បុគ្គលដែលត្រូវទទួលបានការការពារត្រូវបានបុគ្គលិកមន្ទីរស២១ សម្លាប់ដោយចេតនានៅមន្ទីរស២១ (ទួលស្លែង) ឬនៅជើងឯក។ អង្គជំនុំជម្រះយល់ឃើញផងដែរថា អ្នកជាប់ឃុំបានស្លាប់នៅមន្ទីរស២១ ដោយសារតែអំពើអកម្មដែលគេដឹងថាទំនងជានាំឲ្យមានការស្លាប់ និងដោយសារលក្ខខណ្ឌនៃការឃុំខ្លួនដែលត្រូវបានដាក់កំហិតមកលើអ្នក-ជាប់ឃុំទាំងនោះ។

### ២.៦.៣.៣ ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

៤៣៨. បទល្មើសការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ត្រូវបានគេហាមឃាត់យ៉ាងជាក់ច្បាស់ថា ជាអំពើនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនីមួយៗនៃអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន[៧៨៦]។ ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌បង្កើតបានជាបទ-ល្មើសពីរដាច់ដោយឡែកពីគ្នា[៧៨៧]។

---

[៧៨៥] "បញ្ជីឈ្មោះអ្នកទោសជនជាតិវៀតណាមដែលបានចូលមកមន្ទីរស២១" ឯកសារ E68.27។ "បញ្ជីឈ្មោះអ្នកទោសមន្ទីរស២១ ដែលត្រូវបានកំណត់ថាជាជនជាតិវៀតណាម" ឯកសារ E68.30។

[៧៨៦] អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា៥០។ អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា៥១។ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១៣០។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៧។

[៧៨៧] *សូមមើល រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៤៤២។

៤៣៩. ធាតុផ្សំនៃបទល្មើសការធ្វើទារុណកម្មតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក គឺដូចគ្នានឹងធាតុផ្សំនៃបទល្មើសការធ្វើទារុណកម្មតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)[៧៨៨]។

៤៤០. ការធ្វើបាបដោយអមនុស្សធម៌ ត្រូវបានកំណត់និយមន័យដោយយុត្តិសាស្ត្ររបស់តុលាការ ICTY ថា ជាការប្រព្រឹត្តិដោយចេតនានូវអំពើសកម្ម ឬអកម្ម ប្រឆាំងនឹងបុគ្គលដែលត្រូវទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអំពើនេះអាចបណ្តាលឲ្យមានព្យសនកម្ម ផ្លូវចិត្ត ការឈឺចាប់ ឬការរងរបួសផ្នែករាងកាយ ឬជាអំពើដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[៧៨៩]។

៤៤១. សេចក្តីអធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ IV ផ្តល់ជាជំនួយក្នុងការបកស្រាយអំពីបទល្មើសនេះ ៖

> "ការធ្វើបាបដោយអមនុស្សធម៌" មិនមែនមានន័យត្រឹមតែជាការប្រព្រឹត្តិដែលបង្កើតជាការវាយប្រហារ ដែលកំណត់តែទៅលើរាងកាយ ឬសុខភាពប៉ុណ្ណោះនោះឡើយ។ ពិតណាស់ គោលបំណងនៃអនុសញ្ញានេះគឺដើម្បីផ្តល់ឲ្យជនស៊ីវិលនូវការការពារមួយ ដែលនឹងការពារសេចក្តីថ្លៃថ្នូរ ភាពជាមនុស្សជាតិរបស់ពួកគេ និងការពារពួកគេមិនឲ្យទទួលនូវការប្រមាថដូចសត្វធាតុ នៅពេលដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់សត្រូវនោះ។ គោលបំណងនេះនាំឲ្យមានការសន្និដ្ឋានថា តាមរយៈ "ការធ្វើបាបដោយអមនុស្សធម៌" អនុសញ្ញានេះមិនមែនកំណត់អត្ថន័យត្រឹមតែការរងរបួសដល់រាងកាយ ឬដល់សុខភាពប៉ុណ្ណោះទេ។ ឧទាហរណ៍ វិធានការមួយចំនួនដែលអាចកាត់ផ្តាច់ទាំងស្រុងរវាងអ្នកជាប់ឃុំឃាំងជាជនស៊ីវិលនឹងពិភព

---

[៧៨៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ១៣៨។ សូមមើលផងដែរផ្នែក ២.៥.៣.៧។

[៧៨៩] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៤៣។

*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤២៦។

00573587



ខាងក្រៅ និងជាពិសេសពីក្រុមគ្រួសាររបស់ពួកគេ ឬដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរ អាចត្រូវបានចាត់ទុកថាជាការធ្វើបាបដោយអមនុស្សធម៌[៧៥០]។

៤៤២. អំពើទាំងឡាយដែលបង្កើតបានជាការធ្វើទារុណកម្មឬការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានការរងរបួសយ៉ាងធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព នឹងបង្កើតបានជាការធ្វើបាបដោយអមនុស្សធម៌ផងដែរក្នុងពេលតែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ បទល្មើសនេះក៏មានវិសាលភាពគ្របដណ្តប់លើអំពើឯទៀតផងដែរ ដែលរំលោភលើគោលការណ៍នៃការប្រព្រឹត្តិដោយមនុស្សធម៌ ជាពិសេស ការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[៧៥១]។ ការវាយតម្លៃនេះគឺជាបញ្ហានៃអង្គហេតុដែលត្រូវយកមកពិចារណានូវកាលៈទេសៈតាមករណីនីមួយៗ[៧៥២]។ អំពើទាំងឡាយ ដូចជា កាយវិកលកម្ម និងប្រភេទផ្សេងទៀត នៃព្យសនកម្មដល់រាងកាយយ៉ាងធ្ងន់ធ្ងរ ការវាយ និងការប្រើអំពើហិង្សាដទៃទៀត[៧៥៣] និងការរងរបួសផ្នែកស្មារតីនិងរាងកាយយ៉ាងធ្ងន់ធ្ងរ[៧៥៤] ត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌។

៤៤៣. ការធ្វើបាបដោយអមនុស្សធម៌មានលក្ខណៈខុសពីការធ្វើទារុណកម្ម ដោយហេតុថាការធ្វើបាបដោយអមនុស្សធម៌ មិនចាំបាច់ត្រូវបានធ្វើឡើងដោយមានគោលបំណងជាក់លាក់ណាមួយឡើយ។ តុលាការ ICTY បានរកឃើញថា ការធ្វើបាបដោយអមនុស្សធម៌អាចត្រូវបានបង្កើតឡើងដោយអំពើមួយ

---

[៧៥០] សេចក្តីអធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ IV (Pictet ed. 1958) ទំព័រ៥៩៨។

[៧៥១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៤៤។

[៧៥២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៤៤។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥៥។

[៧៥៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-1) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៧៣០។

[៧៥៤] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaškić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ២៣៩។

ដែលបានបង្កឲ្យមានការឈឺចាប់ដល់ផ្លូវចិត្ត និងរាងកាយយ៉ាងធ្ងន់ធ្ងរ ក៏ប៉ុន្តែកម្រិតនៃភាពធ្ងន់ធ្ងរនេះ មិនចាំបាច់ស្មើនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសការធ្វើទារុណកម្មឡើយ[៧៥៥]។

៤៤៤. ចារីពិតជាបានប្រព្រឹត្តនូវអំពើសកម្ម ឬអកម្ម ដោយមានចេតនាធ្វើឲ្យមានការឈឺចាប់ដល់រាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ឬបានប្រព្រឹត្តអំពើសកម្ម ឬអកម្មដោយមកពីការធ្វេសប្រហែស ដោយមិនគិតថាអំពើរបស់ខ្លួនអាចបណ្តាលឲ្យមានការឈឺចាប់ ឬធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះទេ[៧៥៦]។

### ២.៦.៣.៤ សំអាងហេតុទាក់ទងនឹងការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

៤៤៥. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ១៤៩. នៅក្នុងពេលសួរចម្លើយ បុគ្គលិកនៅមន្ទីរស២១ បានបង្កដោយចេតនាឲ្យមានការឈឺចាប់ ឬការទទួលរងទុក្ខផ្លូវកាយ ឬផ្លូវចិត្តដល់បុគ្គលដែលត្រូវទទួលបានការការពារ។ ការប្រើប្រាស់វិធីទាំងនេះក្នុងពេលសួរចម្លើយ គឺមានគោលបំណងទាញយកចម្លើយសារភាពដែលអាចឲ្យដឹងអំពីព័ត៌មានយោធា ឬអាចគាំទ្រដល់យុទ្ធសាស្ត្រឃោសនារបស់បក្សកុម្មុយ-នីស្តកម្ពុជា។
>
> ១៥០. បុគ្គលិកមន្ទីរស២១ បានបង្កដោយចេតនាឲ្យមានរបួសផ្លូវចិត្តធ្ងន់ធ្ងរ និងការឈឺចាប់ដល់រាងកាយ ឬសុខភាពរបស់អ្នកទោស ឬឲ្យពួកគេស្ថិតក្នុងស្ថានភាពដែលអាចកំណត់បានជាការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[៧៥៧]។

#### ២.៦.៣.៤.១ ការធ្វើទារុណកម្ម

---

[៧៥៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៤២។

[៧៥៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៤៣។

[៧៥៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៤៩-១៥០។

៤៤៦. អ្នកជាប់ឃុំជនជាតិវៀតណាមនៅមន្ទីរស២១ (ទួលស្លែង) ត្រូវបានសួរចម្លើយដោយសាក្សី ម៉ម ណៃ ហៅចាន់ ដោយមានជំនួយពីអ្នកបកប្រែឈ្មោះ ផា ថងចាន់[៧៩៨]។ ជនជាប់ចោទបានឲ្យដឹងថា "ជនជាតិវៀតណាមទាំងទាហាន ទាំងស៊ីវិល ដូចគ្នាជាមួយនឹងជនជាតិខ្មែរយើង ដែលគេចាប់យកមកឃុំឃាំង ហើយធ្វើទារុណកម្មសួរចម្លើយហ្នឹង គ្រាន់តែប្លែកៗត្រង់កម្រិតទារុណកម្មទៅលើជនជាតិវៀតណាម ខ្ញុំជឿថាមិនមានខ្លាំងក្លាទេ ពីព្រោះថា សំណូមពរចង់បានតែពាក្យគេយកទៅផ្សាយវិទ្យុប៉ុណ្ណឹងឯង"[៧៩៩]។ គាត់បានបន្ថែមទៀតថា ទោះបីជាការធ្វើទារុណកម្មត្រូវបានធ្វើទៅលើជនជាតិវៀតណាម ក្នុងករណី "ចាំបាច់" ឬ "ជៀសមិនរួច"ក្តី ក៏ការធ្វើទារុណកម្មទាំងនោះកើតមានឡើង "តិចតួចណាស់"[៨០០]។ បញ្ហានេះត្រូវបានបញ្ជាក់នៅក្នុងកំណត់ដៃរបស់ ម៉ម ណៃ ហៅ ចាន់ ដែលបានណែនាំដល់អ្នកសួរចម្លើយកុំឲ្យវាយជនជាតិវៀតណាម នៅពេលដែលពួកវៀតណាមទាំងនោះទំនងជាមិនដឹងនូវព័ត៌មាននោះទេ[៨០១]។

៤៤៧. គោលបំណងនៃការសួរចម្លើយអ្នកជាប់ឃុំជនជាតិវៀតណាម បានកើនឡើងជាបន្តបន្ទាប់នៅពេលជម្លោះប្រដាប់អាវុធកាន់តែរីកធំឡើង។ កាលពីដំបូង អ្នកជាប់ឃុំទាំងនោះត្រូវបានសួរចម្លើយអំពី "ទិសដៅមកយកការណ៍" និងបណ្តាញរបស់អ្នកទាំងនោះនៅក្នុងប្រទេសកម្ពុជា ព្រមទាំងចេតនារបស់

---

[៧៩៨] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៨, ៨, ៣៤-៣៥។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧-៣៨។ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ម៉ម ណៃ) ទំព័រ១៨-២១។ សូមមើលផងដែរ ផ្នែក (២.៣.៣.៤.៣.២)។

[៧៩៩] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៧-៣៨។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ ប៉េស ម៉ាត់) ទំព័រ៦៧-៦៨ (បញ្ជាក់ថា គាត់បានឃើញអ្នកជាប់ឃុំជាជនជាតិវៀតណាម ដែលគាត់គិតថាត្រូវបានគេធ្វើទារុណកម្ម) ។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ៣០-៣១, ៤៤ (បញ្ជាក់ថា អ្នកជាប់ឃុំដែលត្រូវបានគួរដោយលោក វ៉ាន់ ណាត គឺជាជន ជាតិវៀតណាម)។

[៨០០] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧-៩, ១៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៥-៦៦។ ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៣-៥៤។

[៨០១] "សៀវភៅកំណត់ហេតុមន្ទីរស២១ របស់ ម៉ម ណៃ ហៅ ចាន់" ឯកសារ E3/231, ERN (ភាសាខ្មែរ) 00077952-00077953។

វៀតណាមក្នុងការឈ្លានពានប្រទេសកម្ពុជា និងបញ្ចូលប្រទេសកម្ពុជាទៅក្នុងសហព័ន្ធឥណ្ឌូចិន[៨០២]។ ចាប់ពីថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ មក ចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ត្រូវបានថត សម្លេង និងផ្សាយតាមវិទ្យុដើម្បីគោលបំណងឃោសនា[៨០៣]។

៤៤៨. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំជនជាតិវៀតណាមត្រូវបានទទួល រងនូវការធ្វើទារុណកម្ម ទោះបីជាក្នុងចំនួនតិចជាង និងកម្រិតស្រាលជាងអ្នកជាប់ឃុំដទៃទៀត ក៏ដោយ។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិខ្មែរដែលគេចាត់ទុកថាជាអ្នកគាំទ្រវៀតណាម ក៏ត្រូវបានសួរចម្លើយនៅក្នុងលក្ខណៈដូចគ្នា និងដើម្បីបម្រើគោលបំណងដូចគ្នាទៅនឹងអ្នកជាប់ឃុំ ជនជាតិខ្មែរដទៃទៀតដែរ[៨០៤]។

## ២.៦.៣.៤.២ ការធ្វើបាបដោយអមនុស្សធម៌

៤៤៩. ការធ្វើបាបមួយចំនួនដែលបានប្រព្រឹត្តទៅលើបុគ្គលដែលត្រូវទទួលបានការការពារ មិនមាន កម្រិតធ្ងន់ធ្ងរដូចគ្នាទៅនឹងការធ្វើទារុណកម្ម ឬការបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរនោះទេ ប៉ុន្តែវាជាការ រំលោភទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈលក្ខខណ្ឌទូទៅ នៃ ការឃុំខ្លួន និងវិធីសាស្ត្រជាច្រើនដែលបានប្រើដើម្បីទទួលបានចម្លើយសារភាពដោយបង្ខំពីអ្នកជាប់- ឃុំជនជាតិវៀតណាម[៨០៥]។ អង្គជំនុំជម្រះយល់ឃើញថា បុគ្គលដែលត្រូវទទួលបានការការពារបាន ទទួលរងនូវការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ពួកគេ។ អង្គជំនុំជម្រះ យល់ឃើញទៀតថា ការធ្វើបាបទាំងនេះ គឺបង្កឡើងដោយចេតនា ឬដោយគ្មានការពិចារណាអ្វីទាល់តែ សោះពីសំណាក់បុគ្គលិកមន្ទីរស២១។

---

[៨០២] ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៣, ៦-៧, ៩-១០។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (អង្គហេតុដែលបានព្រមព្រៀង) ទំព័រ៦៧-៦៨។

[៨០៣] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៥៣-៥៤។ ប្រតិចារឹក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២-៣, ៣៦-៣៧។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ឹម ហ៊ុយ) ទំព័រ៣-៤។ សូមមើលផងដែរ ផ្នែក (២.១.២.)។

[៨០៤] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៦៧។ សូមមើលផងដែរ ផ្នែក (២.៤.៤)។

[៨០៥] សំណុំរឿងនោះមានចម្លើយសារភាពរបស់ជនជាតិវៀតណាម ចំនួន៨២ (ឯកសារ E3/665 ដល់ឯកសារ E3/747)។

## ២.៦.៣.៥ ការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព

៤៥០. បទល្មើសនៃការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ត្រូវបានគេហាមឃាត់យ៉ាងជាក់ច្បាស់ថា ជាអំពើនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនីមួយៗ នៃអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន[៨០៦]។ បទល្មើសនេះតំណាងឲ្យបទល្មើសណាមួយ ដែលធាតុផ្សំរបស់វាអាចជំនួសគ្នាទៅវិញទៅមកបាន[៨០៧]។

៤៥១. យុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់និយមន័យបទល្មើសនេះថា គឺជា "ការប្រព្រឹត្តិដោយចេតនានូវអំពើសកម្ម ឬអកម្ម ដែលបង្កឲ្យមានការឈឺចាប់ ឬរងរបួសផ្នែកស្មារតី ឬរាងកាយយ៉ាងធ្ងន់ធ្ងរ លុះត្រាតែមានភស្តុតាងបញ្ជាក់អំពីកំរិតនៃការឈឺចាប់ ឬការរងរបួស"[៨០៨]។

៤៥២. សេចក្ដីអធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ IV កត់សម្គាល់ដូចខាងក្រោម ៖

> *ការបង្កដោយចេតនាឲ្យមានការឈឺចាប់យ៉ាងខ្លាំង* សំដៅទៅលើការឈឺចាប់ ដែលបានបង្កឡើងដោយគ្មានទីបញ្ចប់ ដែលក្នុងន័យនេះការធ្វើទារុណកម្មត្រូវបានបង្កឲ្យមានឡើង ឬការពិសោធជីវសាស្ត្រក៏ត្រូវបានគេអនុវត្តផងដែរ។ ដូច្នេះ អំពើនោះអាចនឹងត្រូវបានធ្វើឡើងជាការដាក់ទណ្ឌកម្ម ជាការសងសឹក ឬដោយសារហេតុផលផ្សេងទៀត ដូចជាភាពសប្បាយរីករាយពេលឃើញអ្នកដទៃឈឺចាប់។ ដោយយល់ឃើញថា ការឈឺចាប់នៅក្នុងករណីនេះ បើតាមការប្រើប្រាស់ពាក្យពេចន៍ ហាក់បីដូចជាមិនសំដៅទៅលើការរងរបួសដល់រាងកាយ ឬសុខភាពនោះទេ វាអាចជាការមន្ទិលសង្ស័យប្រសិនបើបទល្មើសនេះ មិនមែនជាបទល្មើស

---

[៨០៦] អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា៥០។ អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា៥១។ អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១៣០។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៧។

[៨០៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥០៦។

[៨០៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៤៥។

ពិសេស ដែលមិនត្រូវបានដោះស្រាយតាមច្បាប់ជាតិ។ ដោយសារតែអនុសញ្ញានេះមិនបានបញ្ជាក់ឱ្យច្បាស់ថា ចង់សំដៅតែទៅលើការឈឺចាប់ដល់រាងកាយតែប៉ុណ្ណោះនោះ ដូចនេះអនុសញ្ញានេះត្រូវបានគេយល់ឃើញថាអាចគ្របដណ្តប់លើការឈឺចាប់ផ្លូវចិត្តផងដែរ។

*ការបង្កឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព* គឺជាទស្សនាទានមួយ ដែលធម្មតាមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដែលជាទូទៅប្រើជាលក្ខខណ្ឌវិនិច្ឆ័យមួយអំពីភាពធ្ងន់ធ្ងរ ដែលជនរងគ្រោះបាត់បង់សមត្ថភាពបំពេញការងាររយៈពេលយូរ[៨០៩]។

អង្គជំនុំជម្រះយល់ស្របតាមការវិភាគខាងលើ ចំពោះបទល្មើសនៃការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ។

៤៥៣. បទល្មើសនេះមានលក្ខណៈខុសគ្នាពីការធ្វើទារុណកម្ម ជាពិសេសដោយសារតែអំពើសកម្ម ឬអកម្ម ដែលត្រូវបានចោទប្រកាន់នោះ មិនចាំបាច់ត្រូវបានប្រព្រឹត្តឡើងសម្រាប់គោលបំណងជាក់លាក់ណាមួយឡើយ[៨១០]។ បទល្មើសនេះក៏មានលក្ខណៈខុសគ្នាផងដែរពីបទល្មើសនៃការធ្វើបាបដោយអមនុស្សធម៌ ដោយសារតែបទល្មើសនេះតម្រូវឱ្យមានការរងរបួសដល់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរនោះ។ អំពើទាំងឡាយ ដែលព្យសនកម្មកើតចេញពីអំពើនោះគ្រាន់តែទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់បុគ្គលម្នាក់ មិនរាប់បញ្ចូលនៅក្នុងបទល្មើសនេះឡើយ[៨១១]។

៤៥៤. ព្យសនកម្មផ្លូវចិត្ត ឬរាងកាយ ដែលបានកើតមានចំពោះជនរងគ្រោះ មិនចាំបាច់ធ្ងន់ធ្ងររហូតមិនអាចព្យាបាលបាន ឬក៏អចិន្ត្រៃយ៍ឡើយ ប៉ុន្តែព្យសនកម្មនេះត្រូវបង្កឱ្យមានការលំបាកខាងផ្លូវចិត្តហួសពីធម្មតា ភាពអាម៉ាស់ ឬភាពអាប់ឱន។ ការលំបាកផ្លូវចិត្តហួសពីធម្មតា ភាពអាម៉ាស់ ឬភាព

---

[៨០៩] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សេចក្តីអធិប្បាយចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ IV (Pictet ed. 1958) ទំព័រ៥៩៨ ជាពិសេស មាត្រា១៤៧ ទំព័រ៥៩៩។

[៨១០] *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៥០៨, ៥១១។

[៨១១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង* អ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៤៥។

អាប់ឱន ត្រូវតែជាព្យសនកម្ម ដែលបណ្ដាលឱ្យមានផលវិបាករយៈពេលយូរ និងធ្ងន់ធ្ងរដល់លទ្ធភាពរបស់មនុស្សក្នុងជីវភាពធម្មតា[៨១២]។

៤៥៥. យុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់ថា ធាតុចេតនាចាំបាច់ចំពោះបទល្មើសនេះ រួមបញ្ចូលទាំងសមត្ថភាពខាងឆន្ទៈ និងការធ្វេសប្រហែស[៨១៣] ។

### ២.៦.៣.៦ សំអាងហេតុទាក់ទងនឹងការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព

៤៥៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៤៨. បុគ្គលដែលត្រូវទទួលបានការការពារទាំងនេះ ត្រូវបានដាក់ឱ្យប្រឈមមុខដោយចេតនាទៅនឹងការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារអំពើអមនុស្សធម៌ដែលរួមមាន ៖ ការមិនផ្ដល់ឱ្យដោយចេតនានូវម្ហូបអាហារគ្រប់គ្រាន់ បរិក្ខារអនាម័យ និងការព្យាបាលជំងឺដោយសមរម្យ។ អ្នកទោសត្រូវបានវាយដំ និងដាក់ឱ្យប្រឈមមុខនឹងការរឹតត្បិតដ៏តឹងតែងក្នុងអំឡុងពេលនៃការឃុំឃាំង។ ភាពធ្ងន់ធ្ងរនៃស្ថានភាពរួម ឬស្ថានភាពដាច់ដោយឡែកធ្វើឱ្យអ្នកជាប់ឃុំឃាំងថមថយកម្លាំងចិត្ត អស់តម្លៃ និងអស់លក្ខណៈជាមនុស្សជាតិ។ ទាំងនេះជាស្ថានភាពដែលធ្វើឱ្យពួកគេស្ថិតក្នុងការភ័យខ្លាចជានិច្ច[៨១៤]។

---

[៨១២] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៥១១-៥១៣។

[៨១៣] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥២ ។

[៨១៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៤៨ ។

៤៩៧. បុគ្គលដែលត្រូវទទួលបានការការពារ បានទទួលរងនូវលក្ខខណ្ឌឃុំខ្លួនដូចគ្នាទៅនឹងអ្នកជាប់-ឃុំនៅមន្ទីរស២១ដទៃទៀតដែរ[៨១៥] ដោយសារអ្នកទាំងនោះទទួលរងរបួសផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បុគ្គលិកមន្ទីរស២១បានបង្កដោយចេតនាឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់ជនជាតិវៀតណាម និងបុគ្គលដែលត្រូវទទួលបានការការពារដទៃទៀត ដោយសារការអនុវត្តនូវលក្ខខណ្ឌឃុំខ្លួនដ៏លំបាកនៅមន្ទីរស២១ ក៏ដូចជាការខ្វះខាតម្ហូបអាហារ និង ថ្នាំសង្កូវ ជាដើម (ផ្នែក ២.៤.៥)។

### ២.៦.៣.៧ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

៤៩៨. បទល្មើសនៃការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់-ទោសដោយយុត្តិធម៌ និងទៀងទាត់ គឺជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរដែលត្រូវបានហាមឃាត់យ៉ាងជាក់ច្បាស់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ IV និងអនុសញ្ញាទីក្រុងហ្សឺណែវ III[៨១៦]។

៤៩៩. ចារីពិតជាបានដកហូតនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ពីមនុស្សម្នាក់ ឬច្រើននាក់ ដោយមិនបានផ្តល់នូវការធានាតាមផ្លូវតុលាការ ដូចដែលបានចែងជាពិសេសនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទី IV និងអនុសញ្ញាទីក្រុងហ្សឺណែវ III។ ការធានាតាមផ្លូវតុលាការទាំងនេះរួមមាន សិទ្ធិទទួលបានការវិនិច្ឆ័យទោសដោយតុលាការឯករាជ្យ និងអនាគតិ[៨១៧] សិទ្ធិទទួលបានព័ត៌មានឲ្យបានឆាប់រហ័សអំពីបទចោទទាំងឡាយ[៨១៨] សិទ្ធិទទួលបាននូវការជំនុំជម្រះទោសដោយអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស[៨១៩] សិទ្ធិទទួលបានការការពារតាមគោលការណ៍នីត្យានុកូលភាព[៨២០]

---

[៨១៥] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៦-៣៩។ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ (ហ៊ីម ហ៊ុយ) ទំព័រ៣៩, ៤០, ៤៨។ សូមមើលផងដែរផ្នែក ២.៤.៥.១-២.៤.៥.៤ ។

[៨១៦] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១៣០។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៧។

[៨១៧] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៤(២)។

[៨១៨] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១០៤។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៧១(២)។

[៨១៩] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៧។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៣៣។

[៨២០] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៩៩(១)។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៦៧។

សិទ្ធិមិនត្រូវបានផ្តន្ទាទោសលើសពីម្តងចំពោះអំពើដដែល ឬទៅលើបទចោទដដែល[៨២១] សិទ្ធិទទួលបានព័ត៌មានអំពីសិទ្ធិឧបាស្រ័យ[៨២២] និងសិទ្ធិមិនត្រូវបានផ្តន្ទាទោស ឬប្រហារជីវិតដោយគ្មានសាលក្រមជាមុន ដែលប្រកាសដោយតុលាការដែលបានបង្កើតឡើងតាមច្បាប់[៨២៣]។

៤៦០. យុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់ថា ធាតុចេតនាចាំបាច់ចំពោះបទល្មើសនេះ រួមបញ្ចូលទាំងសមត្ថភាពខាងឆន្ទៈ និងការធ្វេសប្រហែស[៨២៤]។

### ២.៦.៣.៨ សំអាងហេតុទាក់ទងនឹងការដកហូតនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌

៤៦១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា ៖

> ១៤៧. យ៉ាងហោចណាស់បុគ្គលដែលត្រូវទទួលបានការការពារចំនួន៤០០នាក់ ត្រូវបានដកហូតដោយចេតនានូវសិទ្ធិទទួលបានការវិនិច្ឆ័យដោយតុលាការអនាគតិ និងឯករាជ្យ ដូចដែលបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងជាពិសេសសិទ្ធិត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប អំពីបទល្មើសដែលចោទប្រកាន់ទៅលើពួកគេ សិទ្ធិមិនត្រូវបានដាក់ទោសជាសមូហភាព សិទ្ធិទទួលបានការការពារតាមគោលការណ៍នីត្យានុកូលភាព ឬសិទ្ធិទទួលបានការផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច[៨២៥]។

៤៦២. រាល់បុគ្គលដែលត្រូវទទួលបានការការពារទាំងអស់ រួមទាំងជនជាតិវៀតណាម និងជនជាតិខ្មែរ ដែលគេចាត់ទុកថាជាអ្នកគាំទ្រវៀតណាមនោះ ត្រូវបានដកហូតនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ (ផ្នែក២.៤.៣)។ អង្គជំនុំជម្រះយល់ឃើញថា មិនមានការរៀបចំណាមួយដើម្បីត្រួត-

[៨២១] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៦។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១១៧(៣)។

[៨២២] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១០៦។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៧៣។

[៨២៣] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១០០-១០៥, ១០៧។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៦៤-៧០, ៧៤-៧៥។

[៨២៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥២។

[៨២៥] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៤៧។

ពិនិត្យឈ្លើយសឹកដែលត្រូវបានចាប់ខ្លួន ឬជនស៊ីវិលទាំងនោះឡើយ ហើយក៏មិនមានយន្តការណាមួយដើម្បីប្រាប់អ្នកទាំងនោះអំពីហេតុផលក្នុងការចាប់ខ្លួន ឬផ្តល់ឱកាសឲ្យពួកគេជំទាស់ទៅនឹងមូលហេតុនៃការចាប់ខ្លួន ឬប្តឹងតវ៉ាអ្វីឡើយ។ លើសពីនេះទៀត ការដាក់ទណ្ឌកម្មដែលត្រូវបានអនុវត្តទៅលើពួកគេ គឺជាការបំពានយ៉ាងច្បាស់ក្រឡែត។ គ្មានការជំនុំជម្រះ ហើយការសម្លាប់ក្រៅប្រព័ន្ធតុលាការត្រូវបានអនុវត្តទៅលើអ្នកជាប់ឃុំដោយសារតែគោលនយោបាយ។ ទោះបីជាមិនមានប្រព័ន្ធតុលាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មន្ទីរស២១បានដំណើរការជាស្ថាប័នរដ្ឋមួយដែលមានអំណាចក្នុងការឃុំខ្លួន សួរចម្លើយ និងសម្លាប់មនុស្សដែរ។ ដូច្នេះមន្ទីរនេះមានភារកិច្ចអនុវត្តនូវអំណាចទាំងនេះស្របទៅតាមសិទ្ធិក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌ ដែលធានាដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។

៤៦៣. អង្គជំនុំជម្រះយល់ឃើញថា ជនជាតិវៀតណាមមានមិនតិចជាង ៣៤៥ នាក់ និងបុគ្គលដែលត្រូវទទួលបានការការពារជាច្រើននាក់ផ្សេងទៀត ដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ ត្រូវបានដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់។

### ២.៦.៣.៩ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

៤៦៤. ធាតុផ្សំនៃបទល្មើសការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់តាមមាត្រា៦នៃច្បាប់ អ.វ.ត.ក គឺមានសារធាតុនៃធាតុផ្សំដូចគ្នាទៅនឹងធាតុផ្សំនៃបទល្មើសការដាក់ក្នុងមន្ទីរឃុំឃាំង តាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)[៨២៦]។

៤៦៥. ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ត្រូវបានហាមឃាត់យ៉ាងជាក់ច្បាស់ ថាជាការបំពារ-បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ IV[៨២៧]។ ទោះបីជានៅក្នុងករណីមួយចំនួន ការឃុំខ្លួន

---

[៨២៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić និងអ្នកផ្សេងទៀត សាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៣០១។ *ផងដែរសូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić និងអ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៦៩-៧៣។ សូមមើលផងដែរផ្នែក ២.៥.៣.៥។

ជនស៊ីវិលក្នុងពេលមានជម្លោះប្រដាប់អាវុធអាចត្រូវបានអនុញ្ញាតក៏ដោយ បទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ត្រង់ផ្នែកដែលពាក់ព័ន្ធ បញ្ជាក់ថាការដកហូតសិទ្ធិសេរីភាពគឺអនុញ្ញាតតែក្នុងករណីដែលមានមូលហេតុសមស្រប ដែលអាចជឿបានថា សន្តិសុខរបស់រដ្ឋគឺស្ថិតនៅក្នុងស្ថានភាពមួយដែលគ្មានសុវត្ថិភាព[៨២៨]។ បន្ថែមលើនេះទៀត ការឃុំខ្លួនដោយស្របច្បាប់នៅពេលដំបូងអាចក្លាយទៅជាការឃុំខ្លួនដោយខុសច្បាប់ ប្រសិនបើភាគីដែលមានសិទ្ធិឃុំខ្លួនមិនបានគោរពសិទ្ធិជាមូលដ្ឋានតាមនីតិវិធីរបស់អ្នកជាប់ឃុំ ឬបង្កើតតុលាការ ឬក្រុមប្រឹក្សាគ្រប់គ្រងសមស្រប ដូចមានចែងក្នុងមាត្រា៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV[៨២៩]។

៤៦៦. យុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់ថា ធាតុចេតនាចាំបាច់ចំពោះបទល្មើសនេះ រួមបញ្ចូលទាំងសមត្ថភាពខាងឆន្ទៈ និងការធ្វេសប្រហែស ដូចគ្នាទៅនឹងការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងអស់[៨៣០]។

---

[៨២៧] អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៧។ *សូមមើលផងដែរ*អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៥ (ការអនុញ្ញាតនូវវិធានការមួយចំនួនចំពោះបុគ្គលដែលជាប់សង្ស័យយ៉ាងច្បាស់ ឬពាក់ព័ន្ធនឹងសកម្មភាពមួយចំនួន ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់រដ្ឋ ប៉ុន្តែត្រូវមានការប្រព្រឹត្តិដោយមនុស្សធម៌និងគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់បុគ្គលនោះ។

[៨២៨] មាត្រា៤២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ចែងថា៖ ការឃុំឃាំង ឬការដាក់បុគ្គលដែលត្រូវទទួលបានការការពារនៅកន្លែងណាមួយដែលបានកំណត់ទុកអាចធ្វើឡើងបាន ប្រសិនបើមានភាពចាំបាច់ដាច់ខាតខាងសន្តិសុខរបស់ភាគី ដែលធ្វើការឃុំខ្លួន។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Delalić* *និង អ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០០ កថាខណ្ឌ៣២០-៣២១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kordić* *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៧២។

[៨២៩] សូមមើល មាត្រា៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV (ចែងអំពីការត្រួតពិនិត្យមើលនូវរយៈពេលនៃការឃុំខ្លួនដោយតុលាការ ឬក្រុមប្រឹក្សាណាមួយដែលសមស្រប ហើយត្រូវជូនដំណឹងអំពីស្ថានភាពនៃអ្នកជាប់ឃុំទៅភាគីម្ខាងទៀត) ។

[៨៣០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Blaškić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14-T) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៥២ ។

00573598



## ២.៦.៣.១០ សំអាងហេតុទាក់ទងនឹងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

៤៦៧. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៤៦. ជនស៊ីវិលវៀតណាមជាងមួយរយនាក់ត្រូវបានឃុំឃាំងនៅមន្ទីរស២១។ គ្មានភាពខុសគ្នាឡើយរវាងជនស៊ីវិលវៀតណាម និងអ្នកទោសផ្សេងៗទៀត ពោលគឺ ពួកគេទាំងអស់ត្រូវបានដកហូតនូវសិទ្ធិសេរីភាពរបស់ពួកគេដោយបំពារបំពាន[៨៣១]។

៤៦៨. អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរស២១ទាំងអស់ ត្រូវបានបង្ខាំងដោយចេតនា និងដោយបំពាន ដោយគ្មានមូលដ្ឋានគតិយុត្តិ (ផ្នែក ២.៤.៣)។ វាជាការពិតផងដែរថា ជនស៊ីវិលវៀតណាមមិនតិចជាង៧៩នាក់ និងបុគ្គលដែលត្រូវទទួលបានការការពារក្នុងចំនួនដ៏ច្រើន ត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) (ផ្នែក ២.៣.៣.៤.២)។ មិនមានហេតុផលសមរម្យក្នុងការធ្វើយុត្តិកម្មអំពីការឃុំឃាំងជនស៊ីវិលទាំងនោះឡើយ ហើយអ្នកជាប់ឃុំរួមទាំងជនស៊ីវិលដែលត្រូវទទួលបានការការពារ ត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) ក៏មិនមានឱកាសក្នុងការជំទាស់តវ៉ាទៅនឹងការឃុំខ្លួនពួកគេឡើយ (ផ្នែក ២.៤.៣.២)។

៤៦៩. ដោយមិនមានកត្តាផ្សេងៗដែលអាចចង្អុលបានថា សន្តិសុខនៅក្នុងប្រទេសកម្ពុជាតម្រូវឱ្យមានការឃុំខ្លួនអ្នកទាំងនោះ នៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាមនោះទេ ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថា ជនស៊ីវិលដែលត្រូវទទួលបានការការពារ និងយ៉ាងហោចណាស់ជនជាតិវៀតណាមមួយចំនួន ត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរស២១។

## ២.៧ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ

៤៧០. អនុលោមតាមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ដែលចែងអំពីទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះឧក្រិដ្ឋកម្មដែលស្ថិត

---

[៨៣១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៤៦។

នៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ បទប្បញ្ញត្តិមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ស្រដៀងគ្នានឹងបទប្បញ្ញត្តិស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានចែងក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍នានា* (*ad hoc*) ហើយមាត្រានេះចេញមកពីសញ្ញាណនៃច្បាប់អន្តរជាតិ[៨៣២]។ មាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

> ជនសង្ស័យណាមួយ ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។
>
> តួនាទី ឬឋានៈរបស់ជនសង្ស័យ មិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។
>
> ប្រការដែលថាសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋនេះ។
>
> ប្រការដែលថា ជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ។

---

[៨៣២] *សូមមើល* មាត្រា៧(១) នៃលក្ខន្តិកៈតុលាការ ICTY មាត្រា៦(១) នៃលក្ខន្តិកៈតុលាការ ICTR និងមាត្រា៦(១) នៃលក្ខន្តិកៈតុលាការ SCSL (មាត្រាទាំងអស់នេះ ចែងថា "ជនណា ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុង [មាត្រាពាក់ព័ន្ធនៃលក្ខន្តិកៈទាំងនេះ] ត្រូវតែទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ")។

៤៧១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថាជនជាប់ចោទ "ដែលតាមរយៈអំពើសកម្ម និងអកម្មរបស់ខ្លួននៅទីក្រុងភ្នំពេញ និងលើទឹកដីកម្ពុជាក្នុងឋានៈជាអនុលេខា ឬលេខាមន្ទីរស២១ បានរៀបចំផែនការ បានញុះញង់ឲ្យប្រព្រឹត្ត បានបញ្ជា បានប្រព្រឹត្ត បានជួយនិងជំរុញដល់ចារីនៃបទឧក្រិដ្ឋទាំងនោះ ឬជាអ្នកទទួលខុសត្រូវក្នុងនាមជាមេកើយ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានលើក្រម-ព្រហ្មទណ្ឌឆ្នាំ១៩៥៦ របស់ប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ មិនបានចោទប្រកាន់ជនជាប់ចោទពីទម្រង់នៃការទទួលខុសត្រូវលើការប្រព្រឹត្តិបទទារុណកម្មដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ របស់ប្រទេសកម្ពុជានោះទេ[៨៣៣]។

៤៧២. នៅពេលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចោទប្រកាន់ទម្រង់នៃការទទួលខុសត្រូវជាច្រើនទាក់ទងនឹងបទចោទនីមួយៗ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិដើម្បីជ្រើសរើសទម្រង់នៃការទទួលខុសត្រូវមួយ ឬទម្រង់ផ្សេងៗទៀត ដើម្បីវាយតម្លៃភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងជនជាប់ចោទ[៨៣៤]។ អង្គជំនុំជម្រះមិនតម្រូវឲ្យធ្វើសំអាងហេតុលម្អិតទៅលើទម្រង់នៃការទទួលខុសត្រូវនីមួយៗ ឬលើរាល់ទម្រង់នៃការទទួលខុសត្រូវដែលចោទប្រកាន់ទាំងអស់នោះទេ ហើយអង្គជំនុំជម្រះអាចជ្រើសរើសក្នុងការពិនិត្យពិចារណាតែទម្រង់នៃការទទួលខុសត្រូវដែលពិពណ៌នាច្បាស់លាស់បំផុតនូវអំពើរបស់ជនជាប់ចោទ[៨៣៥]។

៤៧៣. គោលការណ៍នីត្យានុកូលភាព (ផ្នែក ១.៥) អនុវត្តចំពោះទម្រង់ផ្សេងៗនៃការទទួលខុសត្រូវព្រមទាំងសារធាតុនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់។ ហេតុដូចនេះ អង្គជំនុំជម្រះត្រូវតែបង្ហាញឲ្យ

---

[៨៣៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ទំព័រ៧២-៧៣ ដែលបានធ្វើការកែប្រែដោយសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ៦៣។

[៨៣៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-98-33-T) ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ៦០២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-97-20-T) ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ៣៩៧។

[៨៣៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៧៦។

00573601



ឃើញថា ទម្រង់នៃការទទួលខុសត្រូវ ដែលចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ត្រូវបានទទួលស្គាល់តាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៤៧៤. ទម្រង់នៃការទទួលខុសត្រូវមួយចំនួនដែលមានចែងក្នុងមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ក៏មានចែងផងដែរនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក្នុងអំឡុងពេលនោះ លើកលែងតែការទទួលខុសត្រូវចំពោះការរៀបចំផែនការ និងការទទួលខុសត្រូវរបស់ថ្នាក់លើ[៨៣៦]។ ប៉ុន្តែ ការរៀបចំផែនការត្រូវបានផ្តន្ទាទោសតាមបទប្បញ្ញត្តិជាក់លាក់មួយចំនួន[៨៣៧] តាមទម្រង់នៃការទទួលខុសត្រូវក្តី ឬជាបទឧក្រិដ្ឋក្តី ដែលការផ្តន្ទាទោសចំពោះអំពើទាំងនេះក៏មានចែងយ៉ាងច្បាស់ផងដែរ ។

៤៧៥. បន្ថែមលើនេះទៀត គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះការប្រព្រឹត្តិនូវការរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងធម្មនុញ្ញ Nuremberg និងត្រូវបានយកមកអនុវត្តនៅក្នុងសេចក្តីសម្រេចរបស់តុលាការ Nuremberg[៨៣៨]។ សេចក្តីសម្រេចរបស់តុលាការ Nuremberg ទាំងនេះបានបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល គ្របដណ្តប់ចំពោះបុគ្គលទាំងឡាយណា ដែលប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ រួមទាំងបុគ្គលទាំងឡាយណាដែលបានបញ្ជា ឬជួយក្នុងការប្រព្រឹត្ត[៨៣៩]។ យុត្តិសាស្ត្របន្តបន្ទាប់ និងកម្រងច្បាប់អន្តរជាតិ បានបញ្ជាក់

---

[៨៣៦] សូមមើលមាត្រា៧៦ និងមាត្រា៨២ ដល់៨៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

[៨៣៧] សូមមើលមាត្រា២៩០, ២២៣ និង២៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

[៨៣៨] *សូមមើល* កិច្ចព្រមព្រៀងសម្រាប់ការកាត់សេចក្តី និងផ្តន្ទាទោស ចំពោះឧក្រិដ្ឋជនសង្គ្រាមធំៗនៃសម្ព័ន្ធមិត្តអឺរ៉ុប និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥ ឯកសារលេខ៨២ UNTS ២៧៩ មាត្រា៦។

[៨៣៩] *សូមមើលឧទាហរណ៍ ការជំនុំជម្រះ Bruno Tesch និងបុគ្គលពីរនាក់ផ្សេងទៀត ("រឿងក្តី Zyklon B")* ថ្ងៃទី០១-០៨ ខែមីនា ឆ្នាំ១៩៤៦ (*របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (Law Reports of Trials of War Criminals) (១៩៤៧)* ភាគ I ទំព័រ៩៣ (យល់ឃើញថា ការផ្គត់ផ្គង់ឧស្ម័នដែលអាចសម្លាប់មនុស្សនៅជំរំប្រមូលផ្តុំ ដោយបានដឹងអំពីការប្រើប្រាស់ឧស្ម័ននេះ ជាការទទួលខុសត្រូវព្រហ្មទណ្ឌ)។ *ការជំនុំជម្រះ Werner និងបុគ្គល ប្រាំបី នាក់ផ្សេងទៀត* ថ្ងៃទី២៩ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៤៦ *របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (១៩៤៨)* ភាគ V ទំព័រ៥៤ (ជនជាប់ចោទ ដែលផ្តល់ការជួយជ្រោមជ្រែង ត្រូវបានផ្តន្ទាទោសថា "ជាប់ពាក់ព័ន្ធក្នុងការសម្លាប់")។ *ការជំនុំជម្រះ Wilhelm List និងអ្នកផ្សេងទៀត ("ការជំនុំជម្រះចំណាប់ខ្មាំង")* ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៤៧ ដល់ថ្ងៃទី១៩ ខែកុម្ភៈ

ជាថ្មីអំពីប្រភេទទំនៀមទម្លាប់នៃទម្រង់ទទួលខុសត្រូវនីមួយៗ ដែលមានចែងនៅក្នុងកថាខណ្ឌទីមួយ នៃមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ព្រមទាំងការអនុវត្តទម្រង់នេះទៅលើឧក្រិដ្ឋកម្មអន្តរជាតិជាច្រើនរួមមានការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៨៤០]។

---

ឆ្នាំ១៩៤៨ *របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (១៩៤៩)* ភាគី VIII ទំព័រ៣៤ (រកឃើញនូវការទទួលខុសត្រូវព្រហ្មទណ្ឌដែលផ្អែកលើការចេញបញ្ជាឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋ)។ *ការជំនុំជម្រះ Franz Schonfeld និងអ្នកប្រាំបួននាក់ផ្សេងទៀត* ថ្ងៃទី១១-២៦ ខែមិថុនា ឆ្នាំ១៩៤៦ *របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (១៩៤៩)* ភាគ XI ទំព័រ៦៤ (ជនជាប់ចោទ ដែលផ្តល់ការជួយ ជ្រោមជ្រែងដល់ចារី ត្រូវបានផ្តន្ទាទោសថា "ជាប់ពាក់ព័ន្ធក្នុងការសម្លាប់")។ *Ohlendorf និងសំណុំរឿងផ្សេងទៀត ("រឿងក្តី Einsatzgruppen")* សេចក្តីសម្រេចថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ១៩៤៨ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៥០)* ភាគ IV ទំព័រ៤១១ (យល់ឃើញថា ជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលអំពើរបស់ជនជាប់ចោទមានឥទ្ធិពលយ៉ាងខ្លាំងលើចារីទាំងនោះ)។ *សូមមើលផងដែរ* ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៤៥) បោះពុម្ពផ្សាយនៅក្នុង *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង* ភាគ I ទំព័រ XVI-XIX មាត្រា២(២)។

[៨៤០] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* មតិយោបល់ និងសាលក្រមរបស់អង្គជំនុំជម្រះតុលាការដំបូង ICTY (IT-94-1-T) ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៦៦៩ (លើកឡើងថា ទម្រង់ទទួលខុសត្រូវទាំងអស់ ដែលមានចែងនៅក្នុងមាត្រា៧ នៃលក្ខន្តិកៈតុលាការ ICTY និងដែលបានឆ្លុះបញ្ចាំងអំពីទម្រង់នានាដែលរាយនាមក្នុងមាត្រា២៩ នៃច្បាប់ អ.វ.ត.ក មានលក្ខណៈជាមូលដ្ឋានទំនៀមទម្លាប់)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1-T) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ១៩១-២៤៩ (ទាក់ទងនឹងមូលដ្ឋានទំនៀមទម្លាប់នៃការជួយនិងជំរុញ)។ *សូមមើលផងដែរ* អនុសញ្ញាទីក្រុងហ្សឺណែវ III ទាក់ទងនឹងការប្រព្រឹត្តិចំពោះឈ្លើសសឹកសង្គ្រាមថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ១៣៥ មាត្រា១២៩(១) (ទាក់ទងនឹងការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះ "បុគ្គលនានា ដែលប្រព្រឹត្ត ឬបញ្ជាឲ្យប្រព្រឹត្តលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរណាមួយនៃអនុសញ្ញាបច្ចុប្បន្ន")។ អនុសញ្ញាទីក្រុងហ្សឺណែវ IV ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ៧៥ UNTS ២៨៧ មាត្រា១៤៦(១) (ដូចគ្នា)។ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ១០១៥ UNTS ២៤៣ មាត្រា III ("កំណត់ថាជាការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបុគ្គលដែល "ប្រព្រឹត្ត ចូលរួម ដោយផ្ទាល់ក្នុងការញុះញង់ ឬសមគំនិត [ឬ] [...] ជួយលើកទឹកចិត្ត ឬសហការដោយផ្ទាល់នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍")។ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិព្រៃផ្សៃ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ

៤៧៦. លើសពីនេះ តុលាការ Nuremberg យល់ឃើញថា ការខកខានរបស់ថ្នាក់លើក្នុងការអនុវត្តតួនាទីរបស់ខ្លួនដើម្បីគ្រប់គ្រងអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ អាចនាំឱ្យមានការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ[៨៤១]។ ក្រោយមកគោលការណ៍នេះត្រូវបានចងក្រងនៅក្នុងមាត្រា៨៦ និងមាត្រា៨៧ នៃពិធីសារបន្ថែមទាក់ទងនឹងអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ("ពិធីសារបន្ថែមI")[៨៤២]។ ទោះបីជាពិធីសារបន្ថែម I ត្រូវបានអនុម័តនៅឆ្នាំ១៩៧៧ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល ICTY យល់ឃើញថា "ការទទួលខុសត្រូវចំពោះការបញ្ជា គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទាក់ទងនឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិ មុនពេលអនុម័តយកពិធីសារបន្ថែម I"[៨៤៣] នេះទៅទៀត។ អង្គជំនុំ-

---

៣៩/៤៦ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ មាត្រា៤(១) (ទាក់ទងនឹងប្រភេទអំពើឧក្រិដ្ឋ "ដែលជាការសមគំនិត ឬការចូលរួមនៅក្នុងការធ្វើទារុណកម្ម")។

[៨៤១] *សូមមើលផងដែរ ការជំនុំជម្រះឧត្តមសេនីយ៍ Tomoyuki Yamashita* សាលក្រមរបស់សាលាដំបូង និងតុលាការកំពូលសហរដ្ឋអាមេរិក សេចក្ដីសម្រេច *Habeas* ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៤៦ *របាយការណ៍ច្បាប់របស់ឧក្រិដ្ឋជនសង្គ្រាម (១៩៤៨)* ភាគី IV ទំព័រ១។ *ការជំនុំជម្រះ Wilhelm von Leeb និងអ្នកជាប់ចោទដប់បីនាក់ផ្សេងទៀត ("ការជំនុំជម្រះមេបញ្ជាការជាន់ខ្ពស់អាល្លឺម៉ង់")* ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៤៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤៨ *របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (១៩៤៩)* ភាគ XII ទំព័រ១។ *ការជំនុំជម្រះ Oswald Pohl និងអ្នកផ្សេងទៀត ("រឿងក្ដី Pohl")* សេចក្ដីសម្រេចថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធាNuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៥០)* ភាគ V ទំព័រ១៩៣។

[៨៤២] ពិធីសារបំពេញបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ចូលជាធរមាននៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៨ ១១២៥ UNTS ៣ មាត្រា៨៦ (ការខកខានក្នុងការចាត់វិធានការណ៍) និងមាត្រា៨៧ (កាតព្វកិច្ចរបស់មេបញ្ជាការ)។ *សូមមើលផងដែរ*ពិធីសារបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ ចូលជាធរមាននៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៨ ១១២៥ UNTS ៦០៩ មាត្រា១(១) (ចែងអំពី "ការបញ្ជាដែលមានការទទួលខុសត្រូវ")។

[៨៤៣] *រឿងក្ដីត រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ហិប្រឆាំងនឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-AR72) ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ២៩ (បានសន្និដ្ឋានផងដែរថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ មុនឆ្នាំ១៩៩១)។ អង្គជំនុំជម្រះយល់ឃើញ

ជម្រះយល់ឃើញថា ការទទួលខុសត្រូវដោយការបញ្ជា គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ។

៤៧៧. យុត្តិសាស្ត្ររបស់តុលាការ Nuremberg និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិថ្មីៗជាច្រើន ក៏បានបង្ហាញថា ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩[៨៤៤] ការទទួលខុសត្រូវរបស់ថ្នាក់លើមិនត្រូវបានកំណត់ចំពោះតែមេបញ្ជាការយោធាប៉ុណ្ណោះនោះទេ។ ដូចដែលបាន រៀប

---

ថា គ្មានតុលាការព្រហ្មទណ្ឌអន្តរជាតិណាមួយ លើកឡើងនូវសម្អាងហេតុច្បាស់លាស់ថាតើ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមានចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ *នៅក្នុងករណីគ្មាន*ជម្លោះប្រដាប់អាវុធ ទោះបីជាមានការលើកឡើងមួយចំនួនថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចមានចែងអំពីការទទួលខុសត្រូវនេះ។ *សូមមើល រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* សេចក្តីសម្រេចស្តីពីការតវ៉ារួមទៅនឹងយុត្តាធិការ អង្គជំនុំជម្រះសាលាដំបូង ICTY (IT-01-47-PT) ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ៩៣(v)។

[៨៤៤] *សូមមើលឧទាហរណ៍ ការជំនុំជម្រះ Karl Brandt និងអ្នកផ្សេងទៀត ("រឿងក្តី Medical")* សេចក្តីសម្រេចថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៧ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៥០)* ភាគ I-II ទំព័រ១ (យល់ឃើញថា មេដឹកនាំរដ្ឋាភិបាលស៊ីវិលមួយរូប អាចសម្រេចឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់)។ *ការជំនុំជម្រះ Friedrich Flick និងអ្នកផ្សេងទៀត ("រឿងក្តី Flick")* សេចក្តីសម្រេចថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៤៧ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង (១៩៥០)* ភាគ VI ទំព័រ១ (យល់ឃើញថា ឧស្សាហករណ៍ជនស៊ីវិលមួយរូប មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយផ្អែកលើ "ការដឹង និងការយល់ព្រម" ចំពោះឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន)។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១៩៥ ("គោលការណ៍ដែលយោធា *និងថ្នាក់លើផ្សេងទៀត* អាចសម្រេចឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើរបស់អ្នកនៅក្រោមបង្គាប់ខ្លួន គោលការណ៍នេះត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់ និងអនុសញ្ញា") (គូសបញ្ជាក់បន្ថែម)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-95-1-A-A) ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ កថាខណ្ឌ៥១ ("វាកើតចេញពីយុត្តិសាស្ត្រអន្តរជាតិ ដែលទ្រឹស្តីនៃការទទួលខុសត្រូវជាន់ខ្ពស់មិនត្រឹមតែកំណត់ចំពោះថ្នាក់លើផ្នែកយោធាទេ ប៉ុន្តែការទទួលខុសត្រូវនេះគ្របដណ្តប់ផងដែរលើថ្នាក់លើផ្នែកស៊ីវិល")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-2004-16-A) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ២៥៧ ("បន្ថែមលើមេបញ្ជាការយោធា ការទទួលខុសត្រូវរបស់ថ្នាក់លើក្រោមមាត្រា៦(៣) នៃលក្ខន្តិកៈ[តុលាការ SCSL] រួមបញ្ចូលមេដឹកនាំនយោបាយ និងជនស៊ីវិលថ្នាក់លើផ្សេងទៀតដែលស្ថិតនៅក្នុងមុខតំណែងមានអំណាច")។

រាប់លម្អិតខាងក្រោម កម្រិតនៃការគ្រប់គ្រងដែលបុគ្គលម្នាក់អនុវត្តលើអ្នកផ្សេងទៀត មាន លក្ខណៈសំខាន់ជាងប្រភេទមុខងាររបស់បុគ្គលនោះ បើតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

៤៧៨. អង្គជំនុំជម្រះយល់ឃើញថា គ្រប់ពេលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ មានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

### ២.៧.១ ការប្រព្រឹត្តិ

៤៧៩. អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា "ការប្រព្រឹត្តិ" ដែលជាទម្រង់នៃការទទួលខុសត្រូវ រួមបញ្ចូលទាំងការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្ម និងការប្រព្រឹត្តិតាមរយៈការចូលរួមក្នុងទម្រង់នៃសហឧក្រិដ្ឋកម្មរួម។

#### ២.៧.១.១ ការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្ម

៤៨០. ដូចដែលបានយល់ជាទូទៅថា ការប្រព្រឹត្តិរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈអំពើសកម្ម ឬអកម្ម ដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ[៨៤៥]។

៤៨១. ជនជាប់ចោទត្រូវតែបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនា ឬបានដឹងអំពីភាពសំខាន់ដែលថាឧក្រិដ្ឋកម្មទំនងនឹងកើតមានឡើងដោយសារតែផលវិបាកនៃអំពើរបស់ខ្លួន[៨៤៦]។

---

[៨៤៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៨៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kumuhanda* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-99-54A-T) ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ កថាខណ្ឌ ៥៩៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៤៩។

[៨៤៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-03-66-T) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ៥០៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៥០។

### ២.៧.១.២ សំអាងហេតុទាក់ទងនឹងការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្ម

៤៨២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៥៣. ឌុច បានធ្វើទារុណកម្មដោយផ្ទាល់ ឬប្រព្រឹត្តអមនុស្សធម៌ចំពោះអ្នកទោសនៅមន្ទីរ ស២១ ហើយអំពើនេះត្រូវបានប្រព្រឹត្តក្នុងឱកាសដាច់ដោយឡែកពីគ្នា និងតាមរយៈមធ្យោបាយផ្សេងៗ។ ឌុច មិនត្រូវបានចោទប្រកាន់ពីទម្រង់នៃការទទួលខុសត្រូវលើ "ការប្រព្រឹត្តិ" បទទារុណកម្មក្រោមច្បាប់ជាតិឡើយ[៨៨៧]។

៤៨៣. ជនជាប់ចោទបាននិយាយថា គាត់បានចូលរួមក្នុងការសួរចម្លើយអ្នកជាប់ឃុំបីនាក់គឺ កុយ ធួន ឈិត អ៊ីវ និង ម៉ា ម៉េងឃាង។ គាត់បានទទួលស្គាល់ថាគាត់បានទះកំផ្លៀង ឈិត អ៊ីវ ដើម្បីបញ្ចៀសកុំឲ្យ អ៊ិន លន ហៅ ណាត ធ្វើទារុណកម្មអ្នកជាប់ឃុំរូបនេះ។ ជនជាប់ចោទក៏បានទទួលស្គាល់ថាគាត់បានត្រួតពិនិត្យយ៉ាងហ្មត់ចត់លើការសួរចម្លើយ ម៉ែន សាន ហៅ យ៉ា និង សៀត ឆែ ហៅ ទុំ ប៉ុន្តែគាត់បានបដិសេធថាមិនបានសួរចម្លើយអ្នកជាប់ឃុំទាំងនោះដោយផ្ទាល់ឡើយ។ ជនជាប់ចោទបាន

---

[៨៨៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ១៥៣ ដែលត្រូវបានធ្វើការកែប្រែដោយ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណៅជាភាសាបារាំងនៃ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"" (ដែលសរសេរថា « Le paragraphe 153 de l'Ordonnance *est remplacé comme suit* : Duch n'a pas à répondre du crime de torture, tel que défini par le droit interne cambodgien, sur la base du mode de participation 'commission' ») មិនស៊ីគ្នានឹងសំណៅជាភាសាខ្មែរ និងភាសាអង់គ្លេស (ដែលបានសរសេរថា "កថាខណ្ឌ១៥៣នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានកែប្រែ*ដោយបានគូសបញ្ជាក់បន្ថែមដូចតទៅនេះ៖* Duch is not indicted for the mode of liability of 'commission' for the domestic crime of torture" និងជាភាសាខ្មែរ "ឌុច មិនត្រូវបានចោទប្រកាន់ពីទម្រង់នៃការទទួលខុសត្រូវលើ "ការប្រព្រឹត្តិ" បទទារុណកម្មក្រោមច្បាប់ជាតិឡើយ") (គូសបញ្ជាក់បន្ថែម)។ អង្គជំនុំជម្រះយល់ឃើញថាភាពខុសគ្នានៃសំណៅទាំងនេះ ដោយសារតែការភ័ន្តច្រឡំយ៉ាងច្បាស់ចំពោះការបកប្រែនៅក្នុងសំណៅជាភាសាបារាំង។

00573607



បដិសេធថា មិនបានចូលរួមក្នុងការសួរចម្លើយ ឬធ្វើទារុណកម្មអ្នកជាប់ឃុំផ្សេងៗទៀតនៅមន្ទីរ ស២១ឡើយ[៨៤៨]។

៤៨៤. សាក្សីមួយចំនួនបានបញ្ជាក់ថា ម្ដងម្កាលជនជាប់ចោទបានវាយ និងទាត់ធាក់អ្នកទោស[៨៤៩]។ សាក្សី វ៉ាន់ ណាត បានផ្ដល់សក្ខីកម្មថា ជនជាប់ចោទបានទាត់ធាក់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ ម៉េង ត្រង់ក្បាល ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងបានបដិសេធរឿងនេះ [៨៥០]។ អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយមួយចំនួនរបស់ជនជាប់ចោទនៅពេលសវនាការទាក់ទងនឹងការចូលរួមរបស់គាត់ក្នុងការធ្វើ ទារុណកម្មមានលក្ខណៈមិនច្បាស់លាស់ ឬផ្ទុយគ្នា[៨៥១]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះ យល់ឃើញថា ការទាត់ធាក់ ឬការវាយពីសំណាក់ជនជាប់ចោទមិនមានភស្តុតាងបញ្ជាក់ទៅតាម បទដ្ឋានតម្រូវនោះទេ ហើយអង្គជំនុំជម្រះក៏យល់ឃើញថា ការទះកំផ្លៀង ឈិត អ៊ុំ មិនបានបង្កឲ្យ មានការទទួលរងរបួស ឬការឈឺចាប់ធ្ងន់ធ្ងរ ដូចការឈឺចាប់ដោយសារការធ្វើទារុណកម្ម ឬអំពើ អមនុស្សធម៌ផ្សេងៗទៀតដែរ។

[៨៤៨] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២២-២៤, ២៦-២៨។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ១៨-១៩, ២៧។ "កំណត់ហេតុនៃការតទល់មុខគ្នា" ឯកសារ E3/396, ERN (ភាសាខ្មែរ) 00166591-00166592។

[៨៤៩] ប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៦៨-៧០។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (សោម ម៉េត) ទំព័រ៧-៨។ ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៨០-៨១។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ការអានកំណត់ហេតុស្ដាប់ចម្លើយរបស់ ញ៉ែម អេន) ទំព័រ៨៩-៩១។ "កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ (E3/413 ERN (ភាសាខ្មែរ) 00146597-00146598 ។ ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ២៧, ៥៦-៥៧។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ៦៩។

[៨៥០] ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ (វ៉ាន់ ណាត) ទំព័រ៧៧។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ២៨-៣០។

[៨៥១] *ប្រៀបធៀប* ប្រតិចារឹក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ២៤-២៨។ "គោលជំហររបស់មេធាវីការពារក្ដីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 កថាខណ្ឌ២១៣(ឃ) (មិនយល់ព្រម)។ ប្រតិចារឹក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៩៦-៩៧។

៤៨៥. ដំបូងឡើយសាក្សី ប្រាក់ ខន បាននិយាយថា ជនជាប់ចោទបានចូលរួមក្នុងការធ្វើទារុណកម្ម លើស្ត្រីម្នាក់ និងបានឆក់ខ្សែភ្លើង វាយ និងដោះសម្លៀកបំពាក់របស់ស្ត្រីនោះថែមទៀត[៨៥២]។ ប៉ុន្តែនៅពេលសវនាការ គាត់បានផ្តល់សក្ខីកម្មថា ដែក ប៊ូ ទេ ដែលជាអ្នកបានធ្វើទារុណកម្មលើស្ត្រីនោះ ដោយមានវត្តមានជនជាប់ចោទផងដែរ[៨៥៣]។ ជនជាប់ចោទបានបដិសេធថា មិនមានរឿងបែបនេះកើតឡើងឡើយ [៨៥៤]។ ចម្លើយរបស់សាក្សី ប្រាក់ ខន ទាក់ទងនឹងអង្គហេតុនេះគឺមិនស៊ីសង្វាក់គ្នាឡើយ ហើយអង្គជំនុំជម្រះយល់ឃើញថា អង្គហេតុនេះមិនមានភស្តុតាងបញ្ជាក់ទៅតាមបទដ្ឋានតម្រូវនោះទេ។

៤៨៦. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទមិនទទួលខុសត្រូវចំពោះការធ្វើទារុណ-កម្ម ឬអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្មនោះទេ។

### ២.៧.១.៣ ការប្រព្រឹត្តិបទល្មើសតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម

#### ២.៧.១.៣.១ សារណា និងប្រវត្តិនីតិវិធី

៤៨៧. សហព្រះរាជអាជ្ញាបានលើកសេចក្តីសន្និដ្ឋានថា ទ្រឹស្តីនៃការទទួលខុសត្រូវដែលគេស្គាល់ថាជា "សហឧក្រិដ្ឋកម្មរួម" អាចអនុវត្តបាននៅ អ.វ.ត.ក និងអាចអនុវត្តចំពោះការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទ។ ជាពិសេស សហព្រះរាជអាជ្ញាបានលើកយកយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ICTY និងយុត្តិសាស្ត្រតុលាការ Nuremberg ដើម្បីទាញសេចក្តីសន្និដ្ឋានថា ជនជាប់ចោទ "បានប្រព្រឹត្ត" ឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម[៨៥៥]។ ទោះបីជាជនជាប់ចោទមិនបាន

---

[៨៥២] "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន" ឯកសារ E3/413 ERN (ភាសាខ្មែរ) 00146599 ។

[៨៥៣] ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ (ប្រាក់ ខន) ទំព័រ១៩-២០, ៤៣-៤៥។ ប្រតិចារឹក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤១-៤២។

[៨៥៤] ប្រតិចារឹក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣០-៣២។

[៨៥៥] "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" E73 ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩។

លើកឡើងអំពីការអនុវត្តទូទៅនៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ក៏ដោយ ក៏ជនជាប់ចោទបានតវ៉ា ចំពោះការអនុវត្តទ្រឹស្តីនេះចំពោះការចោទប្រកាន់នានាលើរូបគាត់[៨៥៦]។

៤៨៨. សហចៅក្រមស៊ើបអង្កេតមិនបានបញ្ចូលសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[៨៥៧]។ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការមិនបញ្ចូលសហឧក្រិដ្ឋកម្មរួម ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨[៨៥៨]។ អង្គបុរេជំនុំជម្រះបានលើកសំអាងហេតុថា ទោះបីជាអង្គហេតុនានាដែលពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ត្រូវបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏ប៉ុន្តែអង្គហេតុទាំងនេះជាផ្នែកមួយនៃសំណុំ-រឿងលេខ ០០២/១៩-០៩-២០០៧ ហើយមិនបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ (សំណុំរឿងនេះ) បន្ទាប់ពីពេលចេញដីកាបំបែកសំណុំរឿងនោះទេ[៨៥៩]។ លើសពីនេះ ទោះបីជាដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាដែលយោងទៅលើវិធាន៦៦ បានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ចូលសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ-

---

[៨៥៦] "ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការអនុវត្តទៅលើរឿងក្តីនូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម" E73/2 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

[៨៥៧] អង្គជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងបញ្ហាដាច់ដោយឡែកមួយថា សហកម្មឧក្រិដ្ឋកម្មរួមគឺជាទម្រង់ទទួលខុសត្រូវដែលអាចយកមកអនុវត្តចំពោះមុខ អ.វ.ត.ក និងសហឧក្រិដ្ឋកម្មរួមមានចែងនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ *សូមមើល* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស "ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម" D97/13។ *សូមមើលផងដែរ* ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៧) "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" D97/17/6 (សាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចថា ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធរបស់សហឧក្រិដ្ឋ-កម្មរួមអាចយកមកអនុវត្តបាននៅ អ.វ.ត.ក ប៉ុន្តែទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម មិនអាចយកមកអនុវត្តបានទេ)។

[៨៥៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០៨-១៤២។

[៨៥៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៧-១២៣។ *សូមមើលផងដែរ* ផ្នែក ១.២ ។

ជម្រះក៏ដោយ[៨៦០] ក៏មិនមានអង្គហេតុពាក់ព័ន្ធបន្ថែមណាមួយត្រូវបានបញ្ចូលនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ក្រោយពេលចេញដីកាបំបែកសំណុំរឿងនោះទេ។ អង្គបុរេជំនុំជម្រះសម្រេចថា ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់ថា "ជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមមែននោះ ការយល់ឃើញលើកម្រិត និងវិសាលភាពនៃការទទួលខុសត្រូវរបស់គាត់ នឹងអាចខុសពីការរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទ "មិនទទួលដំណឹងអំពីការចោទប្រកាន់ចំពោះការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម មុនពេលចេញដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានោះទេ។ សហឧក្រិដ្ឋកម្មរួមនៅមន្ទីរស២១ មិនមែនជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរឡើយ។ ដោយសារមូលហេតុនេះ អង្គបុរេជំនុំជម្រះនឹងមិនបន្ថែមបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងដំណាក់កាលនេះឡើយ"។ អង្គបុរេជំនុំ-ជម្រះបដិសេធមិនពិចារណាអំពីសហឧក្រិដ្ឋកម្មរួមមានចែង ឬមិនមានចែងច្បាស់លាស់នៅក្នុងមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ឬថាតើសហឧក្រិដ្ឋកម្មរួមនេះជាផ្នែកមួយនៃច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ យ៉ាងណានោះទេ[៨៦១]។

---

[៨៦០] ជាពិសេស វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា បានចែងដូចតទៅ៖ "សហឧក្រិដ្ឋកម្មរួម ចាប់ផ្តើមមានអត្ថិភាពចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ មក គឺនៅពេលដែល សុន សេន បានណែនាំទៅ ណាត និង ឌុច ឲ្យរៀបចំបង្កើតជាមន្ទីរស២១។ សហឧក្រិដ្ឋកម្មរួមបានមានអត្ថិភាពចាប់តាំងពីមន្ទីរស២១ បានដំណើរការទាំងស្រុងនៅក្នុងខែតុលា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។ គោលបំណងនៃសហឧក្រិដ្ឋកម្មរួម គឺការចាប់ខ្លួន ការឃុំឃាំង ប្រព្រឹត្តកម្មឃោរឃៅ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការកម្ទេចចោលជាលក្ខណៈប្រព័ន្ធ ចំពោះ "ខ្មាំង" ទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ ដោយការប្រព្រឹត្តិនូវអំពើឧក្រិដ្ឋផ្សេងៗ ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះស្រាប់។ គឺជាប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់ដែលមានការរៀបចំមួយដែលមានអត្ថិភាពនៅមន្ទីរស២១ ចាប់តាំងពីពេលកកើតនៃសហឧក្រិដ្ឋកម្មរួមរហូតដល់ចុងបញ្ចប់របស់វា។ រាល់ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅមន្ទីរស២១ ដូចដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរនេះ គឺសុទ្ធតែស្ថិតនៅក្នុងគោលបំណងនៃសហឧក្រិដ្ឋកម្មរួមនេះ។ ឌុច បានចូលរួមប្រព្រឹត្តនៅក្នុងអំឡុងពេលដែលសហឧក្រិដ្ឋកម្មរួមនេះមានអត្ថិភាពរួមគ្នាជាមួយនឹងអ្នកចូលរួមដទៃៗទៀត នៅក្នុងរយៈកាលផ្សេងៗគ្នាដោយរាប់បញ្ចូលទាំងអតីតប្រធានមន្ទីរស២១ ឈ្មោះ ណាត និងសមាជិកដទៃៗទៀតនៃគណៈកម្មាធិការមន្ទីរស២១ ពោលគឺ ឃឹម វ៉ាក ហៅ ហ៊ី និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ព្រមទាំងអ្នកនៅក្រោមបង្គាប់របស់ពួកគេផងដែរ"។ "វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពរទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" D96 កថាខណ្ឌ២៥០-២៥១។

[៨៦១] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១២៣, ១៣៦, ១៤១-១៤២។

៤៨៩. នៅក្នុងអំឡុងសវនាការបឋមកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីនានាថា សហព្រះរាជអាជ្ញានឹងស្នើសុំឱ្យអង្គជំនុំជម្រះអនុវត្តសហ-ឧក្រិដ្ឋកម្មរួមជាការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ[៨៦២]។ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ(“សំណើសុំរបស់ ក.ស.ព ពាក់ព័ន្ធនឹង JCE”) បានស្នើសុំឱ្យអង្គជំនុំជម្រះប្រកាសថា សហឧក្រិដ្ឋកម្មរួម (នៅក្នុងទម្រង់នីមួយៗទាំងបីរបស់វា) អាចយកមកអនុវត្តជាទូទៅ ជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក បាន ហើយថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម[៨៦៣]។

---

[៨៦២] ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ៨-៩ (“ខ្ញុំសូមយកឱកាសនេះដើម្បីអញ្ជើញអង្គជំនុំជម្រះសាលាដំបូង និងភាគីថា នៅក្នុងពេលជំនុំជម្រះលើអង្គសេចក្តី សហព្រះរាជអាជ្ញាចង់ឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាទៅលើការទទួលយកសហឧក្រិដ្ឋកម្មរួមមកពិចារណា នៅក្នុងដំណើរការក្តីចំពោះជនជាប់ចោទ។ [...] ខ្ញុំចង់ជូន និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងគិតថានេះ -- គិតថានឹងទទួលយកចំណុចទាក់ទងការសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណើរ ការនីតិវិធី។ ទស្សនាទានមួយនេះគឺតំណាង ហើយគាំទ្រដោយអង្គហេតុដែលមានចែងនៅក្នុងសំណុំរឿង ហើយជាងនេះទៅទៀតនោះ ប្រភេទទីមួយនិងទីពីរនៃសហឧក្រិដ្ឋកម្មរួម គឺអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាទៅលើទំនួលខុសត្រូវទាំងពេញលេញតែម្តងរបស់ជនជាប់ចោទ។ យើងខ្ញុំសូមសន្និដ្ឋាននិងលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងជាការពិតគឺមានកាតព្វកិច្ច ទើបការពិចារណាទៅលើអង្គហេតុដែលមាននៅក្នុងសំណុំរឿង។ ប៉ុន្តែ យ៉ាងណាក៏ដោយគឺមានសេរីភាពក្នុងការបកស្រាយច្បាប់ ហើយនិងអនុវត្តច្បាប់ ហើយធ្វើការកំណត់ប្រភេទ និងពិចារណាទៅលើអង្គហេតុដែលមាននៅក្នុងសំណុំរឿង។ ភាពឯករាជ្យនេះ ជាការពិតទៅគឺជាកាតព្វកិច្ច គឺមានន័យថាអង្គជំនុំជម្រះសាលាដំបូងគឺមិនមានកាតព្វកិច្ចគោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ហានេះទេ។ យើងខ្ញុំសូមលើកទឡ្ហីករណ៍សំអាងថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃទៅលើការអនុវត្តទៅបាននៃទស្សនាទានសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណើរការក្តីរបស់យើងមួយនេះ។ ហើយ [...] សូមអញ្ជើញអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការពិចារណាទៅលើភាពអាចអនុវត្តទៅបាននៃសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណើរការក្តីមួយនេះ”)។

[៨៦៣] “សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម” E73 ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩។ *សូមមើលផងដែរ* “សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ៖ សារណាគាំទ្រទាក់ទងនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញាស្នើឱ្យអនុវត្តក្នុងករណីនេះនូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម” E73/3 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

៤៩០. នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានាថា បញ្ហានៃការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងនាមជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម គឺជាបញ្ហាស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីនានាឆ្លើយតបទៅនឹងសំណើសុំរបស់ ក.ស.ព ទាក់ទងនឹង JCE។ អង្គជំនុំជម្រះលើកឡើងបន្ថែមថា អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំនេះ នៅក្នុងសាលក្រមរបស់ខ្លួន[៨៦៤]។

៤៩១. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនជាប់ចោទ បានដាក់សារណាឆ្លើយតបទៅនឹងសំណើសុំរបស់ ក.ស.ព ទាក់ទងនឹង JCE (“ចម្លើយតបរបស់ជនជាប់ចោទទាក់ទងនឹង JCE”) ដោយអះអាងថា សំណើសុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួមរបស់ ក.ស.ព មិនអាចទទួលយកបានឡើយ បើយោងទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមិនបានបញ្ចូលសហឧក្រិដ្ឋ-កម្មរួមទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ។ ចម្លើយតបរបស់ជនជាប់ចោទទាក់ទងនឹង JCE បានលើកទឡ្ហីករណ៍បន្ថែមថា សំណើសុំរបស់ ក.ស.ព ទាក់ទងនឹង JCE គួរតែត្រូវបដិសេធ ដោយផ្អែកលើមូលដ្ឋានថា អង្គហេតុដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានបង្ហាញធាតុផ្សំគ្រប់គ្រាន់ ដែលបង្កើតឲ្យមានជាការចូលរួមជាប្រភេទសហឧក្រិដ្ឋកម្មរួមនោះទេ ហើយសហព្រះរាជអាជ្ញា ក៏មិនអាចបង្ហាញភាពជាក់លាក់ឲ្យបានគ្រប់គ្រាន់ស្តីអំពីទម្រង់នៃការទទួលខុសត្រូវដែរ។ ចម្លើយតបរបស់ជនជាប់ចោទទាក់ទងនឹង JCE បានបន្ថែមថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចអនុវត្តសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងត្រូវអនុញ្ញាតឲ្យជនជាប់ចោទ “បង្ហាញនូវសេចក្តីកត់សម្គាល់របស់ខ្លួន ទាក់ទងនឹងការកំណត់បទចោទថ្មីដែលគ្រោងធ្វើនៅមុនការសម្រេចសេចក្តីលើរឿងក្តី”[៨៦៥]។

### ២.៧.១.៣.២ វិធាន៩៨(២) នៃវិធានផ្ទៃក្នុង

[៨៦៤] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៧។

[៨៦៥] “ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យមានការអនុវត្តទៅលើរឿងក្តីនូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម” E73/2 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ ៧-១០, ១៥-២៧, ៣៨។

៤៩២. បញ្ហាជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះមិនជាប់កាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់បទចោទប្រកាន់ដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែនោះទេ។ ជាក់ស្តែងវិធាន៩៨(២) នៃវិធានផ្ទៃក្នុងចែងថា៖

> សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ។

៤៩៣. ភាគីនានាមិនបានតវ៉ាទៅនឹងវិធាន៩៨(២) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យមានការផ្លាស់ប្តូរការកំណត់បទចោទចំពោះបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលរួមបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែនោះទេ[៨៦៦]។ ទោះបីជាបទប្បញ្ញត្តិនានានៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមិនមានចែងយ៉ាងច្បាស់ទាក់ទងនឹងការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ការផ្លាស់ប្តូរការកំណត់បទចោទប្រកាន់នេះត្រូវបានអនុញ្ញាតផ្អែកតាមវិធាន៩៨(២)[៨៦៧]។

៤៩៤. ទោះបីជាយ៉ាងណាក៏ដោយ វិធាន៩៨(២) នៃវិធានផ្ទៃក្នុងកំណត់ថា ការកែប្រែការកំណត់បទចោទឡើងវិញដោយអង្គជំនុំជម្រះត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែប៉ុណ្ណោះ។ ការធ្វើដូច្នេះស្របគ្នានឹងសមត្ថ-

---

[៨៦៦] *សូមមើលឧទាហរណ៍* "ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឱ្យមានការអនុវត្តទៅលើរឿងក្តីនូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម" E73/2 ជើងទំព័រលេខ១០។

[៨៦៧] *សូមមើល* វិធាន៥៥ (សមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការផ្លាស់ប្តូរការកំណត់បទចោទចំពោះបទល្មើស) នៃវិធានផ្ទៃក្នុងរបស់តុលាការ ICC (ICC-BD/01-01-04 ចូលជាធរមាននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤) (អនុញ្ញាតឱ្យផ្លាស់ប្តូរការកំណត់បទចោទចំពោះបទល្មើស ឱ្យស្របគ្នានឹងទម្រង់នៃការចូលរួមខុសគ្នា)។

កិច្ចដែលបានផ្តល់ទៅឱ្យអង្គជំនុំជម្រះសាលាដំបូងនៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[៨៦៨] ក៏ដូចជាក្នុងប្រព័ន្ធច្បាប់បារាំងដែលច្បាប់កម្ពុជាយកជាគំរូ[៨៦៩]។ អង្គជំនុំជម្រះយល់ឃើញថា បទប្បញ្ញត្តិនៃវិធាន៩៨(២)នៃវិធានផ្ទៃក្នុងដែលចែងថាមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទនោះគឺជាការលើកឡើងជាថ្មីនៃការកំណត់យ៉ាងច្បាស់ដែលមានន័យថា ការផ្លាស់ប្តូរការកំណត់បទចោទថ្មីណាមួយមិនត្រូវធ្វើឱ្យលើសពីអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់នោះទេ។

៤៩៥. ដូចគ្នានេះដែរ វិធានរបស់តុលាការ ICC បានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទប្រកាន់បន្ទាប់ពីពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ[៨៧០]។ ទោះបីជាយ៉ាងណាក៏ដោយ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា ជាទូទៅអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យធ្វើការផ្លាស់ប្តូរជាផ្លូវការ នូវបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅពេលដែលអង្គហេតុបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងមួយទៀត ឬច្រើនដែលបទល្មើសទាំងនោះមិនបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៨៧១]។ ការផ្លាស់ប្តូរការកំណត់បទចោទកើតចេញពីរចនាសម្ព័ន្ធខុសគ្នាជាច្រើន រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា និង អ.វ.ត.ក ដែលយន្តការនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍*មួយចំនួន ដែលផ្អែកលើច្បាប់ កុំមិនឡូ (Common Law) មិនមានលក្ខណៈដូចគ្នានឹងយន្តការរបស់ អ.វ.ត.ក ដែលផ្អែកលើច្បាប់ស៊ីវិល (Civil Law) នោះទេ។ ខុសពីតុលាការ ICTY និងតុលាការ ICTR គ្មានយន្តការណាមួយនៅក្នុង អ.វ.ត.ក អនុញ្ញាតឱ្យភាគីនានា ឬអង្គជំនុំជម្រះ ធ្វើការកែប្រែជាផ្លូវការលើដីកាបញ្ជូនរឿងទៅជំនុំ-

---

[៨៦៨] *សូមមើល ឧទាហរណ៍* មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។ មាត្រា១០ និង មាត្រា១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ (SOC)។

[៨៦៩] *សូមមើល* តុលាការកំពូលផ្នែកឧក្រិដ្ឋកម្ម ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៦, ព្រឹត្តប័ត្រឧក្រិដ្ឋកម្ម លេខ១៣៦៖ " តុលាការមជ្ឈិមជាអ្នកមានសមត្ថកិច្ចកែប្រែការកំណត់អង្គហេតុដែលបានចោទប្រកាន់ និងជំនួសដោយអង្គហេតុថ្មី [...] ក្នុងលក្ខខណ្ឌដែលបទចោទមិនត្រូវបានផ្លាស់ប្តូរ និងបន្ថែម ដូចដែលមានចែងក្នុងពាក្យបណ្តឹង។"

[៨៧០] *សូមមើល* បទបញ្ជា៥៥នៃបទបញ្ជាតុលាការ ICC (សមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការផ្លាស់ប្តូរការកំណត់បទចោទ) (ICC-BD/01-01-04 ចូលជាធរមានថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤)។

[៨៧១] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kupreškić *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-16-T) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៧៤៨។

ជម្រះនោះទេ។ មូលដ្ឋាននៃការផ្លាស់ប្តូរការកំណត់បទចោទនៅ អ.វ.ត.ក គឺមានចែងនៅក្នុងវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងដែលចែងយ៉ាងច្បាស់អំពីយថាភាពនេះ ដោយគោរពទៅតាមការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។

៤៩៦. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន៩៨(២)នៃវិធានផ្ទៃក្នុងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្លាស់ប្តូរការកំណត់បទចោទដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដើម្បីឲ្យស្របជាមួយនឹងទម្រង់នៃការទទួលខុសត្រូវថ្មីមួយ ប្រសិនបើមានការផ្លាស់ប្តូរការកំណត់បទចោទ។ នៅពេលមានការផ្លាស់ប្តូរការកំណត់បទចោទ អង្គជំនុំជម្រះត្រូវតែធានាផងដែរថា (i) មិនមានការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង(ii) ទម្រង់នៃការទទួលខុសត្រូវថ្មីនោះ អាចយកមកអនុវត្តបាននៅ អ.វ.ត.ក។

##### ២.៧.១.៣.២.១ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

៤៩៧. មាត្រា៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

> នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងសិទ្ធិស្មើគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦៖
> ក. ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន។
> ខ. មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង។

៤៩៨. តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលឯកសារជាមូលដ្ឋានរបស់ខ្លួនមានចែងស្រដៀងគ្នានូវបទប្បញ្ញត្តិទាក់ទងនឹងការជំនុំជម្រះដោយយុត្តិធម៌[៨៧២] បានលើកឡើងថា ទោះបីជាតុលាការព្រហ្មទណ្ឌមួយអាច

---

[៨៧២] *សូមមើល* មាត្រា ៦(៣) នៃអនុសញ្ញាអឺរ៉ុបសម្រាប់ការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ("បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ដោយបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិអប្បបរមាដូចខាងក្រោម៖ ក) ទទួលព័ត៌មានភ្លាមៗ និងលម្អិតជា

ផ្លាស់ប្តូរការកំណត់បទចោទដែលខ្លួនមានយុត្តាធិការក៏ដោយ ក៏អង្គជំនុំជម្រះត្រូវផ្តល់ឱ្យជនជាប់ចោទនូវលទ្ធភាពអនុវត្តសិទ្ធិការពារខ្លួន "ដោយជាក់ស្តែង និងមានប្រសិទ្ធភាព និងជាពិសេសនៅក្នុងពេលសមស្រប"[៨៧៣]។ តាមការអនុវត្តជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា ការអនុវត្តបែបនេះគឺបានធានាថាជនជាប់ចោទបានដឹងអំពីលទ្ធភាពនៃការកំណត់បទចោទថ្មី និងផ្តល់ឱ្យជនជាប់ចោទនូវលទ្ធភាពគ្រប់គ្រាន់ដើម្បីការពារខ្លួនប្រឆាំងនឹងការកំណត់បទចោទថ្មីនោះ[៨៧៤]។

៤៩៩. ស្រដៀងគ្នានេះដែរ វិធាន៥៥ របស់តុលាការ ICC អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ICC ផ្លាស់ប្តូរការកំណត់បទចោទដោយមិនចាំបាច់ធ្វើការផ្លាស់ប្តូរការកំណត់បទចោទជាផ្លូវការ ដោយអនុលោមតាមលក្ខខណ្ឌនីតិវិធី ដូចខាងក្រោម៖

---

ភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ខ)មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន [...]")។

[៨៧៣] រឿងក្តី *Pélissier និងSassi តទល់នឹង ប្រទេសបារាំង* សាលក្រម ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ តុលាការECtHR (no. 25444/94) ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ៦២។ *សូមមើលផងដែររឿងក្តី I.H. និងអ្នកផ្សេងទៀត តទល់នឹង ប្រទេសអូទ្រីស* សេចក្តីសម្រេចចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ តុលាការECtHR (no. 42780/98) ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ កថាខណ្ឌ៣៤ ("ដើម្បីឱ្យសិទ្ធិរបស់ជនជាប់ចោទអាចអនុវត្តបានដោយប្រសិទ្ធភាព ជនជាប់ចោទត្រូវតែទទួលបានការរៀបចំពេញលេញ ទទួលបានព័ត៌មានលម្អិតទាក់ទងនឹងបទល្មើសដែលចោទប្រកាន់ រួមទាំងការកំណត់បទចោទដែលតុលាការអាចនឹងសម្រេចលើបញ្ហានោះ។ ព័ត៌មាននេះត្រូវតែផ្តល់ឱ្យមុនពេលជំនុំជម្រះ ក្នុងអំឡុងពេលធ្វើសេចក្តីព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ឬយ៉ាងហោចណាស់ ក្នុងអំឡុងពេលជំនុំជម្រះតាមរយៈមធ្យោបាយផ្សេងៗដូចជាការបន្តថិរវេលានៃការចោទប្រកាន់ផ្លូវការ ឬមិនច្បាស់លាស់ជាដើម។ ការគ្រាន់តែសំអាងលើលទ្ធភាព ដែលមានលក្ខណៈអរូបិយដែលថា តុលាការអាចសម្រេចខុសពីអ្វីដែលជាការចោទប្រកាន់ ដែលទាក់ទងនឹងធាតុផ្សំនៃបទល្មើសគឺពិតជាសំអាងមិនគ្រប់គ្រាន់នោះទេ")។

[៨៧៤] *សូមមើលរឿងក្តី Abramyan តទល់នឹង ប្រទេសរុស្ស៊ី* សេចក្តីសម្រេចចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ តុលាការECtHR (no. 10709/02) ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ៣៦-៤០។ *សូមមើលផងដែររឿងក្តី Dallos តទល់នឹង ប្រទេសហុងគ្រី* សេចក្តីសម្រេចចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ តុលាការECtHR (no. 29082/95) ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ កថាខណ្ឌ៤៧-៥៣ (យល់ឃើញថា ការផ្លាស់ប្តូរការកំណត់បទចោទ នឹងមិនបានធ្វើឱ្យបាត់បង់នូវសិទ្ធិនៃការការពារខ្លួន នៅពេលដែលជនជាប់ចោទមានឱកាសគ្រប់គ្រាន់ដើម្បីការពារខ្លួនក្នុងអំឡុងពេលនៃការពិនិត្យមើលដំណើរការនីតិវិធី)។ *រឿងក្តី Sipavičus តទល់នឹង ប្រទេសលីទុយអានី (Lithuania)* សេចក្តីសម្រេចចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២ តុលាការ ECtHR (no. 49093/99) ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២ កថាខណ្ឌ២៣-៣៤។

១. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ផ្អែកតាមមាត្រា៧៤ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទដើម្បីឱ្យស្របទៅនឹងឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា៦, ៧ ឬ៨ ឬឱ្យស្របទៅនឹងទម្រង់នៃការចូលរួមរបស់ជនជាប់ចោទតាមមាត្រា២៥ និង២៨ ដោយមិនឱ្យលើសពីអង្គហេតុនិងកាលៈទេសៈដែលបានកំណត់នៅក្នុងបទចោទ និងការកែប្រែណាមួយនៃបទចោទនោះទេ។

២. គ្រប់ពេលនៅក្នុងដំណាក់កាលជំនុំជម្រះ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាការកំណត់បទចោទអាចមានការផ្លាស់ប្ដូរ អង្គជំនុំជម្រះត្រូវជូនដំណឹងអំពីលទ្ធភាពនៃការផ្លាស់ប្ដូរការកំណត់បទចោទនោះទៅភាគី ហើយក្រោយពីបានពិនិត្យភស្ដុតាង អង្គជំនុំជម្រះត្រូវផ្ដល់ឱកាសឱ្យភាគីដើម្បីដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់នៅក្នុងដំណាក់កាលសមស្របនៃដំណើរការនីតិវិធី។ អង្គជំនុំជម្រះអាចលើកពេលសវនាការដើម្បីធានាថា ភាគីដែលត្រូវចូលរួមមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំឱ្យមានប្រសិទ្ធភាព ឬប្រសិនបើចាំបាច់ អង្គជំនុំជម្រះអាចនឹងបង្គាប់ឱ្យមានសវនាការមួយដើម្បីពិចារណាលើបញ្ហាទាំងអស់ពាក់ព័ន្ធនឹងការផ្លាស់ប្ដូរការកំណត់បទចោទដែលស្នើសុំនោះ។

៣. ដើម្បីអនុវត្តតាមស្មារតីនៃអនុវិធាន២នេះ អង្គជំនុំជម្រះត្រូវធានាជាពិសេសថា៖
- ក- ជនជាប់ចោទមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួនឱ្យមានប្រសិទ្ធភាព ដោយអនុលោមតាមមាត្រា៦៧(១)(ខ) និង
- ខ- ប្រសិនជាចាំបាច់ ជនជាប់ចោទត្រូវទទួលបានឱកាសដើម្បីតទល់ជាមួយសាក្សីដែលមាន ឬត្រូវបានគេសួរចម្លើយ ស្នើសុំឱ្យកោះហៅសាក្សីថ្មី ឬបង្ហាញភស្ដុតាងផ្សេងទៀត ដែលទទួលយកបានតាមមាត្រា៦៧(១)(ង)នៃលក្ខន្តិកៈទីក្រុងរ៉ូម[៨៧៥]។

៥០០. អង្គជំនុំជម្រះតុលាការកំពូល ICC បានបញ្ជាក់ថា ការផ្លាស់ប្ដូរការកំណត់បទចោទអនុលោមតាមវិធាន៥៥ មិនបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

[៨៧៥] វិធាន៥៥ នៃវិធានផ្ទៃក្នុងរបស់តុលាការ ICC (សមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការផ្លាស់ប្ដូរការកំណត់បទចោទ) (ICC-BD/01-01-04 ចូលជាធរមាន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤)។

នោះទេ[៨៧៦]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងបន្ថែមថា របៀបនៃការអនុវត្តលក្ខខណ្ឌនីតិវិធីដែលមាននៅក្នុងវិធាន៥៥(២)និង(៣) និងថាតើអាចតម្រូវឲ្យមានវិធានការធានាបន្ថែមណាមួយដើម្បីការពារឲ្យពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ ឬយ៉ាងណានោះ គឺអាស្រ័យទៅលើកាលៈទេសៈនៃរឿងក្ដីនីមួយៗ[៨៧៧]។

៥០១. នៅក្នុងអំឡុងពេលសវនាការនៃរឿងក្ដីនេះ សហព្រះរាជអាជ្ញាបានលើកឡើងនូវសំណើសុំឲ្យអង្គជំនុំជម្រះអនុវត្តនូវសហឧក្រិដ្ឋកម្មរួមចំពោះការចោទប្រកាន់លើជនជាប់ចោទ ដោយរួមបញ្ចូលនូវទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមផងដែរ[៨៧៨]។ សំណើសុំរបស់សហព្រះរាជអាជ្ញាបានបង្ហាញអំពី

---

[៨៧៦] *ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga Dyilo សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក Lubanga Dyilo និងរដ្ឋអាជ្ញា តទល់នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ដែលមានចំណងជើងថា "សេចក្ដីសម្រេចស្ដីពីការជូនដំណឹងដល់ភាគី និងអ្នកចូលរួមនានាអំពីការកំណត់បទចោទដែលអាចនឹងផ្លាស់ប្ដូរ អនុលោមតាមបទបញ្ញា៥៥(២) នៃបទបញ្ញារបស់តុលាការ" អង្គជំនុំជម្រះតុលាការកំពូល ICC (ICC-01/04-01/06 OA 15 OA 16) ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៨៧ (បដិសេធចោលការបកស្រាយបទបញ្ញា៥៥ របស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែយល់ឃើញថាការផ្លាស់ប្ដូរការកំណត់បទចោទអនុលោមតាមបទបញ្ញានោះ មិនបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទេ)។

[៨៧៧] *ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga Dyilo សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក Lubanga Dyilo និងរដ្ឋអាជ្ញា *តទល់*នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ដែលមានចំណងជើងថា "សេចក្ដីសម្រេចស្ដីពីការជូនដំណឹងដល់ភាគីនិងអ្នកចូលរួមនានាអំពីការកំណត់បទចោទដែលអាចនឹងផ្លាស់ប្ដូរ អនុលោមតាមបទបញ្ញា៥៥(២) នៃបទបញ្ញារបស់តុលាការ" អង្គជំនុំជម្រះតុលាការកំពូល ICC (ICC-01/04-01/06 OA 15 OA 16) ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៨៥-៨៧។

[៨៧៨] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៨-៩ ។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ទំព័រ៤៥ ("ដូចដែលយើងបានបញ្ជាក់ពីខាងដើមនៃដំណើរការនោះ យើងជំរុញឲ្យតុលាការនេះពិចារណា ហើយនឹងអនុវត្តនូវទ្រឹស្ដីសហឧក្រិដ្ឋរួម ឬហៅថា *JCE* ចំពោះអង្គហេតុនៃរឿងនេះ")។ "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" E73។ "សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាដោយមានឧបសម្ព័ន្ធពី ១-៥" E159/9 (ដាក់ជាឯកសារសម្ងាត់) ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៣២៣-៣៣៤។ សូមមើលផងដែរផ្នែក ២.៧.១.៣.១ ។

ប្រភេទ និងគោលបំណងនៃសហឧក្រិដ្ឋកម្មរួម រយៈពេលដែលសហឧក្រិដ្ឋកម្មរួមមានអត្ថិភាព និង អត្តសញ្ញាណនៃបុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងសហឧក្រិដ្ឋកម្មរួម[៨៧៩]។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ បន្ទាប់ពីទទួលបានសំណើរបស់ ក.ស.ព ទាក់ទងនឹង JCE អង្គជំនុំជម្រះបានជូនដំណឹងដល់ជនជាប់ចោទអំពីការអនុវត្តសហឧក្រិដ្ឋកម្មរួម ដែលជាបញ្ហាកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះនៅក្នុងសាលក្រមរបស់ខ្លួន[៨៨០]។ ជនជាប់ចោទត្រូវបានផ្ដល់នូវឱកាសឱ្យឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព ទាក់ទងនឹង JCE និងបានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

---

[៨៧៩] ទាក់ទងទៅនឹងប្រភេទ គោលបំណង និងពេលវេលា *សូមមើល* "សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាដោយមានឧបសម្ព័ន្ធទី ១-៥" ឯកសារ E159/9 កថាខណ្ឌ ៣៣១ ("ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបានបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានពណ៌នាថាជាអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ សហឧក្រិដ្ឋកម្មរួមបានមានអត្ថិភាពនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ នៅពេល សុន សេន បានណែនាំឱ្យ អ៊ិន លន *ហៅ* ណាត និងជនជាប់ចោទឱ្យបង្កើតមន្ទីរស២១។ សហឧក្រិដ្ឋកម្មរួមបានកើតឡើងយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ និងមន្ទីរស២១ ត្រូវបានគេបោះបង់ចោល។ គោលបំណងនៃសហឧក្រិដ្ឋកម្មរួមគឺដើម្បីចាប់ខ្លួន ឃុំខ្លួន ធ្វើបាប សួរចម្លើយ ធ្វើទារុណកម្ម និងប្រហារជីវិត "ខ្មាំង" របស់កម្ពុជាប្រជាធិបតេយ្យ ជាលក្ខណៈប្រព័ន្ធដោយប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានពិពណ៌នានៅក្នុងសេចក្ដីសន្និដ្ឋាននេះ។ ប្រព័ន្ធនៃការបង្ក្រាបដែលត្រូវបានគេរៀបចំមួយ បានកើតឡើងមាននៅមន្ទីរស២១ ពេញរយៈកាលទាំងមូលនៃសហឧក្រិដ្ឋកម្មរួម។ ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅមន្ទីរស២១ គឺសុទ្ធតែស្ថិតនៅក្នុងគោលបំណងនៃសហឧក្រិដ្ឋកម្មរួមនេះ"។ *សូមមើលផងដែរ* "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" ឯកសារ E73 កថាខណ្ឌ២៤។ "វិធាន ៦៦ ដីកាសន្និដ្ឋានស្ដាពរទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ 'ឌុច'" ឯកសារ D96 (ដាក់ជាឯកសារសម្ងាត់) ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ២៥០។ ទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកដែលជាប់ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម *សូមមើល* "សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាដោយមានឧបសម្ព័ន្ធទី ១-៥" ឯកសារ E159/9 កថាខណ្ឌ៣៣២ ("ជនជាប់ចោទបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ពេញអត្ថិភាពទាំងមូលរបស់វាជាមួយនឹងអ្នកផ្សេងៗទៀត ដែលបានចូលរួមសម្រាប់រយៈកាលផ្សេងៗគ្នា រួមទាំង ណាត អតីតលេខាមន្ទីរស-២១ផង និងសមាជិកដទៃទៀតរបស់គណៈកម្មាធិការមន្ទីរស-២១ ពោលគឺ ឃឹម វ៉ាត់ ហៅ ហោ និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ព្រមទាំងអ្នកក្រោមបង្គាប់របស់ពួកគាត់")។ *សូមមើលផងដែរ* "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" ឯកសារ E73 កថាខណ្ឌ២៥។ វិធាន ៦៦ ដីកាសន្និដ្ឋានស្ដាពរទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ 'ឌុច'" ឯកសារ D96 កថាខណ្ឌ២៥១។

[៨៨០] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៧-៨។

៥០២. អង្គជំនុំជម្រះយល់ឃើញថា សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ត្រូវបានដាក់នៅក្នុងពេលវេលាសមស្រប និងមានភាពពាក់ព័ន្ធ ហើយមានការចង្អុលបង្ហាញយ៉ាងច្បាស់លាស់។ មិនតែប៉ុណ្ណោះ អង្គជំនុំជម្រះបដិសេធអំណះអំណាងរបស់ជនជាប់ចោទនៅក្នុងចម្លើយ-តបរបស់គាត់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមដែលថា អង្គជំនុំជម្រះមានកាតព្វកិច្ចកំណត់អំពីការអនុវត្តសហឧក្រិដ្ឋកម្មរួមមុនការពិភាក្សាសម្រេចរបស់ខ្លួន និងត្រូវផ្តល់ឱកាសបន្ថែមទៀតដល់ជនជាប់ចោទដើម្បីឱ្យគាត់ធ្វើការឆ្លើយតបទៅនឹងការសម្រេច ដែលត្រូវបានយល់ស្របរួចហើយនោះ[៨៨១]។ ជនជាប់-ចោទបានទទួលដំណឹងជាច្រើនដង និងមានពេលវេលាគ្រប់គ្រាប់ ដើម្បីឆ្លើយតបទៅនឹងលទ្ធភាពជាក់-លាក់ដែលថា សហឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ជាប្រព័ន្ធរបស់វា អាចត្រូវបានយកមកអនុវត្តចំពោះបទចោទប្រឆាំងរូបគាត់។ សហមេធាវីការពារក្តីរបស់ជនជាប់ចោទ ក៏បានបង្ហាញអំពីការដឹងរបស់ខ្លួនថា អង្គជំនុំជម្រះអាចអនុវត្តសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណើរការនីតិវិធីរឿងក្តីនេះ[៨៨២]។

៥០៣. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំ-ជម្រះដោយយុត្តិធម៌ មិនត្រូវបានរំលោភបំពាននោះទេ ទោះបីជាមានការផ្លាស់ប្តូរបទចោទក៏ដោយ។

### ២.៧.១.៣.៣ ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក

#### ២.៧.១.៣.៣.១ សញ្ញាណនៃសហឧក្រិដ្ឋកម្មរួម

---

[៨៨១] *សូមមើល* “ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឱ្យមានការអនុវត្តទៅលើរឿងក្តី នូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម” E73/2 ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ ៣២-៣៩។

[៨៨២] ប្រតិចារិក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ ៦៥ (“ហើយមួយទៀត លោកព្រះរាជអាជ្ញាអន្តរជាតិ លោក Robert Petit ដែលថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគួរតែយកមកអនុវត្តនៅទីនេះ យកមកអនុវត្តនៅ មន្ទីរស២១។ ខ្ញុំអត់មានប្រកែកទេ អនុវត្តចុះ ក៏ប៉ុន្តែត្រូវអនុវត្តទៅគុក ១៩៥ ទៀត”)។ ប្រតិចារិក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ ១១ (លើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះគួរព្រមានដល់សាក្សីថា ពួកគេអាចមានការទទួលខុសត្រូវ ជាអ្នកចូលរួមជាមួយជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម) (សវនាការសម្ងាត់)។

៥០៤. សញ្ញាណនៃ "សហឧក្រិដ្ឋកម្មរួម" បានកើតមានឡើងតាមរយៈយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ICTY ដែលបានរកឃើញថា ជនជាប់ចោទអាចត្រូវបានសម្រេចឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ "ការប្រព្រឹត្ត" បទឧក្រិដ្ឋមួយតាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម[៨៨៣]។ ទោះបីជាយ៉ាងណាក៏ដោយ សហឧក្រិដ្ឋកម្មរួមមិនមែនជាការបង្កើតថ្មីរបស់តុលាការ ICTY ឡើយ[៨៨៤]។ ដូចដែលបានកត់សម្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូល ICTY ទស្សនាទានច្បាប់ជាមូលដ្ឋានដែលសហឧក្រិដ្ឋកម្មរួមផ្អែកលើនោះ អាចត្រូវបានរកឃើញនៅក្នុងឯកសារនានា ឬសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌ Nuremberg និងមាននៅក្នុងទម្រង់នានានៃប្រព័ន្ធច្បាប់ជាតិជាច្រើនទៀត[៨៨៥]។

៥០៥. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះការចូលរួមក្នុងផែនការ ឬគោលបំណងឧក្រិដ្ឋកម្មរួម មានចែងនៅក្នុងមាត្រា៦ នៃធម្មនុញ្ញ Nuremberg និងនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងផងដែរ[៨៨៦]។ យុត្តិសាស្ត្រជាបន្តបន្ទាប់របស់តុលាការព្រហ្មទណ្ឌ Nuremberg រួមទាំងយុត្តិសាស្ត្ររបស់តុលាការជាតិកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមបានបញ្ជាក់ថា ការចូលរួមបែបនេះអាចជាមូលដ្ឋានចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល[៨៨៧]។ ជាពិសេស យុត្តិសាស្ត្រទាំងនេះបានកំណត់

---

[៨៨៣] *ជាទូទៅ សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៥-២៣៤។

[៨៨៤] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ៥៤ (មតិយោបល់ដាច់ដោយឡែកពីគ្នារបស់ចៅក្រម Shahabuddeen)។

[៨៨៥] *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩៥-២២០, ២២៤-២២៥។

[៨៨៦] *សូមមើល* មាត្រា ៦ នៃធម្មនុញ្ញ Nuremberg (ដែលចែងថា "អ្នកដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និងអ្នកសមគំនិតដែលចូលរួមក្នុងការបង្កើត ឬការអនុវត្តផែនការរួម ឬការសមគំនិតដើម្បីប្រព្រឹត្ត [ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និង/ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ ដែលត្រូវបានអនុវត្តដោយបុគ្គលណាមួយក្នុងការអនុវត្តផែនការបែបនេះ"។ *សូមមើលផងដែរ* មាត្រា២ នៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ។

[៨៨៧] *សូមមើល ឧទាហរណ៍ ការជំនុំជម្រះ Otto Sandrock អ្នកបីនាក់ផ្សេងទៀត (រឿងក្តី Almelo ) ចុះថ្ងៃទី២៤-២៦ ខែវិច្ឆិកា ឆ្នាំ១៩៤៥ របាយការណ៍ច្បាប់អំពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (ឆ្នាំ១៩៤៧) លេខ I ទំព័រ ៣៥។ ផងដែរសូម*

ពិរុទ្ធភាពដោយផ្អែកលើការចូលរួមជាបុគ្គលនៅក្នុងគោលបំណង ឬផែនការឧក្រិដ្ឋកម្មរួមមួយ ដែលត្រូវបានប្រព្រឹត្តនៅក្នុងជំរំប្រមូលផ្តុំ។ ដូចដែលបានកត់សម្គាល់ទាក់ទងទៅនឹងរឿងក្តីជំរំប្រមូលផ្តុំ *Dachau* ថា៖

> ដូច្នេះ វាហាក់ដូចជាអ្វីដែលជាចំណុចសំខាន់បំផុតនៅក្នុងរឿងក្តីទាំងមូលនេះ គឺថានៅក្នុងជំរំប្រមូលផ្តុំនោះមានប្រព័ន្ធទូទៅមួយដែលមានលក្ខណៈព្រៃផ្សៃ និងការសម្លាប់អ្នកទោស (ភាគច្រើនជាប្រជាជនរបស់សម្ព័ន្ធមិត្ត) ហើយប្រព័ន្ធនេះត្រូវបានអនុវត្តដោយ មានការដឹងឮពីជនជាប់ចោទ និងដោយមានការចូលរួមយ៉ាងសកម្ម ព្រោះជនជាប់ចោទគឺជាបុគ្គលិកនៅទីនោះ។ ហេតុដូចនេះ ការសម្រេចរបស់តុលាការលើអំពើបែបនេះ បង្កើតបានជាគោលការណ៍ "ការប្រព្រឹត្តិអនុលោមតាមផែនការរួម ដើម្បីរំលោភច្បាប់នានា និងការធ្វើសង្គ្រាម"។ បុគ្គលគ្រប់រូបដែលបានចូលរួមនៅក្នុងផែនការរួមបែបនេះ ត្រូវសម្រេចឱ្យជាប់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ទោះបីជាប្រភេទ និងកម្រិតនៃការចូលរួមអាចខុសគ្នាក៏ដោយ[៨៨៨]។

---

*មើលការជំនុំជម្រះ* *Franz Schonfeld* *និងអ្នកប្រាំបួននាក់ផ្សេងទៀត ចុះថ្ងៃទី១១-២៦ ខែមិថុនា ឆ្នាំ១៩៤៦ របាយការណ៍ច្បាប់អំពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (ឆ្នាំ១៩៤៩) លេខ XI ទំព័រ ៦៥*។

[៨៨៨] ការជំនុំជម្រះ Martin Gottfried Weiss និងអ្នកសាមសិបប្រាំបួននាក់ផ្សេងទៀត *(រឿងក្តីជំរំប្រមូលផ្តុំ* Dachau ចុះថ្ងៃទី១៥ ខែវិច្ឆិកា-ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៤៥ *របាយការណ៍ច្បាប់អំពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (ឆ្នាំ១៩៤៩) លេខ XI ទំព័រ ១៤*។ *សូមមើលផងដែរ ការជំនុំជម្រះ Josef Kramer និងអ្នកសែសិបបួននាក់ផ្សេងទៀត (រឿងក្តី* Belsen) ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៤៥ *របាយការណ៍ច្បាប់អំពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (ឆ្នាំ១៩៤៧) លេខ II ទំព័រ១២០* (ដែលមេធាវីដែលតែងតាំងសម្រាប់ផលប្រយោជន៍សាធារណៈ (Judge Advocate) បានសង្ខេបដោយយល់ស្របទៅនឹងអំណះអំណាងរបស់រដ្ឋអាជ្ញា មានដូចខាងក្រោម : "ចំពោះអយ្យការ ប្រសិនបើជនជាប់ចោទទាំងអស់ ដែលត្រូវបានគេយកមកបម្រើការជាបុគ្គលិកនៅជំរំ Auschwitz បានដឹងថា មានប្រព័ន្ធមួយ និងដំណើរនៃការប្រព្រឹត្តមួយ ហើយថាក្នុងវិធីតែមួយ ឬវិធីផ្សេងគ្នាក្នុងការគាំទ្រលើកិច្ចព្រមព្រៀងរួមមួយ ដើម្បីគ្រប់គ្រងជំរំតាមរបៀបព្រៃផ្សៃ ជនទាំងនោះមានឈ្មោះថាបានកំពុងចូលរួមក្នុងទង្វើរួម។ ពួកគេបានសុំតុលាការកុំឱ្យចាត់ទុកជាអំពើរបស់បុគ្គល ដោយពួកគេផ្តល់អំណះអំណាងថា អំពើពួកគេធ្វើដោយស្ម័គ្រ ជាក្រុមមួយ ដើម្បីជួយឱ្យប្រព័ន្ធនោះដំណើរការទៅមុខ។ ពួកគេបានស្នើថា ប្រសិនបើតុលាការសម្រេចថា ពួកគេកំពុងធ្វើដូច្នេះ ពួកគេម្នាក់ៗ និងគ្រប់ៗគ្នា នឹងទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង")។

៥០៦. ដោយផ្អែកមួយផ្នែកធំទៅលើសេចក្តីប្រកាសជាសាធារណៈនានារបស់តុលាការព្រហ្មទណ្ឌ Nuremberg អង្គជំនុំជម្រះតុលាការកំពូល ICTY បានរកឃើញថា ទ្រឹស្តីនៃផែនការ ឬគោលបំណងឧក្រិដ្ឋកម្មរួមមួយត្រូវទទួលស្គាល់ថាជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៨៨៩]។ យុត្តិសាស្ត្ររបស់តុលាការ ICTY ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍ផ្សេងទៀតបានអនុវត្តតាមនោះ បានសម្រេចប្រើពាក្យ "សហឧក្រិដ្ឋកម្មរួម" ដើម្បីពិពណ៌នាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌពិសេសនេះ។ ប្រភេទខុសគ្នានៃសហឧក្រិដ្ឋកម្មរួមចំនួនបី ត្រូវបានកំណត់ច្បាស់លាស់[៨៩០]។

៥០៧. នៅក្នុងប្រភេទទីមួយ ឬ"ទម្រង់មូលដ្ឋាន" នៃសហឧក្រិដ្ឋកម្មរួម សមាជិកទាំងអស់មានចេតនាឧក្រិដ្ឋដូចគ្នា និងប្រព្រឹត្តអនុលោមតាមគោលបំណងរួមមួយ។ ឧទាហរណ៍ ផែនការមួយដែលត្រូវបានបង្កើតឡើងដោយអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមដើម្បីសម្លាប់ នៅពេលដែលពួកគេម្នាក់ៗមានចេតនាក្នុងការសម្លាប់ ទោះបីជាអ្នកចូលរួមម្នាក់ៗអាចអនុវត្តតួនាទីខុសគ្នាក៏ដោយ។ ប្រភេទទីពីរនៃសហឧក្រិដ្ឋកម្មរួម "ទម្រង់ជាប្រព័ន្ធ" គឺជាទម្រង់ខុសគ្នាពីទម្រង់មូលដ្ឋាន ដែលត្រូវបានកំណត់លក្ខណៈពិសេស តាមរយៈអត្ថិភាពនៃប្រព័ន្ធធ្វើបាបដែលមានការរៀបចំ។ ឧទាហរណ៍ ការសម្លាប់រង្គាល ឬជំរំប្រមូលផ្តុំដែលអ្នកទោសត្រូវបានគេសម្លាប់ ឬត្រូវបានធ្វើបាប អនុលោមតាមសហឧក្រិដ្ឋកម្មរួម។ ប្រភេទទីបីនៃសហឧក្រិដ្ឋកម្មរួមដែលជា "ទម្រង់ទូលាយ" ពាក់ព័ន្ធករណីមួយចំនួនដែលទាក់ទងនឹងគោលបំណងរួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលចារីម្នាក់ ក្នុងចំណោមចារីជាច្រើនបានប្រព្រឹត្តអំពើមួយ

[៨៨៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៥-២៣៤ (យល់ឃើញថា សញ្ញាណនៃផែនការរួមមានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ យ៉ាងហោចណាស់ចាប់ពីឆ្នាំ១៩៩២)។

[៨៩០] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Milutinović និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើសំណើរបស់ Dragoljub Ojdanić ជំទាស់ទៅនឹងយុត្តាធិការ – សហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-37-AR72) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣៦។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៥៨។ *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-14-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ២០៦។

ដែលស្ថិតនៅខាងក្រៅគោលបំណងរួមដែលតាមរយៈផលវិបាកជាធម្មជាតិ និងតាមរយៈផលវិបាកដែលគេមើលឃើញយ៉ាងច្បាស់ជាមុនធ្វើឲ្យប៉ះពាល់ដល់គោលបំណងរួម[៨៥១]។

៥០៨. យុត្តាធិការរបស់តុលាការបានកំណត់ធាតុផ្សំសត្យានុម័តទូលំទូលាយចំនួនបី សម្រាប់ប្រភេទទាំងបីនៃសហឧក្រិដ្ឋកម្មរួមនេះ[៨៥២]។ ទីមួយ ចាំបាច់ត្រូវមានមនុស្សច្រើន ទោះបីជាពួកគេមិនចាំបាច់ត្រូវបានគេចាត់តាំងជារចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលក៏ដោយ។ វាមានភាពចាំបាច់ក្នុងការចង្អុលបង្ហាញថាមានមនុស្សជាច្រើនបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក៏ប៉ុន្តែ "វាមិនចាំបាច់ក្នុងការកំណត់ឈ្មោះរបស់បុគ្គលដែលពាក់ព័ន្ធម្នាក់ៗឡើយ"[៨៥៣]។ ទីពីរ ចាំបាច់ត្រូវមានអត្ថិភាពនៃគោល-បំណងរួមដែលស្មើទៅនឹង ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋដែលអង្គជំនុំជម្រះមានយុត្តាធិការ។ ការបង្កើត ឬការរៀបចំពីមុនៗដើម្បីគោលបំណងនេះគឺមិនមែនជាការចាំបាច់នោះទេ។ វាអាចកើតមានឡើងដោយឥតព្រាងទុកមុន និងអាចត្រូវបានទាញសេចក្តីសន្និដ្ឋានពីអង្គហេតុ[៨៥៤]។ ទីបី ចាំបាច់ត្រូវមានការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួម។ ការចូលរួមនេះមិនចាំបាច់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ណាមួយឡើយ ប៉ុន្តែអាចធ្វើឡើងក្នុងទម្រង់ជាការជួយ ឬរួមចំណែកដល់ការអនុវត្តគោលបំណងរួមនោះ[៨៥៥]។ ការរួមចំណែករបស់ជនជាប់ចោទមិនមែនជាលក្ខខណ្ឌចាំបាច់ ឬជាសារធាតុ

[៨៥១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ៩៧-៩៩។

[៨៥២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៣៦៤។

[៨៥៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។

[៨៥៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៧។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30-1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១១៨ (បញ្ជាក់ថា ទាក់ទិនទៅនឹងទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម វាមិនចាំបាច់លើកនូវអំណះអំណាងឡើយទាក់ទងទៅនឹងឧក្រិដ្ឋកម្មនីមួយៗ ដែលត្រូវបានប្រព្រឹត្តដោយមានគោលបំណងរួម)។

[៨៥៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ១០០។

នោះទេ ប៉ុន្តែយ៉ាងហោចណាស់ការរួមចំណែកនេះគួរតែជាផ្នែកមួយ ដ៏សំខាន់ចំពោះបទឧក្រិដ្ឋដែលជននោះត្រូវបានរកឃើញថាមានការទទួលខុសត្រូវ[៨៥៦]។

៥០៩. ទោះជាយ៉ាងនេះក្តី ប្រភេទទាំងបីនៃសហឧក្រិដ្ឋកម្មរួមមានធាតុផ្សំអត្តនោម័តរបស់វាខុសគ្នា។ ក្រោមទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ជនជាប់ចោទត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ហើយសហចារីទាំងអស់ត្រូវតែមានចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនេះផងដែរ។ ទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមដែលមានទម្រង់ខុសគ្នាពីទម្រង់មូលដ្ឋាន ប៉ុន្តែពាក់ព័ន្ធជាពិសេសនឹងប្រព័ន្ធធ្វើបាបដែលត្រូវបានគេព្រមព្រៀងជារួម (ឧទាហរណ៍ ការសម្លាប់រង្គាល ឬជំរំប្រមូលផ្តុំ) តម្រូវថា ជនជាប់ចោទបានដឹងអំពីចរិតលក្ខណៈនៃប្រព័ន្ធ និងមានចេតនាជួយជ្រោមជ្រែង ប្រព័ន្ធធ្វើបាបជារួមនេះ[៨៥៧]។ ចំពោះទម្រង់ទូលាយពាក់ព័ន្ធនឹងអំពើទាំងឡាយដែលជាផលវិបាកជាធម្មជាតិ និងផលវិបាកដែលគេអាចមើលឃើញយ៉ាងច្បាស់ជាមុននៃផែនការរួម ទោះបីជាអំពើនោះស្ថិតនៅខាងក្រៅផែនការរួមដែលជនជាប់ចោទមានចេតនារួមក៏ដោយ។ នៅចំណុចនេះ ជនជាប់ចោទត្រូវតែដឹងថា បទឧក្រិដ្ឋនៅខាងក្រៅផែនការរួមគឺជាផលវិបាកជាធម្មជាតិ និងអាចរំពឹងទុកជាមុនបាននៃផែនការ និងប្រាកដជាបានស្ម័គ្រចិត្តទទួលយកហានិភ័យនៃបទឧក្រិដ្ឋ[៨៥៨]។

[៨៥៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២១៥។

[៨៥៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ១០១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-30-1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១១៨ (បញ្ជាក់ថា ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជា ការធ្វើទុក្ខបុកម្នេញ ជនជាប់ចោទត្រូវមានចេតនារើសអើងផងដែរ)។

[៨៥៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ១០១។

00573626



៥១០. លើសពីនេះទៀត ប្រព័ន្ធច្បាប់ជាតិមួយចំនួន បានរក្សាគោលការណ៍ច្បាប់ ដែលជាទូទៅស្រដៀងគ្នាទៅនឹងគោលការណ៍ច្បាប់នៃសហឧក្រិដ្ឋកម្មរួម[៤៩៩]។ ជាពិសេស មាត្រា៨២ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ បញ្ជាក់អំពីការរួមប្រព្រឹត្តិថាជាទម្រង់មួយនៃការទទួលខុសត្រូវក្រោមចំណងជើង "ការចូលរួមដោយផ្ទាល់"។ មាត្រា៨២ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏បញ្ជាក់ទៀតដែរថាជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្មដោយផ្ទាល់ក្តី ដោយប្រយោលក្តីត្រូវមានទោសដូចជាអាទិចារី[៥០០]។ នៅពេលដែលមិនមានយុត្តិសាស្ត្ររបស់តុលាការកម្ពុជាទាក់ទងនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ យុត្តិសាស្ត្ររបស់តុលាការបារាំងក៏មានសារៈប្រយោជន៍ផងដែរ ដោយសារតែក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ស្រដៀងគ្នានឹងក្រមព្រហ្មទណ្ឌបារាំង។ យុត្តិសាស្ត្ររបស់តុលាការបារាំង ដែលពាក់ព័ន្ធបង្ហាញការយល់ដឹងដ៏ទូលំទូលាយអំពីការរួមប្រព្រឹត្ត (co-authorship or co-perpetration) ដែលជាន់គ្នាដោយអន្លើជាមួយនឹងសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម[៥០១]។ អង្គជំនុំជម្រះ កត់សម្គាល់ថា ការយោងទៅលើនីតិកម្មជាតិ និងយុត្តិសាស្ត្ររបស់តុលាការ គឺគ្រាន់តែបង្ហាញថា សញ្ញាណនៃសហឧក្រិដ្ឋកម្មរួម (ឬគោលបំណងរួម) ដែលត្រូវបានតម្កល់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានមូលដ្ឋាននៅក្នុងប្រព័ន្ធច្បាប់ជាតិជាច្រើន ដែលក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ។ ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់យ៉ាងត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងបញ្ហាដាច់ដោយឡែកមួយថា ទោះបីជាមានភាពស្រដៀងគ្នារវាងការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (ទម្រង់ មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ) និងការរួមប្រព្រឹត្តផ្អែកតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ក៏ដោយ ក៏សញ្ញាណទាំងពីរនេះគឺមិនដូចគ្នានោះទេ។ ទោះបីជាសញ្ញាណទាំងពីរ តម្រូវឱ្យអ្នកចូលរួមមានចេតនារួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ក៏ "ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម បើទោះជាការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមត្រូវតែជាការចូលរួមជាក់ស្តែងក៏ដោយ វាហាក់ដូចជាបញ្ចូលស្ថានភាព ដែលជនជាប់ចោទអាចស្ថិតនៅកាន់តែឆ្ងាយ

---

[៤៩៩] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៤-២២៥ (ការស្ទង់មតិអំពីប្រព័ន្ធច្បាប់ជាតិចំពោះគោលការណ៍ច្បាប់មួយចំនួន ដែលជាន់គ្នាជាមួយនឹងសហឧក្រិដ្ឋកម្មរួម)។

[៥០០] មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ *សូមមើលផងដែរ* មាត្រា២៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[៥០១] *សូមមើល ឧទាហរណ៍* Code Pénal (2009, 106th ed., Dalloz) មាត្រា ១២១-៧ កថាខណ្ឌ ១០ ទំព័រ ១២២ (យោងទៅលើយុត្តិសាស្ត្របារាំងចាប់ពីឆ្នាំ១៩៧៤)។

ពីការប្រព្រឹត្តិជាក់ស្តែងនៃអំពើពិរុទ្ធនៃបទល្មើស ជាងការចូលរួមផ្ទាល់ដែលតម្រូវតាមច្បាប់ជាតិ[៥០២]។ ជាចុងក្រោយ សហឧក្រិដ្ឋកម្មរួមដែលត្រូវបានអនុវត្តដោយអង្គជំនុំជម្រះនេះ មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមែនច្បាប់ជាតិទេ។

២.៧.១.៣.៣.២ ការអនុវត្តផ្អែកតាមមាត្រា២៩ ថ្មី នៃ ច្បាប់ អ.វ.ត.ក

៥១១. មាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសញ្ញាណនៃសហ-ឧក្រិដ្ឋកម្មរួមថាជាទម្រង់នៃការទទួលខុសត្រូវឡើយ។ ទោះបីជាយ៉ាងណាក៏ដោយពាក្យពេចន៍នៃមាត្រា២៩ថ្មីនៃច្បាប់ អ.វ.ត.ក ឆ្លុះបញ្ចាំងពីទម្រង់នៃការទទួលខុសត្រូវនៃលក្ខន្តិកៈរបស់តុលាការ ICTY[៥០៣]។ គួរកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការ ICTY បានសម្រេចថា ពាក្យ "បានប្រព្រឹត្ត" នៅក្នុងមាត្រា៧(១) នៃលក្ខន្តិកៈរបស់តុលាការនេះ បានរួមបញ្ចូលយ៉ាងច្បាស់នូវការចូលរួមនៅក្នុងសហ-ឧក្រិដ្ឋកម្មរួម[៥០៤]។ អង្គជំនុំជម្រះរបស់តុលាការ ICTR និងតុលាការ SCSL បានបង្ហាញសំអាងហេតុស្រដៀងគ្នាថា សហឧក្រិដ្ឋកម្មរួមត្រូវបានបញ្ចូលជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់លក្ខន្តិកៈ

---

[៥០២] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៣៧) "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" D97/17/6 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ៤១។

[៥០៣] *សូមមើល* មាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈតុលាការ ICTY ("ជនណាម្នាក់ដែល បានធ្វើផែនការ បានបញ្ឆេះបញ្ចូល បានបញ្ជា បានប្រព្រឹត្ត ឬបើពុំដូច្នោះទេ បានជួយនិងជំរុញនៅក្នុងការធ្វើផែនការ ការរៀបចំ ឬការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ យោងតាមមាត្រា២ ដល់មាត្រា៥ នៃច្បាប់លក្ខន្តិកៈបច្ចុប្បន្ន ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋនោះ")។ ផងដែរ សូមមើល មាត្រា ៦(១) នៃច្បាប់លក្ខន្តិកៈតុលាការ ICTR និងច្បាប់លក្ខន្តិកៈតុលាការ SCSL។

[៥០៤] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩០។

របស់តុលាការទាំងនេះ[៥០៥]។ អង្គជំនុំជម្រះពិចារណាថា សញ្ញាណនៃការប្រព្រឹត្តិតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម មានចែងនៅក្នុងមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក[៥០៦]។

៥១២. ដោយពិចារណាអំពីធម្មនុញ្ញ Nuremberg ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលត្រូវបានយកមកពិភាក្សាបន្តបន្ទាប់ខាងលើ អង្គជំនុំជម្រះពិចារណាបន្ថែមថា ទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម ព្រមជាមួយនឹងទម្រង់មូលដ្ឋានដែលជាទម្រង់ដើម គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[៥០៧]។ ដោយពិចារណាពីឋានៈជាលក្ខណៈទំនៀមទម្លាប់នៃសហឧក្រិដ្ឋកម្មរួម (ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ) ចាប់តាំងពីតុលាការព្រហ្មទណ្ឌ Nuremberg និងភាពច្បាស់លាស់នៃទស្សនទានច្បាប់កម្ពុជាទាក់ទងនឹងការចូលរួមប្រព្រឹត្ត ដែលយកមកអនុវត្តក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋត្រូវបានបំពេញ (ផ្នែក ១.៥)។

៥១៣. អង្គជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងអំឡុងសវនាការបឋមថាពួកគាត់នឹងផ្អែកលើទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ[៥០៨]។ លើសពីនេះ

---

[៥០៥] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Gacumbitsi សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ១៥៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-14-T) ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ២០៨។

[៥០៦] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៣៧) "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" D97/17/6 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៤៩។

[៥០៧] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៣៧) "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" D97/17/6 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៦៩។ *សូមមើលផងដែរ* កថាខណ្ឌ៧១ (ទាក់ទងនឹងភាពស្រដៀងគ្នារវាងទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ)។

[៥០៨] *សូមមើល* ប្រតិចារិក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៨-៩ (សំដៅតែទៅលើទម្រង់ពីរដំបូងនៃសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ)។ ទោះបីជាយ៉ាងណា *សូមមើល* "សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យ អនុវត្តសហឧក្រិដ្ឋកម្មរួម" E73 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ (លើកអំណះអំណាងសុំឱ្យមានការ អនុវត្តទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួម)។

00573629



ទៀត នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និងនៅក្នុងដីកាសន្និដ្ឋានស្ថាពរផ្អែកតាមវិធាន៦៦ សហព្រះរាជអាជ្ញាគ្រាន់តែស្នើសុំឱ្យអនុវត្តទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមជាជម្រើសតែប៉ុណ្ណោះ[៩០៩]។ ដូច្នេះអង្គជំនុំជម្រះពិចារណាថា អង្គជំនុំជម្រះមិនចាំបាច់ប្រកាសជាទូទៅ ស្ដីពីឋានៈទំនៀមទម្លាប់នៃទម្រង់ទូលាយ ដែលជាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ។

## ២.៧.១.៤ សំអាងហេតុទាក់ទងនឹងការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម

៥១៤. អង្គជំនុំជម្រះលើកឡើងនូវសំអាងហេតុជាច្រើន ដែលទាក់ទងនឹងលក្ខណៈឧក្រិដ្ឋនៃប្រព័ន្ធគ្រប់-គ្រងមន្ទីរស២១ដោយជនជាប់ចោទ ដែលសំអាងហេតុទាំងនេះបង្ហាញហេតុផលយ៉ាងច្បាស់អំពីទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះយល់ឃើញថា ក្រោយពីកិច្ចប្រជុំជាមួយ សុន សេន នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ជនជាប់ចោទបានជួយជ្រោមជ្រែងក្នុងការបង្កើតមន្ទីរស២១ ជាមួយ អ៊ិន លន ហៅ ណាត ដែលជាប្រធានកាលពីដំបូង (ផ្នែក ២.៣.៣)។ ក្នុងនាមជាប្រធាន និងជាលេខានៃមន្ទីរស២១ ជនជាប់ចោទបានបន្តធ្វើឱ្យកាន់តែប្រសើរ និងគ្រប់គ្រងប្រតិបត្តិការរបស់មន្ទីរស២១ ដោយមានជំនួយពីអនុលេខា និងសមាជិកនៃគណៈកម្មាធិការមន្ទីរស២១ គឺ ឃឹម វ៉ាក ហៅ ហ៊ី និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ រហូតដល់ពេលបោះបង់ចោលមន្ទីរស២១ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ (ផ្នែក ២.៣.៣.៤)។ ជនជាប់ចោទបានប្រព្រឹត្តអំពើនានាជាមួយបុគ្គលទាំងនេះ និងតាមរយៈអ្នកក្រោមបង្គាប់របស់គាត់ដើម្បីប្រតិបត្តិការមន្ទីរស២១ (ទួលស្លែង) ដែលត្រូវបានគេចាត់ទុកថាជាកន្លែងឃុំខ្លួន សួរចម្លើយ និងសម្លាប់ដោយខុសច្បាប់ចំពោះជនទាំងឡាយដែលគេយល់ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងជនជាតិខ្មែរ និងជនបរទេស។ ប្រព័ន្ធសហការរួមនៃការធ្វើបាប និងការធ្វើទារុណកម្ម ត្រូវបានអនុវត្តដោយចេតនាដើម្បីបង្ក្រាបអ្នកជាប់ឃុំ និងទាញយកចម្លើយសារភាពពីអ្នកជាប់ឃុំក្នុងពេលសួរចម្លើយ (ផ្នែក ២.៣ និង ២.៤)។ ស២៤ ត្រូវបានប្រើប្រាស់ជាកន្លែងបន្ថែមសម្រាប់ឱ្យអ្នកជាប់ឃុំធ្វើពលកម្មដោយបង្ខំ ដោយសារអ្នកទាំងនោះត្រូវបានបក្សកុម្មុយនីស្តកម្ពុជា

---

[៩០៩] "សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ដោយមានឧបសម្ព័ន្ធពី ១-៥" E159/9 ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៣៣៤។ *សូមមើលផងដែរ* "វិធាន ៦៦ ដីកាសន្និដ្ឋានស្ថាពរ ទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" D96 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ២៥៣។

ចាត់ទុកថាជាជនសង្ស័យ (ផ្នែក ២.៣.៣.៧ និង ២.៤.២.១)។ ក្នុងនាមជាអនុប្រធាន និងក្រោយមកជាប្រធាន និងជាលេខានៃមន្ទីរស២១ ជនជាប់ចោទជាប់ពាក់ព័ន្ធយ៉ាងជ្រៅនៅក្នុងប្រព័ន្ធឧក្រិដ្ឋកម្មនេះ និងបានចូលរួមយ៉ាងពេញលេញក្នុងការអនុវត្ត និងធ្វើឱ្យប្រសើរឡើងនូវមន្ទីរស២១ តាមរយៈការធានានូវការចាប់ខ្លួន និងការឃុំខ្លួនអ្នកជាប់ឃុំសំខាន់ៗមួយចំនួន និងតាមរយៈការការចូលរួមដោយផ្ទាល់របស់គាត់ក្នុងអំឡុងពេលនៃការចាប់ខ្លួនអ្នកជាប់ឃុំសំខាន់ៗមួយចំនួន (ផ្នែក ២.៣.៣.៥.៣)។

៥១៥. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទបានដឹងអំពីលក្ខណៈឧក្រិដ្ឋនៃប្រព័ន្ធគ្រប់គ្រងមន្ទីរស២១ ហើយគាត់បានប្រព្រឹត្តដោយចេតនា ដើម្បីបន្តសម្រេចគោលបំណងឧក្រិដ្ឋរបស់មន្ទីរនេះ។ លើសពីនេះ តាមមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះយល់ឃើញថា ចេតនាជាក់លាក់របស់ជនជាប់ចោទដែលរើសអើងអ្នកជាប់ឃុំនៅមន្ទីរស២១ ដោយផ្អែកលើមូលដ្ឋានថា ពួកគេទាំងនោះត្រូវបានសន្មតថាជាអ្នកប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.៥.៣.១៤.៤)។

៥១៦. ហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា ដោយសារតែជនជាប់ចោទចូលរួមនៅក្នុងទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមនៅមន្ទីរស២១ ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរួមមានបទល្មើសការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូល-ហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវផងដែរចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចជាការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

៥១៧. ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះទម្រង់នៃការទទួលខុសត្រូវបន្ថែម ដូចមានចែងនៅក្នុងមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក មិនបានបង្កើតឱ្យមានពិរុទ្ធភាពបន្ថែមលើឧក្រិដ្ឋកម្មដូចគ្នានោះទេ។ ការរកឃើញនូវការទទួលខុសត្រូវរបស់ជនជាប់ចោទ ដោយផ្អែកតាមទម្រង់បន្ថែមទាំងនេះ អាចជួយអង្គ-

ជំនុំជម្រះក្នុងការផ្តន្ទាទោសជនជាប់ចោទចំពោះការចូលរួមពេញលេញចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវទទួលខុសត្រូវ[៥១០]។

២.៧.២ ការរៀបចំផែនការ

៥១៨. ការរៀបចំផែនការតម្រូវថាមានបុគ្គលម្នាក់ ឬច្រើននាក់ បានរៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយក្រោយមកការប្រព្រឹត្តិអំពើទាំងនោះ បង្កើតឱ្យមានឧក្រិដ្ឋកម្មមួយឬច្រើន[៥១១]។ ជាចាំបាច់ដែលគេត្រូវតែបង្ហាញឱ្យឃើញថាផែនការគឺជាកត្តារួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅប្រព្រឹត្តឧក្រិដ្ឋកម្ម[៥១២]។

៥១៩. ជនជាប់ចោទត្រូវតែមានចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពសំខាន់ដែលថាឧក្រិដ្ឋកម្មទំនងនឹងត្រូវបានប្រព្រឹត្ត នៅពេលអនុវត្តផែនការនោះ[៥១៣]។

២.៧.៣ សំអាងហេតុទាក់ទងនឹងការរៀបចំផែនការ

៥២០. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថាៈ

---

[៥១០] *ប្រៀបធៀប រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kamuhanda សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-54A-A) ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ មតិដាច់ដោយឡែក និងមតិយោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ៤០៥-៤១៦។

[៥១១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៦។

[៥១២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-15-A) ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ៦៨៧ ១១៧០។

[៥១៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៣១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៦៨។

00573632



> ១៥៩. ឌុច បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំ ឬការដាក់ឱ្យដំណើរការនូវគម្រោងដែលឈានទៅដល់ការបង្កើតមន្ទីរស២១ ដោយដឹងថាសកម្មភាពនៃមន្ទីរនេះនឹងក្លាយជាអំពើឧក្រិដ្ឋ។ ម្យ៉ាងវិញទៀត នៅពេលដែលមន្ទីរនេះបានបង្កើត ឌុច បានរៀបចំផែនការឧក្រិដ្ឋកម្មជាក់លាក់នានា ដែលត្រូវបានប្រព្រឹត្តជាមួយនឹងចេតនាថា ឧក្រិដ្ឋកម្មទាំងនេះត្រូវតែប្រព្រឹត្ត[៥១៤]។

៥២១. ជនជាប់ចោទបានជួយរៀបចំដំណើរការមន្ទីរស២១ តាំងតែពីពេលចាប់ផ្តើម។ គាត់បានបន្តខិតខំធ្វើឱ្យដំណើរការនៅមន្ទីរស២១ កាន់តែមានប្រសិទ្ធភាព តាមរយៈការផ្លាស់ប្តូរទីតាំងមន្ទីរស២១ មកដាក់នៅវិទ្យាល័យពញាយ៉ាត និងបានជ្រើសរើស ជើងឯក សម្រាប់ជាកន្លែងសម្លាប់ (ផ្នែក ២.៣.៣.១ ផ្នែក ២.៣.៣.៤.១ និងផ្នែក ២.៣.៣.៦) ។ អង្គជំនុំជម្រះយល់ឃើញថា ការរៀបចំផែនការរបស់ជនជាប់ចោទ គឺជាកត្តាមួយដែលរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរស២១។ អង្គជំនុំជម្រះយល់ឃើញបន្ថែមថា ជនជាប់ចោទមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ឬយ៉ាងហោចណាស់បានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តដើម្បីអនុវត្តតាមផែនការរបស់ជនជាប់ចោទ។

### ២.៧.៤ ការញុះញង់

៥២២. ការញុះញង់តម្រូវថា បុគ្គលម្នាក់តាមរយៈអំពើសកម្ម ឬអកម្ម ជំរុញបុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[៥១៥]។ ការទទួលខុសត្រូវចំពោះការញុះញង់ អាចជាលទ្ធផលដែលកើតឡើងដោយអំពើស្ងៀមស្ងាត់ ជាលាយលក្ខណ៍អក្សរ ឬដោយទម្រង់អ្វីក៏ដោយរបស់ជនជាប់ចោទ ដោយមិនចាំបាច់តែការនិយាយនោះទេ។ ផ្ទុយពីការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ ការញុះញង់មិនតម្រូវឱ្យជនជាប់ចោទមានអំណាចណាមួយលើចារីទេ។ ដូចគ្នានេះផងដែរ ការញុះញង់តម្រូវឱ្យមានលក្ខខណ្ឌលើសពីការជួយសម្រួលចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលការជួយសម្រួលនេះអាចគ្រប់គ្រាន់សម្រាប់តែ

---

[៥១៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៥៩។

[៥១៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៧។

ការជួយនិងជំរុញ[៥១៦] តែប៉ុណ្ណោះ។ ការញុះញង់ត្រូវតែជាកត្តារួមចំណែកយ៉ាងសំខាន់មួយចំពោះអំពើឧក្រិដ្ឋដែលនឹងត្រូវប្រព្រឹត្ត[៥១៧]។

៥២៣. ក្នុងករណីមួយចំនួន ការខកខានរបស់ថ្នាក់លើម្តងហើយម្តងទៀតក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើចារីចំពោះឧក្រិដ្ឋកម្មអាចមានន័យស្មើនឹងការញុះញង់ឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមផ្សេងទៀត[៥១៨]។

៥២៤. ជនជាប់ចោទត្រូវតែមានចេតនាបង្កហេតុ ឬនាំហេតុឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពសំខាន់ដែលថាឧក្រិដ្ឋកម្មទំនងនឹងត្រូវបានប្រព្រឹត្តដោយសារតែការញុះញង់[៥១៩]។

---

[៥១៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Orić សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-03-68-T) ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០០៦ កថាខណ្ឌ២៧១។

[៥១៧] *រឿងក្តីត រដ្ឋអាជ្ញា តទល់នឹង* Karera សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-01-74-A) ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ៣១៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić និង អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៧។

[៥១៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Hazihasanovic *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-A) ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ៣០ ("អង្គជំនុំជម្រះតុលាការកំពូលគូសបញ្ជាក់ថា ការខកខានរបស់ថ្នាក់លើក្នុងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មដែលថ្នាក់លើបានដឹង ទំនងជាធ្វើឲ្យអ្នកនៅក្រោមបង្គាប់របស់គាត់យល់ឃើញថា ថ្នាក់លើរបស់គាត់ទទួលយកការប្រព្រឹត្តិបែបនោះ ទោះបីជាថ្នាក់លើមិនបានលើកទឹកចិត្តឲ្យប្រព្រឹត្តិអំពើទាំងនោះក្តី ដែលការយល់ឃើញនេះអាចនាំឲ្យមានការកើនឡើងនូវហានីយភ័យនៃការប្រព្រឹត្ត ឧក្រិដ្ឋកម្មថ្មីៗផ្សេងទៀត")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Bagilishema សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTR (ICTR-95-IA-T) ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៥០។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៣១១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Halilovic សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-01-48-T) ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ៩៥-៩៦។

[៥១៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić និង អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៣២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៧១។

## ២.៧.៥ សំអាងហេតុទាក់ទងនឹងការញុះញង់

៥២៥. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៦០. ក្នុងនាមជាអនុប្រធាន ជាប្រធានមន្ទីរស២១ និងក្នុងនាមជាសមាជិកសកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ឌុច បានជំរុញនិងលើកទឹកចិត្តបុគ្គលិកនៅមន្ទីរស២១ ឲ្យប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ដូចបានពិពណ៌នាក្នុងដីកាដំណោះស្រាយនេះ តាមរយៈការណែនាំ ការបង្រៀនជាទ្រឹស្តី និងមាគ៌ានយោបាយរបស់បក្ស និងប្រគល់ជាភារកិច្ចដល់ពួកគេ ក៏ដូចជាតាមរយៈវត្តមានរបស់គាត់នៅកន្លែងកើតហេតុ និងការចូលរួមរបស់គាត់នៅគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការមន្ទីរស២១។ ការដឹកនាំ និងការចូលរួមរបស់ ឌុច គឺពិតជាកត្តាចំបងក្នុងការធ្វើឲ្យមន្ទីរស២១ មានដំណើរការ ហើយបង្ហាញអំពីចេតនាក្នុងការដាក់ឲ្យបុគ្គលិកនៃមន្ទីរនេះ ប្រព្រឹត្តបទឧក្រិដ្ឋដូចបានរៀបរាប់ខាងលើ[៥២០]។

៥២៦. ជនជាប់ចោទបានបង្រៀនទ្រឹស្តីដល់បុគ្គលិកមន្ទីរស២១ រួមទាំងក្មេងជំទង់ៗដែលងាយនឹងធ្វើការអប់រំឲ្យពួកគេក្លាយទៅជាមនុស្សឃោរឃៅ ហើយចាត់ទុកអ្នកជាប់ឃុំទាំងអស់នៅមន្ទីរស២១ ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទៀតនោះគាត់បានទទួលយកក្មេងៗទាំងនោះឲ្យធ្វើជាអ្នកក្រោមបង្គាប់របស់គាត់។ គាត់ក៏បានបណ្តុះបណ្តាលជាក់ស្តែងដល់អ្នកសួរចម្លើយនៅមន្ទីរស២១ ស្តីអំពីការប្រើអំពើហិង្សាទៅលើរូបរាងកាយ និងផ្លូវចិត្តចំពោះអ្នកជាប់ឃុំ (ផ្នែក ២.៣.៣.៥.២)។ អង្គជំនុំជម្រះយល់ឃើញថា ការអប់រំ និងការបណ្តុះបណ្តាលដែលប្រព្រឹត្តដោយជនជាប់ចោទ គឺជាកត្តានានា ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរស២១។ អង្គជំនុំជម្រះយល់ឃើញបន្ថែមថា ជនជាប់ចោទមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំង នេះ ឬយ៉ាងហោចណាស់ជនជាប់ចោទបានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តដោយការញុះញង់របស់គាត់។

[៥២០] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៦០។

## ២.៧.៦ ការបញ្ជា

៥២៧. ការបញ្ជាតម្រូវថាបុគ្គលម្នាក់ក្នុងឋានៈជាអ្នកមានអំណាច បង្គាប់បុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មមួយ[៥២១]។ ទោះបីជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងថ្នាក់លើនឹងអ្នកនៅក្រោមបង្គាប់ជាផ្លូវការរវាងបុគ្គលទាំងពីរ មិនមែនជាលក្ខខណ្ឌចាំបាច់នោះទេ[៥២២]។ បុគ្គលដែលបញ្ជា ត្រូវតែមានអំណាចតាមផ្លូវច្បាប់ ឬតាមអង្គហេតុ ក្នុងការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[៥២៣]។ ការទទួលខុសត្រូវចំពោះការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មអាចកើតមាននៅពេលជនជាប់ចោទចេញបញ្ជា ផ្តល់អំណាច ឬផ្ទេរបញ្ជា ដែលរួមទាំងតាមរយៈអន្តរការី[៥២៤]។ វាគ្មានលក្ខខណ្ឌដែលថាការបញ្ជាត្រូវតែចេញជា

---

[៥២១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kajelijeli* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-98-44A-T) ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ៧៦៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-15-A) ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ១៦៤។

[៥២២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordić *និង* អ្នកផ្សេងទៀតសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៨។ *រឿងក្តី* Semanza *តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-97-20-A) ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៣៦១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៧៣។ [*កត់សម្គាល់ឃើញថា ក.ស.ព បានលើកឡើងដោយកំហុសថា ចំណុចនេះមិនអាចដោះស្រាយបាន ដោយសារមូលហេតុច្បាប់នៅក្នុងកថាខណ្ឌ២៥៤ នៃវិធាន៦៦ ដីកាសន្និដ្ឋានស្ថាពរ*]។

[៥២៣] *រឿងក្តី* Semanza *តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-97-20-A) ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៣៦១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Gacumbitsi សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៨១-១៨២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Limaj *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-03-66-T) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ៥១៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៧៣។

[៥២៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinović សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៨៧។

លាយលក្ខណ៍អក្សរ ឬជាទម្រង់ពិសេសណាមួយនោះទេ ហើយអត្ថិភាពនៃការបញ្ជាក៏អាចនឹងបង្ហាញតាមរយៈភស្តុតាងតាមស្ថានភាពផងដែរ[៥២៥]។ គេត្រូវតែបង្ហាញឱ្យឃើញថា ការចេញបញ្ជាគឺជាកត្តារួមចំណែកយ៉ាងសំខាន់មួយចំពោះអំពើឧក្រិដ្ឋដែលនឹងត្រូវប្រព្រឹត្ត[៥២៦]។

៥២៨. ជនជាប់ចោទត្រូវតែមានចេតនានាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មទំនងនឹងត្រូវបានប្រព្រឹត្តដោយសារតែការអនុវត្តបញ្ជានោះ[៥២៧]។

២.៧.៧ សំអាងហេតុទាក់ទងនឹងការបញ្ជា

៥២៩. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៥៤. ឌុច បានកាន់មុខតំណែងដែលមានអំណាចនៅមន្ទីរស២១ ក្នុងរយៈពេលនៃយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក។ មុខតំណែងនេះអនុញ្ញាតឱ្យ ឌុច បញ្ជាអ្នកនៅក្រោមបង្គាប់ ឱ្យអនុវត្តរាល់ការងារចាំបាច់ពាក់ព័ន្ធនឹងដំណើរការនៃមន្ទីរស២១។ មន្ទីរស២១នេះ ដំណើរការក្នុងលក្ខណៈជាខ្សែសង្វាក់នៃការបញ្ជាដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ ហើយតួនាទីរបស់បុគ្គលិកម្នាក់ៗ ត្រូវបានចែងនិងអនុវត្តយ៉ាងហ្មត់ចត់។
>
> ១៥៥. បញ្ជា និងសេចក្តីណែនាំ ទោះជាពី ឌុច ក្តី ឬពីថ្នាក់លើរបស់គាត់ក្តីត្រូវបានដាក់ចេញ ឬបញ្ជាបន្តជាមួយនឹងចេតនា និងការដឹងយ៉ាងច្បាស់អំពីផលវិបាក ពីបញ្ជានេះ ហើយដោយដឹងថា បញ្ជា ឬសេចក្តីណែនាំទាំងនេះ នឹងត្រូវបានគោរព និងអនុវត្តជាប្រព័ន្ធចាត់តាំង។ បញ្ជានៅមន្ទីរស២១ អាចមានលក្ខណៈច្បាស់លាស់

[៥២៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Kamuhanda* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-54A-A) ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ៧៦។

[៥២៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Milutinović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៨៨។

[៥២៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៤១-៤២។

00573637



ឬស្រពិចស្រពិល ទូទៅ ឬជាក់លាក់ និងអាចបញ្ជូនទៅផ្ទាល់ ឬមិនផ្ទាល់ទៅដល់អ្នកអនុវត្ត។

១៥៦. តាមរយៈរបៀបដែលខ្លួនដឹកនាំនៅស២១ ឌុច បានរួមចំណែកយ៉ាងសំខាន់ដល់ព្រឹត្តិការណ៍នានាដែលបានកើតឡើង ហើយអំពើជាច្រើនទៀតដែលអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្ត អាចត្រូវបានកំណត់បានជាអំពើឧក្រិដ្ឋស្របតាមអត្ថន័យនៃច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក[៥២៨]។

៥៣០. ក្នុងនាមជាអនុប្រធានមន្ទីរស២១ ពីខែតុលា ឆ្នាំ១៩៧៥ ដល់ខែមីនា ឆ្នាំ១៩៧៦ ជនជាប់ចោទបានប្រើអំណាចលើបុគ្គលិករបស់អង្គភាពសួរចម្លើយនៃមន្ទីរស២១(ផ្នែក ២.៣.៣.៣)។ ក្នុងនាមជាប្រធានមន្ទីរស២១ ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ពេលដែលបោះបង់មន្ទីរនេះនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ជនជាប់ចោទគឺពិតជាប្រធានមន្ទីរស២១ និងបានប្រើអំណាចលើបុគ្គលិកទាំងអស់របស់មន្ទីរនេះ (ផ្នែក ២.៣.៣.៤)។

៥៣១. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទបានចេញបញ្ជា បញ្ជូនបញ្ជា ឬផ្សព្វផ្សាយបញ្ជាឱ្យទៅបុគ្គលិកមន្ទីរស២១ ដើម្បីចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់អ្នកជាប់ឃុំ (ផ្នែក ២.៣.៣.៥.៣-២.៣.៣.៥.៥)។ អង្គជំនុំជម្រះយល់ឃើញថា បញ្ជាទាំងនោះគឺជាកត្តាដែលរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស២១។ អង្គជំនុំជម្រះយល់ឃើញបន្ថែមថា ជនជាប់ចោទមានចេតនាឱ្យកើតមាននូវការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ឬយ៉ាងហោចណាស់ ជនជាប់ចោទបានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តដោយសារតែមានការអនុវត្តបញ្ជារបស់គាត់។

### ២.៧.៨ ការជួយនិងជំរុញ

៥៣២. បញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណៅជាភាសាបារាំងនៃមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ប្រដូចពាក្យ“ជួយនិងជំរុញ” ទៅនឹងសញ្ញាណនៃពាក្យ“complicité”(ការសមគំនិត)។

[៥២៨] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៥៤-១៥៦។

ផ្ទុយទៅវិញ សំណៅជាភាសាបារាំងនៃលក្ខន្តិកៈតុលាការ ICTY និង ICTR បានប្រដូចពាក្យ "ជួយនិងជំរុញ" ទៅនឹងពាក្យ "aidé et encouragé"[៥២៩] (ជួយនិងលើកទឹកចិត្ត)។ ដោយពិចារណាឃើញថា បទប្បញ្ញត្តិមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក យកលំនាំតាមបទប្បញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា និងដោយពិចារណាថា មាត្រានេះចេញមកពីសញ្ញាណនៃច្បាប់អន្តរជាតិ អង្គជំនុំជម្រះយល់ឃើញថាពាក្យ "aidé et encouragé" ឆ្លុះបញ្ចាំងកាន់តែច្បាស់អំពីលក្ខណៈទម្រង់នៃការទទួលខុសត្រូវនេះ ជាងសញ្ញាណនៃពាក្យ "complicité" ព្រោះវាអាចគ្របដណ្តប់អំពើកាន់តែទូលាយ[៥៣០]។ អត្ថបទជាភាសាខ្មែរនៃមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក គាំទ្រផងដែរចំពោះការបកស្រាយនេះ[៥៣១] ។

៥៣៣. ការជួយនិងជំរុញ រួមមានការជួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រខាងស្មារតី ដែលមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋរបស់ចារី[៥៣២]។ ទោះបីជាត្រូវបានពិចារណាជារួមនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ពាក្យ "ជួយ" និង ពាក្យ"ជំរុញ" មិនមានន័យដូចគ្នាទេ។ ពាក្យ "ជួយ" ពាក់ព័ន្ធនឹងការផ្តល់ជំនួយ ប៉ុន្តែពាក្យ "ជំរុញ" ពាក់ព័ន្ធនឹង "ការជួយសម្រួលឲ្យប្រព្រឹត្តអំពើណាមួយដោយសារតែ (ការលើកទឹកចិត្ត)"[៥៣៣]។

---

[៥២៩] *សូមមើល* មាត្រា៧(១) នៃលក្ខន្តិកៈតុលាការ ICTY និងមាត្រា៦(១) នៃលក្ខន្តិកៈតុលាការ ICTR។ ភាសាបារាំងមិនមែនជាភាសាផ្លូវការរបស់តុលាការ SCSL។

[៥៣០] ដូចបានបញ្ជាក់នៅក្នុងមាត្រា៨៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ (ដែលនៅក្នុងក្រមនេះ ការជួយនិងការជំរុញ ការញុះញង់ និងការបញ្ជាត្រូវបានចាត់ទុកថាជាទម្រង់នៃបទសមគំនិត ក្នុងចំណោមទម្រង់ផ្សេងទៀត)។

[៥៣១] អត្ថបទជាភាសាខ្មែរ នៃមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ត្រង់ផ្នែកដែលពាក់ព័ន្ធ ប្រសិនបើបកប្រែតាមន័យត្រង់សំដៅទៅលើ ... ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្ម (បានបញ្ជាក់យ៉ាងច្បាស់) ។

[៥៣២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Blaskić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៤៥-៤៦, ៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-2001-64-A) ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៤០។

[៥៣៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៨៩ ជើងទំព័រ១០៧។

៥៣៤. ភស្តុតាងទាក់ទងនឹងផែនការ ឬការព្រមព្រៀងរវាងអ្នកជួយនិងអ្នកជំរុញ ជាមួយនឹងអ្នកប្រព្រឹត្ត មិនតម្រូវឲ្យមាននោះទេ[៥៣៤]។ ជនជាប់ចោទមិនអាចត្រូវបានផ្តន្ទាទោស ចំពោះការជួយនិងជំរុញចំពោះឧក្រិដ្ឋកម្មដែលមិនបានប្រព្រឹត្តនោះទេ។ ផ្ទុយទៅវិញជនជាប់ចោទអាចត្រូវបានផ្តន្ទាទោសចំពោះការជួយនិងជំរុញ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទោះបីជាមិនមានការជំនុំជម្រះ ឬកំណត់អត្តសញ្ញាណរបស់ចារីក៏ដោយ[៥៣៥]។

៥៣៥. ការទទួលខុសត្រូវចំពោះការជួយនិងជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម តម្រូវឲ្យបង្ហាញភស្តុតាងថាជនជាប់ចោទបានដឹងថាឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ហើយដែលឧក្រិដ្ឋកម្មនោះពិតជាបានប្រព្រឹត្តមែន ហើយជនជាប់ចោទបានដឹងថាអំពើរបស់ខ្លួនបានជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ[៥៣៦]។ គេអាចធ្វើការសន្និដ្ឋានអំពីការដឹងនេះដោយផ្អែកលើស្ថានភាពនីមួយៗ[៥៣៧]។ លើសពីនេះ លក្ខខណ្ឌតម្រូវដែលជនជាប់ចោទបានដឹងអំពីចេតនារបស់ចារី ទោះបីជាមិនបានរួមចំណែកឲ្យមានចេតនាទាំងនេះក៏ដោយ ក៏ជនជាប់ចោទត្រូវទទួលខុសត្រូវដូចគ្នាចំពោះចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់ទាំងនោះ ដូចជាការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាដើម[៥៣៨]។

---

[៥៣៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-94-1-A) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ២២៩។

[៥៣៥] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៩២។

[៥៣៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៤៩-៥០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-16-A) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ២៤៣។

[៥៣៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-05-87-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ភាគ I កថាខណ្ឌ៩៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២៨០។

[៥៣៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-02-60-A) ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ១២៧ ("ធាតុផ្សំអត្តនោម័តចាំបាច់នៃការជួយនិងជំរុញ គឺការដឹង ដែលការប្រព្រឹត្តិអំពើនេះ ជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មច្បាស់លាស់នៃចារី"។ នៅក្នុងករណីនៃឧក្រិដ្ឋកម្មដែលមានចេតនាច្បាស់

## ២.៧.៩ សំអាងហេតុទាក់ទងនឹងការជួយនិងជំរុញ

៥៣៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចែងថា៖

> ១៦១. មនុស្សនៅក្រោមបង្គាប់របស់ ឌុច គោរពនិងកោតខ្លាចអំណាចរបស់គាត់ ហើយនៅគ្រប់កម្រិតនៃដំណើរការរបស់មន្ទីរស២១ ឌុច ផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រផ្នែកស្មារតីដល់ពួកគេ។ ការជួយនិងជំរុញនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាដូចបានរៀបរាប់ក្នុងដីកាដំណោះស្រាយនេះ។ ជាងនេះទៅទៀត ឌុច បានដឹងច្បាស់ថា ទង្វើរបស់គាត់នឹងជួយដល់ការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ហើយ ឌុច ក៏បានយល់អំពីធាតុផ្សំសំខាន់ៗ និងដឹងអំពីចេតនារបស់ចារីផងដែរ[៩៣៩]។

៥៣៧. ដោយពិចារណាលើសំអាងហេតុពីមុនរបស់អង្គជំនុំជម្រះ វាច្បាស់ណាស់ដែលថាការជួយជាក់ស្តែង ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតី ដែលជនជាប់ចោទផ្តល់ឲ្យបុគ្គលិករបស់គាត់មានឥទ្ធិពលយ៉ាងខ្លាំងចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរស២១ (ផ្នែក ២.៣.៣.៥)។ អង្គជំនុំជម្រះយល់ឃើញបន្ថែមថា ជនជាប់ចោទបានដឹងថាអំពើរបស់គាត់បានជួយឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។ លើសពីនេះ តាមរយៈការបង្រៀន បុគ្គលិករបស់គាត់ឲ្យចាត់ទុកអ្នកជាប់ឃុំទាំងអស់ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ២.៣.៣.៥.២) ជនជាប់ចោទបានដឹងអំពីចេតនារើសអើងរបស់ចារីនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

## ២.៧.១០ ការទទួលខុសត្រូវរបស់ថ្នាក់លើ

៥៣៨. អនុលោមតាមការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ខ្លួន ធាតុផ្សំចំនួនបីត្រូវតែបំពេញ៖ (ក) ត្រូវតែមានទំនាក់ទំនងរវាង

---

លាស់ដូចជា ការធ្វើទុក្ខបុកម្នេញ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អ្នកជួយនិងអ្នកជំរុញ ត្រូវតែដឹងអំពីចេតនាច្បាស់លាស់របស់ចារី”) (ជើងទំព័រត្រូវបានលុបចោល)។

[៩៣៩] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៦១។

ថ្នាក់លើនឹងអ្នកនៅក្រោមបង្គាប់ រវាងជនជាប់ចោទជាមួយនឹងជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម (ខ) ជនជាប់ចោទត្រូវតែបានដឹង និងមានហេតុផលដឹងថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្តហើយ (គ) ជនជាប់ចោទខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ ខាងក្រោមនេះគឺជាការពិភាក្សាអំពីធាតុផ្សំនីមួយៗ។

៥៣៩. អង្គជំនុំជម្រះកត់សម្គាល់ថា ជនជាប់ចោទអាចនឹងមិនត្រូវបានផ្តន្ទាទោសក្នុងពេលតែមួយចំពោះទម្រង់នៃការទទួលខុសត្រូវ "ផ្ទាល់" ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទីមួយនៃមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក និងការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ[៩៤០]។ លើសពីនេះ នៅពេលទម្រង់នៃការទទួលខុសត្រូវ "ផ្ទាល់" និងការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបង្កើតឡើងទាក់ទងនឹងអំពើដូចគ្នា អង្គជំនុំជម្រះគួរតែផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវ "ផ្ទាល់" តែប៉ុណ្ណោះ ហើយពិចារណាអំពីឋានៈជាថ្នាក់លើរបស់ជនជាប់ចោទជាស្ថានទម្ងន់ទោសក្នុងការផ្តន្ទាទោស[៩៤១]។

---

[៩៤០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៩១-៩២ (យល់ឃើញថា ការផ្តន្ទាទោសក្នុងពេលដំណាលគ្នាចំពោះការទទួលខុសត្រូវជាបុគ្គល និងការទទួលខុសត្រូវរបស់ថ្នាក់លើទាក់ទងនឹងបទចោទដូចគ្នា ដែលផ្អែកលើអង្គហេតុដូចគ្នា ជាការភ័ន្តច្រឡំផ្នែកច្បាប់ដែលធ្វើឱ្យអសុពលភាពសាលក្រមសាលាដំបូង។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-98-44A-A) ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៨១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-16-T) ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ៨០០។

[៩៤១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៩១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-98-44A-A) ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៨២។

### ២.៧.១០.១ ទំនាក់ទំនងរវាងថ្នាក់លើនឹងអ្នកនៅក្រោមបង្គាប់

៥៤០. ការជ្រើសតាំងជាផ្លូវការ ជាមេបញ្ជាការ ឬថ្នាក់លើម្នាក់ មិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ចាប់ផ្ដើមឲ្យទទួលខុសត្រូវរបស់ថ្នាក់លើទេ។ ការទទួលខុសត្រូវរបស់ថ្នាក់លើរបៀបនេះអាចកើតចេញតាមរយៈអំណាចរបស់ថ្នាក់លើទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម[៥៤២] ទោះបីជាតាមរយៈអង្គច្បាប់ក្ដី ឬតាមអង្គហេតុក្ដី។ ដើម្បីបង្ហាញឲ្យឃើញនូវអត្ថិភាពនៃទំនាក់ទំនងរវាងថ្នាក់លើនឹងអ្នកនៅក្រោមបង្គាប់ គេត្រូវតែបង្ហាញឲ្យឃើញថាជនជាប់ចោទមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់[៥៤៣]។ និយាយម្យ៉ាងវិញទៀត ជនជាប់ចោទត្រូវតែមានសមត្ថភាពខាងសម្ភារៈដើម្បីទប់ស្កាត់ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់[៥៤៤]។

៥៤១. កត្តានានាដែលបង្ហាញថា ជនជាប់ចោទមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់រួមមាន៖ ប្រភេទនៃតួនាទីរបស់ជនជាប់ចោទ ដែលរួមមានតួនាទីរបស់បុគ្គលនោះនៅក្នុង

---

[៥៤២] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១៩១-១៩២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-98-44A-A) ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៨៥។

[៥៤៣] *សូមមើល* មាត្រា២៩ នៃច្បាប់ អ.វ.ត.ក (ចែងថា ថ្នាក់លើត្រូវមាន "បញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់") (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-95-1-A-A) ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ កថាខណ្ឌ៦១ (អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់ជាថ្មីថា លក្ខខណ្ឌនៅក្នុងគ្រប់ករណីទាំងអស់ គឺដើម្បីចង់ដឹងថាតើជនជាប់ចោទ បានអនុវត្តការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់របស់ខ្លួនដែរ ឬយ៉ាងណា")។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៣៦៤-៣៧៨ (ទាក់ទងនឹងតម្រូវការនៃ "ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព")។

[៥៤៤] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-95-1-A-A) ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ កថាខណ្ឌ៦១ *ទាញហេតុសំអាង រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ១៩៨។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-16-A) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ២៥៧។

វចនាសម្ព័ន្ធយោធា ឬនយោបាយ នីតិវិធីសម្រាប់តែងតាំង និងកិច្ចការដាក់ស្លែងដែលបានអនុវត្ត[៥៤៥] សមត្ថភាពរបស់ជនជាប់ចោទក្នុងការចេញបញ្ជា ទោះបីជាបញ្ជានោះពិតជាត្រូវបានអនុវត្ត ឬមិនបានអនុវត្តក្តី[៥៤៦] ស្ថានភាពដែលអ្នកនៅក្រោមបង្គាប់បង្ហាញអំពីការគោរពវិន័យម៉ឹងម៉ាត់នៅពេលមានវត្តមានរបស់ជនជាប់ចោទ[៥៤៧] អំណាចក្នុងការប្រើប្រាស់វិធានការវិន័យ[៥៤៨] និងអំណាចដោះលែង ឬផ្ទេរអ្នកទោស[៥៤៩]។

៥៤២. បន្ថែមពីលើនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើអាចកើតចេញពីមូលដ្ឋាននៃទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលរបស់អ្នកនៅក្រោមបង្គាប់។ រាល់បុគ្គលដែលស្ថិតនៅក្នុងតួនាទីជាអ្នកបញ្ជាដែលមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួនក្នុងករណីដែលលក្ខខណ្ឌផ្សេងទៀតនៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបំពេញ[៥៥០]។

---

[៥៤៥] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Halilović សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-48-A) ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ៦៦។

[៥៤៦] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Strugar* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-42-A) ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ២៥៣-២៥៤។

[៥៤៧] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២០៦។

[៥៤៨] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Strugar* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-42-A) ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ២៦០-២៦២។

[៥៤៩] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២០៦។

[៥៥០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៦៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៥២។

### ២.៧.១០.២ ថ្នាក់លើបានដឹង ឬមានហេតុផលដឹង

៥៤៣. ដើម្បីសម្រេចឲ្យមានការទទួលខុសត្រូវរបស់ថ្នាក់លើក្រោមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ថ្នាក់លើត្រូវតែបានដឹង ឬមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់បម្រុងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មនោះ។ ការដឹងរបស់ថ្នាក់លើមិនអាចសន្មតជាមុនទេ ប៉ុន្តែការដឹងរបស់ថ្នាក់លើអាចត្រូវបានបង្ហាញតាមរយៈភស្តុតាងផ្ទាល់ ឬភស្តុតាងប្រយោល[៥៥១]។ ថ្នាក់លើត្រូវតែដឹងអំពីអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន និងមិនមែនគ្រាន់តែការដឹងអំពីការកើតឡើងនូវឧក្រិដ្ឋកម្មប៉ុណ្ណោះទេ[៥៥២]។

៥៤៤. ថ្នាក់លើម្នាក់នឹងត្រូវបានចាត់ទុកថា មានហេតុផលដែលអាចដឹងថាឧក្រិដ្ឋកម្មបម្រុងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្ត តែក្នុងស្ថានភាពដែលគាត់មានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើការបញ្ជាក់ក្នុងការស៊ើបអង្កេត[៥៥៣]។ ព័ត៌មាននេះអាចជាប្រភេទព័ត៌មានទូទៅ និងមិនតម្រូវឲ្យមានព័ត៌មានលម្អិតជាក់លាក់ចំពោះឧក្រិដ្ឋកម្មដែលបម្រុងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តនោះទេ។ ថ្នាក់លើមិនទទួលខុសត្រូវប្រសិនបើខកខានមិនបានស្វែងរកព័ត៌មានបែបនេះដោយផ្ទាល់ខ្លួនតាំងពីដំបូងនោះទេ[៥៥៤]។ ផ្ទុយទៅវិញ

---

[៥៥១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kordic *និង* Čerkez សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-T) ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤២៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៣០៩។

[៥៥២] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Orić សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-03-68-A) ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ៥៧-៥៩។

[៥៥៣] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-A) ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ២៨។

[៥៥៤] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić សាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-21-T) ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ៣៩៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Sesay *និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៣១០។

ថ្នាក់លើម្នាក់ដែលព្យាយាមមិនព្រមទទួលព័ត៌មានពាក់ព័ន្ធ ទោះបីជាមានមធ្យោបាយក្នុងការទទួលព័ត៌មាននោះក្តី ក៏អាចត្រូវបានចាត់ទុកថាមានហេតុផលដឹងដែរ[៩៥៥]។

២.៧.១០.៣ ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម

៩៤៥. អនុលោមតាមការទទួលខុសត្រូវរបស់ថ្នាក់លើ ជនជាប់ចោទអាចទទួលខុសត្រូវ ប្រសិនបើគាត់ខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនោះ។ វិធានការចាំបាច់គឺជាវិធានការសមស្របទាំងឡាយសម្រាប់ថ្នាក់លើក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលអំពើនេះបង្ហាញឡើងតាមរយៈកិច្ចខិតខំពិតប្រាកដដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្ម។ វិធានការសមស្របគឺជាវិធានការទាំងឡាយណាដែលស្ថិតនៅក្នុងអំណាចជាក់ស្តែងរបស់ថ្នាក់លើ។ ការកំណត់ថាជាវិធានការចាំបាច់ និងសមស្រប ត្រូវតែធ្វើឡើងដោយផ្អែកតាមករណីនៃរឿងក្តីនីមួយៗ ហើយការកំណត់នេះមិនមែនជាបញ្ហានៃច្បាប់សារធាតុនោះទេ ប៉ុន្តែជាបញ្ហានៃភស្តុតាង[៩៥៦]។

៩៤៦. ការខកខានក្នុងការដាក់ទណ្ឌកម្ម និងការខកខានក្នុងការទប់ស្កាត់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងគ្នាដែលបានប្រព្រឹត្តនៅពេលខុសៗគ្នា៖ ការខកខានក្នុងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មពីមុន ដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ក៏ដូចគ្នាដែរ ការខកខានក្នុងការទប់ស្កាត់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនាពេលខាងមុខ ដែលបម្រុងនឹងប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់។ ការខកខានទាំងពីរនេះ តំណាងឱ្យ

---

[៩៥៥] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY(IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២២៦ ។*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៦២-៦៤ ៤០៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៣១២។

[៩៥៦] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង. Halilović* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-48-A) ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ៦៣។

កាតព្វកិច្ចផ្លូវច្បាប់ពីរផ្សេងគ្នា ការខកខានណាមួយនៃការខកខានទាំងពីរនេះ នាំឲ្យមានការទទួលខុសត្រូវក្រោមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក[៥៥៧]។

៥៤៧. ការខកខានក្នុងការទប់ស្កាត់ និងការខកខានក្នុងការដាក់ទណ្ឌកម្ម មិនត្រឹមតែខុសប្លែកគ្នាតាមអង្គច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ខុសប្លែកគ្នាតាមអង្គហេតុចំពោះប្រភេទនៃការដឹង ដែលពាក់ព័ន្ធចំពោះមូលដ្ឋាននីមួយៗនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ តួនាទីក្នុងការទប់ស្កាត់របស់ថ្នាក់លើ កើតចេញនៅពេលដែលថ្នាក់លើបានដឹង ឬមានហេតុផលដឹងថាឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្ត ប៉ុន្តែតួនាទីក្នុងការដាក់ទណ្ឌកម្មកើតចេញនៅក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្ម[៥៥៨]។

## ២.៧.១០.៤ សំអាងហេតុទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ

៥៤៨. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលផ្អែកតាមទម្រង់នៃការទទួលខុសត្រូវ "ផ្ទាល់" ដូចមានចែងនៅក្នុងមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមមានបទល្មើស៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវផងដែរចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចជា ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

---

[៥៥៧] *រឿងក្តីវង្គអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-47-A) ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ២៥៩។

[៥៥៨] *រឿងក្តីវង្គអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-0១-៤៧-A) ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ២៦០។

៥៤៩. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនេះ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ជាការពិត ជនជាប់ចោទបានគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើបុគ្គលិកមន្ទីរស២១ទាំងអស់ ដោយគាត់បានដឹងថា អ្នកនៅក្រោមបង្គាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមស្របដើម្បីទប់ស្កាត់ការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ ឬដាក់ទណ្ឌកម្មចំពោះចារីទាំងនោះទេ (ផ្នែក២.៣.៣)។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមយុត្តិសាស្ត្រដែលមាន អង្គជំនុំជម្រះនឹងពិចារណាតែឋានៈជាថ្នាក់លើរបស់ជនជាប់-ចោទនៅពេលផ្តន្ទាទោសប៉ុណ្ណោះ។

## ២.៧.១១ ការការពារខ្លួនដែលបានលើកឡើងដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

៥៥០. នៅក្នុងអំឡុងពេលសវនាការ ជនជាប់ចោទបានអះអាងថា ក្នុងនាមជាអនុប្រធាន និងក្រោយមកជាប្រធាន និងជាលេខាមន្ទីរស២១ គាត់បានប្រព្រឹត្តទៅតាមបញ្ជាថ្នាក់លើរបស់គាត់[៥៥៩]។ ជនជាប់-ចោទបានលើកបន្តទៀតថា គាត់បានប្រព្រឹត្តក្រោមការបង្ខិតបង្ខំ ប្រសិនបើគាត់មិនធ្វើតាមបញ្ជាទាំងនេះទេ គាត់នឹងត្រូវបានគេសម្លាប់[៥៦០]។ មេធាវីការពារក្តីបានលើកអំណះអំណាងថា ការប្រព្រឹត្តិផ្អែកទៅតាមបញ្ជារបស់ថ្នាក់លើ ឬក្រោមការបង្ខិតបង្ខំ គួរតែឲ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដូច្នេះជនជាប់ចោទគួរសម្រេចឲ្យរួចខ្លួនពីបទចោទ បើមិនដូច្នោះទេ ការប្រព្រឹត្តិក្នុងកាលៈ-ទេសៈទាំងពីរនេះ គឺជាស្ថានសម្រាលទោស សម្រាប់គោលបំណងនៃការផ្តន្ទាទោស[៥៦១]។

---

[៥៥៩] ប្រតិចារឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៤៨-៤៩។ ប្រតិចារឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ២៨-២៩, ៥៦-៥៧។ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦១-៦២។

[៥៦០] ប្រតិចារឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ១៦, ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ២៦-២៧។ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦១-៦៣។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល) ទំព័រ ៣៤-៣៥។

[៥៦១] ប្រតិចារឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី) ទំព័រ ៧៩-៨០។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី) ទំព័រ ៣៤-៣៦ និង ៤៨។ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ ៨៥-៨៧។

## ២.៧.១១.១ បញ្ជារបស់ថ្នាក់លើ

៥៥១. មាត្រា២៩(៤) ថ្មី នៃច្បាប់ អ.វ.ត.ក បានចែងថា ៖

> ប្រការដែលជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ[៥៦២]។

៥៥២. លិខិតុបករណ៍គតិយុត្តិអន្តរជាតិដទៃទៀត ដូចជា ធម្មនុញ្ញ Nuremberg និងលក្ខន្តិកៈរបស់តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ ក៏បានចែងផងដែរថា ការប្រព្រឹត្តិទៅតាមបញ្ជារបស់ថ្នាក់លើមិនបង្កើតបានជាការការពារខ្លួនស្របច្បាប់ ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ[៥៦៣]។ ទោះបីជាយ៉ាងណាក៏ដោយ មាត្រា៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ច្រានចោលការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មសង្គ្រាមជាលក្ខណៈបុគ្គល ប្រសិនបើ ជនជាប់ចោទ មិនបានដឹងថាបញ្ជានោះខុសច្បាប់ ហើយមិនមានអ្វីមកបង្ហាញថាបញ្ជានោះគឺជាបញ្ជាខុសច្បាប់នោះទេ[៥៦៤]។ នៅក្នុងករណីនេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទបានដឹងថា បទបញ្ជាឲ្យ

---

[៥៦២] សូមមើលមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ដែលជាច្បាប់ជាតិដែលពាក់ព័ន្ធក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ចែងថា ៖ “ក្នុងករណីដែលសេចក្តីបង្គាប់ជាអនីត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូបនោះ ចៅក្រមត្រូវថ្លឹងមើលតាមការណ៍គួរ នូវភាពនៃការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការណ៍ នោះ”។

[៥៦៣] លក្ខន្តិកៈនៃតុលាការយោធាអន្តរជាតិ មាត្រា៨ ៖ “ប្រការដែលថាចុងចោទបានអនុវត្តតាមបញ្ជារបស់រដ្ឋាភិបាល ឬថ្នាក់លើរបស់គាត់ នឹងមិនត្រូវលើកលែងឲ្យជននោះរួចផុតពីការទទួលខុសត្រូវឡើយ ប៉ុន្តែអាចត្រូវបានពិចារណាអំពីស្ថានសម្រាលទោស ប្រសិនបើតុលាការសម្រេចថាយុត្តិធម៌តម្រូវឲ្យមានដូច្នេះ”។ មាត្រា៧(៤) នៃលក្ខន្តិកៈរបស់តុលាការ ICTY ចែងថា ៖ “ប្រការដែលថាជនជាប់ចោទបានអនុវត្តតាមបញ្ជារបស់រដ្ឋាភិបាល ឬថ្នាក់លើរបស់គាត់ នឹងមិនត្រូវលើកលែងឲ្យជននោះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែអាចត្រូវបានពិចារណាអំពីស្ថានសម្រាលទោស ប្រសិនបើតុលាការអន្តរជាតិសម្រេចថាយុត្តិធម៌តម្រូវឲ្យមានដូច្នេះ”។ សូមមើលផងដែរនូវពាក្យពេចន៍ស្រដៀងគ្នានេះ នៅក្នុងមាត្រា៦(៤) នៃលក្ខន្តិកៈរបស់តុលាការ ICTR និងមាត្រា៦(៤) នៃលក្ខន្តិកៈរបស់តុលាការ SCSL។

[៥៦៤] មាត្រា៣៣(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថា ៖ “ប្រការដែលបទល្មើសព្រហ្មទណ្ឌមួយស្ថិតក្នុងយុត្តាធិការរបស់តុលាការ ត្រូវបានប្រព្រឹត្តដោយជនម្នាក់ តាមបញ្ជារបស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើ ទោះជាយោធាក្តី ឬជនស៊ីវិលក្តី នឹងមិនត្រូវឲ្យជននោះរួចផុតពីបន្ទុកនៃការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងតែ (ក) ជននោះមានកាតព្វកិច្ច

សម្លាប់ ឱ្យធ្វើទារុណកម្ម និងការឃុំឃាំងដោយបំពានទៅលើបុគ្គលដែលត្រូវទទួលបានការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាអំពើខុសច្បាប់ (ផ្នែក ២.៧.១.៤)។ អង្គជំនុំជម្រះយល់ឃើញផងដែរថា ជនជាប់ចោទបានដឹងថាអំពើដែលបង្កើតបានជាការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាបទឧក្រិដ្ឋ (កថាខណ្ឌ ៤០៧)។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទក៏បានដឹងផងដែរថា បទបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឱ្យប្រព្រឹត្តនូវអំពើអ្វីមួយនោះគឺជាអំពើខុសច្បាប់។

### ២.៧.១១.២ ការបង្ខិតបង្ខំ

៥៥៣. បទប្បញ្ញត្តិ អ.វ.ត.ក មិនបានចែងឱ្យបានជាក់លាក់ថាតើការបង្ខិតបង្ខំអាចឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដែរ ឬទេ ទោះបីជាមាត្រា៩៧(២) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ បានចែងថា ៖

> គ្រោះថ្នាក់យ៉ាងធំបំផុត នឹងត្រូវធ្លាក់មកលើអ្នកណាម្នាក់ ក្នុងពេលជាបន្ទាន់ក្រៃពេក មិនអាចនឹងចៀសបានដោយងាយ ហើយអ្នកមានគ្រោះនោះ នឹងដោះខ្លួនឱ្យរួចពីគ្រោះនេះបាន ក៏លុះតែបានប្រព្រឹត្តបទល្មើសណាមួយទើបរួច ម៉្យាងទៀតគ្រោះថ្នាក់នោះកាលកើតមក ក៏មិនមែនកើតមានឡើងមកពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ នឹងមិនមែនខ្លួនចារីនោះជាអ្នកបង្កបង្កើត បណ្តាលឱ្យមានគ្រោះថ្នាក់នោះដែរ[៩៦៥]។

៥៥៤. តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដោយរួមទាំងតុលាការកំពូល ICTY បានយល់ឃើញថា ការបង្ខិតបង្ខំមិនអាចគ្រប់គ្រាន់សម្រាប់ការពារជនជាប់ចោទឱ្យរួចផុតពីការចោទប្រកាន់

---

ផ្លូវច្បាប់ត្រូវគោរពបញ្ជារបស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើនោះ (ខ) ជននោះមិនបានដឹងថាបញ្ជានោះខុសច្បាប់ និង (គ) បញ្ជានោះមិនបានបង្ហាញជាក់ស្តែងថាខុសច្បាប់។ (២) ចំពោះគោលបំណងនៃមាត្រានេះ បទបញ្ជាឱ្យប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាអំពើខុសច្បាប់យ៉ាងច្បាស់ក្រឡែត"។

[៩៦៥] បកប្រែពីភាសាបារាំងដែលជាសំណៅដើម ។

ទាំងស្រុងពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាម ដែលពាក់ព័ន្ធនឹងការសម្លាប់ជីវិតជនស្លូតត្រង់នោះទេ ប៉ុន្តែ គេអាចយកមកពិចារណាជាស្ថានសម្រាលនៃការផ្តន្ទាទោសបាន[៥៦៦]។

---

[៥៦៦] សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Erdemovic* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-22-A) ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៧ (បដិសេធសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការបង្ខិតបង្ខំមិនត្រូវបានសម្រេចថាជាការការពារឲ្យរួចផុតពីការចោទប្រកាន់ទាំងស្រុងនោះទេ ទោះបីជាការបង្ខិតបង្ខំដែលមានលក្ខខណ្ឌតម្រូវតឹងរ៉ឹងយ៉ាងណាក៏ដោយ (ដូចយោងក្នុងសាលក្រមខាងលើ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-22-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦) និងការបញ្ជូនបញ្ហានេះត្រឡប់ទៅអង្គជំនុំជម្រះសាលាដំបូងវិញ)។ ក្នុងសំអាងហេតុដែលថា ការបង្ខិតបង្ខំមិនអាចចាត់ទុកថាជាការការពាររួចពីការចោទប្រកាន់ទាំងស្រុងនោះ មតិភាគច្រើនបានធ្វើការវាយតម្លៃទៅលើស្ថានភាពជនរងគ្រោះ ប្រភេទនៃបទល្មើស ស្ថានភាពជនជាប់ចោទ (ទាហានដែលអនុវត្តប្រតិបត្តិការវាយប្រយុទ្ធ) និងលក្ខណៈខុសគ្នារវាងប្រព័ន្ធច្បាប់ស៊ីវិល (ដែលជាទូទៅទទួលស្គាល់ការបង្ខិតបង្ខំគឺជាការការពាររួចពីការចោទប្រកាន់ទាំងស្រុង) និងប្រព័ន្ធច្បាប់កុំមិនឡូ (ដែលជាទូទៅមិនទទួលស្គាល់បែបនោះឡើយ)។ មតិភាគច្រើនបានទុកចំហចោលនូវលទ្ធភាពដែលថាការបង្ខិតបង្ខំ អាចជាការការពាររួចពីការចោទប្រកាន់ទាំងស្រុងទាក់ទងនឹងបទឧក្រិដ្ឋដែលមិនសូវមានលក្ខណៈធ្ងន់ធ្ងរ (សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ដូចសេចក្តីយោងខាងលើ យោបល់ដាច់ដោយឡែករួម របស់ចៅក្រម McDonald និងចៅក្រម Vohrah កថាខណ្ឌ៦៦, ៧០, ៨៨)។ ផ្ទុយទៅវិញ ចៅក្រម Cassese យល់ឃើញថា ការបង្ខិតបង្ខំអាចជាការការពាររួចពីការចោទប្រកាន់ទាំងស្រុង រួមទាំងពាក់ព័ន្ធទៅនឹងការសម្លាប់ជនស៊ីវិលស្លូតត្រង់ (ដូចសេចក្តីយោងខាងលើ យោបល់ជំទាស់ និងដាច់ដោយឡែក របស់ចៅក្រម Cassese កថាខណ្ឌ១៦ និង ៣៣))។ ក្នុងឆ្នាំ១៩៩៨ អង្គជំនុំជម្រះសាលាដំបូងបានទទួលបញ្ហាដែលត្រូវបានបង្វិលមកវិញនោះ ហើយបានអនុវត្តនូវសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការបង្ខិតបង្ខំ តាមបញ្ជាអង្គច្បាប់ មិនអាចជាការការពាររួចពីការចោទប្រកាន់ទាំងស្រុង ឡើយនៅក្នុងករណីនោះ ទោះបីជាអង្គជំនុំជម្រះនេះបានប្រើប្រាស់ការបង្ខិតបង្ខំ នៅក្នុងការសម្រាលទោសក៏ដោយ (ដូចសេចក្តីយោងខាងលើ សាលក្រមផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-22-T*bis*) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៨)។ សូមមើល ឧទាហរណ៍ មាត្រា៣១(១)(ឃ) នៃលក្ខន្តិកៈទីក្រុងរ៉ូម។ សូមមើល ផងដែរនូវការជំនុំជម្រះ *Otto Ohlendorf និងអ្នកផ្សេងទៀត (រឿងក្តី Einsatzgruppen)* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម វ៉ុល IV ទំព័រ៤៨០ និង សហរដ្ឋអាមេរិក ទល់នឹង *Alfred Krupp និងអ្នកផ្សេងទៀត* តុលាការយោធាសហរដ្ឋអាមេរិកនៅ Nuremberg, 1949 (X) LRTWC ទំព័រ១៤៩ ("[...] ប្រសិនបើឆន្ទៈរបស់ជនជាប់ចោទ នៅក្នុងការប្រព្រឹត្តិអំពើខុសច្បាប់មិនមានអំណាចជាងគេ ហើយគ្រាន់តែជាឆន្ទៈស្របជាមួយនឹងឆន្ទៈរបស់អ្នកទាំងឡាយដែលជាអ្នកបង្ខិតបង្ខំដែលត្រូវបានចោទប្រកាន់ ការមានយុត្តិកម្មចំពោះអំពើរបស់ជនជាប់ចោទគឺមិនចាំបាច់ទេ")។ សូមមើលផងដែរ រឿងក្តីអគ្គរដ្ឋអាជ្ញានៃប្រទេស អ៊ីស្រាអែល ទល់នឹង *Eichmann* (1961) 36 ILR 5 ទំព័រ ៣៤០។

៥៥៥. នៅពេលសវនាការ ជនជាប់ចោទបានរៀបរាប់អំពីរចនាសម្ព័ន្ធរបស់មជ្ឈិមបក្ស ភាពគ្មានជម្រើសក្រៅតែពីការគោរពតាមប្រព័ន្ធនោះ និងប្រការដែលថា សូម្បីតែសមាជិកបក្សជាន់ខ្ពស់ក៏ត្រូវបានចាត់ទុកថាជាខ្មាំង និងត្រូវបានសម្លាប់ផងដែរ[៥៦៧]។ ទោះបីជាជនជាប់ចោទបានរៀបរាប់អំពីស្ថានភាពជាច្រើន ដែលខ្លួនគាត់ផ្ទាល់មានការភ័យខ្លាចក៏ដោយ[៥៦៨] ក៏គាត់មិនបានលើកឡើងអំពីការមិនគោរពតាមបញ្ជាណាមួយឡើយ[៥៦៩]។ ម្យ៉ាងទៀត អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទមានអំណាចពេញលេញ និងបានអនុវត្តអំណាចនេះនៅមន្ទីរស២១ ហើយថាអំពើរបស់គាត់ក្នុងការអនុវត្តតួនាទីទាំងនេះ បានបង្ហាញឲ្យឃើញនូវកម្រិតដ៏ខ្ពស់នៃប្រសិទ្ធភាពការងារ និងពេញចិត្តចំពោះភារកិច្ចរបស់គាត់[៥៧០]។អង្គជំនុំជម្រះបានយល់ឃើញផងដែរថា ជនជាប់ចោទបានអនុវត្តគោលនយោបាយបក្សកុម្មុយ-នីស្តកម្ពុជា និងបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឲ្យគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ប្រព្រឹត្តទៅបានដោយរលូន ដូចជាការចងក្រងនូវចម្លើយសារភាពជាច្រើន ដែលជាការប្រឌិត (ផ្នែក ២.៣.៣.៥.៤)។

៥៥៦. ទោះបីជាមានការអះអាងថា ការតែងតាំងទាំងនេះប្រឆាំងទៅនឹងឆន្ទៈរបស់គាត់ក៏ដោយ អង្គ-ជំនុំជម្រះយល់ឃើញថា ការទទួលយកនូវការតែងតាំងរបស់ជនជាប់ចោទជាអនុប្រធាន និងក្រោយ

---

[៥៦៧] ប្រតិចារឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៤៤, ៤៧។ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Raoul JENNAR ទំព័រ ៤៥-៤៧, ៤៨-៤៩។

[៥៦៨] ប្រតិចារឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ១៦, ៤៩-៥០។ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦៣។ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៥-៦, ២៦។ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៦១-៦៣។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៣៥។

[៥៦៩] សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Erdemovic*, អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-22-T) ថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ យោបល់ជំទាស់ និងដាច់ដោយឡែក របស់ចៅក្រម Cassese កថាខណ្ឌ១៥ (លើកនូវយោបល់ថា ការមិនស្តាប់តាមបញ្ជា គឺជាបុរេលក្ខខណ្ឌមួយសម្រាប់បង្កើតឲ្យមាននូវការ បង្ខិតបង្ខំ)។

[៥៧០] "សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា "សំឡេងចេញពីមន្ទីរស២១ – ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត" E3/427, ERN (ភាសាខ្មែរ) 00192847។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (Craig ETCHESON) ទំព័រ ១៥, ២០-២១, ៦៦-៦៧។ ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ (David CHANDLER) ទំព័រ ៣៤-៣៥, ៤១-៤៣, ៤៦-៤៧។

មកជាប្រធានមន្ទីរស២១ គឺផ្ទុះបញ្ជាំងនូវភាពស្មោះត្រង់របស់គាត់ចំពោះបក្សកុម្មុយនីស្តកម្ពុជា។ ជំនឿផ្ទាល់ខ្លួនរបស់គាត់ទៅលើបក្ស និងការប្តេជ្ញាអនុវត្តតាមគោលដៅរបស់បក្សទំនងជានៅមានដដែល សូម្បីតែក្រោយពេលដែលគាត់បានចាកចេញពីមន្ទីរស២១ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ក៏ដោយ[៩៧១]។

៥៥៧. អង្គជំនុំជម្រះទទួលស្គាល់ថា រហូតដល់ចុងបញ្ចប់នៃអត្ថិភាពរបស់មន្ទីរស២១ ជនជាប់ចោទអាចមានការភ័យខ្លាចថា គាត់ ឬសាច់ញាតិជិតស្និទ្ធរបស់គាត់នឹងត្រូវគេសម្លាប់ ប្រសិនបើថ្នាក់លើរបស់គាត់មិនពេញចិត្តនឹងអំពើរបស់គាត់។ ទោះបីយ៉ាងណាក៏ដោយ គេមិនអាចអះអាងថាមានការបង្ខិតបង្ខំនោះទេ នៅពេលដែលការគំរាមកំហែងនោះកើតចេញមកពីការអនុវត្តគោលនយោបាយដែលធ្វើឱ្យមានភាពភ័យរន្ធត់ ដែលជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត។

៥៥៨. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាជនជាប់ចោទមិនបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំក្នុងនាមគាត់ជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ឡើយ។ ហេតុដូច្នេះការបង្ខិតបង្ខំមិនមានការពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ និងស្ថានសម្រាលនៃការផ្តន្ទាទោសនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានពិចារណាលើកត្តានានានៅក្នុងការសម្រេចអំពីទោស ដែលកត្តាទាំងនោះមានដូចជា បរិយាកាសបង្ខិតបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីតាមឋានានុក្រមរបស់ជនជាប់ចោទនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា (ផ្នែក ៣.៣.៣)។

### ២.៧.១២ ពិរុទ្ធភាពពីបទល្មើសច្រើន

៥៥៩. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល អនុលោមតាមមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចំពោះបទល្មើសដូចខាងក្រោមនេះ ដែលជាបទឧក្រិដ្ឋប្រឆាំង

---

[៩៧១] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៦៦។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៧២-៧៥ និងប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ ៣៤-៣៨ (ពណ៌នាអំពីស្មារតីភក្តីដែលនៅមានចំពោះខ្មែរក្រហម (ទោះបីជាមានការពេញចិត្តតិចតួចទៅៗ) រហូតដល់គាត់ត្រូវបានចាប់ខ្លួន)។

និងមនុស្សជាតិ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

៥៦០. ក្នុងករណីដែលអំពើរបស់ជនជាប់ចោទបំពេញនូវធាតុផ្សំនៃបទល្មើសច្រើនផ្សេងគ្នា អង្គជំនុំ-ជម្រះនឹងវាយតម្លៃអំពីស្ថាននៃពិរុទ្ធភាពបទល្មើសច្រើន។ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍បានទទួលស្គាល់ថា ពិរុទ្ធភាពច្រើនបទគឺក្នុងគោលបំណង "រៀបរាប់អំពីពិរុទ្ធភាពទាំងស្រុងរបស់ជនជាប់ចោទណាម្នាក់ ឬបង្ហាញឱ្យឃើញច្បាស់នូវអំពើឧក្រិដ្ឋរបស់គាត់"[៩៧២]។ ដោយសារតែពិរុទ្ធភាពពីបទល្មើសច្រើន បង្កើតជាហានិភ័យប៉ះពាល់ដល់ជនជាប់ចោទ[៩៧៣] អង្គជំនុំជម្រះតុលាការកំពូល ICTY បានបង្កើតលក្ខខណ្ឌវិនិច្ឆ័យលើបញ្ហានេះ ដូចខាងក្រោម ៖

> ៤១៧. ពិរុទ្ធភាពពីបទល្មើសច្រើន ដោយផ្អែកតាមបទប្បញ្ញត្តិច្បាប់ផ្សេងគ្នា ប៉ុន្តែផ្អែកទៅលើអំពើដូចគ្នា អាចធ្វើទៅបានតែក្នុងករណីដែលបទប្បញ្ញត្តិច្បាប់មួយដែលពាក់ព័ន្ធមានធាតុផ្សំខុសគ្នាជាសត្យានុម័ត ពីបទប្បញ្ញត្តិច្បាប់មួយទៀត។ ធាតុផ្សំមួយខុសគ្នាជាសត្យានុម័តពីធាតុផ្សំមួយទៀត ប្រសិនបើភស្តុតាងនៃអង្គហេតុដែលត្រូវបង្ហាញរបស់ធាតុផ្សំទាំងនោះមិនដូចគ្នា។

[៩៧២] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kunarac* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-23 & IT-96-23/1-A) ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១៦៩។

[៩៧៣] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić និង* អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ យោបល់ជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ស្តីអំពីពិរុទ្ធភាពពីបទល្មើសច្រើន កថាខណ្ឌ២។

៩១៨. ក្នុងករណីដែលលក្ខខណ្ឌវិនិច្ឆ័យមិនត្រូវបានបំពេញ អង្គជំនុំជម្រះត្រូវតែសម្រេចពាក់ព័ន្ធទៅនឹងបទល្មើសដែលអង្គជំនុំជម្រះយល់ថាមានពិរុទ្ធភាព។ ការសម្រេចនេះត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដែលថា ពិរុទ្ធភាពស្របតាមបទប្បញ្ញត្តិជាក់លាក់ត្រូវយកមកអនុវត្ត។ ដូច្នេះប្រសិនបើមានអង្គហេតុ ដែលត្រូវសម្រេចសេចក្តីដោយបទប្បញ្ញត្តិពីរផ្សេងគ្នា ដែលបទប្បញ្ញត្តិមួយនៃបទប្បញ្ញត្តិទាំងពីរនោះមានធាតុផ្សំបន្ថែមជាសត្យានុម័តលើបទប្បញ្ញត្តិមួយទៀត ដូច្នេះការកំណត់ពិរុទ្ធភាពត្រូវធ្វើឡើងដោយផ្អែកលើបទប្បញ្ញត្តិដែលមានធាតុផ្សំបន្ថែមនោះ[៩៧៤]។

៥៦១. ប្រសិនបើអំពើដូចគ្នារំលោភទៅលើបទប្បញ្ញត្តិច្បាប់ពីរខុសគ្នានោះ វាគឺជាបញ្ហាអង្គច្បាប់។ លក្ខខណ្ឌវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* និងយុត្តិសាស្ត្រក្រោយៗមកទៀតដែលបានយកលក្ខខណ្ឌវិនិច្ឆ័យនោះមកអនុវត្ត បានសង្កត់ធ្ងន់ទៅលើធាតុផ្សំផ្លូវច្បាប់នៃបទឧក្រិដ្ឋនីមួយៗ ដែលអាចជាកម្មវត្ថុនៃពិរុទ្ធភាពពីបទល្មើសច្រើន ជាងអំពើជាក់លាក់ដែលបានប្រព្រឹត្តដោយជនជាប់ចោទ[៩៧៥]។

### ២.៧.១២.១ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

៥៦២. យោងតាមយុត្តិសាស្ត្រនៃតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ ពិរុទ្ធភាពពីបទល្មើសច្រើនត្រូវបានប្រើសម្រាប់បទឧក្រិដ្ឋស្រដៀងគ្នា ជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយពិចារណាទៅលើលក្ខណៈខុសគ្នានៃប្រភេទបទឧក្រិដ្ឋទាំងពីរ[៩៧៦]។

---

[៩៧៤] *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១២-៤១៣។

[៩៧៥] សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៣៨៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល SCSL (SCSL-04-15-A) ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ១១៩១។

[៩៧៦] សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-14/2-T) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ (កត់សម្គាល់ លក្ខខណ្ឌតម្រូវកម្រិតខុសគ្នានៃបទឧក្រិដ្ឋ ទាំងពីរ និងការដាក់បញ្ចូលពិរុទ្ធភាពពីបទល្មើសច្រើន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ

ដូច្នេះ អង្គជំនុំជម្រះប្រកាសពិរុទ្ធភាពលើជនជាប់ចោទចំពោះបទល្មើសជាក់លាក់នៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដូចជា៖ ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រួតគ្នាជាមួយនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មានដូចជា ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

### ២.៧.១២.២ ការធ្វើទុក្ខបុកម្នេញ និងបទល្មើសជាក់លាក់ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៥៦៣. នៅពេលប្រៀបធៀបជាមួយបទល្មើសទាំងអស់ផ្សេងៗទៀត ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បទល្មើសការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានធាតុផ្សំបន្ថែម គឺចេតនារើសអើងពីសំណាក់ចារី (ផ្នែក ២.៥.៣.១៣)។

៥៦៤. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ *មិនអចិន្ត្រៃយ៍* បានធ្វើការពិចារណាលម្អិតទៅលើទំនាក់-ទំនងរវាងបទល្មើសការធ្វើទុក្ខបុកម្នេញ និងបទល្មើសដែលមានធាតុផ្សំផ្សេងៗទៀត ដែលត្រូវចោទប្រកាន់ថាជាអំពើនៃការធ្វើទុក្ខបុកម្នេញ។ ទោះបីជាយុត្តិសាស្ត្រមុនៗ មានទស្សនៈមួយផ្សេងពីនេះក៏ដោយ[៩៧៧] អង្គជំនុំជម្រះតុលាការកំពូល ICTY ទំនងជាមានទំនោរទៅរកការកំណត់ពិរុទ្ធភាពពី

---

នៃការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា (កថាខណ្ឌ ៨២០) អំពើអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ (កថាខណ្ឌ ៨២១) ព្រមទាំង ការដាក់ក្នុងមន្ទីរឃុំឃាំង និងការឃុំខ្លួនដោយខុសច្បាប់ (កថាខណ្ឌ ៨២៤))។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić* និងអ្នកផ្សេងទៀត សាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៣៧ ។

[៩៧៧] សូមមើលរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Krstić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២៣១-២៣៣។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Krnojelac* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-97-25-A) ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ១៨៨ និងផ្នែកសេចក្តីសម្រេច។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Vasiljević* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-98-32-A) ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ

បទល្មើសច្រើនចំពោះការធ្វើទុក្ខបុកម្នេញ និងបទល្មើសជាក់លាក់ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយផ្អែកលើហេតុផលថាបទល្មើសធ្វើទុក្ខបុកម្នេញ មានធាតុផ្សំខុសគ្នាជាសត្យានុម័តពីធាតុផ្សំដែលមាននៅក្នុងបទល្មើសជាក់លាក់ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៩៧៨]។

៥៦៥. ចៅក្រមពីរនាក់ក្នុងចំណោមចៅក្រមប្រាំនាក់របស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសាលដីកាលើរឿងក្តី *Kordić* និងអ្នកផ្សេងទៀត ដែលផ្ទុះបញ្ច្រាំងនូវយុត្តិសាស្ត្រដែលត្រូវបានបង្កើតពីមុនរបស់អង្គជំនុំជម្រះនោះ បានជំទាស់ទៅនឹងការលើកឡើងថា ការកំណត់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញអាចត្រួតគ្នាជាមួយការកំណត់ពិរុទ្ធភាពពីបទល្មើសផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រសិនបើការកំណត់ពិរុទ្ធភាពទាំងពីរនេះ ផ្អែកទៅលើអំពើឧក្រិដ្ឋដូចគ្នានោះ[៩៧៩]។ ទោះបីជាធាតុផ្សំនៃបទល្មើសការធ្វើទុក្ខបុកម្នេញ និងបទល្មើសជាក់លាក់ផ្សេងៗទៀត អាចខុសគ្នានៅពេលដែលពិចារណាជារបៀបអរូបិយក៏ដោយ ដោយយោងទៅលើលក្ខខណ្ឌវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* បញ្ហាគឺថាតើការតម្រូវឲ្យមានការបង្ហាញភស្តុតាងនៃអង្គហេតុនៅក្នុងបទល្មើសមួយ ដូចគ្នាទៅនឹងការតម្រូវនៅ

---

១៤៦-១៤៧ និងផ្នែកសម្រេចសេចក្តី។ ទោះបីយ៉ាងណាក៏ដោយ តុលាការអន្តរជាតិ*មិនអចិន្ត្រៃយ៍*ក្រោយៗទៀត បានគាំទ្រវិធីសាស្ត្រដែលត្រូវបានយកមកអនុវត្តដោយសាលដីកាលើរឿងក្តី *Kordić* និងអ្នកផ្សេងទៀត (សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Nahimana* និងអ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-99-52-A) ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ១០២៤-១០២៦)។

[៩៧៨] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić* និង អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៣៨-១០៤៣ (ពិចារណា ពោលគឺ ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យមានការបង្ហាញភស្តុតាងថា អំពើសកម្ម ឬអកម្ម មាននូវការរើសអើង និងការបង្ហាញភស្តុតាងនៃចេតនារើសអើងជាក់លាក់។ ផ្ទុយទៅវិញ ការធ្វើមនុស្សឃាត តម្រូវឲ្យមានការបង្ហាញភស្តុតាងត្រឹមតែថា ជនជាប់ចោទបានបង្កឲ្យការស្លាប់ដល់បុគ្គលម្នាក់ ឬច្រើននាក់ ដោយមិនគិតថាតើអំពើសកម្ម ឬអកម្មនេះ មាននូវការរើសអើង ឬមានចេតនាជាក់លាក់ជាការរើសអើងនោះទេ)។

[៩៧៩] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kordić* និង អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ យោបល់ជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ស្តីពីពិរុទ្ធភាពពីបទល្មើសច្រើន កថាខណ្ឌ ១ និង ១៣ (យល់ឃើញថា សាលដីកាមុនៗរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Krnojelac, Vasiljević* និង អ្នកផ្សេងទៀត បង្ហាញនូវការអនុវត្តដ៏ត្រឹមត្រូវនូវលក្ខខណ្ឌវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ហើយពិចារណាថា មិនមានមូលហេតុត្រឹមត្រូវសមហេតុផលឡើយ ដើម្បីអនុវត្តផ្ទុយពីយុត្តិសាស្ត្រនេះ)។

00573657



ក្នុងបទល្មើសមួយទៀត ឬយ៉ាងណា[៥៨០]។ ឧទាហរណ៍ ប្រសិនបើការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ សំអាងទៅលើការធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ ហើយមានភស្តុតាងគាំទ្រការចោទប្រកាន់នោះ អយ្យការមិនចាំបាច់បង្ហាញភស្តុតាងបន្ថែមដើម្បីបញ្ជាក់ពិរុទ្ធភាពអំពីមនុស្សឃាត ឬអំពើអមនុស្សធម៌ឡើយ។ ភស្តុតាង ដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្វើទុក្ខបុកម្នេញ តាមរយៈការធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ ចាំបាច់ត្រូវរួមបញ្ចូលភស្តុតាងនៃការធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌រួចទៅហើយ។ បទល្មើសទាំងនេះបានបញ្ចូលគ្នានៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញ[៥៨១]។ អង្គជំនុំជម្រះគាំទ្រការអនុវត្តលក្ខខណ្ឌវិនិច្ឆ័យលើរឿងក្តី *Čelebići* ប៉ុន្តែ យល់ស្របថាចាំបាច់ត្រូវរៀបរាប់ឱ្យបានលម្អិតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងរបស់ពិរុទ្ធជននៅក្នុងផ្នែកសេចក្តីសម្រេច ដូច្នេះហើយត្រូវចង្អុលបង្ហាញនូវអំពើជាក់លាក់នោះដែលជាមូលដ្ឋានកំណត់ពីពិរុទ្ធភាពនៃការធ្វើទុក្ខបុកម្នេញ[៥៨២]។

---

[៥៨០] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kordić និង* អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ យោបល់ជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ស្តីអំពីពិរុទ្ធភាពពីបទល្មើសច្រើន កថាខណ្ឌ ៥។

[៥៨១] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kordić* និង អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A), ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ យោបល់ជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ស្តីអំពីពិរុទ្ធភាពពីបទល្មើសច្រើន កថាខណ្ឌ ១០ និង ១២ (កត់សម្គាល់ថា ប្រសិនបើការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានធាតុផ្សំខុសគ្នាជាសត្យានុម័តនៃអំពើរើសអើង និងចេតនារើសអើង ដូច្នេះវាមានលក្ខណៈជាក់លាក់ជាងការធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ផ្សេងៗទៀត ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ឯកសារយោងត្រូវបានលុប))។ សូមមើល ដូចសេចក្តីយោងខាងលើ កថាខណ្ឌ ១១ ផងដែរ (កត់សម្គាល់បន្ថែមទៀតថា ការផ្តន្ទាទោសចំពោះការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញ គឺមិនអាចជាពិរុទ្ធភាព ពីបទល្មើសច្រើនបានទេ។ ប្រសិនបើការធ្វើទុក្ខបុកម្នេញមានទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ត្រូវដាក់បញ្ចូលនៅក្នុងការដាក់ក្នុងមន្ទីរឃុំឃាំង (ឯកសារយោងត្រូវបានលុប))។

[៥៨២] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kordić* និង អ្នកផ្សេងទៀត សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/2-A) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ យោបល់ជំទាស់រួមរបស់ចៅក្រម Schomburg និងចៅក្រម Güney ស្តីអំពីពិរុទ្ធភាពពីបទល្មើសច្រើន កថាខណ្ឌ ២។ សូមមើល សេចក្តីយោងខាងលើ កថាខណ្ឌ ៦ ផងដែរ (ពណ៌នាបទល្មើសធ្វើទុក្ខបុកម្នេញថាជា "បទល្មើសមួយប្រភេទ ដែលត្រូវបានបង្កើតឡើងដើម្បីគ្របដណ្តប់នូវបទល្មើសជាក់លាក់ផ្សេងៗទៀត ដែលអាចកើតមានឡើងទៅជាបទល្មើសធ្វើទុក្ខបុកម្នេញ។ ដូច្នេះ វាចាំបាច់ត្រូវពណ៌នាអំពីការបំពារបំពាននៃសិទ្ធិជាមូលដ្ឋានអ្វីខ្លះត្រូវបានក្តោបដោយការចោទប្រកាន់នេះ ដើម្បីជៀសវាងនូវភាពមិនច្បាស់លាស់ដែលមិនត្រូវឱ្យកើតមាន)។

### ២.៧.១២.៣ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

៥៦៦. ការទទួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះបទល្មើសការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ត្រូវផ្អែកទៅលើអំពើជាក់លាក់ដូចគ្នា (ផ្នែក ២.៤.១.)។ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានធាតុផ្សំមួយចំនួនរួមគ្នា។ ធាតុផ្សំដែលបង្ហាញពីលក្ខណៈខុសគ្នារវាងបទល្មើសទាំងពីរនេះគឺថា បទល្មើសសម្លាប់រង្គាលតម្រូវឲ្យមានធាតុផ្សំនៃការសម្លាប់ទ្រង់ទ្រាយធំ (ផ្នែក ២.៥.៣.១)។ ដូច្នេះ ការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទល្មើសដែលស្រូបបញ្ចូលទៅក្នុងបទល្មើសការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៥៨៣]។

### ២.៧.១២.៤ សេចក្តីសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ

៥៦៧. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលផ្អែកតាមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរួមមានបទល្មើសៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សផ្សេងៗទៀត។ ជនជាប់ចោទត្រូវទទួលខុសត្រូវផងដែរចំពោះអំពើបំពារ-បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចជា ការធ្វើមនុស្សឃាតដោយចេតនា

---

[៥៨៣] អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ បានចង្អុលបង្ហាញថាការធ្វើមនុស្សឃាតគឺជាផ្នែកមួយនៃការធ្វើទុក្ខបុកម្នេញ ប៉ុន្តែមិនបាននិយាយពីការសម្លាប់រង្គាលនោះទេ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ ១៤១ (បានចោទប្រកាន់ថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្វើទុក្ខបុកម្នេញតាមរយៈការដាក់អ្នកជាប់ឃុំឲ្យស្ថិតនៅក្រោម "ការឃុំឃាំងដោយខុសច្បាប់ និងដោយបំពារបំពាន ការធ្វើទារុណកម្ម ការធ្វើឲ្យទៅជាទាសករ ការកាប់សម្លាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត"))។ ចំពោះការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះយល់ឃើញថា រាល់សមាសភាពនៃបទល្មើសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងអស់ត្រូវបានស្រូបបញ្ចូលទៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញ ហើយអង្គជំនុំជម្រះយល់ឃើញថាការស្រូបបញ្ចូលដូច្នេះមានផលវិបាកតែបន្តិចបន្តួចតែប៉ុណ្ណោះ ។

ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

៥៦៨. ផ្អែកតាមយុត្តិសាស្ត្រដែលទាក់ទងទៅនិងពិរុទ្ធភាពបទល្មើសច្រើន អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ដែលបទល្មើសនេះស្រូបបញ្ចូលនូវឧក្រិដ្ឋកម្មមួយចំនួនដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការសម្លាប់រង្គាល (រួមទាំងការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត)។ អង្គជំនុំជម្រះយល់ឃើញផងដែរថា ជនជាប់ចោទត្រូវទទួលខុសត្រូវជាបុគ្គលចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ លើឧក្រិដ្ឋកម្មមួយចំនួនដូចជា៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

## ៣ ការផ្តន្ទាទោស

### ៣.១ សារណារបស់ភាគី

៥៦៩. ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលជនជាប់ចោទបានប្រព្រឹត្ត និងស្ថានទម្ងន់ទោសនានា សហព្រះរាជអាជ្ញាស្នើសុំឱ្យផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារអស់មួយជីវិត។ ប៉ុន្តែដើម្បីជាការទូទាត់សំណងឱ្យបានសមស្របទៅនឹងការឃុំខ្លួនជនជាប់ចោទខុសច្បាប់កន្លងមកដោយតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជានោះ សហព្រះរាជអាជ្ញាបានស្នើសុំផ្លាស់ប្តូរពីការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត មកជាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៤៥ឆ្នាំវិញ។ ម្យ៉ាងទៀត

ដោយពិចារណាលើស្ថានសម្រាលនានាផងនោះ សហព្រះរាជអាជ្ញាក៏បានស្នើសុំឲ្យកាត់បន្ថយទោសបន្ថែមចំនួន០៥ឆ្នាំទៀត។ ហេតុដូចនេះ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគាររយៈពេល៤០ឆ្នាំ[៥៨៤]។

៥៧០. នៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ជនជាប់ចោទបានទទួលស្គាល់អំពីការទទួលខុសត្រូវរបស់គាត់ទាំងខាងផ្នែក "ផ្លូវច្បាប់ និងផ្លូវចិត្ត" ចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរស២១[៥៨៥]។ ទោះបីជាបែបនេះក្តី ជនជាប់ចោទបានស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចដោះលែងគាត់ឲ្យមានសេរីភាព និងស្នើសុំអង្គជំនុំជម្រះសម្រេចឲ្យគាត់រួចខ្លួនពីបទចោទចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់មកលើរូបគាត់[៥៨៦]។ មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ ដែលហាក់ ដូចជាមិនបានចូលរួមជាមួយនឹងការស្នើសុំទាំងនេះ បានកត់សម្គាល់ថាអង្គជំនុំជម្រះគួរពិចារណាលើស្ថានសម្រាលទោសនានានៅក្នុងការសម្រេចទោស[៥៨៧]។ បន្ថែមពីលើនេះនៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន ជនជាប់-ចោទបានស្នើសុំអង្គជំនុំជម្រះសម្រេចកាត់បន្ថយទោស ជាការទូទាត់សងជាមួយរយៈពេលនៃការឃុំខ្លួនគាត់បណ្តោះអាសន្នចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ព្រមទាំងបន្ថយទោសរយៈពេលប៉ុន្មានឆ្នាំបន្ថែមទៀត ដើម្បីទូទាត់សងការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលមួយសមរម្យ[៥៨៨]។

[៥៨៤] "សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា" E159/9 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៣៥៧-៤៨៦។

[៥៨៥] ប្រតិចារឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៧-៤៨។

[៥៨៦] ប្រតិចារឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ៥៦-៨១។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៤៥-៤៧។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ៦២។

[៥៨៧] ប្រតិចារឹក ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ៥៤-៦០។ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ៤០។

[៥៨៨] "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី" E159/8 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ១៩។

## ៣.២ ច្បាប់ជាធរមាន

### ៣.២.១ បទប្បញ្ញត្តិ និងក្របខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនៅ អ.វ.ត.ក

៥៧១. វិធាន៩៨(៥) នៃវិធានផ្ទៃក្នុងចែងថា "ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព នោះអង្គជំនុំជម្រះត្រូវផ្តន្ទាទោសជនជាប់ចោទឲ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុង"[៥៨៩] ។ ឯកសារនានារបស់ អ.វ.ត.ក មិនបានបែងចែករវាងបទឧក្រិដ្ឋជាតិ និងបទឧក្រិដ្ឋអន្តរជាតិទាក់ទងនឹងការផ្តន្ទាទោសទេ។

៥៧២. មាត្រា១០ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្ម នៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ គឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត"។ មាត្រា៣៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងបន្ថែមទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដូចតទៅនេះ៖

> ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា៨នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពី៥ឆ្នាំ រហូតដល់មួយជីវិត។
>
> ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ[៥៩០]។

---

[៥៨៩] មិនដូចនីតិវិធីដែលអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត ក្របខណ្ឌច្បាប់ អ.វ.ត.ក មិនបានចែងអំពីលទ្ធភាពនៃសវនាការសម្រេចទោស ឬសវនាការសម្រេចទោសដែលរៀបចំច្បាស់លាស់មួយនោះទេ។ ផ្អែកតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បញ្ហាដែលទាក់ទងនឹងកំហុស និងការផ្តន្ទាទោស ត្រូវបានដោះស្រាយនៅក្នុងពេលសវនាការតែមួយ និងត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចតែមួយ។

[៥៩០] *សូមមើលផងដែរ* មាត្រា៣៩ នៃច្បាប់ អ.វ.ត.ក ។

៥៧៣. កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ក៏បានចែងផងដែរថា អង្គជំនុំជម្រះត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ឲ្យស្របជាមួយបទប្បញ្ញត្តិមាត្រា១៤ និង១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៥៥១]។ មាត្រា១៥(១)ចែងថា មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ ហើយ "ប្រសិនបើក្រោយពីការប្រព្រឹត្តិបទល្មើស ច្បាប់បានបញ្ញត្តឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ"[៥៥២]។ ការពិនិត្យមើលឯកសារណែនាំទាក់ទងនឹងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បង្ហាញថា ការផ្តន្ទាទោស ដែលយកមកអនុវត្តនៅ អ.វ.ត.ក ចំពោះបទឧក្រិដ្ឋទាំងនេះ មិនផ្ទុយនឹងមាត្រា១៥(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ[៥៥៣]។

៥៧៤. ម្យ៉ាងវិញទៀត បទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ទោសក្នុងច្បាប់កម្ពុជា ពុំមានបង្ហាញនូវភាពផ្ទុយគ្នាទៅនឹងមាត្រា ១៥(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលជាច្បាប់ជាធរមានក្នុងអំឡុងពេលបទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្ត បង្ហាញថាទោសប្រហារជីវិតអាចអនុវត្តបានចំពោះបទល្មើសជាច្រើន ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺ-

---

[៥៥១] *សូមមើល* មាត្រា៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក និងមាត្រា១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក។

[៥៥២] *សូមមើលផងដែរ* មាត្រា៦(២)នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងមាត្រា១០(១) នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ (បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម)។

[៥៥៣] *សូមមើលឧទា.* ធម្មនុញ្ញ Nuremberg មាត្រា២៧ (ដែលចែងអំពីលទ្ធភាពនៃ "ការកាត់ទោសប្រហារជីវិត ឬការផ្តន្ទាទោសផ្សេងៗទៀតចំពោះពិរុទ្ធភាព នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថាមានភាពយុត្តិធម៌") និងមាត្រា២៨ (អនុញ្ញាតឲ្យតុលាការដកហូត "ទ្រព្យសម្បត្តិដែលលួចបាន"ពីពិរុទ្ធជន)។ *សូមមើលផងដែរ* បទប្បញ្ញត្តិទោស ដែលមានចែងនៅក្នុងមាត្រា៧៧ នៃលក្ខន្តិកៈតុលាការ ICC មាត្រា២៤ នៃលក្ខន្តិកៈតុលាការ ICTY មាត្រា២៣ នៃលក្ខន្តិកៈតុលាការ ICTR និងមាត្រា១៩ នៃលក្ខន្តិកៈតុលាការ SCSL។

ណែរ[៥៥៤]។ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិកម្ពុជាក្រោយៗមកទៀត អង្គជំនុំជម្រះមិនអាចធ្វើការប្រៀបធៀបគ្នារវាងរបប នៃការកំណត់ទោស ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងដែលមានអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានទេ ដោយសារតែក្រមនេះមិនទាន់ចូលជាធរមានទាំងស្រុងនៅឡើយ[៥៥៥]។ ទោះបីជាមាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក តម្រូវឲ្យអង្គជំនុំជម្រះអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របតាមមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយយ៉ាងណាក៏ដោយ ក៏ច្បាប់ អ.វ.ត.ក ដែលអនុវត្តកិច្ចព្រមព្រៀង បង្កើតនូវរបបនៃការកំណត់ទោសពិសេសដាច់ដោយឡែកមួយ។ ដូច្នេះ គេនៅមិនទាន់ច្បាស់ប្រាកដនៅឡើយថាតើ ដោយឈរលើមូលដ្ឋាននៃមាត្រា៣៣ ថ្មី អង្គជំនុំជម្រះអាចអនុវត្តតាមបទប្បញ្ញត្តិក្រោយរបស់អង្គការនីតិបញ្ញត្តិជាតិ ជំនួសឲ្យបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងបាន ឬយ៉ាងដូចម្តេចចំពោះបទបញ្ញត្តិពាក់ព័ន្ធនឹងការផ្តន្ទាទោស។ ការបកស្រាយដូច្នេះ អាចមានន័យថា ច្បាប់ដែលចេញនាពេលអនាគតរបស់អង្គការនីតិបញ្ញត្តិជាតិ អាចធ្វើឲ្យប៉ះពាល់ដល់អានុភាពនៃកិច្ចព្រមព្រៀង។

៥៧៥. ផ្ទុយទៅវិញ កិច្ចព្រមព្រៀងក្តី ច្បាប់ អ.វ.ត.ក ក្តី និងវិធានផ្ទៃក្នុងក្តី មិនមានចែងអំពីគោលការណ៍ និងកត្តានានាដែលត្រូវយកមកពិចារណានៅពេលធ្វើការផ្តន្ទាទោសឡើយ។ ជាពិសេសបទដ្ឋានទាំងនេះមិនបានបញ្ជាក់ថាការផ្តន្ទាទោសនៅ អ.វ.ត.ក ត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តជាតិ ឬអន្តរជាតិ ឬក៏ត្រូវរួមបញ្ចូលគ្នានៃបទដ្ឋានគតិយុត្តទាំងពីរនេះ[៥៥៦] នោះទេ។

៥៧៦. តុលាការអន្តរជាតិនានា បានបង្កើតឯកសារណែនាំស្តីអំពីការផ្តន្ទាទោស ចំពោះបទឧក្រិដ្ឋដែលមានប្រភេទដូចគ្នា ឬស្រដៀងគ្នាទៅនឹងបទឧក្រិដ្ឋដែលអាចផ្តន្ទាទោសបានចំពោះមុខ អ.វ.ត.ក។ ប៉ុន្តែ

---

[៥៥៤] សូមមើល មាត្រា ២១ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (ទោសសម្លាប់គឺជាទោសឧក្រិដ្ឋថ្នាក់ទីបី រួមបញ្ចូលទាំងបទទារុណកម្មផងដែរ (មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦) និងប្រភេទនៃបទមនុស្សឃាតធ្ងន់ធ្ងរផ្សេងៗទៀត (មាត្រា ៥០៦ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦))។

[៥៥៥] មានតែគន្ថីទី ១ (បទបញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ប៉ុណ្ណោះដែលបានចូលជាធរមាន ។ បទបញ្ញាត្តិផ្សេងទៀតត្រូវបានប្រកាសឲ្យប្រើ ប៉ុន្តែមិនទាន់ចូលជាធរមាន។ ផ្នែកនេះចែងផងដែរថា ចំពោះបទល្មើសដែលមានលក្ខណៈស្រដៀងគ្នានេះគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

[៥៥៦] *ប្រៀបធៀប* មាត្រា២៤ នៃលក្ខន្តិកៈតុលាការ ICTY (បង្ហាញថា "ដើម្បីកំណត់អំពីអាណត្តិនៃការដាក់ពន្ធនាគារ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រើនូវការអនុវត្តជាទូទៅទាក់ទងនឹងការផ្តន្ទាទោសដាក់ពន្ធនាគារ ដែលប្រើប្រាស់សម្រាប់តុលាការអតីតប្រទេសយូហ្គោស្លាវី")។

តុលាការអន្តរជាតិទាំងនេះមិនមានការឯកភាពគ្នាលើវិធីសាស្ត្រផ្តន្ទាទោសនៅចំពោះមុខតុលាការទាំងនេះទេ។ បន្ថែមពីលើនេះ របបនៃការផ្តន្ទាទោសដែលអនុវត្តនៅតុលាការ ICTY តុលាការ ICTR និងតុលាការ SCSL ខុសគ្នាពីរបបនៃការផ្តន្ទាទោសនៅតុលាការ ICC។ ជាលទ្ធផល មិនមានរបបនៃការផ្តន្ទាទោសអន្តរជាតិតែមួយដែលអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានទេ។

៥៧៧. អង្គជំនុំជម្រះយល់ឃើញថា ដោយសារបទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើជនជាប់ចោទគឺជាបទឧក្រិដ្ឋដែលមានលក្ខណៈជាអន្តរជាតិ ហើយដោយសារមានភាពមិនច្បាស់លាស់ និងស្មុគស្មាញនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលបណ្តាលមកពីការវិវត្តនៃច្បាប់នេះចាប់តាំងពីមានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦រហូតមកនោះ[៥៥៧] បានធ្វើឲ្យមានការលំបាកក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាទាំងស្រុងក្នុងការផ្តន្ទាទោស។

៥៧៨. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកំណត់ទោស ប្រសិនបើខ្លួនយល់ឃើញថា មានយុត្តិធម៌។ ដើម្បីធ្វើដូច្នេះ អង្គជំនុំជម្រះត្រូវពិនិត្យមើលការណែនាំពីគោលការណ៍ និងកត្តានានា តាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ[៥៥៨]។

### ៣.២.២ គោលការណ៍ និងកត្តានានាដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស

៥៧៩. ដូចតុលាការព្រហ្មទណ្ឌអន្តរជាតូបនីយកម្មផ្សេងៗទៀតដែរ អ.វ.ត.ក ត្រូវបានប្រគល់អំណាចឲ្យកាត់សេចក្តីបទឧក្រិដ្ឋដែលមានទ្រង់ទ្រាយធំ ឲ្យមកជាឧក្រិដ្ឋកម្មដែលអាចផ្តន្ទាទោសជាលក្ខណៈឯកត្តបុគ្គលបាន។ ក្នុងការធ្វើដូច្នេះ តុលាការមានបំណងបង្ហាញដល់ជនរងគ្រោះដែលនៅរស់រានមានជីវិត គ្រួសាររបស់ពួកគេ សាក្សី និងសាធារណៈជនទូទៅថា ច្បាប់ត្រូវបានអនុវត្តយ៉ាងពិតប្រាកដ។

---

[៥៥៧] ភាគីនានាត្រូវបានផ្តល់នូវឱកាសឲ្យលើកឡើងនូវសេចក្តីសន្និដ្ឋានក្រោយពីការប្រកាសឲ្យប្រើនូវក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ប៉ុន្តែគ្មានភាគីណាមួយធ្វើសេចក្តីសន្និដ្ឋាននោះទេ។ *សូមមើល* "ដីកាពាក់ព័ន្ធនឹងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា" E180/1 ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។

[៥៥៨] លោកចៅក្រម LAVERGNE ជំទាស់ទៅនឹងមតិភាគច្រើននៃចៅក្រមអង្គជំនុំជម្រះទាក់ទងនិងក្រមខណ្ឌច្បាប់ចំពោះការផ្តន្ទាទោស (សូមមើលមតិជំទាស់ និងមតិដោយឡែករបស់ចៅក្រម LAVERGNE ទាក់ទងនឹងការផ្តន្ទាទោស ឯកសារ E188.1)។

បន្ថែមពីលើនេះ ដំណើរការនៃការផ្តន្ទាទោសមានគោលបំណងផ្តល់ជាសារថា ជនគ្រប់រូបដោយមិនគិតអំពីបុណ្យស័ក្តិ ឬឋានៈនោះទេ ត្រូវតែគោរពច្បាប់ និងវិធានដែលគេទទួលស្គាល់ជាសកល[៩៩៩]។

៥៨០. គោលបំណងពិតប្រាកដនៃការផ្តន្ទាទោសគឺដើម្បីដាក់ទណ្ឌកម្ម ប៉ុន្តែ មិនមែនជាការសងសឹកនោះទេ[១០០០]។ ការផ្តន្ទាទោសត្រូវតែមានលក្ខណៈឯកត្តបុគ្គល និងសមាមាត្រទៅនឹងអំពើដែលឆ្លុះ-បញ្ចាំងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ការផ្តន្ទាទោសត្រូវផ្អែកលើការវិភាគដែលមានលក្ខណៈសត្យានុម័ត មានហេតុផលសមរម្យ និងមានការថ្លឹងថ្លែងត្រឹមត្រូវ ទាំងទៅលើអំពើរបស់ជនជាប់ចោទ និងទាំងទៅលើព្យសនកម្មនានា ដែលជាផលវិបាកនៃការប្រព្រឹត្តិអំពើទាំងនោះ[១០០១]។

៥៨១. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ គោលការណ៍សមាមាត្រ និងគោលការណ៍ឯកត្តកម្មទោស គឺជាគោលការណ៍មួយចំនួនក្នុងចំណោមគោលការណ៍អន្តរជាតិនានា ដែលត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់នៃប្រទេសកម្ពុជា[១០០២]។

៥៨២. យុត្តិសាស្ត្រតុលាការអន្តរជាតិបានកំណត់ថា ស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តគឺជា "លក្ខណៈវិនិច្ឆ័យសំខាន់សម្រាប់សម្រេចអំពីទោសឱ្យបានសមស្រប"[១០០៣] ហើយតម្រូវឱ្យ "តុលាការត្រូវពិចារណាអំពីកាលៈទេសៈពិសេសនៃរឿងក្តី ព្រមទាំងទម្រង់ និងកម្រិតនៃការចូលរួម

---

[៩៩៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nikolić* សាលដីកាសម្រេចផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង ICTY (IT-94-2-S) ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ១៣៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-16-T) ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ១៦។

[១០០០] *សូមមើលឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៨៥។

[១០០១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ កថាខណ្ឌ១៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundzija* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-17/1-A) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ២៤៩។

[១០០២] *សូមមើលឧទា.* មាត្រា៣១(២) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

[១០០៣] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14/1-A) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ១៨២។

របស់ជនជាប់ចោទនៅក្នុងបទឧក្រិដ្ឋនោះ”[១០០៤]។ វិធាន១៤៥(១)(គ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងស្រដៀងគ្នាថា៖

> ត្រូវពិចារណាអំពីទំហំនៃព្យសនកម្មដែលបង្កឡើង ជាពិសេសព្យសនកម្មដែលបង្កឡើងចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេ លក្ខណៈនៃអាកប្បកិរិយាខុសច្បាប់ និងវិធីដែលត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ។ ត្រូវពិចារណាអំពីកម្រិតនៃការចូលរួមរបស់ពិរុទ្ធជន កម្រិតនៃចេតនា សភាពលក្ខណៈផ្លូវចិត្ត ពេលវេលានិងទីកន្លែង និងអាយុ ចំណេះដឹង ស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ពិរុទ្ធជន[១០០៥]។

៥៨៣. លើសពីនេះ អង្គជំនុំជម្រះនឹងពិចារណាស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសពាក់ព័ន្ធទាំងអស់ដើម្បីកំណត់ទោស។ សហព្រះរាជអាជ្ញាត្រូវបង្ហាញអំពីស្ថានទម្ងន់ទោសដូចគ្នាទៅនឹងបទដ្ឋានតម្រូវសម្រាប់ការបង្ហាញពីពិរុទ្ធភាព ហើយមានតែកាលៈទេសៈពាក់ព័ន្ធផ្ទាល់ទៅនឹងការប្រព្រឹត្តិបទ-ឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទប៉ុណ្ណោះ ដែលនឹងត្រូវបានយកមកពិចារណាជាស្ថានទម្ងន់ទោស។ ដូចនេះ នៅពេលកត្តាពិសេសណាមួយគឺជាធាតុផ្សំនៃបទឧក្រិដ្ឋជាមូលដ្ឋានហើយនោះ កត្តាពិសេសដដែលនោះមិនអាចត្រូវបានយកមកពិចារណាថាជាស្ថានទម្ងន់ទោសទៀតទេ[១០០៦]។ បន្ថែមពីលើនេះ អង្គហេតុដូចគ្នាមិនអាចយកមកប្រើប្រាស់ទាំងសម្រាប់ការបង្ហាញភាពធ្ងន់ធ្ងរនៃបទល្មើស និងស្ថានទម្ងន់នៃទោសបាននោះទេ[១០០៧]។ វិធាន១៤៥(២)(ខ) នៃវិធាននីតិវិធី និងភស្តុតាងរបស់

---

[១០០៤] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakic* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-97-24-A) ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៣៨០។

[១០០៥] វិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិលេខ PCNICC/2000/1/Add.1 (២000) វិធាន១៤៥(១)(គ)។ ស្រដៀងគ្នានេះដែរ មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ ចែងថា តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ។

[១០០៦] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ កថាខណ្ឌ២៤។

[១០០៧] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Deronjić* សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោសរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-02-61-A) ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ១០៦-១០៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay* និង

00573667



តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងនូវការណែនាំសំខាន់ៗដូចខាងក្រោម ពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស ដែលអង្គជំនុំជម្រះយកមកអនុវត្ត ក្នុងករណីមានភាពពាក់ព័ន្ធ ដើម្បីកំណត់ទោសចំពោះ កាំង ហ្កេកអ៊ាវៈ

(i) ការផ្តន្ទាទោសលើបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តពីពេលមុន ដែលបទឧក្រិដ្ឋទាំងនោះ ស្ថិតក្រោមយុត្តាធិការរបស់តុលាការ ICC ឬតុលាការមានលក្ខណៈស្រដៀងគ្នា។

(ii) ការរំលោភអំណាច ឬសមត្ថកិច្ចផ្លូវការ

(iii) ការប្រព្រឹត្តិបទល្មើសដែលជនរងគ្រោះមិនអាចការពារខ្លួនបាន

(iv) ការប្រព្រឹត្តិបទល្មើសយ៉ាងសាហាវឃោរឃៅ ឬមានជនរងគ្រោះជាច្រើន

(v) ការប្រព្រឹត្តិបទល្មើសដោយសារមានការជំរុញចិត្តដែលពាក់ព័ន្ធការរើសអើង ដោយសារមូលហេតុដែលមានចែងនៅក្នុងមាត្រា២១ កថាខណ្ឌ៣ (ពោលគឺ ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយឬទស្សនៈផ្សេងៗ ជាតិសាសន៍ដើម ជាតិពន្ធុដើម ឬសង្គមដើម ទ្រព្យសម្បត្តិ កំណើត ឬវណ្ណៈផ្សេងៗទៀត)។

(vi) ស្ថានភាពផ្សេងៗទៀត បើទោះបីជាមិនមានចែងខាងលើ ប៉ុន្តែអាស្រ័យតាមលក្ខណៈរបស់វា គឺស្រដៀងគ្នានឹងអ្វីដែលមានចែងដែរ[១០០៨]។

៥៨៤. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងទៀតបានចង្អុលបង្ហាញថា បន្ទុកនៃភស្តុតាងទាក់ទងនឹងស្ថានសម្រាលទោសចំពោះជនជាប់ចោទ គឺមានកំរិតទាបជាងអ្វីដែលត្រូវបង្ហាញចំពោះស្ថានទម្ងន់ទោស[១០០៩]។ ខុសគ្នាពីស្ថានទម្ងន់ទោស ស្ថានសម្រាលទោសអាចនឹងត្រូវយកមកពិចារណាដោយមិនគិតថាតើស្ថានសម្រាលទោសទាំងនោះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទល្មើសដែលចោទប្រកាន់ដែរ ឬ

---

*អ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០៩ កថាខណ្ឌ១៦។

[១០០៨] វិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិលេខ PCNICC/2000/1/Add.1 (២០០០) វិធាន១៤៥(១)(ខ)។

[១០០៩] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ៦៩៧។

យ៉ាងណានោះទេ[១០១០]។ វិធាន១៤៥(២)(ក) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានកំណត់ស្ថានសម្រាលទោសដូចខាងក្រោមនេះ៖

(i) កាលៈទេសៈនៃការខកខានមិនបានធ្វើយុត្តិកម្មចំពោះការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូចជាការបង្ហាញថាសមត្ថភាពខួរក្បាលមានបញ្ហាធ្ងន់ធ្ងរ ឬការបង្ខិតបង្ខំ។

(ii) អំពើរបស់ពិរុទ្ធជនក្រោយពីការប្រព្រឹត្តិបទល្មើស ដែលរួមបញ្ចូលនូវការខិតខំប្រឹងប្រែងរបស់បុគ្គលនោះដើម្បីសងសំណងដល់ជនរងគ្រោះ និងការសហការណាមួយជាមួយតុលាការ[១០១១]។

៥៨៥. ស្ថានសម្រាលទោស មានតួនាទីសំខាន់ផងដែរ ផ្អែកតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[១០១២] នៅក្នុងការសម្រេចអំពីទោស។

### ៣.២.៣ អានុភាពនៃការរកឃើញពិរុទ្ធភាពច្រើនបទនៅពេលផ្តន្ទាទោស

៥៨៦. បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនបានចង្អុលបង្ហាញថាតើអង្គជំនុំជម្រះ អាចធ្វើការផ្តន្ទាទោសសរុបរួមតែមួយ ក្រោយពីបានរកឃើញពិរុទ្ធភាពចំពោះបទល្មើសច្រើន នៅពេលដែលពិរុទ្ធភាពនីមួយៗ គឺផ្អែកលើអំពើឧក្រិដ្ឋដាច់ដោយឡែកពីគ្នារបស់ជនជាប់ចោទនោះទេ។

៥៨៧. ការអនុវត្តនៅតុលាការ Nuremberg និងតុលាការ Tokyo គឺសម្រេចធ្វើការផ្តន្ទាទោសសរុបរួមតែមួយលើបទល្មើសច្រើន ប្រសិនបើមាន។ នៅចំពោះមុខតុលាការ ICTY ICTR និង SCSL

---

[១០១០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-15-T) ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ កថាខណ្ឌ២៨។

[១០១១] វិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិលេខ PCNICC/2000/1/Add.1 (២000) វិធាន១៤៥(១)(ក)។

[១០១២] *សូមមើល* មាត្រា៩៣ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

បញ្ហានេះគឺអាស្រ័យទៅលើអង្គជំនុំជម្រះសាលាដំបូងនីមួយៗ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តន្ទាទោសសរុបរួមតែមួយលើបទឧក្រិដ្ឋច្រើនគឺជាជម្រើសល្អមួយ ដែលគេតែងតែយកមកអនុវត្តនៅក្នុងករណីដែលបទឧក្រិដ្ឋទាំងនោះត្រូវបានចាត់ទុកថា ជាប្រភេទឧក្រិដ្ឋកម្មដែលតម្រូវឲ្យមានការផ្តន្ទាទោសតែមួយប្រភេទ[១០១៣]។

៥៨៨. មាត្រា៧៨(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមចែងថា៖

> "នៅពេលដែលជនណាម្នាក់ ត្រូវបានដាក់ឲ្យជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌលើសពីមួយ តុលាការត្រូវប្រកាសទោសចំពោះបទល្មើសព្រហ្មទណ្ឌទាំងនោះមួយម្តងៗ និងទោសរួម ដែលបញ្ជាក់នូវរយៈពេលសរុបនៃទោសដាក់ពន្ធនាគារ។ រយៈពេលនេះមិនត្រូវឲ្យតិចជាងទោសខ្ពស់បំផុតក្នុងចំណោមទោសទាំងឡាយ ដែលត្រូវបានប្រកាសឡើយ ហើយមិនត្រូវលើសពីទោសពន្ធនាគារ៣០ឆ្នាំ ឬមិនមែនជាទោសដាក់ពន្ធនាគារអស់មួយជីវិត [...]"[១០១៤]។

៥៨៩. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាការអនុវត្តនៅប្រទេសកម្ពុជាមានការប្រែប្រួលទៅតាមករណីក៏ដោយ ក៏ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ចែងថា៖

> "កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង។ ប៉ុន្តែ កាលបើ

---

[១០១៣] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Ntakirutimana* សាលក្រម និងការផ្តន្ទាទោសរបស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-10 & 96-17-T) ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ៩១៧។ *សូមមើលផងដែរ* *Kambanda តទល់នឹង រដ្ឋអាជ្ញា* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR 97-23-A) ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ កថាខណ្ឌ ១០៩-១១០។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤២៩-៤៣០ ។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលក្រមប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង SCSL (SCSL-04-16-T) ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ១២។

[១០១៤] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ U.N. Doc. A/CONF.183/9th អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨ និងចូលជាធរមាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ មាត្រា៧៨(៣)។

ទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ”[១០១៥]។

៥៩០. ហេតុដូច្នេះ អង្គជំនុំជម្រះអាចប្រកាសទោសសរុបរួមតែមួយ ដែលឆ្លុះបញ្ចាំងអំពីអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន។

### ៣.២.៤ ការផ្តន្ទាទោសដែលត្រូវយកមកអនុវត្ត នៅពេលដែលទោសអតិបរមាឲ្យជាប់ពន្ធនាគារអស់មួយជីវិតមិនត្រូវបានយកមកអនុវត្ត

៥៩១. ក្របខណ្ឌច្បាប់ អ.វ.ត.ក មិនបានបញ្ជាក់អំពីទោសដាក់ពន្ធនាគារមានកំណត់ពេលជាអតិបរមាទេនៅពេលដែលការផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិតមិនត្រូវបានយកមកអនុវត្តនោះ។ តុលាការ ICTY ICTR និងSCSL យល់ថាវាគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមទាំងស្រុង ដែលចៅក្រមមានឆន្ទានុសិទ្ធិចាំបាច់ដើម្បីសម្រេចអំពីរយៈពេលនៃទោស ដើម្បីឆ្លុះបញ្ចាំងឲ្យបានល្អបំផុតអំពីការទទួលខុសត្រូវជាឯកត្តបុគ្គលរបស់ជនជាប់ចោទ។

៥៩២. ផ្ទុយមកវិញ មាត្រា៧៧(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថា៖

> [...] តុលាការអាចដាក់ទណ្ឌកម្មលើជនដែលមានពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌតាមមាត្រា៥ នៃលក្ខន្តិកៈនេះនូវទណ្ឌកម្មមួយក្នុងចំណោមទណ្ឌកម្មទាំងឡាយដូចតទៅនេះ ៖
>
> ក. ទោសជាប់ពន្ធនាគារ ដែលមានកំណត់ឆ្នាំ មិនត្រូវលើសពីអតិបរមា៣០ឆ្នាំ ឡើយ ឬ
>
> ខ. ទោសជាប់ពន្ធនាគារអស់មួយជីវិត បើត្រូវធ្វើយុត្តិកម្មដោយស្ថានទម្ងន់ដ៏ធ្ងន់នៃបទល្មើសព្រហ្មទណ្ឌ ព្រមទាំងកាលៈទេសៈឯកត្តបុគ្គលរបស់ពិរុទ្ធជន[១០១៦]។

---

[១០១៥] មាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

[១០១៦] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ U.N. Doc. A/CONF.183/9th អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ និងចូលជាធរមាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ មាត្រា៧៧(១)។

៥៩៣. អាស្រ័យហេតុនេះ តុលាការ ICC មិនបានចែងពីករណីនៃការផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី៣០ឆ្នាំ និងទោសជាប់ពន្ធនាគារអស់មួយជីវិតនោះទេ។

៥៩៤. ស្រដៀងគ្នានេះដែរ មាត្រា៩៥នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ក៏មិនមានចែងអំពីការផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងចន្លោះពី៣០ឆ្នាំទៅទោសជាប់ពន្ធនាគារអស់មួយជីវិតដែរ[១០១៧]។

៥៩៥. ឆ្លងតាមការសម្រេចដោយមតិភាគច្រើន (លោកចៅក្រម LAVERGNE ជំទាស់) និងក្រោយពីបានពិចារណាអំពីការកំណត់ទោសរវាងពី០៥ឆ្នាំ ដល់ការដាក់ពន្ធនាគារអស់មួយជីវិត ដូចមានចែងក្នុងច្បាប់របស់ អ.វ.ត.ក និង បានយល់ឃើញថា ពុំមាន គោលការណ៍ណែនាំជាអន្តរជាតិណាមួយដែលតម្រូវឲ្យប្រតិបត្តិតាមពាក់ព័ន្ធនឹងការកំណត់ទោសនេះ អង្គជំនុំជម្រះសម្រេចអនុវត្តតាមច្បាប់របស់ អ.វ.ត.ក ដែលផ្តល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះក្នុងការកំណត់រយៈពេលជាក់លាក់មួយសម្រាប់ផ្តន្ទាទោសដាក់ពន្ធនាគារ ក្នុងករណីដែលទោសដាក់ពន្ធនាគារអស់មួយជីវិតមិនអាចយកមកអនុវត្តបាន។

## ៣.៣ សំអាងហេតុ

### ៣.៣.១ ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម

៥៩៦. នៅក្នុងការថ្លឹងថ្លែងអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម សហព្រះរាជអាជ្ញាបានសន្និដ្ឋានថាអង្គជំនុំជម្រះគួរពិចារណាអំពីតួនាទីរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ផលវិបាកនៃបទឧក្រិដ្ឋចំពោះជន-

---

[១០១៧] មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ (“កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង៣០ (សាមសិប)ឆ្នាំ”)។ *សូមមើលផងដែរ* មាត្រា១៥និងមាត្រា១២៨(២) នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦។

រងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ និងកាលៈទេសៈជាឯកត្តបុគ្គលរបស់ជនជាប់ចោទ[១០១៨]។ អង្គជំនុំជម្រះយល់ស្របទៅនឹងកត្តាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការសម្រេចអំពីស្ថានទម្ងន់នៃបទ-ឧក្រិដ្ឋនេះ។

៥៩៧. អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទគឺជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានា ដែលមានលក្ខណៈសាហាវយង់ឃ្នង និងគួរឲ្យព្រឺខ្លាច។ ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ ជនជាប់ចោទបានរៀបចំចាត់ចែង និងពង្រឹងប្រព័ន្ធគ្រប់គ្រងមួយអស់រយៈពេលជាងបីឆ្នាំ ដែលបណ្តាលឲ្យមានការសម្លាប់ជីវិតមនុស្សមិនតិចជាង ១២.២៧២នាក់ ហើយភាគច្រើនក្នុងចំណោមជនរងគ្រោះទាំងនោះ ត្រូវបានគេធ្វើទារុណកម្មតាមលក្ខណៈជាប្រព័ន្ធផងដែរ។ ជនរងគ្រោះទាំងឡាយដែលមិនត្រូវបានគេសម្លាប់ ក៏បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួនដែលបានបណ្តាលឲ្យកើតជាជំងឺរាលដាលពាសពេញ ការឈឺស្គមស្គាំងដោយសារអត់អាហារ និងការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត និងការភ័យខ្លាចហួសប្រមាណ។ ជនជាប់ចោទបានធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីធានាថា មន្ទីរស២១ដំណើរការប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅ-បាន ហើយគាត់បានធ្វើដូច្នេះដើម្បីបង្ហាញពីភក្តីភាពដ៏មោះមុតចំពោះថ្នាក់លើរបស់គាត់ និងមនោគម-វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយមិនបានគិតអំពីភាពជាមនុស្សរបស់អ្នកជាប់ឃុំទាំងឡាយដែលគាត់បានមើលការខុសត្រូវនោះឡើយ។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ មន្ទីរស២១បានក្លាយទៅជាឧបករណ៍នៃការធ្វើទុក្ខបុកម្នេញដ៏មានប្រសិទ្ធភាពខ្ពស់មួយ ដែលជួយជ្រោមជ្រែងដល់ការអនុវត្តនូវគោលនយោបាយរើសអើងដោយមូលហេតុនយោបាយ។

៥៩៨. មានតែអ្នកជាប់ឃុំមួយចំនួនតូចតែប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីមន្ទីរស២១។ អ្នករស់រានមានជីវិតពីមន្ទីរស២១ដែលបានមកផ្តល់សក្ខីកម្មផ្ទាល់នៅពេលសវនាការ បានបង្ហាញពីផលវិបាកនៃឧក្រិដ្ឋកម្មដែលធ្វើឲ្យមានការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត[១០១៩]។ សាច់ញាតិ ក្រុមគ្រួសាររបស់

[១០១៨] សូមមើល "សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា" E159/9 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៣៦៨-៣៨៦។

[១០១៩] *សូមមើល ឧទាហរណ៍* (ផ្នែក២.៤.៤.១.២ ផ្នែក ២.៤.៥.១ ផ្នែក ២.៤.៥.២ និងផ្នែក ២.៤.៥.៣) ។

អ្នកជាប់ឃុំនៅមន្ទីរស២១ក៏បានផ្តល់សក្ខីកម្មអំពីទុក្ខវេទនា ភាពនិរាសព្រាត់ប្រាស ដែលជាបច្ច័យនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទមកលើក្រុមគ្រួសាររបស់ពួកគេ[១០២០]។

៥៩៩. លើសពីនេះទៀត ជនជាប់ចោទគឺជាមនុស្សដែលមានប្រាជ្ញាឈ្លាសវៃ និងមានការអប់រំ នៅពេលដែលគាត់បម្រើការងារក្នុងតួនាទីជាអនុប្រធាន និងក្រោយមកជាប្រធាន និងជាលេខាមន្ទីរស២១។ ដូច្នេះហើយគាត់បានយល់យ៉ាងច្បាស់អំពីចរិតលក្ខណៈនៃអំពើរបស់គាត់នៅពេលនោះ។

៦០០. តាមហេតុផលដូចបានបង្ហាញខាងលើ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មរបស់ជនជាប់-ចោទមានលក្ខណៈធ្ងន់ធ្ងរក្រៃលែង។

### ៣.៣.២ កត្តានានានៃស្ថានទម្ងន់ទោស

៦០១. សហព្រះរាជអាជ្ញាបានលើកអំណះអំណាងថា អង្គជំនុំជម្រះគួរពិចារណាលើកត្តាមួយចំនួននៃស្ថានទម្ងន់ទោសដូចខាងក្រោមនៅពេលសម្រេចអំពីទោស ៖ ការបំពានលើសិទ្ធិអំណាច ឬមុខនាទីជាផ្លូវការរបស់ជនជាប់ចោទ ភាពឃោរឃៅព្រៃផ្សៃនៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត ភាពគ្មានទីពឹងនៃជនរងគ្រោះ និងចេតនារើសអើងដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ[១០២១]។ អង្គជំនុំជម្រះយល់ស្របថា កត្តាទាំងនេះគឺជាប់ទាក់ទងទៅនឹងស្ថានទម្ងន់ទោសដែលអង្គជំនុំជម្រះនឹងយកមកពិចារណានៅពេលសម្រេចអំពីទោស។

---

[១០២០] សូមមើល ឧទាហរណ៍ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ (Robert HAMILL) ទំព័រ ៦៤-៧២។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (ហាវ សោភា) ទំព័រ ៣៥-៣៨។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (នេត ផល្លី) ទំព័រ ៨១-៨២។ ប្រតិចារឹក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (អង់តូនីញ៉ា ជូឡុង) ទំព័រ ១០-១២។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ (Martine LEFEUVRE) ទំព័រ ១៦-១៧, ២២-២៣, ២៧-២៩។ ប្រតិចារឹក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ (អ៊ូ សាវរិទ្ធ) ទំព័រ ៤៧-៥២។

[១០២១] "សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា" E159/9 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៣៨៨-៤០៨។

៦០២. អង្គជំនុំជម្រះយល់ឃើញថា ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ ជនជាប់ចោទបានអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ដោយការបំពាក់បំប៉នមនោគមវិជ្ជា ការបង្រៀន និងការគ្រប់គ្រងទៅលើបុគ្គលិកនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកជាប់ឃុំនៅមន្ទីរស២១។ លើសពីនេះទៀត បុគ្គលិកមន្ទីរស២១ជាច្រើនមានវ័យក្មេងៗ និងត្រូវបានបំពុលស្មារតីដោយការតម្រូវឱ្យក្មេងៗទាំងនោះប្រព្រឹត្តអំពើយ៉ាងសាហាវព្រៃផ្សៃបំផុតទៅលើអ្នកជាប់ឃុំ។ ទោះបីជាអង្គជំនុំជម្រះបានផ្តន្ទាទោសជនជាប់ចោទដោយផ្អែកតែទៅលើទម្រង់នៃការទទួលខុសត្រូវ "ដោយផ្ទាល់" របស់គាត់ចំពោះបទល្មើសជាច្រើនក៏ដោយ ក៏តួនាទីជាថ្នាក់លើរបស់ជនជាប់ចោទបានបង្កើតជាផ្នែកមួយនៃស្ថានទម្ងន់ទោសចំពោះបទល្មើសទាំងនោះដែរ[១០២២]។

៦០៣. បទឧក្រិដ្ឋជាច្រើនដែលបានប្រព្រឹត្តនៅមន្ទីរស២១ ត្រូវបានប្រព្រឹត្តដោយមានលក្ខណៈឃោរឃៅ។ អ្នកជាប់ឃុំគឺជាកម្មវត្ថុនៃការប្រើប្រាស់វិធីធ្វើទារុណកម្មដ៏ព្រៃផ្សៃ ហើយក្នុងករណីខ្លះត្រូវបានគេវាយរហូតដល់ស្លាប់។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថាចំនួនជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនេះមានមិនតិចជាង ១២.២៧៣ នាក់ឡើយ ដែលជាកត្តាមួយនៃស្ថានទម្ងន់ទោសបន្ថែមទៀត។

៦០៤. អ្នកជាប់ឃុំនៅមន្ទីរស២១ ដែលរួមមានកុមារ សហព័ទ្ធ និងសមាជិកក្រុមគ្រួសារផ្សេងទៀតរបស់អ្នកជាប់ឃុំគឺមិនមានលទ្ធភាពការពារខ្លួន ហើយងាយនឹងទទួលរងការរំលោភបំពាន។ ក្នុងអំឡុងពេលជាប់ឃុំ ការរស់នៅរបស់អ្នកជាប់ឃុំទាំងនោះគឺស្ថិតនៅក្រោមការឃាមកាមដោយរួមបញ្ចូលទាំងការកំណត់ថ្ងៃ និងវិធីសាស្ត្រនៃការសម្លាប់ផងដែរ។

៦០៥. លើកលែងតែបទល្មើសការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ចំពោះបទល្មើសការធ្វើទុក្ខបុកម្នេញនេះ ចេតនានៃការរើសអើងគឺជាធាតុផ្សំផ្នែកច្បាប់មួយដ៏សំខាន់) ចេតនារើសអើងអាចត្រូវបានពិចារណាជាស្ថានទម្ងន់ទោសក្នុងការផ្តន្ទាទោស ប្រសិនបើរកឃើញថាមានចេតនារើសអើងក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋ។ ចេតនាដូច្នេះអាចទាញចេញពីកាលៈទេសៈផ្សេងៗនៃបទឧក្រិដ្ឋដែលជនជាប់ចោទបានដឹងច្បាស់ និងបានចូលរួមប្រព្រឹត្តនៅក្នុងប្រព័ន្ធនៃការរើសអើងដោយមូល-

[១០២២] សូមមើលផ្នែក (២.៧.១០.៤)។

ហេតុនយោបាយនោះ[១០២៣]។ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ យល់ឃើញថា ជនជាប់ចោទបានប្រព្រឹត្តអំពើឧក្រិដ្ឋដោយមានចេតនារើសអើងជាក់លាក់ដោយផ្អែកទៅលើឋានៈ និងការប្រឆាំងផ្នែកនយោបាយរបស់ជនរងគ្រោះដែលត្រូវបានគេយល់ឃើញថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា (ផ្នែក២.៥.៣.១៤.៤)។ អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទល្មើសការធ្វើទុក្ខបុកម្នេញ និងយល់ឃើញថា បទល្មើសការធ្វើទុក្ខបុកម្នេញស្រូបបញ្ចូលនូវរាល់បទល្មើសផ្សេងៗទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ (ផ្នែក ២.៥.៣.១៤)។ នៅក្នុងការកំណត់អំពីទោស អង្គជំនុំជម្រះយល់ឃើញផងដែរថា ចេតនានៃការរើសអើងគឺជាធាតុផ្សំផ្លូវច្បាប់នៃការធ្វើទុក្ខបុកម្នេញ ដែលអាចយកមកពិចារណាជាស្ថានទម្ងន់ទោស ទោះបីជាចេតនានៃការរើសអើងនេះ មិនជាប់ទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសនៃការធ្វើទុក្ខបុកម្នេញ ឬមិនជាប់ទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសផ្សេងៗទៀត ដែលត្រូវបានស្រូបបញ្ចូលទៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញនោះក៏ដោយ។ ប៉ុន្តែ វាជាស្ថានទម្ងន់ទោស ចំពោះបទឧក្រិដ្ឋផ្សេងៗទៀតទាំងអស់ ដែលជនជាប់ចោទបានប្រព្រឹត្ត ទោះបីជាធាតុចេតនានៃការរើសអើងនេះពុំមែនជាធាតុផ្សំផ្លូវច្បាប់នៃបទល្មើសទាំងនោះក៏ដោយ។

### ៣.៣.៣ កត្តានានានៃស្ថានសម្រាលទោស

៦០៦. នៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន សហមេធាវីការពារក្តីអន្តរជាតិបានលើកអំណះអំណាងថា អង្គជំនុំជម្រះគួរពិចារណាអំពីស្ថានសម្រាលទោសដូចខាងក្រោម៖ អង្គហេតុដែលថាជនជាប់ចោទបានប្រព្រឹត្តទៅតាមបញ្ជារបស់ថ្នាក់លើ និងក្រោមការបង្ខិតបង្ខំ កិច្ចសហការរបស់គាត់ជាមួយ អ.វ.ត.ក វិប្បដិសារីរបស់គាត់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងនិន្នាការរបស់គាត់ចំពោះការស្តារនីតិសម្បទាឡើងវិញ[១០២៤]។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ច-

---

[១០២៣] រឿងក្តីរដ្ឋអាជ្ញាទល់នឹង *Simić និងអ្នកផ្សេងទៀត* សាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-9-T) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៥១។ សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាទល់នឹង *Blaškić* សាលដីកា របស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៦៤។

[១០២៤] ប្រតិចារឹក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ ៥៤-៥៨។

00573676



ពិភាក្សាដេញដោល សហព្រះរាជអាជ្ញាបានជំទាស់ចំពោះការលើកឡើងថាការបញ្ជារបស់ថ្នាក់លើ ឬការបង្ខិតបង្ខំគឺជាស្ថានសម្រាលទោស ប៉ុន្តែបានយល់ស្រុបថាគួរតែពិចារណាអំពីស្ថានសម្រាល-ទោសដល់ជនជាប់ចោទចំពោះកិច្ចសហការជាទូទៅ ការព្រមទទួលយកដោយអន្លើចំពោះការទទួលខុសត្រូវ វិប្បដិសារី និងផលប៉ះពាល់នៃកត្តាទាំងនេះដែលអាចមានចំពោះការផ្សះផ្សាជាតិ[១០២៥]។ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួន សហព្រះរាជអាជ្ញាបានកែប្រែនូវសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយសារតែជនជាប់ចោទបានស្នើសុំឱ្យខ្លួនរួចផុតពីបទចោទ។ ក្នុងករណីនេះ អង្គជំនុំជម្រះមិនគួរពិចារណាអំពីស្ថានសម្រាលទោសចំពោះជនជាប់ចោទនោះទេ[១០២៦]។

៦០៧. លក្ខន្តិកៈរបស់តុលាការ ICTY ICTR និង SCSL អនុញ្ញាតជាពិសេសឱ្យយកការបញ្ជារបស់ថ្នាក់លើមកពិចារណាជាស្ថានសម្រាលទោសបាន[១០២៧]។ អ្នកនៅក្រោមបង្គាប់ដែលអាចបង្ហាញឱ្យឃើញនូវអត្ថិភាពនៃបញ្ជារបស់ថ្នាក់លើ "អាចនឹងទទួលការផ្តន្ទាទោសក្នុងកំរិតស្រាលបានតែនៅក្នុងករណីដែលបង្ហាញច្បាស់ថាបញ្ជារបស់ថ្នាក់លើពិតជាអាចកាត់បន្ថយកម្រិតនៃពិរុទ្ធភាពរបស់អ្នកនៅក្រោមបង្គាប់។ ប្រសិនបើបញ្ជានោះមិនមានឥទ្ធិពលអ្វីទៅលើអាកប្បកិរិយានៃការប្រព្រឹត្តិខុសច្បាប់នោះទេ ដោយសារថាជនជាប់ចោទបានត្រៀមខ្លួនរួចជាស្រេចក្នុងការអនុវត្តបញ្ជានោះ គេមិនអាចនិយាយថាមានស្ថានសម្រាលទោសបានឡើយ"[១០២៨]។ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទខកខានមិនបានបង្ហាញថាបញ្ជារបស់ថ្នាក់លើគួរតែត្រូវបានយកមកពិចារណាជាស្ថានសម្រាលទោស នៅក្នុងកាលៈទេសៈនៃរឿងក្តីនេះទេ ដោយសារថាបទល្មើសត្រូវបានប្រព្រឹត្តក្នុងរយៈពេលមួយយ៉ាងយូរ ចំនួនជនរងគ្រោះមានច្រើននាក់ និងជនជាប់ចោទបានខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឱ្យមន្ទីរស២១ដំណើរការទៅបានយ៉ាងរលូន (ផ្នែក ២.៧.១១.១)។

---

[១០២៥] សូមមើល "សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា" E159/9 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤០៩-៤៥២។

[១០២៦] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (សហព្រះរាជអាជ្ញា) ទំព័រ ៣។

[១០២៧] សូមមើល មាត្រា ៧ (៤) នៃលក្ខន្តិកៈតុលាការ ICTY មាត្រា ៦(៤) នៃលក្ខន្តិកៈតុលាការ ICTR និងតុលាការ SCSL។

[១០២៨] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Erdemović* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-22-T) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៦ កថាខណ្ឌ ៥៣។

៦០៨. ទោះបីជាការបង្ខិតបង្ខំត្រូវបានអះអាងថាជាផ្នែកមួយនៃការបញ្ជារបស់ថ្នាក់លើក៏ដោយ គេត្រូវចាត់ទុកការបង្ខិតបង្ខំថាជាស្ថានសម្រាលទោសដាច់ដោយឡែកមួយ[១០២៩]។ ក៏ប៉ុន្តែ ស្របជាមួយគ្នានេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទខកខានមិនបានបង្ហាញថាការបង្ខិតបង្ខំគួរតែត្រូវបានយកមកពិចារណាជាស្ថានសម្រាលទោសនៅក្នុងកាលៈទេសៈនៃរឿងក្ដីនេះទេ (ផ្នែក ២.៧.១១.២)។ ទោះបីជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះផ្ដល់តម្លៃតិចតួចប៉ុណ្ណោះ ទៅលើបរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាទៅលើតំណែងជាអ្នកនៅក្រោមឱវាទគេរបស់គាត់ នៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា។

៦០៩. ទោះបីជាការស្នើសុំឱ្យរួចផុតពីបទចោទរបស់ជនជាប់ចោទបានលើកឡើងមានការយឺតយ៉ាវក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាឃើញថា កិច្ចសហការរបស់ជនជាប់ចោទជាមួយ អ.វ.ត.ក អាចចាត់ទុកជាស្ថានសម្រាលទោសមួយ[១០៣០]។ ជនជាប់ចោទបានសម្ដែងឆន្ទៈសហការជាមួយ អ.វ.ត.ក ក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងក្នុងពេលដំណើរការនីតិវិធីជំនុំជម្រះ។ គាត់បានផ្ដល់ព័ត៌មានពិស្ដារមួយចំនួនទាក់ទងនឹងតួនាទីរបស់គាត់នៅក្នុងប្រតិបត្តិការរបស់មន្ទីរស២១ និងតួនាទីរបស់គាត់នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយនៅមន្ទីរនោះ។ កិច្ចសហការរបស់ជនជាប់ចោទជាមួយ អ.វ.ត.ក ពិតជាបានជួយសម្រួលដល់ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ។ លើសពីនេះទៀត អង្គជំនុំជម្រះពិចារណាឃើញថា កិច្ចសហការរបស់គាត់បានជួយនៅក្នុងការស្វែងរកការផ្សះផ្សាជាតិ ដែលនេះជាគោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនទៀតរបស់ អ.វ.ត.ក[១០៣១]។

---

[១០២៩] សូមមើលផងដែរ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Martić* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-11-T) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៥០១។ សូមមើល ឧទាហរណ៍ វិធាន ១៤៥(២)(ក)(i) នៃវិធាននៃនីតិវិធី និងភស្តុតាង របស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ។

[១០៣០] សូមមើល វិធាន ១៤៥(២)(ក)(ii) នៃវិធាននៃនីតិវិធី និងភស្តុតាង របស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ។ សូមមើលផងដែរ វិធាន ១០១(ខ)(ii) នៃវិធាននៃនីតិវិធី និងភស្តុតាង របស់តុលាការ ICTY, ICTR និង SCSL។

[១០៣១] សូមមើល បុព្វកថានៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក (ដកស្រង់នូវសារៈសំខាន់នៃការផ្សះផ្សាជាតិ)។ ផងដែរ សូមមើល ប្រតិចារឹក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (Richard GOLDSTONE) ទំព័រ ១៨-១៩ និងប្រតិចារឹក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ (Stéphane HESSEL) ទំព័រ ៣៥-៥០ (ទាក់ទងនឹងការផ្សះផ្សាជាតិ)។

៦១០. នៅចំពោះមុខតុលាការអន្តរជាតិនានា ការបង្ហាញវិប្បដិសារីអាចត្រូវបានចាត់ទុកថាជាស្ថាន-សម្រាលទោសផងដែរ[១០៣២]។ ជនជាប់ចោទបានធ្វើការសុំទោសជាសាធារណៈជាច្រើនដង និងបានសម្តែងនូវវិប្បដិសារីចំពោះបទឧក្រិដ្ឋរបស់គាត់ក្នុងឱកាសជាច្រើន។ ប៉ុន្តែអង្គជំនុំជម្រះយល់ឃើញថា ការខកខានមិនបានបង្ហាញនូវការទទួលខុសត្រូវរបស់គាត់ឱ្យបានពេញលេញ និងដោយគ្មានលក្ខខណ្ឌ បានប៉ះពាល់ដល់ស្ថានសម្រាលទោសដែលអាចនឹងបានមកពីការសម្តែងវិប្បដិសារីរបស់គាត់។ ជាពិសេសសំណើរបស់ជនជាប់ចោទដែលបានស្នើសុំឱ្យខ្លួនរួចផុតពីបទចោទក្នុងអំឡុងពេលធ្វើសេចក្តី-សន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល បើទោះបីពីដំបូងឡើយគាត់បានទទួលស្គាល់នូវកំហុស និងបានសម្តែងនូវវិប្បដិសារីរួចហើយក៏ដោយ។

៦១១. ឧប្បនិស្ស័យនៃការស្តារនីតិសម្បទាឡើងវិញរបស់ជនជាប់ចោទ គឺអាចទទួលយកសម្រាប់ជាការពិចារណានៅពេលសម្រេចអំពីទោស[១០៣៣]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល ICTY បានផ្តល់ការណែនាំថា ការស្តារនីតិសម្បទាឡើងវិញនោះមិនមែនជាកត្តា "ដែលគួរតែផ្តល់នូវទម្ងន់ហួសហេតុពេកនោះទេ"[១០៣៤]។ អ្នកជំនាញលោកស្រី Françoise SIRONI-GUILBAUD និងលោក ការ ស៊ុនបូណាត ដែលត្រូវបានចាត់តាំងឱ្យធ្វើកោសល្យវិច័យចិត្តសាស្ត្រលើជនជាប់ចោទបានបញ្ជាក់ថាពួកគាត់ជឿថាជនជាប់ចោទអាចសម្របខ្លួន និងរួមរស់ជាថ្មីក្នុងសង្គមវិញបានដោយផ្អែកទៅលើបទពិសោធន៍កាលពីអតីតកាលរបស់គាត់ និងស្ថានភាពបច្ចុប្បន្នរបស់គាត់[១០៣៥]។ អង្គជំនុំជម្រះយល់ស្របចំពោះមតិយោបល់របស់អ្នកជំនាញទាំងពីររូបនេះ។ ហេតុដូច្នេះ

---

[១០៣២] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blaškić* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៧០៥។

[១០៣៣] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Furundžija* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-17/1-T) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ២៩១។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kayishema* និងអ្នកផ្សេងទៀត [សេចក្តីសម្រេចផ្តន្ទាទោស] របស់អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៦។

[១០៣៤] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Delalić និងអ្នកផ្សេងទៀត* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៨០៦។

[១០៣៥] សូមមើល "របាយការណ៍កោសល្យវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញលោកស្រី Françoise Sironi-Guilbaud និងលោក ការ ស៊ុនបូណាត" E3/509 ទំព័រ 66-67, ERN (ភាសាអង់គ្លេស) 00211147-00211148។ ប្រតិចារឹក

00573679



អង្គជំនុំជម្រះបានធ្វើការពិចារណាបន្តិចបន្តួចចំពោះឧប្បនិស្ស័យនៃការស្តារនីតិសម្បទាឡើងវិញរបស់ជនជាប់ចោទនៅក្នុងការធ្វើសេចក្តីសម្រេចអំពីទោស។

### ៣.៣.៤ ការវាយតម្លៃអំពីជំងឺវិលកចរិត និងជំងឺផ្លូវចិត្តរបស់ជនជាប់ចោទ

៦១២. របាយការណ៍មួយរបស់អ្នកជំនាញដែលវិភាគអំពីបុគ្គលិកលក្ខណៈ និងចិត្តសាស្ត្ររបស់ជនជាប់ចោទ បានសន្និដ្ឋានថាជនជាប់ចោទមិនមានសញ្ញាណណាមួយអំពីជំងឺវិកលចរិត ឬជំងឺផ្លូវចិត្តទេ[១០៣៦]។ នៅក្នុងការពិភាក្សាលម្អិតអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ អ្នកជំនាញបានប្រើប្រាស់នូវបទពិសោធន៍របស់ខ្លួនដែលមាន និងការវិភាគដែលមានលក្ខណៈវិទ្យាសាស្ត្រ ក៏ដូចជាកត្តាសង្គម សាសនា និងវប្បធម៌ ដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ ដែលអ្នកជំនាញយល់ថាសុទ្ធតែជាកត្តាដែលមានសារៈសំខាន់ក្នុងការវាយតម្លៃឱ្យបានលម្អិតទៅលើជនជាប់ចោទ។

៦១៣. អ្នកជំនាញបានពិពណ៌នាថាជនជាប់ចោទជា "មនុស្សដែលគោរពភារកិច្ចរបស់ខ្លួន ជាមនុស្សដែលបានទទួលរងឥទ្ធិពល និងឆ្លើយតបបានយ៉ាងល្អទៅនឹងភាពជាអ្នកដឹកនាំដ៏ពូកែ" និង"ជាមនុស្សមានភាពចាំបាច់យ៉ាងខ្លាំងចំពោះបក្ស និងមានការទទួលស្គាល់ដោយថ្នាក់លើរបស់គាត់"[១០៣៧]។ អ្នកជំនាញបានកត់សម្គាល់បន្ថែមទៀតអំពីបទពិសោធន៍របស់ជនជាប់ចោទដែលងាយនឹងទទួលយកនូវប្រព័ន្ធវប្បធម៌ខុសៗគ្នាជាបន្តបន្ទាប់ ដែលធ្វើឱ្យជនជាប់ចោទភ្ជាប់ទំនាក់ទំនងភ្លាមៗ និងស៊ីជម្រៅ

---

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (លោកស្រី Françoise SIRONI-GUILBAUD និងលោក ការ ស៊ុនបូណាត) ទំព័រ ២៤-២៥, ៦៩-៧០។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ (លោកស្រី Françoise SIRONI-GUILBAUD និងលោក ការ ស៊ុនបូណាត) ទំព័រ ១៧។

[១០៣៦] "របាយការណ៍កោសល្យវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញ Françoise SIRONI-GUILBAUD និង ការ ស៊ុនបូណាត" ឯកសារ E3/509។ របាយការណ៍នេះត្រូវបានរៀបចំទៅតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវបានបំពេញបន្ថែម ដោយការធ្វើសក្ខីកម្មរបស់អ្នកជំនាញទាំងពីរ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩) និងការធ្វើកោសល្យវិច័យបន្ថែមរបស់ជនជាប់ចោទក្នុងពេលជំនុំជម្រះ។ ជនជាប់ចោទបានសហការយ៉ាងពេញលេញ នៅក្នុងអំឡុងពេលធ្វើកោសល្យវិច័យទាំងនេះ (*ដូចជើងទំព័រខាងលើ* ទំព័រ១៦)។

[១០៣៧] ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ១៧-១៨។

ជាមួយលទ្ធិកុម្មុយនីស្តដែលរូបគាត់ពិពណ៌នាថា "ជាសណ្តាប់ធ្នាប់សង្គមជាក់ស្តែងទាំងស្រុងតែមួយគត់"[១០៣៨]។ មនោគមវិជ្ជាម៉ាក្សបានបំពេញនូវតម្រូវការរបស់គាត់ចំពោះភាពប្រាកដប្រជា ហើយក្រោយមកក៏ត្រូវបានជំនួសដោយការជឿស៊ប់ទៅលើសាសនាគ្រិស្ត ដែលជនជាប់ចោទបានពិពណ៌នាថាជា "ជម្រើសដ៏មានសុវត្ថិភាព និងជាក់ស្តែងទៅតាមស្ថានភាព"[១០៣៩]។ ក្នុងការបង្ហាញនូវអត្តសញ្ញាណលទ្ធិម៉ាក្ស ជនជាប់ចោទបានបង្ហាញនូវភាពវាងវៃ និង"ស្វាមីភក្តិដ៏មោះមុត"[១០៤០] ដោយការធ្វើឱ្យលើសពីការរំពឹងទុករបស់ថ្នាក់លើគាត់ ដើម្បីបំបាត់ចោលនូវភាពមន្ទិលសង្ស័យរបស់គាត់ដែលកើនឡើងជាលំដាប់ពាក់ព័ន្ធទៅនឹងផែនការរបស់អង្គការក្នុងការ "កម្ទេច" ខ្មាំង និងភាពភ័យខ្លាចជាប្រចាំអំពីមរណភាពរបស់គាត់[១០៤១]។

៦១៤. អ្នកជំនាញពិពណ៌នាថា ជនជាប់ចោទ ដោយគ្មានមនោសញ្ចេតនាចំពោះអ្នកដទៃ ដែលអ្នកជំនាញសន្មតថា នេះគឺជាលទ្ធផលមួយផ្នែកនៃដំណើរការបំពាក់បំប៉ន ឬ"ការកសាងសង្គមថ្មី" ដែលបង្កើតឡើងដោយខ្មែរក្រហមក្នុងគោលបំណងដើម្បីលុបបំបាត់ចោលនូវមនោសញ្ចេតនា និងដើម្បីលើកកម្ពស់ភាពម្ចាស់ការខ្លួនឯង[១០៤២]។ អ្នកជំនាញបានកត់សម្គាល់ផងដែរថា ជនជាប់ចោទអាច

---

[១០៣៨] "ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ១៧-១៨។

[១០៣៩] "ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ១៩។

[១០៤០] ប្រតិចារឹក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៣, ៣៥ (រៀបរាប់ពីឥទ្ធិពលនៃការតាំងចិត្តរបស់គាត់ចំពោះបដិវត្តន៍លើទស្សនៈរបស់គាត់ចំពោះគ្រួសារគាត់ និងកត់សម្គាល់ថាជាផលវិបាក រូបគាត់ត្រូវចាត់ទុកមាតាបិតារបស់គាត់ជា "បុគ្គលម្នាក់ ជាគ្រួសារមួយដែលជាកម្មសិទ្ធិរបស់បក្ស" ហើយកូនរបស់គាត់ជា "កូនរបស់អង្គការ" ដែល "ត្រូវថ្នាក់ថ្នមវាដើម្បីបម្រើបដិវត្តន៍")។

[១០៤១] "ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ១៨-១៩។ (កត់សម្គាល់ថា ការដកហូតភាពជាមនុស្សជាតិរបស់ជនរងគ្រោះ ចាំបាច់ត្រូវមានការដកហូតភាពជាមនុស្សរបស់ពេជ្ឈឃាដផងដែរ ដោយដកហូតពីពួកគាត់នូវមនោសញ្ចេតនាផ្ទាល់ខ្លួន ឬជាបុគ្គល និងដាក់ជំនួសវិញនូវមនោសញ្ចេតនាផ្នែកនយោបាយ ដែលអង្គការអាចកេងយកផលប្រយោជន៍ និងអាចត្រួតត្រាបាន)។

[១០៤២] "ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ២២-២៣, ៣១-៣២។ *សូមមើលផងដែរ* "របាយការណ៍កោសល្យវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញ Françoise SIRONI-

បង្កើតនូវយន្តការការពារដ៏រឹងមាំដែលជួយទប់ទល់គាត់មិនឲ្យមានប្រតិកម្មផ្លូវអារម្មណ៍ និងការប៉ះទង្គិចខាងក្នុងខ្លួនដែលបណ្តាលមកពីតថភាពខាងក្រៅរបស់គាត់។ អ្នកជំនាញពិពណ៌នាបន្ថែមទៀតថា នេះគឺជាយន្តការដែលជាមូលដ្ឋានអាចឲ្យជនជាប់ចោទអាចចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គាត់ ដោយមិនមានការខ្វាយខ្វល់អំពីសេចក្តីស្លាប់របស់កុមារនៅមន្ទីរស២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់នោះទេ[១០៤៣]។

៦១៥. អ្នកជំនាញបានពិពណ៌នាបន្ថែមទៀតថា ជនជាប់ចោទជាមនុស្សវៃឆ្លាត មានការចងចាំបានល្អ ព្រមទាំងមានការប្រយ័ត្នប្រយែង ម៉ឺងម៉ាត់ មានភាពល្អិតល្អន់ និងជាមនុស្សងប់ងល់នឹងការងារ។ ទាំងអស់នេះសុទ្ធតែជាលក្ខណៈសម្បត្តិ ដែលបានបង្ហាញឲ្យអង្គជំនុំជម្រះបានឃើញនៅក្នុងអំឡុងពេលសវនាការ។ អ្នកជំនាញក៏បានដឹងផងដែរ និងបានវាយតម្លៃជាវិជ្ជមាននូវសមត្ថភាពដ៏ចំណានរបស់ជនជាប់ចោទចំពោះការត្រួតពិនិត្យលើខ្លួនឯងទាក់ទងទៅនឹងជីវិត និងសកម្មភាពរបស់គាត់តាំងពីពេលស៊ើបអង្កេត រហូតដល់ដំណើរការជំនុំជម្រះ[១០៤៤]។

៦១៦. អង្គជំនុំជម្រះទទួលយកនូវសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ និងយល់ឃើញថាជនជាប់ចោទមិនមានជំងឺវិកលចរិត ឬជំងឺផ្លូវចិត្តអ្វីឡើយ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់។ អង្គជំនុំជម្រះទទួលយកនូវការវាយតម្លៃរបស់អ្នកជំនាញអំពីសមត្ថភាពរបស់ជនជាប់ចោទក្នុងការស្តារនីតិសម្បទា និងអាចរួមរស់នៅក្នុងសង្គមសាជាថ្មីឡើងវិញ[១០៤៥]។ អង្គជំនុំជម្រះយល់ស្របទៅនឹងការវាយតម្លៃរបស់អ្នកជំនាញដែលថាជនជាប់ចោទជាបុគ្គលវៃឆ្លាត មានចំណេះដឹង និងមានរបៀបរៀប

---

GUILBAUD និង ការ ស៊ុនបូណាត) ឯកសារ E3/509 ទំព័រ ៥៤-៥៦, ៧២-៧៤, ៩៨-៩៩ ERN (ភាសាខ្មែរ) 00210099-00211001, 00211017-00211019, 00211043-00211044។

[១០៤៣] "បាយការណ៍កោសល្យវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញ Françoise SIRONI-GUILBAUD និង ការ ស៊ុនបូណាត ឯកសារ E3/509" ទំព័រ៧១-៧២ និង៧៣-៧៤ (ភាសាខ្មែរ) 00211016-00211017 និង 00211018-00241019 ។

[១០៤៤] ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ១៣ (កត់សម្គាល់ ការវាយតម្លៃលើជនជាប់ចោទអំពីជម្រើសរបស់គាត់ថាជាជម្រើសត្រឹមត្រូវនៅពេលនោះ ប៉ុន្តែកត់សម្គាល់នូវ "ការព្យាយាមដកខ្លួនរបស់គាត់ចេញពីសកម្មភាពរបស់គាត់កាលពីអតីតកាល")។

[១០៤៥] ប្រតិចារឹក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ (ការ ស៊ុនបូណាត និង Françoise SIRONI-GUILBAUD) ទំព័រ២៤-២៥។ (កត់សម្គាល់ផងដែរនូវ សមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបទពិសោធន៍ជីវិត)។

វយ ដែលគាត់បានសំដែងឲ្យអង្គជំនុំជម្រះពេញចិត្ត ក៏ដូចជាធ្វើឲ្យជនរងគ្រោះស្ងប់អារម្មណ៍ចំពោះអំពើរបស់គាត់។ ទោះបីជាការស្នើសុំឲ្យរួចផុតពីបទចោទរបស់ជនជាប់ចោទបានលើកឡើងមានការយឺតយ៉ាវក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទបានដឹងយ៉ាងច្បាស់ អំពីការទទួលខុសត្រូវរបស់គាត់ចំពោះការឃើចាប់ និងការស្លាប់របស់ប្រជាជនស្លូតត្រង់រាប់ពាន់នាក់នៅមន្ទីរស២១ និងស្ថានទម្ងន់ដ៏ធ្ងន់ធ្ងរបំផុតនៃការចូលរួម និងការដឹកនាំរបស់គាត់នៅមន្ទីរស២១។

៣.៣.៥ សាក្សីអំពីអត្តចរិតរបស់ជនជាប់ចោទ

៦១៧. សាក្សីបានមកផ្តល់សក្ខីកម្មនៅពេលសវនាការ ចំពោះអ្វីដែលពួកគាត់ធ្លាប់បានស្គាល់អំពីអត្តចរិត និងអាកប្បកិរិយារបស់ជនជាប់ចោទ នៅមុនពេល និងក្រោយពេលនៃការកើតឡើងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ។

៦១៨. បើតាមសាក្សីឈ្មោះ ស៊ូ សាត ដែលជាអតីតមិត្តរួមថ្នាក់របស់ជនជាប់ចោទនៅវិទ្យាល័យកំពង់ធំ ក្នុងអំឡុងឆ្នាំសិក្សា ១៩៥៩-១៩៦០ និង ១៩៦០-១៩៦១ ជនជាប់ចោទគឺជាយុវជនម្នាក់ដែលមានអត្តចរិតស្លូតបូត សុភាពរាបសា រួសរាយ ត្រឹមត្រូវ ស្មោះត្រង់ ជាសិស្សពូកែ ដែលមានការគោរពចំពោះលោកគ្រូអ្នកគ្រូ ចូលចិត្តចែករំលែកចំណេះដឹង និងចេះជួយយកអាសាមិត្តរួមថ្នាក់។ នៅសម័យនោះ ជនជាប់ចោទមិនបានបង្ហាញឲ្យឃើញថា គាត់មានជំនក់ចិត្តចំពោះមនោគមន៍វិជ្ជានយោបាយណាមួយទេ[១០៤៦]។

៦១៩. នៅឆ្នាំ១៩៦៥ បន្ទាប់ពីបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិគរុកោសល្យ ជនជាប់ចោទត្រូវបានតែងតាំងជាគ្រូបង្រៀនគណិតវិទ្យានៅអនុវិទ្យាល័យស្គន់។ សិស្សពីររូបក្នុងចំណោមសិស្សរបស់គាត់ ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៦៨ ឈ្មោះ ទេព សែម និង ទេព សុខ បានពិពណ៌នាថា ជនជាប់ចោទគឺជាគ្រូបង្រៀនគំរូម្នាក់ដែលហ្មត់ចត់ក្នុងការងារ ជាមនុស្សម្នាក់ដែលរួសរាយ តស៊ូព្យាយាម ជួយយកអាសាជនក្រលំបាកជានិច្ច ព្រមទាំងទទួលបានការស្រឡាញ់ចូលចិត្ត និងការគោរពពីសំណាក់សិស្សរបស់គាត់។ សេចក្តីសប្បុរសរបស់គាត់បានជំរុញឲ្យគាត់បង្រៀនបន្ថែមដោយឥត

[១០៤៦] កំណត់ហេតុសវនាការ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ (ស៊ូ សាត) ទំព័រទី២៥ ដល់ ៣៦។

គិតថ្លៃដល់សិស្សទីទ័លក្របំផុត ព្រមទាំងបរិច្ចាគនូវសៀវភៅនិងសម្ភារៈសិក្សានានាដល់សិស្សដែលមានការខ្វះខាតខ្លាំងផងដែរ[១០៤៧]។

៦២០. សាក្សីឈ្មោះ ជូ វិន ហ៊ុន ស្មៀន និង ប៉េង ពាន់ ដែលបានស្គាល់ជនជាប់ចោទកាលពីពេលដែលជនជាប់ចោទបំពេញការងារជាគ្រូបង្រៀននៅផ្ដាំ បន្ទាប់មកនៅស្វាយចេកក្នុងអំឡុងទស្សវត្សរ៍ឆ្នាំ៦០ ដែលកាលនោះជនជាប់ចោទបានក្លែងឈ្មោះថា ហង្ស ពិន បានប្រាប់អង្គជំនុំជម្រះថា ពួកគាត់នៅចងចាំបានអំពីមនុស្សម្នាក់ ដែលពួកគាត់មានការស្រឡាញ់ចូលចិត្ត ហើយដែលមនុស្សម្នាក់នោះគឺជាគ្រូបង្រៀនម្នាក់ដែលមានការតស៊ូ មានសមត្ថភាព ឧស្សាហ៍ព្យាយាម និងមានភាពហ្មត់ចត់ក្នុងការងារ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន មានចរិតស្លូតបូត និងចូលចិត្តភាពឯកោ។ សាក្សីទាំងនេះបានបញ្ជាក់ក្រោយជនជាប់ចោទត្រូវបានចាប់ខ្លួនថា ពួកគាត់មានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលដឹងថាជនជាប់ចោទជាមេដឹកនាំប្រតិបត្តិការនានាដែលបានប្រព្រឹត្តនៅមន្ទីរស២១[១០៤៨]។

៦២១. ទាក់ទងដល់ការចូលកាន់សាសនាប្រូតេស្តង់របស់ខ្លួន ជនជាប់ចោទបានបញ្ជាក់ថា នេះគឺជាដំណាក់កាលទីបីក្នុងជីវិតរបស់គាត់។ ដំណាក់កាលទីមួយ គឺជាដំណាក់កាលនៃការសិក្សា ការប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន និង"ការស្រឡាញ់នូវគម្រិះវិជ្ជា"។ ដំណាក់កាលទីពីរ គឺជាដំណាក់កាលនៃការចូលប្រឡូកក្នុងនយោបាយ និង"ការស្រឡាញ់ចំពោះមនុស្សជាតិ" ហើយដំណាក់កាលចុងក្រោយនេះគឺជាដំណាក់កាលនៃការប្រកាន់ជំនឿចំពោះគ្រិស្តសាសនា និង"ការស្រឡាញ់ចំពោះព្រះជាម្ចាស់"[១០៤៩]។ គ្រូគង្វាល Christopher LAPEL បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អំពីសារៈសំខាន់និងភាពស្មោះស្ម័គ្រអស់ពីដួងចិត្តរបស់ជនជាប់ចោទក្នុងការប្រណិប័តន៍គ្រិស្តសាសនា។ គ្រូគង្វាល

---

[១០៤៧] កំណត់ហេតុសវនាការ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ (ទេព សែម) ទំព័រទី៣៣ ដល់ ៤៣ និងពី ៤៨ ដល់ ៥០ ។ កំណត់ហេតុសវនាការ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ (ទេព សុក) ទំព័រទី៥១ ដល់ ៦៦។

[១០៤៨] កំណត់ហេតុសវនាការ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ (ជូ វិន) ទំព័រទី៦៧ ដល់ ៨៨។ កំណត់ហេតុសវនាការ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ (ហ៊ុន ស្មៀន) ទំព័រទី៣ ដល់ ១៥។ កំណត់ហេតុសវនាការ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ (ប៉េង ពាន់) ទំព័រទី១៦ ដល់៣២។

[១០៤៩] កំណត់ហេតុវិភាគចិត្តសាស្ត្ររបស់អ្នកជំនាញ François Sironi-Guilbaud និង កា ស៊ុនបូណាត។ ឯកសារលេខ E3/509 ទំព័រ៨៣ និង៨៦ ERN 00211028-00211031។

រូបនោះបានទទួលស្គាល់ថា លោកបានជួបជនជាប់ចោទជាលើកដំបូងនៅខេត្តបាត់ដំបងក្នុងខែធ្នូ ឆ្នាំ ១៩៩៥ ដែលកាលនោះ ជនជាប់ចោទមានឈ្មោះថា ហង់ ពិន។ គាត់បានបញ្ជាក់ទៀតថា ជនជាប់-ចោទបានធ្វើពិធីលាងបាបបែបគ្រិស្តសាសនានៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៦ ហើយថាបន្ទាប់ពីបានរៀនធម៌វិន័យអស់រយៈពេលពីរសប្តាហ៍មកជនជាប់ចោទបានវិលត្រលប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ ដែលនៅទីនោះ ជនជាប់ចោទមានភារកិច្ចជាអ្នកផ្សព្វផ្សាយសាសនា ដោយមើលការខុសត្រូវទៅលើសហគមន៍មួយមាន១៤ គ្រួសារ។ លោកគ្រូគង្វាលក៏បានបញ្ជាក់ថែមទៀតថា ការចូលកាន់សាសនាគ្រិស្តនោះគឺធ្វើឡើងដោយគ្មានការបង្ខិតបង្ខំទេ ដោយលោកបានបញ្ជាក់ក្នុងសក្ខីកម្មរបស់លោកថា ជនជាប់ចោទគឺជាមនុស្សម្នាក់ដែលមាន “ចិត្ត ជួយយកអាសាដល់អ្នកដទៃ” និងមានបំណងមុតមាំចង់ “ចែករំលែកបន្ទូលរបស់ព្រះជាម្ចាស់”។ ជាទីបញ្ចប់ សាក្សីបានបន្ថែមទៀតថា គាត់មានមោទនភាពជាខ្លាំង ដែលជនជាប់ចោទបានទទួលស្គាល់អំពើឧក្រិដ្ឋដែលគាត់បានប្រព្រឹត្ត និងព្រមទទួលយកការដាក់ទណ្ឌកម្មលើរូបគាត់[១០៥០]។

៦២២. អង្គជំនុំជម្រះសន្និដ្ឋានថា នៅក្នុងជីវិតរបស់ជនជាប់ចោទ មុននឹងក្លាយខ្លួនទៅជាប្រធានម១៣ និងក្រោយមកជាប្រធានមន្ទីរស២១ ជនជាប់ចោទគឺជាសិស្សម្នាក់ បន្ទាប់មកជាគ្រូបង្រៀនម្នាក់ ដែលទទួលបាននូវការគោរពឲ្យតម្លៃពីសង្គម ហើយក៏ជាអ្នកដែលបានត្រៀមខ្លួនជានិច្ចក្នុងការជួយមិត្តរួមថ្នាក់ ក៏ដូចជាជួយសិស្សរបស់ខ្លួនដែរ។ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទបានបង្ហាញអំពីការភ្ជាប់ខ្លួនជានិច្ចទៅនឹងការងារ ជាមួយនឹងការតាំងចិត្តដ៏មោះមុត មិនត្រឹមតែក្នុងការសិក្សា និងក្នុងវិជ្ជាជីវៈជាគ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងជំនឿ នយោបាយ និងសាសនា ទៀតផង។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា មិនមានកត្តាណាមួយនៅក្នុងជីវិតគ្រួសារ និងជីវិតវិជ្ជាជីវៈរបស់គាត់ ដែលលុបលាងចំពោះអំពើឧក្រិដ្ឋរបស់គាត់បាននោះទេ ទោះក្នុងករណីណាក៏ដោយ។

[១០៥០] កំណត់ហេតុសវនាការ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ (Christopher LAPEL) ទំព័រទី១ ដល់ ២៤។

### ៣.៣.៦ បច្ច័យនៃការរំលោភសិទ្ធិរបស់ជនជាប់ចោទពីពេលមុននៅពេលសម្រេចអំពីទោស

៦២៣. ជនជាប់ចោទត្រូវបានឃុំខ្លួនជាបន្តបន្ទាប់ ចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ បន្ទាប់ពីគាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយតុលាការយោធាកម្ពុជាក្រោមបទចោទប្រកាន់ជាច្រើន អនុលោមតាមច្បាប់កម្ពុជា។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយយោងតាមដីការបស់សហចៅក្រមស៊ើប-អង្កេត ជនជាប់ចោទត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ជាកន្លែងដែលគាត់ត្រូវបានឃុំខ្លួនរហូតមកដល់ពេលនេះ[១០៥១]។

៦២៤. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលសម្រេចថា ប្រសិនបើរកឃើញថាមានពិរុទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលគាត់ត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។ លើសពីនេះ អង្គជំនុំជម្រះរកឃើញថាការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ គឺជាការឃុំខ្លួនដែលមានកំហុសក្នុងការអនុវត្តច្បាប់នីតិវិធី និងរំលោភលើសិទ្ធិរបស់ជនជាប់-ចោទក្នុងការទទួលបាននូវការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប និងការឃុំខ្លួនត្រឹមត្រូវផ្អែកតាមបញ្ញត្តិច្បាប់។ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព នោះគាត់មានសិទ្ធិទទួលបាននូវការកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសចំពោះគាត់ ដែលត្រូវសម្រេចនៅដំណាក់កាលនៃការផ្តន្ទាទោស ចំពោះការរំលោភលើសិទ្ធិទាំងនេះ[១០៥២] ។

៦២៥. មិនមានការបង្កើតរូបមន្តដែលកម្រិតចំនួនឆ្នាំ សម្រាប់ការកាត់បន្ថយទោសជនជាប់ចោទនោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការ ICTR បានផ្តល់នូវការណែនាំ

---

[១០៥១] សូមមើល "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ" E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ២-៥ (ប្រវត្តិនីតិវិធី)

[១០៥២] "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ" E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។

ខ្លះៗចំពោះបញ្ហានេះ[១០៥៣]។ លើសពីនេះ អង្គជំនុំជម្រះពិចារណាឃើញថា ការកាត់បន្ថយរយៈពេលត្រូវតែ "កំណត់ឱ្យបានច្បាស់លាស់"[១០៥៤] ហើយត្រូវផ្អែកទៅលើកាលៈទេសៈទាំងអស់នៃរឿងក្ដី។

៦២៦. នៅក្នុងករណីនៃរឿងក្ដីនេះ ជនជាប់ចោទត្រូវបានឃុំខ្លួនដោយខុសច្បាប់នីតិវិធី ដោយតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជាអស់រយៈពេលជាង០៨ឆ្នាំ ជារយៈពេលមួយវែងជាងរយៈពេលឃុំខ្លួនបណ្ដោះអាសន្នដែលច្បាប់បានកំណត់។ នេះហាក់បីដូចជាបង្ហាញថាមិនមានការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ឡើយក្នុងអំឡុងពេលដែលជនជាប់ចោទជាប់ឃុំតាមការចោទប្រកាន់នានាមកលើរូបគាត់ ហើយចំណែកការបន្តឃុំខ្លួនក៏មិនមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ដែរ។ នៅក្នុងករណីខ្លះ ការពន្យារចិរវេលានៃការឃុំខ្លួនជនជាប់ចោទត្រូវបានបង្គាប់បញ្ជាដោយព្រះរាជអាជ្ញាជាជាងស្ថាប័នតុលាការដែលមានសមត្ថកិច្ច[១០៥៥]។

៦២៧. ទាំងស្ថានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលគាត់ជាប់សង្ស័យ ទាំងឧបសគ្គនៃប្រព័ន្ធច្បាប់កម្ពុជាដែលដំណើរការនៅពេលនោះគឺមិនអាចធ្វើជាយុត្តិកម្មចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទបាននោះទេ។ តាមសំអាងហេតុខាងលើនេះ (លោកចៅក្រម LAVERGNE ជំទាស់ទៅនឹងមតិភាគច្រើននៃចៅក្រមអង្គជំនុំជម្រះទាក់ទងនិងក្រមខណ្ឌច្បាប់ចំពោះការផ្ដន្ទាទោស) អង្គជំនុំជម្រះសម្រេច-

---

[១០៥៣] សូមមើលរឿងក្ដី រដ្ឋអាជ្ញា ទល់នឹង *Barayagwiza និងអ្នកផ្សេងទៀត* សាលក្រម និងការផ្ដន្ទាទោសរបស់អង្គជំនុំជម្រះ សាលាដំបូង ICTR (ICTR-99-52-T) ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ១១០៦-១១០៧។ រឿងក្ដី *Semanza ទល់នឹង* រដ្ឋអាជ្ញា សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-97-20-A) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៣២៣-៣២៨។ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Kajelijeli* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល (ICTR-98-44A-A) ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៣២៤។

[១០៥៤] សូមមើលរឿងក្ដី *Beck ទល់នឹង* ប្រទេសណ័រវេ សេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (លេខ 26390/95) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ២៧។ រឿងក្ដី *Chraidi ទល់នឹង* ប្រទេសអាល្លឺម៉ង់ សេចក្ដីសម្រេចរបស់តុលាការ ECtHR (លេខ 65655/01) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ កថាខណ្ឌ ២៤-២៥។ រឿងក្ដី *Dzelili* ទល់នឹងប្រទេសអាល្លឺម៉ង់ សេចក្ដីសម្រេចរបស់តុលាការ ECtHR (លេខ 65745/01) ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ៨៣-៨៥។

[១០៥៥] សូមមើល "សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ" E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ ១៨-២១។

ថា ការកាត់បន្ថយទោសរយៈពេល ០៥ ឆ្នាំ ពីទោសដែលត្រូវផ្តន្ទាលើជនជាប់ចោទ គឺសំណង សមរម្យហើយ។

### ៣.៣.៧ ការកំណត់ទោស

#### ៣.៣.៧.១ ទោសជាប់ពន្ធនាគារ

៦២៨. ដើម្បីកំណត់ទោសមួយឲ្យបានសមស្រប អង្គជំនុំជម្រះបានពិចារណានូវកាលៈទេសៈទាំងអស់ នៃរឿងក្តីនេះ រួមទាំងគោលការណ៍នៃការផ្តន្ទាទោសដែលពាក់ព័ន្ធ និងកត្តាទាំងអស់ដែលបានពិភាក្សាពីមុននេះ។

៦២៩. អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានជាឯកច្ឆន្ទថា ពិតជាមានស្ថានសម្រាលទោសដែលអនុញ្ញាតឲ្យ អង្គជំនុំជម្រះ កំណត់ទោសដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ជាក់លាក់មួយបាន ក្នុងករណីដែលទោសដាក់ពន្ធនាគារអស់មួយជីវិតមិនត្រូវយកមកអនុវត្តនោះ។ ស្ថានសម្រាលទោសទាំងនេះមានដូចជា៖ កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ការសម្តែងវិប្បដិសារីរបស់ខ្លួន (ទោះបីជាត្រូវកាត់បន្ថយនូវការសម្រាលដោយសារគាត់បានស្នើសុំឲ្យរួចផុតពីការចោទប្រកាន់លើរូបគាត់ នៅក្នុងសម្តីចុងក្រោយរបស់គាត់យ៉ាងណាក្តី) បរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់បានបំពេញការងារ និងសក្តានុពលដែលអាចស្តារនីតិសម្បទាបានរបស់គាត់។

៦៣០. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមផងដែរ លើស្ថានទម្ងន់ទោសជាច្រើន រួមទាំងលក្ខណៈនៃបទល្មើសដែលគួរឲ្យតក់ស្លុតរន្ធត់យ៉ាងខ្លាំង និងសាហាវយង់ឃ្នងដែលត្រូវបានប្រព្រឹត្តមកលើជនរងគ្រោះយ៉ាងតិច ១២.២៧៣ នាក់ ក្នុងរយៈពេលដែលបានអូសបន្លាយយ៉ាងយូរ។ នៅពេលធ្វើការពិចារណារួមគ្នាទាំងមូល កត្តាទាំងអស់នេះអាចឲ្យអង្គជំនុំជម្រះកំណត់រយៈពេលមួយជាក់លាក់សម្រាប់ផ្តន្ទាទោសដាក់ពន្ធនាគារបាន។

៦៣១. តាមមូលដ្ឋានដូចបានរៀបរាប់ខាងលើ មតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះ (លោកចៅក្រម Lavergne ជំទាស់) សម្រេចកំណត់រយៈពេលដាក់ពន្ធនាគារចំនួន៣៥ ឆ្នាំ[១០៥៦]។

៦៣២. អង្គជំនុំជម្រះយល់ឃើញថា ការកាត់បន្ថយទោសចំនួន ០៥ ឆ្នាំ ពីទោសដែលបានកំណត់ខាងលើនេះ គឺជាការផ្តល់ជូនដ៏សមរម្យចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការឃុំខ្លួនគាត់ដោយខុសនីតិវិធីច្បាប់ដោយតុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៦៣៣. ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលគាត់ត្រូវបានជាប់ឃុំកន្លងមក[១០៥៧] ដូចខាងក្រោម៖

ក. ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ *ពោលគឺ* រយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា។

ខ. ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់ថ្ងៃសាលក្រមចូលជាស្ថាពរ *ពោលគឺ* រយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក។

### ៣.៣.៧.២ ការរឹបអូសទ្រព្យសម្បត្តិរបស់ជនជាប់ចោទ

៦៣៤. អង្គជំនុំជម្រះបានទទួលស្គាល់ថា ជនជាប់ចោទពុំមានទ្រព្យសម្បត្តិ ប្រាក់កាស ឬអចលនទ្រព្យផ្ទាល់ខ្លួនដែលទទួលបានដោយខុសច្បាប់ ឬដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋឡើយ។ ដូច្នេះ ពុំមានទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូស ស្របតាមមាត្រា៣៩ ថ្មី នៃច្បាប់ អ.វ.ត.ក ទេ[១០៥៨]។

---

[១០៥៦] សូមមើលមតិជំទាស់ និងមតិដោយឡែករបស់ចៅក្រម LAVERGNE ទាក់ទងនឹងការផ្តន្ទាទោស ឯកសារ E188.1។

[១០៥៧] សូមមើល "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។

## ៤. សំណងរដ្ឋប្បវេណី

៦៣៥. វិធាន១០០(១) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះត្រូវសម្រេចអំពីភាពដែលអាចទទួលយកបាន និងខ្លឹមសារនៃការទាមទារចំពោះជនជាប់ចោទ"។ ចាប់តាំងពីការចាប់ផ្តើមការជំនុំជម្រះ បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងដែលចែងទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើវិសោធនកម្មជាច្រើនដង[១០៥៩]។ វិសោធនកម្មទាំងនេះ មានគោលបំណងមួយក្នុងចំណោមគោលបំណងនានា គឺដើម្បីធានាថាដំណើរការនីតិវិធី អ.វ.ត.ក អនុញ្ញាតឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីសាធារណជន ទាក់ទងនឹងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំៗ និងសមស្របជាមួយបរិបទនៅក្នុងប្រទេសកម្ពុជា[១០៦០]។ ដោយសារតែដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០១ បានចាប់ផ្តើមមុនពេលធ្វើវិសោធនកម្មវិធានទាំងនេះ ដូចនេះបទប្បញ្ញត្តិដែលត្រូវបានធ្វើវិសោធនកម្មទាំងនេះមិនអាចយកមកអនុវត្តនៅក្នុងរឿងក្តីនេះបានទេ[១០៦១]។

---

[១០៥៨] សូមមើល "ការសាកសួរអំពីប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់ជនជាប់ចោទ" E175 ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨។

[១០៥៩] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី៤) ដែលប្រកាសឱ្យប្រើនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ និងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី៥) ដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ (http://www.eccc.gov.kh/khmer/internal_rules.aspx)។

[១០៦០] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ដែលបានចេញផ្សាយនៅពេលបញ្ចប់កិច្ចប្រជុំពេញអង្គ អ.វ.ត.ក លើកទី៦ (http://www.eccc.gov.kh/english/cabinet/press/131/ECCC_Plenary_11_Sep_2009_Eng.pdf)។

[១០៦១] វិធាន១១៤(៣) នៃវិធានផ្ទៃក្នុង ដែលត្រូវបានអនុម័តនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចែងថា "វិសោធនកម្មទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំពេញអង្គលើកទី៧នេះ នឹងត្រូវអនុវត្តចំពោះសំណុំរឿងរបស់ អ.វ.ត.ក ដែលមកត្រឹមថ្ងៃអនុម័តនេះ មិនទាន់មានដីកាដំណោះស្រាយ"។ ប្រសិនបើមិនមានចែងផ្ទុយពីនេះ ឯកសារយោងទាំងអស់ក្នុងផ្នែកនេះនៃវិធានផ្ទៃក្នុង ត្រូវជាប់ទាក់ទងនឹងវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។

## ៤.១ ប្រវត្តិនីតិវិធី

៦៣៦. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចជាបឋមថា អាចទទួលយកបាននៅពេលពាក្យសុំនោះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបំពេញ[១០៦២]។ ជាទូទៅ ដោយផ្អែកតាមការអនុវត្តរបស់តុលាការអន្តរជាតិស្រដៀងគ្នានេះ អង្គជំនុំជម្រះបានធ្វើការវាយតម្លៃលើសេចក្តីបញ្ជាក់ដំបូងអំពីការជឿជាក់លើព័ត៌មាន ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ឲ្យ[១០៦៣]។ នីតិវិធីនៃការសម្រេចទទួលយកពាក្យសុំបែបនេះមានលក្ខណៈខុសគ្នាពីការសម្រេចរបស់អង្គជំនុំជម្រះ ដែលសម្រេចលើអង្គសេចក្តីនៃពាក្យសុំទាំង-

[១០៦២] *សូមមើល* "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារ E2/94 ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ (យល់ឃើញថា ការបញ្ជាក់អត្តសញ្ញាណ ត្រូវតែច្បាស់លាស់ ហើយការបញ្ជាក់អត្តសញ្ញាណនេះនឹងត្រូវចាត់ទុកថាមិនគ្រប់គ្រាន់ ប្រសិនបើព័ត៌មានដែលផ្តល់ឲ្យគ្រាន់តែត្រឹមត្រូវដោយផ្អែកលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលជំនុំជម្រះនោះ)។ អនុលោមតាមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចអំពីភាពមិនអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលនេះ ដែលសេចក្តីសម្រេចនេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ (វិធាន១០៤(៤)(ឃ))។

[១០៦៣] *សូមមើលឧទា.* វិធាន៨៦ នៃវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសឡេប៉ាណន់ (នៅក្នុងការសម្រេចថាតើជនរងគ្រោះម្នាក់អាចចូលរួមនៅក្នុងដំណើរការនីតិវិធី អង្គបុរេជំនុំជម្រះត្រូវពិចារណា [...] ថាតើអ្នកដាក់ពាក្យសុំបានផ្តល់ភស្តុតាង*បឋម* ដែលបង្ហាញថាគាត់គឺជាជនរងគ្រោះម្នាក់ដូចមានចែងនៅក្នុងវិធាន២ ["បុគ្គលធម្មតាមួយរូប ដែលទទួលរងការខូចខាតលើរូបរាងកាយ សម្ភារៈ ឬផ្លូវចិត្ត ដោយសារតែលទ្ធផលផ្ទាល់នៃការវាយប្រហារដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ"]។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga Dyilo "សេចក្តីសម្រេចស្តីពីការចូលរួមរបស់ជនរងគ្រោះ" អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC-01/04-01/06-1119) ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ៩៩៖ "អង្គជំនុំជម្រះមិនត្រូវចូលរួមនៅក្នុងការវាយតម្លៃលើសារធាតុនៃការជឿជាក់បាន ឬទុកចិត្តបាននៃពាក្យសុំរបស់ជនរងគ្រោះ នៅមុនពេលចាប់ផ្តើមការជំនុំជម្រះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះគ្រាន់តែធានាថា មានមូលដ្ឋានគួរឲ្យជឿទុកចិត្ត *ជាបឋម* ដែលបង្ហាញថា អ្នកដាក់ពាក្យសុំបានទទួលរងការខូចខាតដោយសារតែការប្រព្រឹត្តិបទល្មើស ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ។ អង្គជំនុំជម្រះសាលាដំបូងនឹងវាយតម្លៃលើព័ត៌មាននានា ដែលរួមបញ្ចូលទាំងទម្រង់ពាក្យសុំរបស់ជនរងគ្រោះ និងសេចក្តីថ្លែងរបស់ជនរងគ្រោះ (ប្រសិនបើមាន) ដើម្បីធានាថា ចំណងទាក់ទងចាំបាច់ត្រូវបានបំពេញ"។

អស់នៅក្នុងសាលក្រម ដែលផ្អែកលើមូលដ្ឋាននៃភស្តុតាងទាំងអស់ដែលបានដាក់ជូននៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី[១០៦៤]។

៦៣៧. នៅក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨នាក់ ដែលបានចូលរួមនៅក្នុងដំណើរការនីតិវិធីក្នុងដំណាក់កាលស៊ើបអង្កេត[១០៦៥]។ អង្គជំនុំជម្រះបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ៦៦ ទៀត នៅមុនថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលជាថ្ងៃកំណត់ឈប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គ-ជំនុំជម្រះសាលាដំបូង ហើយក្នុងចំណោមពាក្យសុំទាំងនោះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៥ ត្រូវបានប្រកាសទទួលយកនៅពេលសវនាការបឋម ឬតាមរយៈសេចក្តីសម្រេចចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ និងថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩[១០៦៦]។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៣ នាក់ ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងដំណើរការនីតិវិធី។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានតំណាងដោយមេធាវី និងបានរៀបចំជាបួនក្រុម។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ នាក់ ត្រូវបានស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងដំណើរការជំនុំជម្រះ។

---

[១០៦៤] វិធាន១០០ នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះសាលាដំបូង “ត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះត្រូវសម្រេចអំពីភាពដែលអាចទទួលយកបាន និងខ្លឹមសារនៃការទាមទារចំពោះជនជាប់ចោទ”។ *ប្រៀបធៀប* “ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ឯកសារ E159/6 ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៦-៨ (ស្នើសុំអង្គជំនុំជម្រះឲ្យចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានទទួលស្គាល់ជាបណ្តោះអាសន្នថាជាដើមបណ្តឹងរដ្ឋប្បវេណី)។

[១០៦៥] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ២៧-២៨។

[១០៦៦] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ៣៦-៣៧, ៣៩-៤០។ *សូមមើលផងដែរ* “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាងលើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី” ឯកសារ E2/94 ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ និង “សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ E2/36, E2/51 និង E2/69” ឯកសារ E2/94/2 ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩។ *សូមមើលបន្ត* “សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ ពាក់ព័ន្ធនឹងភស្តុតាងនៃអត្តសញ្ញាណចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36)” ឯកសារ E2/94/4 ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩។ “សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី” E2/5/3 ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩។

៦៣៨. នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ មេធាវីការពារក្តី បានបង្ហាញអំពីចេតនាធ្វើការតវ៉ាចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដោយផ្អែកលើមូលហេតុជាក់លាក់[១០៦៧]។ ការលើកទឡ្ហីករណ៍តទល់គ្នាទាក់ទងនឹងការតវ៉ាទាំងនោះបានធ្វើឡើងនៅថ្ងៃទី២៦ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩[១០៦៨]។ នៅក្នុងអំឡុងពេលសវនាការ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គៀង វណ្ណារី (E2/77) និង អេង ស៊ីថា (E2/49) បានជូនដំណឹងដល់អង្គជំនុំជម្រះអំពីការសុំដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវិញ[១០៦៩]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន ស្រី (E2/65) បានបោះបង់សិទ្ធិសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩[១០៧០]។ នៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោល និងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមបានស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចថា ការទាមទារ

---

[១០៦៧] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ២-៧។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ៣៩-៤០ និងប្រតិចារឹក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ទំព័រ៦-៧។

[១០៦៨] ប្រតិចារឹក ចុះថ្ងៃទី២៦ និង ទី២៧ ខែសីហា ឆ្នាំ២០០៩។ មេធាវីការពារក្តីបានជំទាស់ពីដំបូងនូវដើមបណ្តឹងរដ្ឋប្បវេណី E2/22, E2/37, E2/66, D25/15, E2/30, E2/38, E2/41, E2/49, E2/57, E2/63, E2/64, E2/65, E2/69, E2/70, E2/71, E2/73, E2/74, E2/75, E2/76, E2/77, E2/81, E2/82, E2/83, D25/20, E2/35, និង E2/62។ មេធាវីការពារក្តីបានដកការជំទាស់ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/57 និង D25/20 ("កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី") E1/69 ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩។ "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" E1/70 ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩)។ *សូមមើល* ចម្លើយតប "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១- សំណើសុំបង្ហាញស្ថានភាពរបស់លោក លី ហ៊រ ថាគាត់ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស២១ និងយថាភាពនៃឯកសារនានាជាផ្នែកនៃកំណត់ហេតុ" (ឯកសារ E137) ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩។ "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១- សំណើសុំកំណត់លក្ខណៈនៃទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំនួនបួនរូប ជាមួយនឹងជនរងគ្រោះផ្ទាល់នៃមន្ទីរស២១" (ឯកសារ E140) ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩។ "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ -សំណើសុំផ្តល់ភស្តុតាងក្នុងការគាំទ្រដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំនួន ៥នាក់" (ឯកសារ E165) ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩។ "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២- សំណើសុំផ្តល់ភស្តុតាងក្នុងការគាំទ្រដើមបណ្តឹងរដ្ឋប្បវេណីក្រុម២៖ E2/22, E2/35, E2/64, E2/66 និងE2/83" (ឯកសារ E163/3) ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩។

[១០៦៩] ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៦-៧, ៨-៩។

[១០៧០] "CPG3៖ លិខិតបោះបង់សិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ឯកសារ E2/65/5 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩។

សំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០ នាក់ អាចទទួលយកបាន និងទទួលស្គាល់នូវសិទ្ធិទទួលបានសំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ[១០៧១]។

## ៤.២ ការវាយតម្លៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៦៣៩. នៅពេលប្រកាសទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញដល់អង្គជំនុំជម្រះអំពីទំនាក់ទំនងដោយផ្ទាល់រវាងកំហុសរបស់ជនជាប់ចោទ និងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយផ្ទាល់។

### ៤.២.១ អត្ថិភាពនៃព្យសនកម្ម

៦៤០. វិធាន២៣(២) នៃវិធានផ្ទៃក្នុងចែងថា ដើម្បីឲ្យបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបានព្យសនកម្មត្រូវតែជា "ការខូចខាតរាងកាយ សម្ភារៈ ឬផ្លូវចិត្ត" ព្រមទាំង "ជាផលវិបាកដោយផ្ទាល់ពីបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន"[១០៧២]។

---

[១០៧១] "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ - សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារលេខ E159/7 ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២)" E159/6 ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤" ឯកសារ E159/4 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ - សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារ E159/5 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

[១០៧២] ទោះបីជាមិនមានការផ្លាស់ប្តូរខ្លឹមសារក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបានរបស់ពាក្យសុំទាំងនេះ និងបទដ្ឋានភស្តុតាងទាំងនេះត្រូវបានបញ្ជាក់ច្បាស់នៅក្នុងវិសោធនកម្ម ដែលបានអនុម័តនៅកិច្ចប្រជុំពេញអង្គលើកទី៧។ វិធាន២៣ *ស្ទួន* (១) បានចែង ដូចខាងក្រោម៖

"ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ:

ក - បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់

00573694



៦៤១. បន្ថែមពីលើការប៉ះទង្គិចផ្លូវចិត្ត ព្យសនកម្មដែលចោទប្រកាន់នោះ ក៏អាចរួមបញ្ចូលទាំងជំងឺផ្លូវចិត្ត ឬជំងឺវិកលចរិត ដូចជា ជំងឺបាក់ស្បាត ឬព្យសនកម្មសម្ភារៈដែលទាក់ទងនឹងការបាត់បង់ទ្រព្យសម្បត្តិ ឬប្រាក់ចំណូល។ ព្យសនកម្មដែលទទួលរងត្រូវតែមានលក្ខណៈជារូបវន្ត[១០៧៣]។ អង្គជំនុំជម្រះធ្លាប់បានសម្រេចពីមុនថា ស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានបន្តដោយសិទ្ធិវ័ន្តរបស់អ្នកដែលតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព[១០៧៤]។

---

ខ - បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព ។
នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ"។

[១០៧៣] *សូមមើលខ១.* ប្រតិចារឹក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ (ឈឹម សុធារ៉ា) ទំព័រ៤១-៤២, ៤៤-៤៦ (រៀបរាប់លម្អិតអំពីផលវិបាកចំពោះស្ថានភាពរាងកាយ និងផ្លូវចិត្តរបស់សមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់របស់មន្ទីរស២១ និងប្រភេទនៃការប៉ះទង្គិចផ្លូវចិត្ត ដែលបណ្តាលមកពីការដឹងអំពីមរណភាពរបស់សាច់ញាតិនៅមន្ទីរស២១ ដែលក្នុងនោះ រួមបញ្ចូលទាំងការកំណត់បង្ហាញពីការឈឺចាប់របស់ជនរងគ្រោះ កំហុស ភាពមិនអាចជួយបាន និងស្ថានភាពវិកលចរិត ដូចជា ជំងឺបាក់ស្បាត។ ទោះបីជាមានតែវិធាន២៣(២) នៃសំណៅជាភាសាអង់គ្លេស ចែងអំពីការខូចខាតខាងផ្លូវចិត្ត (psychological injury) ក៏សំណៅជាភាសាបារាំងប្រើពាក្យ "préjudice moral" និងសំណៅជាភាសាខ្មែរប្រើពាក្យ "ការខូចខាតខាងផ្លូវចិត្ត"។ *សូមមើលបន្ថែមអំពី ស្ថានការណ៍នៅប្រទេស Uganda* "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចដែលមានឈ្មោះថា "សេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ [...]" របស់អង្គបុរេជំនុំជម្រះ II" អង្គជំនុំជម្រះតុលាការកំពូល ICC ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ (ICC-02/04-179) កថាខណ្ឌ៣៥។

[១០៧៤] ដើមបណ្តឹងរដ្ឋប្បវេណី សួស សារិន ឯកសារ D25/24 បានទទួលមរណភាពនៅមុនពេលសវនាការចាប់ផ្តើមឯកសារ E2/5/1.2។ *សូមមើល* "សំបុត្រមរណភាព - សួស សារិន" E2/5/1.2។ អង្គជំនុំជម្រះកំណត់ថាប្តីរបស់គាត់ឈ្មោះ អ៊ុំ ពិសិដ្ឋ ត្រូវបានផ្តល់សិទ្ធិជាសិទ្ធិវ័ន្ត ដើម្បីបន្តបណ្តឹងស៊ីវិលរបស់គាត់។ *សូមមើល* "សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី"។ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១០-១២ (សម្រេចថាសិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ត្រូវបង្ហាញថាជនរងគ្រោះដែលបានទទួលមរណភាពបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលគ្មានភស្តុតាងបញ្ជាក់ សិទ្ធិវ័ន្តអាចត្រឹមតែស្វែងរកដោយខ្លួនឯង នូវសំណងនៃព្យសនកម្មផ្ទាល់ខ្លួន ចំពោះមរណភាពរបស់ជនរងគ្រោះ)។

## ៤.២.២ អត្ថិភាពនៃទំនាក់ទំនងហេតុនិងផលរវាងព្យសនកម្មរបស់ជនរងគ្រោះ និង កំហុសរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច

៦៤២. ព្យសនកម្មដែលទទួលរង ត្រូវតែកើតចេញដោយផ្ទាល់ពីអំពើឧក្រិដ្ឋរបស់ពិរុទ្ធជន។ សញ្ញាណនៃ "ផលវិបាកដោយផ្ទាល់" មានចែងយ៉ាងច្បាស់នៅក្នុងមាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងបានសង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងបទល្មើស និងព្យសនកម្មដែលទទួលរងជាជាងគោលដៅដែលជាចេតនានៃអំពើឧក្រិដ្ឋ។ ដូច្នេះ ការទទួលខុសត្រូវរបស់ជនជាប់ចោទ មិនត្រូវកម្រិតត្រឹមតែបុគ្គលទាំងឡាយណាដែលជាជនរងគ្រោះផ្ទាល់ពីបទល្មើសដែលជនជាប់ចោទប្រព្រឹត្តនោះទេ ប៉ុន្តែត្រូវគ្របដណ្តប់ដល់សាច់ញាតិរបស់ជនរងគ្រោះទាំងឡាយណា ដែលទទួលរងព្យសនកម្មដោយផ្ទាល់ផងដែរ[១០៧៥]។

---

[១០៧៥] ផ្អែកតាមច្បាប់ប្រទេសបារាំង ដែលចែងអំពីបុរេលក្ខខណ្ឌស្រដៀងគ្នា សមាជិកជិតស្និទ្ធរបស់ជនរងគ្រោះដោយផ្ទាល់ត្រូវបានចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណីដោយយោងតាមសិទ្ធិរបស់ពួកគាត់។ *សូមមើល* មាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំងចែងថា "បណ្តឹងរដ្ឋប្បវេណីមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែល បណ្តាលមកពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបណ្តាលមកពីបទលហុ ដល់អ្នកដែលទទួលរងការខូចខាត ដែលបង្កឡើងដោយផ្ទាល់ពីបទល្មើស។ (*គូសបញ្ជាក់បន្ថែម*) *សូមមើលបន្ថែម* មាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "មិនមែនគ្រាន់តែត្រូវឱ្យមានជាមួយគ្នា នូវបទល្មើសលើច្បាប់ព្រហ្មទណ្ឌ ហើយនិងការខូចខាតដែលត្រូវបណ្តាលឱ្យមានប៉ុណ្ណោះទេ ត្រូវឱ្យមានថែមទៀតផងរវាងបទទាំងពីរនេះ នូវទំនាក់ទំនងរវាងហេតុនិងផល ឬសេចក្តីម្យ៉ាងទៀតថា ត្រូវឱ្យការខូចខាតនេះជាលទ្ធផលផ្ទាល់របស់បទល្មើស ហើយត្រូវឱ្យកើតមានពិតប្រាកដមែន" (គូសបញ្ជាក់បន្ថែម)។ ការបើកទូលាយសញ្ញាណនៃព្យសនកម្មចំពោះបុគ្គលទាំងអស់ដែលទទួលរងការខូចខាតដោយសារតែផលវិបាកដោយផ្ទាល់នៃបទល្មើស គឺជាការឆ្លុះបញ្ចាំងចេញពីលិខិតុបករណ៍ច្បាប់អន្តរជាតិមួយ។ *សូមមើលឧទា.* គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានសម្រេច និងប្រកាសដោយមហាសន្និបាតអង្គការសហប្រជាជាតិ (GA UN Resolution 60/147 ឯកសារ អ.ស.ប A/RES/60/147) មាត្រា៨ ចែងថា " ចំពោះគោលបំណងនៃឯកសារបច្ចុប្បន្ននេះ ជនរងគ្រោះគឺជាបុគ្គលទាំងឡាយដែលទទួលរងព្យសនកម្មជាបុគ្គល ឬជារួម រួមបញ្ចូលទាំងព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្ត ការរងទុក្ខខាងអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬការរំលោភយ៉ាងធ្ងន់ធ្ងរ

៦៤៣. ទោះបីជាសមាជិកគ្រួសារជិតស្និទ្ធបំផុតរបស់ជនរងគ្រោះស្ថិតនៅក្នុងវិសាលភាពនៃវិធាន ២៣(២)(ខ)ក៏ដោយ ក៏ការបង្ហាញការខូចខាតដោយផ្ទាល់ទៅលើសមាជិកគ្រួសារសាច់ឆ្ងាយៗពិតជាមានការលំបាកណាស់[១០៧៦]។ នៅក្នុងករណីលើកលែងមួយចំនួន អង្គជំនុំជម្រះយល់ឃើញថា ការខូចខាតដែលចោទប្រកាន់ដោយសមាជិកនៃគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះក៏អាចចាត់ទុកថាជាផលវិបាកផ្ទាល់នៃបទល្មើស និងអាចបង្ហាញបាននៅពេលដែលអ្នកដាក់ពាក្យសុំមានលទ្ធភាពបង្ហាញភស្តុតាងទាំងភាពជាសាច់ញាតិ និងអត្ថិភាពនៃកាលៈទេសៈដែលបណ្តាលឱ្យមានចំណងពិសេសនៃសេចក្តីស្រលាញ់ ឬអ្នកនៅក្នុងបន្ទុករបស់អ្នកដែលបានទទួលមរណភាព។ នៅក្នុងករណីនេះ អង្គជំនុំជម្រះទទួលយកមតិយោបល់របស់អ្នកជំនាញ ឈឹម សុធារ៉ា ទាក់ទងនឹងប្រភេទនៃទំនាក់ទំនងគ្រួសារ

---

លើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះតាមរយៈអំពើសកម្ម ឬអកម្មដែលជាការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ តាមករណីសមស្រប [...] ពាក្យ *"ជនរងគ្រោះ" រួមបញ្ចូល ទាំងសាច់ញាតិជិតស្និត ឬអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះដោយផ្ទាល់* និងបុគ្គលទាំងឡាយដែលទទួលរងព្យសនកម្ម ដោយសារការចូលអន្តរាគមន៍ជួយជនរងគ្រោះឱ្យរួចផុតពីគ្រោះថ្នាក់ ឬទប់ស្កាត់មិនឱ្យក្លាយជាជនរងគ្រោះ។ (គូសបញ្ជាក់បន្ថែម)"។

[១០៧៦] សូមមើល តុលាការអន្តរអាមេរិកស្តីសិទ្ធិមនុស្ស *រឿងក្តី* Garrido y Baigorria *តទល់នឹង* Argentina, សាលក្រមស្តីពីសំណង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៤។ *រឿងក្តី* Castillo Páez *តទល់នឹង* Peru សេចក្តីសម្រេចលើសំណង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៨៨-៩០, ១៤២-១៤៣។ *សំណុំរឿង* *"While Van" (Paniagua Morales a.o.)* *តទល់នឹង* Guatemala សេចក្តីសម្រេចលើសំណង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ១០៦ ១០៨ (ប្រើប្រាស់សញ្ញាណទូលាយនៃពាក្យ "គ្រួសារ" និងអនុវត្តគោលការណ៍សន្មតភស្តុតាងនៃការខូចខាតខាងផ្លូវចិត្តដែលទទួលរងដោយឪពុកម្តាយ ឬកូនរបស់បុគ្គលដែលត្រូវបានគេសម្លាប់)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga Dyilo "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចលើការចូលរួមរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨" អង្គជំនុំជម្រះតុលាការកំពូល ICC ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ (ICC-01/04-01/06-1432) កថាខណ្ឌ៣២៖"ព្យសនកម្មដែលជនរងគ្រោះមួយរូបទទួលរងដោយសារតែការប្រព្រឹត្តិបទល្មើសមួយស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអាចបណ្តាលឱ្យជនរងគ្រោះផ្សេងទៀតទទួលរងនូវព្យសនកម្មនេះដែរ។ ករណីនេះមាននៅពេលដែលមានទំនាក់ទំនងជិតស្និតផ្ទាល់រវាងជនរងគ្រោះ ដូចជាទំនាក់ទំនងរវាងទាហានក្មេងៗ និងឪពុកម្តាយរបស់ទាហានក្មេងៗទាំងនោះ"។

នៅក្នុងវប្បធម៌នៃប្រទេសកម្ពុជា[១០៧៧] ហេតុដូចនេះ អង្គជំនុំជម្រះវាយតម្លៃអំពីអំណះអំណាងរបស់សមាជិកគ្រួសារសាច់ឆ្ងាយដែលបានព្យាយាមបង្ហាញព័ត៌មានអំពីទំនាក់ទំនងពិសេសដោយផ្ទាល់ជា-មួយជនរងគ្រោះនៅមន្ទីរស២១ និង ស២៤។

## ៤.៣ ការទទួលខុសត្រូវរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី

៦៤៤. កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថា មានពិរុទ្ធភាពពីបទល្មើសនានា ដែលបានប្រព្រឹត្តនៅមន្ទីរស២១ និងស២៤ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (ដែលរួមបញ្ចូលទាំង ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត) និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ ឥឡូវនេះ អង្គជំនុំជម្រះនឹងពិចារណាអំពីថាតើពិរុទ្ធជនអាចត្រូវបានរកឃើញថាគាត់ត្រូវទទួលខុសត្រូវចំពោះព្យសនកម្មដែលមានលក្ខណៈពិសេស ដែលបានលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរប្រភេទនេះដែរ ឬទេ ពោលគឺអ្នកទាំងឡាយណាដែលអះអាងថា ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬស២៤ និងបុគ្គលទាំង

---

[១០៧៧] ប្រតិចារឹក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ (ឈឹម សុផាវ៉ា) ទំព័រ៤៥-៤៨ និង ៦១-៦២ (បានកត់សម្គាល់ពីទំនោរចិត្តរបស់គ្រួសារកម្ពុជាក្នុងការរស់នៅជាមួយសមាជិកគ្រួសារផ្សេងទៀត ដូចជាឪពុកម្ដាយចាស់ជរា ឬជាមួយបងប្អូន និងគ្រួសាររបស់ពួកគាត់ ដូច្នេះហើយ ចំណងនៃសេចក្ដីស្រលាញ់ក៏កើតមានផងដែរចំពោះ ជីដូនជីតា បងប្អូនជីដូនមួយ ឪពុកមា និងម្ដាយមីង។ ទោះជាចំណងនៃសេចក្ដីស្រលាញ់ទាំងនេះមានជាទូទៅក៏ដោយ ភាពជិតស្និទ្ធនៃសេចក្ដីស្រលាញ់ទាំងនេះអាស្រ័យទៅលើករណីជាក់ស្ដែង)។

ឡាយដែលអះអាងអំពីភាពជាសាច់ញាតិ ឬទំនាក់ទំនងពិសេសនៃសេចក្តីស្រលាញ់ ឬអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះនៃមន្ទីរស២១ ឬស២៤[១០៧៨]។

### ៤.៣.១ ដើមបណ្តឹងរដ្ឋប្បវេណីដែលប្រកាសថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬស២៤

៦៤៥. ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៨ នាក់ ដែលអះអាងថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬស២៤ អង្គជំនុំជម្រះយល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ ខាងក្រោមបានបង្ហាញព័ត៌មានអំពីអំណះអំណាងនេះ និងបានបង្ហាញភស្តុតាងថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង[១០៧៩]។

---

[១០៧៨] *សូមមើល*វិធាន ២៣(៦)(ខ) ដែលចែងថា "អង្គជំនុំជម្រះមិនត្រូវចេញសេចក្តីសម្រេចស្តីពីបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្ទុយគ្នានឹងសេចក្តីសម្រេចអំពីបណ្តឹងអាជ្ញានៃរឿងក្តីដូចគ្នានោះទេ"។ ទោះបីជាវិធានផ្ទៃក្នុងចែងថា ការសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់នឹងបញ្ចប់នូវការទាមទារសំណងក៏ដោយ ក៏ការទទួលខុសត្រូវរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗមិនចាំបាច់ដូចទៅនឹងការសម្រេចទោសទៅលើជនជាប់ចោទនោះទេ។ បន្ថែមពីលើនេះ ទោះបីជាអង្គជំនុំជម្រះមិនត្រូវបានតម្រូវឱ្យកំណត់ឱ្យបានច្បាស់ចំពោះរាល់ជនរងគ្រោះនីមួយៗនៅពេលផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់លើជនជាប់ចោទក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាលើកាលៈទេសៈពិសេសៗនៃដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅក្នុងពេលវាយតម្លៃលើភស្តុតាង។

[១០៧៩] នៅក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលគាំទ្រដល់ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាបញ្ជីអ្នកជាប់ឃុំ បញ្ជីឈ្មោះផ្លូវការ ឬសៀវភៅចុះបញ្ជី ចម្លើយសារភាព រូបថត និងភស្តុតាងផ្សេងទៀត ដែលយកមកពីមន្ទីរស២១ ដែលកំណត់អត្តសញ្ញាណថាជាអ្នកជាប់ឃុំ។ នៅពេលដែលជនជាប់ចោទបានទទួលស្គាល់ដោយខ្លួនឯងអំពីភាពពិតប្រាកដនៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារភស្តុតាងដែលផ្តល់ជូនផ្សេងទៀត អង្គជំនុំជម្រះក៏ទទួលយកនូវការពិតទាំងនេះដែរ។ អង្គជំនុំជម្រះមិនអាចកំណត់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថាមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ ដោយផ្អែកលើសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវនោះទេ។ *សូមមើលឧទា. រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kony និងអ្នកផ្សេងទៀត* "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចដែលមានឈ្មោះថា 'សេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ [...] នៃអង្គបុរេជំនុំជម្រះ II" អង្គជំនុំជម្រះតុលាការកំពូល ICC (ICC-02/04-01/05-371) ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៣៦ និង៣៨

- ប៊ូ ម៉េង (D25/1)
- ជុំ ម៉ី (D25/3)
- ជុំ នៅ (D25/16) និង
- ជិន ម៉េត (E2/80)

៦៤៦. វាហួសពីវិមតិសង្ស័យដែលថា អ្នកនៅរស់រានមានជីវិតមួយចំនួនតូចពីមន្ទីរស២១ ឬស២៤ ត្រូវបានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរលើរូបរាងកាយ និងផ្លូវចិត្តបន្ថែមទៀតចំពោះការបាត់បង់សមាជិកគ្រួសាររបស់ពួកគាត់ដោយសារតែផលវិបាកផ្ទាល់នៃការប្រព្រឹត្តិបទឧក្រិដ្ឋដែល កាំង ហ្គេក-អ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាពនេះ[១០៨០]។

៦៤៧. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនពិតជាទទួលរងនូវការខូចខាតលើរូបរាងកាយ និងផ្លូវចិត្ត ដោយសារតែគាត់ជាជនរងគ្រោះនៅមន្ទីរស២១ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា អង្គ-ហេតុមិនបានបង្ហាញតាមបទដ្ឋានតម្រូវដែលថា ដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ គឺជាជនរង-

---

("គោលការណ៍សំខាន់នៃវិធានគតិយុត្តិគឺថា សេចក្តីសម្រេចរបស់តុលាការត្រូវតែផ្អែកលើអង្គហេតុនានាដែលបង្ហាញដោយភស្តុតាង។ ការផ្តល់ភស្តុតាងដើម្បីបង្ហាញការចោទប្រកាន់ គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការនីតិវិធីតុលាការ [...]។ ភស្តុតាងដែលគ្រប់គ្រាន់អ្វីក៏ដោយ (ទោះបីជាភស្តុតាងឯកសារ ឬភស្តុតាងផ្សេងទៀត) មិនអាចកំណត់ដោយអរូបិយទេ ប៉ុន្តែត្រូវតែវាយតម្លៃផ្អែកតាមរឿងក្តីនីមួយៗ និងពិចារណាគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងបរិបទដែលតុលាការនេះកំពុងដំណើរការ"។

[១០៨០] អ្នកនៅរស់រានមានជីវិតទាំងអស់បានផ្តល់ការពិពណ៌នាគួរឲ្យជឿជាក់អំពីអតីតកាល និងការឈឺចាប់នៅពេលបច្ចុប្បន្នរបស់ពួកគាត់ ដោយសារតែផលវិបាកនៃការឃុំខ្លួនពួកគាត់នៅក្នុងគុក។ *សូមមើលឧទា.* ប្រតិចារឹក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០៩ (ជុំ នៅ) ទំព័រ៦៦-៦៩, ៧០-៧២ (បានរៀបរាប់អំពីការបាត់បង់កូនតូចរបស់គាត់ ពេលកំពុងជាប់ឃុំឃាំងនៅស២៤ និងបាត់បង់ស្វាមីរបស់គាត់ឈ្មោះ នូ សាមឿន ផងដែរនៅមន្ទីរ ស-២១។ ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ (ប៊ូ ម៉េង) ទំព័រ០៨-២៥, ៣៤-៣៦ (រៀបរាប់លម្អិតអំពីការឃុំខ្លួន និងការធ្វើទារុណកម្មបន្ថែម លើការរៀបរាប់អំពីការបាត់បង់ប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន *ហៅ* ធី នៅមន្ទីរ ស២១)។ ប្រតិចារឹក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ជុំ ម៉ី) ទំព័រ០៨-១២, ១៨-២៣ (រៀបរាប់ថា គាត់ត្រូវបានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅមន្ទីរស២១ ក្នុងអំឡុងពេលរងទារុណកម្ម ក្រចកជើងរបស់គាត់ត្រូវបានដក ហើយគាត់ត្រូវបានគេកាត់ម្រាមដៃមួយ)។ ប្រតិចារឹក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ជិន ម៉េត) ទំព័រ ៤៣-៦៥ (រៀបរាប់អំពីការឃុំខ្លួននៅស២៤ និងរងនូវការឈឺចាប់ ដែលក្នុងចំណោមនោះរួមមានការហូបមិនគ្រប់គ្រាន់ និងការធ្វើការងារធ្ងន់រយៈពេលយូរ)។

គ្រោះនៃឧក្រិដ្ឋកម្មទាំងឡាយ ដែលប្រព្រឹត្តឡើងដោយ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅមន្ទីរស២១ (ទួលស្លែង) ឬនៅស២៤ នោះទេ។

- ទោះបីជាអង្គជំនុំជម្រះមិនមានការសង្ស័យថា ឡាយ ចាន់ (E2/23) ទទួលរងការខូចខាតយ៉ាងខ្លាំងដោយសារតែ ការឃុំខ្លួន ការសួរចម្លើយ និងការធ្វើទារុណកម្មក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មិនមានភស្តុតាងបង្ហាញថាការខូចខាតនេះកើតឡើងនៅមន្ទីរស២១ទេ។ ភស្តុតាងជាក់ស្តែងពីការចុះឈ្មោះអ្នកទោសផ្លូវការ រូបថត ឬចម្លើយសារភាព មិនបានបញ្ជាក់អំពីការអះអាងរបស់គាត់ដែលថា គាត់ត្រូវបានឃុំខ្លួននៅមន្ទីរស២១ឡើយ។ ការរៀបរាប់អំពីស្ថានភាពឃុំខ្លួននេះ មិនស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងជាច្រើនដែលដាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងប្រតិបត្តិការនៅមន្ទីរស២១[១០៨១] ទេ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាមិនមានភស្តុតាងដែលបញ្ជាក់ថា ឡាយ ចាន់ (E2/32) ត្រូវបានជាប់ឃុំនៅមន្ទីរស២១ ឬស២៤ ទេ។ ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញអំពីទំនាក់ទំនងហេតុ និងផលរវាងព្រឹត្តិការណ៍ដែលបានរៀបរាប់និងឧក្រិដ្ឋកម្ម ដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច មានពិរុទ្ធភាពនោះ ដូច្នេះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោល ។

- ណាំ ម៉ុន (E2/32) បានលើកឡើងថា ដំបូងគាត់ជាបុគ្គលិកពេទ្យម្នាក់នៅមន្ទីរស២១ និងក្រោយមក គាត់ត្រូវបានឃុំខ្លួននៅទីនោះ ក្រោយពេលចាប់ខ្លួនបងប្រុសគាត់មួយចំនួនដែលពួកគាត់ជាអ្នកយាមនៅមន្ទីរស២១។ គាត់ត្រូវបានបញ្ជូនពីមន្ទីរស២១ ទៅស២៤ និង

---

[១០៨១] ប្រតិចារឹក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ (ឡាយ ចាន់) ទំព័រ០៦-០៧, ០៩-១១, ១៥-១៧ (បានរៀបរាប់ថា គាត់មិនអាចចាំបានអំពីការចុះឈ្មោះ ឬថតរូបជាផ្លូវការ ឬតម្រូវឱ្យផ្តល់ជីវប្រវត្តិទេ។ គាត់បានរៀបរាប់អំពីបន្ទប់ឃុំឃាំងគាត់ដែលមិនស៊ីគ្នានឹងអ្នកផ្សេងទៀតដែលរៀបរាប់អំពីបន្ទប់ឃុំឃាំងនៅមន្ទីរស២១ ហើយគាត់បានទាមទារឱ្យដោះលែងគាត់ពីមន្ទីរស២១ ដោយគ្មានការពន្យល់អ្វីសោះ ដែលការលើកឡើងនេះ ផ្ទុយគ្នានឹងគោលនយោបាយដែលមាន។ ក្នុងអំឡុងពេលទស្សនាមន្ទីរស២១ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនអាចចំណាំបានផ្នែកនៃមន្ទីរស២១ ដែលជាកន្លែងដែលគាត់ត្រូវបានឃុំខ្លួននោះទេ)។

ក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងផ្សេងទៀត[១០៨២]។ ព័ត៌មានដែលបានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ មិនស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយដែលគាត់បានឆ្លើយនៅពេលសវនាការ ព្រមទាំងសារណាដែលបានដាក់ជាបន្តបន្ទាប់របស់គាត់នោះទេ[១០៨៣]។ គាត់មិនអាចផ្ដល់ព័ត៌មានជាក់លាក់ណាមួយទាក់ទងនឹងមន្ទីរស២១ ឬស២៤ ហើយភស្តុតាងដែលគាត់ផ្ដល់ឲ្យដើម្បីគាំទ្រអំពីទំនាក់ទំនងសាច់ញាតិទៅនឹងបុគ្គលនៅក្នុងរូបថត ដែលត្រូវបានសម្លាប់នៅមន្ទីរស២១ មិនបានបង្ហាញច្បាស់ថា អ្នកទាំងនោះគឺជាសាច់ញាតិរបស់គាត់ទេ[១០៨៤]។ ទោះបីជាមានផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត និងការកន្លងផុតនៃពេលវេលាក្ដី ក៏អង្គជំនុំជម្រះសន្និដ្ឋានបានថា ណាំ ម៉ុន (E2/32) មិនត្រូវបានឃុំខ្លួននៅមន្ទីរស២១(ទួលស្លែង) ឬស២៤ ទេ។ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់អំពីការរងទុក្ខរបស់គាត់យ៉ាងច្រើនក្ដី ក៏ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោលដែរ។

---

[១០៨២] ប្រតិចារឹក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ (ណាំ ម៉ុន) ទំព័រ៤៧-៥២។

[១០៨៣] ផ្អែកតាមឆ្នាំកំណើតដែលបង្ហាញនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី E2/32 ដែលកើតថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៦៨ ដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការជាបុគ្គលិកពេទ្យនៅមន្ទីរស២១ នៅអាយុ៦ ឬ៧ឆ្នាំ។ លើសពីនេះចម្លើយរបស់គាត់នៅក្នុងសវនាការមិនស្របគ្នាជាច្រើនចំណុចជាមួយនឹងចម្លើយដែលផ្ដល់ដោយសាក្សី ឬអ្នកជំនាញផ្សេងទៀតនៅក្នុងអំឡុងពេលដំណើរការនីតិវិធី៖ *សូមមើល* ប្រតិចារឹក ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ (ណាំ ម៉ុន) ទំព័រ៦៧-៧០។ *សូមមើលផងដែរ* "សេចក្ដីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួនទៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)" ឯកសារE176 ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ១៤ (បដិសេធចោលសំណើដែលស្នើសុំឲ្យទទួលយកសារណាជាលាយលក្ខណ៍អក្សរដាក់ជាភស្តុតាង)។ *សូមមើលផងដែរ* ប្រតិចារឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ២៨-២៩ និង "សហមេធាវីក្រុម២ - ការសុំដាក់សេចក្ដីថ្លែងការណ៍បន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីលេខ E2/32 នៃសំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង" ឯកសារ E2/32/5 ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩។

[១០៨៤] ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ (ណាំ ម៉ុន) ទំព័រ១៥-២០ (ការលើកឡើងមានលក្ខណៈមិនស៊ីសង្វាក់គ្នារវាងឈ្មោះ ឬពេលវេលានៃមរណភាពរបស់ជនរងគ្រោះផ្ទាល់ដែលជាសាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី)។ បន្ថែមពីលើនេះឈ្មោះ ឬឈ្មោះហៅក្រៅដែលគាត់ទុកថាជាសាច់ញាតិរបស់គាត់ មិនមាននៅក្នុងបញ្ជីឈ្មោះបុគ្គលិក ឬបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរស២១ទេ។

- ភោគ ខន (E2/33) បានរៀបរាប់អំពីការធ្វើទារុណកម្ម និងស្លរចម្លើយលើរូបគាត់នៅក្នុងគុកក្បែរទីក្រុងភ្នំពេញក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ[១០៨៥]។ ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអាចត្រូវបានទាហានខ្មែរក្រហមឃុំខ្លួន និងធ្វើទារុណ-កម្មក្តី ក៏មិនមានភស្តុតាងពិតប្រាកដបង្ហាញថាការឃុំខ្លួន និងការធ្វើទារុណកម្មនេះ កើតឡើងនៅមន្ទីរស២១ (ទួលស្លែង) ដែរ[១០៨៦]។ ការរៀបរាប់អំពីកន្លែងឃុំខ្លួនគាត់មិនស៊ីសង្វាក់គ្នានឹងកន្លែងឃុំខ្លួននៅមន្ទីរស២១ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនត្រូវបានគេថតរូប ឬបង្ខំឲ្យផ្តល់ជីវប្រវត្តិដែលផ្ទុយទៅនឹងប្រតិបត្តិការរបស់មន្ទីរស២១[១០៨៧]។ បន្ថែមពីលើនេះ ការរៀបរាប់អំពីការលួចរត់របស់ដើមបណ្តឹងរដ្ឋប្បវេណីពីកន្លែងប្រហារជីវិត និងការផ្តល់ព័ត៌-មានអំពីទីតាំងភូមិសាស្ត្រ មិនស៊ីសង្វាក់គ្នានឹងជើងឯក ដែលជាកន្លែងដែលគាត់បានអះអាងថាគាត់បានរួចផុតពីការស្លាប់[១០៨៨]។ ភោគ ខន បានអះអាងបន្ថែមថា ប្រពន្ធរបស់គាត់ និងជីដូនមួយគាត់ម្នាក់ក៏ត្រូវបានសម្លាប់នៅមន្ទីរស២១ដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងបង្ហាញថាប្រពន្ធរបស់គាត់ត្រូវបានឃុំខ្លួននៅមន្ទីរស២១ទេ។ ទោះបីជាបុគ្គលដែល

[១០៨៥] ប្រតិចារិក ចុះថ្ងៃទី៧ និងទី៨ ខែកក្កដា ឆ្នាំ២០០៩ (ភោគ ខន)។

[១០៨៦] ឯកសារមន្ទីរស២១ ដែលមានបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី គឺជាការវិភាគនៃចម្លើយសារភាពរបស់អ្នកជាប់ឃុំឈ្មោះ សុខ ណាន់ ដែលគាត់មានឈ្មោះ ភោគ សាខុន ថាជាសត្រូវ។ *សូមមើល* “ឧបសម្ព័ន្ធ៖ ជីវប្រវត្តិ ភោគ សាខុន” E5/7/1.3។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានការបង្ហាញថា ឈ្មោះនេះធ្លាប់ត្រូវបានប្រើប្រាស់ដោយដើមបណ្តឹងរដ្ឋប្បវេណីទេ។ លើសពីនេះ ការទទួលយកឯកសារនេះ គឺនៅជាបញ្ហាចោទ ដោយសារតែចម្លើយសារភាពដែលចោទប្រកាន់ អាចត្រូវបានទទួលក្រោមការធ្វើទារុណកម្ម។ *សូមមើល* “ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម” D130/8 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ (ឯកសារនៅក្នុងសំណុំរឿងលេខ០០២)។

[១០៨៧] ប្រតិចារិក ចុះថ្ងៃទី០៧ និងទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ភោគ ខន) ទំព័រ ៧០-៧១, ៨២-៨៣។ ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលស្គាល់បន្តទៀតនៅពេលធ្វើដំណើរទស្សនាជាក្រុមទៅកាន់សារមន្ទីរទួលស្លែងក្នុងឆ្នាំ២០០៨ ថារូបគាត់មិនអាចចំណាំបានទេថាទីតាំងនេះគឺជាកន្លែងដែលរូបគាត់ត្រូវបានឃុំខ្លួននោះ។ *សូមមើល* ប្រតិចារិក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ (ភោគ ខន) ទំព័រ១២។

[១០៨៨] ប្រតិចារិក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ (ភោគ ខន) ទំព័រ ៥៩-៦០, ៦៩-៧១។ ប្រតិចារិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ (ភោគ ខន) ទំព័រ០៨-០៩។

មានឈ្មោះ ឈឿង ភាំ ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១ក៏ដោយ ក៏អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទទួលស្គាល់ថាគាត់មិនអាចផ្ដល់ភស្ដុតាងបញ្ជាក់អំពីទំនាក់ទំនងរបស់គាត់ជាមួយ ឈឿង ភាំ ទេ[១០៨៩]។ ដូច្នេះ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបដិសេធចោល។

- លី ហ៊ (E2/61) បានអះអាងថា ដំបូងគាត់ត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) និងក្រោយមកគាត់ត្រូវបានគេបញ្ជូនទៅស២៤ដែលជាកន្លែងដែលគាត់បានរត់គេចខ្លួន[១០៩០]។ ទោះបីជាមានអ្នកជាប់ឃុំមួយរូបឈ្មោះ អ៊ា ហ៊ីរ នៅមន្ទីរស២១ ដោយយោងតាមឯកសារ និងការរៀបរាប់ ក៏វានៅតែមានចម្ងល់ថា តើអ្នកជាប់ឃុំរូបនេះគឺជាដើមបណ្ដឹងរដ្ឋប្បវេណីដែរឬយ៉ាងណា[១០៩១]។ បន្ថែមពីលើនេះ នៅក្នុងបណ្ណសារមន្ទីរស២១ មិនបានបង្ហាញអំពីការបញ្ជូនអ្នកជាប់ឃុំរូបនេះពីមន្ទីរស២១ ទៅស២៤ ឡើយ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនបានរៀបរាប់អំពីការដឹកជញ្ជូនដែលខ្លួនបានអះអាងនោះទេ ដែលវាផ្ទុយទៅនឹងប្រតិបត្តិការរបស់មន្ទីរស២១[១០៩២]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ លី ហ៊ មិនបានបង្ហាញតាមបទដ្ឋានតម្រូវនោះទេ។

---

[១០៨៩] "សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣ - សេចក្ដីសន្និដ្ឋានបញ្ចប់" ឯកសារ E159/5 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៩៣។

[១០៩០] ប្រតិចារឹក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ (លី ហ៊) ទំព័រ០៧-០៨។

[១០៩១] អង្គជំនុំជម្រះមិនច្បាស់ទេថា លី ហ៊ ត្រូវបានស្គាល់ថាជា អ៊ា ហ៊ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (*ប្រៀបធៀប* "ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ -- សំណើសុំបញ្ចូលស្ថានភាពរបស់លោក លី ហ៊ីរ *[លី ហ៊]* ជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ និងយថាភាពនៃឯកសារនានា ជាផ្នែកនៃកំណត់ហេតុ" ឯកសារ E137 ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩។

[១០៩២] ទោះបីជាមានចំណារជាលាយលក្ខណ៍អក្សរលើជីវប្រវត្តិនៃអ្នកជាប់ឃុំឈ្មោះ អ៊ា ហ៊ បង្ហាញថា គាត់ត្រូវគេ "ដោះលែងនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦" ("ជីវប្រវត្តិរបស់ អ៊ា ហ៊" E2/61.2 ERN 00368571) អ្នកជាប់ឃុំ និងសាក្សីជាច្រើន ដែលរួមបញ្ចូលទាំងអតីតសមាជិកមន្ទីរស២១ បានផ្ដល់សក្ខីកម្មថា លើកលែងតែករណីមួយចំនួនតិចតួចដែលមិនមានពាក់ព័ន្ធនឹងអ្នកទោសធម្មតា អ្នកជាប់ឃុំមន្ទីរស២១ទាំងអស់ត្រូវបានសម្លាប់ចោល (*សូមមើលឧទា.* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ (សួស ធី) ទំព័រ ៧៥-៧៦)។

### ៤.៣.២ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត

៦៤៨. ដូចដែលបានកត់សម្គាល់ ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលបានអះអាងថាខ្លួនជាជនរងគ្រោះដោយសារតែគាត់បានបាត់បង់សាច់ញាតិជិតស្និតនៅមន្ទីរស២១ និងស២៤ ត្រូវតែបង្ហាញថាយ៉ាងហោចណាស់មានសមាជិកគ្រួសាររបស់ពួកគាត់ណាម្នាក់គឺជាជនរងគ្រោះដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែល កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាពនោះ។ អង្គជំនុំជម្រះយល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោមមិនមានលទ្ធភាពបង្ហាញនូវអត្ថិភាព នៃជនរងគ្រោះថាជាសាច់ញាតិជិតស្និទ្ធតាមបទដ្ឋានតម្រូវនោះឡើយ។

- សូ សូង (E2/34) បានអះអាងថា បងថ្លៃរបស់គាត់ឈ្មោះ មាស ស៊ុន *ហៅ* តេង ស៊ុន ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស២១។ ដើម្បីគាំទ្រអំណះអំណាងនេះ គាត់បានផ្ដល់រូបថតដែលមាននៅក្នុងបណ្ណសាររបស់សារមន្ទីរទួលស្លែង[១០៥៣]។ ប៉ុន្តែរូបថតនោះមិនបានបង្ហាញអំពីការបញ្ជាក់នៃអត្តសញ្ញាណ ហើយរូបថតនោះទៀតសោតមិនបានបង្ហាញថាបុគ្គលនៅក្នុងរូបថតគឺពិតជា មាស ស៊ុន នោះទេ។ បន្ថែមពីលើនេះ មិនមានភស្តុតាងបង្ហាញអំពីការស្និតនៅក្នុងបន្ទុក ឬទំនាក់ទំនងពិសេសនៃសេចក្ដីស្រលាញ់រវាងដើមបណ្ដឹងរដ្ឋប្បវេណី និងបងថ្លៃរបស់គាត់នោះទេ[១០៥៤]។

- ឆាយ កន *ហៅ* លៀង កន (E2/35) បានអះអាងថាក្មួយរបស់គាត់ម្នាក់ ឈ្មោះ ញ៉ែម ឆើយ ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ គាត់បានឃើញរូបថតក្មួយគាត់នៅពេលគាត់ទៅទស្សនាគុកទួលស្លែង[១០៥៥]។ ទោះបីជា លៀង កន បានបង្ហាញថាក្មួយរបស់គាត់ដែលជាកូនកំព្រាកាលពីនៅក្មេងបានរស់នៅជាមួយគាត់ក៏ដោយ[១០៥៦] ក៏មិនមានឯកសារណាមួយគាំទ្រចំពោះអំណះ-

---

[១០៥៣] *សូមមើល* "រូបថតរបស់ តេង ស៊ុន" សម្គាត់ ឯកសារE5/7/1.4។ "លិខិតបញ្ជាក់" E161.2។

[១០៥៤] ទោះបីជាភាពជាសាច់ញាតិតាមរយៈអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់ដោយលិខិតបញ្ជាក់ ("ពាក្យធានាអះអាង" E2/34/5.2) ក៏ភាពជាសាច់ញាតិតែមួយនេះមិនគ្រប់គ្រាន់ទេ (ផ្នែក៤.២.២)។

[១០៥៥] *សូមមើល* "រូបថតរបស់ លៀង កន នៅមន្ទីរស២១" សម្គាត់ ឯកសារE2/35.2។

[១០៥៦] *សូមមើល* "លិខិតបញ្ជាក់ធានាអះអាងរបស់មេឃុំ ចំពោះ ឆាយ កើន" សម្គាត់ E163/3.5។

អំណាងរបស់គាត់ដែរ។ មិនមានភស្តុតាងបង្ហាញថា រូបថតរបស់អ្នកជាប់ឃុំដែលជាមូលដ្ឋានគាំទ្រអំណះអំណាងរបស់គាត់គឺពិតជា ញ៉ែម ងឹយ ឡើយ[១០៩៧]។

- ហៀត តីដៅ (E2/38) បានអះអាងអំពីការបាត់បង់សមាជិកគ្រួសារមួយចំនួនរបស់គាត់ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ហើយបានលើកឡើងថា ពូរបស់គាត់ឈ្មោះ សុះ អែល *ហៅ* តៀ អែល ត្រូវបានចាប់ខ្លួននៅខែមេសា ឆ្នាំ១៩៧៥ និងត្រូវបានឃុំខ្លួននៅមន្ទីរស២១[១០៩៨]។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងគាំទ្រចំពោះអំណះអំណាងនេះទេ។

- ដើមបណ្តឹងរដ្ឋប្បវេណី (E2/62) អះអាងថា បងប្រុសរបស់គាត់ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១។ ក្នុងការគាំទ្រចំពោះអំណះអំណាងនេះ គាត់បានបង្ហាញរូបថតដែលយកមកពីបណ្ណសាររបស់ សារមន្ទីរទួលស្លែង[១០៩៩]។ ប៉ុន្តែរូបថតនេះមិនអាចកំណត់អត្តសញ្ញាណបានទេ ដូច្នេះមិនអាច កំណត់បានថារូបថតនោះជារូបនរណានោះទេ។ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួល ស្គាល់ហើយថាមិនមានឯកសារបង្ហាញអំពីទំនាក់ទំនងសាច់ញាតិជាមួយជនរងគ្រោះនៃមន្ទីរ ស២១នោះទេ[១១០០]។

- ប៉ាន់ ប៊ុច (E2/63) បានអះអាងថា ប្អូនថ្លៃប្រុសរបស់គាត់ឈ្មោះ ភ្លាំង ហួយ ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស២១ ប៉ុន្តែមិនមានភស្តុតាងគាំទ្រចំពោះអំណះអំណាងនេះទេ[១១០១]។

- លឹម យ៉ុន (E2/69) បានអះអាងថា បងប្រុសរបស់គាត់ម្នាក់ត្រូវបានឃុំខ្លួននៅមន្ទីរស២១ ជាការបន្ថែមលើអំណះអំណាងនៃការចាប់ខ្លួន និងការសម្លាប់សាច់ញាតិមួយចំនួនរបស់គាត់

---

[១០៩៧] ប្រតិចារឹក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី) ទំព័រ៣៥-៣៦ (កត់សម្គាល់ថាការស្វែងរក ព័ត៌មានបន្ថែមមិនបានបង្ហាញជាប្រយោជន៍នោះទេ)។

[១០៩៨] "ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ - ហៀត តីដៅ" E2/38។

[១០៩៩] *សូមមើល* "រូបថតនៅ មន្ទីរស២១" សម្គាត់ E165/1/1.2។ "លិខិតបញ្ជាក់របស់ប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង" សម្គាត់ E165/1/1.3។

[១១០០] ប្រតិចារឹក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី) ទំព័រ១៦-១៧។

[១១០១] លើសនេះទៀត ភាពជាសាច់ញាតិតាមរយៈអាពាហ៍ពិពាហ៍តែឯងគឺជាមូលដ្ឋានមិនគ្រប់គ្រាន់សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ (ផ្នែក៤.២.២)។

នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ[១១០២]។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងគាំទ្រចំពោះអំណះអំណាងនេះទេ។

- ចាន់ យឿង (E2/70) បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ សុខ ប៊ុន ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១។ ទោះបីជាអាចបញ្ជាក់អំពីភាពជាសាច់ញាតិក្តី[១១០៣] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទទួលស្គាល់ថា មិនមានភស្តុតាងបញ្ជាក់អំពីការឃុំខ្លួនគាត់នៅមន្ទីរស២១ ទេ[១១០៤]។

- នង សារ៉ាត ហៅ ពណ៌ (E2/73) បានអះអាងថា បងជីដូនមួយរបស់គាត់ឈ្មោះ នង សារួត និងពូរបស់គាត់ឈ្មោះ នង សង ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស២១[១១០៥]។ ប៉ុន្តែអ្នកដាក់ពាក្យសុំមិនបានផ្តល់ភស្តុតាងជាឯកសារទាក់ទងនឹងការឃុំខ្លួន ឬបញ្ជាក់អំពីភាពជាសាច់ញាតិនោះទេ។

- ង៉ែត អ៊ុយ (E2/74) បានអះអាងថា ប្តីរបស់គាត់ឈ្មោះ ប្រាក់ ប៉ាត ដែលជាអតីតកម្មាភិបាលកងទ័ពខ្មែរក្រហមត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរស២១។ ដើម្បីគាំទ្រអំណះអំណាងនេះ គាត់បានយោងលើសក្ខីកម្មរបស់ក្មួយខាងប្តីគាត់ ដែលធ្លាប់ធ្វើការនៅមន្ទីរស២១[១១០៦]។ ទោះបីជាយ៉ាងណាក៏ដោយ អត្តសញ្ញាណជាក់លាក់នៃសាក្សីសំខាន់នេះមិន

---

[១១០២] "ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ - លឹម យ៉ុន" E2/69។

[១១០៣] *សូមមើល* "លិខិតបញ្ជាក់របស់របស់មេឃុំ ចំពោះ ចាន់ យឿង" E161.5 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។

[១១០៤] "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ - សេចក្តីសន្និដ្ឋានបញ្ចប់" E159/5 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១១៥-១១៨។

[១១០៥] *សូមមើល* "ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី - នង សារ៉ាត" ឯកសារ E2/73។

[១១០៦] "ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មដែលអះអាងដោយ ង៉ែត អ៊ុយ" E2/74.1។

ត្រូវបានបង្ហាញនោះទេ។ បន្ថែមពីលើនេះ មិនមានការបញ្ជាក់ ឬឯកសារគាំទ្រចំពោះអំណះ-អំណាងនេះ ឬចំណងសហព័ទ្ធនោះទេ[១១០៧]។

- ធៀវ នាប *ហៅ* ខៀវ នាប (E2/75) បានអះអាងថា ប្តីរបស់គាត់ឈ្មោះ ហេង ជឿន ហៅ ជឿន ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៨ ខណៈពេលដែលប្តីរបស់គាត់គឺជាកម្មាភិបាលនៅមន្ទីរ ៨៧០ និងត្រូវបានបញ្ជូនទៅព្រៃស (ស២៤)។ គាត់បានអះអាងថា បានឃើញការចាប់ខ្លួនប្តីគាត់ និងអះអាងបន្ថែមថាយោធាមួយរូបឈ្មោះ រ៉េត បានប្រាប់គាត់អំពីមរណភាពរបស់ប្តីគាត់នៅស២៤[១១០៨]។ ទោះបីជាយ៉ាងណាក៏ដោយ អត្តសញ្ញាណពិតប្រាកដនៃសាក្សីនេះមិនត្រូវបានគេស្គាល់នោះទេ និងមិនមានការបញ្ជាក់ ឬឯកសារណាមួយគាំទ្រចំពោះអំណះ-អំណាងរបស់គាត់ទេ។ លើសពីនេះ មិនមានភស្តុតាងបង្ហាញអំពីភាពជាសាច់ញាតិឡើយ។

-ម៉ន សុធា (E2/82) បានអះអាងថា ម្តាយរបស់គាត់ ដែលជាអតីតអ្នកការទូត និងសមាជិកគ្រួសារជាច្រើននាក់ផ្សេងទៀតរបស់គាត់ បានបាត់ខ្លួនក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញក្នុងខែមេសាឆ្នាំ១៩៧៥[១១០៩]។ ទោះបីជាចម្លើយរបស់គាត់ ទំនងជាអាចជឿជាក់បានក៏ដោយ ក៏ចម្លើយនេះមិនមានភស្តុតាងបង្ហាញអំពីការជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាពនោះទេ។

-ហុង សាវ៉ាត (E2/83) បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ ឡឹក ស្រេង ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១[១១១០]។ គាត់បានអះអាងថា គាត់បានចំណាំឪពុកមារបស់

[១១០៧] "ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មដែលអះអាងដោយ ង៉ែត អ៊ុយ" E2/74.1។ ប្រតិចារឹក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១) ទំព័រ១៦-១៧។

[១១០៨] "ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មដែលអះអាងដោយ ធៀវ នាប" E2/75.1។

[១១០៩] "ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ - ម៉ន សុធា" សម្គាត់ ឯកសារE2/82។ ប្រតិចារឹក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០០៩ (ម៉ុច សុវណ្ណារី) ទំព័រ ៤៨។

[១១១០] *សូមមើល* "លិខិតបញ្ជាក់របស់មេឃុំ ចំពោះ យូ ហុង" សម្គាត់ ឯកសារ E163/3.11 (បង្ហាញភស្តុតាងអំពីភាពជាសាច់ញាតិ)។

គាត់តាមរយៈរូបថត នៅពេលដែលគាត់បានប្រទះឃើញរូបថតនោះក្នុងឆ្នាំ២០០៨ នៅពេលគាត់ទស្សនាសារមន្ទីរទួលស្លែង។ ប៉ុន្តែ រូបថតនេះ ឬឯកសារភស្តុតាងផ្សេងៗមិនបានផ្តល់ជូនដើម្បីគាំទ្រអំពីការឃុំខ្លួនឪពុកមារបស់គាត់នៅមន្ទីរស២១នោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាយុ១១ឆ្នាំនៅពេលដែលឪពុកមារបស់គាត់បានបាត់ខ្លួននោះ ក៏មិនបានផ្តល់ភស្តុតាងអំពីចំណងពិសេសនៃសេចក្តីស្រលាញ់ ឬការនៅក្នុងបន្ទុករបស់ឪពុកមាគាត់ទេ។

៦៤៩. ដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោម ក៏មិនបានផ្តល់ភស្តុតាងអំពីភាពជាសាច់ញាតិ ឬចំណងពិសេសនៃសេចក្តីស្រលាញ់ ឬការនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់នៃមន្ទីរស២១ ឬស២៤ ទេ។

- ឃួន សារិន (D25/11) ដែលបានអះអាងដោយផ្អែកលើការចាប់ខ្លួន និងការសម្លាប់ឈ្មោះ ខៀវ សាគួរ ដែលគាត់ជាបុគ្គលិកម្នាក់របស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន។ ទោះបីជាមានភស្តុតាងដែលបង្ហាញអំពីការឃុំខ្លួន ខៀវ សាគួរ នៅមន្ទីរស២១ ក្តី[១១១១] ក៏មិនមានឯកសារភស្តុតាងណាមួយបង្ហាញអំពីលក្ខណៈនៃភាពជាសាច់ញាតិជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬភស្តុតាងបង្ហាញអំពីចំណងពិសេសនៃសេចក្តីស្រលាញ់ណាមួយនោះទេ។ ទោះបីជា កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនបានជំទាស់ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ក៏ដោយ ក៏អង្គជំនុំជម្រះបដិសេធពាក្យសុំនេះចោលដែរ។

- សួន សៀង (D25/15) បានទទួលព័ត៌មានពីមិត្តភក្តិរបស់គាត់ថា ប្អូនប្រុសរបស់គាត់បីនាក់ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ ប៉ុន្តែ មិនមានភស្តុតាងបង្ហាញអំពីការឃុំខ្លួនរបស់ពួកគេនោះទេ។ គាត់បានអះអាងបន្ថែមទៀតថា បងប្អូនជីដូនមួយរបស់គាត់ឈ្មោះ ប៉ែន អ៊ុំ *ហៅ* រិទ្ធ ក៏ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១ ដែរ។ ទោះបីជាការឃុំខ្លួនឈ្មោះ ប៉ែន អ៊ុំ

[១១១១] *សូមមើល ឧទា.* "ចម្លើយសារភាពរបស់ ខៀវ សាគួរ" សម្គាត់ ឯកសារE2/12.1 (មានជាភាសាខ្មែរប៉ុណ្ណោះ)។

00573709



នៅមន្ទីរស២១ ត្រូវបានបញ្ជាក់ក្ដី[១១១២] ក៏ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មិនមានភស្តុតាងបញ្ជាក់អំពីភាពជាសាច់ញាតិជាមួយជនរងគ្រោះនេះទេ[១១១៣]។

- ឈឹម ស៊ីថា (E2/22) បានរៀបរាប់ពីការចាប់ខ្លួន ការធ្វើបាប និងការសម្លាប់យោធាមកពីកងពលធំលេខ៣១០ ដែលរូបគាត់ជាសមាជិក។ ទោះបីជាមានយោធាជាច្រើននៅក្នុងកងពលនេះត្រូវបានឃុំខ្លួននៅមន្ទីរស២១ក៏ដោយ ក៏មិនមានជនរងគ្រោះផ្ទាល់ណាមួយក្នុងចំណោមជនរងគ្រោះទាំងនេះ ត្រូវបានបញ្ជាក់អត្តសញ្ញាណថាជា កូវ ផល្លា នោះទេ[១១១៤]។ លិខិតបញ្ជាក់ពីប្រធានភូមិ និងមេឃុំរបស់គាត់បង្ហាញថា ឈឹម ស៊ីថា គឺជាឪពុកមារបស់ កូវ ផល្លា។ ប៉ុន្តែ មិនមានភស្តុតាងបញ្ជាក់អំពីចំណងពិសេសនៃសេចក្ដីស្រលាញ់ណាមួយនោះទេ[១១១៥]។

- ភ្លាន ហ៊ិត (E2/37) បានអះអាងថា រូបគាត់ត្រូវបានចាប់ខ្លួនជាមួយនឹងមិត្តភក្តិ១០នាក់ផ្សេងទៀត ដែល៦នាក់ក្នុងចំណោមពួកគាត់ចុងបញ្ចប់ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ ទោះបីជាយ៉ាងណាក៏ដោយ ចំណងមិត្តភាពមិនស្ថិតនៅក្នុងដែនកំណត់នៃលក្ខណៈវិនិច្ឆ័យតាមវិធាន ២៣(២)(ខ) នៃវិធានផ្ទៃក្នុងនោះទេ(ផ្នែក៤.៤.៤)។

- ញ៉ិប គឹមស្រ៊ា (E2/64) បានអះអាងថា ឪពុកមារបស់គាត់ឈ្មោះ ជាប បារ៉ូ *ហៅ* ប៉ែន ប្រពន្ធរបស់គាត់ឈ្មោះ ឃុត ផន និងប្អូនជីដូនមួយរបស់គាត់ចំនួន ៥ នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ មានភស្តុតាងបង្ហាញថាឈ្មោះ ជាប ប៉ារ៉ូ *ហៅ* ប៉ែន ត្រូវបានឃុំខ្លួននៅមន្ទីរស២១[១១១៦]។ ទោះជាយ៉ាងនេះក្ដី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ

[១១១២] *សូមមើល* “ប្រវត្តិរូបរបស់ ប៉ែន អ៊ុំ ពីមន្ទីរស២១” សម្ងាត់ ឯកសារE165/1/2.6។ “ប្រវត្តិរូប - ប៉ែន អ៊ុំ” សម្ងាត់ ឯកសារE165/1/2.4។

[១១១៣] *សូមមើល* “សៀវភៅគ្រួសាររបស់ សួន សៀង” ឯកសារE165/1/2.1។

[១១១៤] *សូមមើល* “ប្រវត្តិរូបអ្នកទោសជាប់ឃុំឈ្មោះ កូវ ផល្លា” សម្ងាត់ ឯកសារE163/3.4។

[១១១៥] *សូមមើល* “លិខិតធានាអះអាងរបស់មេឃុំ ចំពោះ ឈឹម ភុំ” សម្ងាត់ ឯកសារE163/3.2។

[១១១៦] *សូមមើល* “ប្រវត្តិអ្នកទោសជាប់ឃុំ” ឯកសារE163/3.8។ “ចម្លើយសារភាពរបស់ ជាប ប៉ារ៉ូ ហៅ ប៉ែន” សម្ងាត់ E163/3.9។

ដែលបានកើតនៅឆ្នាំ១៩៧៨ បានទទួលស្គាល់ថា ខ្លួនមិនបានស្គាល់ឪពុកមា ម្តាយមីង និងប្អូនជីដូនមួយរបស់គាត់ទេ[១១១៧]។ ហេតុដូច្នេះ មិនមានចំណងពិសេសនៃសេចក្តីស្រលាញ់រវាងអ្នកដាក់ពាក្យសុំ និងសាច់ញាតិទាំងនោះទេ។

- ស៊ឹម ពៅ (E2/71) បានអះអាងថា បងថ្លៃប្រុសរបស់គាត់ឈ្មោះ ង៉ុយ ស្រេង ត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរស២១[១១១៨]។ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន គាត់បានផ្តល់ប្រវត្តិរូបមួយដែលបានមកពីបណ្ណសាររបស់មន្ទីរស២១[១១១៩]។ ទោះបីជា ង៉ុយ ស្រេង ត្រូវបានឃុំខ្លួននៅមន្ទីរស២១ក្តី ក៏ភាពជាសាច់ញាតិតាមរយៈអាពាហ៍ពិពាហ៍តែមួយនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបង្ហាញអំពីចំណងនៃសេចក្តីស្រលាញ់ ឬភាពនៅក្នុងបន្ទុកនោះទេ (ផ្នែក៤.២.២)។

- Jeffrey JAMES (E2/86) និង Joshua ROTHSCHILD (E2/88) បានអះអាងថា ឪពុកមារបស់ពួកគាត់ឈ្មោះ James W. CLARK ត្រូវបានឃុំខ្លួននៅមន្ទីរ ស២១។ ការឃុំខ្លួនរូបលោក James W. CLARK គឺជាការពិត[១១២០]។ ប៉ុន្តែភាពជាសាច់ញាតិរបស់អ្នកដាក់ពាក្យសុំជាមួយនឹងជនរងគ្រោះមិនមានភស្តុតាងបង្ហាញដល់កម្រិតបទដ្ឋានតម្រូវនោះទេ[១១២១]។

---

[១១១៧] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ (សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១) ទំព័រ ៣៤-៣៥។

[១១១៨] *សូមមើល* "លិខិតបញ្ជាក់របស់មេឃុំ ចំពោះ ស៊ឹម ពៅ" ឯកសារE161.6 (មានតែជាភាសាខ្មែរប៉ុណ្ណោះ) (បញ្ជាក់អំពីភាពជាសាច់ញាតិតាមរយៈការរៀបអាពាហ៍ពិពាហ៍)។

[១១១៩] *សូមមើល* "គម្រោងប្រវត្តិ ង៉ុយ ស្រេង" ឯកសារE2/71.2។

[១១២០] ការផ្តល់ជូនចម្លើយសារភាពរបស់ James W. Clark ពីសារមន្ទីរទួលស្លែង។ *សូមមើល* "ចម្លើយសារភាពរបស់ James W. Clark" ឯកសារE2/86.3 និង E2/88.3។ "សេចក្តីថ្លែងរបស់ James William Clark" ឯកសារE2/86.5 និង E2/88.5។

[១១២១] *សូមមើល* "លិខិតឆ្លងដែនរបស់ Jeffrey James" ឯកសារE2/86.1។ "លិខិតឆ្លងដែនរបស់ Joshua Rothschild" ឯកសារE2/88.1។ "សំបុត្របញ្ជាក់កំណើតរបស់ Jeffrey James" ឯកសារE140.10 (បញ្ជាក់ថា អ្នកដាក់ពាក្យសុំគឺជាកូនប្រុសរបស់ Sherry Alice Clark ប៉ុន្តែមិនបានបញ្ជាក់ថា Sherry Alice Clark គឺជាបង/ប្អូនស្រីរបស់ James W. Clark ទេ។

ទោះបីជាបានរៀបរាប់ពីការឈឺចាប់របស់ខ្លួននៅពេលដែលបានដឹងពីជោគវាសនារបស់ជនរងគ្រោះក៏ដោយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែលមានអាយុទើបតែប្រាំឆ្នាំ និងប្រាំបីឆ្នាំ នៅពេលដែល James W. CLARK ត្រូវបានចាប់ខ្លួនមិនមានភស្តុតាងបញ្ជាក់អំពីចំណងពិសេសនៃសេចក្តីស្រលាញ់ជាមួយនឹងជនរងគ្រោះនោះទេ។

៦៥០. អង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោមនេះ បានបង្ហាញអំពីអំណះអំណាងថាជាជនរងគ្រោះផ្ទាល់នៃមន្ទីរស២១ ឬស២៤ ឬបានបង្ហាញអំពីអត្ថិភាពនៃភាពជាសាច់ញាតិជិតស្និទ្ធ ឬចំណងពិសេសនៃសេចក្តីស្រលាញ់ជាមួយនឹងជនរងគ្រោះផ្ទាល់នៃមន្ទីរស២១ ឬស២៤ ឬការនៅក្នុងបន្ទុករបស់ជនរងគ្រោះទាំងនោះ[១១២២]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញបន្ថែមថា មរណភាពរបស់ជនរងគ្រោះទាំងនោះ បង្កឱ្យមានព្យសនកម្មដែលមានចែងនៅក្នុងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ហើយការខូចខាតនេះ គឺជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មទាំងឡាយដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាព[១១២៣]។

- ប៊ូ ម៉េង (D25/1) បានបាត់បង់ប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន *ហៅ* ធី។

---

[១១២២] នៅក្នុងករណីជាច្រើន អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនៃភាពជាសាច់ញាតិ អាចត្រូវបានទាញសន្និដ្ឋានចេញពីទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យគ្រួសារ ដែលមាននៅក្នុងចម្លើយសារភាព ឬជីវប្រវត្តិរបស់អ្នកជាប់ឃុំ ជាពិសេសនៅពេលចម្លើយសារភាព ឬជីវប្រវត្តិរបស់អ្នកជាប់ឃុំ ស៊ីសង្វាក់គ្នានឹងព័ត៌មានដែលផ្តល់ឱ្យដោយអ្នកដាក់ពាក្យសុំ។ អង្គជំនុំជម្រះបានទទួលយកព័ត៌មាននេះ ដោយសារតែវាកត់ត្រាអំពីអត្តសញ្ញាណរបស់អ្នកជាប់ឃុំ ហើយព័ត៌មាននេះស្ថិតនៅក្នុងផ្នែកបឋមនៃឯកសារ ដែលគេមិនអាចសន្មតដោយសមហេតុផលថាព័ត៌មានទាំងនេះទទួលបានដោយការធ្វើទារុណកម្មនោះទេ។ *សូមមើលឧទា.* "ចម្លើយសារភាពរបស់ Michael Scott DEEDS" ឯកសារE3/472/3 (ទាក់ទងនឹងភាពជាសាច់ញាតិជាមួយនឹង Timothy Scott DEEDS)។

[១១២៣] ដោយសារតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងមួយចំនួន ត្រូវបានទទួលយកដោយផ្អែកលើមូលដ្ឋានជាជនរងគ្រោះដែលជាសមាជិកគ្រួសារជិតស្និត ក៏ជនរងគ្រោះផ្សេងទៀតដែលជាសមាជិកគ្រួសារសាច់ឆ្ងាយត្រូវបានបង្ហាញគ្រាន់តែទុកសម្រាប់ជាព័ត៌មានតែប៉ុណ្ណោះ។ នៅពេលពាក្យសុំផ្អែកទាំងស្រុងលើទំនាក់ទំនងទៅនឹងសមាជិកគ្រួសារសាច់ឆ្ងាយ អង្គជំនុំជម្រះនឹងពិចារណាថាតើភស្តុតាងដែលមាន បានបង្ហាញអំពីអត្ថិភាពនៃចំណងពិសេសនៃសេចក្តីស្រលាញ់ ឬភាពនៅក្នុងបន្ទុកដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះនឹងទទួលយកភស្តុតាងនានា ដែលទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានដេញដោលក្នុងពេលសវនាការតែប៉ុណ្ណោះ។

- ជុំ នៅ (D25/16) បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ នូ សាមឿន និងកូនរបស់គាត់ម្នាក់។
- ឈិន ណារី (D25/2) បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ ទា ហាវតិក។
- ហាវ សោភា (D25/4) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ចិន សៀ *ហៅ* ហាវ ហាន។
- ភឹងហុត ស៊ុនថារី (D25/5) និងអ៊ឹម ស៊ុន្ទី (D25/7) បានបាត់បង់ឪពុក និងប្ដីឈ្មោះ ភឹង តុន ។
- ជុំ ស៊ីរ៉ាត (D25/6) បានបាត់បង់ប្អូនប្រុសពីរនាក់ឈ្មោះ ជុំ ណារិត និង ជុំ ស៊ីណារ៉េត។
- មាសកេត សំភាត់ (D25/8) ជូឡុង អង់តូនីយ៉ា (TIOULONG Antonya) (D25/27) ជូឡុង ណេវ៉ា (TIOULONG-ROHMER Neva) (D25/28) គីម៉ារី ណេវីនកា (KIMARI Nevinka) (D25/26) និង គីម៉ារី វីសាកា (KIMARI Visaka) (E2/29) បានបាត់បង់កូនស្រី ប្អូនស្រី និងម្ដាយឈ្មោះ ជូឡុង រង្សី និងកូនប្រសាប្រុស ប្អូនថ្លៃប្រុស និងឪពុកឈ្មោះ លឹម គីម៉ារី។
- រស់ ម៉េន (D25/9) បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ រស់ ធឹម។
- ឆែ ប៊ាប (D25/10) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ឆែ ហេង។
- ជ្រាំង សំអ៊ាន (D25/12) បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ជ្រាំង សំអុន *ហៅ* សោម សំអុន។
- ស៊ាង វ៉ាន់ឌី (D25/13) បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ស៊ាង ផុន[១១២៤]។
- តូច មុនិន្ទ (D25/14) បានបាត់បង់បងប្រុសជីដូនមួយឈ្មោះ ជា ខន ដែលបានចិញ្ចឹមបីបាច់រូបគាត់ ហើយដែលគាត់ជាសាច់ញាតិដែលនៅរស់រានមានជីវិតតែម្នាក់គត់។
- កាន់ ស៊ុន្ទរ៉ា (D25/17) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ជឹម ឡាង និងបងថ្លៃស្រីឈ្មោះ អោម ឃិនដូនី។
- ម៉ាន សួត (D25/18) បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ ម៉ាន ស៊ឹម *ហៅ*រៀម។

---

[១១២៤] "កំណត់ហេតុស្លាប់ចម្លើយតបរបស់ សៀង ផុន *ហៅ* ផា" ឯកសារE141.1។

- គង់ ទេស (D25/19) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ សេក ផៀក។
- ង៉ែត សុខ (D25/20) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ណុប សរ *ហៅ* ណុប ង៉ាន *ហៅ* ចារីន *ហៅ* ង៉ែត ង៉ែម[១១២៥]។
- តាត់ ឡូន (D25/21) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ស៊ិត *ហៅ* សុក ប៊ុន។
- Timothy Scott DEEDS (D25/22) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ Michael DEEDS។
- យឹម ឡេង (D25/23) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ធ្លក លួន *ហៅ* យ៉ន។
- អ៊ុម ពិសិដ្ឋ គឺជាសិទ្ធិវន្តរបស់ សួស សារិន (D25/24) ដែលបានបាត់បង់បងស្រីរបស់គាត់ឈ្មោះ សួស សារណ្ណ។
- កែ ខុន (D25/25) និង កែ សាម៉ូត (E2/46) បានបាត់បង់បងប្រុសឈ្មោះ កែ កេងស៊ី។
- អៀម សួយ (E2/21) ដែលបានបាត់បងប្រុសរបស់គាត់ឈ្មោះ ជុក ចយ *ហៅ* ជៀវ។
- អ៊ុល សាយ *ហៅ* វៀម (E2/24) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ អេង ម៉ាក *ហៅ* វ៉ើន។
- ស៊ីន លឹមសៀ (E2/25) បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ស៊ីន ឈុនលឹម។
- អ៊ូ សារវិទ្ធ (E2/26) ញ៉ឹក អ៊ូដាវី(NHEK Oudavy) (E2/31) និង អ៊ូ កាមេឡា (OU Kamela) (E2/27) បានបាត់បង់ប្អូនប្រុស ប្តី និងឪពុកឈ្មោះ អ៊ូ វិនខី។
- រស់ ជួ ស៊ីអ៊ី (ROS Chuorsiy) (E2/28) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ រស់ សារិន។
- ញ៉ឹម គឹមហៀន (E2/30) បានបាត់បង់បងប្រុសទាំងពីររបស់គាត់ឈ្មោះ ញ៉ឹម គួយ និង ញ៉ឹម ចាន់[១១២៦]។

---

[១១២៥] *សូមមើល* "លិខិតបញ្ជាក់កំណើតរបស់ ង៉ែត សុខ" ឯកសារE165/1/5។ "អត្តសញ្ញាណប័ណ្ណរបស់ ង៉ែត សុខ" ឯកសារ E165/1/1 (បញ្ជាក់អំពីភាពជាសាច់ញាតិ)។ "ជីវប្រវត្តិរបស់ សរ ហៅ ចារីន" ឯកសារE3/467/2 និង E165/1/5.2។ "លិខិតបញ្ជាក់" ឯកសារ E165/1/5.3 (មានតែជាភាសាខ្មែរប៉ុណ្ណោះ) (បញ្ជាក់អំពីការឃុំខ្លួន ណុប សរ *ហៅ* ណុប ង៉ាន ហៅ ចារីន នៅមន្ទីរស២១)។

00573714



- សួន សុខុម៉ាលី(SUON Sokhomaly) (E2/39) ដែលបានបាត់បង់ប្តីរបស់គាត់ឈ្មោះ សួន កាសេត។
- ស៊ីន ស៊ីណែត ហៅ ស្រ៊ុន (E2/41) បានបាត់បង់ជីតារបស់គាត់ឈ្មោះ ភាច គីម *ហៅ* ស៊ិន ដែលរូបគាត់បានរស់នៅជាមួយតាំងពីគាត់អាយុ៧ឆ្នាំ[១១២៧]។
- រូន ស្រីណុប (E2/42) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ រូន ម៉ាត់ *ហៅ*សារី។
- អែល លីម៉ះ (E2/43) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ីស្មាអែល អាម៉ាត់ *ហៅ* សុខ។
- ស្មាន ស (E2/45) និង ស្មាន ណុប (E2/44) បានបាត់បង់ប្អូនប្រុសឈ្មោះ ស្មាន ស្លេះ *ហៅ* ឡេង សុខា និងបាត់បង់កូនប្រុស និងក្មួយឈ្មោះ សា ម៉ាត់ *ហៅ* សារឿន។
- ម៉ែន ឡាយ (E2/47) បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ មិន កាន។
- ញ៉ែម សុផាន (E2/48) បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ញ៉ែម ថុល *ហៅ*វ៉ា។
- នេត ផល្លី (E2/50) បានបាត់បង់បងប្រុសឈ្មោះ នេត ប៊ុនធី។
- ម៉ាន ម៉ះ *ហៅ* ម៉ាន ម៉ាលីម៉ះ (E2/51) បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ តា ឡុសម៉ាត់ *ហៅ* ម៉ាន ម៉ាត់។
- កុំ មេន *ហៅ* គុម មេន (E2/52) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ ស្រី យ៉េង។
- ទ្រី ង៉ិចលាង (E2/53) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ខឿង មួយស៊័រ

---

[១១២៦] *សូមមើល* "ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មដែលអះអាងដោយ ជា អ៊ឹម" ឯកសារE2/30.10។ "សេចក្តីថ្លែងរបស់ គីម គុជ និង ហែម សាគូ ឯកសារ E164/1.1" (បានបញ្ជាក់ដោយមេឃុំ និងបញ្ជាក់អំពីភាពជាសាច់ញាតិ)។ "រូបថតរបស់ ញឹម គួយ" ឯកសារE2/30.2។ "រូបថត ញឹម គួយ ថតនៅមន្ទីរស២១" ឯកសារ E2/30.9។ "រូបថត ញឹម ចាន់" ឯកសារE2/30.3។ "រូបថត ញឹម ចាន់ ថតនៅមន្ទីរស២១" ឯកសារE2/30.9។ "សេចក្តីអះអាងរបស់ គីម គុជ និង ហែម សាគូ" ឯកសារE164/1.2 (បញ្ជាក់ថា បុគ្គលដែលនៅក្នុងរូបថតគឺ ញឹម គួយ, ញឹម ចាន់, និង ដួង វុំ)។ "ប្រវត្តិរូបអ្នកទោសជាប់ឃុំ ឈ្មោះ ញឹម ចាន់" ឯកសារ E2/30.6។

[១១២៧] *សូមមើល* "លិខិតបញ្ជាក់កំណើតរបស់ ស៊ិន ស៊ីណែត" ឯកសារE165/1/3។ "សៀវភៅគ្រួសារ របស់ ស៊ិន ស៊ីណែត" ឯកសារE165/1/3.1។ "ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង របស់ឈ្មោះ ភាច គីម" ឯកសារE165/1/3.2។ "រូបថតជនរងគ្រោះនៅមន្ទីរស២១" ឯកសារE165/1/3.4។ "រូបថតរបស់ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ពីអត្តសញ្ញាណរូបថតជនរងគ្រោះនៅមន្ទីរស២១" ឯកសារE165/1/3.5។

- ហេង ង៉ិចហុង (E2/54) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ហេង។
- បេង ចាន់ថន (E2/55) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ បេង ពុំ។
- យុន ឈឺន (E2/56) បានបាត់បង់ក្មួយប្រុសរបស់គាត់ឈ្មោះ យុន លឿន ដែលបានរស់នៅជាមួយគាត់រហូតដល់អាយុ១៥ឆ្នាំ នៅពេលដែលក្មួយរបស់គាត់បានចូលបដិវត្តន៍។
- លី យៀក (E2/57) បានបាត់បង់ប្អូនស្រីរបស់គាត់ឈ្មោះ អ៊ួយ រ៉ែន *ហៅ* ម៉ៅ[១១២៨]។
- ពូល ពន្លឹក *ហៅ* ង៉ែត (E2/58) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ពូល ទឿន *ហៅ* ចាំង។
- ចាន់ គ្រួច (E2/59) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ចាន់ នួន *ហៅ* ស៊ីនួន។
- នង គឹមលៀង (E2/60) បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ នង គឹមហ្កេច ហៅ នង គឹមវ៉េត[១១២៩]។
- ពេញ សុខខេន (E2/66) បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ពេញ សុភាព[១១៣០]។
- កាន សាន (E2/72) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ កាន កន។
- អ៊ុង វឿន *ហៅ* ហ៊ុល វឿន (E2/76) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ុង គាំ ហៅ ភ័ណ[១១៣១]។

---

[១១២៨] *សូមមើល* "លិខិតបញ្ជាក់កំណើតរបស់ លី យៀក" ឯកសារE165/1/4។ "សៀវភៅស្នាក់នៅរបស់ លី យៀក" ឯកសារE165/1/4.1។ *សូមមើលផងដែរ* "បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃនៃមន្ទីរ ស.២១" ឯកសារE165/1/4.2។ (បញ្ជាក់អំពីភាពជាសាច់ញាតិ និងការឃុំខ្លួន អ៊ួយ រ៉ែន ហៅ ម៉ៅ នៅមន្ទីរ ស២១ ដែលឈ្មោះនេះមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសដោយមានចំណារបញ្ជាក់ថា រូបគាត់ស្លាប់ដោយជំងឺ ឯកសារ E165/1/4.2។

[១១២៩] *សូមមើល* "ទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់ឈ្មោះ នង គឹមលាង" ឯកសារ E2/60។ "ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងរបស់ឈ្មោះ នង គឹមវ៉េត" ឯកសារ E2/60.1។

[១១៣០] *សូមមើល* "ប្រវត្តិរូប ពេញ សុភាព" ឯកសារ E2/66.3។ "ការបញ្ជាក់ពីវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ" ឯកសារ E2/66/3 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។ សូមមើលផងដែរ "អត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ ពេញ សុខខេន" ឯកសារ E2/66/5។ "លិខិតបញ្ជាក់របស់មេឃុំ ចំពោះ យិន សំអាន" ឯកសារ E163/3.10 (បញ្ជាក់ ពីភាពជាសាច់ញាតិ)។

[១១៣១] *សូមមើល* "លិខិតបញ្ជាក់របស់មេឃុំ" ឯកសារ E164/1.9 (បញ្ជាក់ពីភាពជាសាច់ញាតិ)។ "ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ អ៊ុង គាំ" ឯកសារ E2/76.4។

00573716



- មាស សារឿន (E2/78) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក តុប។
- សេក សៀក (E2/79) បានបាត់បង់បងប្រុសជីដូនមួយ និងគូដណ្តឹងរបស់គាត់ ឈ្មោះ ម៉ក់ ឈឿន ដែលបានរស់នៅជាមួយក្រុមគ្រួសាររបស់គាត់។
- ឆាត គីម ឈុន (E2/81) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អាំ ផាត់ និងសាច់ញាតិរបស់គាត់ឈ្មោះ ពត ម៉យ ហៅ សាផល[១១៣២]។
- អ៊ុក វ៉ាំសោធិន (E2/84) បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក ជី។
- Martine LEFEUVRE (E2/85) និង អ៊ុក នារី (E2/89) បានបាត់បង់ប្តី និងឪពុក ឈ្មោះ អ៊ុក កេត។ និង
- Robert HAMILL (E2/87) បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ Kerry HAMILL។

## ៤.៤ ការទាមទារសំណង

៦៥១. ការសុំទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលព្យសនកម្មរបស់ពួកគាត់ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះថា វាបណ្តាលមកពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តិដោយ កាំង ហ្គេកអ៊ាវ នឹងត្រូវបានផ្តល់ជូននៅពេលដែលការទាមទារនោះ៖

ក). មានលក្ខណៈជាសំណងផ្លូវចិត្ត និងជាសមូហភាព អនុលោមតាមវិធាន២៣(១)(ខ) នៃវិធានផ្ទៃក្នុង និង

ខ). មានលក្ខណៈច្បាស់លាស់ ឬជាក់លាក់គ្រប់គ្រាន់ ដើម្បីអាចឲ្យមានការចេញដីកាបង្គាប់ប្រឆាំងនឹងពិរុទ្ធជន។

---

[១១៣២] *សូមមើល* "លិខិតបញ្ជាក់របស់មេឃុំ ចំពោះ ឆាត គីមឈុន" ឯកសារ E161.10 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។ "រូបថតរបស់ឈ្មោះ អំ ផុន" សម្គាត់ ឯកសារ E161.12 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។ "លិខិតបញ្ជាក់របស់មេឃុំចំពោះ ឆាត គីមឈុន" ឯកសារ E161.11 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។ "ប្រវត្តិរូបអ្នកទោសជាប់ឃុំ របស់ ឈ្មោះ ពត ម៉យ" សម្គាត់ ឯកសារ E2/81.3 (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។ "ប្រវត្តិរូបរបស់ឈ្មោះ ពត ម៉យ" សម្គាត់ ឯកសារ E2/81.4។

### ៤.៤.១ សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៦៥២. នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានបង្គាប់ឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីទម្រង់នៃសំណងផ្លូវចិត្ត និងជាសមូហភាពដែលទាមទារប្រឆាំងនឹងជនជាប់ចោទ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព[១១៣៣]។ នៅក្នុងការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីសន្និដ្ឋានរួមមួយដែលសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ជនរងគ្រោះនៃការរំលោភលើសិទ្ធិមនុស្ស និងអំពើហិង្សាទ្រង់ទ្រាយធំក្នុងការទទួលបាននូវសំណង និងបានស្នើសុំថាសំណងដែលត្រូវផ្តល់ដោយជនជាប់ចោទ នោះគួររួមមានបញ្ចូលជាអប្បបរមានូវ[១១៣៤]៖

- ការចងក្រង និងផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោសដែលធ្វើឡើងដោយ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅក្នុងអំឡុងពេលសវនាការ ដែលក្នុងនោះគាត់ទទួលស្គាល់នូវការឈឺចាប់របស់ជនរង-គ្រោះ និងការចងក្រងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី។
- ការទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ (ទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត) រួមទាំងការដឹកជញ្ជូនទៅកាន់ និងត្រឡប់មកពីកន្លែងផ្តល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃ។
- ការផ្តល់ថវិកាដល់កម្មវិធីសិក្សាអប់រំ ដែលជូនដំណឹងដល់ប្រជាជនកម្ពុជាអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ជាពិសេសនៅមន្ទីរស២១។

---

[១១៣៣] សូមមើល "សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល" ឯកសារE159 ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

[១១៣៤] "សារណារួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង" ឯកសារE159/3 ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ ៤៣-៤៤ (ស្នើសុំ "សំណងផ្លូវចិត្ត និងជាសមូហភាពដែលប្រកបដោយអត្ថន័យ[...]" ដែល អ.វ.ត.ក "គួរតែព្យាយាមបង្កើតឲ្យដល់កម្រិតអតិបរមា [...] ដោយធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល ដែលមានស្រាប់")។

00573718



- ការបង្កើតបូជនីយដ្ឋាន និងរបងវត្ថុនៅមន្ទីរស២១ (បឹងជើងឯក និងគុកព្រៃស) ក៏ដូចជានៅក្នុងមូលដ្ឋានសហគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។
- បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០១ ទៅក្នុងសាលក្រមស្ថាពរ រួមទាំងការពិពណ៌នាអំពីទំនាក់ទំនងរបស់ពួកគាត់ ជាមួយនឹងមន្ទីរ ស២១[១១៣៥]។

៦៥៣. ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាជាអ្នកទីទ័លក្រមិនមានលទ្ធភាព ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យអង្គជំនុំជម្រះប្រកាសអំពីសមត្ថកិច្ចរបស់ អ.វ.ត.ក ដើម្បីធានាថារាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់សំណងនោះ ដោយអនុលោមទៅតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬក៏អង្គភាពជនរងគ្រោះនឹងផ្តល់សំណងនោះ តាមរយៈការបង្កើតមូលនិធិក្នុងភារៈគ្រប់គ្រង (Trust Fund)[១១៣៦]។

៦៥៤. នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ឡើងវិញនូវសំណើសុំដែលបានគូសបញ្ជាក់នៅក្នុងសារណារួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយមានដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ និងក្រុម៣ បានផ្តល់ព័ត៌មាន បន្ថែមពិស្តារ ឬការទាមទារបន្ថែមទៀត។ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានស្នើឱ្យ មាន ៖

- ការបញ្ជាក់នៅក្នុងសាលក្រមស្ថាពរអំពីការទទួលស្គាល់នូវសិទ្ធិទទួលបានសំណង។
- ការផ្សព្វផ្សាយសាលក្រមរបស់អង្គជំនុំជម្រះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។
- ការផ្តល់សេវាថែទាំសុខភាពដោយឥតគិតថ្លៃសម្រាប់ជនរងគ្រោះទូទៅ និងជាពិសេសជនរងគ្រោះនៅមន្ទីរស២១ ដែលការថែទាំសុខភាពនោះរួមបញ្ចូលទាំងជំនួយផ្លូវចិត្ត ហើយជំនួយ

---

[១១៣៥] "សារណារួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង" ឯកសារE159/3 ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ១៦, ២១, ២៤, ២៦-៣០, ៤៥។

[១១៣៦] "សារណារួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង" ឯកសារE159/3 កថាខណ្ឌ២-៤១, ៤៧។

បែបនោះ ដែលត្រូវបានផ្តល់ជូនតាមរយៈអង្គការចិត្តសង្គមអន្តរវប្បធម៌គួរត្រូវបានគាំទ្រ និងពង្រឹងបន្ថែមតាមរយៈការផ្តល់សំណង។

- គំនិតផ្តួចផ្តើមអប់រំសង្គមកម្ពុជា ស្តីពីការរំលោភបំពានទៅលើសិទ្ធិមនុស្ស អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ វិធានការជាក់លាក់ដែលបានស្នើឡើងនៅក្នុងបញ្ហានេះ រួមមានការផ្តល់ប្រាក់បៀវត្សរ៍ និងការហ្វឹកហ្វឺនគ្រូបង្រៀន កសាងសាលារៀន រៀបចំកម្មវិធីសិក្សា បោះពុម្ពឯកសារសម្រាប់សិក្សា និងការបណ្តុះបណ្តាលជាបន្តបន្ទាប់សម្រាប់អ្នកចូលរួមនៅមូលដ្ឋានអំពីកម្មវិធីអប់រំសិទ្ធិ។

- ជំនួយក្នុងទម្រង់នៃការផ្តល់មូលនិធិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូច និងវគ្គបណ្តុះបណ្តាលស្តីពីជំនាញអាជីវកម្ម។

- ការសាងសង់បូជនីយដ្ឋាន ជាពិសេស នៅជើងឯក និងព្រៃស រួមទាំងការធ្វើស្លាកឈ្មោះដែលមានចារឈ្មោះជនរងគ្រោះទាំងអស់ ព្រមទាំងផ្ទាំងសិលាប្រកាសព័ត៌មានដែលមានរាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាវត្ត និងរបងវត្ត នៅតាមមូលដ្ឋានសហគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

- ការប្រកាសឲ្យមានថ្ងៃចងចាំថ្នាក់ជាតិមួយ ផ្សេងពីទិវាជ័យជម្នះ ៧មករា ដើម្បីជាការចងចាំដល់ជនរងគ្រោះដែលបានស្លាប់ និងបានទទួលរងការឈឺចាប់ ក្រោមស្នាដៃពួកខ្មែរក្រហម និង

- ការលាតត្រដាងទាំងស្រុង និងដោយស្មោះត្រង់អំពីទ្រព្យសម្បត្តិក្នុងនាមជាជនជាប់ចោទ[១១៣៧]។

៦៥៥. ចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានស្នើឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យកាន់តែច្បាស់អំពីគម្រោងសម្រាប់អនុវត្តការផ្តល់សំណង និងស្នើសុំឲ្យអង្គភាពជនរងគ្រោះបន្តអាណត្តិរបស់ខ្លួនដើម្បីប្រឹក្សាយោបល់ទូលំទូលាយស្តីពីរបៀបក្នុងការអនុវត្តសំណងក្នុងបរិបទប្រទេសកម្ពុជា[១១៣៨]។

---

[១១៣៧] "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ - សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារE159/7 ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១២១។

[១១៣៨] "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ - សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារE159/7 ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១១៩-១២៤។

៦៥៦. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានស្នើឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះសំណងដូចខាងក្រោមនេះ ដោយមិនគិតអំពីទ្រព្យសម្បត្តិ ឬប្រាក់ចំណូលបច្ចុប្បន្នរបស់គាត់ឡើយ ៖

- សរសេរលិខិតមួយច្បាប់ផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើសុំរដ្ឋាភិបាលផ្តល់នូវការសុំអភ័យទោសដ៏ស្មោះត្រង់ ឥតក្លែងបន្លំនិងប្រកបដោយសច្ចៈចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

- រៀបចំផ្ទាំងសិលាជាបូជនីយដ្ឋានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ពួកគាត់ និងការរៀបចំផ្ទាំងសិលាព័ត៌មានអំពីជនរងគ្រោះ រួមទាំងការផ្តល់នូវការបកប្រែព័ត៌មាននេះជាពីរភាសាផ្លូវការផ្សេងទៀតរបស់ អ.វ.ត.ក។

- រៀបចំសាងសង់បូជនីយដ្ឋាននៅទីតាំងអតីតមណ្ឌលកែប្រែនៅព្រៃស និងរៀបចំឱ្យមានការប្រកួតប្រជែងដេញថ្លៃផ្នែកស្ថាបត្យកម្មជាអន្តរជាតិ។

- រៀបចំដំណើរទស្សនកិច្ចដោយគ្មានការបង់ប្រាក់ យ៉ាងហោចណាស់ក៏សម្រាប់ដើមបណ្តឹង-រដ្ឋប្បវេណីចំនួន១៣នាក់ ដែលមិនមែនជាអ្នករស់នៅទីក្រុងភ្នំពេញ ទៅកាន់សារមន្ទីរទួល-ស្លែង ព្រៃស និងជើងឯក បីដងក្នុងមួយឆ្នាំ ហើយការធ្វើទស្សនកិច្ចម្តងៗមានរយៈពេលបួនថ្ងៃ។

- ផ្តល់សេវាព្យាបាលសុខភាព និងថ្នាំពេទ្យ និងសេវាផ្នែកចិត្តសាស្ត្រសម្រាប់អ្នកនៅរស់រានមានជីវិតពីទួលស្លែង ព្រៃស និងជើងឯក ប្រសិនបើមាន និងផ្តល់សេវាព្យាបាលសុខភាព និងថ្នាំពេទ្យ និងសេវាផ្នែកចិត្តសាស្ត្រជូនជនរងគ្រោះដោយប្រយោល ប្រសិនបើជំងឺនោះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។

- រៀបចំផ្សព្វផ្សាយឯកសារសោតទស្សន៍ យ៉ាងហោចណាស់មានរយៈពេល១០០ម៉ោងអំពីការជំនុំជម្រះក្តី រួមបញ្ចូលទាំងការផ្សព្វផ្សាយទៅតាមបណ្តាខេត្តនានា ដោយបញ្ចាំងឯកសារសោតទស្សន៍នោះឱ្យបានទៀងទាត់។

---

- ផ្តល់ឯកសារជាលាយលក្ខណ៍អក្សរ និងថតជាសំឡេងចំនួន១០ច្បាប់ និងធ្វើការពន្យល់អំពីសាលក្រមស្តាពរប្រឆាំងនឹងជនជាប់ចោទ សម្រាប់ដាក់នៅក្នុងវត្តមួយ ក្នុងឃុំនីមួយៗ

- ប្រារព្ធពិធីរំឭកចំនួន១៧លើក ដើម្បីដាក់ឈ្មោះអគារសាធារណៈតាមឈ្មោះជនរងគ្រោះ និងការបង្កើតផ្ទាំងសិលាព័ត៌មាន។ និង

- សរសេរលិខិតចំហមួយផ្ញើទៅជូនរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើថា មួយភាគបីនៃថ្លៃចូលទៅទស្សនកិច្ចមន្ទីរស២១ និងជើងឯក ត្រូវយកមកប្រើប្រាស់សម្រាប់សំណងទាំងនេះ ហើយប្រាក់ដែលនៅសល់ត្រូវយកមកបែងចែកឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលនេះជាការផ្តល់សំណងជាសាច់ប្រាក់[១១៣៩]។

៦៥៧. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានស្នើសុំសំណងផ្លូវចិត្ត និងជាសមូហភាព ដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មានអំពីដំណើរការជំនុំជម្រះក្តីនៅតាមបណ្តាខេត្តនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការតាំងពិព័រណ៍នៅតាមទីធ្លាសាធារណៈ។

- ចងក្រង និងបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោសរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងអំឡុងពេលសវនាការ ដោយទទួលស្គាល់នូវការឈឺចាប់នានាដែលជនរងគ្រោះបានទទួលរង រួមជាមួយនឹងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

- ផ្តល់ជូនដល់ជនរងគ្រោះនូវជំនួយផ្នែកសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ដោយរួមបញ្ចូលទាំងការថែទាំវេជ្ជសាស្ត្រផ្នែករាងកាយ និងផ្លូវចិត្ត និងទទួលបាននូវការរ៉ាប់រងលើថ្លៃធ្វើដំណើរទៅកាន់ និងត្រឡប់ពីមណ្ឌលសុខភាព។

---

[១១៣៩] "សហមេធាវីការពារក្តីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារE159/6 ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ១៤-២១។

- ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីអប់រំនៅតាមសាលារៀន និងសារមន្ទីរនានាដើម្បីផ្សព្វផ្សាយដល់ពលរដ្ឋកម្ពុជាឲ្យយល់ដឹងអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ជាពិសេសនៅមន្ទីរស២១ និងនៅជើងឯក។

- សាងសង់ឬជនីយដ្ឋាននៅជើងឯក និងព្រៃស។

- ឆ្លាក់ឈ្មោះជនរងគ្រោះទាំងឡាយដែលជាប់ឃុំឃាំងនៅមន្ទីរស២១ នៅលើជញ្ជាំងខាងក្រៅនៃមន្ទីរស២១។

- សាងសង់ស្តូកមួយដើម្បីជាការរំឭកដល់ជនរងគ្រោះដែលគេមិនស្គាល់អត្តសញ្ញាណ។

- សាងសង់ផ្លូវដើរមួយអមជញ្ជាំងខាងក្រៅនៃមន្ទីរស២១។

- ថែរក្សាអគារ និងបន្ទប់ឃុំឃាំងនៃមន្ទីរស២១ឲ្យស្ថិតក្នុងស្ថានភាពដើម និងរក្សាទុកឲ្យបានគង់វង្សនូវឧបករណ៍ធ្វើទារុណកម្មនានា ដែលនៅសេសសល់នៅទីនោះ។

- ថែរក្សាបណ្ណសារទាំងឡាយដែលមាននៅមន្ទីរស២១ រួមទាំងបណ្ណសារដែលបើកទូលាយដល់សាធារណជន ឬបណ្ណសារដែលពុំអនុញ្ញាតឲ្យសាធារណជនប្រើប្រាស់។

- ថែរក្សាផ្ទាំងគំនូរដែលគូរដោយ វ៉ាន់ ណាត ដែលដាក់បង្ហាញនៅមន្ទីរស២១។

- ថែរក្សាការពារសារមន្ទីរជើងឯក។

- បញ្ចូលក្នុងសាលក្រមស្ថាពរ នូវឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ព្រមទាំងការបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ ជាមួយនឹងមន្ទីរស២១ ផងដែរ និង

- ចុះផ្សាយផ្នែកនៃសាលក្រមដែលទាក់ទងនឹងអង្គហេតុ ទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ ក៏ដូចជាផ្នែកសម្រេចសេចក្តីទៅក្នុងរាជកិច្ច និងសារព័ត៌មានជាតិផ្សេងៗទៀត

ក្នុងរយៈពេលចាប់ពី៦ខែ ទៅ១ឆ្នាំ បន្ទាប់ពីមានការជូនដំណឹងអំពីសាលក្រមនោះ និងធានាឲ្យមានការចាក់ផ្សាយសាលក្រមនេះ ជាប្រចាំនៅតាមបណ្តាញទូរទស្សន៍ និងវិទ្យុជាតិ[១១៤០]។

៦៥៨. ក្នុងករណីដែលជនជាប់ចោទត្រូវបានកំណត់ថាជាអ្នកទីទ័លក្រមិនមានលទ្ធភាព ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានស្នើបន្ថែមទៀតឲ្យអង្គជំនុំជម្រះធ្វើសំណើទៅរាជរដ្ឋាភិបាលកម្ពុជា ឲ្យអនុវត្តវិធានការទាំងនេះ ដោយអនុលោមទៅតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬក៏បង្គាប់ឲ្យមានការបង្កើតមូលនិធិស្ម័គ្រចិត្តពិសេសមួយ ដែលរៀបចំដោយអង្គភាពជនរងគ្រោះ។ ចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះបង្កើតយន្តការសម្រាប់ការអនុវត្តសំណង និងយន្តការមួយទៀតសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកសំណងផ្លូវចិត្ត ក្នុងករណីដែលមិនមានការអនុវត្តទៅតាមការផ្តល់សំណង[១១៤១]។

៦៥៩. ក្នុងការឆ្លើយតបនៅក្នុងដីកាសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួនមិនជំទាស់ទៅនឹងការផ្តល់សំណងតាមសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ហើយបានធ្វើការកត់សម្គាល់ជាពិសេសអំពីសំណើសុំសំណងក្នុងទម្រង់នៃការចងក្រង និងផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោសដែលធ្វើឡើងដោយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងអំឡុងពេលសវនាការ ដែលទទួលស្គាល់នូវការឈឺចាប់របស់ជនរងគ្រោះ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីបានចង្អុលបង្ហាញថាជនជាប់ចោទត្រូវបានរកឃើញរួចហើយថាជាអ្នកទីទ័លក្រ នៅពេលបញ្ជូនរូបគាត់មក អ.វ.ត.ក[១១៤២]។

---

[១១៤០] "សហមេធាវីការពារក្តីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារE159/5 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ *សូមមើលផងដែរ* "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣៖ សារណាបន្ថែមទាក់ទងនឹងការសងសំណង" ឯកសារE159/3/1 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

[១១៤១] "សហមេធាវីការពារក្តីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) សេចក្តីសន្និដ្ឋានបញ្ចប់" ឯកសារE159/5 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

[១១៤២] "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី" ឯកសារE159/8 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៤៩-៥០។

### ៤.៤.២ ក្របខណ្ឌគតិយុត្តិ

៦៦០. ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក រួមទាំងសិទ្ធិសម្រាប់ជនរងគ្រោះដើម្បីចូលរួមជាភាគីនៅក្នុងដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌលើជនជាប់ចោទ ក្នុងការគាំទ្រការចោទប្រកាន់ និងដើម្បីដាក់បណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងការទាមទារសំណងផ្លូវចិត្ត និងជាសមូហភាព ប្រឆាំងនឹងជនជាប់ចោទចំពោះព្យសនកម្មដែលបង្កឡើងដោយផ្ទាល់ពីឧក្រិដ្ឋកម្មនានាដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព[១១៤៣]។

៦៦១. ទោះបីជាវិធានផ្ទៃក្នុងមិនស្របតាមច្បាប់ជាតិជាច្រើនចំណុចក៏ដោយ ក៏សញ្ញាណនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក កើតចេញមកពីទម្រង់ស្រដៀងគ្នានៃការចូលរួមដែលត្រូវបានទទួលស្គាល់នៅចំពោះមុខតុលាការជាតិមួយចំនួន រួមទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ[១១៤៤]។ លក្ខណៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺថា ការផ្តល់សំណងគឺជាបន្ទុកផ្ទាល់មុខរបស់ពិរុទ្ធជន បន្ទាប់ពីមានការសម្រេចអំពីការទទួលខុសត្រូវចំពោះព្យសនកម្មដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីថា ជាព្យសនកម្មដែលបាន បណ្តាលមកពីការប្រព្រឹត្តិ

---

[១១៤៣] វិធានផ្ទៃក្នុង ២៣(១) ចែងថា "គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី ៖ ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង ខ) អនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាននេះ"។

[១១៤៤] មិនដូចជាតុលាការកម្ពុជាសាមញ្ញឡើយ ពោលគឺ អ.វ.ត.ក មិនមានសមត្ថកិច្ចផ្តល់សំណងជាប្រាក់ជាលក្ខណៈបុគ្គលទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ផ្ទុយទៅវិញ ការផ្តល់សំណងនៅក្នុងបរិបទ អ.វ.ត.ក គឺជាសំណង "ផ្លូវចិត្ត និងសមូហភាព" (វិធានផ្ទៃក្នុង ២៣(១)(ខ))។ ការងាកចេញបែបនេះពីច្បាប់ជាតិ ត្រូវបានពិចារណាថាចាំបាច់ ដោយគិតអំពីចំនួនដ៏ច្រើននៃដើមបណ្តឹងរដ្ឋប្បវេណី ដែលរំពឹងថាមាននៅចំពោះមុខ អ.វ.ត.ក និងផលវិបាកដែលមិនអាចចៀសផុត នៃការកំណត់បរិមាណក្នុងវិសាលភាពពេញលេញនៃការបាត់បង់ ដែលក្រុមជនរងគ្រោះដែលមានលក្ខណៈមិនច្បាស់លាស់បានទទួលរង។ ដូច្នេះ សំណងនៅចំពោះមុខ អ.វ.ត.ក គឺធ្វើឡើងក្នុងលក្ខណៈជានិមិត្តរូបជាសារវន្ត (មានគោលបំណងទទួលស្គាល់ជាផ្លូវការដល់ជនរងគ្រោះ និងជួយស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរ និងថែរក្សានូវការចងចាំជារួម) ជាជាងក្នុងលក្ខណៈជាការសងជំងឺចិត្ត។

បទល្មើសព្រហ្មទណ្ឌ។ អ.វ.ត.ក មិនមានសមត្ថកិច្ចអនុវត្តការផ្តល់សំណងឡើយ[១១៤៥]។ ដូច្នេះ សំណង ផ្តល់ដោយ អ.វ.ត.ក ប្រឆាំងនឹងពិរុទ្ធជនអាចអនុវត្តបានចំពោះ តែសំណងណាដែលត្រូវអនុវត្ត ដោយប្រព័ន្ធតុលាការជាតិធម្មតាតែប៉ុណ្ណោះ។

៦៦២. អង្គជំនុំជម្រះទទួលស្គាល់គោលការណ៍ ដែលបញ្ជាក់អំពីសិទ្ធិរបស់ជនរងគ្រោះនៃការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ធិសញ្ញាអន្តរជាតិមួយ ចំនួន និងលិខិតុបករណ៍ផ្សេងៗទៀត[១១៤៦] សេចក្តីប្រកាសរបស់ស្ថាប័នអង្គការសហប្រជាជាតិ[១១៤៧] និង

---

[១១៤៥] *សូមមើល* មាត្រា១ នៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក (ផ្តល់សមត្ថកិច្ចឲ្យវិនិច្ឆ័យ បុគ្គលទាំងឡាយដែលជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩")។

[១១៤៦] *សូមមើល ឧទា.* មាត្រា ២(៣), ៩(៥) និង ១៤(៦) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តិ ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាប, 1465 UNTS 85 ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤។ មាត្រា៧៥ នៃលក្ខន្តិកៈតុលាការ ICC។ មាត្រា២៤ នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិសម្រាប់ការពារបុគ្គលទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 61/177 ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦, A/RES/61/177 មិនទាន់ចូលជាធរមាននៅឡើយ។ សិទ្ធិនេះក៏ត្រូវបានចែងផងដែរ នៅក្នុងសន្ធិសញ្ញាតាមតំបន់មួយចំនួន ដូចជា មាត្រា៥(៥), ១៣ និង៤១ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងមាត្រា២៥, ៦៣(១) និង៦៨ នៃអនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស 1144 UNTS 123 ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ និងមាត្រា២១(២) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិមនុស្ស 1520 UNTS 217 ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។ *សូមមើលផងដែរ* "គោលការណ៍ និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានលើច្បាប់ សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ" និងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ60/147 ឯកសារអង្គការសហប្រជាជាតិលេខ A/RES/60/147 ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ និងសេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទឧក្រិដ្ឋ និងការរំលោភបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

[១១៤៧] *សូមមើលឧទា.* គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ យោបល់ទូទៅលេខ ៣១ [៨០], *លក្ខណៈនៃកាតព្វកិច្ចគតិយុត្តិទូទៅដែលតម្រូវឲ្យអនុវត្តដោយភាគីរដ្ឋនៃកតិកាសញ្ញា* U.N. Doc. CCPR/C/21/Rev.1/Add.13

00573726



សេចក្តីសម្រេចរបស់តុលាការប្រចាំតំបន់នានា[១១៤៨]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមានការលំបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួនចំពោះសំណើសុំនៅចំពោះមុខអង្គជំនុំជម្រះ និងប្រភេទនៃសំណង ដែលអនុញ្ញាតស្របតាមវិធានផ្ទៃក្នុង។ ការដាក់កំហិតបែបនេះមិនអាចចៀសវាងបានដោយយុត្តាធិការនោះទេ ប៉ុន្តែទាមទារឲ្យធ្វើវិសោធនកម្មវិធានផ្ទៃក្នុង[១១៤៩]។

---

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ១៥-១៧។ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ យោបល់ទូទៅ លេខ២ ការអនុវត្តមាត្រា២ ដោយភាគីរដ្ឋ (U.N. Doc. CAT/C/GC/2/CRP. 1/Rev.4 (2007)) ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ ១៥។

[១១៤៨] *សូមមើលឧទា.* រឿងក្តី *Velasquez Rodriguez* សាលក្រមរបស់តុលាការអន្តរអាមេរិកផ្នែកសិទ្ធិមនុស្ស (Series C No. 4) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៨ កថាខណ្ឌ ១៧៤។ *សូមមើលផងដែរ* រឿងក្តី *Papamichalopoulos ទល់នឹង* ប្រទេសក្រិច សាលក្រមរបស់តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស (លេខ 14556/89) ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៣៦។

[១១៤៩] តម្រូវការក្នុងការសម្របការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងតម្រូវការពិសេសនៃការជំនុំជម្រះក្តីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងបរិបទកម្ពុជាជាក់លាក់ គឺជាកម្លាំងជំរុញដ៏សំខាន់នៅខាងក្រោយការកែទម្រង់ដែលកំពុងអនុវត្តចំពោះការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក។ សូមមើល សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ដែលបានចេញពេលបញ្ចប់កិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក លើកទី៧៖ http://www.eccc.gov.kh/khmer/cabinet/press/113/Press_Release__Khmer_.pdf (បញ្ជាក់អំពីសេចក្តីសម្រេចផ្តល់អំណាចដល់អង្គភាពគាំពារជនរងគ្រោះ ក្នុងការផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះឲ្យបានកាន់តែទូលំទូលាយជាងមុន ដើម្បីបង្កើត និងអនុវត្តកម្មវិធី និងវិធានការថ្មីៗ ដែលកើតឡើងនៅក្រៅកិច្ចដំណើរការនីតិវិធីតុលាការជាផ្លូវការ ដែលរួមមានសេវាកម្មដែលមានចំនួនច្រើនជាងមុន ព្រមទាំងការដាក់បញ្ចូលជនរងគ្រោះឲ្យបានច្រើនគ្រប់ទិសទី ច្រើនជាងមុន មិនត្រឹមតែបុគ្គលដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក ឡើយ។ វិសោធនកម្មវិធានផ្ទៃក្នុងនេះ បញ្ជាក់យ៉ាងច្បាស់ថា វិធានការទាំងនេះអាចត្រូវបានបង្កើតឡើងដោយមានកិច្ចសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលនៅក្រៅ អ.វ.ត.ក ដែលផ្តល់លទ្ធភាពក្នុងការបង្កើតនូវកម្មវិធីទូលំទូលាយជាងមុន ដែលអាចសម្រេចបានក្នុងរង្វង់សមត្ថភាព និងធនធានដែលមានក្នុង អ.វ.ត.ក។

00573727



៦៦៣. លើសពីនេះទៀត សមត្ថកិច្ចរបស់ អ.វ.ត.ក មិនដូចសមត្ថកិច្ចរបស់តុលាការសិទ្ធិមនុស្ស ក្នុងតំបន់មួយចំនួន[១១៥០] ដែលអាចចេញសេចក្តីសម្រេចអំពីការទទួលខុសត្រូវរបស់រដ្ឋ ឬចេញបញ្ជាឱ្យរដ្ឋជាអ្នកផ្តល់សំណងដល់ពលរដ្ឋរបស់ខ្លួន នៅពេលណាដែលគេរកឃើញថារដ្ឋជាអ្នកទទួលខុសត្រូវចំពោះការបំពារបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនមានយុត្តាធិការលើអាជ្ញាធរកម្ពុជា ឬស្ថាប័នអន្តរជាតិណាមួយនោះទេ។ អង្គជំនុំជម្រះក៏មិនអាចដាក់កាតព្វកិច្ចលើ ឬផ្តល់សិទ្ធិឱ្យអ្នកណាម្នាក់ ឬស្ថាប័នណាមួយ ដែលមិនមែនជាភាគីនៅចំពោះមុខខ្លួននោះទេ។ យ៉ាងច្រើនបំផុត អង្គជំនុំជម្រះអាចត្រឹមជួយជំរុញអាជ្ញាធរជាតិ ឬស្ថាប័នអន្តរជាតិ ឬអ្នកដែលអាចនឹងជួយផ្តល់ជំនួយបង្ហាញសាមគ្គីភាពជាមួយជនរងគ្រោះតាមរយៈការផ្តល់ជំនួយគាំទ្រជាហិរញ្ញវត្ថុ ឬជំនួយតាមរូបភាពផ្សេង ដែលជួយដល់ការស្តារឡើងវិញ ការធ្វើសមាហរណកម្ម និងការលើកស្ទួយភាពថ្លៃថ្នូររបស់មនុស្សជាតិឡើងវិញ។

៦៦៤. នៅពេលដែលពិរុទ្ធជនត្រូវបានរកឃើញថាជាអ្នកទីទ័លក្រគ្មានលទ្ធភាព ក៏ អ.វ.ត.ក មិនមានយន្តការដែលអនុញ្ញាតឱ្យមានការសងជំនួស ឬបន្ថែមសំណង ដែលបានធ្វើឡើងប្រឆាំងនឹងអ្នកទាំងនោះ ដោយមូលនិធិដែលផ្តល់ដោយអាជ្ញាធរជាតិ ឬតតិយជនបានឡើយ។

៦៦៥. លើសពីនេះទៀត អង្គជំនុំជម្រះមិនអាចចេញការបង្គាប់ណាមួយបានឡើយ នៅពេលដែលកម្មវត្ថុនៃការទាមទារមានលក្ខណៈស្រពិចស្រពិល ឬមិនពិតប្រាកដ និងដែលមិនអាចអនុវត្តបាន។ ដូច្នេះ បុរេលក្ខខណ្ឌចំពោះការផ្តល់សំណងគឺត្រូវបញ្ជាក់យ៉ាងច្បាស់អំពីប្រភេទនៃសំណងដែលជនរងគ្រោះចង់បានទំនាក់ទំនងរវាងប្រភេទនៃសំណង និងព្យសនកម្មដែលបង្កឡើងដោយពិរុទ្ធជនដែលជាអ្នកត្រូវផ្តល់សំណង និងចំនួននៃសំណងដែលពិរុទ្ធជនត្រូវសង។ ទាំងនេះគឺជាលក្ខខណ្ឌដើម្បីធ្វើឱ្យការទាមទារសំណងនោះមានប្រសិទ្ធភាព។ ការដាក់បន្ទុកលើអង្គជំនុំជម្រះជាអ្នកសម្រេចលើបញ្ហាទាំងនេះគឺផ្ទុយទៅនឹងយន្តការដែលចង់ឱ្យសំណងផុសចេញពីអ្នកទាមទារ។ ការឱ្យអង្គជំនុំជម្រះ

[១១៥០] មាត្រា៥(៥), ១៣ និង៤១ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងមាត្រា២៥, ៦៣(១) និង៦៨ នៃអនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស 1144 UNTS 123 ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ និងមាត្រា២១(២) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស 1520 UNTS 217 ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។

00573728



ធ្វើបែបនេះក៏មិនស្របគ្នាទៅនឹងតម្រូវការនៃសវនាការប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស និងមិនសមស្របទៅនឹងរយៈពេលកំណត់នៃ អ.វ.ត.ក និងធនធានដែល អ.វ.ត.ក មាននោះដែរ។

៦៦៦. នៅក្នុងបរិបទបច្ចុប្បន្ននេះ ឧបសគ្គជាក់ស្តែងគឺថាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនូវការបាត់បង់យ៉ាងធំធេង ហើយការបាត់បង់ទាំងនេះមិនអាចនឹងសងរួចវិញដោយពិរុទ្ធជនដែលអង្គជំនុំជម្រះបានកំណត់រួចហើយថាជាអ្នកទីទ័លក្រគ្មានលទ្ធភាព[១១៥១]។

### ៤.៤.៣ ការវិភាគអំពីប្រភេទផ្សេងៗនៃសំណងដែលបានស្នើសុំ

#### ៤.៤.៣.១ សំណើពាក់ព័ន្ធទៅនឹងខ្លឹមសារនៃសាលក្រម

៦៦៧. ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យបញ្ចូលឈ្មោះពួកគាត់ និងឈ្មោះជនរងគ្រោះដែលជាសាច់ញាតិជិតស្និតនៅក្នុងសាលក្រមចុងក្រោយ រួមទាំងសេចក្តីបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស២១។ ទោះបីជាសំណងនៅចំពោះមុខ អ.វ.ត.ក ត្រូវបានកំណត់ត្រឹមវិធានការដែលត្រូវបង្គាប់ប្រឆាំងនឹងពិរុទ្ធជនយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតែងងអាចទទួលយកសំណើជាក់លាក់មួយនេះដោយការបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិជិតស្និតដែលបានបាត់បង់ជីវិតនៅមន្ទីរស២១ ទៅក្នុងសាលក្រមនេះបាន។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា ការទទួលស្គាល់ជាផ្លូវការដូចគ្នាអំពីការឈឺចាប់នៅចំពោះមុខស្ថាប័នអន្តរជាតិផ្សេងៗទៀត ត្រូវបានកំណត់ប្រភេទថាជាសំណងដែលមានសារៈសំខាន់ជានិមិត្តរូបសម្រាប់ជនរងគ្រោះ[១១៥២]។

---

[១១៥១] យោងតាម "Déclaration des revenus et biens" (ការប្រកាសអំពីប្រាក់ចំណូល និងទ្រព្យសម្បត្តិ) ដែលធ្វើឡើងដោយជនជាប់ចោទ តាមសំណើរបស់អង្គជំនុំជម្រះ នៅក្នុងខែតុលា ឆ្នាំ២០០៩ (E175/1.1) កាំង ហ្គេកអ៊ាវ មិនមានគណនីធនាគារ មិនមានទ្រព្យសម្បត្តិ និងមិនមានប្រាក់ចំណូលអ្វីឡើយ។ *សូមមើល* "Déclaration des revenus et biens" E175/1.1 ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩។ អង្គជំនុំជម្រះកត់សម្គាល់ថា ជនជាប់ចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំងចាប់តាំងពីឆ្នាំ១៩៩៩។

[១១៥២] *សូមមើលឧទា.* និទណ្ឌភាព របស់គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសម្រេចចិត្តលេខ 2002/79 (ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/RES/2001/70) ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ កថាខណ្ឌ៩៖"*[គណៈកម្មាធិការសិទ្ធិ*

## ៤.៤.៣.២ ការចងក្រង និងការបោះពុម្ពផ្សាយពាក្យសម្ដីសុំអភ័យទោស

៦៦៨. ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការចងក្រង និងបោះពុម្ពផ្សាយពាក្យសម្ដីសុំអភ័យទោសដែលបានធ្វើឡើងដោយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ក្នុងអំឡុងពេលសវនាការ រួមជាមួយនឹងមតិយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ពាក្យសម្ដីអភ័យទោសជាច្រើនត្រូវបានធ្វើឡើងក្នុងអំឡុងពេលសវនាការ។ ដោយសារតែការចងក្រងពាក្យសម្ដីសុំអភ័យទោស និងការសម្ដែងនូវ វិប្បដិសារីទាំងនេះ អាចធ្វើឲ្យជនរងគ្រោះអាចធូរចិត្តបានខ្លះ ពីព្រោះថា នេះគឺជាអ្វីដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់ និងការឈឺចាប់របស់ជនរងគ្រោះ ដោយសារតែអំពើឧក្រិដ្ឋរបស់គាត់។អង្គជំនុំជម្រះយល់ព្រមតាមសំណើនេះ[១១៥៣]។ ប៉ុន្តែ អង្គជំនុំជម្រះបដិសេធសំណើសុំបញ្ចូលសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅដាក់ក្នុងការចងក្រងនេះ ដោយ

---

*មនុស្ស ទទួលស្គាល់ថា* សម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ការដឹងជាសាធារណៈអំពីការឈឺចាប់របស់ពួកគេ និងការពិតអំពីចារី... នៃការរំលោភបំពានទាំងនេះ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការស្តារនីតិសម្បទា និងការផ្សះផ្សា និងទទូចឲ្យបណ្តារដ្ឋនានាបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការផ្តល់ឲ្យជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សនូវដំណើរការមួយប្រកបដោយសមធម៌ និងយុត្តិធម៌ ដែលការរំលោភបំពានទាំងនេះ អាចត្រូវបានស៊ើបអង្កេត និងបញ្ចេញឲ្យដឹងជាសាធារណៈ និងដើម្បីលើកទឹកចិត្តជនរងគ្រោះឲ្យចូលរួមក្នុងដំណើរការនេះ"។

[១១៥៣] ទោះបីជាមិនមានការចេញដីកាបង្គាប់ប្រឆាំងនឹងពិរុទ្ធជនយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់នូវការទទួលស្គាល់ដ៏ទូលំទូលាយនៃវិធានការស្រដៀងគ្នាជាសំណង។ *សូមមើល ឧទា.* *Rainbow Warrior (New Zealand/France)* សេចក្តីសម្រេច តុលាការមជ្ឈត្តកម្ម (UNRIAA, ភាគ XX, ទំព័រ ២១៧) ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩០) នៅទំព័រ ២៧២-២៧៣ កថាខណ្ឌ ១២២ (កត់សម្គាល់នូវការអនុវត្តរបស់សាលាក្តី និងតុលាការអន្តរជាតិក្នុងការប្រើប្រាស់ដំណោះស្រាយអាចទទួលយកបានជាទម្រង់នៃសំណង (ក្នុងទស្សនទូលំទូលាយ)។ ដំណោះស្រាយអាចទទួលយកបាន អាចរួមមានការសម្តែងនូវវិប្បដិសារី ការសុំអភ័យទោសជាផ្លូវការ ការប្រកាសសាលក្រម ឬវិធីសាស្ត្រដ៏សមស្របផ្សេងទៀត។ ទម្រង់ដ៏សមស្របនៃដំណោះស្រាយអាចទទួលយកបាន នឹងអាស្រ័យទៅលើកាលៈទេសៈ ហើយមិនអាចពិពណ៌នាជាមុនបានឡើយ)។ *សូមមើលផងដែរ* "សេចក្តីព្រៀងរបស់អង្គការសហប្រជាជាតិ សេចក្តីណែនាំ និងគោលការណ៍ ជាមូលដ្ឋានស្តីពីសិទ្ធិទទួលបាននូវដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌"។ ឧបសម្ព័ន្ធ ឯកសារអង្គការសហប្រជាជាតិ E/CN.4/2000/62 ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ (រួមទាំងក្នុងចំណោមវិធានការនានាដែលបង្កើតបានជាដំណោះស្រាយអាចទទួលយកបានដល់ការសុំអភ័យទោសជនរងគ្រោះ រួមទាំងការទទួលស្គាល់ជាសាធារណៈអំពីការពិត និងការយល់ព្រម ទទួលអំពីការទទួលខុសត្រូវ)។

ហេតុថា សេចក្ដីថ្លែងការណ៍ទាំងនេះមានលក្ខណៈមិនដូចគ្នាទៅនឹងពាក្យសម្ដីសុំអភ័យទោសដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច បានធ្វើនោះឡើយ ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ទាំងនោះក៏មិនជាក់លាក់នោះដែរ។

### ៤.៤.៣.៣ សំណើទាក់ទងនឹងការបោះពុម្ពផ្សាយសាលក្រម និងការផ្សព្វផ្សាយ

៦៦៩. ក្នុងចំណោមសំណើសុំផ្សេងទៀត សំណើសុំចងក្រងឯកសារ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនូវផ្នែកនៃសាលក្រម ត្រូវបដិសេធចោល ដោយហេតុថា ខ្វះភាពជាក់លាក់។ លក្ខណៈពិតប្រាកដនៃវិធានការដែលបានស្នើសុំ និងថ្លៃសងជំងឺចិត្តមានភាពមិនច្បាស់លាស់ និងមិនអាចកំណត់បានឡើយ ហេតុដូច្នេះមិនអាចជាការផ្ដល់នូវសំណងប្រឆាំងនឹងពិរុទ្ធជនបានឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ថា សាលក្រមនឹងត្រូវចេញផ្សាយជាសាធារណៈ ហើយមាននៅលើគេហទំព័រ អ.វ.ត.ក ដែលប្រព័ន្ធផ្សព្វផ្សាយទាំងអស់អាចរកមើលបានបើមានបំណងយោងទៅលើសាលក្រមនេះ។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា ការផ្ដល់ព័ត៌មានជាសាធារណៈស្ដីអំពីសាលក្រមនឹងកើត មានជាលក្ខណៈនៃសកម្មភាពអប់រំផ្សព្វផ្សាយរបស់ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ដែលអាចរួមចំណែកយ៉ាងសំខាន់ដល់ការផ្ដួចផ្ដើមគំនិតផ្សះផ្សានៅក្នុងសង្គមកម្ពុជាទាំងមូល និងការអប់រំសាធារណៈ។

### ៤.៤.៣.៤ សំណើសុំសំណងជាប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ឬការបង្កើតនូវមូលនិធិមួយ

៦៧០. សំណើទាំងអស់ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្ដី ដែលស្នើសុំនូវសំណងជាប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏បង្កើតមូលនិធិក្នុងភារៈគ្រប់គ្រងសម្រាប់ជនរងគ្រោះ គឺលើសពីវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេច។ ដូច្នេះសំណើទាំងឡាយ ដូចជា ការផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការផ្ដល់ប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូច និងវគ្គបណ្ដុះបណ្ដាលស្ដីពីជំនាញអាជីវកម្មត្រូវបដិសេធចោល។

### ៤.៤.៣.៥ សំណើសុំនូវវិធានការមួយចំនួនពីរាជរដ្ឋាភិបាលកម្ពុជា

៦៧១. ទោះបីជាសំណើទាំងនេះទំនងជារួមចំណែកដល់សំណងផ្លូវចិត្ត និងជាសមូហភាពចំពោះព្យសនកម្មដែលជនរងគ្រោះបានទទួលរងយ៉ាងណាក៏ដោយ ក៏សំណើទាំងនេះស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ពីព្រោះសំណើទាំងនេះមិនមែនជាវិធានការដែលអាចត្រូវបំពេញបានឡើយ តាមរយៈដីកាបង្គាប់ដែលធ្វើឡើងប្រឆាំងនឹងពិរុទ្ធជននោះ។ សំណើទាំងនេះ ត្រូវបដិសេធចោលដោយ ហេតុថាការបង្កើតទិវារំឭកថ្នាក់ជាតិសម្រាប់ជនរងគ្រោះ និងការចេញសេចក្ដីថ្លែងសុំអភ័យទោសជាផ្លូវការគឺស្ថិតនៅក្នុងបុព្វសិទ្ធិផ្ដាច់មុខរបស់រាជរដ្ឋាភិបាលកម្ពុជាដែល អ.វ.ត.ក ពុំមានសមត្ថកិច្ចបង្ខំបានឡើយ។

### ៤.៤.៣.៦ សំណើសុំកសាងវត្ត និងបូជនីយដ្ឋានផ្សេងៗទៀត

៦៧២. ទោះបីជាមានការគាំទ្រចំពោះសំណើទាំងនេះយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះយល់ថាសំណើទាំងអស់នោះមិនមានភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងចំនួនជាក់លាក់នៃបូជនីយដ្ឋាន ដែលបានស្នើសុំនោះឡើយ ដូចជា លក្ខណៈ ទីតាំង និងតម្លៃរបស់បូជនីយដ្ឋាន។ មិនមានការផ្ដល់នូវព័ត៌មានទាក់ទងទៅនឹងអត្តសញ្ញាណនៃម្ចាស់ទីតាំងដែលបានស្នើសុំទាំងនោះ តើពួកគេយល់ព្រមឲ្យសាងសង់បូជនីយ-ដ្ឋានដែលបានស្នើសុំនីមួយៗនោះដែរ ឬទេ ឬថាតើលិខិតអនុញ្ញាតបន្ថែម ដូចជា លិខិតអនុញ្ញាតឲ្យសាងសង់ ដែលចាំបាច់ដើម្បីធ្វើឲ្យវិធានការនីមួយៗមានប្រសិទ្ធភាពដែរ ឬទេ។ ដោយសារតែឯកសារនៅចំពោះមុខអង្គជំនុំជម្រះមិនអាចឲ្យអង្គជំនុំជម្រះចេញដីកាបង្គាប់ប្រឆាំង នឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ឲ្យបង់ថ្លៃជាសំណងជាក់លាក់បាននោះ ដូច្នេះសំណើទាំងនេះត្រូវ បដិសេធចោល។

### ៤.៤.៣.៧ សំណើសុំឲ្យអភិរក្សបណ្ណសារមន្ទីរស២១ គំនូររបស់ វ៉ាន់ ណាត និង បរិវេណមន្ទីរស២១ និងស២៤

៦៧៣. ទោះបីជាមានការទទួលស្គាល់អំពីសារៈសំខាន់នៃការប្រឹងប្រែងអភិរក្សទីកន្លែងនេះយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើទាំងនេះមិនស្ថិតនៅក្នុងទម្រង់នៃការទាមទារដែលកំណត់បរិមាណ និងមានលក្ខណៈច្បាស់លាស់ដែលអាចធ្វើឲ្យចេញដីកាបង្គាប់ប្រឆាំងនឹង

កាំង ហ្កេកអ៊ាវ ហៅ ឌុច បានឡើយ។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានទទួលព័ត៌មានពិស្តារទាក់ទងទៅនឹងកម្មសិទ្ធិស្របច្បាប់បច្ចុប្បន្ននៃទីតាំង បណ្ណសារ ឬសម្ភារៈ ទាំងនេះឡើយ ឬក៏ការយល់ព្រមពីកម្មសិទ្ធិករ ឬភោគី ចំពោះសំណើសុំប្រើប្រាស់ ឬកែប្រែទីកន្លែងទាំងនោះទេ[១១៥៤] ឬក៏ការបែងចែកប្រាក់ចំណូលដែលបានមកពីទីកន្លែងទាំងនោះទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ដូច្នេះ សំណើទាំងនេះត្រូវបដិសេធចោល។

### ៤.៤.៣.៨ សំណើសុំផ្តល់នូវការថែទាំសុខភាពដោយឥតគិតថ្លៃ និងវិធានការអប់រំ

៦៧៤. សំណើប្រភេទនេះមានលក្ខណៈមិនមែនជាសំណងនិមិត្តរូបទេ ប៉ុន្តែបម្រើផលប្រយោជន៍ជនរងគ្រោះច្រើននាក់គឺស្ថិតនៅក្រៅវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេច[១១៥៥]។ ការផ្តល់សេវាសុខភាពដោយមិនបង់ថ្លៃដល់សមាជិកគ្រួសារជនរងគ្រោះច្រើននាក់ អាចជាការដាក់កាតព្វកិច្ចដល់អាជ្ញាធរសុខាភិបាលជាតិដែលការស្នើសុំនេះហួសពីសមត្ថកិច្ចរបស់ អ.វ.ត.ក។ អង្គ-ជំនុំជម្រះក៏មិនអាចចេញដីកាឱ្យមានការចាត់វិធានការ ដែលអាចប៉ះពាល់គោលនយោបាយអប់រំជាតិដូចជា ការបណ្តុះបណ្តាលគ្រូ ការផ្តល់ប្រាក់ខែ និងការរៀបចំកម្មវិធីសិក្សាបានឡើយ។ ទោះបីជាវិធាន ២៣(១)(ខ) អាចអនុញ្ញាតឱ្យមានការផ្តល់សំណងបែបនេះក៏ដោយ ក៏ភស្តុតាងត្រូវតែបង្ហាញឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងនៃវិធានការ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ និងឧក្រិដ្ឋកម្មដែលពិរុទ្ធជនត្រូវទទួលខុសត្រូវ។ គ្មានភស្តុតាងបែបនេះត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ លើសពីនេះទៀត ចំនួន និងអត្តសញ្ញាណនៃអ្នកដែលត្រូវទទួលបានផលប្រយោជន៍ពីសំណើទាំងនេះ លក្ខណៈនៃវិធានការដែលស្នើសុំ និងថ្លៃចំណាយទាំងនោះ មិនមានលក្ខណៈជាក់លាក់ពិតប្រាកដ និងមិនអាចកំណត់ជាតួលេខបានឡើយនៅក្នុងធនធានដែលអង្គជំនុំជម្រះមាន។

---

[១១៥៤] *សូមមើលឧទា.* "សេចក្តីសន្និដ្ឋានបញ្ចប់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣)" ឯកសារ E159/5 ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN (ភាសាខ្មែរ) 00399805-00399806 (ដែលស្នើសុំ ក្នុងចំណោមវិធានការផ្សេងទៀត ឱ្យមានការសាងសង់ស្តូបមួយដើម្បីជាការរំឭកដល់ជនរងគ្រោះ សាងសង់ផ្លូវដើរមួយ និងឆ្លាក់ឈ្មោះអ្នកជាប់ឃុំទាំងឡាយ នៅលើជញ្ជាំងខាងក្រៅនៃមន្ទីរស២១)។

[១១៥៥] សូមមើលវិធាន២៣(១)(ខ) នៃវិធានផ្ទៃក្នុង។

៦៧៥. ទោះបីជាតម្រូវការរបស់ជនរងគ្រោះនូវផ្នែកនេះមិនមានការតវ៉ាក៏ដោយ ក៏សំណើទាំងនេះមានលក្ខណៈមិនអាចទទួលបានការបំពេញចិត្ត តាមរយៈការចេញដីកាបង្គាប់ប្រឆាំងនឹងពិរុទ្ធជនឡើយ ហើយសំណើដែលមានក្នុងទម្រង់នេះមិនអាចផ្តល់នូវមូលដ្ឋានសម្រាប់ចេញដីកាបង្គាប់ដែលអាចអនុវត្តចំពោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានទេ។ ។ ដូច្នេះ សំណើទាំងនេះត្រូវបដិសេធ ចោល។

## ៥. ផ្នែកសេចក្តីសម្រេច

៦៧៦. តាមសំអាងហេតុដូចខាងលើ និងក្រោយពីបានពិចារណាលើវាល់ភស្តុតាង និងសេចក្តីសន្និដ្ឋានទាំងអស់របស់ភាគី **អង្គជំនុំជម្រះសម្រេចដូចខាងក្រោម** ៖

៦៧៧. អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** មានពិរុទ្ធភាពតាមមាត្រា៥ មាត្រា៦ និងមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ពីបទ ៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលរួមបញ្ចូលនូវបទល្មើសការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើ-ផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត និង
- ការបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩៖
  - ការធ្វើមនុស្សឃាតដោយចេតនា
  - ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌
  - ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
  - ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និង
  - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

ដែលបានប្រព្រឹត្តនៅទីក្រុងភ្នំពេញ និងលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

៦៧៨. តាមសំអាងហេតុដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីអញ្ញត្រកម្ម អង្គជំនុំជម្រះមិនពិចារណាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ពីបទឧក្រិដ្ឋជាតិនៃការធ្វើមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើមាត្រា៥០១ មាត្រា៥០៦ និងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលអាចផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក ស្របតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក[១១៥៦] ទេ។

៦៧៩. អង្គជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ ឆ្នាំ។

៦៨០. អង្គជំនុំជម្រះកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសខាងលើចំនួន០៥ ឆ្នាំ ដោយសារតែការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៦៨១. ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ និងរយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់សាលក្រមនេះចូលជាស្ថាពរ[១១៥៧]។

៦៨២. អង្គជំនុំជម្រះប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានឈ្មោះនៅក្នុងកថាខណ្ឌ ៦៤៥ និង៦៥០ ពិតជាបានទទួលរងគ្រោះដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាព។

៦៨៣. អង្គជំនុំជម្រះត្រូវចងក្រងសេចក្តីថ្លែងសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់ការទទួលខុសត្រូវដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច បានធ្វើនៅក្នុងអំឡុងពេលសវនាការ។ កម្រងនេះត្រូវដាក់

---

[១១៥៦] "សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលបានលើកឡើងដោយមេធាវីការពារក្តី" ឯកសារលេខ E187 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

[១១៥៧] សូមមើល "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។

នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នៅក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ។ អង្គជំនុំជម្រះបដិសេធចោលនូវការទាមទារផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

៦៨៤. សាលក្រមនេះប្រកាសជាសាធារណៈនៅសាលសវនាការធំនៃ អ.វ.ត.ក នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។

បើកផ្លូវប្តឹងសាទុក្ខដល់ភាគីតាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

ដោយសារស្ថានភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលគាត់មានពិរុទ្ធ ត្រូវរក្សាជនជាប់ចោទក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតសាលក្រមចូលជាស្ថាពរ ឬរហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក សម្រេចសេចក្តីលើបណ្តឹងសាទុក្ខ។

សាលក្រមនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

**ក្រុមចៅក្រម**

| | | | | |
|---|---|---|---|---|
| **ណីម ស៊ុយហុង** | Matteo CRIPPA | **សែ កុលវុឌ្ឍី** | Natacha WEXELS-RISER | **ឌុច ផារី** |

ចៅក្រម **និល ណុន**
ប្រធាន

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **ធូ មណី**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C B T C

# ៦. ឧបសម្ព័ន្ធ I÷ ប្រវត្តិនីតិវិធី

## ៦.១ ការចាប់ខ្លួន ការផ្ទេរ និងការឃុំខ្លួនជនជាប់ចោទ

១. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ សមត្ថកិច្ចយោធាកម្ពុជាបានចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទនៅពន្ធនាគារតុលាការយោធាក្រុងភ្នំពេញ។ ជនជាប់ចោទត្រូវបានចោទប្រកាន់ដោយតុលាការយោធាកម្ពុជាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខជាតិ និងក្រោយមកទៀត ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ-កម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវទទួលបានការការពារ[១]។ ការឃុំខ្លួនគាត់បណ្តោះអាសន្ន ដែលត្រូវបានពន្យារជារៀងរាល់ឆ្នាំ បានបន្តក្រោមយុត្តាធិការរបស់តុលាការយោធា រហូតដល់មានការបញ្ជូនរូបគាត់ទៅ អ.វ.ត.ក[២]។

២. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ជនជាប់ចោទត្រូវបានសហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក ចេញដីកាបង្គាប់ឲ្យឃុំខ្លួន និងត្រូវបានបញ្ជូនទៅឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់អ.វ.ត.ក។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនបណ្តោះអាសន្ន

---

[១] "ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ" ឯកសារ E52/4.3 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។ "ដីកាឃុំខ្លួន" ឯកសារ E52/4.8 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។ "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ" ឯកសារ E52/4.26 ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩។ "ដីកាឃុំខ្លួន" ឯកសារ E52/4.22 ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩។ *សូមមើលផងដែរ* "ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលើកទី២" ឯកសារ E52/4.9 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។ "ដីកាសម្រេចពន្យាររយៈពេលស៊ើបអង្កេត" E52/4.34 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០។ "ដីកាសម្រេចពន្យាររយៈពេលស៊ើបអង្កេត" E52/4.46 ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១។

[២] "ដីកាឃុំខ្លួន ឌុច" ឯកសារ E52/4.47 ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២។ ឯកសារ E52/4.48 ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៣។ ឯកសារ E52/4.54 ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៤។ ឯកសារ E52/4.57 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥។ ឯកសារ E52/4.60 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦។ "ដីកាឃុំខ្លួន" ឯកសារ E52/4.63 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧។ *សូមមើលផងដែរ* "ដីកាសម្រេចពន្យាររយៈពេលស៊ើបអង្កេត" ឯកសារ E52/4.52 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤។

ជនជាប់ចោទ[៣]។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ដោយមេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចនេះ[៤]។ ក្រោយមកទៀត សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចឲ្យជនជាប់ចោទស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នតទៅទៀត រហូតដល់គាត់បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[៥]។ សេចក្តីសម្រេចនេះត្រូវបានតំកល់ដោយអង្គបុរេជំនុំជម្រះ[៦]។

៣. នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ មេធាវីការពារក្តីបានជំទាស់តវ៉ាទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន និងបានស្នើសុំឲ្យដោះលែងជនជាប់ចោទក្នុងអំឡុងពេលសវនាការ[៧]។ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តី និងបានបង្គាប់ថា ជនជាប់ចោទត្រូវស្ថិតក្នុងការឃុំខ្លួនជាបន្តទៀតសម្រាប់រយៈពេលនៃដំណើរការសវនាការ[៨]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនពីមុនរបស់ជនជាប់ចោទ នៅចំពោះមុខតុលាការយោធា គឺជាការរំលោភច្បាប់កម្ពុជាជាធរមាន និងរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះទោសដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ អង្គជំនុំ-ជម្រះប្រកាសថា ប្រសិនបើរកឃើញថាជនជាប់ចោទមានពិរុទ្ធភាព ជនជាប់ចោទ ត្រូវមានសិទ្ធិទទួលបានការកាត់បន្ថយទោស ដែលនឹងត្រូវបានសម្រេចនៅដំណាក់កាលផ្តន្ទាទោស ជាសំណងសម្រាប់

---

[៣] "ដីកាបង្គាប់ឲ្យនាំខ្លួន" ឯកសារ C1 ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ "ដីកាឃុំខ្លួន" ឯកសារ C4/2 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ "ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ឯកសារ C3/10 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។

[៤] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" ឯកសារ C5/45 ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧។

[៥] "ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ឯកសារ C3/II, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨។ .

[៦] "ដីកាបង្គាប់ឲ្យឃុំខ្លួន" ឯកសារ D99/3/43 ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨។

[៧] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E1/7។

[8] "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" ឯកសារ E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ៩-១៤, ២២-២៦។ "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ E1/32។

00573740



ការរំលោភបំពានទាំងនេះ[៩]។ អង្គជំនុំជម្រះបានប្រកាសទៀតថា នៅក្នុងការគិតអំពីរយៈពេលនៃការដាក់ទោស ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់សងវិញនូវរយៈពេល ដែលគាត់បានជាប់ឃុំចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ មក[១០]។

៦.២ ដំណាក់កាលស៊ើបអង្កេត

៦.២.១ ការស៊ើបអង្កេតបឋម

៤. សហព្រះរាជអាជ្ញាបានផ្ដួចផ្ដើមឲ្យមានកិច្ចស៊ើបសួរបឋមនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦[១១]។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជូនសហចៅក្រមស៊ើបអង្កេត ដែលបានបើកផ្លូវឲ្យមានកិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹងបុគ្គលចំនួនប្រាំនាក់ ដែលរួមមានទាំងជនជាប់ចោទផងដែរ[១២]។

៦.២.២ ការបង្ហាញខ្លួនលើកដំបូង និងការចោទប្រកាន់

៥. ជនជាប់ចោទបានបង្ហាញខ្លួនជាលើកដំបូង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ ជនជាប់ចោទត្រូវបានទទួលដំណឹងថា គាត់ត្រូវស្ថិតនៅក្រោមការស៊ើប-អង្កេតចំពោះអង្គហេតុ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងត្រូវ

[៩] "សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" ឯកសារ E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ៣៤-៣៦។

[១០] *ដូចដើងទំព័រខាងលើ* ឯកសារ E39/5 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ២៧-២៩។

[១១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៤។

[១២] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារ D3 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។

បានចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយក្រោយមកទៀត ត្រូវបានចោទប្រកាន់ពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[១៣]។

៦.២.៣ ដីកាបំបែកសំណុំរឿង

៦. នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបំបែកសំណុំរឿងរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុមន្ទីរស២១។ អង្គហេតុទាំងនេះត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ០០១/១៨-០៧-២០០៧ និងរួមមានទាំងរឿងក្តីនេះផងដែរ[១៤]។

៦.២.៤ សេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេត និងដីកាដំណោះស្រាយ

៧. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីអនុលោមតាមវិធានផ្ទៃក្នុង៦៦(១) ថា ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានបញ្ចប់ហើយ[១៥]។ អនុលោមតាមវិធានផ្ទៃក្នុង៦៦(៤) សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨[១៦] នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ហើយមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨[១៧]។

---

[១៣] "កំណត់ហេតុនៃការចូលខ្លួនដំបូង" ឯកសារ D7 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ "កំណត់ហេតុនៃការសួរចម្លើយ" ឯកសារ D20 ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៧។

[១៤] "ដីកាបំបែកសំណុំរឿង" ឯកសារ D18 ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ អង្គហេតុដទៃទៀតទាំងអស់ ដែលទាក់ទងនឹងជនសង្ស័យដែលមានរាយឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបានស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧។

[១៥] "សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ" ឯកសារ D89 ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨។

[១៦] "ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ" ឯកសារ D95 ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨។

[១៧] "វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពរទាក់ទងនឹង កាំង ហ្កេកអ៊ាវ ហៅ "ឌុច"" ឯកសារ D96 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨។ "សារណាពីសំណាក់ក្រុមមេធាវីការពារក្តីរបស់ កាំង ហ្កេកអ៊ាវ ដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា" ឯកសារ D96/1 ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨។

៨. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយបានបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងពីបទបំពារ-បំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

## ៦.៣ បណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ

### ៦.៣.១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា

៩. នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ដោយលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយមិនបានចោទប្រកាន់ជនជាប់ចោទចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ រួមមានអំពើមនុស្សឃាត និងការធ្វើទារុណ-កម្ម អនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋតាមរយៈការចូល-រួមក្នុងសហឧក្រិដ្ឋកម្មរួម[១៨]។

---

[១៨] “សៀវភៅចុះបណ្តឹងឧទ្ធរណ៍” ឯកសារ D99/3 ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨។ “បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”” ឯកសារ D99/3/3 ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨។

### ៦.៣.២ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ

១០. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បទឧក្រិដ្ឋក្រោមច្បាប់ជាតិ នៃបទទារុណកម្ម និងបទមនុស្សឃាត ដែលអាចផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ អ.វ.ត.ក និងមាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មានធាតុផ្សំខុសគ្នា ដែលមិនមាននៅក្នុងបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិនៃបទមនុស្សឃាត និងបទទារុណកម្ម។ ដោយសារតែបទល្មើសទាំងនេះមិនត្រូវបានស្រូបបញ្ចូលទៅក្នុងបទឧក្រិដ្ឋអន្តរជាតិ អង្គបុរេជំនុំជម្រះ បានបន្ថែមការចោទប្រកាន់ទាំងនេះទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ[១៩]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានទៀតថា ទោះបីជាអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងអំពីការប្រព្រឹត្តិរួមនៃអំពើទាំងឡាយ ដែលត្រូវបានប្រព្រឹត្តនៅក្នុងមន្ទីរស២១ យ៉ាងណាក៏ដោយ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមមិនបានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរឡើយ។ ដោយសារតែជនជាប់ចោទមិនបានទទួលដំណឹងអំពីការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានចោទប្រកាន់នៅមុនពេលចេញដីកាសន្និដ្ឋានស្ថាពរ អង្គបុរេជំនុំជម្រះបានបដិសេធមិនធ្វើការចោទប្រកាន់ជនជាប់ចោទ ចំពោះទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ[២០]។ អានុភាពនៃសាលដីកានេះគឺត្រូវបញ្ជូនជនជាប់ចោទយកទៅជំនុំជម្រះទោស អនុលោមតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែនេះ។

---

[១៩] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" ឯកសារ D99/3/42 ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ៧២, ៨៤, ៩៩-១០១, ១០៣, ១០៧។

[២០] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" ឯកសារ D99/3/42 ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ១២៥, ១៤១។

## ៦.៤ ដើមបណ្តឹងរដ្ឋប្បវេណី

### ៦.៤.១ ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី

១១. មានបុគ្គលជាច្រើននាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០១។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលស៊ើបអង្កេត ហើយក្រោយមក មានអ្នកដាក់ពាក្យសុំចំនួន ៦៦ នាក់ បន្ថែមទៀត បានដាក់ពាក្យសុំដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីមុនថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩[២១] ដែលជាថ្ងៃកំណត់ឈប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ក្រោយមកអ្នកដាក់ពាក្យសុំចំនួន៤នាក់ ក្នុងចំណោមអ្នកដាក់ពាក្យសុំទាំងនោះត្រូវបានដកចេញ ឬត្រូវបានបដិសេធ[២២] ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៩០នាក់ បានចូលរួមក្នុងដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿងលេខ០០១។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរៀបចំជាបួនក្រុម ដោយក្រុមនីមួយៗមានមេធាវីតំណាង។

---

[២១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ៦។

[២២] "សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះអ្នកដាក់ពាក្យសុំ E2/36, E2/51 និង E2/69 " ឯកសារ E2/94/2 ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើសំណើសុំពន្យារពេលក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារ E2/92/2 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩។ "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពាក់លិខិតបោះបង់សិទ្ធិសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ឯកសារ E2/65/5 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើសំណើសុំពន្យារពេលក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ឯកសារ E2/92/2 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ (បដិសេធដោយសារខ្វះខាតនូវការបញ្ជាក់ភស្តុតាង សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ស្នើដោយយឺតពេលសុំឱ្យទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នង ចាន់ផល (E2/92))។ ក្រោយមក នង ចាន់ផល បានផ្តល់សក្ខីកម្មជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ (ប្រតិចារឹក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩)។

### ៦.៤.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

១២. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ បន្ទាប់ពីមានសំណើសុំឱ្យស្តាប់ចម្លើយពីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៧នាក់ ដែលអះអាងថាជាអតីតអ្នកជាប់ឃុំនៅមន្ទីរស២១ និង ១៥ នាក់ផ្សេងទៀត រវាងថ្ងៃទី១៧ និងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ [២៣]។

## ៦.៥ កិច្ចដំណើរការជំនុំជម្រះ

### ៦.៥.១ ការរៀបចំដំណើរការជំនុំជម្រះ និងសវនាការបឋម

១៣. នៅមុន និងក្នុងអំឡុងពេលកិច្ចដំណើរការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំស្តីពីការរៀបចំសវនាការជាច្រើនលើក។ កិច្ចប្រជុំទាំងនោះត្រូវបានធ្វើឡើងដោយសម្ងាត់ និងបានជួយដល់អង្គជំនុំជម្រះនៅក្នុងការរៀបចំចាត់ចែងបញ្ហានីតិវិធីជាច្រើន ដែលពាក់ព័ន្ធនឹងការជំនុំជម្រះក្តី [២៤]។

១៤.សវនាការបឋមបានធ្វើឡើយនៅថ្ងៃទី១៧ និងទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩។ នៅក្នុងចំណោមបញ្ហាផ្សេងៗដែលបានលើកឡើង សវនាការនេះបានពិចារណាលើបញ្ហាអញ្ញត្រកម្មដែលបានលើកឡើង

---

[២៣] "សេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី" ឯកសារ E57 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩។ កាលពីដំបូង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨នាក់ បានស្នើសុំផ្តល់ចម្លើយជូនអង្គជំនុំជម្រះ។ ក្រោយមកចំនួននេះបានធ្លាក់ចុះនៅសល់២២នាក់ បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦នាក់ បានបដិសេធ ឬមិនអាចស្តាប់ចម្លើយដោយអង្គជំនុំជម្រះ។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩, ១១-១២ ខែសីហា ឆ្នាំ២០០៩, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ និងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩, រួមមានឯកសារ E1/43, E1/61, E1/64, E1/66 និងE1/67។

[២៤] កិច្ចប្រជុំរៀបចំសវនាការ ប្រព្រឹត្តទៅនៅថ្ងៃទី១៥ និង១៦ ខែមករា, ថ្ងៃទី១១ ខែមិថុនា និងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ជាបន្តបន្ទាប់។

ដោយមេធាវីការពារក្តី សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដាក់ភស្តុតាងថ្មី វិធានការការពារ និងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះទៀត អង្គជំនុំជម្រះបានស្នើសុំឱ្យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី លើកឡើងនូវបញ្ហាមួយចំនួនឱ្យបានជាក់លាក់ក្នុងអំឡុងពេលសវនាការ និងបានពិនិត្យឡើងវិញផងដែរលើការវិវឌ្ឍន៍ទៅលើអង្គហេតុដែលបានព្រមព្រៀង និងការរៀបចំបញ្ចប់បញ្ជីសាក្សី[២៥]។ ក្នុងអំឡុងសវនាការបឋមនេះ អង្គជំនុំជម្រះក៏បានធ្វើសេចក្តី-សម្រេចកោះហៅសាក្សី និងអ្នកជំនាញមួយចំនួនផងដែរដើម្បីមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលជំនុំជម្រះ[២៦]។

### ៦.៥.២ អញ្ញត្រកម្ម

១៥. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ មេធាវីការពារក្តី បានដាក់អញ្ញត្រកម្មមួយដោយបញ្ជាក់ថា ការចោទប្រកាន់លើជនជាប់ចោទតាមច្បាប់ជាតិអំពីបទធ្វើទារុណកម្ម និងបទមនុស្សឃាត អនុលោមតាមមាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មិនអាចធ្វើ

---

[២៥] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3 និង E1/4។ *សូមមើលផងដែរ* "របៀបវារៈសម្រាប់សវនាការបឋម" ឯកសារ E8/1 ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩។ "សេចក្តីណែនាំស្នើសុំព័ត៌មានបន្ថែមពីភាគីនានា និងសហចៅក្រមស៊ើបអង្កេត ក្នុងការរៀបចំសវនាការបឋម" ឯកសារ E5/11 ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩។

[២៦] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3 និងE1/4។ នៅដំណាក់កាលជាច្រើនក្នុងអំឡុងសវនាការ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចបន្ថែមមួយចំនួនដើម្បីដកសាក្សី និងអ្នកជំនាញមួយចំនួនចេញពីបញ្ជី។ *សូមមើលឧទាហរណ៍* "សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សី និងអ្នកជំនាញ៖ មូលហេតុ" ឯកសារ E40/1 ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើសំណើសុំវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី E2/62 និងE2/89 និងសាក្សី KW-10 និងKW-24" ឯកសារ E135 ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩។ "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច" ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ និងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ រួមមានឯកសារ E1/39, E1/43, E1/50, E1/70 និង E1/75។

ទៅបានពីព្រោះថា ចិរវេលាអាជ្ញាយុកាលបានផុតរលត់ទៅហើយ[២៧]។ អង្គជំនុំជម្រះសាលាដំបូង បានជម្រាបថា សេចក្តីសម្រេចលើអញ្ញត្រកម្មនោះ នឹងចេញនៅពេលដំណាលគ្នា ជាមួយសាលក្រម លើអង្គសេចក្តី[២៨]។

### ៦.៥.៣ សវនាការលើអង្គសេចក្តី

១៦. អនុលោមតាម"សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ" របស់អង្គជំនុំជម្រះសាលាដំបូង សវនាការ លើអង្គសេចក្តីត្រូវបានចែកចេញជាអង្គហេតុចំនួនប្រាំពីរតាមលំដាប់លំដោយដូចខាងក្រោមនេះ ៖

i. បញ្ហាទាក់ទងទៅនឹងមន្ទីរម១៣
ii. ការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ
iii. ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១
iv. ជម្លោះប្រដាប់អាវុធ
v. ប្រតិបត្តិការរបស់មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក
vi. ការបង្កើត និងប្រតិបត្តិការរបស់ស២៤ និង
vii. បញ្ហាទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ[២៩]។

---

[២៧] "អញ្ញត្រកម្មទាក់ទងទៅនឹងការរំលត់បណ្តឹងអាជ្ញា ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមច្បាប់ជាតិ" ឯកសារ E9/1 ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩។ "សេចក្តីសន្និដ្ឋានឆ្លើយតបជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់សហមេធាវីការពារក្តីចំពោះការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦" ឯកសារ E9/7 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។ "សារណាស្តីអំពីអញ្ញត្រកម្មរបស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១" ឯកសារ E9/5 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។ "សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ស្តីអំពីអញ្ញត្រកម្មទាក់ទងទៅនឹងការរំលត់បណ្តឹងអាជ្ញា ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមច្បាប់ជាតិ" ឯកសារ E9/8 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។ "សារណាចម្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ចំពោះអញ្ញត្រកម្មលើការផុតរលត់បណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្ម ទាក់ទងនឹងច្បាប់ជាតិ" ឯកសារ E9/6 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។ "សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្តីពីអញ្ញត្រកម្មលើកឡើងដោយក្រុមការពារក្តី" ឯកសារ E9/9 ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។

[២៨] "សេក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលបានលើកឡើងដោយមេធាវីការពារក្តី" របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

១៧. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ សវនាការលើអង្គសេចក្តីបានចាប់ផ្តើមដោយមានការអានផ្នែកនៃការវិភាគអង្គហេតុ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ និងការអានបទចោទប្រឆាំងនឹងជនជាប់ចោទ[៣០]។ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន បន្ទាប់មកជនជាប់ចោទ ហើយមេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានតបនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩[៣១]។

១៨. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះសាលា-ដំបូងថា មេធាវីការពារក្តីបានយល់ស្រប ឬមិនបានជំទាស់ទៅនឹងអង្គហេតុចំនួន២៣៨ ក្នុងចំណោមអង្គហេតុដែលបានលើកឡើងចំនួន៣៥១ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ-ជម្រះដែលត្រូវបានធ្វើការកែប្រែ[៣២]។ ដោយមានការបង្គាប់ពីអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជ-អាជ្ញាបានអាននូវអង្គហេតុទាំងនេះនៅក្នុងពេលសវនាការ[៣៣]។

---

[២៩] "សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ" ឯកសារ E26 ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។

[៣០] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ឯកសារ ។ *សូមមើលផងដែរ* "ដីកាកំណត់កាលវិភាគចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូង" ឯកសារ E15 ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩។

[៣១] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/6។ "សេចក្តីណែនាំស្តីពីការធ្វើសេចក្តីសន្និដ្ឋានក្នុងអំឡុងសវនាការលើអង្គសេចក្តី" ឯកសារ E19 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩។ អង្គជំនុំជម្រះបានបដិសេធសំណើដាក់សេចក្តីសន្និដ្ឋានរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើល* "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី" ឯកសារ E23/4 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩។

[៣២] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃនីតិវិធី" ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/6។ "ការឆ្លើយតបទៅនឹងសេចក្តីណែនាំស្នើសុំព័ត៌មានបន្ថែមពីភាគីនានា និងសហចៅក្រមស៊ើបអង្កេតក្នុងការរៀបចំសវនាការបឋម" ឯកសារ E5/11/1 ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩។ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការព្រមព្រៀងលើអង្គហេតុ" ឯកសារ E5/11/2 ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ ។ *សូមមើលផងដែរ* "គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ" ឯកសារ E5/11/6.1 ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩។ "កំណត់សម្គាល់បន្ថែមរបស់ក្រុមការពារក្តីទៅលើឯកសារដែលមានចំណងជើងថា ៖ 'គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ' " ឯកសារE5/11/6 ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩។

[៣៣] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ឯកសារ E1/7។

១៩. នៅពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សីចំនួន២៤នាក់ រួមទាំងសាក្សីដែលផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ជនជាប់ចោទចំនួន០៧នាក់ និងអ្នកជំនាញចំនួន ០៩នាក់។ ក្រៅពីការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ ក្នុងអំឡុងពេលដំណើរការជំនុំជម្រះ អង្គជំនុំជម្រះក៏បានអានឲ្យកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីជាច្រើន នៅថ្ងៃទី០៤ ទី០៥ ទី១១ និងទី១២ ខែសីហា ឆ្នាំ២០០៩ ផងដែរ។ អង្គជំនុំជម្រះបានស្នើឲ្យភាគីធ្វើការកត់សម្គាល់ទៅលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ[៣៤]។

### ៦.៥.៤ បញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត

#### ៦.៥.៤.១ សំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម

២០. នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលា-ដំបូងប្រកាសថា សញ្ញាណនៃសហឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្តបាននៅ អ.វ.ត.ក ហើយយកសហឧក្រិដ្ឋកម្មរួមនេះ ទៅអនុវត្តចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលបានចោទប្រកាន់ចំពោះជនជាប់-ចោទ[៣៥]។ អង្គជំនុំជម្រះបានរម្លឹកថា សហព្រះរាជអាជ្ញាបានបញ្ជាក់អំពីគោលបំណងរបស់ខ្លួនដែលពឹងផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមក្នុងអំឡុងពេលសវនាការបឋម ហើយបានបញ្ជាក់ថានេះគឺជាបញ្ហាដែលមានសារៈសំខាន់នៅចំពោះមុខអង្គជំនុំជម្រះ[៣៦]។ បន្ទាប់ពីមានការដាក់សារណា

---

[៣៤] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីខាងក្រោមត្រូវបានអាននៅក្នុងតុលាការ៖ ខៀវ ចេស (E3/456) ប៉េស ម៉ាត់ (E3/457) ញ៉ែម អេន (E3/458) ញ៉េប ហួ (E3/460) គង់ ផៃ (E3/461, E3/462, E3/396, E3/244) ម៉ក់ ស៊ីធីម (E3/484, E3/396) តយ តេង (E3/485, E3/486, E3/218, E3/242) សោម សំអុល (E3/487) មាស ប៉េងគ្រី (E3/446, E3/242, E3/218) អ៊ុក ប៊ុនសេង (E3/490) ហ៊ិន (ហន) អៀម (E3/491) ផាច សៀក (E3/495) កាំង ប៉ាន់ (E3/496) និង (ក្នុងទម្រង់សង្ខេប) ជ័យ សុភារ៉ា (E3/488)។ *សូមមើល* "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី – ចុះថ្ងៃទី០៤, ០៥, ១១ និង ១២ ខែសីហា ឆ្នាំ២០០៩" រួមមានឯកសារ E1/57, E1/58, E1/61 និង E1/62។

[៣៥] "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" ឯកសារ E73 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩។

[៣៦] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី – ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩" ឯកសារ E1/39។

ពីភាគីរួចមក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហានេះនឹងចេញនៅក្នុងពេលដំណាលគ្នាជាមួយសាលក្រមលើអង្គសេចក្តី[៣៧]។

### ៦.៥.៤.២ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានទៅលើការផ្តន្ទាទោស និងអត្តចរិតរបស់ជនជាប់ចោទ

២១. នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ បន្ទាប់ពីមានសំណើរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសេចក្តីសម្រេចផ្ទាល់មាត់ចំនួនពីរ ដោយមានមតិភាគច្រើនរបស់ចៅក្រម និងមតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម LAVERGNE[៣៨]។ អង្គជំនុំជម្រះបានសម្រេចថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងការផ្តន្ទាទោស ដោយរួមទាំងសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសទៅលើជនជាប់ចោទ សេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់អំពីការផ្តន្ទាទោស[៣៩]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[៣៧] "ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១-- សេចក្តីជូនដំណឹងទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម" ឯកសារ E73/1 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។ "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣៖ សារណាគាំទ្រទាក់ទងនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញាស្នើឱ្យអនុវត្តក្នុងករណីនេះ ស្តីពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួម"ឯកសារ E73/3 ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩។ "ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឱ្យមានការអនុវត្តទៅលើរឿងក្តី នូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម"ឯកសារ E73/2 ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

[៣៨] "សំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស" ឯកសារ E72 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩។

[៣៩] មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យយោងទៅលើអង្គហេតុទាំងនោះ តែក្នុងករណីដែលត្រូវយោងទៅលើពិរុទ្ធភាព និងភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ *សូមមើល* "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E1/70។ *សូមមើលផងដែរ* "សេចក្តីសម្រេចលើសំណើរួម របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេច អំពីសិទ្ធិរបស់សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" ឯកសារ E72/3 ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩។

ដែលស្នើសុំតាំងសំណួរទៅកាន់ជនជាប់ចោទ អ្នកជំនាញ០២រូប និងសាក្សី០៩រូប ទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ[៦០]។

២២. សេចក្តីសម្រេចទាំងពីររបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្តឹងសាទុក្ខ ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ និងដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩[៦១]។ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងសាទុក្ខទាំងនេះមិនអាចទទួលយកបាន អនុលោមតាមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង[៦២]។

### ៦.៥.៥ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

---

[៦០] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E1/70។ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការជួបជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់-ចោទ" ឯកសារ E72/3 ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩។

[៦១] "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) ពាក្យបណ្តឹងឧទ្ធរណ៍" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩។ "បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការសួរសំណួរទៅជនជាប់ចោទ សាក្សី និងអ្នកជំនាញស្តីពីអត្តចរិតរបស់ជនជាប់ចោទ និងបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់សេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស" ឯកសារ E169 ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩។

[៦២] "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និង ក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩" ឯកសារ E169/1/2 ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។

២៣. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីទម្រង់នៃការទាមទារសំណងផ្លូវចិត្ត និងសំណងសមូហភាពប្រឆាំងនឹងជនជាប់ចោទក្នុងករណីដែលមានពិរុទ្ធភាព[៤៣]។

២៤. នៅចន្លោះថ្ងៃទី២៣ និងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ភាគីទាំងអស់បានដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន[៤៤]។ បន្ទាប់ពីជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរួចមក គាត់បានស្នើដោយផ្ទាល់មាត់សុំដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គាត់ទៅក្នុងសំណុំរឿង ហើយអង្គជំនុំជម្រះបានយល់ព្រមទៅលើសំណើនេះ[៤៥]។

---

[៤៣] "សារណារួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណង" ឯកសារ E159/3 ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។ "សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣៖ សារណាបន្ថែមទាក់ទងនឹងការសងសំណង" ឯកសារ E159/3/1 ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩។

[៤៤] សូមមើល "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច ថ្ងៃទី២៣-២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ការដាក់បញ្ចូលឯកសារ E1/78 ដល់ E/81។ *សូមមើលផងដែរ* "ដីកាកំណត់កាលវិភាគសម្រាប់ភាគីធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល" ឯកសារ E170 ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩។ "ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ សេក្ដីសន្និដ្ឋានបញ្ចប់" ឯកសារ E159/7 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម២)" ឯកសារ E159/6 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៤" ឯកសារ E159/4 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣- សេចក្ដីសន្និដ្ឋានបញ្ចប់" ឯកសារ E159/5 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាដោយមានឧបសម្ព័ន្ធពី១-៥" ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដី" ឯកសារ E159/8 ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្ដីណែនាំស្ដីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល" ឯកសារ E159 ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

[៤៥] "សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្ដី" ឯកសារ E159/10 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩។ "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩" ឯកសារ E1/80។

00573753



២៥. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋានតប នៅថ្ងៃទី២៦ និងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយមេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានតបវិញ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩[៤៦]។

២៦. ជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់គាត់ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ទោះបីជាជនជាប់ចោទបានទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តក៏ដោយ ក៏ជនជាប់ចោទបានស្នើសុំឱ្យរួចខ្លួនពីបទចោទ និងស្នើសុំឱ្យដោះលែងគាត់។ បន្ទាប់ពីបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសបិទសវនាការ[៤៧]។

### ៦.៥.៦ ដំណើរការនីតិវិធីបន្តបន្ទាប់ទៀត

២៧. ក្រោយមកទៀត ភាគីទាំងអស់ត្រូវបានផ្តល់ឱកាសឱ្យធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្តីពីអានុភាពនៃក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ ប្រសិនបើមាន ដែលក្រមនេះបានចូលជាធរមានក្រោយសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ប៉ុន្តែមិនមានភាគីណាមួយប្រើប្រាស់ឱកាសនេះឡើយ[៤៨]។

២៨. អង្គជំនុំជម្រះបានប្រកាសសាលក្រមរបស់ខ្លួន និងបានដាក់បញ្ចូលសាលក្រមជាលាយលក្ខណ៍អក្សរទៅក្នុងសំណុំរឿងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ អង្គជំនុំជម្រះបាន ផ្តន្ទាទោសជនជាប់-ចោទ ដាក់ពន្ធនាគាររយៈពេល៣៥ ឆ្នាំ ដោយផ្អែកទៅលើពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស

---

[៤៦] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច ថ្ងៃទី២៦-២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/81 និង E1/82។

[៤៧] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82។

[៤៨] "ដីកាពាក់ព័ន្ធនឹងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា" ឯកសារ E180/1 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០។

ជាតិ៖ ការធ្វើទុក្ខបុកម្នេញ (រួមមាន ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរ ឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ ផ្សេងៗទៀត) ព្រមទាំងបទឧក្រិដ្ឋការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

## ៧. ឧបសម្ព័ន្ធ II÷ រូបភាពមន្ទីរស២១

## (ទួលស្លែង) ដែលថតពីលើអាកាស

រូបភាពសារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដែលថតពីលើអាកាស ឯកសារ E3/16 ERN (ខ្មែរ បារាំង និងអង់គ្លេស) 00189137 ។



សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អវតក/អជសង
E188

## ៨. ឧបសម្ព័ន្ធ III÷ បញ្ជីឈ្មោះដើមបណ្ដឹង

## រដ្ឋប្បវេណី

## ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានអនុញ្ញាតិឱ្យចូលរួមក្នុងដំណើរការនីតិវិធី

| របាស នាម | ឈ្មោះ | អាសយដ្ឋាន | ថ្ងៃខែឆ្នាំកំណើត | ទីកន្លែងកំណើត | មុខរបរ |
|---|---|---|---|---|---|
| D25/1 | លោក ប៊ូ ម៉េង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/2 | លោកស្រី ឈិន ណារី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/3 | លោក ជុំ មុី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/4 | លោកស្រី ហារ សោភា | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/5 | លោកស្រី ភឹង ហ្គុត ស៊ុនថារី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/6 | លោក ជុំ ស៊ីរ៉ាត | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| D25/7 | លោកស្រី អ៊ឹម ស៊ុន្ធី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/8 | លោកស្រី មាសកេត សំភាត់ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/9 | លោកស្រី រស់ ម៉េន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/10 | លោក ផែ ប៉ាប | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/11 | លោក ឃួន សារិន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/12 | លោក ជ្រាំង សំអ៊ាន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/13 | លោក ស៊ាង វ៉ាន់ឌី | កោសលុប | កោសលុប | កោសលុប | កោសលុប |

00573758

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អវតក/អជសដ

E188

| | | | | | |
|---|---|---|---|---|---|
| D25/14 | លោក តូច មុនិន្ទ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/15 | លោក សួន សៀង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/16 | លោកស្រី ជុំ នៅ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/17 | លោកស្រី កាន់ ស៊ុន្ទរ៉ា | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/18 | លោក ម៉ាន សួត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/19 | លោកស្រី គង់ ទេស | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| D25/20 | លោកស្រី ង៉ែត សុខ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/21 | លោក តាត់ ឡូន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/22 | លោក Timothy Scott DEEDS | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/23 | លោក យឹម ឡេង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/24 | លោក អ៊ុម ពិសិដ្ឋ (សិទ្ធិវន្ត របស់លោកស្រី សួស សារិន ដែលបានទទួល មរណៈភាព) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/25 | លោក កែ ខុន | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| D25/26 | លោកស្រី គីម៉ារី ណេវីនកា (KIMARI Nevinka) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/27 | លោកស្រី ជូឡុង អង់តូនីញ៉ា (TIOULONG Antonya) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| D25/28 | លោកស្រី ជូឡុង ណេវ៉ា (TIOULONG-ROHMER Neva) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/21 | លោកស្រី អៀម សួយ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/22 | លោក ឈឹម ស៊ីថា | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/23 | លោក ឡាយ ចាន់ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/24 | លោកស្រី អ៊ុល | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | សាយ ហៅ រៀម | | | | |
| E2/25 | លោក ស៊ីន លឹមសៀ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/26 | លោក អ៊ូ សាវរិទ្ធ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/27 | លោកស្រី អ៊ូ កាមេឡា (OU Kamela) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/28 | លោកស្រី រស់ ជួស៊ុីអ៊ី (ROS Chuor Siy) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/29 | លោកស្រី គីម៉ារី វីសាកា (KIMARI Visaka) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/30 | លោកស្រី ញ៉ឹម គឹមហឿន | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| E2/31 | លោកស្រី ញ៉ឹក អ៊ូដាវី (NHEK Oudavy) | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/32 | លោកស្រី ណាំ ម៉ុន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/33 | លោក ភោគ ខន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/34 | លោកស្រី សូ សួង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/35 | លោកស្រី ឆាយ កន *ហៅ* លៀង កន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/37 | លោក ភ្លាន ហ្វិត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/38 | លោក ហៀត តីជៅ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/39 | លោកស្រី សួន | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | សុខុម៉ាលី (SUON Sokhomaly) | | | | |
| E2/41 | លោកស្រី ស៊ិន ស៊ីណែត ហៅ ស្រ៊ុន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/42 | លោកស្រី រួន ស្រីណុប | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/43 | លោកស្រី អែល លីម៉ះ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/44 | លោកស្រី ស្មាន ណុប | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/45 | លោកស្រី ស្មាន ស | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/46 | លោកស្រី កែ សាម៉ូត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/47 | លោកស្រី ម៉ែន ឡាយ | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| E2/48 | លោកស្រី ញ៉ែម សុផាន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/50 | លោក នេត ផល្លី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/51 | លោកស្រី ម៉ាន ម៉ះ *ហៅ* ម៉ាន ម៉ាលីម៉ះ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/52 | លោកស្រី កុំ មេន *ហៅ* គុម មេន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/53 | លោកស្រី ទ្រី ង៉ិចលាង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/54 | លោកស្រី ហេង ង៉ិចហុង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/55 | លោក បេង ចាន់ថន | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| E2/56 | លោក យុន ឈឹន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/57 | លោក លី យៀក | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/58 | លោក ពូល ពន្លឹក ហៅ ង៉ែត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/59 | លោក ចាន់ ក្រូច | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/60 | លោកស្រី នង គឹមលៀង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/61 | លោក លី ហ៊ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/62 | កោសលុប | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/63 | លោកស្រី ប៉ាន់ ប៊ិច | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/64 | លោកស្រី ញិប | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | គឹមស្រ៊ា | | | | |
| E2/66 | លោកស្រី ពេញ សុខេន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/69 | លោកស្រី លឹម យ៉ុន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/70 | លោកស្រី ចាន់ យឿង | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/71 | លោកស្រី សឹម ពៅ | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/72 | លោកស្រី កាន សាន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/73 | លោក នង សារ៉ាត ហៅ ពណី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/74 | លោកស្រី ង៉ែត | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| | អ៊ុយ | | | | |
| E2/75 | លោកស្រី ធៀវ នាប ហៅ ខៀវ នាប | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/76 | លោកស្រី អ៊ុង វឿន ហៅ ហ៊ុល វឿន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/78 | លោកស្រី មាស សាវឿន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/79 | លោកស្រី សេក សៀក | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/80 | លោកស្រី ជិន ម៉េត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/81 | លោក ឆាត គឹមឈុន | កោសលុប | កោសលុប | កោសលុប | កោសលុប |

00573768

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អវតក/អជសង
E188

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| E2/82 | លោក ម៉ន សុធា | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/83 | លោកស្រី ហុង សាវ៉ាត | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/84 | លោក អ៊ុក វ៉ាសោធិន | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/85 | លោកស្រី Martine LEFEUVRE | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/86 | លោក Jeffrey JAMES | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/87 | លោក Robert HAMILL | កោសលុប | កោសលុប | កោសលុប | កោសលុប |

| | | | | | |
|---|---|---|---|---|---|
| E2/88 | លោក Joshua ROTHSCHILD | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/89 | កញ្ញា អ៊ុក នារី | កោសលុប | កោសលុប | កោសលុប | កោសលុប |

## ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានដកពាក្យសុំតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលសវនាការ

| | | | | | |
|---|---|---|---|---|---|
| E2/49 | លោក អេង ស៊ីថា | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/65 | លោកស្រី ប៊ុន ស្រី | កោសលុប | កោសលុប | កោសលុប | កោសលុប |
| E2/77 | លោកស្រី គៀង វណ្ណារី | កោសលុប | កោសលុប | កោសលុប | កោសលុប |

00573770



## ៩. ឧបសម្ព័ន្ធទី IV÷ អក្សរកាត់ និងសន្ទានុក្រម

| | |
|---|---|
| ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦ ដែលបានប្រកាកឲ្យប្រើនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៥៥ ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា (តាមព្រះរាជក្រមលេខ ៩៣៣ នស) ឆ្នាំ១៩៥៦ ទំព័រ ១១-៤០៣។ |
| ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល |
| ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ |
| ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ដែលបានប្រកាកឲ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ (លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះដែលត្រូវយកទៅអនុវត្តភ្លាម ក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ |
| ជនជាប់ចោទ | កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| ពិធីសារបន្ថែមទីI | ពិធីសារបំពេញបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ហើយពិធីសារនេះទាក់ទងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារលេខ ១១២៥ U.N.T.S.3 ចូលជាធរមាននៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៨។ |
| ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ | ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឯកសារលេខ D99 (ដាក់ជាឯកសារសម្ងាត់) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ហើយដែលត្រូវបានធ្វើការកែប្រែដោយសេចក្តីសម្រេចចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៨ របស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ |
| មាត្រា ២ រួម | មាត្រា២ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ទាំងបួន។ |

| | |
|---|---|
| ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង | ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង៖ ការផ្តន្ទាទោសទៅលើបុគ្គលទាំងឡាយណាដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ដែលបានចុះហត្ថលេខានៅទីក្រុងBerlin នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ ដែលបានបោះពុម្ពនៅឆ្នាំ(១៩៤៦) នៅក្នុងព្រឹត្តប័ត្រផ្លូវការរបស់ក្រុមប្រឹក្សាគ្រប់គ្រងអាល្លឺម៉ង់ ទំព័រ ៥០-៥៥។ |
| មេធាវីការពារក្តី | មេធាវីសម្រាប់ជនជាប់ចោទ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| កិច្ចព្រមព្រៀង អ.វ.ត.ក | កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលចុះហត្ថលេខានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ហើយបានចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។ |
| ច្បាប់ អ.វ.ត.ក | ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប-តេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយមានការធ្វើវិសោធនកម្មដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)។ |
| ECHR | អនុសញ្ញារបស់សហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន |
| ERN | លេខយោងឯកសារ |
| FULRO | រណៈសិស្សរួបរួមដើម្បីរំដោះជាតិសាសន៍ដែលត្រូវគេជិះជាន់ |
| អនុសញ្ញាទីក្រុងហ្សឺណែវ I | អនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់កែលំអលក្ខខណ្ឌរបស់អ្នកជំងឺនិងអ្នករបួសនៅក្នុងកងកម្លាំងប្រដាប់អាវុធនៅទីសមរភូមិ លេខ ៧៥ UNTS ៣១ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០ |
| អនុសញ្ញាទីក្រុងហ្សឺណែវ II | អនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់កែលំអលក្ខខណ្ឌសមាជិកកងកម្លាំងប្រដាប់-អាវុធដែលមានរបួស ជំងឺ និងលិចនាវានៅសមុទ្រ ឯកសារលេខ ៧៥ UNTS ៨៥ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០ |
| អនុសញ្ញាទីក្រុងហ្សឺណែវ III | អនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងទៅនឹងការប្រព្រឹត្តិចំពោះអ្នកទោសសង្គ្រាម |

| | |
|---|---|
| | ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឯកសារលេខ ៧៥ UNTS ១៣៥ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០ |
| អនុសញ្ញាទីក្រុងហ្សឺណែវ IV | អនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឯកសារលេខ ៧៥ UNTS ២៨៧ ចូលជាធរមាននៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៥០ |
| អនុសញ្ញាទីក្រុងហ្សឺណែវ | អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន ឆ្នាំ ១៩៤៩ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ |
| ICC | តុលាការព្រហ្មទណ្ឌអន្តរជាតិ |
| ICCPR | កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICRC | គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ |
| ICTR | តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីកាត់សេចក្តីបុគ្គលដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅលើទឹកដីប្រទេសរ៉ូវ៉ាន់ដា និងដើម្បីកាត់ទោសប្រជាជនរ៉ូវ៉ាន់ដាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀតដែលបានប្រព្រឹត្តនៅលើទឹកដីប្រទេសជិតខាង ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។ |
| ICTY | តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីកាត់សេចក្តីបុគ្គលដែលទទួលខុសត្រូវចំពោះការរលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីអតីតយូហ្គោស្លាវីពីឆ្នាំ ១៩៩១។ |
| JCE | សហឧក្រិដ្ឋកម្មរួម |
| Nuremberg Charter | ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ការកាត់សេចក្តីនៃឧក្រិដ្ឋកម្មសង្គ្រាមធំៗ ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងសម្រាប់ការកាត់សេចក្តី និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មសង្គ្រាមធំៗនៃសហគមន៍អឺរ៉ុប(កិច្ចព្រមព្រៀងទីក្រុងឡុង) នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥ លេខ ២៨ UNTC ២៨០។ |
| Nuremberg Principles | គោលការណ៍នៃច្បាប់អន្តជាតិដែលបានទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការ |

| | |
|---|---|
| | Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការ Nuremberg ។ |
| Nuremberg Tribunal | តុលាការយោធាអន្តរជាតិសម្រាប់ការកាត់សេចក្តីនៃឧក្រិដ្ឋកម្មសង្គ្រាមធំៗ |
| ក.ស.ព | ការិយាល័យសហព្រះរាជអាជ្ញា |
| លក្ខន្តិកៈទីក្រុងរ៉ូម | លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិ A/CONF.183/9th ដែលបានអនុម័តកាលពីថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ និងបានចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២។ |
| ស២១ | មន្ទីរស២១ ដោយរួមបញ្ចូលទាំងមន្ទីរស២១ (ទួលស្លែង) ជើងឯក និងស២៤ |
| ស២១ (ទួលស្លែង) | មន្ទីរស២១ (ទួលស្លែង) |
| ស២៤ | ជំរំកែប្រែព្រៃស |
| SCSL | តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេស សេរ៉ាលេអូន *(Sierra Leone)* |
| ធម្មនុញ្ញ តូក្យូ | ធម្មនុញនៃតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ ឯកសារលេខ T.I.A.S No.1589 |
| តុលាការ តូក្យូ | តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ |
| អ៊ុនតាក់ (UNTAC) | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| TPO | អង្គការចិត្តសង្គម អន្តរវប្បធម៌ |